# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## សំយុត្តនិកាយ   សឡាយតនវគ្គ
## អដ្ឋមភាគ
## ៣៦



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## SAṂYUTTANIKĀYA

## SAḶĀYATANAVAGGA

## AṬṬHAMABHĀGA

## 36

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី ប៊ូរ គ្រី

សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ ៥០០ ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធ ចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំៗ តែងតែបានទទួលយកមកតម្កល់ ទុកធ្វើជាគ្រឹះ ដើម្បី ធ្វើការស្រាវ ជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើម ឡើយគេនាំគ្នា កត់ត្រាលើ ស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈ ក៏មាន លុះចំណេរតមកក៏បាននាំគ្នា បោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ន នេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេស ម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើប យើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុប មិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំ ក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេច ព្រះពុទ្ធអង្គរួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួល ពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមឌ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

ប៊ូរ-គ្រី

Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
**This book is strictly for free distribution, it is not for sale.**
**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# សេចក្តីណែនាំក្នុងការអាន

១) *ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។*

*ឧទាហរណ៍*

*-ពាក្យខ្មែរៈ* **សម៑ល** *ក្នុងពាក្យនេះ ព្យញ្ជនៈ* **ល** *គឺជាជើងរបស់ព្យញ្ជនៈ* **ម** *ដូច្នេះពាក្យនេះគឺ* **សម្ល** *។*

*-ពាក្យបាលីៈ* **តស៑ស** *គឺ* **តស្ស** *។*

២) *ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ* (**ជួន-ណាត**) *ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។*

៣) *ចំពោះ* **សន្ទឹកក្រាប់ពាក្យខុស-ត្រូវ** *ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។*

# សុត្តន្តបិដក

## សំយុត្តនិកាយ  សឡាយតនវគ្គ

## អដ្ឋមភាគ

## ៣៦

ព.ស. ២៤៩៤

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស សឡាយតនវគ្គោ

# អដ្ឋមោ ភាគោ

# វេទនាសំយុត្តំ

## បឋមកសគាថវគ្គោ

[១] តិស្សោ ឥមា ភិក្ខវេ វេទនា ។ កាតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា ខោ ភិក្ខវេ តិស្សោ វេទនា ។

[២] សមាហិតោ សម្បជានោ
សតោ ពុទ្ធស្ស សាវកោ
វេទនា ច បជានាតិ
វេទនានញ្ច សម្ភវំ ។
យត្ថ ចេតា និរុជ្ឈន្តិ
មគ្គញ្ច ខយគាមិនំ

# សុត្តន្តបិដក

# សំយុត្តនិកាយ សឡាយតនវគ្គ

# អដ្ឋមភាគ

# វេទនាសំយុត្ត

# បឋមកសគាថវគ្គ

[១] ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង ។ វេទនា ៣ យ៉ាង តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខ-វេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ វេទនាមាន ៣ យ៉ាងនេះឯង ។

[២] ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ មានចិត្តតម្កល់មាំ (ដោយ
ឧបចារសមាធិនិងអប្បនាសមាធិ) ជាអ្នកដឹងខ្លួន មានស្មារតី
តែងដឹងច្បាស់នូវវេទនាផង នូវហេតុជាទីកើតឡើងនៃវេទនា
ទាំងឡាយផង ។ មួយវិញទៀត វេទនាទាំងឡាយនុ៎ះ
រលត់ទៅក្នុងព្រះនិព្វានឯណា ភិក្ខុតែងដឹងច្បាស់នូវព្រះ

វេទនានំ ខយា ភិក្ខុ

និច្ឆាតោ បរិនិព្វុតោតិ ។ បឋមំ ។

[៣] តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា ខោ ភិក្ខវេ តិស្សោ វេទនា ។

[៤] សុខំ វា យទិ វា ទុក្ខំ

អទុក្ខមសុខំ សហ

អជ្ឈត្តញ្ច ពហិទ្ធា ច

យំ កិញ្ចិ អត្ថិ វេទិតំ ។

ឯតំ ទុក្ខន្តិ ញត្វាន

មោសធម្មំ បលោកិនំ

ផុស្ស ផុស្ស វយំ ផុស្សំ

ឯវំ តត្ថ វិរជ្ជតីតិ ។ ទុតិយំ ។

[៥] តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា

និព្វាននោះផង នូវមគ្គជាដំណើរទៅកាន់ធម៌ជាទីក្ស័យផង ភិក្ខុ ដែលជាអ្នកមិនមានសេចក្តីស្រេកឃ្លាន (មិនមានតណ្ហា) និព្វាន ហើយ ព្រោះអស់ទៅ នៃវេទនាទាំងឡាយ ។ ចប់សូត្រទី ១ ។

[៣] ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង ។ វេទនា ៣ យ៉ាង តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខ-វេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ វេទនាមាន ៣ យ៉ាងនេះឯង ។

[៤] បើមានវេទនាណាមួយ ដែលអរិយសាវ័កបានសោយ ហើយ ទោះជាសុខក្តី ជាទុក្ខក្តី ព្រមទាំងមិនទុក្ខមិនសុខក្តី ទាំងខាងក្នុងទាំងខាងក្រៅ ។ អរិយសាវ័កបានដឹងថា ធម្ម-ជាតនុ៎ះជាទុក្ខ មានសេចក្តីវិនាសទៅជាធម្មតា បែកធ្លាយ ទៅជាប្រក្រតី ច្រើនតែពាល់ត្រូវដោយប្រាជ្ញា ទើបនឿយ ណាយក្នុងវេទនាទាំងនោះ យ៉ាងនេះ ។ ចប់សូត្រទី ២ ។

[៥] ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង ។ វេទនា ៣ យ៉ាង តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខ-

បឋមកសគាថវគ្គោ

វេទនា ។ សុខាយ ភិក្ខវេ វេទនាយ រាគានុសយោ បហាតព្វោ ទុក្ខាយ វេទនាយ បដិឃានុសយោ បហាតព្វោ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ បហាតព្វោ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ សុខាយ វេទនាយ រាគានុសយោ បហីនោ ហោតិ ទុក្ខាយ វេទនាយ បដិឃានុសយោ បហីនោ ហោតិ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ បហីនោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ និរាគានុសយោ សម្មទ្ទសោ អច្ឆេច្ឆិ តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។

[៦] សុខំ វេទយមានស្ស
វេទនំ អប្បជានតោ
សោ រាគានុសយោ ហោតិ
អនិស្សរណទស្សិនោ ។
ទុក្ខំ វេទយមានស្ស
វេទនំ អប្បជានតោ
បដិឃានុសយោ ហោតិ

វេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះរាគានុស័យ (អនុស័យគឺតម្រេក) ក្នុងសុខវេទនាចេញ ត្រូវលះបដិឃានុស័យ (អនុស័យគឺសេចក្តីថ្នាំងថ្នាក់ចិត្ត) ក្នុងទុក្ខវេទនាចេញ ត្រូវលះអវិជ្ជានុស័យ (អនុស័យគឺសេចក្តីល្ងង់) ក្នុងអទុក្ខមសុខវេទនាចេញ ។ ម្នាលភិក្ខុទាំងឡាយ រាគានុស័យក្នុងសុខវេទនាដែលភិក្ខុលះបង់បានហើយ បដិឃានុស័យក្នុងទុក្ខវេទនាដែលភិក្ខុលះបង់បានហើយ អវិជ្ជានុស័យក្នុងអទុក្ខមសុខវេទនាដែលភិក្ខុលះបង់បានហើយ ក្នុងកាលឯណា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា អ្នកឃើញច្បាស់នូវអនុស័យដែលគ្មានរាគៈ ភិក្ខុនោះ បានកាត់បង់នូវតណ្ហា គាស់រំលើងនូវសញ្ញោជនៈ បានធ្វើនូវទីបំផុតនៃទុក្ខ ព្រោះត្រាស់ដឹងដោយប្រពៃនូវមានះ ។

[៦] កាលភិក្ខុសោយនូវសុខវេទនា តែមិនបានដឹងច្បាស់
រាគានុស័យនោះ រមែងមានដល់ភិក្ខុដែលមិនឃើញនូវឧបាយ
ជាគ្រឿងរលាស់ចេញ ។ កាលភិក្ខុសោយនូវទុក្ខវេទនា
តែមិនបានដឹងច្បាស់ បដិឃានុស័យ ក៏មានដល់ភិក្ខុ

## ៤



អនិស្សរណទស្សិនោ ។
អទុក្ខមសុខំ សន្តំ
ភូរិប្បញ្ញេន ទេសិតំ
តំ ចាបិ អភិនន្ទតិ
នេវ ទុក្ខា បមុច្ចតិ ។
យតោ ច ភិក្ខុ អាតាបី
សម្បជញ្ញំ[១] ន រិញ្ចតិ
តតោ សោ វេទនា សព្វា
បរិជានាតិ បណ្ឌិតោ ។
សោ វេទនា បរិញ្ញាយ
ទិដ្ឋេ ធម្មេ អនាសវោ
កាយស្ស ភេទា ធម្មដ្ឋោ
សំខ្យំ នោបេតិ វេទគូតិ ។ តតិយំ ។

១ ឱ. សម្បជញ្ញំ ន រិញ្ចតិ ។

ដែលមិនឃើញនូវឧបាយជាគ្រឿងរលាស់ចេញដែរ ។ សេចក្តីមិនទុក្ខមិនសុខជារបស់មាននៅ ដែលព្រះសម្មាសម្ពុទ្ធមានបញ្ញាដូចជាផែនដីទ្រង់សំដែងហើយ បើភិក្ខុរីករាយចំពោះសេចក្តីមិនទុក្ខមិនសុខនោះ មិនរួចចាកទុក្ខបានទេ ។ មួយវិញទៀត ភិក្ខុមានព្យាយាមដុតកម្តៅកិលេស រមែងលះបង់ (នូវវេទនាទាំងនោះ) ដោយសម្បជញ្ញៈ (បញ្ញា) ក្នុងកាលឯណា ភិក្ខុនោះជាបណ្ឌិត តែងកំណត់ដឹងនូវវេទនាទាំងអស់បាន ក្នុងកាលនោះឯង ។ ភិក្ខុនោះកំណត់ដឹងនូវវេទនាទាំងឡាយក្នុងបច្ចុប្បន្ននេះ ជាអ្នកមិនមានអាសវៈតាំងនៅក្នុងធម៌ ជាអ្នកដល់នូវវេទ លុះទម្លាយរាងកាយទៅមិនគួររាប់ថា (ជាអ្នកមានភពទៀតឡើយ) ។ ចប់សូត្រទី ៣ ។

៨

## បឋមកសគាថវគ្គោ

[៧] អស្សុតវា ភិក្ខវេ បុថុជ្ជនោ ឯវំ វាចំ(១) ភាសតិ អត្ថិ មហាសមុទ្ទេ បាតាលោតិ ។ តំ ខោ បនេតំ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អសន្តំ អសំវិជ្ជមានំ ឯវំ វាចំ ភាសតិ អត្ថិ មហាសមុទ្ទេ បាតាលោតិ ។ សារីរិកានំ ខោ ឯតំ ភិក្ខវេ ទុក្ខានំ វេទនានំ អធិវចនំ យទិទំ បាតាលោតិ ។ អស្សុតវា ភិក្ខវេ បុថុជ្ជនោ សារីរិកាយ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ បាតាលេ ន បច្ចុដ្ឋាសិ គាធញ្ច នជ្ឈគា ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ សារីរិកាយ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ សម្មោហំ នាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ សុតវា អរិយសាវកោ បាតាលេ បច្ចុដ្ឋាសិ គាធញ្ច អជ្ឈគាតិ ។

១ យំ វាចំ ភាសតិ ។

បឋមកសគាថវគ្គ

[៧] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលនូវវាចាយ៉ាងនេះថា បាតាលមានក្នុងមហាសមុទ្រ ។ ម្នាលភិក្ខុទាំង-ឡាយ ចំណែកបុថុជ្ជនអ្នកមិនចេះដឹង តែងពោលនូវវាចាទុំះ ដែលមិនមាន មិនប្រាកដយ៉ាងនេះថា បាតាលមានក្នុងមហាសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បាតាលទុំះ ជាឈ្មោះនៃទុក្ខវេទនាទាំងឡាយដែលប្រព្រឹត្តទៅក្នុងសរីរៈ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង កាលបើទុក្ខវេទនាប្រព្រឹត្តទៅក្នុងសរីរៈពាល់ត្រូវ ទើបសោយសោក លំបាក ខ្សឹកខ្សួល គក់ទ្រូងកន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេងវង្វោង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹងនេះ ហៅថាមិនប្រាកដក្នុងបាតាលផង មិនបាននូវទីពឹងផង ។ ម្នាលភិក្ខុទាំង-ឡាយ ឯអរិយសាវ័កអ្នកចេះដឹង កាលបើទុក្ខវេទនាប្រព្រឹត្តទៅក្នុងសរីរៈពាល់ត្រូវ ក៏មិនសោយសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវការវង្វេងវង្វោងទេ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹងនេះ ហៅថាមានប្រាកដក្នុងបាតាលផង បាននូវទីពឹងផង ។

៦



[៨] យោ ឯតា ណាធិវាសេតិ

ឧប្បន្នា វេទនា ទុក្ខា

សារីរិកា ចាណហរា

យាហិ ផុដ្ឋោ បវេធតិ ។

អក្កន្ទតិ បរោទតិ

ទុព្វលោ អប្បថាមកោ

ន សោ ចាតាលេ បច្ចុដ្ឋាសិ

អថោ គាធម្បិ នជ្ឈគា ។

យោ ចេតា អធិវាសេតិ

ឧប្បន្នា វេទនា ទុក្ខា

សារីរិកា ចាណហរា

យាហិ ផុដ្ឋោ ន វេធតិ

សចេ ចាតាលេ បច្ចុដ្ឋាសិ

អថោ គាធម្បិ អជ្ឈគាតិ ។ ចតុត្ថំ ។

សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ

[៨] អ្នកឯណា មិនអត់សង្កត់នូវទុក្ខវេទនា ដែលកើតឡើងទាំងនោះបានទេ កាលដែលទុក្ខវេទនាពាល់ត្រូវហើយ រមែងញាប់ញ័រ ព្រោះអាល័យជីវិតប្រព្រឹត្តទៅក្នុងសរីរៈ ។ មួយវិញទៀត អ្នកដែលមានប្រាជ្ញាថយ មានកម្លាំងប្រាជ្ញាតិច អ្នកនោះតែងកន្ទក់កន្ទេញ ទ្រហោយំ មិនប្រាកដក្នុងបាតាលផង មិនបាននូវទីពឹងផង ។ មួយទៀត អ្នកឯណាបានអត់សង្កត់ នូវទុក្ខវេទនាដែលកើតឡើងទាំងនោះ កាលដែលទុក្ខវេទនាពាល់ត្រូវហើយ មិនញាប់ញ័រ ព្រោះអាល័យជីវិតប្រព្រឹត្តទៅក្នុងសរីរៈ ទើបប្រាកដក្នុងបាតាលផង បានដល់នូវទីពឹងផង ។ ចប់សូត្រទី ៤ ។

៧

## បឋមកសគាថវគ្គោ

[៩] តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ សុខា ភិក្ខវេ វេទនា ទុក្ខតោ ទដ្ឋព្វា ទុក្ខា វេទនា សល្លតោ ទដ្ឋព្វា អទុក្ខមសុខា វេទនា អនិច្ច-តោ ទដ្ឋព្វា ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ សុខា វេទនា ទុក្ខតោ ទិដ្ឋា ហោតិ ទុក្ខា វេទនា សល្លតោ ទិដ្ឋា ហោតិ អទុក្ខមសុខា វេទនា អនិច្ចតោ ទិដ្ឋា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សម្មទ្ទសោ អច្ឆេ-ជ្ជិ តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។

[១០] យោ សុខំ ទុក្ខតោ អទ្ទ
ទុក្ខមទក្ខិ សល្លតោ
អទុក្ខមសុខំ សន្តំ
អទក្ខិ នំ អនិច្ចតោ ។
សចេ សម្មទ្ទសោ ភិក្ខុ
បរិជានាតិ វេទនា

បឋមកសតាចវគ្គ

[៩] ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង ។ វេទនា ៣ យ៉ាង តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខ-វេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ សុខវេទនា ភិក្ខុគប្បីឃើញថាជាទុក្ខ ទុក្ខវេទនា ភិក្ខុគប្បីឃើញថាជាកូនសរ អទុក្ខមសុខវេទនា ភិក្ខុគប្បីឃើញថាជារបស់មិនទៀង ។ ម្នាលភិក្ខុទាំងឡាយ សុខវេទនាដែលភិក្ខុបានឃើញថាជាទុក្ខ ទុក្ខវេទនាដែលភិក្ខុបានឃើញថាជាកូនសរ អទុក្ខ-មសុខវេទនាដែលភិក្ខុបានឃើញ ថាជារបស់មិនទៀង ក្នុងកាលឯណា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ជាអ្នកឃើញដោយប្រពៃ បានកាត់នូវតណ្ហា គាស់រំលើងនូវសញ្ញោជនៈ បានធ្វើនូវទីបំផុតនៃទុក្ខ ព្រោះត្រាស់ដឹងដោយប្រពៃនូវមានះ ។

[១០] អ្នកឯណាបានឃើញសុខវេទនាថាជាទុក្ខវេទនាវិញ
បានឃើញទុក្ខវេទនាថាជាកូនសរ បានឃើញអទុក្ខមសុខ-
វេទនានោះថាជាសភាវៈមិនទៀងទៅវិញ ។ បើភិក្ខុបាន
ឃើញដោយប្រពៃ កំណត់ដឹងនូវវេទនាទាំងឡាយ

សោ វេទនា បរិញ្ញាយ
ធិដ្ឋេ ធម្មេ អនាសវោ
កាយស្ស ភេទា ធម្មដ្ឋោ
សំខ្យំ នូបេតិ វេទគូតិ ។ បឋមំ ។

[១១] អស្សុតវា ភិក្ខវេ បុថុជ្ជនោ សុខម្បិ វេទនំ វេទយតិ ទុក្ខម្បិ វេទនំ វេទយតិ អទុក្ខមសុខម្បិ វេទនំ វេទយតិ ។ សុតវា ភិក្ខវេ អរិយសាវកោ សុខម្បិ វេទនំ វេទយតិ ទុក្ខម្បិ វេទនំ វេទយតិ អទុក្ខសុខម្បិ វេទនំ វេទយតិ ។ តត្រ ភិក្ខវេ កោ វិសេសោ កោ អធិប្បាយសោ ។ កឹ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេនាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ អស្សុតវា ភិក្ខវេ បុថុជ្ជនោ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ សោ ទ្វេ វេទនា វេទយតិ កាយិកញ្ច ចេតសិកញ្ច ។

ភិក្ខុនោះ លុះកំណត់ដឹងនូវវេទនាទាំងឡាយ ក្នុងបច្ចុប្បន្ន នេះហើយ ជាអ្នកមិនមានអាសវៈ ឋិតនៅក្នុងធម៌ ជាអ្នកដល់នូវវេទ លុះទម្លាយរាងកាយទៅ មិនគួររាប់ថា (ជាអ្នកមានភពទៀតឡើយ) ។ ចប់សូត្រទី ៥ ។

[១១] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងសោយនូវសុខវេទនាផង សោយនូវទុក្ខវេទនាផង សោយនូវអទុក្ខមសុខវេទនាផង ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង តែងសោយនូវសុខវេទនាដែរ សោយនូវទុក្ខវេទនាដែរ សោយនូវអទុក្ខមសុខវេទនាដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកជនទាំងពីរពួកនោះ មានសេចក្តីប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច ។ ចុះអរិយសាវកអ្នកចេះដឹងនិងបុថុជ្ជនដែលជាអ្នកមិនចេះដឹង តើមានដំណើរផ្សេងៗ គ្នាដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយនៃយើងខ្ញុំព្រះអង្គ មានព្រះមានព្រះភាគជាប្រធាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង កាលបើទុក្ខវេទនាពាល់ត្រូវ តែងសោយសោក លំបាក ខ្សឹកខ្សួល គក់ទ្រូងកន្ទក់កន្ទេញ ដល់នូវការវង្វេងវេងវោង បុថុជ្ជននោះ រមែងសោយនូវវេទនាទាំងពីរ ប្រព្រឹត្តទៅក្នុងកាយនិងប្រព្រឹត្តទៅក្នុងចិត្ត ។

៩

## បឋមកសគាថវគ្គោ

[១២] សេយ្យថាបិ ភិក្ខវេ បុរិសំ សល្លេន វិជ្ឈេយ្យុំ តមេនំ ទុតិយេន សល្លេន អនុវេធំ វិជ្ឈេយ្យុំ ឯវំ ហិ សោ ភិក្ខវេ បុរិសោ ទ្វេ សល្លេន[១] វេទនា វេទយតិ កាយិកញ្ច ចេតសិកញ្ច ។ ឯវមេវ ខោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ សោ ទ្វេ វេទនា វេទយតិ កាយិកញ្ច ចេតសិកញ្ច ។ តស្សាយេវ ខោ បន ទុក្ខាយ វេទនាយ បដិឃវា ហោតិ តមេនំ ទុក្ខាយ វេទនាយ បដិឃវន្តំ យោ ទុក្ខាយ វេទនាយ បដិឃានុសយោ សោ អនុសេតិ សោ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ កាមសុខំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ ន ហិ ភិក្ខវេ បជានាតិ អស្សុតវា បុថុជ្ជនោ អញ្ញត្រ កាមសុខា ទុក្ខាយ វេទនាយ និស្សរណំ តស្ស

---

១ ឱ. ទ្វេ សល្លេ វេទនា ។ម . ទ្វិ សល្លេន វេទនំ ។

[១២] ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលចាក់បុរសដែលមានដំបៅដោយសរ គប្បីចាក់ទម្លុះទៅតាមដំបៅនោះដោយសរជាគម្រប់ពីរ ម្នាលភិក្ខុទាំងឡាយ តាមដែលពិត បុរសនោះតែងសោយនូវវេទនាពីរយ៉ាងដែលប្រព្រឹត្តទៅក្នុងកាយផង ប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះសរមានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹងកាលបើទុក្ខវេទនាពាល់ត្រូវ រមែងសោយសោក លំបាក ខ្សឹកខ្សួលគក់ទ្រូងកន្ទក់កន្ទេញ ដល់នូវការវង្វេងវេងវោង បុថុជ្ជននោះតែងសោយនូវវេទនាទាំងពីរ ដែលប្រព្រឹត្តទៅក្នុងកាយផង ប្រព្រឹត្តទៅក្នុងចិត្តផង មានឧបមេយ្យដូច្នោះដែរ ។ ឯបុថុជ្ជនមានសេចក្តីចង្អៀតចង្អល់ដោយទុក្ខវេទនានោះឯងហើយ សេចក្តីចង្អៀតចង្អល់ជាអនុស័យឯណាដោយទុក្ខវេទនា សេចក្តីចង្អៀតចង្អល់ជាអនុស័យនោះ តែងធ្វើបុគ្គលដែលមានសេចក្តីចង្អៀតចង្អល់ដោយទុក្ខវេទនានោះឯង ឲ្យត្រាំត្រែងនៅបុគ្គលនោះ កាលបើទុក្ខវេទនាពាល់ត្រូវ ទើបរីករាយចំពោះសេចក្តីសុខក្នុងកាម ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុថុជ្ជនអ្នកមិនចេះដឹង ទុកជាវៀរចាកកាមសុខចេញហើយ ក៏មិនដឹងនូវឧបាយជាគ្រឿងរលាស់ចេញនូវទុក្ខវេទនាបាន កាលបើបុថុជ្ជននោះ

កាមសុខំ ច អភិនន្ទតោ យោ សុខាយ វេទនាយ រាគានុសយោ សោ អនុសេតិ សោ តាសំ វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្ស-រណញ្ច យថាភូតំ នប្បជានាតិ ។ តស្ស តាសំ វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទី-នវញ្ច និស្សរណញ្ច យថាភូតំ អប្បជានតោ យោ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ សោ អនុ-សេតិ សោ សុខញ្ចេ វេទនំ វេទយតិ សញ្ញុត្តោ នំ វេទយតិ ទុក្ខញ្ចេ វេទនំ វេទយតិ សញ្ញុត្តោ នំ វេទយ-តិ អទុក្ខមសុខញ្ចេ វេទនំ វេទយតិ សញ្ញុត្តោ នំ វេទ-យតិ ។ អយំ វុច្ចតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ សញ្ញុត្តោ ជាតិយា ជរាយ មរណេន សោកេហិ បរិ-ទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ សញ្ញុត្តោ ទុក្ខស្មាតិ វទាមិ ។

រីករាយចំពោះកាមសុខ អនុស័យគឺតម្រេកដោយសុខវេទនាឯណា អនុ-ស័យគឺតម្រេកនោះ រមែងឲ្យបុថុជ្ជនត្រាំត្រែងនៅ បុថុជ្ជននោះមិនដឹងច្បាស់នូវហេតុដែលកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវឧបាយជាគ្រឿងរលាស់ចេញផង នូវវេទនាទាំងនោះតាមពិត ។ កាលបុថុជ្ជននោះមិនដឹងច្បាស់នូវហេតុដែលកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវឧបាយជាគ្រឿងរលាស់ចេញផង នូវវេទនាទាំងនោះតាមពិត អនុស័យគឺអវិជ្ជាដោយអទុក្ខមសុខវេទនាឯណា អនុស័យគឺអវិជ្ជានោះ តែងឲ្យបុថុជ្ជនត្រាំត្រែងនៅ បុថុជ្ជននោះ រមែងសោយនូវសុខវេទនា ជាអ្នកប្រកបដោយកិលេស សោយនូវវេទនានោះផង សោយនូវទុក្ខវេទនា ជាអ្នកប្រកបដោយកិលេស សោយនូវវេទនានោះផង សោយនូវអទុក្ខមសុខវេទនា ជាអ្នកប្រកបដោយកិលេស សោយនូវវេទនានោះផង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹងនេះ ហៅថា អ្នកប្រកបព្រមដោយជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ តថាគតពោលថាជាអ្នកប្រកបដោយទុក្ខ ។

១១

បឋមកសគាថវគ្គោ

[១៣] សុតវា ច ខោ ភិក្ខវេ អរិយសាវកោ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ សោ ឯកំ វេទនំ វេទយតិ កាយិកំ ន ចេតសិកំ ។

[១៤] សេយ្យថាបិ ភិក្ខវេ បុរិសំ សល្លេន វិជ្ឈេយ្យុំ តមេនំ ទុតិយេន សល្លេន អនុវេធំ វិជ្ឈេយ្យុំ ។ ឯវំ ហិ សោ ភិក្ខវេ បុរិសោ ឯកសល្លេន វេទនំ វេទយតិ ។ ឯវមេវ ខោ ភិក្ខវេ សុតវា អរិយសាវកោ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ សោ ឯកំ វេទនំ វេទយតិ កាយិកំ ន ចេតសិកំ តស្សាយេវ ខោ បន ទុក្ខាយ វេទនាយ បដិឃវា ន ហោតិ តមេនំ ទុក្ខាយ វេទនាយ បដិឃវន្តំ យោ ទុក្ខាយ វេទនាយ បដិឃានុសយោ សោ នានុសេតិ

[១៣] ម្នាលភិក្ខុទាំងឡាយ ឯអរិយសាវ័កអ្នកចេះដឹង កាលបើទុក្ខវេទនាពាល់ត្រូវ រមែងមិនសោយសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងវេងវោង អរិយសាវកនោះ តែងសោយនូវវេទនា ដែលប្រព្រឹត្តទៅក្នុងកាយតែម្យ៉ាង មិនសោយនូវវេទនាដែលប្រព្រឹត្តទៅក្នុងចិត្តឡើយ ។

[១៤] ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលចាក់បុរស ដែលមានដំបៅដោយសរ គប្បីចាក់ទម្លុះតាមដំបៅនោះ ដោយសរជាគម្រប់ពីរ ។ ម្នាលភិក្ខុទាំងឡាយ តាមដែលពិត បុរសនោះ សោយនូវវេទនាដោយសរតែម្យ៉ាងនេះ មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ អរិយសាវ័កអ្នកចេះដឹង កាលបើទុក្ខវេទនាពាល់ត្រូវ រមែងមិនសោយសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងវេងវោង អរិយសាវ័កនោះ តែងសោយនូវវេទនា ដែលប្រព្រឹត្តទៅក្នុងកាយតែម្យ៉ាង មិនសោយនូវវេទនាដែលប្រព្រឹត្តទៅក្នុងចិត្តឡើយ ទាំងមិនមានសេចក្តីចង្អៀតចង្អល់ ដោយទុក្ខវេទនានោះឯង អនុស័យគឺសេចក្តីចង្អៀតចង្អល់ ដោយទុក្ខវេទនាឯណា អនុស័យគឺសេចក្តីចង្អៀតចង្អល់នោះ រមែងដេកអរិយសាវ័កនោះ ដែលមានសេចក្តីចង្អៀតចង្អល់ ដោយទុក្ខវេទនាមិនឲ្យត្រាំត្រែងបាន

សោ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ កាមសុខំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ បជានាតិ សោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អញ្ញត្រ កាមសុខា ទុក្ខាយ វេទនាយ និស្សរណំ តស្ស កាមសុខំ អភិនន្ទតោ យោ សុខាយ វេទនាយ រាគានុសយោ សោ អនុសេតិ សោ តាសំ វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ តស្ស តាសំ វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានតោ យោ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ សោ នានុសេតិ

អរិយសាវ័កនោះ កាលបើទុក្ខវេទនាពាល់ត្រូវហើយ ក៏មិនត្រេកអរនូវកាមសុខឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាអរិយសាវ័កនោះជាអ្នកចេះដឹងទុកជាស្រេចចាកកាមសុខហើយ ក៏ស្គាល់ច្បាស់នូវឧបាយជាគ្រឿងរលាស់ចេញនូវទុក្ខវេទនាបាន កាលបើអរិយសាវ័កនោះមិនត្រេកអរនឹងកាមសុខហើយ អនុស័យគឺតម្រេកដោយសុខវេទនាឯណា អនុស័យគឺតម្រេកនោះ រមែងធ្វើមិនឲ្យអរិយ-សាវ័កត្រាំត្រែងនៅបាន អរិយសាវ័កនោះរមែងដឹងច្បាស់នូវហេតុដែលកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវឧបាយជាគ្រឿងរលាស់ចេញផង នូវវេទនាទាំងនោះតាមពិត ។ កាលអរិយសាវ័កនោះ ដឹងច្បាស់នូវហេតុជាទីកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវឧបាយជាគ្រឿងរលាស់ចេញផង នូវវេទនាទាំងនោះតាមពិតហើយ អនុស័យគឺអវិជ្ជាដោយអទុក្ខមសុខវេទនាឯណា អនុស័យគឺអវិជ្ជានោះរមែងធ្វើមិនឲ្យអរិយសាវ័កត្រាំត្រែងនៅបាន

១៣

បឋមកសគាថវគ្គោ

សោ សុខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ ទុក្ខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ អទុក្ខមសុខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ ។ អយំ វុច្ចតិ ភិក្ខវេ សុតវា អរិយសាវកោ វិសញ្ញុត្តោ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ វិសញ្ញុត្តោ ទុក្ខស្មាតិ វទាមិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេនាតិ ។

[១៨] ន សោ វេទនំ វេទយតិ សបញ្ញោ

សុខម្បិ ទុក្ខម្បិ ពហុស្សុតោ បិ

អរិយសាវ័កនោះ តែងសោយនូវសុខវេទនាដែរ តែមិនប្រកបដោយកិលេស សោយនូវវេទនានោះផង តែងសោយនូវទុក្ខវេទនាដែរ តែមិនប្រកបដោយកិលេស សោយនូវវេទនានោះផង រមែងសោយនូវអទុក្ខមសុខវេទនាដែរ តែមិនប្រកបដោយកិលេស សោយនូវវេទនានោះផង ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹងនេះហើយ ដែលហៅថាជាអ្នកមិនប្រកបដោយជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ តថាគតពោលថាជាអ្នកមិនប្រកបដោយទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្ដីប្លែកគ្នា នេះជាសេចក្ដីអធិប្បាយ នេះជាដំណើរផ្សេងៗ គ្នា របស់អរិយសាវ័កអ្នកចេះដឹងនិងបុថុជ្ជនអ្នកមិនចេះដឹង ។

[១៥] អរិយសាវ័កនោះ ប្រកបដោយបញ្ញា ជាពហុស្សូត
រមែងមិនសោយវេទនាជាសុខខ្លះ ជាទុក្ខខ្លះ មួយវិញទៀត

អយំ ច ជីវស្ស បុថុជ្ជនេន
អយំ វិសេសោ កុសលស្ស ហោតិ ។
សង្ខាតធម្មស្ស ពហុស្សុតស្ស
វិបស្សតោ លោកមិមំ បរញ្ច
ឥដ្ឋស្ស ធម្មា ន មថេន្តិ ចិត្តំ
អនិដ្ឋតោ នោ បដិឃាតមេតិ ។
តស្សានុរោធា អថវា វិរោធា
វិធមិតា អត្ថគតា ន សន្តិ
បទញ្ច ញត្វា(១) វិរជំ អសោកំ
សម្មា បជានាតិ ភវស្ស បារគូតិ ។ ឆដ្ឋំ ។

[១៦] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន គិលានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ

១ ឱ. ម. វិធូបិតា អត្ថង្គតា សន្តិបទញ្ច ញត្វា ។

អរិយសាវ័កនេះប្លែកចាកបុថុជ្ជន នេះជាសេចក្ដីវិសេសរបស់អ្នកប្រាជ្ញជាអ្នកឈ្លាសវៃ ។ ធម៌ទាំងឡាយដែលជាទីប្រាថ្នា រមែងមិនញាំញីចិត្តរបស់អរិយសាវ័ក ដែលមានធម៌បានពិចារណាហើយ ជាពហុស្សូត ឃើញច្បាស់នូវលោកនេះ នឹងលោកខាងមុខបាន កាលបើអរិយសាវ័កនោះ មិនប្រាថ្នាធម៌ទាំងឡាយ ក៏មិនកម្ចាត់បង់នូវចិត្តបាន ។ អរិយសាវ័កអ្នកដល់នូវត្រើយនៃភព រមែងដឹងច្បាស់នូវសន្តិបទ ប្រាសចាកធូលីគឺកិលេស មិនមានសេចក្ដីសោក ឈ្មោះថាដឹងដោយប្រពៃ ព្រោះសេចក្ដីត្រេកអរក្ដី មិនត្រេកអរក្ដី នៃអរិយសាវ័កនោះ ព្រោះកម្ចាត់បង់ក្ដី ព្រោះដល់នូវកិរិយាតាំងនៅមិនបានក្ដី ក៏ពុំមែនឡើយ ។ ចប់សូត្រទី ៦ ។

[១៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារ-សាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះឯង ព្រះមានព្រះភាគ ចេញអំពីទីពួនសម្ងំក្នុងពេលល្ងាច ស្ដេចទៅកាន់គិលានសាលា (រោងជំងឺ) លុះស្ដេចទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់ហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំង-

សតោ ភិក្ខវេ ភិក្ខុ សម្បជានោ កាលំ អាគមេយ្យ អយំ វោ អម្ហាកំ អនុសាសនី ។

[១៧] កថញ្ច ភិក្ខវេ ភិក្ខុ សតោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អ-ភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ បេ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សតោ ហោតិ ។

ឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសតិដឹងខ្លួន គប្បីរង់ចាំនូវកាលដ៏សមគួរ នេះជាអនុសាសនីគឺពាក្យប្រៀនប្រដៅរបស់តថាគតចំពោះអ្នកទាំងឡាយ ។

[១៧] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកមានសតិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ក្នុងវេទនាទាំងឡាយ ។ បេ ។ ក្នុងចិត្ត ។ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតីយ៉ាងនេះឯង ។

[១៨] កថញ្ច ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សម្បជានការី ហោតិ ។ សតោ ភិក្ខវេ ភិក្ខុ សម្បជានោ កាលំ អាគមេយ្យ អយំ វោ អម្ហាកំ អនុសាសនី ។

[១៨] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដឹងខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលដើរទៅខាងមុខ និងថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលក្រឡេកមើលទៅខាងមុខ និងកាលក្រឡេកមើលទៅទិសផ្សេងៗ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការបត់អវយវៈចូល និងលាអវយវៈចេញ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការប្រើប្រាស់សង្ឃាដី បាត្រនិងចីពរ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការបរិភោគភោជន និងផឹកទឹក ទំពាស៊ីខាទនីយៈ ជញ្ជាប់ (នូវភេសជ្ជៈមានសប្បិជាដើម) ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការបន្ទោបង់នូវឧច្ចារបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេក ភ្ញាក់ឡើង និយាយ និងស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកធ្វើនូវសេចក្តីដឹងខ្លួន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានស្មារតីដឹងខ្លួន គប្បីរង់ចាំនូវកាលដ៏សមគួរ នេះជាអនុសាសនីគឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

១៧

## បឋមកសគាថវគ្គោ

[១៩] តស្ស ចេ ភិក្ខវេ ភិក្ខុនោ ឯវំ សតស្ស សម្បជានស្ស អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ សុខា វេទនា សោ ឯវំ បជានាតិ ឧប្បន្នា ខោ មេ អយំ សុខា វេទនា សា ច ខោ បដិច្ច នោ អប្បដិច្ច កឹ បដិច្ច ឥមមេវ កាយំ បដិច្ច អយំ ខោ បន កាយោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ អនិច្ចំ ខោ បន សង្ខតំ បដិច្ចសមុប្បន្នំ កាយំ បដិច្ច ឧប្បន្នា សុខា វេទនា កុតោ និច្ចា ភវិស្សតីតិ ។ សោ កាយេ ច សុខាយ ច វេទនាយ អនិច្ចានុបស្សី វិហរតិ វយានុបស្សី វិហរតិ វិរាគានុបស្សី វិហរតិ និរោធានុបស្សី វិហរតិ បដិនិស្សគ្គានុបស្សី វិហរតិ ។

[១៩] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមានស្មារតី ជាអ្នកដឹងខ្លួន មិនមានសេចក្តីប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន នៅគ្រប់ឥរិយាបថយ៉ាងនេះហើយ បើសុខវេទនាកើតឡើង ភិក្ខុនោះក៏ដឹងច្បាស់យ៉ាងនេះថា សុខវេទនាកើតឡើងដល់អាត្មាអញ សុខវេទនានោះឯង អាស្រ័យនូវ (បច្ច័យ) មិនមែនមិនអាស្រ័យនូវ (បច្ច័យ) ទេ អាស្រ័យនូវ (បច្ច័យ) អ្វី អាស្រ័យនូវកាយនេះឯង ឯកាយនេះសោតជារបស់មិនទៀង បច្ច័យតាក់តែងឡើង អាស្រ័យ (បច្ច័យ) ទើបកើតឡើង សុខវេទនាដែលកើតឡើងព្រោះអាស្រ័យនូវកាយជារបស់មិនទៀង បច្ច័យតាក់តែងឡើង អា-ស្រ័យ (បច្ច័យ) ទើបកើតឡើង នឹងមានសេចក្តីទៀងទាត់មកអំពីណា ។ ភិក្ខុនោះ ជាអ្នកពិចារណាឃើញនូវសេចក្តីមិនទៀង ពិចារណាឃើញនូវសេចក្តីសាបសូន្យទៅ ពិចារណាឃើញនូវការប្រាសចាកតម្រេក ពិចារណាឃើញនូវសេចក្តីរលត់ ពិចារណាឃើញនូវការលះបង់ចោលជាប្រក្រតី ក្នុងកាយផង ក្នុងសុខវេទនាផង គ្រប់ឥរិយាបថទាំង ៤ ។

តស្ស កាយេ ច សុខាយ ច វេទនាយ អនិច្ចានុបស្សិ-
នោ វិហរតោ វយានុបស្សិនោ វិហរតោ ។ បេ ។ បដិ-
និស្សគ្គានុបស្សិនោ វិហរតោ យោ កាយេ ច សុខាយ
ច វេទនាយ រាគានុសយោ សោ បហិយ្យតិ ។

[២០] តស្ស ចេ ភិក្ខវេ ភិក្ខុនោ ឯវំ សតស្ស
សម្បជានស្ស អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស
វិហរតោ ឧប្បជ្ជតិ ទុក្ខា វេទនា សោ ឯវំ បជានាតិ
ឧប្បន្នា ខោ ម្យាយំ ទុក្ខា វេទនា សា ច ខោ បដិច្ច
នោ អប្បដិច្ច កឹ បដិច្ច ឥមមេវ កាយំ បដិច្ច អយំ
ខោ បន កាយោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ
អនិច្ចំ ខោ បន សង្ខតំ បដិច្ចសមុប្បន្នំ កាយំ បដិច្ច
ឧប្បន្នា ទុក្ខា វេទនា កុតោ អនិច្ចា ភវិស្សតីតិ ។
សោ កាយេ ច ទុក្ខាយ ច វេទនាយ អនិច្ចានុបស្សី
វិហរតិ វយានុបស្សី វិហរតិ វិរាគានុបស្សី វិហរតិ

កាលភិក្ខុនោះពិចារណាឃើញនូវសេចក្តីមិនទៀង ពិចារណាឃើញនូវសេចក្តីសាបសូន្យ ។ បេ ។ ជាអ្នកពិចារណាឃើញនូវការលះបង់ចោលជាប្រក្រតី ក្នុងកាយផង ក្នុងសុខវេទនាផង គ្រប់ឥរិយាបថទាំង ៤ រាគានុស័យក្នុងកាយក្តី ក្នុងសុខវេទនាក្តី ភិក្ខុនោះក៏លះបង់ចេញ ។

[២០] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមានស្មារតី ជាអ្នកដឹងខ្លួន មិនមានសេចក្តីប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន គ្រប់ឥរិយាបថយ៉ាងនេះហើយ ទុក្ខវេទនាកើតឡើង ភិក្ខុនោះក៏ដឹងច្បាស់យ៉ាងនេះថា ទុក្ខវេទនានេះ កើតឡើងដល់អាត្មាអញ ទុក្ខវេទនានោះឯង អាស្រ័យនូវ (បច្ច័យ) មិនមែនមិនអាស្រ័យ (បច្ច័យ) ទេ ចុះអាស្រ័យ (បច្ច័យ) អ្វី អាស្រ័យនូវកាយនេះឯង ឯកាយនេះសោតជារបស់មិនទៀង បច្ច័យតាក់តែងឡើង អាស្រ័យ (បច្ច័យ) ទើបកើតឡើង បើដូច្នោះ ទុក្ខវេទនាដែលកើតឡើង ព្រោះអាស្រ័យនូវកាយជារបស់មិនទៀង បច្ច័យតាក់តែងឡើង អាស្រ័យ (បច្ច័យ) ទើបកើតឡើង នឹងមានសេចក្តីទៀងទាត់មកអំពីណា ។ ភិក្ខុនោះជាអ្នកពិចារណាឃើញនូវសេចក្តីមិនទៀង ពិចារណាឃើញនូវសេចក្តីសាបសូន្យ ពិចារណាឃើញនូវការប្រាសចាកតម្រេក

និរោធានុបស្សី វិហរតិ បដិនិស្សគ្គានុបស្សី វិហរតិ ។ តស្ស កាយេ ច ទុក្ខាយ ច វេទនាយ អនិច្ចានុបស្សិនោ វិហរតោ ។ បេ ។ បដិនិស្សគ្គានុបស្សិនោ វិហរតោ យោ កាយេ ច ទុក្ខាយ ច វេទនាយ បដិឃានុសយោ សោ បហិយ្យតិ ។

[២១] តស្ស ចេ ភិក្ខវេ ភិក្ខុនោ ឯវំ សតស្ស សម្បជានស្ស អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ អទុក្ខមសុខា វេទនា សោ ឯវំ បជានាតិ ឧប្បន្នា ខោ ម្យាយំ អទុក្ខមសុខា វេទនា សា ច ខោ បដិច្ច នោ អប្បដិច្ច កឹ បដិច្ច ឥមមេវ កាយំ បដិច្ច អយំ ខោ បន កាយោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ អនិច្ចំ ខោ បន សង្ខតំ បដិច្ចសមុប្បន្នំ កាយំ បដិច្ច ឧប្បន្នា អទុក្ខមសុខា វេទនា កុតោ និច្ចា ភវិស្សតីតិ ។ សោ កាយេ ច អទុក្ខមសុខាយ ច វេទនាយ អនិច្ចានុបស្សី វិហរតិ វយានុបស្សី វិហរតិ វិរាគានុបស្សី វិហរតិ

ពិចារណាឃើញនូវសេចក្តីរលត់ ពិចារណាឃើញនូវការលះបង់ចោល ជាប្រក្រតី ក្នុងកាយផង ក្នុងទុក្ខវេទនាផង គ្រប់ឥរិយាបថទាំង ៤ ។ កាល ភិក្ខុនោះពិចារណាឃើញនូវសេចក្តីមិនទៀង ។ បេ ។ ពិចារណាឃើញ នូវការលះបង់ចោលជាប្រក្រតី ក្នុងកាយផង ក្នុងទុក្ខវេទនាផង បដិ-ឃានុស័យក្នុងកាយក្តី ក្នុងទុក្ខវេទនាក្តី ភិក្ខុនោះក៏លះបង់ចេញបាន ។

[២១] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ ជាអ្នកមានស្មារតី ដឹងខ្លួន មិនមានសេចក្តីប្រមាទ មានព្យាយាមដុតកម្តៅកិលេស មាន ចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន គ្រប់ឥរិយាបថយ៉ាងនេះហើយ អទុក្ខមសុខ-វេទនាក៏កើតឡើង ភិក្ខុនោះរមែងដឹងច្បាស់យ៉ាងនេះថា អទុក្ខមសុខ-វេទនានេះ កើតឡើងដល់អាត្មាអញ អទុក្ខមសុខវេទនានោះ អាស្រ័យ (បច្ច័យ) មិនមែនមិនអាស្រ័យ (បច្ច័យ) ទេ ចុះអាស្រ័យ (បច្ច័យ) អ្វី អាស្រ័យនូវកាយនេះឯង ឯកាយនេះជារបស់មិនទៀង បច្ច័យតាក់តែង ឡើង អាស្រ័យ (បច្ច័យ) ទើបកើតឡើង អទុក្ខមសុខវេទនាដែលកើត ឡើង ព្រោះអាស្រ័យនូវកាយជារបស់មិនទៀង បច្ច័យតាក់តែងឡើង អាស្រ័យ (បច្ច័យ) ទើបកើតឡើង នឹងមានសេចក្តីទៀងទាត់មកអំពី ណា ។ ភិក្ខុនោះជាអ្នកពិចារណាឃើញនូវសេចក្តីមិនទៀង ពិចារណា ឃើញនូវសេចក្តីសាបសូន្យ ពិចារណាឃើញនូវការប្រាសចាកតម្រេក

និរោធានុបស្សី វិហរតិ បដិនិស្សគ្គានុបស្សី វិហរតិ ។ តស្ស កាយេ ច អទុក្ខមសុខាយ ច វេទនាយ អនិច្ចានុបស្សិនោ វិហរតោ ។ បេ ។ បដិនិស្សគ្គានុ-បស្សិនោ វិហរតោ យោ កាយេ ច អទុក្ខមសុខាយ ច វេទនាយ អវិជ្ជានុសយោ សោ បហិយ្យតិ ។

[២២] សោ សុខញ្ចេ វេទនំ វេទយតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ទុក្ខំ ចេ វេទនំ វេទយតិ ។ បេ ។ អទុក្ខ-មសុខំ ចេ វេទនំ វេទយតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ។ សោ សុខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ ទុក្ខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ

ពិចារណាឃើញនូវសេចក្តីរលត់ ពិចារណាឃើញនូវការលះបង់ចោលជាប្រក្រតី ក្នុងកាយផង ក្នុងអទុក្ខមសុខវេទនាផង គ្រប់ឥរិយាបថទាំង ៤ ។ កាលភិក្ខុនោះពិចារណាឃើញនូវសេចក្តីមិនទៀង ។ បេ ។ ពិចារណាឃើញនូវការលះបង់ចោលជាប្រក្រតី ក្នុងកាយផង ក្នុងអទុក្ខមសុខវេទនាផង អវិជ្ជានុស័យក្នុងកាយក្តី ក្នុងអទុក្ខមសុខវេទនាក្តី ភិក្ខុនោះ ក៏លះបង់ចេញបាន ។

[២២] ភិក្ខុនោះសោយនូវសុខវេទនា រមែងដឹងច្បាស់ថា សុខវេទនានោះមិនទៀងផង ដឹងច្បាស់ថាជាធម្មជាតិដែលអរិយៈមិនបានប្រកាន់មាំផង ដឹងច្បាស់ថាជាធម្មជាតិដែលអរិយៈមិនត្រេកអរផង ទោះបីសោយទុក្ខវេទនា ។ បេ ។ ទោះបីសោយអទុក្ខមសុខវេទនា រមែងដឹងច្បាស់ថា អទុក្ខមសុខវេទនានោះជាធម្មជាតិមិនទៀង ដឹងច្បាស់ថាជាធម្មជាតិដែលអរិយៈមិនបានប្រកាន់មាំ ដឹងច្បាស់ថាជាធម្មជាតិដែលអរិយៈមិនត្រេកអរ ។ ភិក្ខុនោះរមែងសោយសុខវេទនា តែជាអ្នកមិនប្រកបដោយកិលេស ទើបសោយនូវវេទនានោះផង រមែងសោយទុក្ខវេទនា តែជាអ្នកមិនប្រកបដោយកិលេស តែងសោយនូវវេទនានោះផង

២១

បឋមកសគាថវគ្គោ

អនុត្តមសុខញ្ច វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ ។ សោ កាយបរិយន្តិកំ វេទនំ វេទយមានោ កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ជីវិតបរិយន្តិកំ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតិភវិស្សន្តីតិ បជានាតិ ។

[២៣] សេយ្យថាបិ ភិក្ខវេ តេលញ្ច វដ្ដិញ្ច បដិច្ច តេលប្បទីបោ ឈាយេយ្យ តស្សេវ តេលស្ស ច វដ្ដិយា ច បរិយាទានា អនាហារោ និព្វាយេយ្យ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ចេ កាយបរិយន្តិកំ វេទនំ វេទយមានោ កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ជីវិតបរិយន្តិកំ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ

រមែងសោយអទុក្ខមសុខវេទនា តែជាអ្នកមិនប្រកបដោយកិលេស ទើបសោយនូវវេទនានោះផង ។ ភិក្ខុនោះកាលសោយនូវវេទនាមានកាយជាទីបំផុត (ស្មើរនឹងស្លាប់ខ្លួន) រមែងដឹងច្បាស់ថា អាត្មាអញសោយនូវវេទនាមានកាយជាទីបំផុត កាលសោយនូវវេទនាមានជីវិតជាទីបំផុត (ស្មើរនឹងអស់ជីវិត) រមែងដឹងច្បាស់ថា អាត្មាអញសោយនូវវេទនាមានជីវិតជាទីបំផុត រមែងដឹងច្បាស់ថា លុះបែកធ្លាយរាងកាយបន្ទាប់អំពីការអស់ជីវិតទៅ ការសោយនូវវេទនាទាំងពួងដែលអាត្មាអញមិនបានត្រេកអរហើយក្នុងលោកនេះ នឹងមានសេចក្ដីត្រជាក់ ។

[២៣] ម្នាលភិក្ខុទាំងឡាយ ដូចប្រទីបប្រេងគប្បីឆេះឡើងព្រោះអាស្រ័យនូវប្រេងនិងប្រឆេះ ប្រទីបប្រេងនោះ មិនមានអាហារគប្បីរលត់ទៅ ក៏ព្រោះអស់ទៅនៃប្រេងនិងប្រឆេះនោះឯង មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីឧបមេយ្យក៏ដូច្នោះដែរ ភិក្ខុកាលបើសោយនូវវេទនាមានកាយជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មាអញសោយនូវវេទនាមានកាយជាទីបំផុត កាលសោយនូវវេទនាមានជីវិតជាទីបំផុត រមែងដឹងច្បាស់ថា អាត្មាអញសោយនូវវេទនាមានជីវិតជាទីបំផុត

កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វ-
វេទយិតានិ អនភិនន្ទិតានិ សីតិភវិស្សន្តីតិ បជានា-
តីតិ ។ សត្តមំ ។

[២៤] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ
មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា សា-
យណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន គិលាន-
សាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ
និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ សតោ
ភិក្ខវេ ភិក្ខុ សម្បជានោ កាលំ អាគមេយ្យ អយំ
វោ អម្ហាកំ អនុសាសនី ។

[២៥] កថញ្ច ភិក្ខវេ ភិក្ខុ សតោ ហោតិ ។
ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ
អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-

រមែងដឹងច្បាស់ថា លុះបែកធ្លាយរាងកាយបន្ទាប់អំពីការអស់ជីវិតទៅ ការសោយនូវវេទនាទាំងពួង ដែលអាត្មាអញមិនបានត្រេកអរហើយក្នុងលោកនេះ នឹងមានសេចក្តីត្រជាក់ ។ ចប់សូត្រទី ៧ ។

[២៤] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកូដាគារ-សាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចេញអំពីទីពួនសម្ងំក្នុងវេលាសាយណ្ហសម័យ ហើយស្តេចចូលទៅកាន់គិលានសាលា លុះស្តេចទៅដល់ហើយ ទ្រង់គង់លើអា-សនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់រួចហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានស្មារតី ជាអ្នកដឹងខ្លួន គប្បីរង់ចាំនូវកាលដ៏សមគួរ នេះជាអនុសាសនីគឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[២៥] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកមានស្មារតី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី មានសេចក្តីព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកម្ចាត់បង់នូវអភិជ្ឈានិងទោម-

ពោមនស្សំ ។ វេទនាសុ ។ បេ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សតោ ហោតិ ។

[២៦] កថញ្ច ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ ។ បេ ។ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។ សតោ ភិក្ខវេ ភិក្ខុ សម្បជានោ កាលំ អាគមេយ្យ អយំ វោ អម្ហាកំ អនុសាសនី ។

[២៧] តស្ស ចេ ភិក្ខវេ ភិក្ខុនោ ឯវំ សតស្ស សម្បជានស្ស អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ សុខា វេទនា សោ ឯវំ បជានាតិ ឧប្បន្នា ខោ ម្យាយំ សុខា វេទនា សា ច ខោ បដិច្ច នោ

នស្សក្នុងលោកចេញបាន ។ ក្នុងវេទនាទាំងឡាយ ។ បេ ។ ក្នុងចិត្ត ។ ជាអ្នកពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតីយ៉ាងនេះឯង ។

[២៦] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដឹងខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើសេចក្តីដឹងខ្លួន ក្នុងកាលដើរទៅខាងមុខនិងថយក្រោយ ។ បេ ។ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងការនិយាយនិងស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងខ្លួនគប្បីរង់ចាំកាលដ៏សមគួរ នេះជាអនុសាសនីគឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[២៧] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមានស្មារតី ជាអ្នកដឹងខ្លួន មិនមានសេចក្តីប្រមាទ មានព្យាយាមដុតកម្តៅកិលេសមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន គ្រប់ឥរិយាបថយ៉ាងនេះហើយ សុខ-វេទនាក៏កើតឡើង ភិក្ខុនោះរមែងដឹងច្បាស់យ៉ាងនេះថា សុខវេទនានេះកើតឡើងដល់អាត្មាអញ សុខវេទនានោះឯងអាស្រ័យ (បច្ច័យ) មិនមែន

អប្បដិច្ច កឹ បដិច្ច ឥមមេវ ផស្សំ បដិច្ច អយំ ខោ បន ផស្សោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ អនិច្ចំ ខោ បន សង្ខតំ បដិច្ចសមុប្បន្នំ ផស្សំ បដិច្ច ឧប្បន្នា ខោ ម្យាយំ សុខា វេទនា កុតោ និច្ចា ភវិស្សតីតិ ។ សោ ផស្សេ ច សុខាយ ច វេទនាយ អនិច្ចានុបស្សី វិហរតិ វយានុបស្សី វិរាគានុបស្សី និរោធានុបស្សី បដិនិស្សគ្គានុបស្សី វិហរតិ ។ តស្ស ផស្សេ ច សុខាយ ច វេទនាយ អនិច្ចានុបស្សិនោ វិហរតោ វយា វិរាគា និរោធា បដិនិស្សគ្គានុបស្សិនោ វិហរតោ យោ ផស្សេ ច សុខាយ ច វេទនាយ រាគានុសយោ សោ បហិយ្យតិ ។

មិនអាស្រ័យ (បច្ច័យ) ទេ ចុះអាស្រ័យបច្ច័យអ្វី អាស្រ័យនូវផស្សៈនេះ ឯង ចំណែកផស្សនេះសោត ជារបស់មិនទៀង ដែលបច្ច័យតាក់តែង ឡើង អាស្រ័យបច្ច័យទើបកើតឡើង សុខវេទនានេះកើតឡើងដល់ អាត្មាអញ ព្រោះអាស្រ័យនូវផស្សៈដែលជារបស់មិនទៀង ដែលបច្ច័យ តាក់តែង អាស្រ័យបច្ច័យទើបកើតឡើង នឹងមានសេចក្តីទៀងទាត់មក អំពីណា ។ ភិក្ខុនោះជាអ្នកពិចារណាឃើញនូវសេចក្តីមិនទៀង ពិចារ-ណាឃើញនូវសេចក្តីសាបសូន្យ ពិចារណាឃើញនូវការមិនមានតម្រេក ពិចារណាឃើញនូវសេចក្តីរលត់ ពិចារណាឃើញនូវការលះបង់ចោល ជាប្រក្រតី ក្នុងផស្សៈផង ក្នុងសុខវេទនាផង គ្រប់ឥរិយាបថទាំង ៤ ។ កាលភិក្ខុនោះ ជាអ្នកពិចារណាឃើញនូវសេចក្តីមិនទៀង ជាអ្នកពិចារណា ឃើញនូវសេចក្តីសាបសូន្យ នូវការមិនមានតម្រេក នូវសេចក្តីរលត់ និងការលះបង់ចោលជាប្រក្រតី ក្នុងផស្សៈផង ក្នុងសុខវេទនាផង គ្រប់ ឥរិយាបថទាំង ៤ រាគានុស័យដែលមានក្នុងផស្សៈក្តី ក្នុងសុខវេទនាក្តី ភិក្ខុនោះ ក៏លះបង់ចេញបាន ។

បឋមកសគាថវគ្គោ

[២៨] តស្ស ចេ ភិក្ខវេ ភិក្ខុនោ ឯវំ សតស្ស ។ បេ ។ វិហរតោ ឧប្បជ្ជតិ ទុក្ខា វេទនា ។ បេ ។ ឧប្បជ្ជតិ អទុក្ខមសុខា វេទនា សោ ឯវំ បជានាតិ ឧប្បន្នា ខោ ម្យាយំ អទុក្ខមសុខា វេទនា សា ច ខោ បដិច្ច នោ អប្បដិច្ច កឹ បដិច្ច ឥមមេវ ផស្សំ បដិច្ច អយំ ខោ បន ផស្សោ អនិច្ចោ សង្ខតោ បដិច្ច-សមុប្បន្នោ ។ បេ ។ (យថា បុរិមសុត្តេ វិត្ថារោ តថា វិត្ថារេតព្វោ) កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតិភវិស្សន្តីតិ បជានាតិ ។

បឋមកសគាថវគ្គ

[២៨] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមានស្មារតីយ៉ាងនេះ ។ បេ ។ ទុក្ខវេទនាក៏កើតឡើង ។ បេ ។ អទុក្ខមសុខវេទនាក៏កើតឡើង ភិក្ខុនោះរមែងដឹងច្បាស់យ៉ាងនេះថា អទុក្ខមសុខវេទនានេះកើតឡើងដល់អាត្មាអញ អទុក្ខមសុខវេទនានោះអាស្រ័យ (បច្ច័យ) មិនមែនមិនអាស្រ័យបច្ច័យទេ ចុះអាស្រ័យបច្ច័យអ្វី អាស្រ័យនូវផស្សៈនេះឯង ចំណែកផស្សៈនេះសោត ជារបស់មិនទៀង ដែលបច្ច័យតាក់តែង អាស្រ័យបច្ច័យទើបកើតឡើង ។ បេ ។ (សេចក្តីពិស្តារក្នុងសូត្រមុនយ៉ាងណា សូត្រនេះ បណ្ឌិតគប្បីសំដែងឲ្យពិស្តារយ៉ាងនោះចុះ) រមែងដឹងច្បាស់ថា លុះទម្លាយរាងកាយបន្ទាប់អំពីការអស់ជីវិតទៅ ការសោយនូវវេទនាទាំងពួងដែលអាត្មាអញមិនបានត្រេកអរហើយក្នុងលោកនេះ នឹងមានសេចក្តីត្រជាក់ ។

[២៩] សេយ្យថាបិ ភិក្ខវេ តេលញ្ច វដ្ដិញ្ច បដិច្ច តេលប្បទីបោ ឈាយេយ្យ តស្សេវ តេលស្ស ច វដ្ដិយា ច បរិយាទានា អនាហារោ និព្ពាយេយ្យ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ កាយបរិយន្តិកំ វេទនំ វេទយមានោ កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ជីវិត-បរិយន្តិកំ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ កាយស្ស ភេទា ឧទ្ធំ ជីវិតប-រិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតិ-ភវិស្សន្តីតិ បជានាតីតិ ។ អដ្ឋមំ ។

[៣០] តិស្សោ ឥមា ភិក្ខវេ វេទនា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគ-ធម្មា និរោធធម្មា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។

[២៩] ម្នាលភិក្ខុទាំងឡាយ ដូចប្រទីបប្រេងគប្បីឆេះឡើង ព្រោះអាស្រ័យនូវប្រេងនិងប្រឆេះ ប្រទីបប្រេងនោះមិនមានអាហារ គប្បីរលត់ទៅ ព្រោះអស់ទៅនៃប្រេងនិងប្រឆេះនោះឯង មានឧបមា យ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ ភិក្ខុកាលសោយនូវវេទនាមានកាយជាទីបំផុត រមែងដឹងច្បាស់ថា អាត្មាអញសោយនូវវេទនាមានកាយជាទីបំផុត កាលសោយនូវវេទនាមានជីវិតជាទីបំផុត រមែងដឹងច្បាស់ថា អាត្មាអញសោយនូវវេទនាមានជីវិតជាទីបំផុត រមែងដឹងច្បាស់ថា លុះទម្លាយរាងកាយបន្ទាប់អំពីការអស់ជីវិតទៅ ការសោយនូវវេទនាទាំងពួង ដែលអាត្មាអញមិនបានត្រេកអរ ហើយក្នុងលោកនេះ នឹងមានសេចក្តីត្រជាក់ ។ ចប់សូត្រទី ៨ ។

[៣០] ម្នាលភិក្ខុទាំងឡាយ វេទនា ៣ យ៉ាងនេះ មិនទៀង ដែលបច្ច័យតាក់តែងឡើង អាស្រ័យបច្ច័យទើបកើតឡើង មានការអស់ទៅជាធម្មតា មានការសាបសូន្យទៅជាធម្មតា មានការប្រាសចាកតម្រេកជាធម្មតា មានការរលត់ទៅជាធម្មតា ។ វេទនា ៣ យ៉ាង តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។

បឋមកសគាវគ្គោ

ឥមា ខោ ភិក្ខវេ តិស្សោ វេទនា អនិច្ចា សង្ខតា ប-
ដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធ-
ធម្មាតិ ។ នវមំ ។

[៣១] តិស្សោ ឥមា ភិក្ខវេ វេទនា ផស្សជា
ផស្សមូលកា ផស្សនិទានា ផស្សប្បច្ចយា ។ កាតមា
តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា
វេទនា ។ សុខវេទនិយំ[១] ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ
សុខា វេទនា តស្សេវ សុខវេទនិយស្ស ផស្សស្ស និរោ-
ធា យំ តជ្ជំ វេទយិតំ សុខវេទនិយំ ផស្សំ បដិច្ច ឧប្បន្នា
សុខា វេទនា សា និរុជ្ឈតិ សា វូបសមតិ ។ ទុក្ខ-
វេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា

---

១ សុខវេទនីយន្តិបិ ឯវំ សព្វត្ថ ។

ម្នាលភិក្ខុទាំងឡាយ វេទនា ៣ យ៉ាងនេះឯង ជារបស់មិនទៀង ដែលបច្ច័យតាក់តែងឡើង អាស្រ័យបច្ច័យទើបកើតឡើង មានការអស់ទៅជាធម្មតា មានការសាបសូន្យទៅជាធម្មតា មានការប្រាសចាកតម្រេកជាធម្មតា មានការរលត់ទៅជាធម្មតា ។ ចប់សូត្រ ទី ៩ ។

[៣១] ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង ដែលកើតឡើងអំពីផស្សៈ មានផស្សៈជាមូល មានផស្សៈជាហេតុ មានផស្សៈជាបច្ច័យ ។ វេទនា ៣ យ៉ាង តើដូចម្ដេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ សុខវេទនារមែងកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃសុខវេទនា សុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈជាបច្ច័យនៃសុខវេទនាដែលកើតអំពីផស្សៈនោះ ដែលបុគ្គលសោយហើយ សុខវេទនានោះតែងរលត់ទៅ សុខវេទនានោះតែងស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈដែលជាបច្ច័យនៃសុខវេទនានោះឯង ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខវេទនារមែងកើតឡើង ព្រោះអាស្រ័យផស្សៈជាបច្ច័យនៃទុក្ខវេទនា

តស្សេវ ទុក្ខវេទនិយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ ទុក្ខវេទនិយំ ផស្សំ បដិច្ច ឧប្បន្នា ទុក្ខា វេទ-នា សា និរុជ្ឈតិ សា វូបសមតិ ។ អទុក្ខមសុខ-វេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា តស្សេវ អទុក្ខមសុខវេទនិយស្ស ផស្សស្ស និ-រោធា យំ តជ្ជំ វេទយិតំ អទុក្ខមសុខវេទនិយំ ផស្សំ បដិច្ច ឧប្បន្នា អទុក្ខមសុខា វេទនា សា និរុជ្ឈតិ សា វូបសមតិ ។

[៣២] សេយ្យថាបិ ភិក្ខវេ ទ្វិន្នំ កដ្ឋានំ សង្ឃដ្ដា តស្ស សមោធានា[១] ឧស្មា ជាយតិ តេជោ អភិនិព្វ-ត្តតិ តេសំយេវ កដ្ឋានំ នានាភាវា វិនិក្ខេបា យា តជ្ជា ឧស្មា សា និរុជ្ឈតិ សា វូបសមតិ ។

១ ឱ. សមោធានា ។

ទុក្ខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈជាបច្ច័យនៃទុក្ខវេទនាដែលកើតអំពីផស្សៈនោះ ដែលបុគ្គលបានសោយហើយ ទុក្ខវេទនានោះរមែងរលត់ទៅ ទុក្ខវេទនានោះរមែងស្ងប់រម្ងាប់ទៅ ព្រោះរលត់នៃផស្សៈជាបច្ច័យនៃទុក្ខវេទនានោះឯង ។ ម្នាលភិក្ខុទាំងឡាយ អទុក្ខមសុខវេទនារមែងកើតឡើង ព្រោះអាស្រ័យផស្សៈជាបច្ច័យនៃអទុក្ខមសុខវេទនា អទុក្ខមសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈជាបច្ច័យនៃអទុក្ខមសុខវេទនាដែលកើតអំពីផស្សៈនោះ ដែលបុគ្គលបានសោយហើយ អទុក្ខមសុខវេទនានោះរមែងរលត់ទៅ អទុក្ខមសុខវេទនានោះរមែងស្ងប់រម្ងាប់ទៅ ព្រោះការរលត់នៃផស្សៈជាបច្ច័យនៃអទុក្ខមសុខវេទនានោះឯង ។

[៣២] ម្នាលភិក្ខុទាំងឡាយ ដូចចំហាយដែលកើតឡើង ភ្លើងដែលឆេះឡើង ព្រោះការប្រជុំចុះនៃឈើពីរកំណាត់ ដែលបុគ្គលរៀបចំហើយ ចំហាយឯណាដែលកើតអំពីឈើនោះ ចំហាយនោះក៏រលត់ទៅ ចំហាយនោះក៏ស្ងប់រម្ងាប់ទៅ ព្រោះភាវៈផ្សេងៗគ្នា ព្រោះដាក់ដោយឡែកពីគ្នា នៃកំណាត់ឈើទាំងនោះ មានឧបមាយ៉ាងណា ។

២៩

បឋមកសគាថវគ្គោ

ឯវមេវ ខោ ភិក្ខវេ ឥមា តិស្សោ វេទនា ផស្សជា ផស្សមូលកា ផស្សនិទានា ផស្សប្បច្ចយា តជ្ជំ ផស្សំ បដិច្ច តជ្ជា វេទនា ឧប្បជ្ជន្តិ តជ្ជស្ស ផស្សស្ស និរោធា តជ្ជា វេទនា និរុជ្ឈន្តីតិ ។ ទសមំ ។

បឋមកសគាថវគ្គោ បឋមោ ។

តស្សុទ្ទានំ

សមាធិសុខាយ បហានេន
ចាតាលំ ទដ្ឋព្វេន ច
សល្លត្តេន គេលញ្ញំ
អនិច្ចផស្សមូលកាតិ ។

ម្នាលភិក្ខុទាំងឡាយ សេចក្ដីឧបមេយ្យក៏ដូច្នោះដែរ វេទនា ៣ យ៉ាងនេះ កើតអំពីផស្សៈ មានផស្សៈជាមូល មានផស្សៈជាហេតុ មានផស្សៈជាបច្ច័យ វេទនាដែលកើតអំពីផស្សៈនោះ តែងកើតឡើង ព្រោះអាស្រ័យផស្សៈដែលកើតអំពីវេទនាទាំង ៣ នោះ វេទនាដែលកើតអំពីផស្សៈនោះ តែងរលត់ទៅ ព្រោះរលត់នៃផស្សៈដែលកើតអំពីវេទនាទាំង ៣ នោះដែរ ។ ចប់សូត្រទី ១០ ។

ចប់ បឋមកសគាថវគ្គទី ១ ។

# ឧទ្ទាននៃបឋមកសគាថវគ្គនោះគឺ

និយាយអំពីពុទ្ធសាវ័កមានចិត្តតាំងមាំ ១ អំពីសុខវេទនា ១ អំពីការលះបង់រាគានុស័យជាដើម ១ អំពីបាតាលមានក្នុងមហាសមុទ្រ ១ អំពីការឃើញសុខវេទនាថាជាទុក្ខជាដើម ១ អំពីសុខវេទនាជាដើមប្រៀបដោយសរ ១ អំពីព្រះមានព្រះភាគស្ដេចចូលទៅកាន់គិលានសាលាមាន ២ លើក អំពីវេទនា ៣ ជារបស់មិនទៀងជាដើម ១ អំពីវេទនា ៣ មានផស្សៈជាមូល ១ ។

# រហោគតវគ្គោ

[៣៣] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯក-មន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិ-សល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ តិស្សោ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមា តិស្សោ វេទនា វុត្តា ភគ-វតា ។ វុត្តំ ខោ បនេតំ ភគវតា យំ កិញ្ចិ វេទយិតំ តំ ទុក្ខស្មិន្តិ កឹ នុ ខោ ឯតំ ភគវតា សន្ធាយ ភាសិតំ យំ កិញ្ចិ វេទយិតំ តំ ទុក្ខស្មិន្តិ ។ សាធុ សាធុ ភិក្ខុ

# រហោគតវគ្គ

[៣៣] គ្រានោះឯង ភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គសម្ងំនៅក្នុងទីស្ងាត់ឯណោះ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា វេទនា ៣ យ៉ាង គឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ វេទនា ៣ យ៉ាងនេះ ព្រះមានព្រះភាគទ្រង់សំដែងហើយ ។ ក៏ពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា អារម្មណ៍ឯណានីមួយដែលបុគ្គលបានសោយហើយ អារម្មណ៍នោះជាទុក្ខ ពាក្យនេះឯង ព្រះមានព្រះភាគទ្រង់សំដៅអ្វីហ្ន៎ ទើបទ្រង់សំដែងថា អារម្មណ៍ឯណានីមួយដែលបុគ្គលសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រពៃហើយ ៗ

៣១

## រហោគតវគ្គោ

តិស្សោ ឥមា ភិក្ខុ[១] វេទនា វុត្តា មយា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមា តិស្សោ វេទនា វុត្តា មយា ។ វុត្តំ ខោ បនេតំ ភិក្ខុ មយា យំ កិញ្ចិ វេទយិតំ តំ ទុក្ខស្មិន្តិ តំ ខោ បនេតំ ភិក្ខុ មយា សង្ខារានំយេវ អនិច្ចតំ សន្ធាយ ភាសិតំ យំ កិញ្ចិ វេទយិតំ តំ ទុក្ខស្មិន្តិ ។ តំ ខោ បនេតំ ភិក្ខុ មយា សង្ខារានំយេវ ខយធម្មតំ វយធម្មតំ វិរាគធម្មតំ និរោធធម្មតំ វិបរិណាមធម្មតំ សន្ធាយ ភាសិតំ យំ កិញ្ចិ វេទយិតំ តំ ទុក្ខស្មិន្តិ ។

---

១ ភិក្ខវេតិបិ ទិស្សតិ ។

រហោគតវគ្គ

ម្នាលភិក្ខុ វេទនា ៣ យ៉ាងនេះ គឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ តថាគតបានពោលហើយ វេទនា ៣ យ៉ាងនេះ តថាគតបានសំដែងហើយ ។ ម្នាលភិក្ខុ ក៏ពាក្យនេះតថាគតបានពោលទុកថា អារម្មណ៍ឯណានីមួយដែលបុគ្គលបានសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ ម្នាលភិក្ខុ ឯពាក្យនេះតថាគតសំដៅយកសេចក្ដីមិនទៀងនៃសង្ខារនោះឯង ទើបសំដែងថា អារម្មណ៍ឯណានីមួយដែលបុគ្គលបានសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ ។ ម្នាលភិក្ខុ មួយវិញទៀត ពាក្យនេះតថាគតសំដៅសេចក្ដីអស់ទៅជាធម្មតា សេចក្ដីសាបសូន្យទៅជាធម្មតា ការប្រាសចាកតម្រេកជាធម្មតា សេចក្ដីរលត់ជាធម្មតា សេចក្ដីប្រែប្រួលទៅជាធម្មតា នៃសង្ខារទាំងឡាយនោះឯង ទើបសំដែងថា អារម្មណ៍ឯណានីមួយដែលបុគ្គលបានសោយហើយ អារម្មណ៍នោះក៏ជាទុក្ខដូច្នេះ ។

[៣៤] អថខោ បន ភិក្ខុ មយា អនុបុព្វសង្ខារានំ និរោធោ អក្ខាតោ បឋមជ្ឈានំ សមាបន្នស្ស វាចា និរុទ្ធា ហោតិ ទុតិយជ្ឈានំ សមាបន្នស្ស វិតក្កវិចារា និរុទ្ធា ហោន្តិ តតិយជ្ឈានំ សមាបន្នស្ស បីតិ និរុទ្ធា ហោតិ ចតុត្ថជ្ឈានំ សមាបន្នស្ស អស្សាសបស្សាសា និរុទ្ធា ហោន្តិ អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញា និរុទ្ធា ហោតិ វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញា និរុទ្ធា ហោតិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញា និរុទ្ធា ហោតិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញា និរុទ្ធា ហោតិ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច និរុទ្ធា ហោន្តិ ។ ខីណាសវស្ស ភិក្ខុនោ រាគោ និរុទ្ធោ ហោតិ ទោសោ និរុទ្ធោ ហោតិ មោហោ និរុទ្ធោ ហោតិ ។

[៣៤] ម្នាលភិក្ខុ តាមដោយពិត ឯការរលត់នៃសង្ខារទាំង-ឡាយជាលំដាប់ តថាគតបានពោលហើយថា វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈាន តែងរលត់ វិតក្កនិងវិចារនៃបុគ្គលអ្នកចូលកាន់ទុតិយជ្ឈាន តែងរលត់ បីតិនៃបុគ្គលអ្នកចូលកាន់តតិយជ្ឈាន តែងរលត់ អស្សាស-បស្សាសៈនៃបុគ្គលអ្នកចូលកាន់ចតុត្ថជ្ឈាន តែងរលត់ រូបសញ្ញានៃបុគ្គលអ្នកចូលកាន់អាកាសានញ្ចាយតនជ្ឈាន តែងរលត់ អាកាសានញ្ចាយ-តនសញ្ញានៃបុគ្គលអ្នកចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន តែងរលត់ វិញ្ញាណញ្ចាយតនសញ្ញា នៃបុគ្គលអ្នកចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន តែងរលត់ អាកិញ្ចញ្ញាយតនសញ្ញា នៃបុគ្គលអ្នកចូលកាន់នេវសញ្ញានា-សញ្ញាយតនជ្ឈាន តែងរលត់ សញ្ញានិងវេទនានៃបុគ្គលអ្នកចូលកាន់សញ្ញាវេទយិតនិរោធតែងរលត់ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រព ក៏រលត់ ទោសៈក៏រលត់ មោហៈក៏រលត់ ។

### រហោគតវគ្គោ

[៣៥] អថខោ ភិក្ខុ មយា អនុបុព្វសង្ខារានំ
វូបសមោ អក្ខាតោ បឋមជ្ឈានំ សមាបន្នស្ស វាចា
វូបសន្តា ហោតិ ទុតិយជ្ឈានំ សមាបន្នស្ស វិតក្កវិចា-
រា វូបសន្តា ហោន្តិ ។ បេ ។ សញ្ញាវេទយិតនិរោធំ ស-
មាបន្នស្ស សញ្ញា ច វេទនា ច វូបសន្តា ហោន្តិ ។
ខីណាសវស្ស ភិក្ខុនោ រាគោ វូបសន្តោ ហោតិ ទោ-
សោ វូបសន្តោ ហោតិ មោហោ វូបសន្តោ ហោតិ ។

[៣៦] ឆយិមា ភិក្ខុ បស្សទ្ធិយោ បឋមជ្ឈានំ
សមាបន្នស្ស វាចា បដិប្បស្សទ្ធា ហោតិ ទុតិយជ្ឈានំ
សមាបន្នស្ស វិតក្កវិចារា បដិប្បស្សទ្ធា ហោន្តិ តតិ-
យជ្ឈានំ សមាបន្នស្ស បីតិ បដិប្បស្សទ្ធា ហោតិ ច-
តុត្ថជ្ឈានំ សមាបន្នស្ស អស្សាសបស្សាសា បដិប្បស្ស-
ទ្ធា ហោន្តិ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា
ច វេទនា ច បដិប្បស្សទ្ធា ហោន្តិ ។ ខីណាសវស្ស
ភិក្ខុនោ រាគោ បដិប្បស្សទ្ធោ ហោតិ ទោសោ ប-
ដិប្បស្សទ្ធោ ហោតិ មោហោ បដិប្បស្សទ្ធោ ហោតីតិ ។
បឋមំ ។

រហោគតវគ្គ

[៣៥] ម្នាលភិក្ខុ ការរម្ងាប់នៃសង្ខារទាំងឡាយជាលំដាប់ តថាគតបានពោលហើយថា វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈាន ក៏រម្ងាប់ វិតក្កនិងវិចារនៃបុគ្គលអ្នកចូលកាន់ទុតិយជ្ឈាន ក៏រម្ងាប់ ។ បេ ។ សញ្ញានិងវេទនានៃបុគ្គលអ្នកចូលកាន់សញ្ញាវេទយិតនិរោធ ក៏រម្ងាប់ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រពក៏រម្ងាប់ ទោសៈក៏រម្ងាប់ មោហៈក៏រម្ងាប់ ។

[៣៦] ម្នាលភិក្ខុ សេចក្ដីស្ងប់ទាំងឡាយនេះមាន ៦ យ៉ាង គឺ វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈាន ក៏ស្ងប់ វិតក្កៈនិងវិចារៈនៃបុគ្គលអ្នកចូលកាន់ទុតិយជ្ឈាន ក៏ស្ងប់ បីតិនៃបុគ្គលអ្នកចូលកាន់តតិយជ្ឈាន ក៏ស្ងប់ អស្សាសបស្សាសៈនៃបុគ្គលអ្នកចូលកាន់ចតុត្ថជ្ឈាន ក៏ស្ងប់ សញ្ញានិងវេទនានៃបុគ្គលអ្នកចូលកាន់សញ្ញាវេទយិតនិរោធ ក៏ស្ងប់ ។ រាគៈនៃភិក្ខុជាព្រះខីណាស្រពក៏ស្ងប់ ទោសៈក៏ស្ងប់ មោហៈក៏ស្ងប់ ។ ចប់សូត្រទី ១ ។

[៣៧] សេយ្យថាបិ ភិក្ខវេ អាកាសេបិ វិវិធា វាតា វាយន្តិ បុរត្ថិមាបិ វាតា វាយន្តិ បច្ឆិមាបិ វាតា វាយន្តិ ឧត្តរាបិ វាតា វាយន្តិ ទក្ខិណាបិ វាតា វាយន្តិ សរជាបិ វាតា វាយន្តិ អរជាបិ វាតា វាយន្តិ សីតាបិ វាតា វាយន្តិ ឧណ្ហាបិ វាតា វាយន្តិ បរិត្តាបិ វាតា វាយន្តិ អធិមត្តាបិ វាតា វាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ កាយស្មឹ វិវិធា វេទនា ឧប្បជ្ជន្តិ សុខាបិ វេទនា ឧប្បជ្ជតិ[១] ទុក្ខាបិ វេទនា ឧប្បជ្ជតិ អទុក្ខមសុខាបិ វេទនា ឧប្បជ្ជតីតិ ។

---

១ ឱ. ឧប្បជ្ជន្តិ ។

[៣៧] ម្នាលភិក្ខុទាំងឡាយ ដូចខ្យល់ទាំងឡាយមានចំណែកផ្សេងៗ តែងបក់ទៅក្នុងអាកាស គឺខ្យល់បក់ទៅទិសខាងកើតក្តី ខ្យល់បក់ទៅទិសខាងលិចក្តី ខ្យល់បក់ទៅទិសខាងជើងក្តី ខ្យល់បក់ទៅទិសខាងត្បូងក្តី ខ្យល់ប្រកបដោយធូលីបក់ទៅក្តី ខ្យល់មិនមានធូលីបក់ទៅក្តី ខ្យល់ត្រជាក់បក់ទៅក្តី ខ្យល់ក្តៅបក់ទៅក្តី ខ្យល់តិចបក់ទៅក្តី ខ្យល់ខ្លាំងបក់ទៅក្តី មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ វេទនាទាំងឡាយមានចំណែកផ្សេងៗ រមែងកើតឡើងក្នុងកាយនេះ គឺសុខវេទនាក្តី ក៏កើតឡើង ទុក្ខវេទនាក្តី ក៏កើតឡើង អទុក្ខមសុខវេទនាក្តី ក៏កើតឡើង ។

៣៤

រហោគតវគ្គោ

[៣៨] យថាបិ វាតា អាកាសេ

វាយន្តិ វិវិធា បុថូ

បុរត្ថិមា បច្ឆិមា ចាបិ

ឧត្តរា អថ ទក្ខិណា ។

សរជា អរជា ចាបិ

សីតា ឧណ្ហា ច ឯកទា

អធិមត្តា បរិត្តា ច

បុថូ វាយន្តិ មាលុតា ។

តថេវិមស្មឹ កាយស្មឹ

សមុប្បជ្ជន្តិ វេទនា

សុខទុក្ខសមុប្បត្តិ

អទុក្ខមសុខា ច យា ។

យតោ ច ភិក្ខុ អាតាបី

សម្បជានោ និរុជ្ឈតិ

រហោគតវគ្គ

[៣៨] ដូចខ្យល់ទាំងឡាយច្រើនយ៉ាង មានចំណែកផ្សេង ៗ តែងបក់ទៅក្នុងអាកាស គឺបក់ទៅក្នុងទិសខាងកើតក្ដី បក់ទៅក្នុងទិសខាងលិចក្ដី មួយវិញទៀត បក់ទៅក្នុងទិសខាងជើងក្ដី បក់ទៅក្នុងទិសខាងត្បូងក្ដី ។ ខ្យល់ទាំងឡាយជាច្រើនយ៉ាងគឺ ខ្យល់មានធូលីក្ដី មិនមានធូលីក្ដី ត្រជាក់ក្ដី ក្ដៅក្ដី ខ្លាំងក្ដី តិចក្ដី តែងបក់ទៅ ។ សុខវេទនាក្ដី ទុក្ខវេទនាក្ដី អទុក្ខមសុខវេទនាក្ដី ដែលប្រជុំកើតឡើងក្នុងកាយនេះ ក៏ដូច្នោះដែរ ។ ភិក្ខុមានព្យាយាមដុតកម្ដៅកិលេសឲ្យក្ដៅ ជាអ្នកដឹងខ្លួន តែងរលត់ទៅក្នុងកាលណា

តតោ សោ វេទនា សព្វា
បរិជានាតិ បណ្ឌិតោ ។
សោ វេទនា បរិញ្ញាយ
ទិដ្ឋេ ធម្មេ អនាសវោ
កាយស្ស ភេទា ធម្មដ្ឋោ
សង្ខ្យំ នោបេតិ វេទគូតិ ។ ទុតិយំ ។

[៣៩] សេយ្យថាបិ ភិក្ខវេ អាកាសេ វិវិធា វាតា វាយន្តិ បុរត្ថិមាបិ វាតា វាយន្តិ ។ បេ ។ អធិមត្តាបិ វាតា វាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ កាយស្មឹ វិវិធា វេទនា ឧប្បជ្ជន្តិ សុខាបិ វេទនា ឧប្បជ្ជតិ ទុក្ខាបិ វេទនា ឧប្បជ្ជតិ អទុក្ខមសុខាបិ វេទនា ឧប្បជ្ជតីតិ ។ តតិយំ ។

ភិក្ខុជាបណ្ឌិតនោះ តែងកំណត់ដឹងច្បាស់នូវវេទនាទាំងអស់ក្នុងកាលនោះ ។ ភិក្ខុនោះកំណត់ដឹងនូវវេទនាក្នុងបច្ចុប្បន្នហើយ ជាអ្នកមិនមានអាសវៈ តាំងនៅក្នុងធម៌ ជាអ្នកដល់នូវវេទ លុះទម្លាយរាងកាយទៅ មិនគួររាប់ថា (ជាអ្នកមានភព) ។ ចប់សូត្រទី ២ ។

[៣៩] ម្នាលភិក្ខុទាំងឡាយ ដូចខ្យល់ទាំងឡាយមានចំណែកផ្សេងៗ បក់ទៅក្នុងអាកាស គឺខ្យល់បក់ទៅទិសខាងកើតក្តី ។ បេ ។ ខ្យល់ខ្លាំងបក់ទៅក្តី មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ វេទនាមានចំណែកផ្សេងៗ រមែងកើតឡើងក្នុងកាយនេះ គឺសុខវេទនាក្តី ក៏កើតឡើង ទុក្ខវេទនាក្តី ក៏កើតឡើង អទុក្ខមសុខវេទនាក្តី ក៏កើតឡើង ។ ចប់សូត្រទី ៣ ។

## រហោគតវគ្គោ

[៤០] សេយ្យថាបិ ភិក្ខវេ អាគន្តុកាគារំ តត្ថ បុរត្ថិមាយបិ ទិសាយ អាគន្ត្វា វាសំ កប្បេន្តិ បច្ឆិមាយបិ ទិសាយ អាគន្ត្វា វាសំ កប្បេន្តិ ឧត្តរាយបិ ទិសាយ អាគន្ត្វា វាសំ កប្បេន្តិ ទក្ខិណាយបិ ទិសាយ អាគន្ត្វា វាសំ កប្បេន្តិ ខត្តិយាបិ អាគន្ត្វា វាសំ កប្បេន្តិ ព្រាហ្មណាបិ អាគន្ត្វា វាសំ កប្បេន្តិ វេស្សាបិ អាគន្ត្វា វាសំ កប្បេន្តិ សុទ្ទាបិ អាគន្ត្វា វាសំ កប្បេន្តិ ។ ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ កាយស្មឹ វិធា វេទនា ឧប្បជ្ជន្តិ សុខាបិ វេទនា ឧប្បជ្ជតិ ទុក្ខាបិ វេទនា ឧប្បជ្ជតិ អទុក្ខមសុខាបិ វេទនា ឧប្បជ្ជតិ សាមិសាបិ សុខា វេទនា ឧប្បជ្ជតិ សាមិសាបិ ទុក្ខា វេទនា ឧប្បជ្ជតិ សាមិសាបិ អទុក្ខមសុខា វេទនា ឧប្បជ្ជតិ និរាមិសាបិ សុខា វេទនា ឧប្បជ្ជតិ និរាមិសាបិ ទុក្ខា វេទនា ឧប្បជ្ជតិ និរាមិសាបិ អទុក្ខមសុខា វេទនា ឧប្បជ្ជតីតិ ។ ចតុត្ថំ ។

រហោគតវគ្គ

[៤០] ម្នាលភិក្ខុទាំងឡាយ ដូចផ្ទះសំណាក់នៃជនជាអាគន្តុកៈ ក្នុងផ្ទះសំណាក់នោះ មានពួកជនមកអំពីទិសខាងកើតចូលមកអាស្រ័យនៅក៏មាន មកអំពីទិសខាងលិចចូលមកអាស្រ័យនៅក៏មាន មកអំពីទិសខាងជើងចូលមកអាស្រ័យនៅក៏មាន មកអំពីទិសខាងត្បូងចូលមកអាស្រ័យនៅក៏មាន មានពួកក្សត្រិយ៍ចូលមកអាស្រ័យនៅក៏មាន មានពួកព្រាហ្មណ៍ចូលមកអាស្រ័យនៅក៏មាន មានពួកវេស្សៈចូលមកអាស្រ័យនៅក៏មាន មានពួកសុទ្ទៈចូលមកអាស្រ័យនៅក៏មាន មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ វេទនាមានបំណែកផ្សេងៗ តែងកើតឡើងក្នុងកាយនេះ គឺសុខវេទនាក្តី តែងកើតឡើង ទុក្ខវេទនាក្តី តែងកើតឡើង អទុក្ខមសុខវេទនាក្តី តែងកើតឡើង សុខវេទនាប្រកបដោយអាមិសក្តី តែងកើតឡើង ទុក្ខវេទនាប្រកបដោយអាមិសក្តី តែងកើតឡើង អទុក្ខមសុខវេទនាប្រកបដោយអាមិសក្តី តែងកើតឡើង សុខវេទនាមិនប្រកបដោយអាមិសក្តី តែងកើតឡើង ទុក្ខវេទនាមិនប្រកបដោយអាមិសក្តី តែងកើតឡើង អទុក្ខមសុខវេទនាមិនប្រកបដោយអាមិសក្តី តែងកើតឡើង ។ ចប់សូត្រទី ៤ ។

៣៨



[៤១] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កតមា នុ ខោ ភន្តេ វេទនា កតមោ វេទនាសមុទយោ កតមោ វេទនានិរោធោ កតមា វេទនានិរោធគាមិនី បដិបទា កោ វេទនាយ អស្សាទោ កោ វេទនាយ អាទីនវោ កឹ វេទនាយ និស្សរណន្តិ ។ តិស្សោ ឥមា អានន្ទ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា វុច្ចន្តិ អានន្ទ វេទនា ។ ផស្សសមុទយា វេទនាសមុទយោ ផស្សនិរោធា វេទនានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ វេទនានិរោធគាមិនី បដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យំ វេទនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វេទនាយ អស្សាទោ ។ យា វេទនា អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ វេទនាយ អាទីនវោ ។ យោ វេទនាយ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វេទនាយ និស្សរណំ ។

[៤១] គ្រានោះឯង ព្រះអានន្ទមានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វេទនាដូចម្តេច ហេតុជាទីកើតនៃវេទនាដូចម្តេច ការរលត់ទៅនៃវេទនាដូចម្តេច បដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនាដូចម្តេច អានិសង្សនៃវេទនាដូចម្តេច ទោសនៃវេទនាដូចម្តេច ការរលាស់ចេញនូវវេទនា តើដូចម្តេច ។ ម្នាលអានន្ទ វេទនានេះ មាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខ-វេទនា ១ ។ ម្នាលអានន្ទ នេះហៅថាវេទនា ។ ការកើតឡើងនៃវេទនាព្រោះកើតឡើងនៃផស្សៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃផស្សៈ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯងជាបដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនា ។ អដ្ឋង្គិកមគ្គដ៏ប្រសើរ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ សេចក្តីសុខនិងសោមនស្សកើតឡើងព្រោះអាស្រ័យវេទនាឯណា នេះជាអានិសង្សនៃវេទនា ។ វេទនាឯណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសនៃវេទនា ។ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគក្នុងវេទនាឯណា នេះជាគ្រឿងរលាស់ចេញនូវវេទនា ។

៣៩

## រហោគតវគ្គោ

[៤២] អថខោ បនានន្ទ មយា អនុបុព្វសង្ខារានំ និរោធោ អក្ខាតោ បឋមជ្ឈានំ សមាបន្នស្ស វាចា និរុទ្ធា ហោតិ ។ បេ ។ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច និរុទ្ធា ហោន្តិ ។ ខីណាសវស្ស ភិក្ខុនោ រាគោ និរុទ្ធោ ហោតិ ទោសោ និរុទ្ធោ ហោតិ មោហោ និរុទ្ធោ ហោតិ ។

[៤៣] អថខោ បនានន្ទ មយា អនុបុព្វសង្ខារានំ វូបសមោ អក្ខាតោ បឋមជ្ឈានំ សមាបន្នស្ស វាចា វូបសន្តា ហោតិ ។ បេ ។ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច វូបសន្តា ហោន្តិ ។ ខីណាសវស្ស ភិក្ខុនោ រាគោ វូបសន្តោ ហោតិ ទោសោ វូបសន្តោ ហោតិ មោហោ វូបសន្តោ ហោតិ ។

[៤៤] អថខោ បនានន្ទ មយា អនុបុព្វសង្ខារានំ បដិប្បស្សទ្ធិ អក្ខាតា បឋមជ្ឈានំ សមាបន្នស្ស វាចា បដិប្បស្សទ្ធា ហោតិ ។ បេ ។ អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញា បដិប្បស្សទ្ធា ហោតិ

រហោគតវគ្គ

[៤២] ម្នាលអានន្ទ ការរលត់នៃសង្ខារទាំងឡាយជាលំដាប់ តថាគតបានពោលហើយថា វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈាន តែងរលត់ ។ បេ ។ សញ្ញានិងវេទនានៃបុគ្គលអ្នកចូលកាន់សញ្ញាវេទយិតនិរោធក៏រលត់ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រពក៏រលត់ ទោសៈក៏រលត់ មោហៈក៏រលត់ ។

[៤៣] ម្នាលអានន្ទ ចំណែកឯការរម្ងាប់នៃសង្ខារទាំងឡាយជាលំដាប់ តថាគតបានពោលហើយថា វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈានក៏រម្ងាប់ ។ បេ ។ សញ្ញានិងវេទនានៃបុគ្គលអ្នកចូលកាន់សញ្ញាវេទយិតនិរោធក៏រម្ងាប់ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រពក៏រម្ងាប់ ទោសៈក៏រម្ងាប់ មោហៈក៏រម្ងាប់ ។

[៤៤] ម្នាលអានន្ទ ក៏ឯការស្ងប់នៃសង្ខារទាំងឡាយជាលំដាប់ តថាគតបានពោលហើយថា វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈានក៏ស្ងប់ ។ បេ ។ រូបសញ្ញានៃបុគ្គលអ្នកចូលកាន់អាកាសានញ្ចាយតនជ្ឈានក៏ស្ងប់

វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញា បដិប្បស្សទ្ធា ហោតិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញា បដិប្បស្សទ្ធា ហោតិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញា បដិប្បស្សទ្ធា ហោតិ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច បដិប្បស្សទ្ធា ហោន្តិ ។ ខីណាសវស្ស ភិក្ខុនោ រាគោ បដិប្បស្សទ្ធោ ហោតិ ទោសោ បដិប្បស្សទ្ធោ ហោតិ មោហោ បដិប្បស្សទ្ធោ ហោតីតិ ។ បញ្ចមំ ។

[៤៨] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច កតមា នុ ខោ អានន្ទ វេទនា កតមោ វេទនាសមុទយោ កតមោ វេទនានិរោធោ កតមា វេទនានិរោធគាមិនី បដិបទា កោ វេទនាយ អស្សាទោ កោ វេទនាយ អាទីនវោ

អាកាសានញ្ចាយតនសញ្ញានៃបុគ្គលអ្នកចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ក៏ស្ងប់ វិញ្ញាណញ្ចាយតនសញ្ញានៃបុគ្គលអ្នកចូលកាន់អាកិញ្ចញ្ញាយតនជ្ឈានក៏ស្ងប់ អាកិញ្ចញ្ញាយតនសញ្ញានៃបុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈានក៏ស្ងប់ សញ្ញានិងវេទនានៃបុគ្គលអ្នកចូលកាន់សញ្ញាវេទយិតនិរោធក៏ស្ងប់ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រពក៏ស្ងប់ ទោសៈក៏ស្ងប់ មោហៈក៏ស្ងប់ ។ ចប់សូត្រទី ៥ ។

[៤៥] គ្រានោះឯង ព្រះអានន្ទមានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ វេទនាដូចម្តេច ហេតុជាទីកើតឡើងនៃវេទនាដូចម្តេច សេចក្តីរលត់ទៅនៃវេទនាដូចម្តេច បដិបទាជាហេតុឲ្យបានដល់នូវសេចក្តីរលត់ទៅនៃវេទនាដូចម្តេច អានិសង្សនៃវេទនាដូចម្តេច ទោសនៃវេទនាដូចម្តេច

កឹ វេទនាយ និស្សរណន្តិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ ភន្តេ ភគវន្តញ្ញេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ អានន្ទ សុណោហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច តិស្សោ ឥមា អានន្ទ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា វុច្ចន្តិ អានន្ទ វេទនា ។ បេ ។ ផស្សសមុទយា ។ បេ ។ ខីណាសវស្ស ភិក្ខុនោ រាគោ បដិប្បស្សទ្ធោ ហោតិ ទោសោ បដិប្បស្សទ្ធោ ហោតិ មោហោ បដិប្បស្សទ្ធោ ហោតីតិ ។ ឆដ្ឋំ ។

[៤៦] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ

ការរលាស់ចេញនូវវេទនាដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំង-ឡាយនៃយើងខ្ញុំព្រះអង្គ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគបំភ្លឺនូវសេចក្តីនៃភាសិតនុ៎ះ ពួកភិក្ខុបានស្តាប់នូវភាសិតរបស់ព្រះមានព្រះភាគហើយ នឹងចាំទុក ។ ម្នាលអានន្ទ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសំដែងឥឡូវនេះ ។ ព្រះអានន្ទមានអាយុទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ វេទនានេះមាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលអានន្ទ នេះហៅថាវេទនា ។ បេ ។ ព្រោះកើតឡើងនៃផស្សៈ ។ បេ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រពក៏ស្ងប់រម្ងាប់ ទោសៈក៏ស្ងប់រម្ងាប់ មោហៈក៏ស្ងប់រម្ងាប់ ។ ចប់សូត្រទី ៦ ។

[៤៦] គ្រានោះឯង ពួកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ

## ៤២



ភគវន្តំ ឯតទវោចុំ កតមា នុ ខោ ភន្តេ វេទនា កតមោ វេទនាសមុទយោ កតមោ វេទនានិរោធោ កតមា វេទនានិរោធគាមិនី បដិបទា កោ វេទនាយ អស្សាទោ កោ វេទនាយ អាទីនវោ កឹ វេទនាយ និស្សរណន្តិ ។ តិស្សោ ឥមា ភិក្ខវេ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា វុច្ចន្តិ ភិក្ខវេ វេទនា ។ ផស្សសមុទយា វេទនាសមុទយោ ផស្សនិរោធា វេទនានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ វេទនានិរោធគាមិនី បដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យំ វេទនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វេទនាយ អស្សាទោ ។ យា វេទនា អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ វេទនាយ អាទីនវោ ។ យោ វេទនាយ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វេទនាយ និស្សរណំ ។

បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វេទនាដូចម្តេច ហេតុជាទីកើតឡើងនៃវេទនាដូចម្តេច ការរលត់ទៅនៃវេទនាដូចម្តេច បដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនាដូចម្តេច អានិសង្សនៃវេទនាដូចម្តេច ទោសនៃវេទនាដូចម្តេច ការរលាស់ចេញនូវវេទនាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង គឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនា ។ ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃផស្សៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃផស្សៈ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ជាបដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនា ។ អដ្ឋង្គិកមគ្គនោះគឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ សេចក្តីសុខនិងសោមនស្សកើតឡើង ព្រោះអាស្រ័យវេទនាឯណា នេះជាអានិសង្សនៃវេទនា ។ វេទនាឯណាដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសនៃវេទនា ។ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ក្នុងវេទនាឯណា នេះជាការរលាស់ចេញនូវវេទនា ។

៤៣

## រហោគតវគ្គោ

[៤៧] អថខោ បន ភិក្ខវេ មយា អនុបុព្វសង្ខារានំ និរោធោ អក្ខាតោ បឋមជ្ឈានំ សមាបន្នស្ស វាចា និរុទ្ធា ហោតិ ។ បេ ។ ខីណាសវស្ស ភិក្ខុនោ រាគោ និរុទ្ធោ ហោតិ ទោសោ និរុទ្ធោ ហោតិ មោហោ និរុទ្ធោ ហោតិ ។

[៤៨] អថខោ បន ភិក្ខវេ មយា អនុបុព្វសង្ខារានំ វូបសមោ អក្ខាតោ បឋមជ្ឈានំ សមាបន្នស្ស វាចា វូបសន្តា ហោតិ ។ បេ ។ ខីណាសវស្ស ភិក្ខុនោ រាគោ វូបសន្តោ ហោតិ ទោសោ វូបសន្តោ ហោតិ មោហោ វូបសន្តោ ហោតិ ។

[៤៩] ឆយិមា ភិក្ខវេ បស្សទ្ធិយោ បឋមជ្ឈានំ សមាបន្នស្ស វាចា បដិប្បស្សទ្ធា ហោតិ ទុតិយជ្ឈានំ សមាបន្នស្ស វិតក្កវិចារា បដិប្បស្សទ្ធា ហោន្តិ តតិ-យជ្ឈានំ សមាបន្នស្ស បីតិ បដិប្បស្សទ្ធា ហោតិ

រហោគតវគ្គ

[៤៧] ម្នាលភិក្ខុទាំងឡាយ ការរលត់នៃសង្ខារទាំងឡាយជាលំដាប់ តថាគតបានពោលហើយថា វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈានក៏រលត់ ។ បេ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រពក៏រលត់ ទោសៈក៏រលត់ មោហៈក៏រលត់ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ សេចក្ដីរម្ងាប់នៃសង្ខារទាំងឡាយជាលំដាប់ តថាគតបានពោលហើយថា វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈានក៏រលត់ ។ បេ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រពក៏រម្ងាប់ ទោសៈក៏រម្ងាប់ មោហៈក៏រម្ងាប់ ។

[៤៩] ម្នាលភិក្ខុទាំងឡាយ ការស្ងប់នេះមាន ៦ យ៉ាង គឺ វាចានៃបុគ្គលអ្នកចូលកាន់បឋមជ្ឈានក៏ស្ងប់ វិតក្កនិងវិចារនៃបុគ្គលអ្នកចូលកាន់ទុតិយជ្ឈានក៏ស្ងប់ បីតិនៃបុគ្គលអ្នកចូលកាន់តតិយជ្ឈានក៏ស្ងប់

ចតុត្ថជ្ឈានំ សមាបន្នស្ស អស្សាសបស្សាសា បដិប្ប-ស្សទ្ធា ហោន្តិ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច បដិប្បស្សទ្ធា ហោន្តិ ។ ខីណា-សវស្ស ភិក្ខុនោ រាគោ បដិប្បស្សទ្ធោ ហោតិ ទោ-សោ បដិប្បស្សទ្ធោ ហោតិ មោហោ បដិប្បស្សទ្ធោ ហោតីតិ ។ សត្តមំ ។

[៥០] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ។ បេ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវា ឯតទវោច កតមា នុ ខោ ភិក្ខវេ វេទនា កតមោ វេទនាសមុទយោ កតមោ វេទនានិរោធោ កតមា វេទនានិរោធគាមិនី បដិបទា កោ វេទនាយ អស្សាទោ កោ វេទនាយ អាទីនវោ កឹ វេទនាយ និស្សរណន្តិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ តិស្សោ ឥមា ភិក្ខវេ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា វុច្ចន្តិ ភិក្ខវេ វេទនា ។ ផស្សសមុទយា (យថា បុរិមសុត្តន្តោ វិត្ថារិតោ តថា វិត្ថារេតព្វោ) ។ អដ្ឋមំ ។

អស្សាសបស្សាសៈនៃបុគ្គលអ្នកចូលកាន់ចតុត្ថជ្ឈានក៏ស្ងប់ សញ្ញានិង វេទនានៃបុគ្គលអ្នកចូលកាន់សញ្ញាវេទយិតនិរោធក៏ស្ងប់ ។ រាគៈរបស់ភិក្ខុជាព្រះខីណាស្រពក៏ស្ងប់ ទោសៈក៏ស្ងប់ មោហៈក៏ស្ងប់ ។ ចប់សូត្រទី ៧ ។

[៥០] គ្រានោះឯង ពួកភិក្ខុច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វេទនាតើដូចម្ដេច ហេតុជាទីកើតឡើងនៃវេទនាដូចម្ដេច សេចក្ដីរលត់ទៅនៃវេទនាដូចម្ដេច បដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនាដូចម្ដេច អានិសង្សនៃវេទនាដូចម្ដេច ទោសនៃវេទនាដូចម្ដេច ការរលាស់ចេញនូវវេទនាដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយនៃយើងខ្ញុំព្រះអង្គ មានព្រះមានព្រះភាគជាមូល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខ-វេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាវេទនា ។ ព្រោះកើតឡើងនៃផស្សៈ (បណ្ឌិតគប្បីសំដែងឲ្យពិស្ដារដូចសូត្រមុន ៗ ផងចុះ) ។ ចប់សូត្រទី ៨ ។

## រហោគតវគ្គោ

[៤១] អថខោ បញ្ចកង្គោ ថបតិ យេនាយស្មា ឧទាយិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បញ្ចកង្គោ ថបតិ អាយស្មន្តំ ឧទាយឹ ឯតទវោច កតិ នុ ខោ ភន្តេ ឧទាយិ វេទនា វុត្តា ភគវតាតិ ។ តិស្សោ ខោ គហបតិ[១] វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមា ខោ គហបតិ តិស្សោ វេទនា វុត្តា ភគវតាតិ ។

[៤២] ឯវំ វុត្តេ បញ្ចកង្គោ ថបតិ អាយស្មន្តំ ឧទាយឹ ឯតទវោច ន ខោ ភន្តេ ឧទាយិ តិស្សោ វេទនា វុត្តា ភគវតា ទ្វេ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា យាយំ ភន្តេ អទុក្ខមសុខា វេទនា សន្តស្មឹ ឯសា បណីតេ សុខេ វុត្តា ភគវតាតិ ។

១ ឱ. ម. ថបតិ ។

រហោគតវគ្គ

[៥១] គ្រានោះឯង ជាងឈើឈ្មោះបញ្ចកង្គៈ ចូលទៅរកព្រះឧទាយិមានអាយុ លុះចូលទៅដល់ ថ្វាយបង្គំព្រះឧទាយិមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះជាងឈើឈ្មោះបញ្ចកង្គៈអង្គុយក្នុងទីសមគួរហើយ បានពោលនឹងព្រះឧទាយិមានអាយុដូច្នេះថា បពិត្រព្រះឧទាយិដ៏ចម្រើន វេទនាដែលព្រះមានព្រះភាគទ្រង់សំដែងហើយមានប៉ុន្មាន ។ ម្នាលគហបតី វេទនាដែលព្រះមានព្រះភាគទ្រង់សំដែងហើយមាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ម្នាលគហបតី វេទនាមាន ៣ យ៉ាងនេះឯង ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ។

[៥២] កាលព្រះឧទាយិពោលយ៉ាងនេះហើយ ជាងឈើឈ្មោះបញ្ចកង្គៈ បានពោលទៅនឹងព្រះឧទាយិមានអាយុដូច្នេះថា បពិត្រព្រះឧទាយិដ៏ចម្រើន វេទនា ៣ យ៉ាង ព្រះមានព្រះភាគ មិនបានទ្រង់សំដែងទេ វេទនា ២ យ៉ាង ដែលព្រះមានព្រះភាគទ្រង់សំដែងហើយគឺ សុខវេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេ-ទនា ព្រះមានព្រះភាគទ្រង់សំដែងហើយក្នុងសេចក្ដីសុខដ៏ល្អិតឧត្តម ។

៤៦



ទុតិយម្បិ ខោ អាយស្មា ឧទាយិ បញ្ចកង្គំ ថបតឹ ឯតទវោច ន ខោ គហបតិ ទ្វេ វេទនា វុត្តា ភគវតា តិស្សោ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមា តិស្សោ វេទនា វុត្តា ភគវតាតិ ។ ទុតិយម្បិ ខោ បញ្ចកង្គោ ថបតិ អាយស្មន្តំ ឧទាយឹ ឯតទវោច ន ខោ ភន្តេ ឧទាយិ តិស្សោ វេទនា វុត្តា ភគវតា ទ្វេ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា យាយំ ភន្តេ អទុក្ខមសុខា វេទនា សន្តស្មឹ ឯសា បណីតេ សុខេ វុត្តា ភគវតាតិ ។ តតិយម្បិ ខោ អាយស្មា ឧទាយិ បញ្ចកង្គំ ថបតឹ ឯតទវោច ន ខោ គហបតិ ទ្វេ វេទនា វុត្តា ភគវតា តិស្សោ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា

ព្រះឧទាយិមានអាយុ បានពោលនឹងជាងឈើឈ្មោះបញ្ចកង្គៈជាគម្រប់ពីរដងដូច្នេះថា ម្នាលគហបតី វេទនា ២ យ៉ាង ព្រះមានព្រះភាគមិនទ្រង់សំដែងទេ វេទនា ៣ យ៉ាងទេតើ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ គឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ វេទនាទាំង ៣ នេះឯង ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ។ ជាងឈើឈ្មោះបញ្ចកង្គៈ បាននិយាយនឹងព្រះឧទាយិមានអាយុជាគម្រប់ពីរដងទៀតដូច្នេះថា បពិត្រព្រះឧទាយិដ៏ចម្រើនវេទនា ៣ យ៉ាង ព្រះដ៏មានព្រះភាគមិនទ្រង់សំដែងទេ វេទនាតែ ២ យ៉ាង ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ គឺ សុខវេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេទនា ព្រះមានព្រះភាគទ្រង់សំដែងហើយក្នុងសេចក្តីសុខដ៏ល្អិតឧត្តម ។ ព្រះឧទាយិមានអាយុ បានពោលនឹងជាងឈើឈ្មោះបញ្ចកង្គៈជាគម្រប់ ៣ ដងទៀតដូច្នេះថា ម្នាលគហបតី វេទនា ២ យ៉ាង ព្រះមានព្រះភាគមិនទ្រង់សំដែងទេ វេទនា ៣ យ៉ាងទេតើ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ គឺ សុខវេទនា ១ ទុក្ខវេទនា ១

អទុក្ខមសុខា វេទនា ឥមា តិស្សោ វេទនា វុត្តា ភគវ-
តាតិ ។ តតិយម្បិ ខោ បញ្ចកង្គោ ថបតិ អាយស្មន្តំ
ឧទាយឹ ឯតទវោច ន ខោ ភន្តេ ឧទាយិ តិស្សោ
វេទនា វុត្តា ភគវតា ទ្វេ វេទនា វុត្តា ភគវតា សុខា
វេទនា ទុក្ខា វេទនា យាយំ ភន្តេ អទុក្ខមសុខា វេទនា
សន្តស្មឹ ឯសា បណីតេ សុខេ វុត្តា ភគវតាតិ ។
នេវ អសក្ខិ អាយស្មា ឧទាយិ បញ្ចកង្គំ ថបតឹ
សញ្ញាបេតុំ ន បនាសក្ខិ បញ្ចកង្គោ ថបតិ អាយស្មន្តំ
ឧទាយឹ សញ្ញាបេតុំ ។

[៤៣] អស្សោសិ ខោ អាយស្មា អានន្ទោ អា-
យស្មតោ ឧទាយិស្ស បញ្ចកង្គេន ថបតិនា សទ្ធឹ
ឥមំ កថាសល្លាបំ ។ អថខោ អាយស្មា អានន្ទោ
យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ
យាវតកោ អាយស្មតោ ឧទាយិស្ស បញ្ចកង្គេន ថប-
តិនា សទ្ធឹ អហោសិ កថាសល្លាបោ តម្បិ សព្វំ ភគ-

អទុក្ខមសុខវេទនា ១ វេទនា ៣ យ៉ាងនេះឯង ព្រះមានព្រះភាគទ្រង់សំដែងហើយ ។ ជាងឈើឈ្មោះបញ្ចកង្គៈបាននិយាយនឹងព្រះឧទាយិមានអាយុជាគម្រប់ ៣ ដងទៀតដូច្នេះថា បពិត្រព្រះឧទាយិដ៏ចម្រើន វេទ-នា ៣ យ៉ាង ព្រះមានព្រះភាគមិនទ្រង់សំដែងទេ វេទនាតែ ២ យ៉ាង ដែលព្រះមានព្រះភាគទ្រង់សំដែងហើយគឺ សុខវេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេទនា ព្រះមានព្រះភាគទ្រង់សំ-ដែលហើយក្នុងសេចក្តីសុខដ៏ល្អិតឧត្តម ។ ព្រះឧទាយិមានអាយុក៏មិនអាចពន្យល់ជាងឈើឈ្មោះបញ្ចកង្គៈ ឲ្យយល់ព្រមបានឡើយ ចំណែកឯជាងឈើឈ្មោះបញ្ចកង្គៈ ក៏មិនអាចពន្យល់ព្រះឧទាយិមានអាយុឲ្យយល់ព្រមបានដែរ ។

[៥៣] ព្រះអានន្ទមានអាយុ បានស្តាប់ពាក្យចរចានៃព្រះឧទាយិមានអាយុនេះ ជាមួយនឹងជាងឈើឈ្មោះបញ្ចកង្គៈ ។ លំដាប់នោះឯងព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល ពាក្យចរចារបស់ព្រះឧទាយិដ៏មានអាយុ ជាមួយនឹងជាងឈើឈ្មោះបញ្ចកង្គៈ ត្រាតែសព្វគ្រប់ចំពោះព្រះ

វតោ អារោចេសិ ។ សន្តមេវ ខោ អានន្ទ បរិយាយំ បញ្ចកង្គោ ថបតិ ឧទាយិស្ស ភិក្ខុនោ នាព្ភនុមោទិ ។ សន្តំ ច បនានន្ទ បរិយាយំ ឧទាយិ ភិក្ខុ បញ្ចកង្គស្ស ថបតិនោ នាព្ភនុមោទិ ។

[៥៤] ទ្វេបិ មយា អានន្ទ វេទនា វុត្តា បរិយាយេ-ន តិស្សោបិ មយា វេទនា វុត្តា បរិយាយេន បញ្ច-បិ មយា វេទនា វុត្តា បរិយាយេន ឆបិ មយា វេទនា វុត្តា បរិយាយេន អដ្ឋារសាបិ មយា វេទនា វុត្តា បរិយាយេន ឆត្តឹសាបិ មយា វេទនា វុត្តា បរិយាយេន អដ្ឋសតំបិ មយា វេទនា វុត្តា បរិយា-យេន ។ ឯវំ បរិយាយេន ទេសិតោ អានន្ទ មយា ធម្មោ ។ ឯវំ បរិយាយេន ទេសិតេ ខោ អានន្ទ ម-យា ធម្មេ យេ អញ្ញមញ្ញស្ស សុភាសិតំ សុលបិតំ ន សមនុមញ្ញិស្សន្តិ ន សមនុជានិស្សន្តិ ន សមនុ-មោទិស្សន្តិ ។ តេសំ ឯតំ បាដិកង្ខំ ភណ្ឌនជាតា

ដ៏មានព្រះភាគ ។ ម្នាលអានន្ទ ជាងឈើឈ្មោះបញ្ចកង្គៈមិនបាន ទទួលអនុមោទនានូវបរិយាយដែលពិតរបស់ឧទាយិភិក្ខុ ។ ម្នាលអានន្ទ ឯឧទាយិភិក្ខុ ក៏មិនបានទទួលអនុមោទនា នូវបរិយាយដែលពិតរបស់ជាង ឈើឈ្មោះបញ្ចកង្គៈដែរ ។

[៥២] ម្នាលអានន្ទ វេទនាទាំង ២ ក្តី ក៏តថាគតសំដែងហើយ ដោយបរិយាយ វេទនាទាំង ៣ ក្តី ក៏តថាគតសំដែងហើយដោយបរិ- យាយ វេទនាទាំង ៥ ក្តី ក៏តថាគតសំដែងហើយដោយបរិយាយ វេទនា ទាំង ៦ ក្តី ក៏តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ១៨ ក្តី ក៏តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៣៦ ក្តី ក៏តថាគត សំដែងហើយដោយបរិយាយ វេទនាទាំង ១០៨ ក្តី ក៏តថាគតសំដែង ហើយដោយបរិយាយ ។ ម្នាលអានន្ទ ធម៌ដែលតថាគតសំដែងហើយ ដោយបរិយាយយ៉ាងនេះ ។ ម្នាលអានន្ទ កាលបើធម៌ដែលតថាគត សំដែងដោយបរិយាយយ៉ាងនេះហើយ ពួកជនឯណាមិនព្រមសំគាល់ តាម មិនយល់ព្រម មិនព្រមអនុមោទនា នូវធម៌ដែលតថាគតសំដែង ទុកហើយដោយល្អ ពោលទុកហើយដោយល្អដល់គ្នានិងគ្នា ។ ពួក ជនទាំងនោះត្រូវនឹកសង្ស័យនូវហេតុនេះ គឺនឹងមានសេចក្តីប្រកួតប្រកាន់

រហោគតវគ្គោ

កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុ-
ទន្តា វិហរិស្សន្តិ ។ ឯវំ បរិយាយទេសិតោ ខោ អានន្ទ
មយា ធម្មោ ។ ឯវំ បរិយាយទេសិតេ ខោ អានន្ទ មយា
ធម្មេ យេ អញ្ញមញ្ញស្ស សុភាសិតំ សុលបិតំ សម-
នុមញ្ញិស្សន្តិ សមនុជានិស្សន្តិ សមនុមោទិស្សន្តិ ។
តេសំ ឯតំ បាដិកង្ខំ សមគ្គា សម្មោទមានា អវិវទ-
មានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្ប-
ស្សន្តា វិហរិស្សន្តិ ។

[៤៨] បញ្ចិមេ អានន្ទ កាមគុណា ។ កតមេ
បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយ-
រូបា កាមូបសញ្ហិតា រជនីយា ។ បេ ។ កាយវិញ្ញេយ្យា
ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា

មានជម្លោះ ដល់នូវសេចក្តីទាស់ទែង ចាក់ដោតគ្នាទៅវិញទៅមក ដោយលំពែងគឺមាត់ ។ ម្នាលអានន្ទ ធម៌ដែលតថាគតសំដែងហើយ ដោយបរិយាយយ៉ាងនេះឯង ។ ម្នាលអានន្ទ កាលបើធម៌ដែលតថាគត សំដែងដោយបរិយាយយ៉ាងនេះហើយ ពួកជនឯណាព្រមសំគាល់តាម យល់ព្រម ព្រមអនុមោទនាដល់គ្នានិងគ្នា នូវធម៌ដែលតថាគតសំដែង ទុកហើយដោយល្អ ពោលទុកហើយដោយល្អ ។ ជនទាំងនោះត្រូវនឹក សង្ឃឹមនូវហេតុនេះ គឺនឹងជាអ្នកមានសេចក្តីព្រមព្រៀងគ្នា រីករាយរកគ្នា មិនទាស់ទែង ដូចជាទឹកដែលលាយដោយទឹកដោះ ឃើញគ្នានិងគ្នា ដោយចក្ខុជាទីស្រឡាញ់ ។

[៥៥] ម្នាលអានន្ទ កាមគុណទាំងឡាយនេះមាន ៥ យ៉ាង ។ កាមគុណទាំង ៥ យ៉ាង តើដូចម្តេច ។ គឺរូបទាំងឡាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរជាទីតម្រេក ដែលគប្បីដឹងបានដោយចក្ខុ ។ បេ ។ ផោដ្ឋព្វៈទាំងឡាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម

វេទនីយា ។ ឥមេ ខោ អានន្ទ បញ្ច កាមគុណា ។ យំ ខោ អានន្ទ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខំ ។

[៩៦] យេ ខោ អានន្ទ ឯវំ វទេយ្យុំ ឯតំ បរមំ សត្តំ[១] សុខំ សោមនស្សំ បដិសំវេទេន្តីតិ ។ ឥទំ នេ-សាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[៩៧] កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរ-តិ ។ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ យេ ខោ អានន្ទ

១ ឱ. សត្តា ។

គួរជាទីតម្រេក ដែលគប្បីដឹងបានដោយកាយ ។ ម្នាលអានន្ទ កាមគុណទាំងឡាយមាន ៥ យ៉ាងនេះឯង ។ ម្នាលអានន្ទ សេចក្តីសុខសោមនស្សឯណាដែលកើតឡើង ព្រោះអាស្រ័យកាមគុណទាំង ៥ នេះ សេចក្តីសុខសោមនស្សនេះហៅថា កាមសុខ ។

[៥៦] ម្នាលអានន្ទ ពួកជនឯណាគប្បីពោលយ៉ាងនេះថា ពួកសត្វតែងសោយ នូវសេចក្តីសុខសោមនស្សដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតមិនព្រមអនុញ្ញាតពាក្យនេះដល់ជនទាំងនោះទេ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

[៥៧] ម្នាលអានន្ទ សេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនោះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក សម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ពួកជនឯណា

រហោគតវគ្គោ

ឯវំ វទេយ្យុំ ឯតំ បរមំ សន្តំ សុខំ សោមនស្សំ បដិសំវេទេន្តីតិ ។ ឥទំ នេសាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[៤៨] កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ យេ ខោ អានន្ទ ឯវំ វទេយ្យុំ ឯតំ បរមំ សន្តំ សុខំ សោមនស្សំ បដិសំវេទេន្តីតិ ។ ឥទំ នេសាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

គប្បីពោលយ៉ាងនេះថា ពួកសត្វរមែងសោយនូវសេចក្តីសុខសោមនស្ស ដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតមិនព្រមអនុញ្ញាតពាក្យនេះ ដល់ជនទាំង នោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាសេចក្តី សុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

[៥៨] ម្នាលអានន្ទ សេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាង សេចក្តីសុខនុ៎ះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ បាន រម្ងាប់នូវវិតក្កវិចារៈហើយ ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុង សន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្ត ខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខកើតអំពីសមាធិ គឺបឋមជ្ឈាន សម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តី សុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ពួក ជនឯណាគប្បីពោលយ៉ាងនេះថា ពួកសត្វតែងសោយនូវសេចក្តីសុខ សោមនស្សដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតក៏មិនព្រមអនុញ្ញាតពាក្យនេះ ដល់ពួកជនទាំងនេះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាល អានន្ទ ព្រោះថាសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

[៥៩] កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជា-នោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិ-យជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ យេ ខោ អានន្ទ ឯវំ វទេយ្យុំ ឯតំ បរមំ សន្តំ សុខំ សោ-មនស្សំ បដិសំវេទេន្តីតិ ។ ឥទំ នេសាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[៩៩] ម្នាលអានន្ទ មួយវិញទៀត សេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះប្រាសចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតី ជាអ្នកដឹងខ្លួនផង តែងសោយនូវសេចក្តីសុខ ដោយនាមកាយផង ពួកព្រះអរិយៈ តែងសរសើរភិក្ខុនោះថា ជាអ្នកមានឧបេក្ខា ជាអ្នកមានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ហើយចូលកាន់តតិយជ្ឈាន សម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ពួកជនឯណាគប្បីពោលយ៉ាងនេះថា ពួកសត្វតែងសោយនូវសេចក្តីសុខសោមនស្សជារបស់ដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតមិនព្រមអនុញ្ញាតពាក្យនេះដល់ជនទាំងនោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

៥៣

## រហោគតវគ្គោ

[៦០] កតមញ្ចានន្ទ ឯតស្មា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អានន្ទ ឯតស្មា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[៦១] យេ ខោ អានន្ទ ឯវំ វទេយ្យុំ ឯតំ បរមំ សន្តំ សុខំ សោមនស្សំ បដិសំវេទេន្តីតិ ។ ឥទំ តេសាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតស្មា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

រហោគតវគ្គ

[៦០] ម្នាលអានន្ទ ចុះសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរំលត់នូវសេចក្តីសោមនស្សនិងទោមនស្ស ក្នុងកាលមុនផង ហើយចូលកាន់ចតុត្ថជ្ឈាន ជាធម្មជាតិមិនមានទុក្ខ មិនមានសុខ មានស្មារតីបរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។

[៦១] ម្នាលអានន្ទ ពួកជនឯណាគប្បីពោលយ៉ាងនេះថា ពួកសត្វតែងសោយនូវសេចក្តីសុខសោមនស្ស ជារបស់ដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតមិនព្រមអនុញ្ញាតពាក្យនេះ ដល់ជនទាំងនោះទេ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

[៦២] កតមំ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃ-សញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ យេ ខោ អានន្ទ ឯវំ វទេយ្យុំ ឯតំ បរមំ សន្តំ សុខំ សោមនស្សំ បដិ-សំវេទេន្តីតិ ។ ឥទំ នេសាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្ក-ន្តតរញ្ច បណីតតរញ្ច ។

[៦៣] កតមំ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ យេ ខោ អានន្ទ

[៦២] ម្នាលអានន្ទ សេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវរូបសញ្ញាទាំងឡាយ ព្រោះមានបដិឃសញ្ញារលត់អស់ទៅ ព្រោះលែងធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញាដោយប្រការទាំងពួង ទើបចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយគិតថា អាកាសមិនមានទីបំផុតសម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ពួកជនឯណាគប្បីពោលយ៉ាងនេះថា ពួកសត្វរមែងសោយ នូវសេចក្តីសុខសោមនស្សដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតមិនព្រមអនុញ្ញាតពាក្យនេះ ដល់ជនទាំងនោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

[៦៣] ម្នាលអានន្ទ សេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយទើបចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយគិតថា វិញ្ញាណមិនមានទីបំផុតសម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ពួកជនឯណា

ឯវំ វទេយ្យុំ ឯតំ បរមំ សន្តំ សុខំ សោមនស្សំ បដិសំវេទេន្តីតិ ។ ឥទំ នេសាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[៦៤] កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ យេ ខោ អានន្ទ ឯវំ វទេយ្យុំ ឯតំ បរមំ សន្តំ សុខំ សោមនស្សំ បដិសំវេទេន្តីតិ ។ ឥទំ នេសាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[៦៥] កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ

គប្បីពោលយ៉ាងនេះថា ពួកសត្វរមែងសោយនូវសេចក្តីសុខសោមនស្សដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតមិនព្រមអនុញ្ញាតពាក្យនេះ ដល់ជនទាំងនោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

[៦៤] ម្នាលអានន្ទ ចុះសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ បានកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយគិតថា អ្វីតិចតួចមិនមានសម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ពួកជនឯណាគប្បីពោលយ៉ាងនេះថា ពួកសត្វរមែងសោយនូវសេចក្តីសុខសោមនស្សដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតមិនព្រមអនុញ្ញាតពាក្យនេះ ដល់ជនទាំងនោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

[៦៥] ម្នាលអានន្ទ ចុះសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ

សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញា-នាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតត-រញ្ច ។ យេ ខោ អានន្ទ ឯវំ វទេយ្យុំ ឯតំ បរមំ សត្តា សុខំ សោមនស្សំ បដិសំវេទេន្តីតិ ។ ឥទំ នេសាហំ នានុជានាមិ ។ តំ កិស្ស ហេតុ ។ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[៦៦] កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥធានន្ទ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិត-និរោធំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

បានកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន សម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ពួកជនឯណាគប្បីពោលយ៉ាងនេះថា ពួកសត្វតែងសោយនូវសេចក្តីសុខសោមនស្សដ៏ល្អិតក្រៃលែងនុ៎ះ ។ តថាគតមិនព្រមអនុញ្ញាតពាក្យនេះ ដល់ជនទាំងនោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានដែរ ។

[៦៦] ម្នាលអានន្ទ ចុះសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ បានកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់សញ្ញាវេទយិតនិរោធ សម្រេចសម្រាន្តនៅ ។ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃ ដែលល្អជាងនិងថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ ។

ឋានំ ខោ បនេតំ អានន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ សញ្ញាវេទយិតនិរោធំ សមណោ គោតមោ អាហ តញ្ច សុខស្មឹ បញ្ញបេតិ តយិទំ កឹសុ តយិទំ កថំសូតិ ។ ឯវំវាទិនោ អានន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា ន ខោ អាវុសោ ភគវា សុខញ្ញេវ វេទនំ សន្ធាយ សុខស្មឹ បញ្ញបេតិ យត្ថ យត្ថាវុសោ សុខំ ឧបលព្ភតិ យហឹ យហឹ សុខំ តំ តំ តថាគតោ សុខស្មឹ បញ្ញបេតីតិ ។ នវមំ ។

[៦៧] ទ្វេបិ មយា ភិក្ខវេ វេទនា វុត្តា បរិយាយេន តិស្សោបិ មយា វេទនា វុត្តា បរិយាយេន បញ្ចបិ មយា វេទនា វុត្តា បរិយាយេន ឆបិ មយា វេទនា វុត្តា បរិយាយេន អដ្ឋារសាបិ មយា វេទនា វុត្តា បរិយាយេន ឆត្តឹសាបិ មយា វេទនា វុត្តា បរិយាយេន អដ្ឋសតំបិ មយា វេទនា វុត្តា

ពួកអន្យតិរ្ថិយបរិព្វាជកគប្បីពោលយ៉ាងនេះថា ព្រះសមណគោតមទ្រង់ត្រាស់នូវសញ្ញាវេទយិតនិរោធផង ទ្រង់បញ្ញត្តនូវសញ្ញាវេទយិតនិរោធនោះក្នុងសេចក្តីសុខផង សេចក្តីសុខនោះ ដូចម្តេច សេចក្តីសុខនោះមានប្រការដូចម្តេច ដោយហេតុឯណា ម្នាលអានន្ទ ហេតុនុ៎ះ ក៏រមែងមានដែរ ។ ម្នាលអានន្ទ ពួកអន្យតិរ្ថិយបរិព្វាជកអ្នកមានវាទៈយ៉ាងនេះ អ្នកទាំងឡាយគប្បីពោលយ៉ាងនេះវិញថា ម្នាលអាវុសោ ព្រះមានព្រះភាគមិនទ្រង់បញ្ញត្តនូវសញ្ញាវេទយិតនិរោធ ក្នុងសេចក្តីសុខ ព្រោះសំដៅយកសុខវេទនាតែម្យ៉ាងទេ ម្នាលអាវុសោ សេចក្តីសុខដែលបុគ្គលបានទទួលក្នុងទីណាៗ សេចក្តីសុខមាននៅក្នុងទីណាៗ ព្រះតថាគតទ្រង់បញ្ញត្តនូវទីនោះ ៗ ក្នុងសេចក្តីសុខដែរ ។ ចប់សូត្រទី ៩ ។

[៦៧] ម្នាលភិក្ខុទាំងឡាយ វេទនាទាំង ២ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៣ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៥ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៦ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ១៨ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៣៦ ក្តី តថាគតសំ-ដែងហើយដោយបរិយាយ វេទនាទាំង ១០៨ ក្តី តថាគតសំដែងហើយ

បរិយាយេន ។ ឯវំ បរិយាយទេសិតោ ភិក្ខវេ មយា ធម្មោ ឯវំ បរិយាយទេសិតេ ខោ ភិក្ខវេ មយា ធម្មេ យេ អញ្ញមញ្ញស្ស សុភាសិតំ សុលបិតំ ន សមនុមញ្ញិស្សន្តិ ន សមនុជានិស្សន្តិ ន សមនុមោទិស្សន្តិ ។ តេសំ ឯតំ បាដិកង្ខំ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរិស្សន្តីតិ ។ ឯវំ បរិយាយទេសិតោ ភិក្ខវេ មយា ធម្មោ ឯវំ បរិយាយទេសិតេ ខោ ភិក្ខវេ មយា ធម្មេ យេ អញ្ញមញ្ញស្ស សុភាសិតំ សុលបិតំ សមនុមញ្ញិស្សន្តិ សមនុជានិស្សន្តិ សមនុមោទិស្សន្តិ ។ តេសំ ឯតំ បាដិកង្ខំ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរិស្សន្តីតិ ។

ដោយបរិយាយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតសំដែង ហើយដោយបរិយាយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែល តថាគតសំដែងដោយបរិយាយយ៉ាងនេះហើយ ពួកជនឯណាមិនព្រម សំគាល់តាម មិនយល់ព្រម មិនព្រមអនុមោទនា នូវធម៌ដែលតថាគត សំដែងហើយដោយល្អ ពោលទុកហើយដោយល្អ ដល់គ្នានិងគ្នា ។ ជនទាំងនោះត្រូវនឹកសង្ឃឹមហេតុនេះ គឺជាអ្នកមានសេចក្ដីប្រកួតប្រកាន់ មានជម្លោះ ដល់នូវការទាស់ទែង ចាក់ដោតគ្នាទៅវិញទៅមក ដោយ លំពែងគឺមាត់ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតសំដែងហើយ ដោយបរិយាយ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែល តថាគតសំដែងដោយបរិយាយយ៉ាងនេះហើយ ពួកជនឯណានឹងព្រម សំគាល់តាម យល់ព្រម ព្រមអនុមោទនា នូវធម៌ដែលតថាគតសំដែង ទុកល្អហើយ ពោលទុកល្អហើយ ដល់គ្នានិងគ្នា ។ ជនទាំងនោះ ត្រូវ នឹកសង្ឃឹមហេតុនេះ គឺជាអ្នកមានសេចក្ដីព្រមព្រៀង ស្រុះស្រួល មិន ទាស់ទែង ដូចជាទឹកដែលលាយដោយទឹកដោះ ឃើញនូវគ្នានិងគ្នា ដោយចក្ខុជាទីស្រឡាញ់ ។

## រហោគតវគ្គោ

[៦៨] បញ្ចិមេ ភិក្ខវេ កាមគុណា ។ បេ ។ ហដំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ សញ្ញាវេទយិតនិរោធំ សមណោ គោតមោ អាហ តញ្ច សុខស្មឹ បញ្ញបេតិ តយិទំ កឹសុ តយិទំ កថំសូតិ ។ ឯវំវាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា ន ខោ អាវុសោ ភគវា សុខញ្ញេវ វេទនំ សន្ធាយ សុខស្មឹ បញ្ញបេតិ យត្ថ យត្ថ អាវុសោ សុខំ ឧបលព្ភតិ យហឹ យហឹ តំ តំ តថាគតោ សុខស្មឹ បញ្ញបេតីតិ ។ ទសមំ ។

រហោគតវគ្គោ ទុតិយោ ។

រហោគតវគ្គ

[៦៨] ម្នាលភិក្ខុទាំងឡាយ កាមគុណទាំងឡាយនេះមាន ៥ យ៉ាង ។ បេ ។ ពួកអន្យតិរ្ថិយបរិព្វាជកគប្បីពោលយ៉ាងនេះថា ព្រះសមណគោតមទ្រង់ត្រាស់នូវសញ្ញាវេទយិតនិរោធផង ទ្រង់បញ្ញត្តនូវសញ្ញាវេទយិតនិរោធនោះក្នុងសេចក្ដីសុខផង សេចក្ដីសុខនោះដូចម្ដេច សេចក្ដីសុខនោះមានប្រការដូចម្ដេច ដោយហេតុឯណា ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ រមែងមានដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកអន្យតិរ្ថិយបរិព្វាជកជាអ្នកមានវាទៈយ៉ាងនេះ អ្នកទាំងឡាយគប្បីពោលយ៉ាងនេះវិញថា ម្នាលអាវុសោ ព្រះមានព្រះភាគ មិនទ្រង់បញ្ញត្តសញ្ញាវេទយិតនិរោធក្នុងសេចក្ដីសុខ ព្រោះសំដៅយកសុខវេទនាតែម្យ៉ាងទេ ម្នាលអាវុសោ សេចក្ដីសុខដែលបុគ្គលបានទទួលក្នុងទីណាៗ សេចក្ដីសុខមាននៅក្នុងទីណាៗ ព្រះតថាគតទ្រង់បញ្ញត្តនូវទីនោះៗ ក្នុងសេចក្ដីសុខដែរ ។ ចប់សូត្រទី ១០ ។

ចប់ រហោគតវគ្គ ទី ២ ។

សុត្តន្តបិដកេ សំយុត្តនិកាយស្ស សឡាយតនវគ្គោ

# តស្សុទ្ទានំ

រហោគតោ ទ្វេ វាតា ច
និវាសា ទ្វេ ចាឌង្គកា
សម្ពហុលា ច[១] ទ្វេ វុត្តា
បញ្ចកង្គោ ច ភិក្ខុជាតិ ។

---

១ ឱ. ម. រហោគតំ ទ្វេ អាកាសំ អគារំ ទ្វេ ច សន្តកំ អដ្ឋកេន ច ទ្វេ វុត្តា ។ ម. អត្ថគាធញ្ច ទ្វេ វុត្តា ។

សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ

# ឧទ្ទាននៃរហោគតវគ្គនោះគឺ

*និយាយអំពីភិក្ខុសម្ងំនៅក្នុងទីស្ងាត់ ១ និយាយអំពីខ្យល់បក់ទៅក្នុងទិសមាន ២ លើក និយាយអំពីផ្ទះសំណាក់ ១ អំពីព្រះអានន្ទទូលសួរអំពីវេទនាមាន ២ លើក អំពីភិក្ខុច្រើនរូបមាន ២ លើក អំពីជាងឈើឈ្មោះបញ្ចកង្គៈ ១ អំពីវេទនាមានពីរជាដើមចំពោះភិក្ខុទាំងឡាយ ១ ។*

# អដ្ឋសតបរិយាយវគ្គោ

[៦៩] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ មោឡិយសិវ-កោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្ក-មិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មោឡិយសិវកោ បរិព្វាជកោ ភគវន្តំ ឯតទវោច សន្តិ ភោ គោតម ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យំ កិញ្ចាយំ បុរិសបុគ្គលោ បដិ-សំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ បុព្វេកតហេតូតិ ។ ឥធ បន ភវំ គោតមោ កិមាហាតិ ។ បិត្តសមុដ្ឋានានិបិ ខោ សិវក ឯកច្ចានិ វេទយិតានិ ឧប្បជ្ជន្តិ ។ សាមំបិ ខោ ឯតំ សិវក ឯវំ វេទិតព្វំ យថា បិត្តសមុដ្ឋានានិបិ ឯកច្ចានិ វេទយិតានិ ឧប្បជ្ជន្តិ ។

# អដ្ឋសតបរិយាយវគ្គ

[៦៩] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុ-វនជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង មោឡិយ-សិវកបរិព្វាជក ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ អង្គុយក្នុងទីសមគួរ ។ លុះមោឡិយសិវកបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន មានសមណ-ព្រាហ្មណ៍ពួកមួយ ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះ តែងសោយនូវវេទនាណាមួយជាសុខក្តី ទុក្ខក្តី មិនទុក្ខមិនសុខក្តី ការសោយវេទនាទាំងអស់នោះ មានកម្មដែលខ្លួនបានធ្វើហើយក្នុងកាលមុនជាហេតុ ។ ចុះព្រះគោតមដ៏ចម្រើន ទ្រង់ត្រាស់ដូចម្តេចក្នុងហេតុនេះ ។ ម្នាលសិវកៈ ការសោយអារម្មណ៍ពួកខ្លះក្នុងលោកនេះ មានប្រមាត់ជាសមុដ្ឋានកើតឡើងក៏មាន ។ ការសោយអារម្មណ៍ពួកខ្លះក្នុងលោកនេះ មានប្រមាត់ជាសមុដ្ឋានកើតឡើងក៏មាន យ៉ាងណា ម្នាលសិវកៈ ដំណើរនុ៎ះ បុគ្គលគប្បីដឹងច្បាស់ដោយខ្លួនឯង យ៉ាងនោះចុះ ។

លោកស្សបិ ខោ ឯតំ សិវក សច្ចសម្មតំ យថា បិត្តសមុដ្ឋានានិបិ ឥធេកច្ចានិ វេទយិតានិ ឧប្បជ្ជន្តិ ។ តត្រ សិវក យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យំ កិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទយតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ បុព្វេកតហេតូតិ ។ យញ្ច សាមំ ញាតំ តញ្ច អតិធាវន្តិ យំ លោកេ សច្ចសម្មតំ តញ្ច អតិធាវន្តិ ។ តស្មា តេសំ សមណព្រាហ្មណានំ មិច្ឆាតិ វទាមិ ។ សេម្ហសមុដ្ឋានានិបិ ខោ សិវក ។ បេ ។ វាតសមុដ្ឋានានិបិ ខោ សិវក ។ បេ ។ សន្និបាតសមុដ្ឋានានិបិ ខោ សិវក ។ បេ ។ ឧតុបរិណាមជានិបិ ខោ សិវក ។ វិសមបរិហារជានិបិ ខោ សិវក ។

ការសោយអារម្មណ៍ពួកខ្លះក្នុងលោកនេះ មានប្រមាត់ជាសមុដ្ឋានកើតឡើងក៏មាន យ៉ាងណា ម្នាលសិវកៈ ដំណើរនុ៎ះ បុគ្គលសន្មតថាជារបស់ពិតនៃសត្វលោក ក៏យ៉ាងនេះដែរ ។ ម្នាលសិវកៈ បណ្ដាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ឯណា ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះរមែងសោយនូវអារម្មណ៍ឯណានីមួយ ជាសុខក្ដី ទុក្ខក្ដី មិនទុក្ខមិនសុខក្ដី អារម្មណ៍ទាំងអស់នោះសុទ្ធតែមានកម្មដែលខ្លួនធ្វើហើយ ក្នុងកាលមុនជាហេតុ ។ ពួកសមណព្រាហ្មណ៍ រមែងស្ទុះទៅរកហេតុ ដែលខ្លួនបានដឹងច្បាស់ដោយខ្លួនឯងផង រមែងស្ទុះទៅរកហេតុដែលខ្លួនសន្មត ថាជារបស់ពិតក្នុងលោកផង ។ ព្រោះហេតុនោះ តថាគតពោលថា ជាសេចក្ដីខុសរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ។ ម្នាលសិវកៈ ការសោយអារម្មណ៍មានស្លេស្ម ជាសមុដ្ឋានក៏មាន ។ បេ ។ ម្នាលសិវកៈ ការសោយអារម្មណ៍មានខ្យល់ជាសមុដ្ឋានក៏មាន ។ បេ ។ ម្នាលសិវកៈ ការសោយអារម្មណ៍មានការប្រជុំចុះនៃរោគជាសមុដ្ឋានក៏មាន ។ បេ ។ ម្នាលសិវកៈ ការសោយអារម្មណ៍ កើតអំពីសេចក្ដីប្រែប្រួលនៃរដូវក៏មាន ។ ម្នាលសិវកៈ ការសោយអារម្មណ៍ កើតអំពីការថែរក្សាឥរិយាបថមិនស្មើគ្នាក៏មាន ។

៦៣

## អដ្ឋសតបរិយាយវគ្គោ

ឧបក្កមិកានិបិ ខោ សិវក ។ បេ ។ កម្មវិបាកជានិបិ ខោ សិវក ឯកេច្ចានិ វេទយិតានិ ឧប្បជ្ជន្តិ ។ សាមំបិ ខោ ឯតំ សិវក ឯវំ វេទិតព្វំ យថា កម្មវិបាកជានិបិ ឯកេច្ចានិ វេទយិតានិ ឧប្បជ្ជន្តិ ។ លោកស្សបិ ខោ ឯតំ សិវក សច្ចសម្មតំ យថា កម្មវិបាកជានិបិ ឯកេច្ចានិ វេទយិតានិ ឧប្បជ្ជន្តិ ។ តត្ត សិវក យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យំ កិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទយតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ បុព្វេកត-

អដ្ឋសតបរិយាយវគ្គ

ម្នាលសិវកៈ ការសោយអារម្មណ៍កើតអំពីសេចក្តីព្យាយាមក៏មាន ។ បេ ។ ម្នាលសិវកៈ ការសោយអារម្មណ៍ពួកខ្លះក្នុងលោកនេះ កើតអំពីផលនៃកម្មកើតឡើងក៏មាន ។ ការសោយអារម្មណ៍ពួកខ្លះក្នុងលោកនេះ កើតមកអំពីផលនៃកម្មកើតឡើងក៏មាន យ៉ាងណា ម្នាលសិវកៈ ដំណើរនុ៎ះ បុគ្គលគប្បីដឹងច្បាស់ដោយខ្លួនឯង យ៉ាងនោះចុះ ។ ការសោយអារម្មណ៍ពួកខ្លះក្នុងលោកនេះ កើតមកអំពីផលនៃកម្មកើតឡើងក៏មាន យ៉ាងណា ម្នាលសិវកៈ ដំណើរនុ៎ះ បុគ្គលសន្មតថាជារបស់ពិត នៃសត្វលោកក៏យ៉ាងនោះដែរ ។ ម្នាលសិវកៈ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ឯណា ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះ រមែងសោយអារម្មណ៍ឯណានីមួយជាសុខក្តី ទុក្ខក្តី មិនទុក្ខមិនសុខក្តី ការសោយអារម្មណ៍ទាំងអស់នោះសុទ្ធតែមានកម្មដែលខ្លួន

ហោតូតិ ។ យញ្ច សាមំ ញាតំ តញ្ច អតិធាវន្តិ យំ លោកេ សច្ចសម្មតំ តញ្ច អតិធាវន្តិ តស្មា តេសំ សមណព្រាហ្មណានំ មិច្ឆាតិ វទាមីតិ ។

[៧០] ឯវំ វុត្តេ មោឡិយសិវកោ បរិព្វាជកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

[៧១] បិត្តំ សេម្ហញ្ច វាតោ ច

សន្និបាតា ឧតូនិ ច

វិសមំ ឱបក្កមិកញ្ច

កម្មវិបាកេន អដ្ឋមីតិ ។ បឋមំ ។

បានធ្វើហើយក្នុងកាលមុនជាហេតុ ។ ពួកសមណព្រាហ្មណ៍តែងស្ទុះទៅរកហេតុដែលខ្លួនបានដឹងច្បាស់ដោយខ្លួនឯងផង តែងស្ទុះទៅរកហេតុដែលខ្លួនសន្មតថាជារបស់ពិតក្នុងលោកផង ព្រោះហេតុនោះ តថាគតពោលថាជាសេចក្តីខុសរបស់ពួកសមណព្រាហ្មណ៍ទាំងនោះដូច្នេះ ។

[៧០] កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ មោឡិយសិវកបរិព្វាជក បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ សូមព្រះគោតមដ៏ចម្រើនទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

[៧១] ការសោយអារម្មណ៍មានប្រមាត់ជាសមុដ្ឋាន ១
ស្លេស្ម ១ ខ្យល់ ១ ការប្រជុំចុះនៃរោគ ១ រដូវប្រែប្រួល ១
រក្សាឥរិយាបថមិនស្មើគ្នា ១ កើតអំពីសេចក្តីព្យាយាម ១ ជា
គម្រប់ ៨ និងផលនៃកម្ម ។ ចប់សូត្រទី ១ ។

## អដ្ឋសតបរិយាយវគ្គោ

[៧២] អដ្ឋសតបរិយាយំ វោ ភិក្ខវេ ធម្មបរិយាយំ ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ អដ្ឋសតបរិយាយោ ធម្មបរិយាយោ ។ ទ្វេបិ មយា ភិក្ខវេ វេទនា វុត្តា បរិយាយេន តិស្សោបិ មយា វេទនា វុត្តា បរិយាយេន បញ្ចបិ មយា វេទនា វុត្តា បរិយាយេន ឆបិ មយា វេទនា វុត្តា បរិយាយេន អដ្ឋារសាបិ មយា វេទនា វុត្តា បរិយាយេន ឆត្តឹសាបិ មយា វេទនា វុត្តា បរិយាយេន អដ្ឋសតំបិ មយា វេទនា វុត្តា បរិយាយេន ។

[៧៣] កតមា ច ភិក្ខវេ ទ្វេ វេទនា កាយិកា ច ចេតសិកា ច ។ ឥមា វុច្ចន្តិ ភិក្ខវេ ទ្វេ វេទនា ។

[៧៤] កតមា ច ភិក្ខវេ តិស្សោ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា វុច្ចន្តិ ភិក្ខវេ តិស្សោ វេទនា ។

## អដ្ឋសតបរិយាយវគ្គ

[៧២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម្មបរិយាយ ដែលមានបរិយាយ ១០៨ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម្មបរិយាយនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះធម្មបរិយាយមានបរិយាយ ១០៨ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំង ២ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៣ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៥ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៦ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ១៨ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ៣៦ ក្តី តថាគតសំដែងហើយដោយបរិយាយ វេទនាទាំង ១០៨ ក្តី តថាគតសំដែងហើយដោយបរិយាយ ។

[៧៣] ម្នាលភិក្ខុទាំងឡាយ ចុះវេទនាទាំង ២ តើដូចម្តេច គឺ កាយិកវេទនា ១ ចេតសិកវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនាមាន ២ ។

[៧៤] ម្នាលភិក្ខុទាំងឡាយ ចុះវេទនាទាំង ៣ តើដូចម្តេច គឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា វេទនាមាន ៣ ។

[៧៥] កតមា ច ភិក្ខវេ បញ្ច វេទនា សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។ ឥមា វុច្ចន្តិ ភិក្ខវេ បញ្ច វេទនា ។

[៧៦] កតមា ច ភិក្ខវេ ឆ វេទនា ចក្ខុសម្ផស្សជា វេទនា ។ បេ ។ មនោសម្ផស្សជា វេទនា ។ ឥមា វុច្ចន្តិ ភិក្ខវេ ឆ វេទនា ។

[៧៧] កតមា ច ភិក្ខវេ អដ្ឋារស វេទនា ឆ សោមនស្សុបវិចារា ឆ ទោមនស្សុបវិចារា ឆ ឧបេក្ខុបវិចារា ។ ឥមា វុច្ចន្តិ ភិក្ខវេ អដ្ឋារស វេទនា ។

[៧៨] កតមា ច ភិក្ខវេ ឆត្តឹស វេទនា ឆ គេហសិតានិ សោមនស្សានិ ឆ នេក្ខម្មសិតានិ សោមនស្សានិ ឆ គេហសិតានិ ទោមនស្សានិ ឆ នេក្ខម្មសិតានិ ទោមនស្សានិ ឆ គេហសិតា ឧបេក្ខា ឆ នេក្ខម្មសិតា ឧបេក្ខា ។ ឥមា វុច្ចន្តិ ភិក្ខវេ ឆត្តឹស វេទនា ។

[៧៥] ម្នាលភិក្ខុទាំងឡាយ ចុះវេទនាទាំង ៥ តើដូចម្ដេច គឺ សុខិន្ទ្រិយវេទនា ១ ទុក្ខិន្ទ្រិយវេទនា ១ សោមនស្សិន្ទ្រិយវេទនា ១ ទោមនស្សិន្ទ្រិយវេទនា ១ ឧបេក្ខិន្ទ្រិយវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនាមាន ៥ ។

[៧៦] ម្នាលភិក្ខុទាំងឡាយ ចុះវេទនាទាំង ៦ តើដូចម្ដេច គឺចក្ខុ-សម្ផស្សជាវេទនា ១ ។ បេ ។ មនោសម្ផស្សជាវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនាមាន ៦ ។

[៧៧] ម្នាលភិក្ខុទាំងឡាយ ចុះវេទនាទាំង ១៨ តើដូចម្ដេច គឺ សោមនស្សូបវិចារវេទនា ៦ ទោមនស្សូបវិចារវេទនា ៦ ឧបេក្ខូបវិចារ-វេទនា ៦ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនាមាន ១៨ ។

[៧៨] ម្នាលភិក្ខុទាំងឡាយ ចុះវេទនាទាំង ៣៦ តើដូចម្ដេច គឺ គេហសិតសោមនស្សវេទនា ៦ នេក្ខម្មសិតសោមនស្សវេទនា ៦ គេ-ហសិតទោមនស្សវេទនា ៦ នេក្ខម្មសិតទោមនស្សវេទនា ៦ គេហសិត-ឧបេក្ខាវេទនា ៦ នេក្ខម្មសិតឧបេក្ខាវេទនា ៦ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនាមាន ៣៦ ។

៦៧

## អដ្ឋសតបរិយាយវគ្គោ

[៧៩] កតមា ច ភិក្ខវេ អដ្ឋសតំ វេទនា អតីតា ឆត្តឹស វេទនា អនាគតា ឆត្តឹស វេទនា បច្ចុប្បន្នា ឆត្តឹស វេទនា ។ ឥមា វុច្ចន្តិ ភិក្ខវេ អដ្ឋសតំ វេទនា ។ អយំបិ ខោ ភិក្ខវេ អដ្ឋសតបរិយាយោ ធម្មបរិយា-
យោតិ ។ ទុតិយំ ។

[៨០] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកាមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កតមា នុ ខោ ភន្តេ វេទនា កតមោ វេទនាសមុទយោ កតមា វេទនាសមុទយ-
គាមិនី បដិបទា កតមោ វេទនានិរោធោ កតមា វេទនានិរោធគាមិនី បដិបទា កោ វេទនាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ តិស្សោ ឥមា ភិក្ខ-
វេ[១] វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខម-
សុខា វេទនា ។ ឥមា វុច្ចន្តិ ភិក្ខវេ វេទនា ។

១ ឱ. ម. ភិក្ខុ ។

អដ្ឋសតបរិយាយវគ្គ

[៧៩] ម្នាលភិក្ខុទាំងឡាយ វេទនា ១០៨ តើដូចម្តេច គឺវេទនាជាអតីត ៣៦ វេទនាជាអនាគត ៣៦ វេទនាជាបច្ចុប្បន្ន ៣៦ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនាមាន ១០៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាធម្មបរិយាយ មានបរិយាយ ១០៨ ។ ចប់សូត្រទី ២ ។

[៨០] គ្រានោះឯង ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វេទនាដូចម្តេច ហេតុជាទីកើតឡើងនៃវេទនាដូចម្តេច បដិបទាជាហេតុឲ្យដល់នូវហេតុជាទីកើតឡើងនៃវេទនាដូចម្តេច ការរលត់ទៅនៃវេទនាដូចម្តេច បដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនាដូចម្តេច អានិសង្សនៃវេទនាដូចម្តេច ទោសនៃវេទនាដូចម្តេច ការរលាស់ចេញនូវវេទនាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងនេះមាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាវេទនា ។

ផស្សសមុទយា វេទនាសមុទយោ តណ្ហា វេទនាសមុទយគាមិនី បដិបទា ផស្សនិរោធា វេទនានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ វេទនានិរោធគាមិនី បដិបទា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យំ វេទនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វេទនាយ អស្សាទោ ។ យា វេទនា អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ វេទនាយ អាទីនវោ ។ យោ វេទនាយ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វេទនាយ និស្សរណន្តិ ។ តតិយំ ។

[៨១] បុព្វេ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កតមា នុ ខោ វេទនា កតមោ វេទនាសមុទយោ កតមា វេទនាសមុទយគាមិនី បដិបទា កតមោ វេទនានិ-

ហេតុជាទីកើតឡើងនៃវេទនា ព្រោះកើតឡើងនៃផស្សៈ តណ្ហាជាបដិ-បទាជាហេតុឲ្យដល់ នូវការកើតឡើងនៃវេទនា ការរលត់ទៅនៃវេទនា ព្រោះរលត់នៃផស្សៈ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ជាបដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនា ។ អដ្ឋង្គិកមគ្គ តើអ្វីខ្លះ ។ គឺសម្មា-ទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ សេចក្តីសុខសោមនស្សកើតឡើងព្រោះអាស្រ័យនូវវេទនាឯណា នេះជាអានិសង្សនៃវេទនា ។ វេទនាឯណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលទៅជាធម្មតា នេះជាទោសនៃវេទនា ។ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគក្នុងវេទនាឯណា នេះជាការរលាស់ចេញនូវវេទនា ។ ចប់សូត្រទី ៣ ។

[៨១] ម្នាលភិក្ខុទាំងឡាយ កាលពីដើមដែលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់សម្ពោធិញ្ញាណនៅឡើយ មានសេចក្តីត្រិះរិះដូច្នេះថា វេទនាដូចម្តេច ហេតុជាទីកើតឡើងនៃវេទនាដូចម្តេច បដិបទាជាហេតុឲ្យដល់នូវការកើតឡើងនៃវេទនាដូចម្តេច ការរលត់ទៅ

រោធោ កតមា វេទនានិរោធគាមិនី បដិបទា កោ វេទនាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ តិស្សោ ឥមា វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា វុច្ចន្តិ វេទនា ។ ផស្សសមុទយា វេទនាសមុទយោ តណ្ហា វេទនាសមុទយគាមិនី បដិបទា ។ បេ ។ យោ វេទនាយ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វេទនាយ និស្សរណន្តិ ។ ចតុត្ថំ ។

[៨២] ឥមា វេទនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ អយំ វេទនាសមុទយោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ អយំ វេទនាសមុទយគាមិនី បដិបទាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ

នៃវេទនាដូចម្តេច បដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនាដូចម្តេច អានិសង្សនៃវេទនាដូចម្តេច ទោសនៃវេទនាដូចម្តេច ការរលាស់ចេញនូវវេទនាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះទៀតថា វេទនាទាំងឡាយនេះមាន ៣ យ៉ាងគឺ សុខ-វេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ នេះហៅថាវេទនា ។ ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃផស្សៈ តណ្ហាជាបដិបទាជាហេតុឲ្យដល់នូវការកើតឡើងនៃវេទនា ។ បេ ។ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគក្នុងវេទនាឯណា នេះជាការរលាស់ចេញនូវវេទនា ។ ចប់សូត្រទី ៤ ។

[៨២] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮពីកាលមុនថា នេះជាវេទនាដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺកើតឡើងហើយដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮពីកាលមុនថា នេះជាហេតុកើតឡើងនៃវេទនាដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង

។ បេ ។ អាលោកោ ឧទបាទិ ។ អយំ ខោ វេទនានិរោធោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ អយំ វេទនានិរោធគាមិនី បដិបទាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ អយំ វេទនាយ អស្សាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ។ បេ ។ អយំ វេទនាយ អាទីនវោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ។ បេ ។ ឥទំ វេទនាយ និស្សរណន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទីតិ ។ បញ្ចមំ ។

។ បេ ។ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮពីកាលមុនថា នេះជាបដិបទាជាហេតុឲ្យដល់នូវការកើតឡើងនៃវេទនាដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ។ បេ ។ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮពីកាលមុនថា នេះឯងការរលត់ទៅនៃវេទនាដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ។ បេ ។ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮពីកាលមុនថា នេះជាបដិបទាជាហេតុឲ្យដល់នូវការរលត់ទៅនៃវេទនាដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮពីកាលមុនថា នេះជាអានិសង្សនៃវេទនា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮពីកាលមុនថា នេះជាទោសនៃវេទនា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮពីកាលមុនថា នេះជាការរលាស់ចេញនូវវេទនា ។ ចប់សូត្រទី ៨ ។

## អដ្ឋសតបរិយាយវគ្គោ

[៨៣] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ។ បេ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ កតមា នុ ខោ ភន្តេ វេទនា កតមោ វេទនាសមុទយោ កតមា វេទនាសមុទយគាមិនី បដិបទា ។ បេ ។ កោ វេទនាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ តិស្សោ ឥមា ភិក្ខវេ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា វុច្ចន្តិ ភិក្ខវេ វេទនា ។ ផស្សសមុទយា វេទនាសមុទយោ តណ្ហា វេទនាសមុទយគាមិនី បដិបទា ផស្សនិរោធា ។ បេ ។ យោ វេទនាយ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វេទនាយ និស្សរណន្តិ ។ ឆដ្ឋំ ។

## អដ្ឋសតបរិយាយវគ្គ

[៨៣] គ្រានោះឯង ពួកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វេទនាតើដូចម្តេច ហេតុជាទីកើតឡើងនៃវេទនាតើដូចម្តេច បដិបទាជាហេតុឲ្យដល់នូវការកើតឡើងនៃវេទនាតើដូចម្តេច ។ បេ ។ អានិសង្សនៃវេទនាតើដូចម្តេច ទោសនៃវេទនាតើដូចម្តេច ការរលាស់ចេញនូវវេទនាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយនេះមាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាវេទនា ។ ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃផស្សៈ តណ្ហាជាបដិបទា ជាហេតុឲ្យដល់នូវការកើតឡើងនៃវេទនា ព្រោះរលត់នៃផស្សៈ ។ បេ ។ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគក្នុងវេទនាឯណា នេះជាសេចក្តីរលាស់ចេញនូវវេទនា ។ ចប់សូត្រទី ៦ ។

[៨៤] តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមាសំ តិស្សន្នំ វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជា-នន្តិ ។ ន តេមេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សា-មញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អ-ភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមាសំ តិស្សន្នំ វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ ។ តេ ខោមេ ភិក្ខវេ សមណា វា ព្រាហ្មណា វា

[៨៤] ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយនេះមាន ៣ យ៉ាង ។ វេទនា ៣ យ៉ាង តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ ក៏ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់នូវហេតុជាទីកើតឡើងផង នូវការរលត់ផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នូវវេទនាទាំង ៣ នេះ តាមពិត ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនុ៎ះ មិនសន្មតថាជាសមណៈក្នុងពួកសមណៈ ឬសន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ មួយវិញទៀត លោកដ៏មានអាយុទាំងនោះ មិនទាន់បានធ្វើឲ្យជាក់ច្បាស់សម្រេច ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង នូវសាមញ្ញគុណក្តី នូវព្រហ្មញ្ញគុណក្តី ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ បានដឹងច្បាស់នូវហេតុជាទីកើតឡើងផង នូវការរលត់ផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នូវវេទនាទាំង ៣ នេះ តាមពិត ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ

អដ្ឋសតបរិយាយវគ្គោ

សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា ។ តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ សត្តមំ ។

[៨៤] តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមាសំ តិស្សន្នំ វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យ-ថាភូតំ នប្បជានន្តិ ។ បេ ។ បជានន្តិ ។ បេ ។ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ អដ្ឋមំ ។

ទើបសន្មតថាជាសមណៈក្នុងពួកសមណៈផង សន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ។ មួយវិញទៀត លោកមានអាយុទាំងនោះ បានធ្វើឲ្យជាក់ច្បាស់សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង នូវសាមញ្ញ-គុណក្តី នូវព្រហ្មញ្ញគុណក្តី ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ។

ចប់សូត្រទី ៧ ។

[៨៥] ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង ។ វេទនា ៣ យ៉ាង តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខម-សុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់នូវហេតុជាទីកើតឡើងផង នូវការរលត់ទៅផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នូវវេទនាទាំង ៣ នេះ តាមពិត ។ បេ ។ រមែងដឹងច្បាស់ ។ បេ ។ ធ្វើឲ្យជាក់ច្បាស់សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង សម្រេចសម្រាន្តនៅ ។

ចប់សូត្រទី ៨ ។

[៨៦] យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា វេទនំ នប្បជានន្តិ វេទនាសមុទយំ នប្បជានន្តិ វេទនានិរោធំ នប្បជានន្តិ វេទនានិរោធគាមិនីបដិបទំ នប្បជានន្តិ ។ បេ ។ បជានន្តិ ។ បេ ។ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ នវមំ ។

[៨៧] តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា ខោ ភិក្ខវេ តិស្សោ វេទនាតិ ។ ទសមំ ។

[៨៨] អត្ថិ ភិក្ខវេ សាមិសា បីតិ អត្ថិ និរាមិសា បីតិ អត្ថិ ភិក្ខវេ និរាមិសា និរាមិសតរា បីតិ អត្ថិ សាមិសំ សុខំ អត្ថិ និរាមិសំ សុខំ អត្ថិ និរាមិសា និរាមិសតរំ សុខំ អត្ថិ សាមិសា ឧបេក្ខា អត្ថិ

[៨៦] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់នូវវេទនា មិនដឹងច្បាស់នូវហេតុជាទីកើតឡើងនៃវេទនា មិនដឹងច្បាស់នូវការរលត់នៃវេទនា មិនដឹងច្បាស់នូវបដិបទាជាហេតុឲ្យដល់នូវការរលត់នៃវេទនា ។ បេ ។ ដឹងច្បាស់ ។ បេ ។ ធ្វើឲ្យជាក់ច្បាស់សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង សម្រេចសម្រាន្តនៅ ។ ចប់សូត្រទី ៩ ។

[៨៧] ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង ។ វេទនា ៣ យ៉ាង តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខ-វេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ វេទនាមាន ៣ យ៉ាងនេះឯង ។ ចប់សូត្រទី ១០ ។

[៨៨] ម្នាលភិក្ខុទាំងឡាយ បីតិប្រកបដោយអាមិសក៏មាន បីតិមិនប្រកបដោយអាមិសក៏មាន ម្នាលភិក្ខុទាំងឡាយ បីតិប្រាសចាកអាមិស ដ៏លើសជាងបីតិមិនប្រកបដោយអាមិសទៅទៀត ក៏មាន សេចក្តីសុខប្រកបដោយអាមិសក៏មាន សេចក្តីសុខមិនប្រកបដោយអាមិសក៏មាន សេចក្តីសុខប្រាសចាកអាមិស ដ៏លើសជាងសេចក្តីសុខដែលមិនប្រកបដោយអាមិសក៏មាន ឧបេក្ខាប្រកបដោយអាមិសក៏មាន

អដ្ឋសតបរិយាយវគ្គោ

និរាមិសា ឧបេក្ខា អត្ថិ និរាមិសា និរាមិសតរា ឧ-
បេក្ខា អត្ថិ សាមិសោ វិមោក្ខោ អត្ថិ និរាមិសោ
វិមោក្ខោ អត្ថិ និរាមិសា និរាមិសតរោ វិមោក្ខោ ។

[៨៩] កតមា ច ភិក្ខវេ សាមិសា បីតិ ។
បញ្ចិមេ ភិក្ខវេ កាមគុណា ។ កតមេ បញ្ច ។
ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា
កាមូបសញ្ហិតា រជនីយា ។ បេ ។ កាយវិញ្ញេយ្យា ផោ-
ដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា
រជនីយា ។ ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា ។
យា ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច
ឧប្បជ្ជតិ បីតិ អយំ វុច្ចតិ ភិក្ខវេ សាមិសា បីតិ ។

ឧបេក្ខាមិនប្រកបដោយអាមិសក៏មាន ឧបេក្ខាប្រាសចាកអាមិសដ៏លើសជាងឧបេក្ខាដែលមិនប្រកបដោយអាមិសក៏មាន វិមោក្ខប្រកបដោយអាមិសក៏មាន វិមោក្ខមិនប្រកបដោយអាមិសក៏មាន វិមោក្ខប្រាសចាកអាមិសដ៏លើសជាងវិមោក្ខដែលមិនប្រកបដោយអាមិសក៏មាន ។

[៨៩] ម្នាលភិក្ខុទាំងឡាយ ចុះបីតិប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺកាមគុណទាំង ៥ នេះឯង ។ កាមគុណទាំង ៥ យ៉ាង តើដូចម្តេច ។ គឺរូបទាំងឡាយដែលគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ។ បេ ។ ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ។ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បីតិឯណាដែលកើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បីតិប្រកបដោយអាមិស ។

[៩០] កតមា ច ភិក្ខវេ និរាមិសា បីតិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ និរាមិសា បីតិ ។

[៩១] កតមា ច ភិក្ខវេ និរាមិសា និរាមិស-តរា បីតិ ។ យា ខោ ភិក្ខវេ ខីណាសវស្ស ភិក្ខុនោ រាគា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ ទោសា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ មោហា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ ឧប្បជ្ជតិ បីតិ អយំ វុច្ចតិ ភិក្ខវេ និរាមិសា និរាមិសតរា បីតិ ។

[៩០] ម្នាលភិក្ខុទាំងឡាយ ចុះបីតិមិនប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កនិងវិចារ មានបីតិនិងសុខដែលកើតអំពីវិវេកសម្រេចសម្រាន្តនៅ លុះរម្ងាប់បង់នូវវិតក្កនិងវិចារអស់ហើយ បានចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កនិងវិចារ មានតែបីតិនិងសុខដែលកើតអំពីសមាធិគឺបឋមជ្ឈាន សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បីតិមិនប្រកបដោយអាមិស ។

[៩១] ម្នាលភិក្ខុទាំងឡាយ ចុះបីតិប្រាសចាកអាមិស ដ៏លើសជាងបីតិដែលមិនប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បីតិឯណាដែលកើតឡើងដល់ខីណាសវភិក្ខុ ជាអ្នកពិចារណាឃើញនូវចិត្តដែលផុតស្រឡះចាករាគៈហើយ ជាអ្នកពិចារណាឃើញនូវចិត្តដែលផុតស្រឡះចាកទោសៈហើយ ជាអ្នកពិចារណាឃើញនូវចិត្តដែលផុតស្រឡះចាកមោហៈហើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បីតិប្រាសចាកអាមិសដ៏លើសជាងបីតិដែលមិនប្រកបដោយអាមិស ។

៧៧

## អដ្ឋសតបរិយាយវគ្គោ

[៩២] កតមញ្ច ភិក្ខវេ សាមិសំ សុខំ ។ បញ្ចិមេ ភិក្ខវេ កាមគុណា ។ កតមេ បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ បេ ។ កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា ។ យំ ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ ភិក្ខវេ សាមិសំ សុខំ ។

[៩៣] កតមញ្ច ភិក្ខវេ និរាមិសំ សុខំ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុស-លេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ

អដ្ឋសតបរិយាយវគ្គ

[៩២] ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីសុខប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺកាមគុណទាំង ៥ នេះឯង ។ កាមគុណទាំង ៥ តើដូចម្តេច ។ គឺរូបទាំងឡាយដែលគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ។ បេ ។ ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ។ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខសោមនស្សឯណាដែលកើតឡើង ព្រោះអាស្រ័យកាមគុណទាំង ៥ នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខប្រកបដោយអាមិស ។

[៩៣] ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីសុខមិនប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានតែបីតិនិងសុខដែលកើតអំពីវិវេក សម្រេចសម្រាន្តនៅ ។ បេ ។ ព្រោះប្រាសចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតី មានសេចក្តីដឹងខ្លួនផង

សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧប-សម្បជ្ជ វិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ និរាមិសំ សុខំ ។

[៩៤] កតមញ្ច ភិក្ខវេ និរាមិសា និរាមិសតរំ សុខំ ។ យំ ខោ ភិក្ខវេ ខីណាសវស្ស ភិក្ខុនោ រាគា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ ទោសា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ មោហា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ ឧប្បជ្ជតិ សុខំ សោ-មនស្សំ ឥទំ វុច្ចតិ ភិក្ខវេ និរាមិសា និរាមិសតរំ សុខំ ។

សោយសេចក្ដីសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរ-សើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនេះប្រកបដោយឧបេក្ខា មានស្មារតី មានគុណធម៌ជាគ្រឿងនៅសប្បាយ ព្រោះតតិ-យជ្ឈានឯណា បានចូលកាន់តតិយជ្ឈាននោះ សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខមិនប្រកបដោយអាមិស ។

[៩២] ម្នាលភិក្ខុទាំងឡាយ ចុះសុខប្រាសចាកអាមិសដ៏លើសជាងសុខដែលមិនប្រកបដោយអាមិស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខសោមនស្សឯណាដែលកើតឡើងដល់ខីណាសវភិក្ខុ ជាអ្នកពិចារណាឃើញនូវចិត្តដែលផុតស្រឡះចាករាគៈហើយ ជាអ្នកពិចារណាឃើញនូវចិត្តដែលផុតស្រឡះចាកទោសៈហើយ ជាអ្នកពិចារណាឃើញនូវចិត្តដែលផុតស្រឡះចាកមោហៈហើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្ដីសុខប្រាសចាកអាមិស ដ៏លើសជាងសេចក្ដីសុខដែលមិនប្រកបដោយអាមិស ។

៧៩

អដ្ឋសតបរិយាយវគ្គោ

[៩៥] កតមា ច ភិក្ខវេ សាមិសា ឧបេក្ខា ។ បញ្ចិមេ ភិក្ខវេ កាមគុណា ។ កតមេ បញ្ច ។ ចក្ខុ-វិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូប-សញ្ហិតា រជនីយា ។ បេ ។ កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជ-នីយា ។ ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា ។ យា ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ ឧបេក្ខា អយំ វុច្ចតិ ភិក្ខវេ សាមិសា ឧបេក្ខា ។

[៩៦] កតមា ច ភិក្ខវេ និរាមិសា ឧបេក្ខា ។ ឥធ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧប-សម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ និរាមិសា ឧបេក្ខា ។

អដ្ឋសតបរិយាយវគ្គ

[៩៥] ម្នាលភិក្ខុទាំងឡាយ ចុះឧបេក្ខាប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺកាមគុណទាំង ៥ នេះឯង ។ កាមគុណ ៥ តើដូចម្តេច ។ គឺរូបទាំងឡាយដែលគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ។ បេ ។ ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ។ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាឯណាដែលកើតឡើងព្រោះអាស្រ័យនូវកាមគុណទាំង ៥ នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបេក្ខាប្រកបដោយអាមិស ។

[៩៦] ម្នាលភិក្ខុទាំងឡាយ ចុះឧបេក្ខាមិនប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរលត់ទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុនផង បានចូលកាន់ចតុត្ថជ្ឈាន ជាធម្មជាតមិនទុក្ខមិនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបេក្ខាមិនប្រកបដោយអាមិស ។

[៩៧] កតមា ច ភិក្ខវេ និរាមិសា និរាមិសតរា ឧបេក្ខា ។ យា ខោ ភិក្ខវេ ខីណាសវស្ស ភិក្ខុនោ រាគា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ ទោសា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ មោហា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ ឧប្បជ្ជតិ ឧបេក្ខា អយំ វុច្ចតិ ភិក្ខវេ និរាមិសា និរាមិសតរា ឧបេក្ខា ។

[៩៨] កតមោ ច ភិក្ខវេ សាមិសោ វិមោក្ខោ ។ រូបប្បដិសំយុត្តោ វិមោក្ខោ សាមិសោ អរូបប្បដិសំ-យុត្តោ វិមោក្ខោ និរាមិសោ ។

[៩៧] ម្នាលភិក្ខុទាំងឡាយ ចុះឧបេក្ខាប្រាសចាកអាមិសដ៏លើសជាងឧបេក្ខាដែលមិនប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាឯណាដែលកើតឡើងដល់ខីណាសវភិក្ខុ ជាអ្នកពិចារណាឃើញ នូវចិត្តដែលផុតស្រឡះចាករាគៈហើយ ជាអ្នកពិចារណាឃើញ នូវចិត្តដែលផុតស្រឡះចាកទោសៈហើយ ជាអ្នកពិចារណាឃើញ នូវចិត្តដែលផុតស្រឡះចាកមោហៈហើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបេក្ខាប្រាសចាកអាមិសដ៏លើសជាងឧបេក្ខាដែលមិនប្រកបដោយអាមិស ។

[៩៨] ម្នាលភិក្ខុទាំងឡាយ ចុះវិមោក្ខប្រកបដោយអាមិស តើដូចម្តេច ។ វិមោក្ខប្រកបដោយរូប ឈ្មោះថា វិមោក្ខប្រកបដោយអាមិស វិមោក្ខប្រកបដោយអរូប ឈ្មោះថា វិមោក្ខមិនប្រកបដោយអាមិស ។

៨១

អដ្ឋសតបរិយាយវគ្គោ

[៩៩] កតមោ ច ភិក្ខវេ និរាមិសា និរាមិសតរោ វិមោក្ខោ ។ យោ ខោ ភិក្ខវេ ខីណាសវស្ស ភិក្ខុនោ រាគា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ ទោសា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ មោហា ចិត្តំ វិមុត្តំ បច្ចវេក្ខតោ ឧប្បជ្ជតិ វិមោក្ខោ អយំ វុច្ចតិ ភិក្ខវេ និរាមិសា និរាមិសតរោ វិមោក្ខោតិ ។ ឯកាទសមំ ។

អដ្ឋសតបរិយាយវគ្គោ តតិយោ ។

## តស្សុទ្ទានំ

សិវកអដ្ឋសតំ ភិក្ខុ
បុព្វេ ញាណញ្ច ភិក្ខុនា
សមណព្រាហ្មណា តីណិ
សុទ្ធិកំ ច និរាមិសន្តិ ។

វេទនាសំយុត្តំ និដ្ឋិតំ ។

[៩៩] ម្នាលភិក្ខុទាំងឡាយ វិមោក្ខប្រាសចាកអាមិសដ៏លើសជាង វិមោក្ខដែលមិនប្រកបដោយអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វិមោក្ខឯណាដែលកើតឡើងដល់ខីណាសវភិក្ខុ ជាអ្នកពិចារណាឃើញ នូវចិត្តដែលផុតស្រឡះចាករាគៈ ជាអ្នកពិចារណាឃើញ នូវចិត្តដែលផុតស្រឡះចាកទោសៈ ជាអ្នកពិចារណាឃើញ នូវចិត្តដែលផុតស្រឡះចាកមោហៈ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិមោក្ខប្រាសចាកអាមិសដ៏លើសជាងវិមោក្ខដែលមិនប្រកបដោយអាមិស ។ ចប់សូត្រទី ១១ ។

ចប់ អដ្ឋសតបរិយាយវគ្គទី ៣ ។

## ឧទ្ទាននៃអដ្ឋសតបរិយាយវគ្គនោះគឺ

ពោលអំពីសិវកបរិព្វាជក ១ អំពីព្រះអង្គទ្រង់សំដែងធម្មបរិយាយមានមួយរយប្រាំបី ១ អំពីភិក្ខុមួយរូបទូលសួរព្រះអង្គ ១ អំពីកាលមុនដែលព្រះអង្គត្រាស់ដឹង ១ អំពីញាណកើតឡើងដល់ព្រះអង្គ ១ អំពីសម្ពហុលភិក្ខុ ១ អំពីសមណព្រាហ្មណ៍មាន ៣ លើក អំពីវេទនាសុទ្ធ ១ អំពីបីតិប្រកបដោយអាមិសនិងប្រាសចាកអាមិស ១ ។

ចប់ វេទនាសំយុត្ត ។

# មាតុគ្គាមសំយុត្តំ

## បេយ្យាលវគ្គោ

[១០០] បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ មាតុគ្គាមោ ឯកន្តអមនាបោ ហោតិ បុរិសស្ស ។ កតមេហិ បញ្ចហិ ។ ន ច រូបវា ហោតិ ន ច ភោគវា ហោតិ ន ច សីលវា ហោតិ អលសោ ច ហោតិ បជញ្ចស្ស ន លភតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ មាតុគ្គាមោ ឯកន្តអមនាបោ ហោតិ បុរិសស្ស ។

[១០១] បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ មាតុគ្គាមោ ឯកន្តមនាបោ ហោតិ បុរិសស្ស ។ កតមេហិ បញ្ចហិ ។ រូបវា ច ហោតិ ភោគវា ច ហោតិ សីលវា ច ហោតិ ទក្ខោ ច ហោតិ អនលសោ បជញ្ចស្ស លភតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ មាតុគ្គាមោ ឯកន្តមនាបោ ហោតិ បុរិសស្សាតិ ។ បឋមំ ។

# មាតុគ្គាមសំយុត្ត

## បេយ្យាលវគ្គ

[១០០] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយអង្គ ៥ មិនជាទីពេញចិត្តរបស់បុរសដោយពិត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺមាតុគ្រាមមិនបានរូប ១ មិនមានភោគៈ ១ មិនមានសីលាចារ ១ ជាអ្នកខ្ជិលច្រអូស ១ មិនមានកូនជាទីញ៉ាំងវង្សត្រកូលនៃបុរសនោះឲ្យតម្កល់នៅ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយអង្គ ៥ នេះឯង មិនជាទីពេញចិត្តរបស់បុរសដោយពិត ។

[១០១] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយអង្គ ៥ ជាទីពេញចិត្តរបស់បុរសដោយពិត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺមាតុគ្រាមបានរូប ១ មានភោគៈ ១ ជាអ្នកមានសីលាចារ ១ ជាអ្នកវាងវៃមិនខ្ជិលច្រអូស ១ មានកូនជាទីញ៉ាំងវង្សត្រកូលរបស់បុរសនោះឲ្យតម្កល់នៅ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយអង្គ ៥ នេះឯង ជាទីពេញចិត្តរបស់បុរសដោយពិត ។ ចប់សូត្រទី ១ ។

៨៣

## បេយ្យាលវគ្គោ

[១០២] បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ បុរិសោ ឯកន្តអមនាបោ ហោតិ មាតុគ្គាមស្ស ។ កតមេហិ បញ្ចហិ ។ ន ច រូបវា ហោតិ ន ច ភោគវា ហោតិ ន ច សីលវា ហោតិ អលសោ ច ហោតិ បជញ្ចស្ស ន លភតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ បុរិសោ ឯកន្តអមនាបោ ហោតិ មាតុគ្គាមស្ស ។

[១០៣] បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ បុរិសោ ឯកន្តមនាបោ ហោតិ មាតុគ្គាមស្ស ។ កតមេហិ បញ្ចហិ ។ រូបវា ច ហោតិ ភោគវា ច ហោតិ សីលវា ច ហោតិ ទក្ខោ ច ហោតិ អនលសោ បជញ្ចស្ស លភតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ សមន្នាគតោ បុរិសោ ឯកន្តមនាបោ ហោតិ មាតុគ្គាមស្សាតិ ។ ទុតិយំ ។

បេយ្យាលវគ្គ

[១០២] ម្នាលភិក្ខុទាំងឡាយ បុរសប្រកបដោយអង្គ ៥ មិនជាទីពេញចិត្តរបស់មាតុគ្រាមដោយពិត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺបុរសមិនបានរូប ១ មិនមានភោគៈ ១ មិនមានសីលាចារ ១ ខ្ជិលច្រអូស ១ មិនមានកូនជាទីញុំាងវង្សត្រកូលនៃបុរសនោះឲ្យតម្កល់នៅ ១ ។ ម្នាលភិក្ខុទាំងឡាយ បុរសប្រកបដោយអង្គ ៥ នេះឯង មិនជាទីពេញចិត្តរបស់មាតុគ្រាមដោយពិត ។

[១០៣] ម្នាលភិក្ខុទាំងឡាយ បុរសប្រកបដោយអង្គ ៥ ជាទីពេញចិត្តរបស់មាតុគ្រាមដោយពិត ។ អង្គ ៥ គឺអ្វីខ្លះ ។ គឺបុរសបានរូប ១ មានភោគៈ ១ មានសីលាចារ ១ ជាអ្នកវាងវៃមិនខ្ជិលច្រអូស ១ មានកូនជាទីញុំាងវង្សត្រកូលនៃបុរសនោះឲ្យតម្កល់នៅ ១ ។ ម្នាលភិក្ខុទាំងឡាយ បុរសប្រកបដោយអង្គ ៥ នេះឯង ជាទីពេញចិត្តរបស់មាតុ-គ្រាមដោយពិត ។ ចប់សូត្រទី ២ ។

[១០៤] បញ្ចិមានិ ភិក្ខវេ មាតុគ្គាមស្ស អាវេណិ-
កានិ ទុក្ខានិ យានិ មាតុគ្គាមោ បច្ចនុភោតិ អញ្ញត្រេវ
បុរិសេហិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ មាតុគ្គា-
មោ ទហរោវ សមានោ បតិកុលំ គច្ឆតិ ញាតកេហិ
វិនា ហោតិ ។ ឥទំ ភិក្ខវេ មាតុគ្គាមស្ស បឋមំ អាវេ-
ណិកំ ទុក្ខំ យំ មាតុគ្គាមោ បច្ចនុភោតិ អញ្ញត្រេវ
បុរិសេហិ ។

[១០៥] បុន ចបរំ ភិក្ខវេ មាតុគ្គាមោ ឧតុនី
ហោតិ ។ ឥទំ ភិក្ខវេ មាតុគ្គាមស្ស ទុតិយំ អាវេណិកំ
ទុក្ខំ យំ មាតុគ្គាមោ បច្ចនុភោតិ អញ្ញត្រេវ បុរិសេហិ ។

[១០៦] បុន ចបរំ ភិក្ខវេ មាតុគ្គាមោ គព្ភិនី
ហោតិ ។ ឥទំ ភិក្ខវេ មាតុគ្គាមស្ស តតិយំ អាវេណិ-
កំ ទុក្ខំ យំ មាតុគ្គាមោ បច្ចនុភោតិ អញ្ញត្រេវ
បុរិសេហិ ។

[១០៤] ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខដោយឡែករបស់មាតុ-គ្រាមនេះមាន ៥ យ៉ាង ដែលមាតុគ្រាមតែងទទួលរងផ្សេងអំពីបុរស ។ ទុក្ខ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ នៅក្មេងទៅកាន់ត្រកូលប្តី ប្រាសចាកញាតិទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខដោយឡែកទី ១ របស់មាតុគ្រាម ដែលមាតុគ្រាមទទួលរងផ្សេងអំពីបុរសទាំងឡាយ ។

[១០៥] ម្នាលភិក្ខុទាំងឡាយ មួយទៀត មាតុគ្រាមមានរដូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីទុក្ខដោយឡែកទី ២ របស់មាតុ-គ្រាម ដែលមាតុគ្រាមទទួលរងផ្សេងអំពីបុរសទាំងឡាយ ។

[១០៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត មាតុគ្រាមមានគភ៌ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីទុក្ខដោយឡែកទី ៣ របស់មាតុ-គ្រាម ដែលមាតុគ្រាមទទួលរងផ្សេងអំពីបុរសទាំងឡាយ ។

៨៤

## បេយ្យាលវគ្គោ

[១០៧] បុន ចបរំ ភិក្ខវេ មាតុគ្គាមោ វិជាយតិ ។ ឥទំ ភិក្ខវេ មាតុគ្គាមស្ស ចតុត្ថំ អាវេណិកំ ទុក្ខំ យំ មាតុគ្គាមោ បច្ចនុភោតិ អញ្ញត្រេវ បុរិសេហិ ។

[១០៨] បុន ចបរំ ភិក្ខវេ មាតុគ្គាមោ បុរិសស្ស ចារិចរិយំ ឧបេតិ ។ ឥទំ ខោ ភិក្ខវេ មាតុគ្គាមស្ស បញ្ចមំ អាវេណិកំ ទុក្ខំ យំ មាតុគ្គាមោ បច្ចនុភោតិ អញ្ញត្រេវ បុរិសេហិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មាតុគ្គាមស្ស អាវេណិកានិ ទុក្ខានិ យានិ មាតុគ្គាមោ បច្ចនុភោតិ អញ្ញត្រេវ បុរិសេហីតិ ។ តតិយំ ។

[១០៩] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ យេភុយ្យេន កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ មាតុគ្គាមោ បុព្វណ្ហសមយំ មច្ឆេរ-

បេយ្យាលវគ្គ

[១០៧] ម្នាលភិក្ខុទាំងឡាយ មួយទៀត មាតុគ្រាមសម្រាលកូន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីទុក្ខដោយឡែកទី ៤ របស់មាតុគ្រាម ដែលមាតុគ្រាមទទួលរងផ្សេងអំពីបុរសទាំងឡាយ ។

[១០៨] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត មាតុគ្រាមចូលទៅបម្រើបុរស ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា សេចក្តីទុក្ខដោយឡែកទី ៥ របស់មាតុគ្រាម ដែលមាតុគ្រាមទទួលរងផ្សេងអំពីបុរសទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថាសេចក្តីទុក្ខដោយឡែក ៥ យ៉ាងរបស់មាតុគ្រាម ដែលមាតុគ្រាមទទួលរងផ្សេងអំពីបុរសទាំងឡាយ ។ ចប់សូត្រទី ៣ ។

[១០៩] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៣ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ ច្រើនតែទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺមាតុគ្រាមក្នុងលោកនេះ មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់គ្រប

មលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ មជ្ឈន្តិ-
កសមយំ ឥស្សាបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈា-
វសតិ សាយណ្ហសមយំ កាមរាគបរិយុដ្ឋិតេន ចេតសា
អគារំ អជ្ឈាវសតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ
សមន្នាគតោ មាតុគ្គាមោ យេភុយ្យេន កាយស្ស ភេ-
ទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧ-
បបជ្ជតីតិ ។ ចតុត្ថំ ។

[១១០] អថខោ អាយស្មា អនុរុទ្ធោ យេន ភគវា
តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អា-
យស្មា អនុរុទ្ធោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ
មាតុគ្គាមំ បស្សាមិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-
មានុសកេន កាយស្ស ភេទា បរំ មរណា អបាយំ
ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តំ ។ កតីហិ នុ ខោ
ភន្តេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស
ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ
ឧបបជ្ជតីតិ ។

សង្កត់ក្នុងបុព្វណ្ហសម័យគ្រប់គ្រងផ្ទះ ១ មានចិត្តត្រូវសេចក្តីច្រណែនគ្រប-សង្កត់ក្នុងមជ្ឈន្តិកសម័យ[១] គ្រប់គ្រងផ្ទះ ១ មានចិត្តត្រូវកាមរាគគ្របសង្កត់ក្នុងសាយណ្ហសម័យគ្រប់គ្រងផ្ទះ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតុ-គ្រាមប្រកបដោយធម៌ ៣ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ ច្រើនតែទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ចប់សូត្រទី ៤ ។

[១១០] គ្រានោះ ព្រះអនុរុទ្ធមានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ លុះព្រះអនុរុទ្ធមានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធកន្លងបង់ចក្ខុរបស់មនុស្សធម្មតានូវមាតុគ្រាមក្នុងលោកនេះ កាលបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ បពិត្រព្រះអង្គដ៏ចម្រើន មាតុ-គ្រាមប្រកបដោយធម៌ប៉ុន្មានយ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។

១ អដ្ឋកថា ថា មាតុគ្រាមតែដល់វេលាថ្ងៃត្រង់ហើយ ច្រើនមានសេចក្តីក្រោធគ្របសង្កត់ ហើយរករឿងឈ្លោះទាស់ទែងនឹងគេ បើរករឿងឈ្លោះក្នុងផ្ទះខ្លួនមិនបានទេ ក៏ដើរទៅរករឿងឈ្លោះនឹងអ្នកផ្ទះជិតខាង ពុំនោះសោតគយគន់រកហេតុដែលប្តីឈឺឬអង្គុយមិនត្រូវទំនង(នាំឲ្យកើតចិត្តប្រច័ណ្ឌប្តី) ។

## ៨៧

### បេយ្យាលវគ្គោ

[១១១] បញ្ចហិ ខោ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ កោធនោ ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។ បញ្ចមំ ។

[១១២] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ ឧបនាហី ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។ ឆដ្ឋំ ។

## បេយ្យាលវគ្គ

[១១១] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ច្រើនក្រោធ ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ចប់សូត្រទី ៥ ។

[១១២] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ មានគំនុំគុំគួន ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ចប់សូត្រទី ៦ ។

[១១៣] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ ឥស្សុកី ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។ សត្តមំ ។

[១១៤] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ មច្ឆរី ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ។ បេ ។ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។ អដ្ឋមំ ។

[១១៣] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ មានសេចក្តីប្រណែន ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ចប់សូត្រទី ៧ ។

[១១៤] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ មានសេចក្តីកំណាញ់ ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយ ។ បេ ។ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ចប់សូត្រទី ៨ ។

បេយ្យាលវគ្គោ

[១១៥] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ ។ បេ ។ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ អតិចារី ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ ។ បេ ។ ឧបបជ្ជតីតិ ។ នវមំ ។

[១១៦] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ។ បេ ។ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ ទុស្សីលោ ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ។ បេ ។ និរយំ ឧបបជ្ជតីតិ ។ ទសមំ ។

## បេយ្យាលវគ្គ

[១១៥] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង ។ បេ ។ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ប្រព្រឹត្តក្បត់ចិត្តប្តី ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង ។ បេ ។ តែងទៅកើត ។ ចប់សូត្រទី ៩ ។

[១១៦] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយ ។ បេ ។ តែងទៅកើតក្នុងនរក ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ទ្រុស្តសីល ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយ ។ បេ ។ តែងទៅកើតក្នុងនរក ។ ចប់សូត្រទី ១០ ។

[១១៧] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ ។ បេ ។ និរយំ ឧបបជ្ជតីតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ អស្សុតោ ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ ។ បេ ។ និរយំ ឧបបជ្ជតីតិ ។ ឯកាទសមំ ។

[១១៨] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ ។ បេ ។ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ កុសិតោ ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ ស-មន្នាគតោ មាតុគ្គាមោ កាយស្ស ។ បេ ។ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។ ទ្វាទសមំ ។

[១១៧] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង ។ បេ ។ តែងទៅកើតក្នុងនរក ។ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ មិនបានចេះដឹង ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង ។ បេ ។ តែងទៅកើតក្នុងនរក ។ ចប់សូត្រទី ១១ ។

[១១៨] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង ។ បេ ។ តែងទៅកើតក្នុងនរក ។ ប្រកបដោយធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុ-គ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ជាអ្នកខ្ជិលច្រអូស ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយ ។ បេ ។ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ចប់សូត្រទី ១២ ។

៩១

## បេយ្យាលវគ្គោ

[១១៩] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ។ បេ ។ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ច ហោតិ អហិរិកោ ច ហោតិ អនោត្តប្បី ច ហោតិ មុដ្ឋស្សតិ ច ហោតិ ទុប្បញ្ញោ ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ។ បេ ។ និរយំ ឧបបជ្ជតីតិ ។ តេរសមំ ។

[១២០] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ។ បេ ។ និរយំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតី ច ហោតិ អ-ទិន្នាទាយី ច ហោតិ កាមេសុ មិច្ឆាចារី ច ហោតិ មុសាវាទី ច ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ ស-មន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។ ចុទ្ទសមំ ។

បេយ្យាលវគ្គ

[១១៩] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយ ។ បេ ។ តែងទៅកើតក្នុងនរក ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មិនមានសទ្ធា ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ភ្លេចស្មារតី ១ មិនមានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយ ។ បេ ។ តែងទៅកើតក្នុងនរក ។ ចប់សូត្រទី ១៣ ។

[១២០] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយ ។ បេ ។ តែងទៅកើតក្នុងនរក ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) ប្រព្រឹត្តបាណាតិបាត ១ ប្រព្រឹត្តអទិន្នាទាន ១ ប្រព្រឹត្តកាមេសុមិច្ឆាចារ ១ ប្រព្រឹត្តមុសាវាទ ១ ប្រព្រឹត្តសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ចប់សូត្រទី ១៤ ។

[១២១] អថខោ អាយស្មា អនុរុទ្ធោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អនុរុទ្ធោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ មាតុគ្គាមំ បស្សាមិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ កតីហិ នុ ខោ ភន្តេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតីតិ ។ បញ្ចហិ ខោ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ សទ្ធោ ច ហោតិ ហិរិមា ច ហោតិ ឱត្តប្បី ច ហោតិ អក្កោធនោ ច ហោតិ បញ្ញវា ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតីតិ ។

[១២១] គ្រានោះឯង ព្រះអនុរុទ្ធមានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ លុះព្រះអនុរុទ្ធមានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា នូវមាតុគ្រាមក្នុងលោកនេះ កាលបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បពិត្រព្រះអង្គដ៏ចម្រើន មាតុ-គ្រាមប្រកបដោយធម៌ប៉ុន្មានយ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មានសទ្ធា ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ មិនក្រោធ ១ មានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

៩៣

## បេយ្យាលវគ្គោ

[១២២] បញ្ចហិ អង្គេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ សទ្ធោ ច ហោតិ ហិរិមា ច ហោតិ ឱត្តប្បី ច ហោតិ អនុបនាហី ច ហោតិ បញ្ញវា ច ហោតិ ។ ឥមេហិ ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតីតិ ។

[១២៣] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។ សទ្ធោ ច ហោតិ ហិរិមា ច ហោតិ ឱត្តប្បី ច ហោតិ អនិស្សុកី ច ហោតិ បញ្ញវា ច ហោតិ ។ បេ ។

[១២៤] អមច្ឆរី ច ហោតិ បញ្ញវា ច ហោតិ ។ បេ ។ អនតិចារី ច ហោតិ បញ្ញវា ច ហោតិ ។ បេ ។ សីលវា ច ហោតិ បញ្ញវា ច ហោតិ ។ បេ ។ ពហុស្សុតោ ច ហោតិ បញ្ញវា ច ហោតិ ។ បេ ។

បេយ្យាលវគ្គ

[១២២] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មានសទ្ធា ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ មិនចងគំនុំ ១ មានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

[១២៣] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) មានសទ្ធា ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ មិនមានសេចក្តីច្រណែន ១ មានបញ្ញា ១ ។ បេ ។

[១២៤] (មាតុគ្រាម) មិនមានសេចក្តីកំណាញ់ ១ មានបញ្ញា ១ ។ បេ ។ មិនប្រព្រឹត្តក្បត់ចិត្តប្តី ១ មានបញ្ញា ១ ។ បេ ។ មានសីល ១ មានបញ្ញា ១ ។ បេ ។ ជាអ្នកចេះដឹងច្រើន ១ មានបញ្ញា ១ ។ បេ ។

អារទ្ធវីរិយោ ច ហោតិ បញ្ញវា ច ហោតិ ។ បេ ។ ឧ-
បដ្ឋិតស្សតិ ច ហោតិ បញ្ញវា ច ហោតិ ។ ឥមេហិ
ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ
កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ
ឧបបជ្ជតីតិ ។ (ឥមេ អដ្ឋ សុត្តន្តា សង្ខិត្តា) ។ បេ ។

[១២៥] បញ្ចហិ អនុរុទ្ធ ធម្មេហិ សមន្នាគតោ
មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា សុគតឹ
សគ្គំ លោកំ ឧបបជ្ជតិ ។ កតមេហិ បញ្ចហិ ។
បាណាតិបាតា បដិវិរតោ ច ហោតិ អទិន្នាទានា បដិ-
វិរតោ ច ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ច
ហោតិ មុសាវាទា បដិវិរតោ ច ហោតិ សុរាមេរ-
យមជ្ជប្បមាទដ្ឋានា បដិវិរតោ ច ហោតិ ។ ឥមេហិ
ខោ អនុរុទ្ធ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គា-
មោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ
លោកំ ឧបបជ្ជតីតិ ។

បេយ្យាលវគ្គោ បឋមោ សមត្តោ ។

ប្រារព្ធសេចក្តីព្យាយាម ១ មានបញ្ញា ១ ។ បេ ។ មានស្មារតីតម្កល់ខ្ជាប់ ១ មានបញ្ញា ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ (សូត្រទាំង ៨ នេះជាសេចក្តីសង្ខេប) ។ បេ ។

[១២៥] ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ (មាតុគ្រាម) ជាអ្នកវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

ចប់ បេយ្យាលវគ្គទី ១ ។

៩៨

បេយ្យាលវគ្គោ

# តស្សុទ្ទានំ

ទ្វេ មជាថា អមជាថា ច

អាវេណិកា តីហិ អនុរុទ្ធោ

កោងដោ ឧបជាហី ច

ឥស្សុកី មច្ឆរេជ ច ។

អតិចារី ច ទុស្សីលោ

អប្បស្សុតោ ច កុសិតោ

មុដ្ឋស្សតិ បញ្ញវេរំ

កណ្ហបក្ខេ បកាសិតោ ។

អនុរុទ្ធោ អក្កោងដោ

អនុបជាហី អនិស្សុកី

អមច្ឆរី អនតិចារី

សីលវា ច ពហុស្សុតោ

វិរិយសតិ បញ្ញសីលា ច

សុក្កបក្ខេ បកាសិតោតិ ។

បេយ្យាលវគ្គ

# ឧទ្ទាននៃបេយ្យាលវគ្គនោះគឺ

និយាយអំពីមាតុគ្រាមជាទីពេញចិត្ត និងមិនជាទីពេញចិត្ត របស់បុរស ២ លើក អំពីអាវេណិកទុក្ខ ១ អំពីមាតុគ្រាមប្រកបដោយធម៌ ៣ យ៉ាង ១ អំពីព្រះអនុរុទ្ធ ១ អំពីមាតុគ្រាមក្រោធ ១ ចងគំនុំ ១ ប្រណែន ១ កំណាញ់ ១ ។ អំពីមាតុគ្រាមប្រព្រឹត្តក្បត់ចិត្តប្តី ១ ទ្រុស្តសីល ១ ជាអ្នកមិនចេះដឹង ១ មានសេចក្តីខ្ជិលច្រអូស ១ ភ្លេចស្មារតី ១ វេរា ៥ យ៉ាង ១ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយក្នុងកណ្ហបក្ខ (ចំណែកខ្មៅ) ចំពោះព្រះអនុរុទ្ធ ។ អំពីមាតុគ្រាមមិនក្រោធ ១ មិនមានការចងគំនុំ ១ មិនមានសេចក្តីប្រណែន ១ មិនមានសេចក្តីកំណាញ់ ១ មិនប្រព្រឹត្តក្បត់ចិត្តប្តី ១ មានសីល ១ ជាអ្នកចេះដឹងច្រើន ១ មានសេចក្តីព្យាយាម ១ មានសតិ ១ មានសីលប្រាំ ១ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយក្នុងសុក្កបក្ខ (ចំណែកស) ចំពោះព្រះអនុរុទ្ធ ។

# មាតុគ្គាមពលវគ្គោ

[១៦៦] បញ្ចិមានិ ភិក្ខវេ មាតុគ្គាមស្ស ពលានិ ។ កតមានិ បញ្ច ។ រូបពលំ ភោគពលំ ញាតិពលំ បុត្តពលំ សីលពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មាតុគ្គាមស្ស ពលានិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ពលេហិ សមន្នាគតោ មាតុគ្គាមោ វិសារទោ អគារំ អជ្ឈាវសតីតិ ។ បឋមំ ។

[១៦៧] បញ្ចិមានិ ភិក្ខវេ មាតុគ្គាមស្ស ពលានិ ។ កតមានិ បញ្ច ។ រូបពលំ ភោគពលំ ញាតិពលំ បុត្តពលំ សីលពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មាតុគ្គាមស្ស ពលានិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ពលេហិ សមន្នាគតោ មាតុគ្គាមោ សាមិកំ បសយ្ហ អគារំ អជ្ឈាវសតីតិ ។ ទុតិយំ ។

# មាតុគ្គាមពលវគ្គ

[១២៦] ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាមនេះ មាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្លាំងរូប ១ កម្លាំងភោគៈ ១ កម្លាំងញាតិ ១ កម្លាំងកូន ១ កម្លាំងសីល ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាម ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុ-គ្រាមប្រកបដោយកម្លាំងទាំង ៥ យ៉ាងនេះឯង ជាអ្នកក្លាហាននៅគ្រប់គ្រងផ្ទះ ។ ចប់សូត្រទី ១ ។

[១២៧] ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាមនេះ មាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្លាំងរូប ១ កម្លាំងភោគៈ ១ កម្លាំងញាតិ ១ កម្លាំងកូន ១ កម្លាំងសីល ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាម ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ប្រកបដោយកម្លាំងទាំង ៥ នេះឯង តែងបង្រ្កបប្តីនៅគ្រប់គ្រងផ្ទះ ។ ចប់សូត្រទី ២ ។

៩៧

## មាតុគ្គាមពលវគ្គោ

[១២៨] បញ្ចិមានិ ភិក្ខវេ មាតុគ្គាមស្ស ពលានិ ។ កតមានិ បញ្ច ។ រូបពលំ ភោគពលំ ញាតិពលំ បុត្តពលំ សីលពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មាតុគ្គាមស្ស ពលានិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ពលេហិ សមន្នាគតោ មាតុគ្គាមោ សាមិកំ អភិភុយ្យ វត្តតិ ។ ឯកេន ច ខោ ភិក្ខវេ ពលេន សមន្នាគតោ បុរិសោ មាតុគ្គាមំ អភិភុយ្យ វត្តតិ ។ កតមេន ឯកេន ពលេន ។ ឥស្សរិយពលេន អភិភូតំ[១] មាតុគ្គាមំ នេវ រូបពលំ តាយតិ ន ភោគពលំ តាយតិ ន ញាតិពលំ តាយតិ ន បុត្តពលំ តាយតិ ន សីលពលំ តាយតីតិ ។ តតិយំ ។

[១២៩] បញ្ចិមានិ ភិក្ខវេ មាតុគ្គាមស្ស ពលានិ ។ កតមានិ បញ្ច ។ រូបពលំ ភោគពលំ ញាតិពលំ បុត្តពលំ សីលពលំ ។

---
១ ឱ. ភិក្ខវេ ។

## មាតុគ្គាមពលវគ្គ

[១២៨] ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាមនេះ មាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្លាំងរូប ១ កម្លាំងភោគៈ ១ កម្លាំងញាតិ ១ កម្លាំងកូន ១ កម្លាំងសីល ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាម ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុ-គ្រាមប្រកបដោយកម្លាំង ៥ យ៉ាងនេះឯង តែងគ្របសង្កត់ប្តី ។ ម្នាលភិក្ខុទាំងឡាយ បុរសប្រកបដោយកម្លាំងតែមួយប៉ុណ្ណោះ រមែងគ្របសង្កត់មាតុគ្រាមបាន ។ កម្លាំងមួយគឺអ្វី ។ គឺកម្លាំងឥស្សរិយៈ គ្របសង្កត់មាតុគ្រាមបាន មិនបាច់ពឹងកម្លាំងរូប មិនបាច់ពឹងកម្លាំងភោគៈ មិនបាច់ពឹងកម្លាំងញាតិ មិនបាច់ពឹងកម្លាំងកូន មិនបាច់ពឹងកម្លាំងសីល ឡើយ ។ ចប់សូត្រទី ៣ ។

[១២៩] ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាមនេះ មាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្លាំងរូប ១ កម្លាំងភោគៈ ១ កម្លាំងញាតិ ១ កម្លាំងកូន ១ កម្លាំងសីល ១ ។

[១៣០] រូបពលេន ច ខោ ភិក្ខវេ មាតុគ្គាមោ សមន្នាគតោ ហោតិ ន ច ភោគពលេន ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ ។ យតោ ច ខោ ភិក្ខវេ មាតុគ្គាមោ រូបពលេន ច សមន្នាគតោ ហោតិ ភោគពលេន ច ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ រូបពលេន ច ខោ ភិក្ខវេ មាតុគ្គាមោ សមន្នាគតោ ហោតិ ភោគពលេន ច ន ច ញាតិពលេន ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ ។ យតោ ច ខោ ភិក្ខវេ មាតុគ្គាមោ រូបពលេន សមន្នាគតោ ហោតិ ភោគពលេន ច ញាតិពលេន ច ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ រូបពលេន ច ភិក្ខវេ មាតុគ្គាមោ សមន្នាគតោ ហោតិ ភោគពលេន ច ញាតិពលេន ច ន ច បុត្តពលេន ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ ។ យតោ ច ខោ ភិក្ខវេ មាតុគ្គាមោ រូបពលេន ច សមន្នាគតោ ហោតិ ភោ-គពលេន ច ញាតិពលេន ច បុត្តពលេន ច ឯវំ

[១៣០] ម្នាលភិក្ខុទាំងឡាយ (បើ) មាតុគ្រាមប្រកបដោយកម្លាំងរូបតែម្យ៉ាងប៉ុណ្ណោះ មិនប្រកបដោយកម្លាំងភោគៈទេ កាលបើយ៉ាងនេះ មាតុគ្រាមនោះ ឈ្មោះថាមិនបរិបូណ៌ដោយអង្គនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែមាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង កាលបើយ៉ាងនេះ ទើបមាតុគ្រាមនោះ ឈ្មោះថាបរិបូណ៌ដោយអង្គនោះបាន ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង ពិតមែនហើយ ប៉ុន្តែមិនប្រកបដោយកម្លាំងញាតិ កាលបើយ៉ាងនេះ មាតុគ្រាមនោះ ឈ្មោះថាមិនទាន់ពេញលេញដោយអង្គនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែមាតុគ្រាមប្រកបដោយកម្លាំងរូបផង ដោយកម្លាំងភោគៈផង ដោយកម្លាំងញាតិផង កាលបើយ៉ាងនេះ ទើបមាតុគ្រាមនោះ ឈ្មោះថាពេញលេញដោយអង្គនោះបាន ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង កម្លាំងញាតិផង ពិតមែនហើយ ប៉ុន្តែមិនប្រកបដោយកម្លាំងកូន កាលបើយ៉ាងនេះ មាតុគ្រាមនោះ ឈ្មោះថាមិនពេញលេញដោយអង្គនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែមាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង កម្លាំងញាតិផង កម្លាំងកូនផង កាលបើយ៉ាងនេះ

សោ តេន អង្គេន បរិបូរោ ហោតិ ។ រូបពលេន ច ភិក្ខវេ មាតុគ្គាមោ សមន្នាគតោ ហោតិ ភោគព-លេន ច ញាតិពលេន ច បុត្តពលេន ច ន ច សី-លពលេន ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ ។ យតោ ច ខោ ភិក្ខវេ មាតុគ្គាមោ រូបពលេន ច សមន្នាគតោ ហោតិ ភោគពលេន ច ញាតិពលេន ច បុត្តពលេន ច សីលពលេន ច ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មាតុគ្គាមស្ស ពលានីតិ ។ ចតុត្ថំ ។

[១៣១] បញ្ចិមានិ ភិក្ខវេ មាតុគ្គាមស្ស ពលានិ ។ កតមានិ បញ្ច ។ រូបពលំ ភោគពលំ ញាតិពលំ បុត្តពលំ សីលពលំ ។

ទើបមាតុគ្រាមនោះ ឈ្មោះថាពេញលេញដោយអង្គនោះបាន ។ ម្នាល ភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង កម្លាំងញាតិផង កម្លាំងកូនផង ពិតមែនហើយ ប៉ុន្តែមិនប្រកបដោយ កម្លាំងសីល កាលបើយ៉ាងនេះ មាតុគ្រាមនោះឈ្មោះថាមិនពេញលេញ ដោយអង្គនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែមាតុគ្រាមប្រកប ដោយកម្លាំងរូបផង កម្លាំងភោគៈផង កម្លាំងញាតិផង កម្លាំងកូនផង កម្លាំងសីលផង កាលបើយ៉ាងនេះ ទើបមាតុគ្រាមនោះឈ្មោះថាពេញ លេញដោយអង្គនោះបាន ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុ-គ្រាមមាន ៥ យ៉ាងនេះឯង ។ ចប់សូត្រទី ៤ ។

[១៣១] ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាមនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្លាំងរូប ១ កម្លាំងភោគៈ ១ កម្លាំងញាតិ ១ កម្លាំងកូន ១ កម្លាំងសីល ១ ។

[១៣២] រូបពលេន ច ភិក្ខវេ មាតុគ្គាមោ ស-
មន្នាគតោ ហោតិ ន ច សីលពលេន ឋានសេវេ ជំ
កុលេ ន វាសេន្តិ ។ រូបពលេន ច ភិក្ខវេ មាតុគ្គាមោ
សមន្នាគតោ ហោតិ ភោគពលេន ច ន ច សីលព-
លេន ឋានសេវេ ជំ កុលេ ន វាសេន្តិ ។ រូបពលេន ច
ភិក្ខវេ មាតុគ្គាមោ សមន្នាគតោ ហោតិ ភោគពលេន
ច ញាតិពលេន ច ន ច សីលពលេន ឋានសេវេ ជំ
កុលេ ន វាសេន្តិ ។ រូបពលេន ច ភិក្ខវេ មាតុគ្គាមោ
សមន្នាគតោ ហោតិ ភោគពលេន ច ញាតិពលេន ច
បុត្តពលេន ច ន ច សីលពលេន ឋានសេវេ ជំ កុ-
លេ ន វាសេន្តិ ។ យតោ ច ខោ ភិក្ខវេ មាតុគ្គាមោ
រូបពលេន សមន្នាគតោ ហោតិ ភោគពលេន ច ញា-
តិពលេន ច បុត្តពលេន ច សីលពលេន ច វាសេវេ
ជំ កុលេ ន ឋានសេន្តិ ។ សីលពលេន ច ភិក្ខវេ
មាតុគ្គាមោ សមន្នាគតោ ហោតិ ន ច រូបពលេន

[១៣២] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងរូប ពិតមែនហើយ ប៉ុន្តែមិនប្រកបដោយកម្លាំងសីល ញាតិទាំងឡាយរមែងឲ្យមាតុគ្រាមនោះវិនាសចេញ មិនឲ្យនៅក្នុងត្រកូលឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង ពិតមែនហើយ ប៉ុន្តែមិនប្រកបដោយកម្លាំងសីល ញាតិទាំងឡាយរមែងឲ្យមាតុគ្រាមនោះវិនាសចេញ មិនឲ្យនៅក្នុងត្រកូលឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង កម្លាំងញាតិផង ពិតមែនហើយ ប៉ុន្តែមិនប្រកបដោយកម្លាំងសីល ញាតិទាំងឡាយ រមែងឲ្យមាតុគ្រាមនោះវិនាសចេញ មិនឲ្យនៅក្នុងត្រកូលឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង កម្លាំងញាតិផង កម្លាំងកូនផង ពិតមែនហើយ ប៉ុន្តែមិនប្រកបដោយកម្លាំងសីល ញាតិទាំងឡាយ រមែងឲ្យមាតុគ្រាមនោះវិនាសចេញ មិនឲ្យនៅក្នុងត្រកូលឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែមាតុគ្រាមប្រកបដោយកម្លាំងរូបផង កម្លាំងភោគៈផង កម្លាំងញាតិផង កម្លាំងកូនផង កម្លាំងសីលផង ទើបញាតិទាំងឡាយ ឲ្យមាតុគ្រាមនោះនៅក្នុងត្រកូលបាន មិនឲ្យវិនាសឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងសីល ប៉ុន្តែមិនប្រកបដោយកម្លាំងរូប

វាសេន្តេវ ជំ កុលេ ន ជាសេន្តិ ។ សីលពលេន ច ភិក្ខវេ មាតុគ្គាមោ សមន្នាគតោ ហោតិ ន ច ភោគព-លេន វាសេន្តេវ ជំ កុលេ ន ជាសេន្តិ ។ សីលពលេន ច ភិក្ខវេ មាតុគ្គាមោ សមន្នាគតោ ហោតិ ន ច ញាតិ-ពលេន វាសេន្តេវ ជំ កុលេ ន ជាសេន្តិ ។ សីលពលេន ច ភិក្ខវេ មាតុគ្គាមោ សមន្នាគតោ ហោតិ ន ច បុត្តពលេន វាសេន្តេវ ជំ កុលេ ន ជាសេន្តិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មាតុគ្គាមស្ស ពលានីតិ ។ បញ្ចមំ ។

[១៣៣] បញ្ចិមានិ ភិក្ខវេ មាតុគ្គាមស្ស ពលានិ ។ កតមានិ បញ្ច ។ រូបពលំ ភោគពលំ ញាតិពលំ បុត្ត-ពលំ សីលពលំ ។

ពួកញាតិរមែងឲ្យមាតុគ្រាមនោះនៅក្នុងត្រកូល មិនឲ្យវិនាសឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងសីល ប៉ុន្តែមិនប្រកបដោយកម្លាំងភោគៈ ពួកញាតិក៏រមែងឲ្យមាតុគ្រាមនោះ នៅក្នុងត្រកូល មិនឲ្យវិនាសឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំងសីល ប៉ុន្តែមិនប្រកបដោយកម្លាំងញាតិ ពួកញាតិក៏រមែងឲ្យមាតុគ្រាមនោះនៅក្នុងត្រកូល មិនឲ្យវិនាសឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ មាតុគ្រាមប្រកបដោយកម្លាំងសីល ប៉ុន្តែមិនប្រកបដោយកម្លាំងកូន ពួកញាតិក៏រមែងឲ្យមាតុគ្រាមនោះនៅក្នុងត្រកូល មិនឲ្យវិនាសឡើយ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាមមាន ៥ យ៉ាងនេះឯង ។ ចប់សូត្រទី ៥ ។

[១៣៣] ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាមនេះ មាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្លាំងរូប ១ កម្លាំងភោគៈ ១ កម្លាំងញាតិ ១ កម្លាំងកូន ១ កម្លាំងសីល ១ ។

[១៣៤] ន ភិក្ខវេ មាតុគ្គាមោ រូបពលហេតុ វា ភោគពលហេតុ វា ញាតិពលហេតុ វា បុត្តពលហេតុ វា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧប្បជ្ជតិ ។ សីលពលហេតុ ខោ ភិក្ខវេ មាតុគ្គាមោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧប្បជ្ជតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មាតុគ្គាមស្ស ពលានីតិ ។ ឆដ្ឋំ ។

[១៣៥] បញ្ចិមានិ ភិក្ខវេ ឋានានិ ទុល្លភានិ អកតបុញ្ញេន មាតុគ្គាមេន ។ កតមានិ បញ្ច ។ បដិរូបេ កុលេ ជាយេយ្យន្តិ ឥទំ ភិក្ខវេ បឋមំ ឋានំ ទុល្លភំ អកតបុញ្ញេន មាតុគ្គាមេន ។ បដិរូបេ កុលេ ជាយិត្វា បដិរូបំ កុលំ គច្ឆេយ្យន្តិ ឥទម្បិ ភិក្ខវេ

[១៣៤] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមដែលបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោកបាន មិនមែនព្រោះហេតុតែកម្លាំងរូប ព្រោះហេតុតែកម្លាំងភោគៈ ព្រោះហេតុតែកម្លាំងញាតិ ព្រោះហេតុតែកម្លាំងកូនទេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមដែលបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោកបាន ព្រោះហេតុតែកម្លាំងសីលប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់មាតុគ្រាមមាន ៥ យ៉ាងនេះឯង ។ ចប់សូត្រទី ៦ ។

[១៣៥] ម្នាលភិក្ខុទាំងឡាយ ស្ថាន ៥ យ៉ាងនេះ មាតុគ្រាមដែលឥតធ្វើបុណ្យតែងបានដោយកម្រ ។ ស្ថាន ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមាតុគ្រាមតាំងចិត្តថា អាត្មាអញគប្បីកើតក្នុងត្រកូលដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ នេះជាស្ថានទី ១ ដែលមាតុគ្រាមឥតធ្វើបុណ្យតែងបានដោយកម្រ ។ មាតុគ្រាមតាំងចិត្តថា លុះអាត្មាអញកើតក្នុងត្រកូលដ៏សមគួរហើយ សូមទៅកាន់ត្រកូលដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ នេះឯង

១០៣

## មាតុគ្គាមពលវគ្គោ

ទុតិយំ ហានំ ទុល្លភំ អកតបុញ្ញេន មាតុគ្គាមេន ។ បដិរូបេ កុលេ ជាយិត្វា បដិរូបំ កុលំ គន្ត្វា អសបត្តិ អគារំ អជ្ឈាវសេយ្យន្តិ ឥទម្បិ ភិក្ខវេ តតិយំ ឋានំ ទុល្លភំ អកតបុញ្ញេន មាតុគ្គាមេន ។ បដិរូបេ កុលេ ជាយិត្វា បដិរូបំ កុលំ គន្ត្វា អសបត្តិ អគារំ អជ្ឈាវសន្តី បុត្តវតី អស្សន្តិ ឥទម្បិ ភិក្ខវេ ចតុត្ថំ ឋានំ ទុល្លភំ អកតបុញ្ញេន មាតុគ្គាមេន ។ បដិរូបេ កុលេ ជាយិត្វា បដិរូបំ កុលំ គន្ត្វា អសបត្តិ អគារំ អជ្ឈាវសន្តី បុត្តវតី សមានា សាមិកំ អភិភុយ្យ វត្តេយ្យន្តិ ឥទម្បិ ភិក្ខវេ បញ្ចមំ ឋានំ ទុល្លភំ អកតបុញ្ញេន មាតុគ្គាមេន ។ ឥមានិ ខោ ភិក្ខវេ បញ្ច ឋានានិ ទុល្លភានិ អកតបុញ្ញេន មាតុគ្គាមេន ។ សត្តមំ ។

ជាស្ថានទី ២ ដែលមាតុគ្រាមឥតធ្វើបុណ្យតែងបានដោយកម្រ ។ មាតុគ្រាមតាំងចិត្តថា លុះអាត្មាអញកើតក្នុងត្រកូលដ៏សមគួរ ទៅកាន់ត្រកូលដ៏សមគួរហើយ សូមកុំឲ្យមានស្រីរួមប្តីនៅគ្រប់គ្រងផ្ទះឡើយ ម្នាលភិក្ខុទាំងឡាយ នេះឯងជាស្ថានទី ៣ ដែលមាតុគ្រាមឥតធ្វើបុណ្យតែងបានដោយកម្រ ។ មាតុគ្រាមតាំងចិត្តថា លុះអាត្មាអញកើតក្នុងត្រកូលដ៏សមគួរ ទៅកាន់ត្រកូលដ៏សមគួរ មិនមានស្រីរួមប្តីនៅគ្រប់គ្រងផ្ទះហើយ សូមឲ្យមានកូន ម្នាលភិក្ខុទាំងឡាយ នេះឯងជាស្ថានទី ៤ ដែលមាតុគ្រាមឥតធ្វើបុណ្យតែងបានដោយកម្រ ។ មាតុគ្រាមតាំងចិត្តថា លុះអាត្មាអញកើតក្នុងត្រកូលដ៏សមគួរ ទៅកាន់ត្រកូលដ៏សមគួរ មិនមានស្រីរួមប្តីនៅគ្រប់គ្រងផ្ទះ ជាស្រីមានកូនហើយ សូមឲ្យគ្របសង្កត់ប្តីបាន ម្នាលភិក្ខុទាំងឡាយ នេះឯងជាស្ថានទី ៥ ដែលមាតុគ្រាមឥតធ្វើបុណ្យតែងបានដោយកម្រ ។ ម្នាលភិក្ខុទាំងឡាយ ស្ថាន ៥ យ៉ាងនេះឯង ដែលមាតុគ្រាមឥតធ្វើបុណ្យតែងបានដោយកម្រ ។

ចប់សូត្រទី ៧ ។

[១៣៦] បញ្ចិមានិ ភិក្ខវេ ឋានានិ សុលភានិ កាតបុញ្ញេន មាតុគ្គាមេន ។ កាតមានិ បញ្ច ។ បដិរូបេ កុលេ ជាយេយ្យន្តិ ឥទម្បិ ភិក្ខវេ បឋមំ ឋានំ សុលភំ កាតបុញ្ញេន មាតុគ្គាមេន ។ បដិរូបេ កុលេ ជាយិត្វា បដិរូបំ កុលំ គច្ឆេយ្យន្តិ ឥទម្បិ ភិក្ខវេ ទុតិយំ ឋានំ សុលភំ កាតបុញ្ញេន មាតុគ្គាមេន ។ បដិរូបេ កុលេ ជាយិត្វា បដិរូបំ កុលំ គន្ត្វា អសបត្តិ អគារំ អជ្ឈាវសេយ្យន្តិ ឥទម្បិ ភិក្ខវេ តតិយំ ឋានំ សុលភំ កាតបុញ្ញេន មាតុគ្គាមេន ។ បដិរូបេ កុលេ ជាយិត្វា បដិរូបំ កុលំ គន្ត្វា អសបត្តិ អគារំ អជ្ឈាវសន្តី បុត្តវតី អស្សន្តិ ឥទម្បិ ភិក្ខវេ ចតុត្ថំ ឋានំ សុលភំ កាតបុញ្ញេន មាតុគ្គាមេន ។ បដិរូបេ កុលេ ជាយិត្វា បដិរូបំ កុលំ គន្ត្វា អសបត្តិ

[១៣៦] ម្នាលភិក្ខុទាំងឡាយ ស្ថាន ៥ យ៉ាងនេះដែលមាតុគ្រាមធ្វើបុណ្យតែងបានដោយងាយ ។ ស្ថាន ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមាតុគ្រាមតាំងចិត្តថា សូមឲ្យអាត្មាអញកើតក្នុងត្រកូលដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ នេះឯងជាស្ថានទី ១ ដែលមាតុគ្រាមធ្វើបុណ្យតែងបានដោយងាយ ។ មាតុគ្រាមតាំងចិត្តថា លុះអាត្មាអញកើតក្នុងត្រកូលដ៏សមគួរហើយ សូមឲ្យទៅកាន់ត្រកូលដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ នេះឯងជាស្ថានទី ២ ដែលមាតុគ្រាមធ្វើបុណ្យតែងបានដោយងាយ ។ មាតុគ្រាមតាំងចិត្តថា លុះអាត្មាអញកើតក្នុងត្រកូលដ៏សមគួរ ទៅកាន់ត្រកូលដ៏សមគួរហើយ សូមកុំឲ្យមានស្រីរួមប្តីនៅគ្រប់គ្រងផ្ទះឡើយ ម្នាលភិក្ខុទាំងឡាយ នេះឯងជាស្ថានទី ៣ ដែលមាតុគ្រាមធ្វើបុណ្យតែងបានដោយងាយ ។ មាតុគ្រាមតាំងចិត្តថា លុះអាត្មាអញកើតក្នុងត្រកូលដ៏សមគួរ ទៅកាន់ត្រកូលដ៏សមគួរ មិនមានស្រីរួមប្តីនៅគ្រប់គ្រងផ្ទះហើយ សូមឲ្យមានកូន ម្នាលភិក្ខុទាំងឡាយ នេះឯងជាស្ថានទី ៤ ដែលមាតុគ្រាមធ្វើបុណ្យតែងបានដោយងាយ ។ មាតុគ្រាមតាំងចិត្តថា លុះអាត្មាអញកើតក្នុងត្រកូលដ៏សមគួរ ទៅកាន់ត្រកូលដ៏សមគួរ មិនមានស្រីរួមប្តី

មាតុគ្គាមពលវគ្គោ

អគារំ អជ្ឈាវសន្តី បុត្តវតី សមានា សាមិកំ អភិភុយ្យ វត្តេយ្យន្តិ ឥធម្បិ ភិក្ខវេ បញ្ចមំ ឋានំ សុលភំ កតបុញ្ញេន មាតុគ្គាមេន ។ ឥមានិ ខោ ភិក្ខវេ បញ្ច ឋានានិ សុលភានិ កតបុញ្ញេន មាតុគ្គាមេនាតិ ។ អដ្ឋមំ ។

[១៣៧] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ វិសារទោ អគារំ អជ្ឈាវសតិ ។ កតមេហិ បញ្ចហិ ។ បាណាតិបាតា បដិវិរតោ ច ហោតិ អទិន្នាទានា បដិវិរតោ ច ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ច ហោតិ មុសាវាទា បដិវិរតោ ច ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ច ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ វិសារទោ អគារំ អជ្ឈាវសតីតិ ។ នវមំ ។

នៅគ្រប់គ្រងផ្ទះ ជាស្រីមានកូនហើយ សូមឲ្យគ្របសង្កត់ប្តីបាន ម្នាលភិក្ខុទាំងឡាយ នេះឯងជាស្ថានទី ៥ ដែលមាតុគ្រាមធ្វើបុណ្យតែងបានដោយងាយ ។ ម្នាលភិក្ខុទាំងឡាយ ស្ថាន ៥ យ៉ាងនេះឯង ដែលមាតុគ្រាមធ្វើបុណ្យតែងបានដោយងាយ ។ ចប់សូត្រទី ៨ ។

[១៣៧] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកក្លៀវក្លានៅគ្រប់គ្រងផ្ទះបាន ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមាតុគ្រាម ជាអ្នកវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ វៀរចាកសុរាមេរយ-មជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបជាអ្នកក្លៀវក្លានៅគ្រប់គ្រងផ្ទះបាន ។ ចប់សូត្រទី ៩ ។

[១៣៨] បញ្ចហិ ភិក្ខវេ វឌ្ឍីហិ វឌ្ឍមានា អរិយសាវិកា អរិយាយ វឌ្ឍិយា វឌ្ឍតិ សារាទាយិនី ច ហោតិ វរាទាយិនី ច កាយស្ស ។ កតមេហិ បញ្ចហិ ។ សទ្ធាយ វឌ្ឍតិ សីលេន វឌ្ឍតិ សុតេន វឌ្ឍតិ ចាគេន វឌ្ឍតិ បញ្ញាយ វឌ្ឍតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ វឌ្ឍីហិ វឌ្ឍមានា អរិយសាវិកា អរិយាយ វឌ្ឍិយា វឌ្ឍតិ សារាទាយិនី ច ហោតិ វរាទាយិនី ច កាយស្សាតិ ។

សទ្ធាយ សីលេន វឌ្ឍតិ
បញ្ញាយ ចាគេន សុតេន ចូភយំ
សា តាទិសី សីលវតិ ឧបាសិកា
អាទិយតិ សារំ ឥធេវ អត្តនោតិ ។ ទសមំ ។

មាតុគ្គាមពលវគ្គោ ទុតិយោ សមត្តោ ។

[១៣៨] ម្នាលភិក្ខុទាំងឡាយ អរិយសាវិកា កាលបើចម្រើនដោយសេចក្តីចម្រើន ៥ យ៉ាងហើយ តែងចម្រើនដោយសេចក្តីចម្រើនដ៏ប្រ-សើរ ឈ្មោះថាជាអ្នកកាន់យកនូវទ្រព្យមានខ្លឹម កាន់យកនូវទ្រព្យដ៏ប្រសើររបស់កាយបាន ។ សេចក្តីចម្រើន ៥ យ៉ាង គឺអ្វីខ្លះ ។ គឺចម្រើនដោយសទ្ធា ១ ចម្រើនដោយសីល ១ ចម្រើនដោយសុតៈ ១ ចម្រើនដោយចាគៈ ១ ចម្រើនដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវិកា កាលបើចម្រើនដោយសេចក្តីចម្រើនទាំង ៥ យ៉ាងនេះហើយ តែងចម្រើនដោយសេចក្តីចម្រើនដ៏ប្រសើរ ឈ្មោះថាជាអ្នកកាន់យកនូវទ្រព្យមានខ្លឹម កាន់យកនូវទ្រព្យដ៏ប្រសើរ របស់កាយបាន ។

អរិយសាវិការមែងចម្រើនដោយសទ្ធាផង ដោយសីលផង
ដោយបញ្ញាផង និងចម្រើនដោយហេតុទាំងពីរ គឺ ចាគៈផង
សុតៈផង ឧបាសិកាមានសីលបែបនោះ រមែងកាន់យក
នូវទ្រព្យមានខ្លឹមរបស់ខ្លួន ក្នុងលោកនេះដោយពិត ។

ចប់សូត្រទី ១០ ។

ចប់ មាតុគ្គាមពលវគ្គ ទី ២ ។

១០៧

មាតុគ្គាមពលវគ្គោ

# តស្សុទ្ទានំ

បញ្ច វិសារទា បសយ្ហ
អភិភុយ្យ អង្គេន បញ្ចមំ
នាសយិត្វ ហេតុដ្ឋានំ
វិសារទា វឌ្ឍិនា ទសាតិ ។

មាតុគ្គាមសំយុត្តំ និដ្ឋិតំ ។

មាតុគ្គាមពលវគ្គ

# ឧទ្ទាននៃមាតុគ្គាមពលវគ្គនោះគឺ

*និយាយអំពីមាតុគ្រាមប្រកបដោយកម្លាំង ៥ ជាអ្នកក្លៀវក្លា ១ អំពីមាតុគ្រាមបង្ក្រាបប្ដី ១ អំពីមាតុគ្រាមគ្របសង្កត់ប្ដី ១ អំពីមាតុគ្រាមប្រកបដោយអង្គ ១ អំពីពួកញាតិឲ្យមាតុគ្រាមវិនាសជាគម្រប់ប្រាំ ១ អំពីហេតុ ១ អំពីស្ថាន ២ លើក អំពីមាតុគ្រាមក្លៀវក្លា ១ អំពីអរិយសាវិកាចម្រើនដោយសេចក្ដីចម្រើន ១ រួមត្រូវជា ១០ ។*

ចប់ មាតុគ្គាមសំយុត្ត ។

# ជម្ពុខាទកសំយុត្តំ

[១៣៩] ឯកំ សមយំ អាយស្មា សារីបុត្តោ មគធេសុ វិហរតិ នាលគាមកេ ។ អថខោ ជម្ពុខាទកោ បរិព្វាជកោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជម្ពុខាទកោ បរិព្វាជកោ អាយស្មន្តំ សារីបុត្តំ ឯតទវោច និព្វានំ និព្វានន្តិ អាវុសោ សារីបុត្ត វុច្ចតិ កតមំ នុ ខោ អាវុសោ និព្វានន្តិ ។ យោ ខោ អាវុសោ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ឥទំ វុច្ចតិ និព្វានន្តិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស និព្វានស្ស សច្ឆិកិរិយាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា

# ជម្ពុខាទកសំយុត្ត

[១៣៩] សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងនាលគ្រាម នាដែនមគធៈ ។ គ្រានោះឯង បរិព្វាជកឈ្មោះជម្ពុខាទកៈ បានចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលសំណេះសំណាល ជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះជម្ពុខាទកបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏និយាយនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា និព្វាន និព្វាន ម្នាលអាវុសោ ដូចម្តេចហ្ន៎ហៅថា និព្វាន ។ ព្រះសារីបុត្តតបថា ម្នាលអាវុសោ សភាវៈដែលជាទីអស់ទៅនៃរាគៈ អស់ទៅនៃទោសៈ អស់ទៅនៃមោហៈ នេះហៅថា និព្វាន ។ ម្នាលអាវុសោ ចុះមគ្គនិងបដិបទាដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅ ដើម្បី

ឯតស្ស និព្វានស្ស សច្ឆិកិរិយាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតស្ស និព្វា-នស្ស សច្ឆិកិរិយាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតស្ស និព្វានស្ស សច្ឆិ-កិរិយាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតស្ស និព្វានស្ស សច្ឆិកិរិយាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតស្ស និព្វានស្ស សច្ឆិកិរិយាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៤០] អរហត្តំ អរហត្តន្តិ អាវុសោ សារីបុត្ត វុច្ចតិ កតមំ នុ ខោ អាវុសោ អរហត្តន្តិ ។ យោ ខោ អាវុសោ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ឥទំ វុច្ចតិ អរ-ហត្តន្តិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស អរហត្តស្ស សច្ឆិកិរិយាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស អរហត្តស្ស សច្ឆិកិរិយាយាតិ ។

ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានទុ៎ះមានដែរ ។ ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទាដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានទុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះហើយ ដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានទុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មា-សមាធិ ១ ។ ម្នាលអាវុសោ នេះហៅថា មគ្គ នេះហៅថា បដិបទាដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានទុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើនដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានទុ៎ះបាន ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៤០] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា អរហត្ត អរហត្ត ម្នាលអាវុសោ ដូចម្តេចហ្ន៎ ហៅថា អរហត្ត ។ ម្នាលអាវុសោ សភាវៈដែលជាទីអស់ទៅនៃរាគៈ អស់ទៅនៃទោសៈ អស់ទៅនៃមោហៈ នេះហៅថា អរហត្ត ។ ម្នាលអាវុសោ ចុះមគ្គនិងបដិបទាដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តទុ៎ះ មានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តទុ៎ះមានដែរ ។

កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតស្ស អរហត្តស្ស សច្ឆិកិរិយាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតស្ស អរហត្តស្ស សច្ឆិកិរិ-យាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មា-សមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតស្ស អរហត្តស្ស សច្ឆិកិរិយាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតស្ស អរហត្តស្ស សច្ឆិកិរិយាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមា-ទាយាតិ ។

[១៤១] កេ នុ ខោ អាវុសោ សារីបុត្ត លោកេ ធម្មវាទិនោ[១] កេ លោកេ សុប្បដិបន្នា កេ លោកេ សុគតាតិ ។ យេ ខោ អាវុសោ[២] រាគប្បហានា-យ ធម្មំ ទេសេន្តិ ទោសប្បហានាយ ធម្មំ ទេសេន្តិ

១ ឱ. ធម្មានុវាទិនោ ។ ២ អាវុសោ លោកេ ។

ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះហើយ ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មា-សមាធិ ១ ។ ម្នាលអាវុសោ នេះហៅថា មគ្គ នេះហៅថា បដិបទាដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនុ៎ះ ។ ម្នាលអាវុសោមគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនុ៎ះបាន ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៤១] ម្នាលអាវុសោសារីបុត្ត ពួកបុគ្គលដូចម្តេចហ្ន៎ឈ្មោះថាជាធម្មវាទីក្នុងលោក បុគ្គលដូចម្តេចឈ្មោះថាជាអ្នកប្រតិបត្តិល្អក្នុងលោក បុគ្គលដូចម្តេចជាអ្នកមានដំណើរល្អក្នុងលោក ។ ម្នាលអាវុសោ ពួកបុគ្គលឯណាសំដែងធម៌ដើម្បីលះបង់នូវរាគៈ សំដែងធម៌ដើម្បីលះបង់នូវទោសៈ

១១១

## ជម្ពុខាទកសំយុត្តំ

មោហប្បហានាយ ធម្មំ ទេសេន្តិ តេ លោកេ ធម្មវាទិ-
នោ ។ យេ ច ខោ អាវុសោ រាគស្ស បហានាយ បដិបន្នា
ទោសស្ស បហានាយ បដិបន្នា មោហស្ស បហានាយ
បដិបន្នា តេ លោកេ សុប្បដិបន្នា ។ យេសំ ខោ
អាវុសោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ
អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ទោសោ បហីនោ
ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ
អនុប្បាទធម្មោ មោហោ បហីនោ ឧច្ឆិន្នមូលោ តាលា-
វត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ តេ
លោកេ សុគតាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ
បដិបទា ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហា-
នាយាតិ ។ អត្ថិយេវ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា
ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយាតិ ។

សំដែងធម៌ដើម្បីលះបង់នូវមោហៈ បុគ្គលទាំងនោះឈ្មោះថា ជាធម្មវាទីក្នុងលោក ។ ម្នាលអាវុសោ បុគ្គលទាំងឡាយឯណា ជាអ្នកប្រតិបត្តិដើម្បីលះបង់នូវរាគៈ ប្រតិបត្តិដើម្បីលះបង់នូវទោសៈ ប្រតិបត្តិដើម្បីលះបង់នូវមោហៈ បុគ្គលទាំងនោះឈ្មោះថា ជាអ្នកប្រតិបត្តិល្អក្នុងលោក ។ ម្នាលអាវុសោ បុគ្គលទាំងឡាយឯណា លះបង់នូវរាគៈចោលហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យសាបសូន្យទៅ មានសភាពមិនកើតឡើងតទៅទៀតឡើយ លះបង់នូវទោសៈចោលហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យសាបសូន្យទៅ មានសភាពមិនកើតឡើងតទៅទៀតឡើយ លះបង់នូវមោហៈចោលហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យសាបសូន្យទៅ មានសភាពមិនកើតឡើងតទៅទៀតឡើយ បុគ្គលទាំងនោះឈ្មោះថា ជាអ្នកមានដំណើរល្អក្នុងលោក ។ ម្នាលអាវុសោ មគ្គនិងបដិបទា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវរាគៈទោសៈមោហៈនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិ-បទា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវរាគៈទោសៈមោហៈនុ៎ះមានដែរ ។

កតមោ អាវុសោ មគ្គោ កតមា បដិបទា ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៤២] កិមត្ថិយំ អាវុសោ សារីបុត្ត សមណេ គោតមេ ព្រហ្មចរិយំ វុស្សតីតិ ។ ទុក្ខស្ស ខោ អាវុសោ បរិញ្ញត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ

ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវរាគៈទោសៈមោហៈនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវរាគៈទោសៈមោហៈនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវរាគៈទោសៈមោហៈនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវរាគៈទោសៈមោហៈនុ៎ះបាន ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៨២] ម្នាលអាវុសោសារីបុត្ត បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតម តើដើម្បីប្រយោជន៍អ្វី ។ ម្នាលអាវុសោ បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវសេចក្តីទុក្ខ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសេចក្តីទុក្ខនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គ

១១៣

ជម្ពុខាទកសំយុត្តំ

អត្ថិ បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតស្ស ទុក្ខស្ស បរិញ្ញាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៤៣] អស្សាសប្បត្តោ អស្សាសប្បត្តោតិ អាវុសោ សារីបុត្ត វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ សារីបុត្ត អស្សាសប្បត្តោ ហោតីតិ ។ យតោ ខោ អាវុសោ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច

និងបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសេចក្តីទុក្ខទ្រុំះ មានដែរ ។ ម្នាលអាវុសោ អ្វីជាមគ្គ ធ្វើជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសេចក្តីទុក្ខទ្រុំះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ហើយ ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសេចក្តីទុក្ខទ្រុំះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសេចក្តីទុក្ខទ្រុំះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសេចក្តីទុក្ខទ្រុំះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៤៣] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា ភិក្ខុដល់នូវការដកដង្ហើមចេញ ដល់នូវការដកដង្ហើមចេញ ម្នាលអាវុសោសារី-បុត្ត ភិក្ខុដល់នូវការដកដង្ហើមចេញដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ កាលភិក្ខុដឹងច្បាស់នូវការកើតឡើងផង នូវសេចក្តីវិនាសផង

អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ឯត្តាវតា ខោ អាវុសោ អស្សាសប្បត្តោ ហោតីតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស អស្សាសស្ស សច្ឆិកិរិយាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស អស្សាសស្ស សច្ឆិកិរិយាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតស្ស អស្សាសស្ស សច្ឆិកិរិយាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតស្ស អស្សាសស្ស សច្ឆិកិរិយាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតស្ស អស្សាសស្ស សច្ឆិកិរិយាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតស្ស អស្សាសស្ស សច្ឆិកិរិយាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃផស្សាយតនៈទាំង ៦ តាមសេចក្តីពិត ម្នាលអាវុសោ ភិក្ខុជាអ្នកដល់នូវការដកដង្ហើមចេញដោយហេតុយ៉ាងនេះឯង ។ ម្នាលអាវុសោ មគ្គនិងបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញនុ៎ះ មានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញនុ៎ះ មានដែរ ។ ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញនុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

ជម្ពុខាទកសំយុត្តំ

[១៤៤] បរមស្សាសប្បត្តោ បរមស្សាសប្បត្តោតិ អាវុសោ សារីបុត្ត វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ បរមស្សាសប្បត្តោ ហោតីតិ ។ យតោ ខោ អាវុសោ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទា វិមុត្តោ ហោតិ ឯត្តាវតា ខោ អាវុសោ បរ-មស្សាសប្បត្តោ ហោតីតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស បរមស្សាសស្ស សច្ឆិកិរិ-យាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស បរមស្សាសស្ស សច្ឆិកិរិយាយាតិ ។ កតមោ បន អាវុសោ មគ្គោ កតមា បដិបទា ឯតស្ស បរមស្សាសស្ស សច្ឆិកិរិយាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតស្ស បរមស្សា-សស្ស សច្ឆិកិរិយាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។

ជម្ពុខាទកសំយុត្ត

[១៤៤] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា ភិក្ខុដល់នូវការដកដង្ហើមចេញដ៏ឧត្តម ដល់នូវការដកដង្ហើមចេញដ៏ឧត្តម ម្នាលអាវុសោ ភិក្ខុជាអ្នកដល់នូវការដកដង្ហើមចេញដ៏ឧត្តម ដោយហេតុយ៉ាងណា ។ ម្នាលអាវុសោ កាលណាភិក្ខុដឹងច្បាស់នូវការកើតឡើងផង នូវការវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃផស្សាយតនៈទាំង ៦ តាមសេចក្តីពិត ជាអ្នកផុតស្រឡះព្រោះមិនប្រកាន់ ម្នាលអាវុសោ ភិក្ខុជាអ្នកដល់នូវការដកដង្ហើមចេញដ៏ឧត្តម ដោយហេតុយ៉ាងនេះឯង ។ ម្នាលអាវុសោ មគ្គនិងបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញដ៏ឧត្តមនុ៎ះ មានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញដ៏ឧត្តមនុ៎ះមានដែរ ។ ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់ នូវការដកដង្ហើមចេញដ៏ឧត្តមនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញ ដ៏ឧត្តមនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។

សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតស្ស បរមស្សាសស្ស សច្ឆិកិរិយាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតស្ស បរមស្សាសស្ស សច្ឆិកិរិយាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៤៨] វេទនា វេទនាតិ អាវុសោ សារីបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ វេទនាតិ ។ តិស្សោ ឥមា អាវុសោ វេទនាតិ ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា ខោ អាវុសោ តិស្សោ វេទនាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតាសំ តិស្សន្នំ វេទនានំ បរិញ្ញាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ ប-ដិបទា ឯតាសំ តិស្សន្នំ វេទនានំ បរិញ្ញាយាតិ ។

សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទា ដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញដ៏ឧត្តមនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវការដកដង្ហើមចេញដ៏ឧត្តមនុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៤៥] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា វេទនាៗ ម្នាលអាវុសោ វេទនាតើដូចម្តេច ។ ម្នាលអាវុសោ វេទនានេះមាន ៣ ប្រការ ។ វេទនា ៣ ប្រការ គឺអ្វីខ្លះ ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលអាវុសោ វេទនាមាន ៣ ប្រការនេះឯង ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវវេទនាទាំង ៣ នុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវវេទនាទាំង ៣ ប្រការនុ៎ះមានដែរ ។

កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតាសំ តិស្សន្នំ វេទនានំ បរិញ្ញាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតាសំ តិស្សន្នំ វេទនានំ បរិញ្ញាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតាសំ តិស្សន្នំ វេទនានំ បរិញ្ញាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតាសំ តិស្សន្នំ វេទនានំ បរិញ្ញាយ អលញ្ច បនាវុសោ សារី-បុត្ត អប្បមាទាយាតិ ។

[១៤៦] អាសវោ អាសវោតិ អាវុសោ សារីបុត្ត វុច្ចតិ កតមោ នុ ខោ អាវុសោ អាសវោតិ ។ តយោ-មេ អាវុសោ អាសវា កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ ឥមេ ខោ អាវុសោ តយោ អាសវាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតេសំ អាស-វានំ បហានាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតេសំ អាសវានំ បហានាយាតិ ។

ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវវេទនាទាំង ៣ ប្រការនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវវេទនាទាំង ៣ ប្រការនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវវេទនាទាំង ៣ ប្រការនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវវេទនាទាំង ៣ ប្រការនុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះបុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៨៦] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា អាសវៈៗ ម្នាលអាវុសោ អាសវៈតើដូចម្តេច ។ ម្នាលអាវុសោ អាសវៈទាំងនេះមាន ៣ ប្រការគឺ កាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលអាវុសោ អាសវៈមាន ៣ ប្រការនេះឯង ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអាសវៈទាំងនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអាសវៈទាំងនុ៎ះមានដែរ ។

កតមោ អាវុសោ មគ្គោ កតមា បដិបទា ឯតេសំ អាសវានំ បហានាយាតិ ។ អយមេវ ខោ អាវុសោ អរិ-យោ អដ្ឋង្គិកោ មគ្គោ ឯតេសំ អាសវានំ បហានាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតេសំ អាសវានំ បហានាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតេសំ អាសវានំ បហានាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៤៧] អវិជ្ជា អវិជ្ជាតិ អាវុសោ សារីបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ អវិជ្ជាតិ ។ យំ ខោ អាវុសោ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ អយំ វុច្ចតាវុសោ អវិជ្ជាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតិស្សា អវិជ្ជាយ បហានាយាតិ ។

ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអាសវៈទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអាសវៈទាំងនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអាសវៈទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើនដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអាសវៈទាំងនុ៎ះ ម្នាលអាវុសោសារីបុត្តបើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៤៧] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា អវិជ្ជាៗ ម្នាលអាវុសោ អវិជ្ជាតើដូចម្តេច ។ ម្នាលអាវុសោ ការមិនដឹងក្នុងទុក្ខឯណា ការមិនដឹងក្នុងហេតុជាដែនកើតនៃទុក្ខឯណា ការមិនដឹងក្នុងហេតុជាទីរលត់ទុក្ខឯណា ការមិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខឯណា ម្នាលអាវុសោ នេះហៅថា អវិជ្ជា ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអវិជ្ជានុ៎ះមានដែរឬ ។

អត្ថាវុសោ[១] មគ្គោ អត្ថិ បដិបទា ឯតិស្សា អវិជ្ជាយ បហានាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតិស្សា អវិជ្ជាយ បហានាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតិស្សា អវិជ្ជាយ បហានាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតិស្សា អវិជ្ជាយ បហានាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតិស្សា អវិជ្ជាយ បហានាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៤៨] តណ្ហា តណ្ហាតិ អាវុសោ សារីបុត្ត វុច្ចតិ កតមា នុ ខោ អាវុសោ តណ្ហាតិ ។ តិស្សោ ឥមា អាវុសោ តណ្ហា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥមា ខោ អាវុសោ តិស្សោ តណ្ហាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតាសំ តណ្ហានំ បហានាយាតិ ។ អត្ថាវុសោ មគ្គោ អត្ថិ បដិបទា ឯតាសំ តណ្ហានំ បហានាយាតិ ។

---

១ ឱ. អត្ថិ ខោ អាវុសោ ។

ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអវិជ្ជានុ៎ះ មានដែរ ។ ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអវិជ្ជានុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអវិជ្ជានុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអវិជ្ជានុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើនដែលប្រព្រឹត្តទៅដើម្បីលះបង់នូវអវិជ្ជានុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៤៨] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា តណ្ហាៗ ម្នាលអាវុសោ តណ្ហាតើដូចម្តេច ។ ម្នាលអាវុសោ តណ្ហានេះមាន ៣ ប្រការគឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលអាវុសោ តណ្ហាមាន ៣ ប្រការនេះឯង ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវតណ្ហាទាំងនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវតណ្ហាទាំងនុ៎ះមានដែរ ។

កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតាសំ តណ្ហានំ បហានាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតាសំ តណ្ហានំ បហានាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតាសំ តណ្ហានំ បហានាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតាសំ តណ្ហានំ បហានាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៤៩] ឱឃោ ឱឃោតិ អាវុសោ សារីបុត្ត វុច្ចតិ កតមោ នុ ខោ អាវុសោ ឱឃោតិ ។ ចត្តារោមេ អាវុសោ ឱឃា កាមោឃោ ភវោឃោ ទិដ្ឋោឃោ អវិជ្ជោឃោ ។ ឥមេ ខោ អាវុសោ ចត្តារោ ឱឃាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតេសំ ឱឃានំ បហានាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតេសំ ឱឃានំ បហានាយាតិ ។

ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវតណ្ហាទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវតណ្ហាទាំងនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវតណ្ហាទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវតណ្ហាទាំងនុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៤៩] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា ឱឃៈៗ ម្នាលអាវុសោ ឱឃៈ តើដូចម្តេច ។ ម្នាលអាវុសោ ឱឃៈនេះមាន ៤ ប្រការ គឺ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។ ម្នាលអាវុសោ ឱឃៈមាន ៤ ប្រការនេះឯង ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱឃៈទាំងនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱឃៈទាំងនុ៎ះមានដែរ ។

១២១

ជម្ពុខាទកសំយុត្តំ

កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតេសំ ឱឃានំ បហានាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតេសំ ឱឃានំ បហានាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតេសំ ឱឃានំ បហានាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតេសំ ឱឃានំ បហានាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៨០] ឧបាទានំ ឧបាទានន្តិ អាវុសោ សារីបុត្ត វុច្ចតិ កតមំ នុ ខោ អាវុសោ សារីបុត្ត ឧបាទា-នន្តិ ។ ចត្តារិមានិ អាវុសោ ឧបាទានានិ កាមុបា-ទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវាទុបាទានំ ។ ឥមានិ ខោ អាវុសោ ចត្តារិ ឧបាទានានីតិ ។

ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱឃៈទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱឃៈទាំងនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថា មគ្គ នេះហៅថា បដិបទា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱឃៈទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱឃៈទាំងនុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៥០] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា ឧបាទានៗ ម្នាលអាវុសោសារីបុត្ត ឧបាទាន តើដូចម្តេច ។ ម្នាលអាវុសោ ឧបាទាននេះមាន ៤ យ៉ាងគឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ ម្នាលអាវុសោ ឧបាទានមាន ៤ នេះឯង ។

អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតេសំ ឧបាទា-
នានំ បហានាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ
បដិបទា ឯតេសំ ឧបាទានានំ បហានាយាតិ ។ កត-
មោ បនាវុសោ មគ្គោ កតមា បដិបទា ឯតេសំ
ឧបាទានានំ បហានាយាតិ ។ អយមេវ ខោ អាវុសោ
អរិយោ អដ្ឋង្គិកោ មគ្គោ ឯតេសំ ឧបាទានានំ ប-
ហានាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មា-
សមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា
ឯតេសំ ឧបាទានានំ បហានាយាតិ ។ ភទ្ទកោ អាវុសោ
មគ្គោ ភទ្ទិកា បដិបទា ឯតេសំ ឧបាទានានំ បហា-
នាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

ម្នាលអាវុសោ មគ្គនិងបដិបទា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឧបាទាន ទាំងនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅ ដើម្បីលះបង់នូវឧបាទានទាំងនុ៎ះដែរ ។ ម្នាលអាវុសោ ចុះអ្វីជាមគ្គ អ្វីជាបដិបទាដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឧបាទានទាំងនុ៎ះ ។ ម្នាល អាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ដែលប្រព្រឹត្តទៅ ដើម្បីលះបង់នូវឧបាទានទាំងនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅ ថាមគ្គ នេះហៅថាបដិបទា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឧបាទានទាំង នុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅ ដើម្បីលះបង់ឧបាទានទាំងនុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គល គួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

## ជម្ពុខាទកសំយុត្តំ

[១៤១] ភវោ ភវោតិ អាវុសោ សារីបុត្ត វុច្ចតិ កតមោ នុ ខោ អាវុសោ សារីបុត្ត ភវោតិ ។ តយោមេ អាវុសោ ភវា កាមភវោ រូបភវោ អរូបភវោ ។ ឥមេ ខោ អាវុសោ តយោ ភវាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតេសំ ភវានំ បរិញ្ញាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតេសំ ភវានំ បរិញ្ញាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតេសំ ភវានំ បរិញ្ញាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតេសំ ភវានំ បរិញ្ញាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតេសំ ភវានំ បរិញ្ញាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតេសំ ភវានំ បរិញ្ញាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

ជម្ពុខាទកសំយុត្ត

[១៥១] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា ភពៗ ម្នាលអាវុសោសារីបុត្ត ភពតើដូចម្តេច ។ ម្នាលអាវុសោ ភពនេះមាន ៣ ប្រការគឺ កាមភព ១ រូបភាព ១ អរូបភាព ១ ។ ម្នាលអាវុសោ ភពមាន ៣ ប្រការនេះឯង ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវភពទាំងនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវភពទាំងនុ៎ះមានដែរ ។ ម្នាលអាវុសោ ចុះអ្វីជាមគ្គ អ្វីជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវភពទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវភពទាំងនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវភពទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវភពទាំងនុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៩២] ទុក្ខំ ទុក្ខន្តិ អាវុសោ សារីបុត្ត វុច្ចតិ កតមំ នុ ខោ អាវុសោ ទុក្ខន្តិ ។ តិស្សោ ឥមា អាវុសោ ទុក្ខតា ទុក្ខទុក្ខតា សង្ខារទុក្ខតា វិបរិណាមទុក្ខតា ។ ឥមា ខោ អាវុសោ តិស្សោ ទុក្ខតាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតាសំ ទុក្ខតានំ បរិញ្ញាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតាសំ ទុក្ខតានំ បរិញ្ញាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតាសំ ទុក្ខតានំ បរិញ្ញាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតាសំ ទុក្ខតានំ បរិញ្ញាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតាសំ ទុក្ខតានំ បរិញ្ញាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតាសំ ទុក្ខតានំ បរិញ្ញាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៥២] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា ទុក្ខៗ ម្នាលអាវុសោ ទុក្ខតើដូចម្តេច ។ ម្នាលអាវុសោ សេចក្តីទុក្ខនេះមាន ៣ ប្រការគឺ ទុក្ខទុក្ខតា ១ សង្ខារទុក្ខតា ១ វិបរិណាមទុក្ខតា ១ ។ ម្នាលអាវុសោ សេចក្តីទុក្ខមាន ៣ ប្រការនេះឯង ។ ម្នាលអាវុសោ មគ្គនិងបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹង នូវសេចក្តីទុក្ខទាំងនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹង នូវសេចក្តីទុក្ខទាំងនុ៎ះមានដែរ ។ ម្នាលអាវុសោ ចុះអ្វីជាមគ្គ អ្វីជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹង នូវសេចក្តីទុក្ខទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹង នូវសេចក្តីទុក្ខទាំងនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹង នូវសេចក្តីទុក្ខទាំងនុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹង នូវសេចក្តីទុក្ខទាំងនុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

## ជម្ពុខាទកសំយុត្តំ

[១៨៣] សក្កាយោ សក្កាយោតិ អាវុសោ សារីបុត្ត វុច្ចតិ កតមោ នុ ខោ អាវុសោ សក្កាយោតិ ។ បញ្ចិមេ អាវុសោ ឧបាទានក្ខន្ធា សក្កាយោ វុត្តា ភគវតា ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ឥមេ ខោ អាវុសោ បញ្ចុបាទានក្ខន្ធា សក្កាយោ វុត្តា ភគវតាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស សក្កាយស្ស បរិញ្ញាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស សក្កាយស្ស បរិញ្ញាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតស្ស សក្កាយស្ស បរិញ្ញាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតស្ស សក្កាយស្ស បរិញ្ញាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។

ជម្ពុខាទកសំយុត្ត

[១៥៣] ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា សក្កាយៗ ម្នាលអាវុសោ សក្កាយតើដូចម្តេច ។ ម្នាលអាវុសោ ឧបាទានក្ខន្ធទាំង ៥ នេះ ព្រះមានព្រះភាគត្រាស់ថាសក្កាយ ។ ឧបាទានក្ខន្ធទាំង ៥ តើដូចម្តេច ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូ-បាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ម្នាលអាវុ-សោ ឧបាទានក្ខន្ធទាំង ៥ នេះឯង ដែលព្រះមានព្រះភាគត្រាស់ថា សក្កាយ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសក្កាយនុ៎ះមានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសក្កាយនុ៎ះមានដែរ ។ ម្នាលអាវុ-សោ ចុះអ្វីជាមគ្គ អ្វីជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសក្កាយនុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសក្កាយនុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។

អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតស្ស សក្កាយស្ស បរិញ្ញាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតស្ស សក្កាយស្ស បរិញ្ញាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។

[១៥៤] កឹ នុ ខោ អាវុសោ សារីបុត្ត ឥមស្មឹ ធម្មវិនយេ ទុក្ករន្តិ ។ បព្វជ្ជា ខោ អាវុសោ ឥមស្មឹ ធម្មវិនយេ ទុក្ករាតិ ។ បព្វជិតេន បនាវុសោ កឹ ទុក្ករន្តិ ។ បព្វជិតេន ខោ អាវុសោ អភិរតិ ទុក្ករាតិ ។ អភិរតេន បនាវុសោ សារីបុត្ត កឹ ទុក្ករន្តិ ។ អភិរតេន ខោ អាវុសោ ធម្មានុធម្មប្បដិបត្តិ ទុក្ករាតិ ។ កីវចិរំ បនាវុសោ ធម្មានុធម្មប្បដិបន្នោ ភិក្ខុ អរហំ អស្សាតិ ។ ន ចិរំ អាវុសោតិ ។

ជម្ពុខាទកសំយុត្តំ សមត្តំ ។

ម្នាលអាវុសោ នេះហៅថាមគ្គ នេះហៅថាបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសក្កាយទិដ្ឋិ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវសក្កាយទិដ្ឋិ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

[១៥៤] ម្នាលអាវុសោសារីបុត្ត អ្វីហ្ន៎ដែលបុគ្គលធ្វើបានដោយកម្រក្នុងធម្មវិន័យនេះ ។ ម្នាលអាវុសោ បព្វជ្ជាដែលបុគ្គលធ្វើបានដោយកម្រក្នុងធម្មវិន័យនេះ ។ ម្នាលអាវុសោ ចុះអ្វីដែលបព្វជិតធ្វើបានដោយកម្រ ។ ម្នាលអាវុសោ សេចក្តីត្រេកអរ (មិនអផ្សុកក្នុងបព្វជ្ជានេះឯង) ដែលបព្វជិតធ្វើបានដោយកម្រ ។ ម្នាលអាវុសោសារីបុត្ត ចុះអ្វីដែលបព្វជិតមានសេចក្តីត្រេកអរធ្វើបានដោយកម្រ ។ ម្នាលអាវុសោ សេចក្តីប្រតិបត្តិនូវធម៌តាមធម៌ (នេះឯង) ដែលបព្វជិតធ្វើបានដោយកម្រ ។ ម្នាលអាវុសោ ភិក្ខុបានប្រតិបត្តិនូវធម៌តាមធម៌ តើយូរប៉ុន្មានទៅ ទើបសម្រេចជាព្រះអរហន្តបាន ។ ម្នាលអាវុសោ មិនជាយូរប៉ុន្មានទេ ។

ចប់ ជម្ពុខាទកសំយុត្ត ។

១២៧

ជម្ពុខាទកសំយុត្តំ

# តស្សុទ្ទានំ

និព្វានំ អរហត្តញ្ច

ធម្មវាទី កិមត្ថិយំ

អស្សាសោ បរមស្សាសោ

វេទនា អាសវាវិជ្ជា

តណ្ហា ឱឃា ឧបាទានំ

ភវោ ទុក្ខញ្ច សក្កាយោ

ឥមស្មឹ ធម្មវិនយេ ទុក្ករន្តិ ។

ជម្ពុខាទកសំយុត្ត

# ឧទ្ទាននៃជម្ពុខាទកសំយុត្តនោះគឺ

និយាយអំពីព្រះនិព្វាន ១ អំពីព្រះអរហត្ត ១ អំពីធម្មវាទីបុគ្គល ១ អំពីការប្រព្រឹត្តព្រហ្មចរិយៈដើម្បីប្រយោជន៍អ្វី ១ អំពីការដកដង្ហើមចេញ ១ អំពីការដកដង្ហើមចេញដ៏ឧត្តម ១ អំពីវេទនា ១ អំពីអាសវៈ ១ អំពីអវិជ្ជា ១ អំពីតណ្ហា ១ អំពីឱឃៈ ១ អំពីឧបាទាន ១ អំពីភព ១ អំពីទុក្ខ ១ អំពីសក្កាយ ១ អំពីសេចក្តីត្រេកអរដែលបព្វជិតធ្វើបានដោយកម្រក្នុងធម្មវិន័យនេះ ១ ។

# សាមណ្ឌកសំយុត្តំ

[១៨៨] ឯកំ សមយំ អាយស្មា សារីបុត្តោ វជ្ជីសុ វិហរតិ ឧក្កចេលាយំ គង្គាយ នទិយា តីរេ ។ អថខោ សាមណ្ឌកោ បរិព្វាជកោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិ-សារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សាមណ្ឌកោ បរិព្វាជកោ អាយស្មន្តំ សារីបុត្តំ ឯត-ទវោច និព្វានំ និព្វានន្តិ អាវុសោ សារីបុត្ត វុច្ចតិ កតមំ នុ ខោ អាវុសោ និព្វានន្តិ ។ យោ ខោ អាវុសោ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ឥទំ វុច្ចតិ និព្វានន្តិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា

# សាមណ្ឌកសំយុត្ត

[១៥៥] សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅទៀបឆ្នេរទន្លេគង្គា ទៀបស្រុកឧក្កចេលា ក្នុងដែនវជ្ជី ។ គ្រានោះឯង បរិព្វាជកឈ្មោះសាមណ្ឌក ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះសាមណ្ឌកបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏និយាយនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា និព្វានៗ ម្នាលអាវុសោ និព្វានតើដូចម្ដេច ។ ម្នាលអាវុសោ សភាវៈដែលជាទីអស់ទៅនៃរាគៈ អស់ទៅនៃទោសៈ អស់ទៅនៃមោហៈ នេះហៅថានិព្វាន ។ ម្នាលអាវុសោ មគ្គនិងបដិបទា

ឯតស្ស និព្វានស្ស សច្ឆិកិរិយាយាតិ ។ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស និព្វានស្ស សច្ឆិកិរិយាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតស្ស និព្វានស្ស សច្ឆិកិរិយាយាតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ឯតស្ស និព្វានស្ស សច្ឆិកិរិយាយ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ បដិបទា ឯតស្ស និព្វានស្ស សច្ឆិកិរិយាយាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា ឯតស្ស និព្វានស្ស សច្ឆិកិរិយាយ អលញ្ច បនាវុសោ សារីបុត្ត អប្បមាទាយាតិ ។ បេ ។

[១៨៦] កឹ នុ ខោ អាវុសោ សារីបុត្ត ឥមស្មឹ ធម្មវិនយេ ទុក្ករន្តិ ។ បព្វជ្ជា ខោ អាវុសោ ឥមស្មឹ ធម្មវិនយេ ទុក្ករាតិ ។ បព្វជិតេន បនាវុសោ កឹ ទុក្ករន្តិ ។ បព្វជិតេន ខោ អាវុសោ អភិរតិ ទុក្ករាតិ ។

សម្រាប់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះ មានដែរឬ ។ ម្នាលអាវុសោ មគ្គនិងបដិបទាសម្រាប់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះមានដែរ ។ ម្នាលអាវុសោ អ្វីជាមគ្គ អ្វីជាបដិបទា សម្រាប់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះ ។ ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង សម្រាប់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះ ។ មគ្គប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ នេះជាមគ្គ នេះជាបដិបទា សម្រាប់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះ ។ ម្នាលអាវុសោ មគ្គដ៏ចម្រើន បដិបទាដ៏ចម្រើន សម្រាប់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះ ម្នាលអាវុសោសារីបុត្ត បើដូច្នោះ បុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។ បេ ។

[១៥៦] ម្នាលអាវុសោសារីបុត្ត អ្វីហ្ន៎ដែលបុគ្គលធ្វើបានដោយកម្រក្នុងធម្មវិន័យនេះ ។ ម្នាលអាវុសោ បព្វជ្ជាដែលបុគ្គលធ្វើបានដោយកម្រក្នុងធម្មវិន័យនេះ ។ ម្នាលអាវុសោ ចុះអ្វីដែលបព្វជិតធ្វើបានដោយកម្រ ។ ម្នាលអាវុសោ សេចក្តីត្រេកអរដែលបព្វជិតធ្វើបានដោយកម្រ ។

អភិរតេន បនាវុសោ កឹ ទុក្ករន្តិ ។ អភិរតេន ខោ អាវុសោ ធម្មានុធម្មប្បដិបត្តិ ទុក្ករាតិ ។ កីវចិរំ បនាវុសោ ធម្មានុធម្មប្បដិបន្នោ ភិក្ខុ អរហំ អស្សាតិ ។ ន ចិរំ អាវុសោតិ ។

សាមណ្ឌកសំយុត្តំ សមត្តំ ។

បុរិមសុត្តសទិសំ ឧទ្ទានំ ។

ម្នាលអាវុសោ ចុះអ្វីដែលបញ្ជិតមានសេចក្ដីត្រេកអរធ្វើបានដោយកម្រ ។ ម្នាលអាវុសោ សេចក្ដីប្រតិបត្តិនូវធម៌តាមធម៌ ដែលបញ្ជិតមានសេចក្ដីត្រេកអរធ្វើបានដោយកម្រ ។ ម្នាលអាវុសោ ចុះភិក្ខុអ្នកប្រតិបត្តិនូវធម៌តាមធម៌ តើយូរប៉ុន្មានទៅ ទើបសម្រេចជាព្រះអរហន្តបាន ។ ម្នាលអាវុសោ មិនជាយូរប៉ុន្មានទេ ។

ចប់ សាមណ្ឌកសំយុត្ត ។

ឧទ្ទានដូចគ្នានឹងសូត្រមុន ។

# មោគ្គល្លានសំយុត្តំ

[១៨៧] ឯកំ សមយំ អាយស្មា មហាមោគ្គល្លានោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ អាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសុំ ។ អាយស្មា មហាមោគ្គល្លានោ ឯតទវោច ឥធ មយ្ហំ អាវុសោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ បឋមជ្ឈានំ បឋមជ្ឈានន្តិ វុច្ចតិ កតមំ នុ ខោ បឋមជ្ឈានន្តិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ បឋមជ្ឈានន្តិ ។ សោ ខ្វាហំ អាវុសោ វិវិច្ចេវ

# មោគ្គល្លានសំយុត្ត

[១៥៧] សម័យមួយ ព្រះមហាមោគ្គល្លានមានអាយុ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមហាមោគ្គល្លានមានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះមហាមោគ្គល្លានដ៏មានអាយុថា អាវុសោ ។ ព្រះមហាមោគ្គល្លានមានអាយុ បានពោលទៅនឹងភិក្ខុទាំងនោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ កាលខ្ញុំសម្ងំនៅក្នុងទីស្ងាត់ ក្នុងទីឯណោះ មានសេចក្តីបរិវិតក្កកើតឡើងដោយចិត្តយ៉ាងនេះថា គេតែងនិយាយថា បឋមជ្ឈានៗ បឋមជ្ឈាន តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កនិងវិចារ មានបីតិនិងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ នេះហៅថា បឋមជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំស្ងាត់

កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ កាមសហគតា សញ្ញាមនសិការា សមុទាចរន្តិ ។ អថខោ មំ អាវុសោ ភគវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណ បឋមជ្ឈានំ បមាទោ បឋមជ្ឈានេ ចិត្តំ សណ្ឋាបេហិ បឋមជ្ឈានេ ចិត្តំ ឯកោទឹ ករោហិ បឋមជ្ឈានេ ចិត្តំ សមាទហាតិ ។ សោ ខ្វាហំ អាវុសោ អបរេន សមយេន វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ សត្ថារានុគ្គហិតោ សាវកោ មហាភិញ្ញតំ បត្តោតិ ។ មមំ តំ សម្មា វទមានោ វទេយ្យ សត្ថារានុគ្គហិតោ សាវកោ មហាភិញ្ញតំ បត្តោតិ ។

ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កនិងវិចារ មានបីតិនិងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នោះ សញ្ញានិងមនសិការដែលប្រកបដោយកាមក៏ផុសផុលឡើង ។ ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចូលទៅរកខ្ញុំដោយឫទ្ធិ ហើយទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗ ព្រាហ្មណ៍ អ្នកកុំធ្វេសប្រហែសនឹងបឋមជ្ឈានឡើយ អ្នកចូរតម្កល់ចិត្តក្នុងបឋមជ្ឈាន ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងបឋមជ្ឈាន ចូរតម្កល់ចិត្តឲ្យនឹងក្នុងបឋមជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ ក្នុងសម័យដទៃទៀត ខ្ញុំស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កនិងវិចារ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ ប្រសិនបើអ្នកផងគេនិយាយចំពោះសាវ័កឯណាថា សាវ័កដែលព្រះសាស្តាអនុគ្រោះហើយ សម្រេចនូវអភិញ្ញាធំ ។ អ្នកផងគួរនិយាយចំពោះសាវ័កនោះគឺខ្ញុំថា សាវ័កដែលព្រះសាស្តាអនុគ្រោះហើយ សម្រេចនូវអភិញ្ញាធំ ។

## មោគ្គល្លានសំយុត្តំ

[១៥៨] ទុតិយជ្ឈានំ ទុតិយជ្ឈានន្តិ វុច្ចតិ ក-តមំ នុ ខោ ទុតិយជ្ឈានន្តិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ ទុតិយជ្ឈានន្តិ ។ សោ ខ្វាហំ អាវុសោ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទ-នំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមា-ធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ វិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ ។ អថខោ មំ អាវុសោ ភគវា ឥទ្ធិយា ឧបសង្កមិត្វា

[១៥៨] គេតែងនិយាយថា ទុតិយជ្ឈានៗ ទុតិយជ្ឈាន តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្ដីត្រិះរិះដូច្នេះ ថាភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់នូវវិតក្កនិងវិចារអស់ហើយ ក៏ដល់នូវទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិនិងសុខកើតអំពីសមាធិ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះហៅថា ទុតិយជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះរម្ងាប់នូវវិតក្កនិងវិចារអស់ហើយ ក៏ដល់នូវទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិនិងសុខកើតអំពីសមាធិ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការដែលប្រកបដោយវិតក្កក៏ផុសផុលឡើង ។ ម្នាលអាវុសោទាំង-ឡាយ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចូលទៅរកខ្ញុំដោយឫទ្ធិ

ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណ ទុតិយជ្ឈានំ បមាទោ ទុតិយជ្ឈានេ ចិត្តំ សណ្ឋាបេហិ ទុតិយជ្ឈានេ ចិត្តំ ឯកោទឹ ករោហិ ទុតិយជ្ឈានេ ចិត្តំ សមាទហាតិ ។ សោ ខ្វាហំ អាវុសោ អបរេន សមយេន វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ សត្ថារានុគ្គហិ-តោ សាវកោ មហាភិញ្ញតំ បត្តោតិ ។ មមំ តំ សម្មា វទមានោ វទេយ្យ សត្ថារានុគ្គហិតោ សាវកោ មហា-ភិញ្ញតំ បត្តោតិ ។

[១៥៩] តតិយជ្ឈានំ តតិយជ្ឈានន្តិ វុច្ចតិ កតមំ នុ ខោ តតិយជ្ឈានន្តិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំ-

ក៏ទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗ ព្រាហ្មណ៍ អ្នកកុំធ្វេសប្រហែសនឹងទុតិយជ្ឈាន អ្នកចូរតម្កល់ចិត្តក្នុងទុតិយជ្ឈាន ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងទុតិយជ្ឈាន ចូរតម្កល់ចិត្តក្នុងទុតិយជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ ក្នុងសម័យដទៃទៀត ខ្ញុំព្រោះរម្ងាប់នូវវិតក្កនិងវិចារអស់ហើយ បានដល់នូវទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួនប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិនិងសុខកើតអំពីសមាធិ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ អ្នកផងគេនិយាយចំពោះសាវ័កឯណាថា សាវ័កដែលព្រះសាស្តាអនុគ្រោះហើយសម្រេចនូវអភិញ្ញាធំ ។ អ្នកផងគួរនិយាយចំពោះសាវ័កនោះគឺខ្ញុំថា សាវ័កដែលព្រះសាស្តាអនុគ្រោះហើយសម្រេចនូវអភិញ្ញាធំ ។

[១៥៩] គេតែងនិយាយថា តតិយជ្ឈានៗ តតិយជ្ឈាន តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង សោយសុខដោយនាមកាយផង

វេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ តតិយជ្ឈានន្តិ ។ សោ ខ្វាហំ អាវុសោ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរាមិ សតោ ច សម្បជា-នោ សុខញ្ច កាយេន បដិសំវេទេមិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិ-យជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ បីតិសហគតា សញ្ញាម-នសិការា សមុទាចរន្តិ ។ អថខោ មំ អាវុសោ ភ-គវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណ តតិយជ្ឈានំ បមាទោ តតិយជ្ឈានេ ចិត្តំ សណ្ឋបេហិ តតិយជ្ឈានេ ចិត្តំ ឯកោទឹ ករោហិ តតិយជ្ឈានេ ចិត្តំ សមាទហាតិ ។

## មោគ្គល្លានសំយុត្ត

ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី ជាអ្នកមានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏ដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះហៅថា តតិយជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង សោយសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី ជាអ្នកមានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏ដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការដែលប្រកបដោយបីតិក៏ផុសផុលឡើង ។ ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចូលមករកខ្ញុំដោយឫទ្ធិ ហើយទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗ ព្រាហ្មណ៍ អ្នកកុំធ្វេសប្រហែសនឹងតតិយជ្ឈានឡើយ ចូរតម្កល់ចិត្តក្នុងតតិយជ្ឈាន ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងតតិយជ្ឈាន ចូរតម្កល់ចិត្តក្នុងតតិយជ្ឈាន ។

សោ ខ្វាហំ អាវុសោ អបរេន សមយេន បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរាមិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេមិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ ។ បេ ។ មហាភិញ្ញតំ បត្តោតិ ។

[១៦០] ចតុត្ថជ្ឈានំ ចតុត្ថជ្ឈានន្តិ វុច្ចតិ កតមំ នុ ខោ ចតុត្ថជ្ឈានន្តិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧប-

ម្នាលអាវុសោទាំងឡាយ សម័យខាងក្រោយមក ខ្ញុំព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង សោយសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី ជាអ្នកមានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏ដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ អ្នកផងគេនិយាយចំពោះសាវ័កឯណា ។ បេ ។ សម្រេចនូវអភិញ្ញាធំ ។

[១៦០] គេតែងនិយាយថា ចតុត្ថជ្ឈានៗ ចតុត្ថជ្ឈាន តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សអស់ទៅក្នុងកាលមុនផង ក៏ដល់នូវចតុត្ថជ្ឈានជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ មានសតិដ៏បរិសុទ្ធ

## មោគ្គល្លានសំយុត្តំ

សម្បជ្ជ វិហរតិ ឥទំ វុច្ចតិ ចតុត្ថជ្ឈានន្តិ ។ សោ ខ្វាហំ អាវុសោ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិចារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧ-បសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ សុខសហគតា សញ្ញាមនសិការា សមុទាចរន្តិ ។ អថខោ មំ អាវុសោ ភគវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណា ចតុត្ថជ្ឈានំ បមាទោ ចតុត្ថជ្ឈានេ ចិត្តំ សណ្ឋាបេហិ ចតុត្ថជ្ឈានេ ចិត្តំ ឯកោទឹ ករោហិ

ដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះ ហៅថា ចតុត្ថជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សអស់ទៅក្នុងកាលមុនផង ក៏ដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខមិនមែនជាសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការប្រកបដោយសេចក្ដីសុខក៏ផុសផុលឡើង ។ ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចូលមករកខ្ញុំដោយឫទ្ធិ ហើយទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗ ព្រាហ្មណ៍ អ្នកកុំធ្វេសប្រហែសនឹងចតុត្ថជ្ឈានឡើយ ចូរតម្កល់ចិត្តក្នុងចតុត្ថជ្ឈាន ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងចតុត្ថជ្ឈាន

ចតុត្ថជ្ឈានេ ចិត្តំ សមាទហាតិ ។ សោ ខ្វាហំ អាវុសោ អបរេន សមយេន សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ ។ បេ ។ មហាភិញ្ញតំ បត្តោតិ ។

[១៦១] អាកាសានញ្ចាយតនំ អាកាសានញ្ចាយតនន្តិ វុច្ចតិ កតមំ នុ ខោ អាកាសានញ្ចាយតនន្តិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ អាកាសានញ្ចាយតនន្តិ ។ សោ ខ្វាហំ អាវុសោ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ

ចូរតម្កល់ចិត្តក្នុងចតុត្ថជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ សម័យខាងក្រោយមក ខ្ញុំព្រោះលះបង់នូវសុខផង ព្រោះលះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សអស់ទៅក្នុងកាលមុនផង ក៏ដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខមិនមែនជាសុខ មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ អ្នកផងគេនិយាយចំពោះសាវ័កឯណា ។ បេ ។ សម្រេចនូវអភិញ្ញាធំ ។

[១៦១] គេតែងនិយាយថា អាកាសានញ្ចាយតនៈៗ អាកាសានញ្ចាយតនៈ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះអស់ទៅនៃបដិឃសញ្ញា លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏ដល់នូវអាកាសានញ្ចាយតនៈ ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះហៅថា អាកាសានញ្ចាយតនៈ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះកន្លងនូវរូបសញ្ញាដោយប្រការទាំងពួង ព្រោះអស់ទៅនៃបដិឃសញ្ញា លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏ដល់នូវអាកាសានញ្ចាយតនៈដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ

មោគ្គល្លានសំយុត្តំ

វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ រូបសហគតា សញ្ញាមនសិការា សមុទាចរន្តិ ។ អថខោ មំ អាវុសោ ភគវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណា អាកាសានញ្ចាយតនំ បមាទោ អាកាសានញ្ចាយតនេ ចិត្តំ សណ្ឋាបេហិ អាកាសានញ្ចាយតនេ ចិត្តំ ឯកោទឹ ករោហិ អាកាសានញ្ចាយតនេ ចិត្តំ សមាទហាតិ ។ សោ ខោហំ អាវុសោ អបរេន សមយេន សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ ។ បេ ។ មហាភិញ្ញតំ បត្តោតិ ។

ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការប្រកបដោយរូបក៏ផុសផុលឡើង ។ ម្នាលអាវុសោទាំងឡាយ គ្រានោះឯងព្រះមានព្រះភាគទ្រង់ចូលមករកខ្ញុំដោយឫទ្ធិ ទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗ ព្រាហ្មណ៍ អ្នកកុំធ្វេសប្រហែសនឹងអាកាសានញ្ចា-យតនជ្ឈានឡើយ ចូរតម្កល់ចិត្តក្នុងអាកាសានញ្ចាយតនជ្ឈាន ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងអាកាសានញ្ចាយតនជ្ឈាន ចូរតម្កល់ចិត្តក្នុងអាកាសានញ្ចាយតនជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ សម័យខាងក្រោយមក ខ្ញុំព្រោះកន្លងនូវរូបសញ្ញាដោយប្រការទាំងពួង ព្រោះអស់ទៅនៃបដិឃសញ្ញា លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏ដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ អ្នកផងគេនិយាយចំពោះសាវ័កឯណា ។ បេ ។ សម្រេចនូវអភិញ្ញាធំ ។

[១៦២] វិញ្ញាណញ្ចាយតនំ វិញ្ញាណញ្ចាយតនន្តិ វុច្ចតិ កតមំ នុ ខោ វិញ្ញាណញ្ចាយតនន្តិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ វិញ្ញាណញ្ចាយតនន្តិ ។ សោ ខោហំ អាវុសោ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ។ អថខោ មំ អាវុសោ ភគវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណ វិញ្ញាណញ្ចាយតនំ បមាទោ វិញ្ញាណញ្ចាយតនេ ចិត្តំ សណ្ឋាបេហិ វិញ្ញាណញ្ចាយតនេ ចិត្តំ ឯកោទឹ ករោហិ វិញ្ញាណញ្ចាយតនេ ចិត្តំ សមាទហាហិ ។ សោ ខោហំ អាវុសោ អបរេន សមយេន

[១៦២] *គេតែងនិយាយថា វិញ្ញាណញ្ចាយតនៈៗ វិញ្ញាណញ្ចាយតនៈ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះហៅថា វិញ្ញាណញ្ចាយតនៈ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ហើយសម្រេចសម្រាន្តនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការ ដែលប្រកបដោយអាកាសានញ្ចាយតនជ្ឈាន ក៏ផុសផុលឡើង ។ ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចូលមករកខ្ញុំដោយឫទ្ធិ ទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗ ព្រាហ្មណ៍ អ្នកកុំធ្វេសប្រហែសនឹងវិញ្ញាណញ្ចាយតនជ្ឈានឡើយ ចូរតម្កល់ចិត្តក្នុងវិញ្ញាណញ្ចាយតនជ្ឈាន ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងវិញ្ញាណញ្ចាយតនជ្ឈាន ចូរកំណត់ចិត្តក្នុងវិញ្ញាណញ្ចាយតនជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ សម័យខាងក្រោយមក*

សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ ។ បេ ។ មហាភិញ្ញតំ បត្តោតិ ។

[១៦៣] អាកិញ្ចញ្ញាយតនំ អាកិញ្ចញ្ញាយតនន្តិ វុច្ចតិ កតមំ នុ ខោ អាកិញ្ចញ្ញាយតនន្តិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អា-កិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ អាកិញ្ចញ្ញាយតនន្តិ ។ សោ ខោហំ អាវុសោ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ

ខ្ញុំព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ អ្នកផងគេនិយាយចំពោះសាវ័កឯណា ។ បេ ។ សម្រេចនូវអភិញ្ញាធំ ។

[១៦៣] គេតែងនិយាយថា អាកិញ្ចញ្ញាយតនៈៗ អាកិញ្ចញ្ញាយតនៈ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះហៅថា អាកិញ្ចញ្ញាយតនជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នេះ

វិញ្ញាណញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ។ អថខោ មំ អាវុសោ ភគវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណ អាកិញ្ចញ្ញាយតនំ បមាទោ អាកិញ្ចញ្ញាយតនេ ចិត្តំ សណ្ឋបេហិ អាកិញ្ចញ្ញាយតនេ ចិត្តំ ឯកោទឹ ករោហិ អាកិញ្ចញ្ញាយតនេ ចិត្តំ សមាទហាតិ ។ សោ ខោហំ អាវុសោ អបរេន សមយេន សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ ។ បេ ។ មហាភិញ្ញតំ បត្តោតិ ។

[១៦៤] នេវសញ្ញានាសញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនន្តិ វុច្ចតិ កតមំ នុ ខោ នេវសញ្ញានាសញ្ញាយតនន្តិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ឥទំ

សញ្ញានិងមនសិការប្រកបដោយវិញ្ញាណញ្ចាយតនៈ ក៏ផុសផុលឡើង ។ ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចូលមករកខ្ញុំដោយឫទ្ធិ ទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗ ព្រាហ្មណ៍ អ្នកកុំធ្វេសប្រហែសនឹងអាកិញ្ចញ្ញាយតនជ្ឈានឡើយ ចូរតម្កល់ចិត្តក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ចូរតម្កល់ចិត្តក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ សម័យខាងក្រោយមក ខ្ញុំព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង ក៏ដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ អ្នកផងគេនិយាយចំពោះសាវ័កឯណា ។ បេ ។ សម្រេចនូវអភិញ្ញាធំ ។

[១៦៤] គេតែងនិយាយថា នេវសញ្ញានាសញ្ញាយតនៈៗ នេវសញ្ញានាសញ្ញាតនៈ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួង ក៏ដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះ

វុច្ចតិ នេវសញ្ញានាសញ្ញាយតនន្តិ ។ សោ ខោហំ អាវុសោ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហារាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ អាកិញ្ចញ្ញាយតនសហគតា សញ្ញាមនសិការា ស-មុទាចរន្តិ ។ អថខោ មំ អាវុសោ ភគវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណ នេវសញ្ញានាសញ្ញាយតនំ បមាទោ នេវសញ្ញានាសញ្ញាយតនេ ចិត្តំ សណ្ឋបេហិ នេវ-សញ្ញានាសញ្ញាយតនេ ចិត្តំ ឯកោទឹ ករោហិ នេវ-សញ្ញានាសញ្ញាយតនេ ចិត្តំ សមាទហាតិ ។ សោ ខោហំ អាវុសោ អបរេន សមយេន សព្វសោ អា-កិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយ-តនំ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ ។ បេ ។ មហាភិញ្ញតំ បត្តោតិ ។

ហៅថា នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួង ក៏ដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិ-យាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការដែលប្រកបដោយអាកិញ្ចញ្ញាយតនជ្ឈាន ក៏ផុសផុលឡើង ។ ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចូលមករកខ្ញុំដោយឫទ្ធិ ក៏ទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗព្រាហ្មណ៍ អ្នកកុំធ្វេសប្រហែស នឹងនេវសញ្ញានាសញ្ញាយតនជ្ឈានឡើយ ចូរតម្កល់ចិត្តក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន ចូរតម្កល់ចិត្តក្នុងនេវ-សញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលអាវុសោទាំងឡាយ សម័យខាងក្រោយមក ខ្ញុំព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួង ក៏ដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ អ្នកផងគេនិយាយចំពោះសាវ័កឯណា ។ បេ ។ សម្រេចនូវអភិញ្ញាធំ ។

[១៦៨] អនិមិត្តោ ចេតោសមាធិ អនិមិត្តោ ចេតោសមាធីតិ វុច្ចតិ កតមោ នុ ខោ អនិមិត្តោ ចេតោសមាធីតិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ឥធ ភិក្ខុ សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ អនិមិត្តោ ចេតោសមាធីតិ ។ សោ ខោហំ អាវុសោ សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោសមាធិំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ ឥមិនា វិហារេន វិហរតោ អនិមិត្តានុសារីវិញ្ញាណំ ហោតិ ។ អថខោ មំ អាវុសោ ភគវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន មោគ្គល្លាន មា ព្រាហ្មណ

[១៦៨] គេតែងនិយាយថា ចេតោសមាធិមិនមាននិមិត្តៗ ចេ-តោសមាធិមិនមាននិមិត្ត តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង ក៏ដល់នូវចេតោសមាធិមិនមាននិមិត្ត ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះហៅថា ចេតោសមាធិមិនមាននិមិត្ត ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង ក៏ដល់នូវចេតោសមាធិមិនមាននិមិត្ត ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នេះ អនិមិត្តានុសារិវិញ្ញាណក៏កើតឡើង ។ ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចូលមករកខ្ញុំដោយឫទ្ធិ ទ្រង់ត្រាស់ដូច្នេះថា ម្នាលមោគ្គល្លានៗ ព្រាហ្មណ៍ អ្នកកុំ

អនិមិត្តំ ចេតោសមាធឹ បមាទោ អនិមិត្តេ ចេតោសមាធិស្មឹ ចិត្តំ សណ្ឋាបេហិ អនិមិត្តេ ចេតោសមាធិស្មឹ ចិត្តំ ឯកោទឹ ករោហិ អនិមិត្តេ ចេតោសមាធិស្មឹ ចិត្តំ សមាទហាតិ ។ សោ ខ្វាហំ អាវុសោ អបរេន សមយេន សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោសមាធឹ ឧបសម្បជ្ជ វិហាសឹ ។ យំ ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ សត្ថារានុគ្គហិតោ សាវកោ មហាភិញ្ញតំ បត្តោតិ ។ មមំ តំ សម្មា វទមានោ វទេយ្យ សត្ថារានុគ្គហិតោ សាវកោ មហាភិញ្ញតំ បត្តោតិ ។

[១៦៦] អថខោ អាយស្មា មហាមោគ្គល្លានោ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ ទេវេសុ តាវត្តឹសេសុ បាតុរហោសិ ។ អថខោ សក្កោ ទេវានមិន្ទោ

ធ្វេសប្រហែសនឹងចេតោសមាធិមិនមាននិមិត្តឡើយ ចូរតម្កល់ចិត្តក្នុងចេតោសមាធិមិនមាននិមិត្ត ចូរធ្វើចិត្តឲ្យមានអារម្មណ៍តែមួយក្នុងចេតោ-សមាធិមិនមាននិមិត្ត ចូរតម្កល់ចិត្តក្នុងចេតោសមាធិមិនមាននិមិត្ត ។ ម្នាលអាវុសោទាំងឡាយ សម័យខាងក្រោយមក ខ្ញុំព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង ក៏ដល់នូវចេតោសមាធិមិនមាននិមិត្ត ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ អ្នកផងគេនិយាយចំពោះសាវ័កឯណាថា សាវ័កដែលព្រះសាស្តាអនុគ្រោះហើយសម្រេចអភិញ្ញាធំ ។ អ្នកផងគួរនិយាយចំពោះសាវ័កនោះ គឺខ្ញុំថា សាវ័កដែលព្រះសាស្តាទ្រង់អនុគ្រោះហើយ សម្រេចអភិញ្ញាធំ ។

[១៦៦] គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ បាត់អំពីវត្តជេតពន ស្រាប់តែប្រាកដក្នុងតាវត្តិង្សទេវលោក ដូចបុរសមានកម្លាំងលានូវដៃដែលបត់ ឬបត់នូវដៃដែលលា ។ គ្រានោះឯង សក្កទេវានមិន្ទ

បញ្ចហិ ទេវតាសតេហិ សទ្ធឹ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច សាធុ ខោ ទេវានមិន្ទ ពុទ្ធសរណគមនំ ហោតិ ។ ពុទ្ធសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ ធម្មសរណគមនំ ហោតិ ។ ធម្មសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ សង្ឃសរណគមនំ ហោតិ ។ សង្ឃសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា

ព្រមទាំងទេវតា ៥០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសក្កទេវានមិន្ទឋិតនៅក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានមានអាយុនិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះធម៌ជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះសង្ឃជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះសង្ឃជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ

សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធសរណគមនំ ហោតិ ។ ពុទ្ធសរណគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មសរណគមនំ ហោតិ ។ ធម្មសរណគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន សង្ឃសរណគមនំ ។ បេ ។ សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។

[១៦៧] អថខោ សក្កោ ទេវានមិន្ទោ ឆហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។ អថខោ សក្កោ ទេវានមិន្ទោ សត្តហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។ អថខោ សក្កោ ទេវានមិន្ទោ អដ្ឋហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។

តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រព្រះ មោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវ ព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុង សុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។ បពិត្រព្រះមោគ្គល្លានអ្នក និរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះធម៌ជាទីពឹង ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវ-លោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការដល់នូវព្រះ សង្ឃជាទីពឹងប្រពៃណាស់ ។ បេ ។ តែងកើតក្នុងសុគតិសួគ៌ទេវលោក យ៉ាងនេះឯង ។

[១៦៧] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៦០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៧០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨០០ អង្គ ។ បេ ។

[១៦៨] អថខោ សក្កោ ទេវានមិន្ទោ អសីតិយា ទេវតាសហស្សេហិ[១] សទ្ធឹ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច សាធុ ខោ ទេវានមិន្ទ ពុទ្ធសរណគមនំ ហោតិ ។ ពុទ្ធសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ ធម្មសរណគមនំ ហោតិ ។ ធម្មសរណ-
ទេវានមិន្ទ ធម្មសរណគមនំ ហោតិ ។ ធម្មសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ សង្ឃសរណគមនំ ហោតិ ។ សង្ឃសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា

១ ឱ. អសីតិយា ទេវាសតេហិ ។

[១៦៨] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨០.០០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុហើយឋិតនៅក្នុងទីសមគួរ ។ លុះសក្កទេវានមិន្ទឋិតនៅក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានមានអាយុបាននិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះធម៌ជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះសង្ឃជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះសង្ឃជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ

សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធសរណគមនំ ហោតិ ។ ពុទ្ធសរណគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មសរណគមនំ ហោតិ ។ បេ ។ សាធុ ខោ មារិស មោគ្គល្លាន សង្ឃសរណគមនំ ហោតិ ។ សង្ឃសរណគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។

[១៦៩] អថខោ សក្កោ ទេវានមិន្ទោ បញ្ចហិ ទេវតាសតេហិ សទ្ធឹ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច សាធុ ខោ ទេវានមិន្ទ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា

តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។ បេ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ការដល់នូវព្រះសង្ឃជាទីពឹងប្រពៃណាស់ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះសង្ឃជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។

[១៦៩] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៥០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសក្កទេវានមិន្ទឋិតនៅក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានមានអាយុបាននិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ

អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ស្វាក្ខាតោ[១] ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ

១ ឱ. ម. ស្វាក្ខ្យាតោ ។

ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ជាបុគ្គលប្រសើរបំផុត ព្រះអង្គជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយដោយប្រពៃ ជាធម៌គឺព្រះអរិយបុគ្គលឃើញច្បាស់ខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌ដែលព្រះអរិយ-បុគ្គលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជន គប្បីដឹងច្បាស់ដោយខ្លួនឯង ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា

១៨១

## មោគ្គល្លានសំយុត្តំ

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ អរិយកន្តេហិ សីលេហិ សមន្នាគមនំ[១] ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ

១ ឱ. អវេច្ចសមន្នាគមនំ ។

មោគ្គល្លានសំយុត្ត

ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិល្អ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិត្រង់ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹង ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិគួរដល់សាមីចិកម្ម បើរាប់ជាគូនៃបុរសមាន ៤ គូ រាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃនោះជាសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលដទៃបង្អោនចូលមកបូជា លោកគួរទទួលនូវទានដែលបុគ្គលដទៃ ចាត់ចែងដើម្បីភ្ញៀវហើយបង្អោនចូលមកបូជា លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ លោកជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ជាសីលអ្នកជា

វិញ្ញូបសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធេ អវេច្ចប្ប-សាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មេ អវេច្ចប្បសាទេន សមន្នា-គមនំ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ ។ បេ ។

ជាសីលដែលវិញ្ញូជនសរសើរ ជាអបរាមដ្ឋសីល ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសីលជាទីត្រេកអរ នៃព្រះអរិយៈហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ល្អហើយ ។ បេ ។

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ធម្មេ អវេច្ចប្បសាទេន ស-
មន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ
សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ
លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន
សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ សុ-
បដិបន្នោ ភគវតោ សាវកសង្ឃោ ។ បេ ។ អនុត្តរំ
បុញ្ញក្ខេត្តំ លោកស្សាតិ ។ សង្ឃេ អវេច្ចប្បសាទេន
សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេ-
កច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ
សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គ-
ល្លាន អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ
អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយ-
កន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ មារិស
មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ
មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។

ជាធម៌ដែលវិញ្ញូជនគប្បីដឹងច្បាស់ ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិល្អ ។ បេ ។ លោកជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្ដីជ្រះថ្លា មិនកម្រើក្នុងព្រះសង្ឃហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវ-លោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ ។ បេ ។ ប្រព្រឹត្តទៅដើម្បីសមាធិ ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។

[១៧០] អថខោ សក្កោ ទេវានមិន្ទោ ឆហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។ អថខោ សក្កោ ទេវានមិន្ទោ សត្តហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។ អថខោ សក្កោ ទេវានមិន្ទោ អដ្ឋហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។

[១៧១] អថខោ សក្កោ ទេវានមិន្ទោ អសីតិយា ទេវតាសហស្សេហិ សទ្ធឹ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច សាធុ ខោ ទេវានមិន្ទ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគ-

[១៧០] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៦០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៧០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨០០ អង្គ ។ បេ ។

[១៧១] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨០.០០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុ ហើយឋិតក្នុងទីសមគួរ ។ លុះសក្កទេវានមិន្ទឋិតក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុបាននិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្ដីជ្រះថ្លាមិនកម្រើក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិល

ភាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ ។ បេ ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ធម្មេ អវេច្ចប្បសាទេន ស-មន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ ទេវានមិន្ទ សង្ឃេ អវេច្ចប្ប-សាទេន សមន្នាគមនំ ហោតិ សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោក-ស្សាតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគមន-ហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។

មកកាន់ភពថ្មីទៀត ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ល្អហើយ ។ បេ ។ ជាធម៌ដែលវិញ្ញូជនគប្បីដឹងច្បាស់ ជាការប្រពៃពិត ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិល្អហើយ ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។

សាធុ ខោ ទេវានមិន្ទ អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ ។ បេ ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា

បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសីលជាទីត្រេកអរ នៃព្រះអរិយៈ ជាសីលមិនដាច់ ។ បេ ។ ប្រព្រឹត្តទៅដើម្បីសមាធិ ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបដោយ សីលជាទីត្រេកអរ នៃព្រះអរិយៈហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្ដីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្ដានៃទេវតានិងមនុស្សទាំង-ឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុ តែប្រកបព្រមដោយសេចក្ដីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធហើយ លុះបែក ធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបពុរមដោយសេចក្ដីជ្រះថ្លាមិន កម្រើក ក្នុងព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ល្អហើយ ។ បេ ។ ជាធម៌ដែលវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ជាការប្រពៃ ពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះ ហេតុតែប្រកបព្រមដោយសេចក្ដីជ្រះថ្លា មិនកម្រើក ក្នុងព្រះធម៌ហើយ

១៨៧

មោគ្គល្លានសំយុត្តំ

កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគ-មនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន អរិយ-កន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សី-លេហិ សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។

លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាង នេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិល្អហើយ ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ ។ បេ ។ ប្រព្រឹត្តទៅដើម្បីសមាធិ ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង ។

[១៧២] អថខោ សក្កោ ទេវានមិន្ទោ បញ្ចហិ ទេវតាសតេហិ សទ្ធឹ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ ឯកមន្តំ ឋិតំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លានោ ឯតទ-វោច សាធុ ខោ ទេវានមិន្ទ ពុទ្ធសរណគមនំ ហោតិ ។ ពុទ្ធសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេ-ហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ ទេវានមិន្ទ ធម្មសរណគមនំ ហោតិ ។ ធម្មសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ

[១៧២] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៥០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ ។ បេ ។ លុះសក្កទេវានមិន្ទឋិតក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានមានអាយុបាននិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ព័ណ៌សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វរ ១ ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះធម៌ជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង

១៨៩

## មោគ្គល្លានសំយុត្តំ

តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យ-សេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោ-ដ្ឋព្វេហិ ។ សាធុ ខោ ទេវានមិន្ទ សង្ឃសរណគមនំ ហោតិ ។ សង្ឃសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហីតិ ។ សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធ-សរណគមនំ ហោតិ ។ ពុទ្ធសរណគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ

សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ព័ណ៌សម្បុរជាទិព្វ ១ សេចក្ដីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះសង្ឃជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះសង្ឃជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោក សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ព័ណ៌សម្បុរជាទិព្វ ១ សេចក្ដីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង

តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មសរណគមនំ ហោតិ ។ បេ ។ សាធុ ខោ មារិស មោគ្គល្លាន សង្ឃសរណគមនំ ហោតិ ។ សង្ឃសរណគមនហេតុ ខោ មារិស មោគ្គ-ល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហីតិ ។

[១៧៣] អថខោ សក្កោ ទេវានមិន្ទោ ឆហិ ទេវតា-សតេហិ សទ្ធឹ ។ បេ ។ អថខោ សក្កោ ទេវានមិន្ទោ សត្តហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។ អថខោ សក្កោ ទេវានមិន្ទោ អដ្ឋហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។

សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។ បេ ។ បពិត្រ ព្រះមោគ្គល្លានអ្នកនិរទុក្ខ ការដល់នូវព្រះសង្ឃជាទីពឹងប្រពៃណាស់ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះសង្ឃជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាន នូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ព័ណ៌ សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈ ជាទិព្វ ១ ។

[១៧៣] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៦០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៧០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៧០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨០០ អង្គ ។ បេ ។

១៦១

## មោគ្គល្លានសំយុត្តំ

[១៧៤] អថខោ សក្កោ ទេវានមិន្ទោ អសីតិយា ទេវតាសហស្សេហិ សទ្ធឹ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច សាធុ ខោ ទេវានមិន្ទ ពុទ្ធសរណគមនំ ហោតិ ។ ពុទ្ធសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ ទេវានមិន្ទ ធម្មសរណគមនំ ហោតិ ។ បេ ។ សាធុ ខោ ទេវានមិន្ទ សង្ឃសរណគមនំ ហោតិ ។ សង្ឃសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ

## មោគ្គល្លានសំយុត្ត

[១៧៤] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨០.០០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសក្កទេវានមិន្ទឋិតក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានមានអាយុបាននិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះ រមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។ បេ ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះសង្ឃជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះសង្ឃជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោក យ៉ាងនេះឯង

តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហីតិ ។ សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធសរណគមនំ ហោតិ ។ បេ ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មសរណគមនំ ហោតិ ។ បេ ។ សាធុ ខោ មារិស មោគ្គល្លាន សង្ឃសរណ-គមនំ ហោតិ ។ សង្ឃសរណគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហីតិ ។

*សត្វទាំងនោះរមែងបានទ្រព្យរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ពណ៌សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បេ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។ បេ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការដល់នូវព្រះសង្ឃជាទីពឹងប្រពៃណាស់ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះសង្ឃជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះ រមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ពណ៌សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។*

១៦៣

## មោគ្គល្លានសំយុត្តំ

[១៧៤] អថខោ សក្កោ ទេវានមិន្ទោ បញ្ចហិ ទេវតាសតេហិ សទ្ធឹ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច សាធុ ខោ ទេវានមិន្ទ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ ទេវានមិន្ទ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ។ បេ ។ សាធុ ខោ ទេវានមិន្ទ

មោគ្គល្លានសំយុត្ត

[១៧៥] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៥០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសក្កទេវានមិន្ទឋិតក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ ជាការប្រពៃណាស់ ។ បេ ។ បពិត្រទេវានមិន្ទ

សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ។ បេ ។ សាធុ ខោ ទេវានមិន្ទ អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហីតិ ។ សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។

ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃ ជាការប្រពៃណាស់ ។ បេ ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសីល ជាទីត្រេកអរនៃព្រះអរិយៈហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវ-លោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។

## មោគ្គល្លានសំយុត្តំ

សាធុ ខោ មារិស មោគ្គល្លាន ធម្មេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ ។ បេ ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេ-ហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ មារិស មោគ្គល្លាន សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគម-នហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អ-ធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។បេ។ ទិព្វេហិ ផោដ្ឋព្វេហិ ។

មោគ្គល្លានសំយុត្ត

បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ល្អហើយ ។ បេ ។ ជាធម៌ដែលវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវកនៃព្រះមានព្រះភាគលោកប្រតិបត្តិល្អហើយ ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។

សាធុ ខោ មារិស មោគ្គល្លាន អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហីតិ ។

[១៧៦] អថខោ សក្កោ ទេវានមិន្ទោ ឆហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។ អថខោ សក្កោ ទេវានមិន្ទោ សត្តហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។ អថខោ សក្កោ ទេវានមិន្ទោ អដ្ឋហិ ទេវតាសតេហិ សទ្ធឹ ។ បេ ។

បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។

[១៧៦] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៦០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៧០០ អង្គ ។ បេ ។ គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨០០ អង្គ ។ បេ ។

១៦៧

មោគ្គល្លានសំយុត្តំ

[១៧៧] អថខោ សក្កោ ទេវានមិន្ទោ អសីតិយា ទេវតាសហស្សេហិ សទ្ធឹ យេនាយស្មា មហាមោគ្គល្លា-នោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហា-មោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លា-នោ ឯតទវោច សាធុ ខោ ទេវានមិន្ទ ពុទ្ធេ អវេច្ចប្បសា-ទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហិ ។

## មោគ្គល្លានសំយុត្ត

[១៧៧] គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨០.០០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុ ហើយឋិតក្នុងទីសមគួរ ។ លុះសក្កទេវានមិន្ទឋិតក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុបាននិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ជាបុគ្គលប្រសើរ ជាសារថីទូន្មាននូវបុរស ជាសាស្ដានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ព័ណ៌សម្បុរជាទិព្វ ១ សេចក្ដីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។

សាធុ ខោ ទេវានមិន្ទ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ ទេវានមិន្ទ សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរសយុគានិ

បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ល្អហើយ ជាធម៌ដែលព្រះអរិយបុគ្គលឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌ដែលព្រះអរិយបុគ្គលបានសម្រេចមគ្គផលហើយ គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ដែលព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិល្អហើយ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹង ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិគួរដល់សាមីចិកម្ម បើរាប់ជាគូនៃបុរសមាន ៤ គូ

១៦៩

មោគ្គល្លានសំយុត្តំ

អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ ទេវានមិន្ទ អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញូបសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ

រាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃទាំងនោះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលដទៃបង្អោនចូលមកបូជា លោកគួរទទួលនូវទានដែលបុគ្គលចាត់ចែងដើម្បីភ្ញៀវ ហើយបង្អោនចូលមកបូជា លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ លោកជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រទេវានមិន្ទ ការប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ជាសីលអ្នកជា ជាសីលដែលវិញ្ញូជនសរសើរ ជាអបរាមដ្ឋសីល ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ជាការប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈហើយ លុះបែកធ្លាយរាងកាយ

មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហីតិ ។ សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។

ស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ព័ណ៌សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត ជាការប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។

ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ ។ បេ ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ សាធុ ខោ មារិស មោគ្គល្លាន សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។

*ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រម ដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ធម៌ដែលព្រះមានព្រះ ភាគទ្រង់ត្រាស់ល្អហើយ ។ បេ ។ ជាធម៌ដែលវិញ្ញូជនគប្បីដឹងច្បាស់ ដោយខ្លួនឯង ប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិ សួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសេចក្តីជ្រះថ្លាមិន កម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោក ប្រតិបត្តិល្អហើយ ។ បេ ។ លោកជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រម ដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃ ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវ-លោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយ ឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។*

សាធុ ខោ មារិស មោគ្គល្លាន អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តេ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហីតិ ។

[១៧៨] អថខោ ចន្ទនោ ទេវបុត្តោ ។ បេ ។ អថខោ សុយាមោ ទេវបុត្តោ ។ អថខោ សន្តុសិតោ ទេវបុត្តោ ។ អថខោ សុនិម្មិតោ ទេវបុត្តោ ។ អថខោ វសវត្តិ ទេវបុត្តោ ។ (ឥមេ បញ្ច បេយ្យាលា[១] យថា សក្កោ ទេវានមិន្ទោ តថា វិត្ថារេតព្វាតិ) ។

មោគ្គល្លានសំយុត្តំ សមត្តំ ។

---

១ ម. ចេយ្យាលី ។

បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ការប្រកបព្រមដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិប្រពៃពិត ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែប្រកបព្រម ដោយសីលជាទីត្រេកអរនៃព្រះអរិយៈហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះរមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាងគឺ អាយុជាទិព្វ ១ ព័ណ៌សម្បុរជាទិព្វ ១ សេចក្ដីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។

[១៧៨] គ្រានោះឯង ចន្ទនទេវបុត្ត ។ បេ ។ គ្រានោះឯង សុយាមទេវបុត្ត ។ គ្រានោះឯង សន្តុសិតទេវបុត្ត ។ គ្រានោះឯង សុនិម្មិតទេវបុត្ត ។ គ្រានោះឯង វសវត្តិទេវបុត្ត ។ (បេយ្យាលទាំង ៥ នេះ បណ្ឌិតត្រូវសំដែងឲ្យពិស្តារដូចជារឿងសក្កទេវានមិន្ទផងចុះ) ។

ចប់ មោគ្គល្លានសំយុត្ត ។

១៧៣

មោគ្គល្លានសំយុត្តំ

## តស្សុទ្ទានំ

សវិតក្កាវិតក្កញ្ច
សុខេន ច ឧបេក្ខកោ
អាកាសញ្ចេវ វិញ្ញាណំ
អាកិញ្ចញ្ញា នេវសញ្ញិនា[១]
អនិមិត្តោ ច សក្កោ ច
ចន្ទនេកាទសេន ចាតិ ។

១ ឱ. ម. អាកិញ្ចនេវសញ្ញិនា ។

មោគ្គល្លានសំយុត្ត

# ឧទ្ទាននៃមោគ្គល្លានសំយុត្តនោះគឺ

*និយាយអំពីឈានដែលប្រកបដោយវិតក្ក ១ អំពីឈានដែលមិនមានវិតក្ក ១ អំពីការសោយសេចក្ដីសុខដោយកាយ ១ អំពីកិរិយានៅព្រងើយកន្ដើយ ១ អំពីអាកាសានញ្ចាយតនដ្ឋាន ១ អំពីវិញ្ញាណញ្ចាយតនដ្ឋាន ១ អំពីអាកិញ្ចញ្ញាយតនដ្ឋាន ១ អំពីនេវសញ្ញានាសញ្ញាយតនដ្ឋាន ១ អំពីចេតោសមាធិមិនមាននិមិត្ត ១ អំពីសក្កទេវានមិន្ទ ១ អំពីចន្ទនទេវបុត្ត (ជាដើម) ១ រួបរួមជា ១១ ។*

# ចិត្តគហបតិបុច្ឆាសំយុត្តំ

[១៧៩] ឯកំ សមយំ សម្ពហុលា ថេរា ភិក្ខូ មច្ឆិកាសណ្ឌេ វិហរន្តិ អម្ពាដកវនេ ។ តេន ខោ បន សមយេន សម្ពហុលានំ ថេរានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ សញ្ញោជនន្តិ វា អាវុសោ សញ្ញោជនិយា(១) ធម្មាតិ វា ឥមេ ធម្មា នានត្ថា នានាព្យញ្ជនា ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ តត្រេកច្ចេហិ ថេរេហិ ភិក្ខូហិ ឯវំ ព្យាកតំ ហោតិ សញ្ញោជនន្តិ វា អាវុសោ សញ្ញោជនិយា ធម្មាតិ វា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ចាតិ ។ ឯកច្ចេហិ ថេរេហិ ភិក្ខូហិ ឯវំ ព្យាកតំ ហោតិ សញ្ញោជនន្តិ វា អាវុសោ សញ្ញោជនិយា ធម្មាតិ វា ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។

---

១ សញ្ញោជនីយាតិបិ ។

# ចិត្តគហបតិបុច្ឆាសំយុត្ត

[១៧៩] សម័យមួយ ភិក្ខុជាថេរៈច្រើនរូបគង់នៅក្នុងវត្តអម្ពាដកវ័ន នាដង់ព្រៃមច្ឆិកា ។ សម័យនោះឯង កាលដែលភិក្ខុជាថេរៈច្រើនរូបត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត បានអង្គុយប្រជុំគ្នាក្នុងរោងសម្រាប់អង្គុយ ក៏មានអន្តរាកថានេះកើតឡើងថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី[១] មានអត្ថផ្សេងគ្នា មានព្យញ្ជនៈផ្សេងគ្នា ឬមានអត្ថដូចគ្នា[២] ផ្សេងគ្នាតែព្យញ្ជនៈ[៣] ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុជាថេរៈពួកខ្លះ ដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ ភិក្ខុជាថេរៈពួកខ្លះ ដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។

---

១ ធម៌ជាហេតុនៃសញ្ញោជនៈ ។ ២ រូបសេចក្តី ។ ៣ ជាឈ្មោះឬតួអក្សរ ។

## ចិត្តគហបតិបុច្ឆាសំយុត្តំ

[១៨០] តេន ខោ បន សមយេន ចិត្តោ គហបតិ មិគបថកំ អនុប្បត្តោ ហោតិ កេនចិទេវ ករណី-យេន ។ អស្សោសិ ខោ ចិត្តោ គហបតិ សម្ពហុលានំ កិរ ថេរានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរា-កថា ឧទបាទិ សញ្ញោជនន្តិ វា អាវុសោ សញ្ញោជនិ-យា ធម្មាតិ វា ឥមេ ធម្មា នានត្ថា នានាព្យញ្ជនា ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ តត្រេកច្ចេហិ ថេរេហិ ភិក្ខូហិ ឯវំ ព្យាកតំ សញ្ញោជនន្តិ វា អាវុសោ សញ្ញោជនិយា ធម្មាតិ វា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ចាតិ ។ ឯកច្ចេហិ ថេរេហិ ភិក្ខូហិ ឯវំ ព្យាកតំ សញ្ញោជនន្តិ វា អាវុសោ សញ្ញោជនិយា ធម្មាតិ វា ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។

ចិត្តគហបតិបុច្ឆាសំយុត្ត

[១៨០] សម័យនោះឯង ចិត្តគហបតីបានទៅដល់ស្រុកមិគបថកៈ ដោយកិច្ចនីមួយ ។ ចិត្តគហបតីបានឮដំណឹងថា កាលភិក្ខុជាថេរៈច្រើនរូបត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត បានអង្គុយប្រជុំគ្នាក្នុងរោងសម្រាប់អង្គុយ ក៏មានអន្តរាកថានេះកើតឡើងថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថផ្សេងគ្នា មានព្យញ្ជនៈផ្សេងគ្នា ឬមានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុជាថេរៈពួកខ្លះ ដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ ភិក្ខុជាថេរៈពួកខ្លះ ដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។

[១៨១] អថខោ ចិត្តោ គហបតិ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេ ភិក្ខូ អភិ-វាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចិត្តោ គហបតិ ថេរេ ភិក្ខូ ឯតទវោច សុតមេតំ ភន្តេ សម្ពហុលានំ កិរ ថេរានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌ-បាតប្បដិក្កន្តានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និ-បតិតានំ អយមន្តរាកថា ឧទបាទិ សញ្ញោជនន្តិ វា អាវុសោ សញ្ញោជនិយា ធម្មាតិ វា ឥមេ ធម្មា នានត្ថា នានាព្យញ្ជនា ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ ឯកច្ចេហិ ថេរេហិ ភិក្ខូហិ ឯវំ ព្យាកតំ សញ្ញោជនន្តិ វា អាវុសោ សញ្ញោជនិយា ធម្មាតិ វា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ចាតិ ។ ឯកច្ចេហិ ថេ-រេហិ ភិក្ខូហិ ឯវំ ព្យាកតំ សញ្ញោជនន្តិ វា អាវុសោ

[១៨១] គ្រានោះ ចិត្តគហបតីចូលទៅរកពួកភិក្ខុជាថេរៈ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំពួកភិក្ខុជាថេរៈ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ក៏ទូលសួរទៅនឹងពួកភិក្ខុជាថេរៈដូច្នេះថា បពិត្រលោកដ៏ចម្រើនខ្ញុំបានឮដំណឹងដូច្នេះថា កាលដែលភិក្ខុជាថេរៈច្រើនរូបត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត បានអង្គុយប្រជុំគ្នាក្នុងរោងសម្រាប់អង្គុយ ក៏មានអន្តរាកថានេះកើតឡើងថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថផ្សេងគ្នា មានព្យញ្ជនៈផ្សេងគ្នា ឬមានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។ ភិក្ខុជាថេរៈពួកខ្លះ ដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ ភិក្ខុជាថេរៈពួកខ្លះ ដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ

សញ្ញោជនិយា ធម្មាតិ វា ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ ឯវំ គហបតីតិ ។ សញ្ញោជនន្តិ វា ភន្តេ សញ្ញោជនិយា ធម្មាតិ វា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ។ តេនហិ ភន្តេ ឧបមំ[១] ករិស្សាមិ ។ ឧបមាយបិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។

[១៨២] សេយ្យថាបិ ភន្តេ កាឡោ ច ពលិពទ្ទោ ឱទាតោ ច ពលិពទ្ទោ ឯកេន ទាមេន វា យោត្តេន វា សំយុត្តា អស្សុ ។ យោ នុ ខោ ឯវំ វទេយ្យ កាឡោ ពលិពទ្ទោ ឱទាតស្ស ពលិពទ្ទស្ស សញ្ញោជនំ ឱទាតោ ពលិពទ្ទោ កាឡស្ស ពលិពទ្ទស្ស សញ្ញោជនន្តិ ។ សម្មា នុ ខោ សោ វទមានោ វទេយ្យាតិ ។ នោ ហេតំ គហបតិ ។ ន ខោ គហបតិ កាឡោ ពលិពទ្ទោ ឱទាតស្ស ពលិពទ្ទស្ស សញ្ញោជនំ នបិ ឱទាតោ ពលិពទ្ទោ កាឡស្ស ពឡិពទ្ទស្ស សញ្ញោជនំ យេន ខោ តេ ឯកេន ទាមេន វា យោត្តេន វា សំយុត្តា តំ តត្ថ សញ្ញោជនន្តិ ។ ឯវមេវ ខោ ភន្តេ

១ ឱ. ម. ឯត្ថន្តរេ វោតិ បាឋោ អត្ថិ ។

ចិត្តគហបតិបុច្ឆាសំយុត្ត

ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។ អើគហបតី ។ បពិត្រលោកដ៏ចម្រើន ធម៌ទាំងនេះគឺ សញ្ញោជនៈក្តី សញ្ញោជនិយធម៌ក្តី មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ បពិត្រលោកដ៏ចម្រើន បើដូច្នោះ ខ្ញុំព្រះករុណានឹងធ្វើនូវសេចក្តីឧបមា ។ ព្រោះថា វិញ្ញូបុរសពួកខ្លះ ក្នុងលោកនេះ តែងដឹងច្បាស់នូវអត្ថនៃភាសិតដោយសេចក្តីឧបមា ។

[១៨២] បពិត្រលោកដ៏ចម្រើន ដូចគោខ្មៅនិងគោសដែលគេទឹមដោយខ្សែទាមឬខ្សែបរតែមួយ ។ បុគ្គលណា គប្បីពោលយ៉ាងនេះថា គោខ្មៅជាសញ្ញោជនៈ[១] របស់គោស គោស ជាសញ្ញោជនៈរបស់គោខ្មៅ ។ បុគ្គលនោះឈ្មោះថា និយាយត្រូវដែរឬ ។ ពាក្យនោះមិនមែនត្រូវទេ គហបតី ។ ម្នាលគហបតី គោខ្មៅមិនមែនជាសញ្ញោជនៈរបស់គោសទេ គោស ក៏មិនមែនជាសញ្ញោជនៈរបស់គោខ្មៅដែរ គោទាំងនោះគេទឹមដោយខ្សែទាមឬខ្សែបរតែមួយឯណា ខ្សែទាមឬខ្សែបរនោះ ជាសញ្ញោជនៈក្នុងការទឹមនោះ យ៉ាងណាមិញ ។ បពិត្រលោកដ៏ចម្រើន

១ ជាគ្រឿងទឹម ។

ន ចក្ខុ រូបានំ សញ្ញោជនំ ន រូបា ចក្ខុស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ ន សោតំ សទ្ទានំ ។ ន ឃានំ គន្ធានំ ។ ន ជិវ្ហា រសានំ ។ ន កាយោ ផោដ្ឋព្វានំ សញ្ញោជនំ ន ផោដ្ឋព្វា កាយស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ ន មនោ ធម្មានំ សញ្ញោជនំ ន ធម្មា មនស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនន្តិ ។ លាភា តេ គហបតិ សុលទ្ធំ តេ គហបតិ យស្ស តេ គម្ភីរេ ពុទ្ធវចនេ បញ្ញាចក្ខុ កមតីតិ ។ បឋមំ ។

ក្អែកមិនមែនជាសញ្ញោជនៈរបស់រូបទេ រូបមិនមែនជាសញ្ញោជនៈរបស់ក្អែកទេ សេចក្តីត្រេកត្រអាលឯណាកើតឡើង ព្រោះអាស្រ័យនូវក្អែកនិងរូបទាំងពីរនោះ ក្នុងចក្ខុសម្ផស្សនោះ សេចក្តីត្រេកត្រអាលនោះ ជាសញ្ញោជនៈក្នុងចក្ខុសម្ផស្សនោះ ។ ត្រចៀកមិនមែនជាសញ្ញោជនៈរបស់សំឡេងទេ ។ ច្រមុះមិនមែនជាសញ្ញោជនៈរបស់ក្លិនទេ ។ អណ្តាតមិនមែនជាសញ្ញោជនៈរបស់រសទេ ។ កាយមិនមែនជាសញ្ញោជនៈរបស់ផោដ្ឋព្វៈទេ ផោដ្ឋព្វៈមិនមែនជាសញ្ញោជនៈរបស់កាយទេ សេចក្តីត្រេកត្រអាលឯណាកើតឡើង ព្រោះអាស្រ័យនូវកាយនិងផោដ្ឋព្វៈទាំងពីរនោះ ក្នុងកាយសម្ផស្សនោះ សេចក្តីត្រេកត្រអាលនោះ ជាសញ្ញោជនៈក្នុងកាយសម្ផស្សនោះ ។ ចិត្តមិនមែនជាសញ្ញោជនៈរបស់ធម្មារម្មណ៍ទេ ធម្មារម្មណ៍មិនមែនជាសញ្ញោជនៈរបស់ចិត្តទេ សេចក្តីត្រេកត្រអាលឯណាកើតឡើងព្រោះអាស្រ័យនូវចិត្តនិងធម្មារម្មណ៍ទាំងពីរនោះ ក្នុងមនោសម្ផស្សនោះ សេចក្តីត្រេកត្រអាលនោះ ជាសញ្ញោជនៈក្នុងមនោ-សម្ផស្សនោះ ក៏យ៉ាងនោះឯង ។ ម្នាលគហបតី អ្នកហៅពេញជាមានលាភ ម្នាលគហបតី អត្តភាពជាមនុស្ស ពេញហៅថាអ្នកបានដោយល្អ ព្រោះថាអ្នកមានបញ្ញាចក្ខុលុះក្នុងពុទ្ធវចនៈដ៏ជ្រៅ ។ ចប់សូត្រទី ១ ។

១៧៩

## ចិត្តគហបតិបុច្ឆាសំយុត្តំ

[១៨៣] ឯកំ សមយំ សម្ពហុលា ថេរា ភិក្ខូ មច្ឆិកាសណ្ឌេ វិហរន្តិ អម្ពាដកវនេ ។ អថខោ ចិត្តោ គហបតិ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចិត្តោ គហបតិ ថេរេ ភិក្ខូ ឯតទវោច អធិវាសេន្តុ មេ ភន្តេ ថេរា ស្វាតនាយ ភត្តន្តិ ។ អធិវាសេសុំ ខោ ថេរា ភិក្ខូ តុណ្ហីភាវេន ។ អថខោ ចិត្តោ គហបតិ ថេរានំ ភិក្ខូនំ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ថេរេ ភិក្ខូ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[១៨៤] អថខោ ថេរា ភិក្ខូ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ចិត្តស្ស គហបតិនោ និវេសនំ តេនុបសង្កមឹសុ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទឹសុ ។ អថខោ ចិត្តោ គហបតិ យេន ថេរា ភិក្ខូ តេនុបសង្កមិ

ចិត្តគហបតិបុច្ឆាសំយុត្ត

[១៨៣] សម័យមួយ ភិក្ខុជាថេរៈច្រើនរូប គង់នៅក្នុងវត្តអម្ពាដកវ័ន នាដងព្រៃមច្ឆិកា ។ គ្រានោះ ចិត្តគហបតីចូលទៅរកពួកភិក្ខុជាថេរៈ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំពួកភិក្ខុជាថេរៈ ហើយអង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ក៏និមន្តពួកភិក្ខុជាថេរៈដូច្នេះថា បពិត្រលោកដ៏ចម្រើន ព្រះថេរៈទាំងឡាយទទួលភត្តរបស់ខ្ញុំព្រះករុណា ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ពួកភិក្ខុជាថេរៈក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ គ្រានោះ ចិត្តគហបតីដឹងច្បាស់ថា ពួកភិក្ខុជាថេរៈទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំពួកភិក្ខុជាថេរៈ ធ្វើប្រទក្សិណរួចហើយ ក៏ចៀសចេញទៅ ។

[១៨៤] លុះកន្លងរាត្រីនោះទៅហើយ ទើបពួកភិក្ខុជាថេរៈ ក៏ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់ផ្ទះនៃចិត្តគហបតី លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ គ្រានោះ ចិត្តគហបតីចូលទៅរកពួកភិក្ខុជាថេរៈ

ឧបសង្កមិត្វា ថេរេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចិត្តោ គហបតិ អាយស្មន្តំ ថេរំ ឯតទវោច ធាតុនានត្តំ ធាតុនានត្តន្តិ ភន្តេ ថេរ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធាតុនានត្តំ វុត្តំ ភគវ-តាតិ ។

[១៨៤] ឯវំ វុត្តេ អាយស្មា ថេរោ តុណ្ហី អហោ-សិ ។ ទុតិយម្បិ ខោ ចិត្តោ គហបតិ អាយស្មន្តំ ថេរំ ឯតទវោច ធាតុនានត្តំ ធាតុនានត្តន្តិ ភន្តេ ថេរ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធាតុនានត្តំ វុត្តំ ភគវតាតិ ។ ទុតិយម្បិ ខោ អាយស្មា ថេរោ តុណ្ហី អហោសិ ។ តតិយម្បិ ខោ ចិត្តោ គហបតិ អា-យស្មន្តំ ថេរំ ឯតទវោច ធាតុនានត្តំ ធាតុនានត្តន្តិ ភន្តេ ថេរ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធាតុនានត្តំ វុត្តំ ភគវតាតិ ។ តតិយម្បិ ខោ អាយស្មា ថេរោ តុណ្ហី អហោសិ ។

លុះចូលទៅដល់ ក៏ថ្វាយបង្គំពួកភិក្ខុជាថេរៈ ហើយអង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ក៏ទូលសួរទៅនឹងព្រះថេរៈមានអាយុដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន គេតែងនិយាយថា សេចក្តីផ្សេងគ្នានៃធាតុ សេចក្តីផ្សេងគ្នានៃធាតុដូច្នេះ បពិត្រលោកដ៏ចម្រើន ចុះសេចក្តីផ្សេងគ្នានៃធាតុ ដែលព្រះមានព្រះភាគពោលហើយ ដោយហេតុដូចម្តេចហ្ន៎ ។

[១៨៥] កាលបើចិត្តគហបតីពោលយ៉ាងនេះ ព្រះថេរៈដ៏មានអាយុក៏ស្ងៀម ។ ចិត្តគហបតីពោលសួរទៅនឹងព្រះថេរៈមានអាយុជាគម្រប់ ២ ដងដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើនគេតែងនិយាយថា សេចក្តីផ្សេងគ្នានៃធាតុ សេចក្តីផ្សេងគ្នានៃធាតុដូច្នេះ បពិត្រលោកដ៏ចម្រើន ចុះសេចក្តីផ្សេងគ្នានៃធាតុ ដែលព្រះមានព្រះភាគទ្រង់ពោលហើយ ដោយហេតុដូចម្តេចហ្ន៎ ។ ព្រះថេរៈមានអាយុក៏ស្ងៀម ជាគម្រប់ ២ ដងទៀត ។ ចិត្តគហបតីពោលសួរទៅនឹងព្រះថេរៈមានអាយុជាគម្រប់ ៣ ដងដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន គេតែងនិយាយថា សេចក្តីផ្សេងគ្នានៃធាតុ សេចក្តីផ្សេងគ្នានៃធាតុដូច្នេះ បពិត្រលោកដ៏ចម្រើន ចុះសេចក្តីផ្សេងគ្នានៃធាតុដែលព្រះមានព្រះភាគទ្រង់ពោលហើយ មានប៉ុន្មានហ្ន៎ ។ ព្រះថេរៈមានអាយុក៏ស្ងៀម ជាគម្រប់ ៣ ដងទៀត ។

១៨១

## ចិត្តគហបតិបុច្ឆាសំយុត្តំ

[១៨៦] តេន ខោ បន សមយេន អាយស្មា ឥសិទត្តោ តស្មឹ ភិក្ខុសង្ឃេ សព្វនវកោ ហោតិ ។ អថខោ អាយស្មា ឥសិទត្តោ អាយស្មន្តំ ថេរំ ឯតទវោច ព្យាករោមហំ ភន្តេ ថេរ ចិត្តស្ស គហបតិនោ ឯតំ បញ្ហន្តិ ។ ព្យាករោហិ ត្វំ ឥសិទត្ត ចិត្តស្ស គហបតិនោ ឯតំ បញ្ហន្តិ ។ ឯវំ ហិ ត្វំ គហបតិ បុច្ឆសិ ធាតុនានត្តំ ធាតុនានត្តន្តិ ភន្តេ ថេរ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធាតុនានត្តំ វុត្តំ ភគវតាតិ ។ ឯវំ ភន្តេ ។ ឥទំ ខោ គហបតិ ធាតុនានត្តំ វុត្តំ ភគវតា ។ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ ។ បេ ។ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ។ ឯត្តាវតា ខោ គហបតិ ធាតុនានត្តំ វុត្តំ ភគវតាតិ ។

ចិត្តគហបតិបុច្ឆាសំយុត្ត

[១៨៦] សម័យនោះឯង ព្រះឥសិទត្តមានអាយុ ជាភិក្ខុថ្មី បង្អស់ក្នុងភិក្ខុសង្ឃនោះ ។ គ្រានោះ ព្រះឥសិទត្តមានអាយុពោលទៅនឹងព្រះថេរៈមានអាយុដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន ខ្ញុំព្រះករុណាសូមដោះស្រាយនូវប្រស្នានុ៎ះ ដល់ចិត្តគហបតី ។ ព្រះថេរៈពោលថា ម្នាលឥសិទត្ត អ្នកចូរដោះស្រាយនូវប្រស្នានុ៎ះ ដល់ចិត្តគហបតីចុះ ។ ព្រះឥសិទត្តពោលថា ម្នាលគហបតី អ្នកសួរយ៉ាងនេះថា បពិត្រព្រះថេរៈដ៏ចម្រើន គេតែងនិយាយថា សេចក្តីផ្សេងគ្នានៃធាតុ សេចក្តីផ្សេងគ្នានៃធាតុដូច្នេះ បពិត្រលោកដ៏ចម្រើន ចុះសេចក្តីផ្សេងគ្នានៃធាតុដែលព្រះដ៏មានព្រះភាគទ្រង់ពោលហើយ ដោយហេតុដូចម្តេចហ្ន៎ ដូច្នេះមែនឬ ។ ករុណាលោកម្ចាស់ ។ ម្នាលគហបតី សេចក្តីផ្សេងគ្នានៃធាតុនេះ ព្រះដ៏មានព្រះភាគទ្រង់ពោលហើយថា ។ គឺចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ ។ បេ ។ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ។ ម្នាលគហបតី សេចក្តីផ្សេងគ្នានៃធាតុ ដែលព្រះមានព្រះភាគទ្រង់ពោលហើយ ដោយហេតុប៉ុណ្ណោះឯង ។

[១៨៧] អថខោ ចិត្តោ គហបតិ អាយស្មតោ ឥសិទត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ថេរេ ភិក្ខូ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ ថេរា ភិក្ខូ ភុត្តាវិនោ ឱនីតបត្តបាណិនោ ឧដ្ឋាយាសនា បក្កាមឹសុ ។ អថខោ អាយស្មា ថេរោ អាយស្មន្តំ ឥសិទត្តំ ឯតទវោច សាធុ ខោ តំ អាវុសោ ឥសិទត្ត ឯសោ បញ្ហោ បដិភាសិ នេសោ បញ្ហោ មំ បដិភាសិ តេនហាវុសោ ឥសិទត្ត យទា អញ្ញថាបិ ឯវរូបោ បញ្ហោ អាគច្ឆេយ្យ តញ្ញេវេត្ថ បដិភាសេយ្យាសីតិ ។ ទុតិយំ ។

[១៨៨] ឯកំ សមយំ សម្ពហុលា ថេរា ភិក្ខូ មច្ឆិកាសណ្ឌេ វិហរន្តិ អម្ពាដកវនេ ។ អថខោ ចិត្តោ គហបតិ យេន ថេរា ភិក្ខូ តេនុបសង្កមិ

[១៨៧] គ្រានោះ ចិត្តគហបតីត្រេកអរអនុមោទនានឹងភាសិតរបស់ព្រះឥសិទត្តមានអាយុហើយ ក៏ញុំាំងពួកភិក្ខុជាថេរៈឲ្យឆ្អាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ឧត្តមដោយដៃនៃខ្លួន ។ លុះពួកភិក្ខុជាថេរៈឆាន់រួច លែងលូកព្រះហស្តទៅក្នុងបាត្រទៀតហើយ ក៏ក្រោកចាកអាសនៈហើយចៀសចេញទៅ ។ លំដាប់នោះ ព្រះថេរៈមានអាយុ ពោលទៅនឹងព្រះឥសិទត្តមានអាយុដូច្នេះថា ម្នាលអាវុសោឥសិទត្ត ប្រស្នាទុំះប្រាកដដល់លោកដោយប្រពៃហើយ ប្រស្នាទុំះមិនប្រាកដដល់ខ្ញុំទេ ម្នាលអាវុសោឥសិទត្ត បើដូច្នោះ កាលណាបើមានប្រស្នាមានសភាពដូច្នេះ មកដល់ដោយប្រការដទៃ លោកគប្បីទទួលសំដែងប្រស្នានោះ ។ ចប់សូត្រទី ២ ។

[១៨៨] សម័យមួយ ភិក្ខុជាថេរៈច្រើនរូបគង់នៅក្នុងវត្តអម្ពាដកវ័ននាដង់ព្រៃមច្ឆិកា ។ គ្រានោះ ចិត្តគហបតីចូលទៅរកពួកភិក្ខុជាថេរៈ

១៨៣

ចិត្តគហបតិបុច្ឆាសំយុត្តំ

ឧបសង្កមិត្វា ថេរេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចិត្តោ គហបតិ ថេរេ ភិក្ខូ ឯតទវោច អធិវាសេន្តុ មេ ភន្តេ ថេរា ស្វាតនាយ ភត្តន្តិ ។ អធិវាសេសុំ ខោ ថេរា ភិក្ខូ តុណ្ហីភាវេន ។ អថខោ ចិត្តោ គហបតិ ថេរានំ ភិក្ខូនំ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ថេរេ ភិក្ខូ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[១៨៩] អថខោ ថេរា ភិក្ខូ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ចិត្តស្ស គហបតិស្ស និវេសនំ តេនុបសង្កមឹសុ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទឹសុ ។ អថខោ ចិត្តោ គហបតិ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧប-សង្កមិត្វា ថេរេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ និសីទិ ។

លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំពួកភិក្ខុជាថេរៈ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ក៏និមន្តពួកភិក្ខុជាថេរៈដូច្នេះថា បពិត្រលោកដ៏ចម្រើន សូមព្រះថេរៈទាំងឡាយទទួលនូវភត្តរបស់ខ្ញុំព្រះករុណា ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ពួកភិក្ខុជាថេរៈក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លុះចិត្តគហបតីដឹងច្បាស់ថាពួកភិក្ខុជាថេរៈទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំពួកភិក្ខុជាថេរៈធ្វើប្រទក្សិណហើយចេញទៅ ។

[១៨៩] លុះរាត្រីនោះកន្លងទៅហើយ ទើបពួកភិក្ខុជាថេរៈស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់ផ្ទះរបស់ចិត្តគហបតី លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ គ្រានោះ ចិត្តគហបតីចូលទៅរកពួកភិក្ខុជាថេរៈ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំពួកភិក្ខុជាថេរៈ ហើយអង្គុយក្នុងទីសមគួរ ។

ឯកមន្តំ និសិន្នោ ខោ ចិត្តោ គហបតិ អាយស្មន្តំ ថេរំ ឯតទវោច យា ឥមា ភន្តេ ថេរ អនេកវិហិតា ទិដ្ឋិយោ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ (យានិ ចិមានិ ទ្វាសដ្ឋីទិដ្ឋិគតានិ ព្រហ្មជាលេ ភណិតានិ) ។ ឥមា នុ ខោ ភន្តេ ទិដ្ឋិយោ កិស្មឹ សតិ ហោន្តិ កិស្មឹ អសតិ ន ហោន្តីតិ ។

លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ក៏សួរទៅព្រះថេរៈដ៏មានអាយុដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន ទិដ្ឋិទាំងឡាយឯណាមានច្រើនប្រការ តែងកើតឡើងក្នុងលោកថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះគឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈដទៃដូច្នេះក្តី សត្វកើតទៀតខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វមិនកើតទៀតខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វកើតទៀតខ្លះ មិនកើតទៀតខ្លះខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី ។ (ទិដ្ឋិទាំង ៦២ បានពោលក្នុងព្រហ្មជាលសូត្ររួចហើយ) បពិត្រលោកដ៏ចម្រើន កាលបើអ្វីមាន ទើបទិដ្ឋិទាំងនេះក៏មានដែរ កាលបើអ្វីមិនមាន ទិដ្ឋិទាំងនេះក៏មិនមានដែរ ។

## ចិត្តគហបតិបុច្ឆាសំយុត្តំ

[១៩០] ឯវំ វុត្តេ អាយស្មា ថេរោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ចិត្តោ គហបតិ ។ បេ ។ តតិយម្បិ ខោ ចិត្តោ គហបតិ អាយស្មន្តំ ថេរំ ឯតទវោច យា ឥមា ភន្តេ ថេរ អនេកវិហិតា ទិដ្ឋិយោ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ (យានិ ចិមានិ ទ្វាសដ្ឋីទិដ្ឋិគតានិ ព្រហ្មជាលេ ភណិតានិ) ។ ឥមា នុ ខោ ភន្តេ ទិដ្ឋិយោ កិស្មឹ សតិ ហោន្តិ កិស្មឹ អសតិ ន ហោន្តីតិ ។ តតិយម្បិ ខោ អាយស្មា ថេរោ តុណ្ហី អហោសិ ។

ចិត្តគហបតិបុច្ឆាសំយុត្ត

[១៩០] លុះចិត្តគហបតីសួរយ៉ាងនេះហើយ ព្រះថេរៈដ៏មានអាយុក៏ស្ងៀម ។ ចិត្តគហបតីសួរជាគម្រប់ ២ ដងទៀត ។ បេ ។ ចិត្តគហបតីសួរទៅព្រះថេរៈមានអាយុជាគម្រប់ ៣ ដងដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន ទិដ្ឋិទាំងឡាយឯណាមានច្រើនប្រការ តែងកើតឡើងក្នុងលោកថា លោកទៀងដូច្នេះក្តី លោកមិនទៀតដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះគឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈដទៃដូច្នេះក្តី សត្វកើតទៀតខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វមិនកើតទៀតខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វកើតទៀតខ្លះ មិនកើតទៀតខ្លះ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី ។ (ទិដ្ឋិទាំង ៦២ បានពោលក្នុងព្រហ្មជាលសូត្ររួចហើយ) ។ បពិត្រព្រះថេរៈដ៏ចម្រើន កាលបើអ្វីមាន ទើបទិដ្ឋិទាំងនេះក៏មានដែរ កាលបើអ្វីមិនមាន ទិដ្ឋិទាំងនេះក៏មិនមានដែរ ។ ព្រះថេរៈមានអាយុស្ងៀមជាគម្រប់ ៣ ដងទៀត ។

[១៩១] តេន ខោ បន សមយេន អាយស្មា ឥសិទត្តោ តស្មឹ ភិក្ខុសង្ឃេ សព្វនវកោ ហោតិ ។ អថខោ អាយស្មា ឥសិទត្តោ អាយស្មន្តំ ថេរំ ឯតទវោច ព្យាករោមហំ ភន្តេ ថេរ ចិត្តស្ស គហបតិនោ ឯតំ បញ្ហន្តិ ។ ព្យាករោហិ ត្វំ អាវុសោ ឥសិទត្ត ចិត្តស្ស គហបតិនោ ឯតំ បញ្ហន្តិ ។ ឯវំ ហិ ត្វំ គហបតិ បុច្ឆសិ យា ឥមា ភន្តេ ថេរ អនេកវិហិតា ទិដ្ឋិយោ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា ។ បេ ។ ឥមា នុ ខោ ភន្តេ ទិដ្ឋិយោ កិស្មឹ សតិ ហោន្តិ កិស្មឹ អសតិ ន ហោន្តីតិ ។ ឯវំ ភន្តេ ។ យា ឥមា គហបតិ អនេកវិហិតា ទិដ្ឋិយោ លោកេ ឧប្បជ្ជន្តិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ

[១៩១] សម័យនោះឯង ព្រះឥសិទត្តមានអាយុ ជាភិក្ខុថ្មីជាង គេក្នុងភិក្ខុសង្ឃនោះ ។ គ្រានោះ ព្រះឥសិទត្តមានអាយុពោលទៅនឹងព្រះថេរៈមានអាយុដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន ខ្ញុំព្រះករុណាសូមដោះស្រាយប្រស្នានុ៎ះ ដល់ចិត្តគហបតី ។ ម្នាលអាវុសោឥសិទត្ត ចូរលោកដោះស្រាយប្រស្នានុ៎ះ ដល់ចិត្តគហបតីចុះ ។ (ព្រះឥសិទត្តសួរទៅចិត្តគហបតី) ថា ម្នាលគហបតី អ្នកសួរយ៉ាងនេះថា បពិត្រព្រះថេរៈដ៏ចម្រើន ទិដ្ឋិទាំងឡាយឯណាមានច្រើនប្រការ តែងកើតឡើងក្នុងលោកថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ។ បេ ។ បពិត្រព្រះថេរៈដ៏ចម្រើន កាលបើអ្វីមាន ទើបទិដ្ឋិទាំងនេះក៏មានដែរ កាលបើអ្វីមិនមាន ទិដ្ឋិទាំងនេះក៏មិនមានដែរ ដូច្នេះឬ ។ ករុណា លោកម្ចាស់ ។ ម្នាលគហបតី ទិដ្ឋិទាំងឡាយឯណាមានច្រើនប្រការ រមែងកើតឡើងក្នុងលោកថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះគឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃ

សរីរន្តិ វា ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ (យានិ ចិមានិ ទ្វាសដ្ឋី-ទិដ្ឋិគតានិ ព្រហ្មជាលេ ភណិតានិ) ។ ឥមា ខោ គហ-បតិ ទិដ្ឋិយោ សក្កាយទិដ្ឋិយា សតិ ហោន្តិ សក្កាយ-ទិដ្ឋិយា អសតិ ន ហោន្តីតិ ។

[១៩២] កថំ បន ភន្តេ សក្កាយទិដ្ឋិ ហោតីតិ ។ ឥធ គហបតិ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិ-សានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិ-សធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ ។ វេទនំ អត្តតោ សមនុបស្សតិ ។ បេ ។ សញ្ញំ ។ សង្ខារេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ គហបតិ សក្កាយទិដ្ឋិ ហោតីតិ ។

សរីរៈដទៃដូច្នេះក្តី សត្វកើតទៀតខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វមិនកើតទៀតខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វកើតទៀតខ្លះ មិនកើតទៀតខ្លះ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ដូច្នេះក្តី ។ (ទិដ្ឋិទាំង ៦២ បានពោលក្នុងព្រហ្មជាលសូត្ររួចហើយ) ។ ម្នាលគហបតី កាលបើសក្កាយទិដ្ឋិមាន ទិដ្ឋិទាំងនេះក៏មានដែរ កាលបើសក្កាយទិដ្ឋិមិនមាន ទិដ្ឋិទាំងនេះក៏មិនមានដែរ ។

[១៩២] បពិត្រព្រះករុណាដ៏ចម្រើន សក្កាយទិដ្ឋិកើតមាន តើដោយប្រការដូចម្តេច ។ ម្នាលគហបតី បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានសិក្សាក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានសិក្សាក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាជាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបក្នុងខ្លួនខ្លះ នូវខ្លួនក្នុងរូបខ្លះ ។ ឃើញនូវវេទនាថាជាខ្លួន ។ បេ ។ នូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ ឃើញនូវវិញ្ញាណថាជាខ្លួន នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណក្នុងខ្លួនខ្លះ នូវខ្លួនក្នុងវិញ្ញាណខ្លះ ។ ម្នាលគហបតី សក្កាយទិដ្ឋិកើតមានដោយប្រការយ៉ាងនេះឯង ។

[១៩៣] កថំ បន ភន្តេ សក្កាយទិដ្ឋិ ន ហោតីតិ ។ ឥធ គហបតិ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ។ ន វេទនំ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ គហបតិ សក្កាយទិដ្ឋិ ន ហោតីតិ ។ កុតោ ភន្តេ អយ្យោ ឥសិទត្តោ អាគច្ឆតីតិ ។ អវន្តិយា ខោហំ គហបតិ អាគច្ឆាមីតិ ។ អត្ថិ ភន្តេ អវន្តិយា ឥសិទត្តោ នាម កុលបុត្តោ អម្ហាកំ អទិដ្ឋសហាយោ បព្វជិតោ ទិដ្ឋោ សោ អាយស្មតាតិ ។ ឯវំ គហបតីតិ ។ កហំ នុ ខោ សោ ភន្តេ អាយស្មា ឯតរហិ វិហរតីតិ ។

[១៩៣] បពិត្រព្រះករុណាដ៏ចម្រើន សក្កាយទិដ្ឋិមិនកើតមាន ដោយប្រការដូចម្តេច ។ ម្នាលគហបតី អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង បានឃើញព្រះអរិយៈ ឈ្លាសវៃក្នុងអរិយធម៌ បានសិក្សាដោយល្អក្នុងអរិយធម៌ បានឃើញពួកសប្បុរស ឈ្លាសវៃក្នុងសប្បុរិស-ធម៌ បានសិក្សាដោយល្អក្នុងសប្បុរិសធម៌ រមែងមិនឃើញនូវរូបថាជាខ្លួន មិនឃើញនូវខ្លួនថាមានរូបខ្លះ មិនឃើញនូវរូបក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនក្នុងរូបខ្លះ ។ មិនឃើញនូវវេទនា ។ មិនឃើញនូវសញ្ញា ។ មិនឃើញនូវសង្ខារទាំងឡាយ ។ មិនឃើញនូវវិញ្ញាណថាខ្លួន មិនឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ មិនឃើញនូវវិញ្ញាណក្នុងខ្លួនខ្លះ មិនឃើញនូវខ្លួនក្នុងវិញ្ញាណខ្លះ ។ ម្នាលគហបតី សក្កាយទិដ្ឋិមិនកើតមាន ដោយប្រការយ៉ាងនេះឯង ។ បពិត្រព្រះករុណាដ៏ចម្រើន ព្រះឥសិទត្ត ជាម្ចាស់និមន្តមកអំពីទីណា ។ ម្នាលគហបតី អាត្មាមកអំពីដែនអវន្តិ ។ បពិត្រព្រះករុណាដ៏ចម្រើន ឯកុលបុត្តឈ្មោះឥសិទត្តក្នុងដែនអវន្តិ ជាសំឡាញ់ដែលយើងមិនដែលបានឃើញ ឥឡូវបួសហើយ ឯលោកនោះ លោកម្ចាស់ដែលឃើញហើយដែរឬ ។ អើគហបតី ។ បពិត្រព្រះករុណាដ៏ចម្រើន ចុះព្រះឥសិទត្តមានអាយុនោះ ឥឡូវនេះគង់នៅក្នុងទីឯណាហ្ន៎ ។

១៨៩

ចិត្តគហបតិបុច្ឆាសំយុត្តំ

[១៩៤] ឯវំ វុត្តេ អាយស្មា ឥសិទត្តោ តុណ្ហី អហោសិ ។ អយ្យោ ដោ ភន្តេ ឥសិទត្តោតិ ។ ឯវំ គហបតីតិ ។ អភិរមតុ ភន្តេ អយ្យោ ឥសិទត្តោ មច្ឆិ-កាសណ្ឌេ រមណីយំ អម្ពាដកវនំ អហំ អយ្យស្ស ឥសិទត្តស្ស ឧស្សុក្កំ ករិស្សាមិ ចីវរបិណ្ឌបាតសេ-នាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ កល្យាណំ វុច្ចតិ គហបតីតិ ។

[១៩៥] អថខោ ចិត្តោ គហបតិ អាយស្មតោ ឥសិទត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ថេរេ ភិក្ខូ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ ថេរា ភិក្ខូ ភុត្តាវិ-នោ ឱនីតបត្តបាណិនោ ឧដ្ឋាយាសនា បក្កមឹសុ ។ អ-ថខោ អាយស្មា ថេរោ អាយស្មន្តំ ឥសិទត្តំ ឯតទវោច សាធុ ខោ តំ[១] អាវុសោ ឥសិទត្ត ឯសោ បញ្ហោ

១ ឱ. តំ

ចិត្តគហបតិបុច្ឆាសំយុត្ត

[១៩២] លុះចិត្តគហបតីសួរយ៉ាងនេះហើយ ព្រះឥសិទត្តដ៏មានអាយុនៅស្ងៀម ។ បពិត្រព្រះករុណាដ៏ចម្រើន លោកម្ចាស់ជាឥសិទត្តរបស់យើងឬ ។ អើគហបតី ។ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះឥសិ-ទត្តជាម្ចាស់ត្រេកអរនឹងវត្តអម្ពាដកវ័នជាទីសប្បាយ នាដង់ព្រៃមច្ឆិកាចុះខ្ញុំព្រះករុណានឹងធ្វើនូវសេចក្ដីខ្វល់ខ្វាយ ដោយចីវរបិណ្ឌបាតសេនាសនៈគិលានប្បច្ចយភេសជ្ជបរិក្ខារដល់ព្រះឥសិទត្តជាម្ចាស់ ។ ម្នាលគហបតីអ្នកពោលពាក្យល្អហើយ ។

[១៩៥] គ្រានោះ ចិត្តគហបតីត្រេកអរអនុមោទនានឹងភាសិតរបស់ព្រះឥសិទត្តមានអាយុហើយ ក៏ញុំាំងពួកភិក្ខុជាថេរៈឲ្យឆាន់ឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារដ៏ឧត្ដមដោយដៃខ្លួនឯង ។ លំ-ដាប់នោះ ពួកភិក្ខុជាថេរៈ លុះឆាន់រួចលែងលូកដៃទៅក្នុងបាត្រហើយ ក៏ក្រោកចាកអាសនៈចេញទៅ ។ គ្រានោះ ព្រះថេរៈមានអាយុពោលទៅនឹងព្រះឥសិទត្តមានអាយុដូច្នេះថា ម្នាលអាវុសោឥសិទត្ត ប្រស្នាទុំះ

បដិភាសិ នេសោ បញ្ហោ មំ បដិភាសិ តេនហាវុសោ ឥសិទត្ត យថា អញ្ញថាបិ ឯវរូបោ បញ្ហោ អាគច្ឆេយ្យ តញ្ញេវេត្ថ បដិភាសេយ្យាសីតិ ។ អថខោ អាយស្មា ឥសិទត្តោ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ មច្ឆិកាសណ្ឌម្ហា បក្កាមិ យំ មច្ឆិកាសណ្ឌម្ហា បក្កាមិ តថា បក្កន្តោ វ អហោសិ ន បុន បច្ចាគច្ឆីតិ ។ តតិយំ ។

[១៩៦] ឯកំ សមយំ សម្ពហុលា ថេរា ភិក្ខូ មច្ឆិកាសណ្ឌេ វិហរន្តិ អម្ពាដកវនេ ។ អថខោ ចិត្តោ គហបតិ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចិត្តោ គហបតិ ថេរេ ភិក្ខូ ឯតទវោច អធិវាសេន្តុ មេ ភន្តេ ថេរា ស្វាតនាយ គោកុលេ ភត្តន្តិ ។ អធិវាសេសុំ ខោ ថេរា ភិក្ខូ តុណ្ហីភាវេន ។ អថខោ ចិត្តោ គហបតិ ថេរានំ ភិក្ខូនំ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ថេរេ ភិក្ខូ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

ប្រាកដដល់លោកប្រពៃហើយ ប្រស្នានុ៎ះមិនប្រាកដដល់យើងឡើយ ម្នាលអាវុសោឥសិទត្ត បើដូច្នោះ កាលណាបើមានប្រស្នាមានសភាពដូច្នេះមានមកដោយប្រការដទៃ លោកគប្បីទទួលសំដែងប្រស្នានោះ ។ គ្រានោះ ព្រះឥសិទត្តមានអាយុរៀបចំទុកដាក់សេនាសនៈហើយ ក៏កាន់យកបាត្រនិងចីវរចេញទៅអំពីដងព្រៃមច្ឆិកា ព្រោះថាលោកចេញទៅអំពីដងព្រៃមច្ឆិកា ចេញទៅតែម្តង មិនបានត្រឡប់មកទៀតឡើយ ។ ចប់សូត្រទី ៣ ។

[១៩៦] សម័យមួយ ភិក្ខុជាថេរៈច្រើនរូបគង់នៅវត្តអម្ពាដកវ័ននាដងព្រៃមច្ឆិកា ។ គ្រានោះ ចិត្តគហបតីចូលទៅរកពួកភិក្ខុជាថេរៈ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំពួកភិក្ខុជាថេរៈ ហើយអង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ក៏និមន្តពួកភិក្ខុជាថេរៈដូច្នេះថា បពិត្រលោកដ៏ចម្រើន សូមព្រះថេរៈទាំងឡាយទទួលភត្តព្វដ៏ក្រោលគោរបស់ខ្ញុំព្រះករុណា ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ពួកភិក្ខុជាថេរៈក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ចិត្តគហបតីដឹងច្បាស់ថាពួកភិក្ខុជាថេរៈទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំពួកភិក្ខុជាថេរៈ ធ្វើប្រទក្សិណហើយចេញទៅ ។

## ចិត្តគហបតិបុច្ឆាសំយុត្តំ

[១៩៧] អថខោ ថេរា ភិក្ខូ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ចិត្តស្ស គហបតិនោ គោកុលំ តេនុបសង្កមឹសុ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទឹសុ ។ អថខោ ចិត្តោ គហបតិ ថេរេ ភិក្ខូ បណីតេន សប្បិបាយាសេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ ថេរា ភិក្ខូ ភុត្តាវិនោ ឱនីតបត្តបាណិនោ ឧដ្ឋាយាសនា បក្កមឹសុ ។ ចិត្តោបិ ខោ គហបតិ សេសកំ វិស្សជ្ជេថាតិ វត្វា ថេរេ ភិក្ខូ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ តេន ខោ បន សមយេន ឧណ្ហំ ហោតិ កុដ្ឋិតំ ។ តេ ច ថេរា ភិក្ខូ បវេលិយមានេន មញ្ញេ កាយេន គច្ឆន្តិ[១] យថា តំ ភោជនំ ភុត្តាវិនោ ។

១ ម. អញ្ញេ អាកាសេន គច្ឆន្តិ ។

## ចិត្តគហបតិបុច្ឆាសំយុត្ត

[១៩៧] លុះរាត្រីនោះកន្លងទៅហើយ ទើបពួកភិក្ខុជាថេរៈស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់ក្រោលគោរបស់ចិត្តគហបតី លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ គ្រានោះ ចិត្តគហបតីញុំាងពួកភិក្ខុជាថេរៈឲ្យឆាន់ឆ្អែតស្កប់ស្កល់ដោយសប្បិបាយាស (បាយាសលាយទឹកដោះរាវ) ដ៏ឧត្តមដោយដៃខ្លួនឯង ។ ពួកភិក្ខុជាថេរៈ លុះឆាន់រួចលែងលូកដៃទៅក្នុងបាត្រទៀតហើយ ក៏ក្រោកចាកអាសនៈហើយចេញទៅ ។ ចិត្តគហបតីពោលថា សូមព្រះករុណាទាំងឡាយឲ្យទាននូវកត្តដែលសល់ ហើយក៏ដើរតាមក្រោយៗ ពួកភិក្ខុជាថេរៈ ។ សម័យនោះឯង សេចក្តីក្តៅ[១] ខ្លាំងក៏កើតមាន ។ ភិក្ខុជាថេរៈទាំងនោះ ទើបតែនឹងឆាន់ភោជនរួចខំប្រឹងដើរទៅ មានកាយលំបាកពេកណាស់ ។

---

១ ខាងក្រោមក្តៅដោយដីខ្សាច់ ខាងលើក្តៅដោយកម្តៅព្រះអាទិត្យ ។

[១៩៨] តេន ខោ បន សមយេន អាយស្មា មហាកោ តស្មឹ ភិក្ខុសង្ឃេ សព្វនវោ(១) ហោតិ ។ អថខោ អាយស្មា មហាកោ អាយស្មន្តំ ថេរំ ឯតទវោច សាធុ ខ្វស្ស ភន្តេ ថេរស្ស(២) សីតកោ ច វាតោ វាយេយ្យ អព្ភសំបិលាចោ(៣) ច អស្ស ទេវោ ច ឯកមេកំ ផុសយេយ្យាតិ ។ សាធុ ខ្វស្ស អាវុសោ មហាក យំ សីតកោ ច វាតោ វាយេយ្យ អព្ភសំបិលាចោ ច អស្ស ទេវោ ច ឯកមេកំ ផុសយេយ្យាតិ ។ អថខោ អាយស្មា មហាកោ តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខរិ យថាយំ សីតកោ ច វាតោ វាយិ អព្ភសំបិលាចោ ច អស្ស ទេវោ ច ឯកមេកំ ផុសិ ។

១ ម. សព្វនវកោ ។ ២ ម. យំ សីតកោ ។ ៣ ម. អព្ភសំវិលាបោ ។

[១៩៨] សម័យនោះឯង ព្រះមហកៈមានអាយុជាភិក្ខុថ្មីជាងគេក្នុងភិក្ខុសង្ឃនោះ ។ គ្រានោះ ព្រះមហកៈមានអាយុពោលទៅនឹងព្រះថេរៈក៏មានអាយុដូច្នេះថា បពិត្រលោកដ៏ចម្រើន ប្រសិនបើមានខ្យល់ត្រជាក់បក់មក ទាំងមេឃក៏ស្រទំ ទាំងភ្លៀងក៏ធ្លាក់ចុះ មកមួយគ្រាប់ៗជាការប្រពៃណាស់ ។ ព្រះថេរៈពោលថា ម្នាលអាវុសោមហកៈ ប្រសិនបើមានខ្យល់ត្រជាក់បក់មក ទាំងមេឃក៏ស្រទំ ទាំងភ្លៀងក៏ធ្លាក់ចុះមកមួយគ្រាប់ៗ ជាការប្រពៃពិត ។ ទើបព្រះមហកៈមានអាយុតាក់តែងនូវឥទ្ធាភិសង្ខារមានសភាពដូច្នោះ គឺឲ្យមានខ្យល់ត្រជាក់បក់មក ទាំងមេឃក៏ស្រទំ ទាំងភ្លៀងក៏ធ្លាក់ចុះមកមួយគ្រាប់ ៗ ។

ចិត្តគហបតិបុច្ឆាសំយុត្តំ

[១៩៩] អថខោ ចិត្តស្ស គហបតិនោ ឯតទហោសិ យោ ខោ ឥមស្មឹ ភិក្ខុសង្ឃេ សព្វនវោ ភិក្ខុ តស្សាយំ ឯវរូបោ ឥទ្ធានុភាវោតិ ។ អថខោ អាយស្មា មហកោ អាភមំ សម្បាបុណិត្វា អាយស្មន្តំ ថេរំ ឯតទវោច អលមេត្តាវតា ភន្តេ ថេរាតិ អលមេត្តាវតា អាវុសោ មហក កតមេត្តាវតា អាវុសោ មហក បូជិតមេត្តាវតា អាវុសោ មហកាតិ ។ អថខោ ថេរា ភិក្ខូ យថាវិហារំ អគមំសុ អាយស្មាបិ មហកោ សកំ វិហារំ អគមាសិ ។ អថខោ ចិត្តោ គហបតិ យេនាយស្មា មហកោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហកំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចិត្តោ គហបតិ អាយស្មន្តំ មហកំ ឯតទវោច សាធុ មេ ភន្តេ អយ្យោ មហកោ ឧត្តរិមនុស្សធម្មំ ឥទ្ធិបាដិហារិយំ ទស្សេតូតិ ។ តេនហិ ត្វំ គហបតិ

ចិត្តគហបតិបុច្ឆាសំយុត្ត

[១៩៩] គ្រានោះ ចិត្តគហបតីមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុឯណាថ្មីជាងគេបង្អស់ក្នុងភិក្ខុសង្ឃនេះ អានុភាពនៃឫទ្ធិមានសភាពដូច្នេះនេះ ជារបស់ភិក្ខុនោះ ។ លំដាប់នោះ ព្រះមហកៈមានអាយុបានទៅដល់អារាមហើយ ក៏ពោលទៅនឹងព្រះថេរៈមានអាយុដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន ប៉ុណ្ណេះល្មមហើយឬនៅ ព្រះថេរៈក៏ពោលថា ម្នាលអាវុសោមហកៈ ប៉ុណ្ណេះល្មមហើយ ម្នាលអាវុសោមហកៈ ធ្វើប៉ុណ្ណេះចុះ ម្នាលអាវុសោមហកៈ បូជាប៉ុណ្ណេះហើយ ។ គ្រានោះ ពួកភិក្ខុជាថេរៈក៏បានទៅដល់វត្តរៀងខ្លួន ឯព្រះមហកៈមានអាយុ ក៏បានទៅដល់វត្តរបស់ខ្លួនដែរ ។ លំដាប់នោះ ចិត្តគហបតីចូលទៅរកព្រះមហកៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហកៈមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះមហកៈមានអាយុដូច្នេះថា បពិត្រលោកដ៏ចម្រើន សូមព្រះមហកៈជាម្ចាស់សំដែងនូវឥទ្ធិបាដិហារ្យ ជាធម៌របស់មនុស្សដ៏លើសលុបដល់ខ្ញុំករុណាឲ្យទាន ។ ម្នាលគហបតី បើដូច្នោះ ចូរអ្នក

អាឡិន្ទេ ឧត្តរាសង្គំ បញ្ញបេត្វា តិណកលាបំ ឱកា-សេហីតិ ។ ឯវម្ភន្តេតិ ខោ ចិត្តោ គហបតិ អាយស្មតោ មហកស្ស បដិស្សុត្វា អាឡិន្ទេ ឧត្តរាសង្គំ បញ្ញបេត្វា តិណកលាបំ ឱកាសេសិ ។ អថខោ អាយស្មា ម-ហកោ វិហារំ បវិសិត្វា សូចិឃដិកំ ទត្វា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខាសិ យថា តាឡច្ឆិគ្គឡេន ច អគ្គ-ឡន្តរិកាយ ច អច្ចិ និក្ខមិត្វា តិណានិ ឈាបេសិ ន ឧត្តរាសង្គំ ឈាបេសិ ។ អថខោ ចិត្តោ គហបតិ ឧត្តរា-សង្គំ បប្ផោដេត្វា[១] សំវិគ្គោ លោមហដ្ឋជាតោ ឯកមន្តំ អដ្ឋាសិ ។ អថខោ អាយស្មា មហកោ វិហារា និក្ខមិត្វា ចិត្តំ គហបតឹ ឯតទវោច អលមេត្តាវតា គហបតីតិ ។ អលមេត្តាវតា ភន្តេ មហក កតមេត្តាវតា ភន្តេ ម-ហក បូជិតមេត្តាវតា ភន្តេ មហក អភិរមតុ ភន្តេ អយ្យោ មហកោ មច្ឆិកាសណ្ឌេ រមណីយំ អម្ពាដក-វនំ អហំ អយ្យស្ស មហកស្ស ឧស្សុក្កំ ករិស្សាមិ

១ ឱ. បប្បោដេត្វា ។

ក្រាលសំពត់ឧត្តរាសង្គគ្របលើបាច់ស្មៅឲ្យដំរៀង ។ ចិត្តគហបតីទទួលពាក្យរបស់ព្រះមហកៈមានអាយុថា ព្រះករុណា លោកម្ចាស់ ហើយក៏ក្រាលសំពត់ឧត្តរាសង្គគ្របលើបាច់ស្មៅឲ្យដំរៀង ។ លំដាប់នោះ ព្រះមហកៈមានអាយុចូលទៅកាន់វិហារ ចាក់គន្លឹះទ្វារហើយក៏តាក់តែងនូវឥទ្ធាភិសង្ខារមានសភាពដូច្នោះ បណ្តាលឲ្យមានអណ្តាតភ្លើងចេញទៅតាមប្រហោងកូនសោផង តាមចន្លោះទ្វារផង ឆេះនូវស្មៅទាំងឡាយ តែមិនឆេះសំពត់ឧត្តរាសង្គឡើយ ។ គ្រានោះ ចិត្តគហបតីបោកសំពត់ឧត្តរាសង្គ ទៅជាតក់ស្លុតព្រឺរោម ឈរនៅក្នុងទីសមគួរ ។ លំដាប់នោះ ព្រះមហកៈមានអាយុចេញអំពីវិហារហើយ ពោលទៅនឹងចិត្តគហបតីដូច្នេះថា ម្នាលគហបតី ប៉ុណ្ណេះល្មមហើយឬនៅ ។ បពិត្រព្រះមហកៈដ៏ចម្រើន ប៉ុណ្ណេះល្មមហើយ បពិត្រព្រះមហកៈដ៏ចម្រើនធ្វើប៉ុណ្ណេះចុះ បពិត្រព្រះមហកៈដ៏ចម្រើន បូជាប៉ុណ្ណេះហើយ បពិត្រលោកដ៏ចម្រើន សូមព្រះមហកៈជាម្ចាស់ ត្រេកអរចំពោះវត្តអម្ពាដកវ័នជាទីសប្បាយ នាដងព្រៃមច្ឆិកាចុះ ខ្ញុំព្រះករុណានឹងធ្វើនូវសេចក្តីខ្វល់ខ្វាយ

ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា-នន្តិ ។ កល្យាណំ វុច្ចតិ គហបតីតិ ។ អថខោ អាយស្មា មហកោ សេនាសនំ សំសាមេត្វា បត្តចីវ-រមាទាយ មច្ឆិកាសណ្ឌម្ហា បក្កាមិ យំ មច្ឆិកា-សណ្ឌម្ហា បក្កាមិ តថាបក្កន្តោ វ អហោសិ ន បុន បច្ចាគច្ឆីតិ ។ ចតុត្ថំ ។

[២០០] ឯកំ សមយំ អាយស្មា កាមភូ មច្ឆិកា-សណ្ឌេ វិហរតិ អម្ពាដកវនេ ។ អថខោ ចិត្តោ គហបតិ យេនាយស្មា កាមភូ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ កាមភុំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចិត្តំ គហបតឹ អាយស្មា កាមភូ ឯតទវោច វុត្តមិទំ គហបតិ

នេលង្គោ សេតបច្ឆាទោ
ឯការោ វត្តតី រថោ
អនីឃំ បស្ស អប្បត្តំ[១]
ឆិន្នសោតំ អពន្ធនន្តិ ។

១ បស្ស អាយន្តំ ។

ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ដល់ព្រះមហកៈជាម្ចាស់ ។ ម្នាលគហបតី អ្នកពោលពាក្យប្រពៃហើយ លំដាប់នោះ ព្រះមហកៈមានអាយុរៀបចំទុកដាក់សេនាសនៈហើយ ក៏កាន់យកបាត្រនិងចីវរចេញទៅអំពីដងព្រៃមច្ឆិកា ព្រោះថាចេញទៅអំពីដងព្រៃមច្ឆិកា ចេញទៅតែម្តង មិនបានត្រឡប់មកវិញឡើយ ។ ចប់សូត្រទី ៤ ។

[២០០] សម័យមួយ ព្រះកាមភូមានអាយុ គង់នៅក្នុងវត្តអម្ពាដកវ័ន នាដងព្រៃមច្ឆិកា ។ គ្រានោះ ចិត្តគហបតីចូលទៅរកព្រះកាមភូមានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះកាមភូដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីដ៏សមគួរហើយ ព្រះកាមភូមានអាយុក៏ពោលទៅដូច្នេះថា ម្នាលគហបតី នេះព្រះមានព្រះភាគទ្រង់ពោលថា

រថមានអវយវៈឥតទោស មានគ្រឿងពាសមានព័ណ៌ស
មានកាំតែមួយ តែងប្រព្រឹត្តទៅ អ្នកចូរមើលនូវរថនោះដែល
មិនមានទុក្ខ មិនដល់នូវសេចក្តីទុក្ខ មានខ្សែដាច់ហើយ មិន
មានចំណង ។

[២០១] ឥមស្ស នុ ខោ គហបតិ សង្ខិត្តេន ភាសិតស្ស កថំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ កឹ នុ ខោ ឯតំ ភន្តេ ភគវតោ ភាសិតន្តិ ។ ឯវំ គហបតីតិ ។ តេនហិ ភន្តេ មុហុត្តំ អាគមេហិ យាវស្ស អត្ថំ បេក្ខាមីតិ ។ អថខោ ចិត្តោ គហបតិ មុហុត្តំ តុណ្ហី ហុត្វា អាយស្មន្តំ កាមភុំ ឯតទវោច ណេលង្គន្តិ ខោ ភន្តេ សីលានមេតំ អធិវចនំ ។ សេតបច្ឆាទោតិ ខោ ភន្តេ វិមុត្តិយា ឯតំ អធិវចនំ ។ ឯការោតិ ខោ ភន្តេ សតិយា ឯតំ អធិវចនំ ។ វត្តតីតិ ខោ ភន្តេ អភិក្កមប្បដិក្កមស្សេតំ អធិវចនំ ។ រថោតិ ខោ ភន្តេ ឥមស្សេតំ ចាតុម្មហាភូតិកស្ស កាយស្ស អធិវចនំ មាតាបេត្តិកសម្ភវស្ស ឱទនកុម្មាសុបចយស្ស អនិច្ចុច្ឆាទន-

[២០១] ម្នាលគហបតី ភាសិតសង្ខេបនេះ ត្រូវយល់សេចក្តីដោយពិស្តារដូចម្តេចទៅ ។ បពិត្រព្រះករុណាដ៏ចម្រើន នេះប្រាកដជាពាក្យដែលព្រះមានព្រះភាគទ្រង់ពោលហើយឬ ។ អើគហបតី ។ បពិត្រព្រះករុណាដ៏ចម្រើន បើដូច្នោះ សូមព្រះករុណារង់ចាំមួយរំពេចសិន ទំរាំខ្ញុំព្រះករុណាពិចារណានូវអត្ថនៃភាសិតនេះ ។ លំដាប់នោះ ចិត្តគហបតីស្ងៀមតែមួយរំពេច ហើយក៏ពោលតបទៅនឹងព្រះកាមភូដ៏មានអាយុដូច្នេះថា បពិត្រព្រះករុណាដ៏ចម្រើន ពាក្យថា អវយវៈឥតទោសនេះ ជាឈ្មោះរបស់សីល ។ បពិត្រព្រះករុណាដ៏ចម្រើន ពាក្យថា មានគ្រឿងពាសមានព័ណ៌សនេះ ជាឈ្មោះនៃវិមុត្តិ ។ បពិត្រព្រះករុណាដ៏ចម្រើន ពាក្យថា មានកាំតែ ១ នេះ ជាឈ្មោះនៃសតិ ។ បពិត្រព្រះករុណាដ៏ចម្រើន ពាក្យថា តែងប្រព្រឹត្តទៅនេះ ជាឈ្មោះនៃការឈានទៅមុខនិងថយក្រោយ ។ បពិត្រព្រះករុណាដ៏ចម្រើន ពាក្យថា រថនេះ ជាឈ្មោះនៃកាយនេះដែលប្រកបដោយមហាភូតរូប ៤ កើតព្រមអំពីមាតានិងបិតា មានសេចក្តីចម្រើនដោយជាតិបាយនិងនំ ជាសភាវៈមិនទៀង

## ១៩៧



បរិមទ្ទនភេទនវិទ្ធំសនធម្មស្ស ។ រាគោ ខោ ភន្តេ នីឃោ ទោសោ នីឃោ មោហោ នីឃោ តេ ខីណាសវស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា ខីណាសវោ ភិក្ខុ អនីឃោតិ វុច្ចតិ ។ អប្បត្តន្តិ[១] ខោ ភន្តេ អរហតោ ឯតំ អធិវចនំ ។ សោតោតិ ខោ ភន្តេ តណ្ហាយេតំ អធិវចនំ សា ខីណាសវស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា ខីណាសវោ ភិក្ខុ ឆិន្នសោតោតិ វុច្ចតិ ។ រាគោ ខោ ភន្តេ ពន្ធនំ ទោសោ ពន្ធនំ មោហោ ពន្ធនំ តេ ខីណាសវស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភា-

១ ឱ. អាយន្តន្តេ ខោ ។

ចិត្តគហបតិបុច្ឆាសំយុត្ត

មានការផុសខាត់បំបាត់ក្ដិនអាក្រក់និងគក់ច្របាច់ បែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ។ បពិត្រព្រះករុណាដ៏ចម្រើន រាគៈជាទុក្ខ ទោសៈជាទុក្ខ មោហៈជាទុក្ខ ឯសភាវៈមានរាគៈជាដើមនោះ ភិក្ខុជាព្រះខីណាស្រពបានលះបង់ហើយ បានគាស់រំលើងឫសគល់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព ជាសភាវៈមិនកើតឡើងតទៅ ព្រោះហេតុនោះ ភិក្ខុជាព្រះខីណាស្រពទើបហៅថាមិនមានទុក្ខ ។ បពិត្រព្រះករុណាដ៏ចម្រើន ពាក្យថា មិនដល់នូវសេចក្ដីទុក្ខនេះ ជាឈ្មោះនៃព្រះអរហន្ត ។ បពិត្រព្រះករុណាដ៏ចម្រើន ពាក្យថា ខ្សែនេះ ជាឈ្មោះនៃតណ្ហា ឯតណ្ហានោះឯង ភិក្ខុជាព្រះខីណាស្រពបានលះបង់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាពជាសភាវៈមិនកើតឡើងតទៅ ព្រោះហេតុនោះ ភិក្ខុជាព្រះខីណាស្រពទើបហៅថាមានខ្សែដាច់ហើយ ។ បពិត្រព្រះករុណាដ៏ចម្រើន រាគៈជាចំណង ទោសៈជាចំណង មោហៈជាចំណង រាគៈជាដើមនោះ ភិក្ខុជាព្រះខីណាស្រពបានលះបង់ហើយ បានគាស់រំលើងឫសគល់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមាន

វន្តា អាយតឹ អនុប្បាទធម្មា តស្មា ខីណាសវោ ភិក្ខុ អពទ្ធោតិ វុច្ចតិ ។ ឥតិ ខោ ភន្តេ យន្តំ ភគវតា វុត្តំ

នេលង្គោ សេតបច្ឆាទោ
ឯការោ វត្តតី រថោ
អនីឃំ បស្ស អយន្តំ
ឆិន្នសោតំ អពន្ធនន្តិ ។

ឥមស្ស ខោហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ លាភា តេ គហបតិ សុលទ្ធំ តេ គហបតិ យស្ស តេ គម្ភីរេ ពុទ្ធវចនេ បញ្ញាចក្ខុ កមតីតិ ។ បញ្ចមំ ។

[២០២] ឯកំ សមយំ អាយស្មា កាមភូ មច្ឆិកាសណ្ឌេ វិហរតិ អម្ពាដកវនេ ។ អថខោ ចិត្តោ គហបតិ យេនាយស្មា កាមភូ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ កាមភុំ អភិវាទេត្វា

បែបភាព ជាសភាវៈមិនកើតឡើងតទៅ ព្រោះហេតុនោះ ភិក្ខុជាព្រះខីណាស្រពទើបហៅថា មិនមានចំណង ។ បពិត្រព្រះករុណាដ៏ចម្រើន ពាក្យដែលព្រះមានព្រះភាគបានពោលហើយដូច្នេះថា

រថមានអវយវៈឥតទោស មានគ្រឿងពាសមានព័ណ៌ស
មានកាំតែមួយ តែងប្រព្រឹត្តទៅ អ្នកចូរមើលនូវរថដែល
មិនមានទុក្ខ មិនដល់នូវសេចក្តីទុក្ខ មានខ្សែដាច់ហើយ
មិនមានចំណង ។

បពិត្រព្រះករុណាដ៏ចម្រើន ពាក្យនេះ ព្រះមានព្រះភាគទ្រង់ពោលដោយសង្ខេប ខ្ញុំអាចដឹងដោយសេចក្តីពិស្តារបានយ៉ាងនេះឯង ។ ម្នាលគហបតី អ្នកពេញហៅថា ជាមានលាភ ម្នាលគហបតី អត្តភាពជាមនុស្ស ពេញហៅថា អ្នកបានដោយប្រពៃ ព្រោះថាអ្នកមានបញ្ញាចក្ខុលុះទៅក្នុងពុទ្ធវចនៈដ៏ជ្រាលជ្រៅ ។ ចប់សូត្រទី ៥ ។

[២០២] សម័យមួយ ព្រះកាមភូមានអាយុ គង់នៅក្នុងវត្តអម្ពាដកវ័ន នាដងព្រៃមច្ឆិកា ។ គ្រានោះ ចិត្តគហបតីចូលទៅរកព្រះកាមភូមានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះកាមភូមានអាយុហើយ

ឯកាមន្តំ និសីទិ ។ ឯកាមន្តំ និសិន្នោ ខោ ចិត្តោ គហបតិ អាយស្មន្តំ កាមភុំ ឯតទវោច កតិ នុ ខោ ភន្តេ សង្ខារាតិ ។ តយោ ខោ គហបតិ សង្ខារា កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោតិ ។

[២០៣] សាធុ ភន្តេតិ ខោ ចិត្តោ គហបតិ អាយស្មតោ កាមភុស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អាយស្មន្តំ កាមភុំ ឧត្តរឹ បញ្ហំ អបុច្ឆិ កតមោ បន ភន្តេ កាយសង្ខារោ កតមោ វចីសង្ខារោ កតមោ ចិត្តសង្ខារោតិ ។ អស្សាសបស្សាសា ខោ គហបតិ កាយសង្ខារោ វិតក្កវិចារោ វចីសង្ខារា សញ្ញា ច វេទនា ច ចិត្តសង្ខារោតិ ។

[២០៤] សាធុ ភន្តេតិ ខោ ចិត្តោ គហបតិ ឧត្តរឹ បញ្ហំ អបុច្ឆិ កស្មា បន ភន្តេ អស្សាសបស្សាសា កាយសង្ខារោ កស្មា វិតក្កវិចារា វចីសង្ខារោ កស្មា

អង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះកាមភូមានអាយុដូច្នេះថា បពិត្រព្រះករុណាដ៏ចម្រើន សង្ខារមានប៉ុន្មានទៅហ្ន៎ ។ ម្នាលគហបតី សង្ខារមាន ៣ គឺ កាយ-សង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។

[២០៣] ចិត្តគហបតី ត្រេកអរអនុមោទនានឹងភាសិតរបស់ព្រះកាមភូមានអាយុថា ប្រពៃហើយ លោកម្ចាស់ ហើយក៏សួរនូវប្រស្នានឹងព្រះកាមភូមានអាយុតទៅទៀតថា បពិត្រព្រះករុណាដ៏ចម្រើន ចុះកាយសង្ខារតើដូចម្តេច វចីសង្ខារដូចម្តេច ចិត្តសង្ខារដូចម្តេច ។ ម្នាលគហបតី ខ្យល់ដង្ហើមចេញចូល ហៅថា កាយសង្ខារ សេចក្តីត្រិះរិះនិងសេចក្តីពិចារណា ហៅថា វចីសង្ខារ សញ្ញានិងវេទនា ហៅថា ចិត្តសង្ខារ ។

[២០៤] ចិត្តគហបតីពោលថា ប្រពៃហើយ លោកម្ចាស់ ហើយក៏សួរប្រស្នាតទៅទៀតថា បពិត្រព្រះករុណាដ៏ចម្រើន ចុះព្រោះហេតុអ្វីបានជាខ្យល់ដង្ហើមចេញចូល ហៅថា កាយសង្ខារ ព្រោះហេតុអ្វីបានជាសេចក្តីត្រិះរិះនិងសេចក្តីពិចារណា ហៅថា វចីសង្ខារ ព្រោះហេតុអ្វី

សញ្ញា ច វេទនា ច ចិត្តសង្ខារោតិ ។ អស្សាសប្ប-ស្សាសា ខោ គហបតិ កាយិកា ឯតេ ធម្មា កាយ-ប្បដិពទ្ធា តស្មា អស្សាសប្បស្សាសា កាយសង្ខារោ ។ បុព្វេ ខោ គហបតិ វិតក្កេត្វា វិចារេត្វា បច្ឆា វាចំ ភិន្ទតិ តស្មា វិតក្កវិចារា វចីសង្ខារោ ។ សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តប្បដិពទ្ធា តស្មា សញ្ញា ច វេទនា ច ចិត្តសង្ខារោតិ ។

[២០៨] សាធុ ។ បេ ។ បញ្ហំ អបុច្ឆិ កថម្បន ភន្តេ សញ្ញាវេទយិតនិរោធសមាបត្តិ ហោតីតិ ។ ន ខោ គហបតិ សញ្ញាវេទយិតនិរោធំ សមាបជ្ជន្តស្ស ភិក្ខុ-នោ ឯវំ ហោតិ អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជិ-ស្សន្តិ វា អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជាមីតិ វា អហំ សញ្ញាវេទយិតនិរោធំ សមាបន្នោតិ វា ។ អថខ្វស្ស បុព្វេវ តថា ចិត្តំ ភាវិតំ ហោតិ យន្តំ ត-ថត្តាយ ឧបនេតីតិ ។

*បានជាសញ្ញានិងវេទនា ហៅថា ចិត្តសង្ខារ ។ ម្នាលគហបតី ខ្យល់ដង្ហើមចេញចូលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនុ៎ះជាប់ចំពោះដោយកាយ ព្រោះហេតុនោះបានជាខ្យល់ដង្ហើមចេញចូល ហៅថា កាយសង្ខារ ។ ម្នាលគហបតី បុគ្គលត្រិះរិះពិចារណាជាមុនហើយ ទើបបញ្ចេញនូវវាចាជាខាងក្រោយ ព្រោះហេតុនោះ បានជាសេចក្តីត្រិះរិះនិងសេចក្តីពិចារណា ហៅថា វចីសង្ខារ ។ សញ្ញានិងវេទនាប្រព្រឹត្តទៅក្នុងចិត្ត ធម៌ទាំងនុ៎ះឯងជាប់ចំពោះដោយចិត្ត ព្រោះហេតុនោះ បានជាសញ្ញានិងវេទនា ហៅថាចិត្តសង្ខារ ។*

*[២០៥] ចិត្តគហបតីពោលថា ប្រពៃហើយ ។ បេ ។ ក៏សួរនូវប្រស្នាថា បពិត្រព្រះករុណាដ៏ចម្រើន ចុះការចូលសញ្ញាវេទយិតនិរោធ[១] ដោយប្រការដូចម្តេច ។ ម្នាលគហបតី ភិក្ខុដែលចូលសញ្ញាវេទយិតនិរោធមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញចូលសញ្ញាវេទយិតនិរោធក្តី ថា អាត្មាអញកំពុងចូលនូវសញ្ញាវេទយិតនិរោធក្តី ថា អាត្មាអញបានចូលហើយនូវសញ្ញាវេទយិតនិរោធក្តី ។ ព្រោះថាចិត្តឯណាតែងបង្អោនទៅដើម្បីជាបុគ្គលមានសភាព[២]ដូច្នោះ ចិត្តនោះឯង ភិក្ខុនោះបានចម្រើនហើយក្នុងកាលមុន ។*

១ សេចក្តីរលត់នៃសញ្ញានិងវេទនា ។ ២ បង្អោនទៅដើម្បីមិនឲ្យមានចិត្ត គឺមិនឲ្យមានសញ្ញានិងវេទនានោះឯង ។

ចិត្តគហបតិបុច្ឆាសំយុត្តំ

[២០៦] សាធុ ។ បេ ។ បញ្ហំ អបុច្ឆិ សញ្ញាវេទយិតនិរោធំ សមាបជ្ជន្តស្ស បន ភន្តេ ភិក្ខុនោ កតមេ ធម្មា បឋមំ និរុជ្ឈន្តិ យទិ វា កាយសង្ខារោ យទិ វា វចីសង្ខារោ យទិ វា ចិត្តសង្ខារោតិ ។ សញ្ញាវេទយិតនិរោធំ សមាបជ្ជន្តស្ស ខោ គហបតិ ភិក្ខុនោ វចីសង្ខារោ បឋមំ និរុជ្ឈតិ តតោ កាយសង្ខារោ តតោ ចិត្តសង្ខារោតិ ។

[២០៧] សាធុ ។ បេ ។ បញ្ហំ អបុច្ឆិ យ្វាយំ ភន្តេ មតោ កាលកតោ យោ ចាយំ ភិក្ខុ សញ្ញាវេទយិតនិរោធំ សមាបន្នោ ឥមេសំ កឹ នានាករណន្តិ ។ យ្វាយំ គហបតិ មតោ កាលកតោ តស្ស កាយសង្ខារោ និរុទ្ធោ បដិប្បស្សទ្ធោ វចីសង្ខារោ និរុទ្ធោ បដិប្បស្សទ្ធោ ចិត្តសង្ខារោ និរុទ្ធោ បដិប្បស្សទ្ធោ អាយុ បរិក្ខីណោ ឧស្មា វូបសន្តា ឥន្ទ្រិយានិ វិបរិភិន្នានិ ។ យោ ច ខ្វាយំ គហបតិ ភិក្ខុ សញ្ញាវេទយិតនិរោធំ សមាបន្នោ តស្សបិ កាយសង្ខារោ និរុទ្ធោ

ចិត្តគហបតិបុច្ឆាសំយុត្ត

[២០៦] ចិត្តគហបតីពោលថា ប្រពៃហើយ ។ បេ ។ ក៏សួរនូវប្រស្នាថា បពិត្រព្រះករុណាដ៏ចម្រើន ចុះភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ ធម៌ណារលត់មុន កាយសង្ខាររលត់មុនឬវចីសង្ខារឬក៏ចិត្តសង្ខារ ។ ម្នាលគហបតី ភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ វចីសង្ខាររលត់មុន តអំពីនោះទៅកាយសង្ខារ តអំពីនោះទៅចិត្តសង្ខារ ។

[២០៧] ចិត្តគហបតីពោលថា ប្រពៃហើយ ។ បេ ។ ក៏សួរនូវប្រស្នាថា បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុដែលស្លាប់ហើយ ធ្វើមរណកាលហើយ និងភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ ភិក្ខុទាំងពីរពួកនេះ មានការផ្សេងគ្នាដូចម្ដេច ។ ម្នាលគហបតី ភិក្ខុឯណាដែលស្លាប់ហើយ ធ្វើមរណកាលហើយ កាយសង្ខាររបស់ភិក្ខុនោះរលត់ហើយ រម្ងាប់ហើយ វចីសង្ខារក៏រលត់ហើយ រម្ងាប់ហើយ ចិត្តសង្ខារក៏រលត់ហើយ រម្ងាប់ហើយ អាយុក៏អស់ហើយ ភ្លើងធាតុក៏រម្ងាប់ហើយ ឥន្ទ្រិយក៏បែកធ្លាយរាត់រាយហើយ ។ ម្នាលគហបតី ភិក្ខុឯណាដែលបានចូលកាន់សញ្ញាវេទយិតនិរោធហើយ ឯកាយសង្ខារភិក្ខុនោះរលត់ហើយ

បដិប្បស្សទ្ធោ វចីសង្ខារោ និរុទ្ធោ បដិប្បស្សទ្ធោ ចិត្ត-សង្ខារោ និរុទ្ធោ បដិប្បស្សទ្ធោ អាយុ អបរិក្ខីណោ ឧស្មា អវូបសន្តា ឥន្ទ្រិយានិ វិប្បសន្នានិ ។ យ្វាយំ គហបតិ មតោ កាលកតោ យោ ចាយំ ភិក្ខុ សញ្ញាវេទយិតនិរោធំ សមាបន្នោ ឥទំ នេសំ នានា-ករណន្តិ ។

[២០៨] សាធុ ។ បេ ។ ឧត្តរឹ បញ្ហំ អបុច្ឆិ កថម្បន ភន្តេ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋានំ ហោតី-តិ ។ ន ខោ គហបតិ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហន្តស្ស ភិក្ខុនោ ឯវំ ហោតិ អហំ សញ្ញាវេទយិ-តនិរោធសមាបត្តិយា វុដ្ឋហិស្សន្តិ វា អហំ សញ្ញាវេ-ទយិតនិរោធសមាបត្តិយា វុដ្ឋហាមីតិ វា អហំ សញ្ញាវេ-ទយិតនិរោធសមាបត្តិយា វុដ្ឋិតោតិ វាតិ ។ អថខ្វស្ស បុព្វេវ តថា ចិត្តំ ភាវិតំ ហោតិ យន្តំ តថត្តាយ ឧបនេតីតិ ។

រម្ងាប់ហើយ វចីសង្ខារក៏រលត់ហើយ រម្ងាប់ហើយ ចិត្តសង្ខារក៏រលត់ហើយ រម្ងាប់ហើយ តែអាយុមិនអស់ ភ្លើងធាតុមិនទាន់រម្ងាប់ ឥន្ទ្រិយនៅស្រស់បស់នៅឡើយ ។ ម្នាលគហបតី ភិក្ខុដែលស្លាប់ហើយធ្វើមរណកាលហើយ និងភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធហើយនេះឯង ជាការផ្សេងគ្នានៃភិក្ខុទាំងនោះ ។

[២០៨] ចិត្តគហបតីពោលថា ប្រពៃហើយ ។ បេ ។ ក៏សួរនូវប្រស្នាតទៅទៀតថា បពិត្រព្រះករុណាដ៏ចម្រើន ចុះការចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិ ដោយប្រការដូចម្ដេច ។ ម្នាលគហបតី ភិក្ខុដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិ មិនមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិក្ដី ថាអាត្មាអញកំពុងចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិក្ដី ថាអាត្មាអញបានចេញហើយចាកសញ្ញាវេទយិតនិរោធសមាបត្តិក្ដី ។ ព្រោះថាចិត្តឯណាបង្អោនទៅដើម្បីជាបុគ្គលមានសភាពដូច្នោះ ចិត្តនោះឯងភិក្ខុនោះបានចម្រើនហើយក្នុងកាលមុន ។

## ២០៣

### ចិត្តគហបតិបុច្ឆាសំយុត្តំ

[២០៩] សាធុ ភន្តេ ។ បេ ។ ឧត្តរឹ បញ្ហំ អបុច្ឆិ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហន្តស្ស បន ភន្តេ ភិក្ខុនោ កតមេ ធម្មា បឋមំ ឧប្បជ្ជន្តិ យទិ វា កាយសង្ខារោ យទិ វា វចីសង្ខារោ យទិ វា ចិត្តសង្ខារោតិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហន្តស្ស ខោ គហបតិ ភិក្ខុនោ ចិត្តសង្ខារោ បឋមំ ឧប្បជ្ជតិ តតោ កាយសង្ខារោ តតោ វចីសង្ខារោតិ ។

[២១០] សាធុ ។ បេ ។ ឧត្តរឹ បញ្ហំ អបុច្ឆិ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតំ បន ភន្តេ ភិក្ខុំ កតិ ផស្សា ផុសន្តិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតំ ខោ គហបតិ ភិក្ខុំ តយោ ផស្សា ផុសន្តិ សុញ្ញោ[១] ផស្សោ អនិមិត្តោ ផស្សោ អប្បណិហិតោ ផស្សោតិ ។

១ ឱ. ម. សុញ្ញតោ ។

ចិត្តគហបតិបុច្ឆាសំយុត្ត

[២០៩] ចិត្តគហបតីពោលថា ប្រពៃហើយ លោកម្ចាស់ ។ បេ ។ ក៏សួរនូវប្រស្នាតទៅទៀតថា បពិត្រព្រះករុណាដ៏ចម្រើន ចុះភិក្ខុដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិ ធម៌ណាកើតមុន កាយសង្ខារកើតមុនឬវចីសង្ខារឬក៏ចិត្តសង្ខារ ។ ម្នាលគហបតី ភិក្ខុដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិ ចិត្តសង្ខារកើតមុន តអំពីនោះទៅកាយ-សង្ខារ តអំពីនោះទៅវចីសង្ខារ ។

[២១០] ចិត្តគហបតីពោលថា ប្រពៃហើយ ។ បេ ។ ក៏សួរនូវប្រស្នាតទៅទៀតថា បពិត្រព្រះករុណាដ៏ចម្រើន ផស្សៈប៉ុន្មាន ដែលពាល់ត្រូវភិក្ខុដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិរួចហើយ ។ ម្នាលគហបតី ផស្សៈ ៣ គឺ សុញ្ញផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិត-ផស្សៈ ១ តែងពាល់ត្រូវភិក្ខុដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិរួចហើយ ។

[២១១] សាធុ ។ បេ ។ ឧត្តរឹ បញ្ហំ អបុច្ឆិ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតស្ស បន ភន្តេ ភិក្ខុនោ កឹនិន្នំ ចិត្តំ ហោតិ កឹពោណំ កឹបព្ភារន្តិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតស្ស ខោ គហបតិ ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកពោណំ វិវេកបព្ភារន្តិ ។

[២១២] សាធុ ភន្តេតិ ខោ ចិត្តោ គហបតិ អាយស្មតោ កាមភុស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អាយស្មន្តំ កាមភុំ ឧត្តរឹ បញ្ហំ អបុច្ឆិ សញ្ញាវេទយិតនិរោធសមាបត្តិយា បន ភន្តេ កតិ ធម្មា ពហុបការាតិ ។ អទ្ធា ខោ ត្វំ គហបតិ យំ បឋមំ បុច្ឆិតព្វំ តំ[១] បុច្ឆសិ អបិ ច ត្យាហំ ព្យាករិស្សាមិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា ខោ គហបតិ ទ្វេ ធម្មា ពហុបការា សមថោ ច វិបស្សនា ចាតិ ។ ឆដ្ឋំ ។

១ ឱ. តម្បុច្ឆា បុច្ឆសិ ។

[២១១] ចិត្តគហបតីពោលថា ប្រពៃហើយ ។ បេ ។ ក៏សួរនូវប្រស្នាតទៅទៀតថា បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិរួចហើយ មានចិត្តបង្អោនទៅរកអ្វី ទេរទៅរកអ្វី ជ្រេទៅរកអ្វី ។ ម្នាលគហបតី ភិក្ខុដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិរួចហើយ មានចិត្តបង្អោនទៅរកវិវេក ទេរទៅរកវិវេក ជ្រេទៅរកវិវេក ។

[២១២] ចិត្តគហបតី ត្រេកអរអនុមោទនានឹងភាសិតរបស់ព្រះកាមភូមានអាយុថា ប្រពៃហើយ លោកម្ចាស់ ហើយក៏សួរនូវប្រស្នាតទៅទៀតនឹងព្រះកាមភូមានអាយុថា បពិត្រព្រះករុណាដ៏ចម្រើន ចុះធម៌ប៉ុន្មាន ដែលមានឧបការៈច្រើនដល់សញ្ញាវេទយិតនិរោធសមាបត្តិ ។ ម្នាលគហបតី ពាក្យឯណាដែលគេត្រូវសួរមុន ពាក្យនោះអ្នកសួរក្រោយវិញ ណ្ហើយចុះ អាត្មានឹងដោះស្រាយដល់អ្នក ។ ម្នាលគហបតី ធម៌ ២ យ៉ាង គឺសមថនិងវិបស្សនា មានឧបការៈច្រើនដល់សញ្ញាវេទយិតនិរោធសមាបត្តិ ។ ចប់សូត្រទី ៦ ។

ចិត្តគហបតិបុច្ឆាសំយុត្តំ

[២១៣] ឯកំ សមយំ អាយស្មា គោទត្តោ មច្ឆិកាសណ្ឌេ វិហរតិ អម្ពាដកវនេ ។ អថខោ ចិត្តោ គហបតិ យេនាយស្មា គោទត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ គោទត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចិត្តំ គហបតឹ អាយស្មា គោទត្តោ ឯតទវោច យា ចាយំ គហបតិ អប្បមាណា ចេតោវិមុត្តិ យា ច អាកិញ្ចញ្ញា ចេតោវិមុត្តិ យា ច សុញ្ញតា ចេតោវិមុត្តិ យា ច អនិមិត្តា ចេតោវិមុត្តិ ឥមេ ធម្មា នានត្ថា នានាព្យញ្ជនា ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ អត្ថិ ភន្តេ បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច អត្ថិ បន ភន្តេ បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា ឯកត្ថា[១] ព្យញ្ជនមេវ នានន្តិ ។

---

១ ឯកត្ថា ចេវ ។

## ចិត្តគហបតិបុច្ឆាសំយុត្ត

[២១៣] សម័យមួយ ព្រះគោទត្តមានអាយុ គង់នៅក្នុងវត្តអម្ពាដកវ័ន នាដង់ព្រៃមច្ឆិកា ។ គ្រានោះ ចិត្តគហបតីចូលទៅរកព្រះគោទត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះគោទត្តមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ ព្រះគោទត្តមានអាយុក៏ពោលដូច្នេះថា ម្នាលគហបតី អប្បមាណាចេតោវិមុត្តិឯណាក្តី អាកិញ្ចញ្ញាចេតោវិមុត្តិឯណាក្តី សុញ្ញ-តាចេតោវិមុត្តិឯណាក្តី អនិមិត្តាចេតោវិមុត្តិឯណាក្តី ធម៌ទាំងអម្បាលនេះមានអត្ថផ្សេងគ្នា មានព្យញ្ជនៈផ្សេងគ្នា ឬមានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។ បពិត្រព្រះករុណាដ៏ចម្រើន ធម៌ទាំងអម្បាលនេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយនោះរមែងមាន បពិត្រព្រះករុណាដ៏ចម្រើន ធម៌ទាំងអម្បាលនេះ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយនោះក៏មានដែរ ។

[២១៤] កាតមោ ច ភន្តេ បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា ជានត្ថា ចេវ ជានាព្យញ្ជនា ច ។ ឥធ ភន្តេ ភិក្ខុ មេត្តាសហាគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហារតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហាគតេន ចេតសា វិបុលេន មហាគ្គតេ-ន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហារតិ ។ ការុណាសហាគតេន ចេតសា ។ មុទិតាសហាគតេន ចេតសា ។ ឧបេក្ខាសហាគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហារតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហាគតេន ចេតសា វិបុ-លេន មហាគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន

[២១៤] បពិត្រព្រះករុណាដ៏ចម្រើន មួយទៀត ធម៌ទាំងអម្បាល នេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយនោះ តើដូចម្តេច ។ បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ។ ផ្សាយទៅកាន់ទិសទី ២ ក៏ដូចគ្នា ។ កាន់ទិសទី ៣ ក៏ដូចគ្នា ។ កាន់ទិសទី ៤ ក៏ដូចគ្នា ។ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹងក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវភាវៈជាធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ។ មានចិត្តប្រកបដោយករុណា ។ មានចិត្តប្រកបដោយមុទិតា ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ។ ផ្សាយទៅកាន់ទិសទី ២ ក៏ដូចគ្នា ។ កាន់ទិសទី ៣ ក៏ដូចគ្នា ។ កាន់ទិសទី ៤ ក៏ដូចគ្នា ។ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹងក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវភាវៈជាធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ

ផរិត្វា វិហរតិ ។ អយំ វុច្ចតិ ភន្តេ អប្បមាណា ចេតោវិមុត្តិ[១] ។

[២១៥] កតមា ច ភន្តេ អាកិញ្ចញ្ញា ចេតោវិមុត្តិ ។ ឥធ ភន្តេ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភន្តេ អាកិញ្ចញ្ញា ចេតោវិមុត្តិ ។

[២១៦] កតមា ច ភន្តេ សុញ្ញតា ចេតោវិមុត្តិ ។ ឥធ ភន្តេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ សុញ្ញមិទំ អត្តេន វា អត្តនីយេន វាតិ ។ អយំ វុច្ចតិ ភន្តេ សុញ្ញតា ចេតោវិមុត្តិ ។

---

១ ឱ. អប្បមាណេន ចេតសា វិមុត្តិ ។

ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ។ បពិត្រព្រះករុណាដ៏ចម្រើន នេះហៅថា អប្បមាណាចេតោវិមុត្តិ ។

[២១៥] បពិត្រព្រះករុណាដ៏ចម្រើន ចុះអាកិញ្ចញ្ញាចេតោវិមុត្តិ តើដូចម្តេច ។ បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនសមាបត្តិ ដោយប្រការទាំងពួង បានដល់នូវអាកិញ្ចញ្ញាយតនសមាបត្តិ ដោយធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ។ បពិត្រព្រះករុណាដ៏ចម្រើន នេះហៅថា អាកិញ្ចញ្ញាចេតោវិមុត្តិ ។

[២១៦] បពិត្រព្រះករុណាដ៏ចម្រើន ចុះសុញ្ញតាចេតោវិមុត្តិ តើដូចម្តេច ។ បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ពិចារណាដូច្នេះថា ធម្មជាតនេះសូន្យចាកខ្លួនឬចាកវត្ថុជារបស់ខ្លួន ។ បពិត្រព្រះករុណាដ៏ចម្រើន នេះហៅថា សុញ្ញតាចេតោវិមុត្តិ ។

[២១៧] កតមា ច ភន្តេ អនិមិត្តា ចេតោវិ-
មុត្តិ ។ ឥធ ភន្តេ ភិក្ខុ សព្វនិមិត្តានំ អមនសិការា
អនិមិត្តំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ ។ អយំ
វុច្ចតិ ភន្តេ អនិមិត្តា ចេតោវិមុត្តិ ។ អយំ ខោ ភន្តេ
បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា នានត្ថា
ចេវ នានាព្យញ្ជនា ច ។

[២១៨] កតមោ ច ភន្តេ បរិយាយោ យំ ប-
រិយាយំ អាគម្ម ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នា-
នំ ។ រាគោ ភន្តេ បមាណករណោ ទោសោ បមា-
ណករណោ មោហោ បមាណករណោ តេ ខីណា-
សវស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុ-

[២១៧] បពិត្រព្រះករុណាដ៏ចម្រើន ចុះអនិមិត្តាចេតោវិមុត្តិ តើដូចម្តេច ។ បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ បានដល់នូវចេតោសមាធិមិនមាននិមិត្ត ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួងប្រព្រឹត្តទៅគ្រប់ឥរិយាបថ ។ បពិត្រព្រះករុណាដ៏ចម្រើន នេះហៅថាអនិមិត្តាចេតោវិមុត្តិ ។ បពិត្រព្រះករុណាដ៏ចម្រើន ធម៌ទាំងអម្បាលនេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ព្រោះអាស្រ័យនូវបរិយាយឯណា គឺបរិយាយនេះឯង ។

[២១៨] បពិត្រព្រះករុណាដ៏ចម្រើន ធម៌ទាំងអម្បាលនេះ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយនោះ តើដូចម្តេច ។ បពិត្រព្រះករុណាដ៏ចម្រើន រាគៈជាគ្រឿងធ្វើនូវប្រមាណ ទោសៈជាគ្រឿងធ្វើនូវប្រមាណ មោហៈជាគ្រឿងធ្វើនូវប្រមាណ ឯសភាវៈមានរាគៈជាដើមនោះ ភិក្ខុជាព្រះខីណាស្រពបានលះបង់ហើយ បានគាស់រំលើងឫសគល់ហើយ បានធ្វើឲ្យនៅសល់តែទី

២០៩

ចិត្តគហបតិបុច្ឆាសំយុត្តំ

កតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ យាវតា ខោ ភន្តេ អប្បមាណោ ចេតោវិមុត្តិយោ អកុប្បា តាសំ ចេតោវិមុត្តិ អគ្គមក្ខាយតិ ។ សា ខោ បន អកុប្បា ចេតោវិមុត្តិ សុញ្ញា រាគេន សុញ្ញា ទោសេន សុញ្ញា មោហេន ។ រាគោ ខោ ភន្តេ កិញ្ចនំ ទោសោ កិញ្ចនំ មោហោ កិញ្ចនំ តេ ខីណាសវស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ យាវតា ខោ ភន្តេ អាកិញ្ចញ្ញា ចេតោវិមុត្តិយោ អកុប្បា តាសំ ចេតោវិមុត្តិ អគ្គ-មក្ខាយតិ ។ សា ខោ បន អកុប្បា ចេតោវិមុត្តិ សុញ្ញា រាគេន សុញ្ញា ទោសេន សុញ្ញា មោ-ហេន ។ រាគោ ខោ ភន្តេ និមិត្តករណោ ទោសោ

នៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព ជាសភាវៈមិនកើតឡើងតទៅ ។ បពិត្រព្រះករុណាដ៏ចម្រើន អប្បមាណាចេតោវិមុត្តិទាំងឡាយមានកំណត់ត្រឹមណា អកុប្បាចេតោវិមុត្តិប្រាកដជាប្រសើរជាងអប្បមាណាចេតោវិមុត្តិនោះ ។ ព្រោះអកុប្បាចេតោវិមុត្តិនោះ សូន្យចាករាគៈ សូន្យចាកទោសៈ សូន្យចាកមោហៈ ។ បពិត្រព្រះករុណាដ៏ចម្រើន រាគៈជាកង្វល់ ទោសៈជាកង្វល់ មោហៈជាកង្វល់ រាគៈជាដើមនោះ ភិក្ខុជាព្រះខីណាស្រពបានលះបង់ហើយ បានគាស់រំលើងឫសគល់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព ជាសភាវៈមិនកើតឡើងតទៅ ។ បពិត្រព្រះករុណាដ៏ចម្រើន អាកិញ្ចញ្ញាចេតោវិមុត្តិទាំងឡាយមានកំណត់ត្រឹមណា អកុប្បាចេតោវិមុត្តិ ប្រាកដជាប្រសើរជាងអាកិញ្ចញ្ញាចេតោវិមុត្តិទាំងនោះ ។ ព្រោះអកុប្បាចេតោវិមុត្តិនោះ សូន្យចាករាគៈ សូន្យចាកទោសៈ សូន្យចាកមោហៈ ។ បពិត្រព្រះករុណាដ៏ចម្រើន រាគៈជាគ្រឿងធ្វើនូវនិមិត្ត ទោសៈ

និមិត្តករណោ មោហោ និមិត្តករណោ តេ ខីណាស-
វស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តាលវត្ថុកតា
អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ យាវតា ខោ ភន្តេ
អនិមិត្តាចេតោវិមុត្តិយោ អកុប្បា តាសំ ចេតោវិមុត្តិ
អគ្គមក្ខាយតិ ។ សា ខោ បន អកុប្បា ចេតោវិមុត្តិ
សុញ្ញា រាគេន សុញ្ញា ទោសេន សុញ្ញា មោហេន ។
អយំ ខោ ភន្តេ បរិយាយោ យំ បរិយាយំ អាគម្ម
ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ លាភា តេ
គហបតិ សុលទ្ធំ តេ គហបតិ យស្ស តេ គម្ភីរេ
ពុទ្ធវចនេ បញ្ញាចក្ខុ កមតីតិ ។ សត្តមំ ។

ជាគ្រឿងធ្វើនូវនិមិត្ត មោហៈជាគ្រឿងធ្វើនូវនិមិត្ត រាគៈជាដើមនោះ ភិក្ខុជាព្រះខីណាស្រពបានលះបង់ហើយ បានគាស់រំលើងឫសគល់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព ជាសភាវៈមិនកើតឡើងតទៅ ។ បពិត្រព្រះករុណាដ៏ចម្រើន អនិមិត្តាចេតោវិមុត្តិទាំងឡាយមានកំណត់ត្រឹមណា អកុប្បាចេ-តោវិមុត្តិ ប្រាកដជាប្រសើរជាងអនិមិត្តាចេតោវិមុត្តិទាំងនោះ ។ ព្រោះថាអកុប្បាចេតោវិមុត្តិនោះ សូន្យចាករាគៈ សូន្យចាកទោសៈ សូន្យចាកមោហៈ ។ បពិត្រព្រះករុណាដ៏ចម្រើន ធម៌ទាំងអម្បាលនេះ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ព្រោះអាស្រ័យនូវបរិយាយឯណា គឺបរិយាយនេះឯង ។ ម្នាលគហបតី អ្នកពេញហៅថាមានលាភ ម្នាលគហបតីអត្តភាពជាមនុស្ស ពេញហៅថាអ្នកបានដោយប្រពៃហើយ ព្រោះអ្នកមានបញ្ញាចក្ខុលុះទៅក្នុងពុទ្ធវចនៈដ៏ជ្រាលជ្រៅ ។ ចប់សូត្រទី ៧ ។

២១១

## ចិត្តគហបតិបុច្ឆាសំយុត្តំ

[២១៩] តេន ខោ បន សមយេន និគណ្ឋោ នាដបុត្តោ មច្ឆិកាសណ្ឌំ អនុប្បត្តោ ហោតិ មហតិយា និគណ្ឋបរិសាយ សទ្ធឹ ។ អស្សោសិ ខោ ចិត្តោ គហបតិ និគណ្ឋោ កិរ នាដបុត្តោ មច្ឆិកាសណ្ឌំ អនុប្បត្តោ មហតិយា និគណ្ឋបរិសាយ សទ្ធិន្តិ ។ អថខោ ចិត្តោ គហបតិ សម្ពហុលេហិ ឧបាសកេហិ សទ្ធឹ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋេន នាដបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចិត្តំ គហបតឹ និគណ្ឋោ នាដបុត្តោ ឯតទវោច សទ្ទហសិ ត្វំ គហបតិ សមណស្ស គោតមស្ស អត្ថិ អវិតក្កោ អវិចារោ សមាធិ អត្ថិ វិតក្កវិចារានំ និរោធោតិ ។ ន ខ្វាហំ ឯត្ថ ភន្តេ ភគវតោ សទ្ធាយ គច្ឆាមិ អត្ថិ អវិតក្កោ អវិចារោ សមាធិ អត្ថិ វិតក្កវិចារានំ និរោធោតិ ។

## ចិត្តគហបតិបុច្ឆាសំយុត្ត

[២១៩] សម័យនោះឯង និគ្គណ្ឋនាដបុត្តបានទៅដល់ដង់ព្រៃមច្ឆិកា ជាមួយនឹងនិគ្រន្ថជាបរិសទ្យដ៏ច្រើន ។ ចិត្តគហបតីឮដំណឹងថា និគ្គណ្ឋនាដបុត្តមកដល់ដង់ព្រៃមច្ឆិកា ជាមួយនឹងនិគ្រន្ថជាបរិសទ្យដ៏ច្រើន ។ គ្រានោះ ចិត្តគហបតីព្រមទាំងពួកឧបាសកជាច្រើន ចូលទៅរកនិគ្គណ្ឋនាដបុត្ត លុះចូលទៅដល់ហើយ ក៏ធ្វើនូវសេចក្ដីរីករាយជាមួយនឹងនិគ្គណ្ឋនាដបុត្ត លុះបញ្ចប់ពាក្យដែលគួររីករាយគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីសមគួរហើយ និគ្គណ្ឋនាដបុត្តក៏សួរទៅដូច្នេះថា ម្នាលគហបតី អ្នកជឿពាក្យសមណគោតមថា សមាធិមិនមានវិតក្កៈមិនមានវិចារៈក៏មាន សេចក្ដីរលត់នៃវិតក្កៈនិងវិចារៈក៏មានឬ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំមិនប្រព្រឹត្តទៅដោយសេចក្ដីជឿពាក្យរបស់ព្រះមានព្រះភាគក្នុងហេតុនេះថា សមាធិមិនមានវិតក្កៈមិនមានវិចារៈក៏មាន សេចក្ដីរលត់នៃវិតក្កៈនិងវិចារៈក៏មាន ដូច្នេះទេ ។

[២២០] ឯវំ វុត្តេ និគណ្ឋោ នាដបុត្តោ សកំ បរិសំ អបលោកេត្វា[១] ឯតទវោច ឥទំ ភវន្តោ បស្សន្តុ យាវ ឧជុកោ ចាយំ ចិត្តោ គហបតិ យាវ អសឋោ ចាយំ ចិត្តោ គហបតិ យាវ អមាយាវី ចាយំ ចិត្តោ គហបតិ វាតំ វា សោ ជាលេន ពាធេតព្វំ មញ្ញេយ្យ យោ វិតក្កវិចារេ និរោធេតព្វំ មញ្ញេយ្យ សកមុដ្ឋិនា វា សោ គង្គាយ សោតំ អាវារេតព្វំ មញ្ញេយ្យ យោ វិតក្កវិចារេ និរោធេតព្វំ មញ្ញេយ្យាតិ ។ តំ កឹ មញ្ញសិ ភន្តេ កតមំ នុ ខោ បណីតតរំ ញាណំ វា សទ្ធា វាតិ ។ សទ្ធាយ ខោ គហបតិ ញាណំយេវ បណីតតរន្តិ ។ អហំ ខោ ភន្តេ យាវទេវ អាកង្ខាមិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិ-សុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ អហំ ខោ ភន្តេ យាវទេវ អាកង្ខាមិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ អហំ ខោ ភន្តេ

១ ឱ. ម. ឧល្លោកេត្វា ។ ឱលោកេត្វាតិ អដ្ឋកថាយំ ទិស្សតិ ។

[២២០] កាលបើចិត្តគហបតីពោលយ៉ាងនេះ និគ្គណ្ឋនាដបុត្ត ក៏ក្រឡេកមើលបរិសទ្យរបស់ខ្លួនហើយពោលទៅដូច្នេះថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលនូវគហបតីនេះចុះ ចិត្តគហបតីនេះ ពេញជាមនុស្សមានចិត្តត្រង់ ចិត្តគហបតីនេះ ពេញជាមនុស្សមិនអែបអប ចិត្តគហបតីនេះ ពេញជាមនុស្សមិនមានកិច្ចកល បុគ្គលឯណាគប្បីសំគាល់នូវវិតក្កៈនិងវិចារៈថាជាធម្មជាតគួររំលត់បាន បុគ្គលនោះគប្បីសំគាល់នូវខ្យល់ថាជារបស់គួរបៀតបៀនបានដោយអណ្តាតភ្លើង បុគ្គលឯណាគប្បីសំគាល់នូវវិតក្កៈនិងវិចារៈថាជាធម្មជាតគួររំលត់បាន បុគ្គលនោះគប្បីសំគាល់នូវខ្សែនៃគង្គាថាជារបស់គួរឃាត់ដោយក្តាប់ដៃនៃខ្លួនបានដែរ ។ បពិត្រលោកដ៏ចម្រើន ចុះលោកសំគាល់នូវសេចក្តីនោះដូចម្តេច ញាណក្តីសទ្ធាក្តី (បណ្តាធម្មជាតទាំង ២ នេះ) ធម្មជាតណាឧត្តមជាង ។ ម្នាលគហបតី ញាណឧត្តមជាងសទ្ធា ។ បពិត្រលោកដ៏ចម្រើន ខ្ញុំប្រាថ្នាស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខដ៏កើតអំពីសេចក្តីស្ងាត់ ប្រព្រឹត្តនៅគ្រប់ឥរិយាបថកំណត់ត្រឹមណា ។ បពិត្រលោកដ៏ចម្រើន ខ្ញុំប្រាថ្នារម្ងាប់នូវវិតក្កៈវិចារៈ ។ បេ ។ ដល់នូវទុតិយជ្ឈានប្រព្រឹត្តនៅគ្រប់ឥរិយាបថកំណត់ត្រឹមណា ។ បពិត្រលោកដ៏ចម្រើន ខ្ញុំ

យាវទេវ អាកង្ខាមិ បីតិយា ច វិរាគា ។ បេ ។ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ អហំ ខោ ភន្តេ យាវទេវ អាកង្ខាមិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ ន(១) សោ ខ្វាហំ ភន្តេ ឯវំ ជានន្តោ ឯវំ បស្សន្តោ កាយស្ស សមណស្ស វា ព្រាហ្មណស្ស វា សទ្ធាយ គមិស្សាមិ អត្ថិ អវិតក្កោ អវិចារោ សមាធិ អត្ថិ វិតក្កវិចារានំ និរោធោតិ ។

[២២១] ឯវំ វុត្តេ និគណ្ឋោ នាដបុត្តោ សកំ បរិសំ អបលោកេត្វា ឯតទវោច ឥទំ ភវន្តោ បស្សន្តុ យាវ អនុជ្ជុកោ ចាយំ ចិត្តោ គហបតិ យាវ សឋោ ចាយំ ចិត្តោ គហបតិ យាវ មាយាវី ចាយំ ចិត្តោ គហបតីតិ ។ ឥទានេវ ច បន(២) មយំ ភន្តេ

១ ឱ. ន សទ្ធោ ន ហោតិ ។ ២ ឱ. ឥទានេវ ខោ តេ បន ។

ប្រាថ្នានឿយណាយចាកបីតិ ។ បេ ។ ដល់នូវតតិយជ្ឈាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថកំណត់ត្រឹមណា ។ បពិត្រលោកដ៏ចម្រើន ខ្ញុំប្រាថ្នាលះបង់នូវសុខ ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថកំណត់ត្រឹមណា ។ បពិត្រលោកដ៏ចម្រើន កាលបើខ្ញុំដឹងយ៉ាងនេះឃើញយ៉ាងនេះ នឹងមិនប្រព្រឹត្តទៅដោយសេចក្តីជឿពាក្យរបស់សមណៈឬព្រាហ្មណ៍ណាមួយថា សមាធិមិនមានវិតក្កៈមិនមានវិចារៈក៏មាន សេចក្តីរលត់នៃវិតក្កៈនិងវិចារៈក៏មានដូច្នេះទេ ។

[២២១] កាលបើចិត្តគហបតីពោលយ៉ាងនេះ និគ្គណ្ឋនាដបុត្តក៏ក្រឡេកមើលទៅបរិសទ្យរបស់ខ្លួនហើយពោលដូច្នេះថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលនូវគហបតីនេះចុះ ឯចិត្តគហបតីនេះ ពេញជាមនុស្សមានចិត្តមិនត្រង់ ចិត្តគហបតីនេះ ពេញជាមនុស្សអែបអប ចិត្តគហបតីនេះ ពេញជាមនុស្សមានកិច្ចកល ។ បពិត្រលោកដ៏ចម្រើន យើង

ភាសិតំ ឯវំ អាជានាម ឥទំ ភវន្តោ បស្សន្តុ យាវ ឧជុកោ ចាយំ ចិត្តោ គហបតិ យាវ អសឋោ ចាយំ ចិត្តោ គហបតិ យាវ អមាយាវី ចាយំ ចិត្តោ គហបតីតិ ។ ឥទានេវ ច បន មយំ ភន្តេ ភាសិតំ ឯវំ អាជានាម ឥទំ ភវន្តោ បស្សន្តុ យាវ អនុជ្ជុកោ ចាយំ ចិត្តោ គហបតិ យាវ សឋោ ចាយំ ចិត្តោ គហបតិ យាវ មាយាវី ចាយំ ចិត្តោ គហបតីតិ ។ សចេ តេ ភន្តេ បុរិមំ សច្ចំ បច្ឆិមំ តេ មិច្ឆា ។ សចេ បន តេ ភន្តេ បច្ឆិមំ សច្ចំ បុរិមំ តេ មិច្ឆា ។ ឥមេ ខោ បន តេ ភន្តេ ទស សហធម្មិកា បញ្ហា អាគច្ឆន្តិ ។ យទា នេសំ អត្ថំ អាជានេយ្យាសិ ។ បឋមំ[១] បដិហរេយ្យាសិ សទ្ធឹ និគណ្ឋបរិសាយ

១ ឱ. ម. អថ មំ ។

ដឹងច្បាស់ពាក្យដែលលោកពោលហើយក្នុងកាលអម្បាញ់មិញនេះ យ៉ាងនេះថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលនូវគហបតីនេះចុះ ចិត្តគហបតីនេះពេញជាមនុស្សមានចិត្តត្រង់ ចិត្តគហបតីនេះ ពេញជាមនុស្សមិនអែបអប ចិត្តគហបតីនេះ ពេញជាមនុស្សមិនមានកិច្ចកល ។ បពិត្រលោកដ៏ចម្រើន ឥឡូវនេះយើងបានដឹងច្បាស់ពាក្យដែលលោកម្ចាស់ពោលហើយយ៉ាងនេះវិញថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលនូវគហបតីនេះចុះ ចិត្តគហបតីនេះ ពេញជាមនុស្សមានចិត្តមិនត្រង់ ចិត្តគហបតីនេះ ពេញជាមនុស្សអែបអប ចិត្តគហបតីនេះ ពេញជាមនុស្សមានកិច្ចកល ។ បពិត្រលោកដ៏ចម្រើន បើពាក្យមុនរបស់លោកជាពាក្យពិត ពាក្យក្រោយរបស់លោកជាពាក្យខុសវិញ ។ បពិត្រលោកដ៏ចម្រើន បើពាក្យក្រោយរបស់លោកជាពាក្យពិត ពាក្យមុនរបស់លោកជាពាក្យខុសវិញ ។ បពិត្រលោកដ៏ចម្រើន ប្រស្នាទាំង ១០ ប្រកបដោយធម៌នេះឯងនឹងមកដល់លោក ។ កាលណាបើលោកអាចដឹងនូវសេចក្តីនៃប្រស្នាទាំងនោះ ។ លោកគប្បីត្រាស់ដឹងនូវប្រស្នាជាដំបូងជាមួយនឹងនិគ្រន្ថជាបរិសទ្យ

២១៨

ចិត្តគហបតិបុច្ឆាសំយុត្តំ

ឯកោ បញ្ហោ ឯកោ ឧទ្ទេសោ ឯកំ វេយ្យាករណំ ទ្វេ បញ្ហា ទ្វេ ឧទ្ទេសា ទ្វេ វេយ្យាករណានិ តយោ បញ្ហា តយោ ឧទ្ទេសា តីណិ វេយ្យាករណានិ ចត្តារោ បញ្ហា ចត្តារោ ឧទ្ទេសា ចត្តារិ វេយ្យាករណានិ បញ្ច បញ្ហា បញ្ច ឧទ្ទេសា បញ្ច វេយ្យាករណានិ ឆ បញ្ហា ឆ ឧទ្ទេសា ឆ វេយ្យាករណានិ សត្ត បញ្ហា សត្ត ឧទ្ទេសា សត្ត វេយ្យាករណានិ អដ្ឋ បញ្ហា អដ្ឋ ឧទ្ទេសា អដ្ឋ វេយ្យាករណានិ នវ បញ្ហា នវ ឧទ្ទេសា នវ វេយ្យាករណានិ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យាករណានីតិ ។ អថខោ ចិត្តោ គហបតិ និគណ្ឋំ នាដបុត្តំ ឥមេ ទស សហធម្មិកេ បញ្ហេ អាបុច្ឆិត្វា ឧដ្ឋាយាសនា បក្កាមីតិ ។ អដ្ឋមំ ។

[២២២] តេន ខោ បន សមយេន អចេលោ កស្សបោ មច្ឆិកាសណ្ឌំ អនុប្បត្តោ ហោតិ ចិត្តស្ស គហបតិនោ បុរាណគិហិសហាយោ ។ អស្សោសិ ខោ ចិត្តោ គហបតិ អចេលោ កិរ កស្សបោ មច្ឆិកាសណ្ឌំ អនុប្បត្តោ អម្ហាកំ បុរាណគិហិសហាយោតិ ។ អថខោ

ចិត្តគហបតិបុច្ឆាសំយុត្ត

ប្រស្នា ១[១] ឧទ្ទេស ១[២] វេយ្យាករណ៍ ១[៣] ប្រស្នា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ប្រស្នា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ប្រស្នា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ប្រស្នា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ប្រស្នា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ប្រស្នា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ ប្រស្នា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ប្រស្នា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ប្រស្នា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ។ លំដាប់នោះ ចិត្តគហបតីសួរប្រស្នាទាំង ១០ ដែលប្រកបដោយធម៌នោះ ចំពោះនិគ្គណ្ឋនាដបុត្តរួចហើយ ក៏ក្រោកចាកអាសនៈចេញទៅ ។ ចប់សូត្រទី ៨ ។

[២២២] សម័យនោះឯង អចេលកស្សបជាសំឡាញ់ កាលនៅជាគ្រហស្ថពីដើម របស់ចិត្តគហបតីបានមកដល់ដង់ព្រៃមច្ឆិកា ។ ចិត្តគហបតីបានឮដំណឹងថា អចេលកស្សបជាសំឡាញ់កាលនៅជាគ្រហស្ថពីដើមរបស់យើង បានមកដល់ដង់ព្រៃមច្ឆិកាហើយ ។ លំដាប់នោះ

---

១ ផ្លូវរបស់ប្រស្នាតែ ១ គឺការស្វែងរកប្រស្នាតែ ១ ។ ២ ការសួរនូវប្រស្នាតែ ១ ដូចពាក្យសួរជា អ្វីដែលមានតែ ១ ឬសួរថា ១ មិនដែលមាន ២ គឺអ្វី ។ ៣ ការដោះស្រាយនូវប្រស្នាតែ ១ ដូចពាក្យថា សត្វទាំងពួងរស់នៅដោយអាហារ ។

ចិត្តោ គហបតិ យេន អចេលោ កស្សបោ តេនុប-
សង្កមិ ឧបសង្កមិត្វា អចេលេន កស្សបេន សទ្ធឹ
សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា
ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចិត្តោ
គហបតិ អចេលំ កស្សបំ ឯតទវោច កីវចិរំ បព្វ-
ជិតោសិ ភន្តេ កស្សបាតិ ។ តឹសមត្តានិ ខោ មេ
គហបតិ វស្សានិ បព្វជិតស្សាតិ ។ ឥមេហិ បន តេ
ភន្តេ តឹសមត្តេហិ វស្សេហិ អត្ថិ កោចិ ឧត្តរិម-
នុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគ-
តោ ផាសុវិហារោតិ ។ ឥមេហិ ខោ មេ គហបតិ
តឹសមត្តេហិ វស្សេហិ នត្ថិ កោចិ ឧត្តរិមនុស្សធម្មា
អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ ផាសុវិ-
ហារោ អញ្ញត្រ នគ្គេយ្យា ច មុណ្ឌេយ្យា ច ភាឝ្ប-
និប្បោតនាយ[១] ចាតិ ។

១ ឱ. ម. បាវាឡនិប្ផោដនាយ ចាតិ ។

ចិត្តគហបតីក៏ចូលទៅរកអចេលកស្សប លុះចូលទៅដល់ហើយ ក៏ធ្វើនូវសេចក្ដីរីករាយជាមួយនឹងអចេលកស្សប លុះបញ្ចប់ពាក្យដែលគួររីករាយគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះចិត្តគហបតីអង្គុយក្នុងទីដ៏សមគួរហើយ ក៏សួរទៅអចេលកស្សបដូច្នេះថា បពិត្រកស្សបដ៏ចម្រើន លោកបួសអស់កាលយូរប៉ុន្មានហើយ ។ ម្នាលគហបតី យើងបួសបាន ៣០ វស្សាហើយ ។ បពិត្រលោកដ៏ចម្រើន ចុះឧត្តរិមនុស្សធម៌នីមួយ ដ៏វិសេសដោយញាណទស្សនៈ អាចធ្វើនូវភាពជាព្រះអរិយៈជាគ្រឿងនៅសប្បាយ លោកបានត្រាស់ដឹងហើយ ដោយអំណាចវស្សាទាំង ៣០ នេះដែរឬ ។ ម្នាលគហបតី វៀរលែងតែការអាក្រាតនិងកោរត្រងោល និងបោសធូលីដោយអម្បោសកន្ទុកក្ងោកចេញ ឧត្តរិមនុស្សធម៌នីមួយ ដ៏វិសេសដោយញាណទស្សនៈ អាចធ្វើនូវភាពជាព្រះអរិយៈជាគ្រឿងនៅសប្បាយ យើងមិនបានត្រាស់ដឹង ដោយអំណាចវស្សាទាំង ៣០ នេះឡើយ ។

## ២១៧

### ចិត្តគហបតិបុច្ឆាសំយុត្តំ

[២២៣] ឯវំ វុត្តេ ចិត្តោ គហបតិ អចេលំ កស្សបំ ឯតទវោច អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ធម្មស្ស ស្វាក្ខាតតា យត្រ ហិ នាម តឹសមត្តេហិ វស្សេហិ ន កោចិ ឧត្តរិមនុស្សធម្មោ អលមរិយញ្ញាណទស្សនវិសេ- សោ អធិគតោ ភវិស្សតិ ផាសុវិហារោ អញ្ញត្រ នគ្គេ- យ្យា ច មុណ្ឌេយ្យា ច វាឡនិប្បោឋនាយ ចាតិ ។ តុយ្ហ- ម្បន គហបតិ កីវចិរំ ឧបាសកត្តំ ឧបគតស្សាតិ ។ មយ្ហម្បិ ខោ បន ភន្តេ តឹសមត្តានិ វស្សានិ ឧបា- សកត្តំ ឧបគតស្សាតិ ។ ឥមេហិ បន តេ គហបតិ តឹសមត្តេហិ វស្សេហិ អត្ថិ កោចិ ឧត្តរិមនុស្សធម្មោ អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ ផាសុវិ- ហារោតិ ។ កិហិនោបិ សិយា ភន្តេ អហំ ហិ ភន្តេ

## ចិត្តគហបតិបុច្ឆាសំយុត្ត

[២២៣] កាលបើអចេលកស្សប ពោលយ៉ាងនេះ ចិត្តគហបតីក៏ពោលទៅនឹងអចេលកស្សបដូច្នេះថា អើហ្ន៎ អស្ចារ្យណាស់ អើហ្ន៎ ចំឡែកពេកណាស់ ដោយសភាពនៃធម៌ដែលលោកពោលដោយប្រពៃថា វៀរលែងតែការអាក្រាតនិងកោរត្រងោល និងការបោសធូលីដោយអម្បោសកន្ទុយក្ងោកចេញ ឧត្តរិមនុស្សធម៌នីមួយដ៏វិសេសដោយញាណ-ទស្សនៈ អាចធ្វើនូវភាពជាព្រះអរិយៈជាគ្រឿងនៅសប្បាយ យើងមិនបានត្រាស់ដឹងដោយអំណាចវស្សាទាំង ៣០ នេះឡើយ ។ ម្នាលគហបតី ចុះអ្នកបានចូលមកជាឧបាសកអស់កាលយូរប៉ុន្មានហើយ ។ បពិត្រលោកដ៏ចម្រើន យើងបានចូលមកជាឧបាសក ៣០ ឆ្នាំមកហើយ ។ ម្នាលគហបតី ចុះឧត្តរិមនុស្សធម៌នីមួយដ៏វិសេសដោយញាណទស្សនៈ អាចធ្វើនូវភាពជាព្រះអរិយៈជាគ្រឿងនៅសប្បាយ អ្នកបានត្រាស់ដឹងហើយដោយអំណាចឆ្នាំទាំង ៣០ នេះដែរឬ ។ បពិត្រលោកដ៏ចម្រើន ឧត្តរិ-មនុស្សធម៌គង់មានដល់គ្រហស្ថខ្លះដែរ បពិត្រលោកដ៏ចម្រើន ព្រោះថាខ្ញុំ

យាវទេវ អាកង្ខាមិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ អហំ ហិ ភន្តេ យាវទេវ អាកង្ខាមិ វិតក្កវិចារានំ វូបសមា ទុតិយជ្ឈានំ ឧប-សម្បជ្ជ វិហរាមិ ។ អហំ ហិ ភន្តេ យាវទេវ អាកង្ខាមិ បីតិយា ច វិរាគា ។ បេ ។ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ អហញ្ហិ ភន្តេ យាវទេវ អាកង្ខាមិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ សចេ ខោ បនាហំ ភន្តេ ភគវតា បឋមតរំ ព្យាក-រេយ្យំ[១] ។ អនច្ឆរិយំ ខោ បនេតំ យំ មំ ភគវា[២] ឯវំ[៣] ព្យាករេយ្យ នត្ថិ តំ សញ្ញោជនំ យេន សញ្ញោ-ជនេន សំយុត្តោ ចិត្តោ គហបតិ បុន ឥមំ លោកំ អាគច្ឆេយ្យាតិ ។

១ ឱ. ម. ភគវតោ បឋមតរំ កាលំ កវេយ្យ ។ ២ ភគវតា ។ ៣ ឯតំ ។

ប្រាថ្នាស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខកើតអំពីសេចក្ដីស្ងាត់ ប្រព្រឹត្តនៅគ្រប់ឥរិយាបថកំណត់ត្រឹមណា ។ បពិត្រលោកដ៏ចម្រើន ខ្ញុំប្រាថ្នារម្ងាប់នូវវិតក្កៈនិងវិចារៈ បានដល់នូវទុតិយជ្ឈាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថកំណត់ត្រឹមណា ។ បពិត្រលោកដ៏ចម្រើន ខ្ញុំប្រាថ្នានឿយណាយចាកបីតិ ។ បេ ។ បានដល់នូវតតិយជ្ឈាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថកំណត់ត្រឹមណា ។ បពិត្រលោកដ៏ចម្រើន ខ្ញុំប្រាថ្នាលះបង់សុខ ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថកំណត់ត្រឹមណា ។ បពិត្រលោកដ៏ចម្រើន ប្រសិនបើខ្ញុំព្យាករមុនព្រះដ៏មានព្រះភាគ ។ ព្រះមានព្រះភាគព្យាករនូវខ្ញុំយ៉ាងនេះថា ចិត្តគហបតីប្រកបដោយសញ្ញោជនៈឯណា ហើយគប្បីមកកាន់លោកនេះវិញ សញ្ញោជនៈនោះមិនមានឡើយដូច្នេះ ដោយហេតុឯណា ហេតុនោះមិនជាអស្ចារ្យឡើយ ។

## ចិត្តគហបតិបុច្ឆាសំយុត្តំ

[២២៤] ឯវំ វុត្តេ អចេលោ កស្សបោ ចិត្តំ គហបតឹ ឯតទវោច អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ធម្មស្ស ស្វាក្ខាតតា យត្រ ហិ នាម គិហី ឱទាតវសនោ ឯវរូបំ ឧត្តរិមនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ អធិគមិស្សតិ ផាសុវិហារំ លភេយ្យាហំ គហបតិ ឥមស្មឹ ធម្មវិនយេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អថខោ ចិត្តោ គហបតិ អចេលំ កស្សបំ អាទាយ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេ ភិក្ខូ ឯតទវោច អយំ ភន្តេ អចេលោ កស្សបោ អម្ហាកំ បុរាណគិហិសហាយោ ឥមំ ថេរា បព្វាជេន្តុ ឧបសម្បាទេន្តុ

ចិត្តគហបតិបុច្ឆាសំយុត្ត

[២២៤] កាលបើចិត្តគហបតីពោលយ៉ាងនេះ អចេលកស្សប ក៏ពោលទៅនឹងចិត្តគហបតីដូច្នេះថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចំឡែកពេកណាស់ ដោយសភាពនៃធម៌ដែលគហបតីពោលដោយប្រពៃ ព្រោះថាគ្រហស្ថស្លៀកស ក៏គង់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ដ៏វិ-សេសដោយញាណទស្សនៈ អាចធ្វើនូវភាពជាព្រះអរិយៈជាគ្រឿងនៅសប្បាយ មានសភាពដូច្នេះដែរ ម្នាលគហបតី យើងគប្បីបាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងធម៌វិន័យនេះ ។ លំដាប់នោះ ចិត្តគហបតីនាំយក អចេលកស្សប ចូលទៅរកពួកភិក្ខុជាថេរៈ លុះចូលទៅដល់ហើយ ក៏ពោលទៅនឹងពួកភិក្ខុជាថេរៈដូច្នេះថា បពិត្រព្រះករុណាដ៏ចម្រើន អចេ-លកស្សបនេះ ជាសំឡាញ់កាលនៅជាគ្រហស្ថពីដើមរបស់យើង សូមព្រះថេរៈទាំងឡាយ ឲ្យអចេលកស្សបនេះ បានបព្វជ្ជាបានឧបសម្បទាផង

អហមស្ស ឧស្សុក្កំ ករិស្សាមិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ អលត្ថ អចេលោ កស្សបោ ឥមស្មឹ ធម្មវិនយេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ច បនាយស្មា កស្សបោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា កស្សបោ អរហតំ អហោសីតិ ។

នវមំ ។

ខ្ញុំព្រះករុណានឹងធ្វើនូវសេចក្តីខ្វល់ខ្វាយ ដោយចីវរបិណ្ឌបាតសេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដល់អចេលកស្សបនេះ ។ អចេលកស្សប ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងធម៌វិន័យនេះ ។ ព្រះកស្សប មានអាយុ លុះបានឧបសម្បទាហើយ មិនយូរប៉ុន្មានក៏ចៀសចេញទៅ តែម្នាក់ឯង មិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្តទាំងឡាយចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ឯណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះជាទីបំផុតនៃព្រហ្មចរិយ ហើយបានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយអាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គ-ភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្តមួយដែរ ។ ចប់សូត្រទី ៩ ។

២២១

ចិត្តគហបតិបុច្ឆាសំយុត្តំ

[២២៨] តេន ខោ បន សមយេន ចិត្តោ គហបតិ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថ-ខោ សម្ពហុលា អារាមទេវតា វនទេវតា រុក្ខទេវតា ឱសធិតិណវនប្បតីសុ អធិវត្ថា ទេវតា សង្គម្ម សមា-គម្ម ចិត្តំ គហបតឹ ឯតទវោចុំ បណិធេហិ គហបតិ អនាគតមទ្ធានំ រាជា អស្សំ ចក្កវត្តីតិ ។ ឯវំ វុត្តេ ចិត្តោ គហបតិ[១] អារាមទេវតា វនទេវតា រុក្ខទេវតា ឱសធិតិណវនប្បតីសុ អធិវត្ថា ទេវតា ឯតទវោច តម្បិ អនិច្ចំ តម្បិ អទ្ធុវំ តម្បិ បហាយ គមនីយន្តិ ។

១ ឱ. ម. ឯត្ថន្តរេ តា ឥតិ បទំ អត្ថិ ។

## ចិត្តគហបតិបុច្ឆាសំយុត្ត

[២២៩] សម័យនោះឯង ចិត្តគហបតីមានអាពាធ ដល់នូវសេចក្តីទុក្ខឈឺធ្ងន់ ។ គ្រានោះ ពួកទេវតាច្រើនគឺអារាមទេវតា[១] វនទេវតា[២] រុក្ខទេវតា[៣] និងពួកទេវតាដែលនៅអាស្រ័យឰដ៏ស្មៅនិងដើមឈើសម្រាប់ធ្វើថ្នាំ មកសមាគមប្រជុំគ្នាហើយ ក៏ពោលទៅនឹងចិត្តគហបតីដូច្នេះថា ម្នាលគហបតី អ្នកចូរតាំងសេចក្តីប្រាថ្នាថា អាត្មាអញគប្បីបានជាស្តេចចក្រពត្តិក្នុងកាលជាអនាគតចុះ ។ កាលបើពួកទេវតាពោលយ៉ាងនេះ ចិត្តគហបតីក៏ពោលតបទៅនឹងពួកអារាមទេវតា វនទេវតា រុក្ខទេវតា និងពួកទេវតាដែលនៅអាស្រ័យឰដ៏ស្មៅនិងដើមឈើសម្រាប់ធ្វើថ្នាំ (ទាំងនោះ) ដូច្នេះថា របស់នោះមិនទៀងទេ របស់នោះមិនឋិតថេរទេ បុគ្គលត្រូវតែលះបង់របស់នោះទៅ (កាន់បរលោក) ។

---

១ ទេវតាដែលអាស្រ័យនៅឰដ៏សួនឈើមានផ្កា សួនឈើមានផ្លែ ។ ២ ទេវតាដែលអាស្រ័យនៅឰដ៏ដងព្រៃ ។ ៣ ទេវតាដែលអាស្រ័យឰដ៏ដើមឈើធំ ។

[២២៦] ឯវំ វុត្តេ ចិត្តស្ស គហបតិនោ មិត្តាមច្ចា ញាតិសាលោហិតា ចិត្តំ គហបតឹ ឯតទវោចុំ សតឹ អយ្យបុត្ត ឧបដ្ឋបេហិ មា វិប្បលបសីតិ ។ កិន្តា-ហំ[១] វទាមិ យំ មំ តុម្ហេ ឯវំ វទេថ សតឹ អយ្យបុត្ត ឧបដ្ឋបេហិ មា វិប្បលបសីតិ ។ ឯវំ ខោ ត្វំ អយ្យបុត្ត វទេសិ តម្បិ អនិច្ចំ តម្បិ អទ្ធុវំ តម្បិ បហា-យ គមនីយន្តិ ។ តថា ហិ បន មំ អារាមទេវតា វនទេវតា រុក្ខទេវតា ឱសធិតិណវនប្បតីសុ អធិវត្ថា ទេវតា ឯវមាហំសុ បណិធេហិ គហបតិ អនាគត-មទ្ធានំ រាជា អស្សំ ចក្កវត្តីតិ ។ តាហំ ឯវំ វទាមិ តម្បិ អនិច្ចំ តម្បិ អទ្ធុវំ តម្បិ បហាយ គមនីយន្តិ ។

---

១ កិន្នាហំ ។

[២២៦] កាលបើចិត្តគហបតីពោលយ៉ាងនេះ ពួកមិត្តអមាត្យ និងញាតិសាលោហិតរបស់ចិត្តគហបតី ក៏ពោលទៅនឹងចិត្តគហបតីដូច្នេះថា នែអយ្យបុត្ត អ្នកចូរប្រុងស្មារតី កុំរវើរវាយឡើយ ។ ចិត្តគហបតីពោលថា ចុះខ្ញុំពោលដូចម្តេច បានជាអ្នកទាំងឡាយពោលមកនឹងខ្ញុំយ៉ាងនេះថា នែអយ្យបុត្ត អ្នកចូរប្រុងស្មារតី កុំរវើរវាយឡើយ ។ នែអយ្យបុត្ត អ្នកពោលយ៉ាងនេះថា របស់នោះមិនទៀងទេ របស់នោះមិនឋិតថេរទេ បុគ្គលត្រូវតែលះបង់របស់នោះទៅ (កាន់បរលោក) ។ ដូច្នោះមែនហើយ ព្រោះពួកអារាមទេវតា វនទេវតា រុក្ខទេវតា និងពួកទេវតាដែលនៅអាស្រ័យឰដ៏ស្មៅនិងដើមឈើសម្រាប់ធ្វើថ្នាំ ពោលប្រាប់ខ្ញុំយ៉ាងនេះថា ម្នាលគហបតី អ្នកចូរតាំងសេចក្តីប្រាថ្នាថា អាត្មាអញគប្បីបានជាស្តេចចក្រពត្តិ ក្នុងកាលជាអនាគតចុះ ។ ខ្ញុំក៏ពោលតបទៅនឹងពួកទេវតាទាំងនោះយ៉ាងនេះថា របស់នោះមិនទៀងទេ របស់នោះមិនឋិតថេរទេ បុគ្គលត្រូវតែលះបង់របស់នោះទៅ (កាន់បរលោក) ។

២២៣



កិម្បន[១] តា អយ្យបុត្ត អារាមទេវតា វនទេវតា រុក្ខទេវតា ឱសធិតិណវនប្បតីសុ អធិវត្ថា ទេវតា អត្ថវសំ សម្បស្សមានា ឯវមាហំសុ បណិធេហិ គហបតិ អនាគតមទ្ធានំ រាជា អស្សំ ចក្កវត្តីតិ ។ តាសំ ខោ អារាមទេវតានំ វនទេវតានំ រុក្ខទេវតានំ ឱសធិតិណវនប្បតីសុ អធិវត្ថានំ ទេវតានំ ឯវំ ហោតិ អយំ ខោ ចិត្តោ គហបតិ សីលវា កល្យាណធម្មោ សចេ បណិធេហិស្សតិ អនាគតមទ្ធានំ រាជា អស្សំ ចក្កវត្តីតិ ។ តស្ស ខោ អយំ ឥជ្ឈិស្សតិ សីលវតោ ចេតោបណិធិ សីលស្ស វិសុទ្ធត្តា ធម្មិកោ[២] ធម្មិកំ ផលំ អនុប្បទស្សតីតិ ។ ឥមំ ខោ តា អារាមទេវតា វនទេវតា រុក្ខទេវតា ឱសធិតិណវនប្បតីសុ អធិវត្ថា ទេវតា អត្ថវសំ សម្បស្សមានា ឯវមាហំសុ បណិធេហិ គហបតិ

១ ម. កិន្តេ ។ ២ អដ្ឋកថាយំ ឯត្ថន្តរេ ធម្មរាជាតិ បទំ អត្ថិ ។

នៃអយ្យបុត្ត ចុះពួកអារាមទេវតា វនទេវតា រុក្ខទេវតា និងពួកទេវតា ដែលអាស្រ័យនៅឰដ៏ស្មៅនិងដើមឈើសម្រាប់ធ្វើថ្នាំទាំងនោះ ឃើញនូវអំណាចប្រយោជន៍ដូចម្តេច បានជាពោលយ៉ាងនេះថា ម្នាលគហបតី អ្នកចូរតាំងសេចក្តីប្រាថ្នាថា អាត្មាអញគប្បីបានជាស្តេចចក្រពត្តិ ក្នុងកាលជាអនាគតចុះដូច្នេះ ។ ពួកអារាមទេវតា វនទេវតា រុក្ខទេវតា និងពួកទេវតា ដែលអាស្រ័យនៅឰដ៏ស្មៅនិងដើមឈើ សម្រាប់ធ្វើថ្នាំទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ចិត្តគហបតីនេះ មានសីល មានធម៌ល្អ បើគាត់នឹងតាំងសេចក្តីប្រាថ្នាថា អាត្មាអញគប្បីបានជាស្តេចចក្រពត្តិ ក្នុងកាលជាអនាគត (ក៏បាន) ។ ឯសេចក្តីប្រាថ្នាក្នុងចិត្តនេះ របស់ចិត្ត-គហបតីដែលមានសីលនោះ នឹងសម្រេចព្រោះសីលបរិសុទ្ធ បុគ្គលប្រ-កបដោយធម៌នឹងថែមឲ្យនូវកម្លាំងដ៏ប្រកបដោយធម៌ ។ ពួកអារាមទេវតា វនទេវតា រុក្ខទេវតា និងពួកទេវតាដែលអាស្រ័យនៅឰដ៏ស្មៅនិងដើមឈើសម្រាប់ធ្វើថ្នាំទាំងនោះ ឃើញនូវអំណាចប្រយោជន៍នេះឯង បានជាពោលយ៉ាងនេះថា ម្នាលគហបតី អ្នកចូរតាំងសេចក្តីប្រាថ្នាថា

អនាគតមទ្ធានំ រាជា អស្សំ ចក្កវត្តីតិ ។ តាហំ ឯវំ វទាមិ តម្បិ អនិច្ចំ តម្បិ អទ្ធុវំ តម្បិ បហាយ គមនីយន្តិ ។ តេនហិ អយ្យបុត្ត អម្ហេបិ ឱវទាហីតិ ។

[២២៧] តស្មា ហិ វោ ឯវំ សិក្ខិតព្វំ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតា ភវិស្សាម ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគតា ភវិស្សាម ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ

អាត្មាអញគប្បីបានជាស្តេចចក្រពត្តិ ក្នុងកាលជាអនាគតចុះ ។ ខ្ញុំក៏ពោលតបទៅនឹងទេវតាទាំងនោះយ៉ាងនេះថា របស់នោះមិនទៀងទេ របស់នោះមិនឋិតថេរទេ បុគ្គលត្រូវតែលះបង់របស់នោះទៅ (កាន់បរលោក) ។ នៃអយ្យបុត្ត បើដូច្នោះ ចូរអ្នកទូន្មានយើងទាំងឡាយផង ។

[២២៧] ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អស្តេចទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់ខ្ជាក់ចោលនូវត្រៃភព ។ យើងទាំងឡាយនឹងប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយដោយប្រពៃ ព្រះ (នព្វលោកុត្តរធម៌) ជាធម៌ដែលព្រះអរិយបុគ្គលឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ដែលព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតា ភវិស្សាម សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ ចាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ យំ ខោ បន កិញ្ចិ កុលេ ទេយ្យធម្មំ សព្វន្តំ អប្បដិវិភត្តំ ភវិស្សតិ សីលវន្តេហិ កល្យាណធម្មេហីតិ ។ ឯវំ ហិ វោ សិក្ខិតព្វន្តិ ។

ចិត្តគហបតិបុច្ឆាសំយុត្ត

ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ។ យើងទាំងឡាយនឹងប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើក្នុងព្រះសង្ឃថា ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិត្រង់ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិដើម្បីព្រះនិព្វាន ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិដ៏សមគួរ ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសមាន ៤ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃនុ៎ះជាសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយនាំមកបូជា គួរដល់អញ្ជលិកម្ម ជាស្រែបុណ្យនៃសត្វលោករកស្រែដទៃក្រៃលែងជាងគ្មាន ។ មួយទៀត ទេយ្យធម៌ឯណាបន្តិចបន្តួចក្នុងត្រកូល ទេយ្យធម៌ទាំងអស់នោះ បុគ្គលអ្នកមានសីល មានធម៌ល្អមិនមានចែកមុខឡើយ ។ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

២២៦

សុត្តន្តបិដកេ សំយុត្តនិកាយស្ស សឡាយតនវគ្គោ

អថខោ ចិត្តោ គហបតិ មិត្តាមច្ចេ ញាតិសាលោហិតេ ពុទ្ធេ ច ធម្មេ ច សង្ឃេ ច ចាគេ ច សមាទបេត្វា កាលមកាសីតិ ។

ចិត្តគហបតិបុច្ឆាសំយុត្តំ សមត្តំ ។

## តស្សុទ្ទានំ

សញ្ញោជនា ទ្វេ ឥសិទត្តា
មហកោ កាមភូ បិ ច
គោទត្តោ ច និគណ្ឋោ ច
អចេលេន គិលានន្តិ ។

លំដាប់នោះ ចិត្តគហបតី លុះញុំាងមិត្តអមាត្យនិងញាតិសាលោហិតឲ្យទទួលប្រតិបត្តិក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងការបរិច្ចាគរួចហើយ ក៏ធ្វើមរណកាលទៅ ។

ចប់ ចិត្តគហបតិបុច្ឆាសំយុត្ត ។

# ឧទ្ទាននៃចិត្តគហបតិបុច្ឆាសំយុត្តនោះគឺ

និយាយអំពីសញ្ញោជនៈ ១ ព្រះឥសិទត្ត ២ លើក ព្រះមហកៈ ១ ព្រះកាមភូ ១ ព្រះគោទត្ត ១ និគ្គណ្ឋនាដបុត្ត ១ អចេលកស្សប ១ ចិត្តគហបតីឈឺ ១ ។

# គាមណិសំយុត្តំ

[២២៨] អថខោ ចណ្ឌោ គាមណី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចណ្ឌោ គាមណី ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ ចណ្ឌោ ចណ្ឌោតេវ[១] សង្ខំ គច្ឆតិ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន មិធេ-កច្ចោ សោរតោ សោរតោតេវ[២] សង្ខំ គច្ឆតីតិ ។ ឥធ គាមណិ ឯកច្ចស្ស រាគោ អប្បហីនោ ហោតិ រាគស្ស អប្បហីនត្តា បរេ កោបេន្តិ បរេហិ កោបិយមានោ កោបំ បាតុករោតិ សោ ចណ្ឌោតេវ សង្ខំ គច្ឆតិ ។ ទោ-សោ អប្បហីនោ ហោតិ ទោសស្ស អប្បហីនត្តា បរេ កោបេន្តិ បរេហិ កោបិយមានោ កោបំ បាតុករោតិ

---

១ ម. ចណ្ឌោត្វេវ ។ ២ ឱ. សោរតោតេវ ។

# គាមណិសំយុត្ត

[២២៨] គ្រានោះ គាមណី[១] ឈ្មោះចណ្ឌ[២] ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះចណ្ឌគាមណីអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យគេរាប់បុគ្គលពួកមួយក្នុងលោកនេះថា ជាអ្នកកាច អ្នកកាច បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យគេរាប់បុគ្គលពួកមួយក្នុងលោកនេះថា ជាអ្នកស្លូត អ្នកស្លូត ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលគាមណី បុគ្គលពួកមួយក្នុងលោកនេះ មិនទាន់លះបង់រាគៈ ព្រោះតែមិនទាន់លះបង់រាគៈ បានជាពួកជនដទៃរមែងធ្វើបុគ្គលនោះឲ្យក្រោធបាន កាលបើពួកជនដទៃធ្វើឲ្យក្រោធហើយ ក៏រមែងធ្វើសេចក្តីក្រោធឲ្យប្រាកដឡើង បុគ្គលនោះទើបរាប់ថាជាអ្នកកាច ។ បុគ្គលដែលមិនទាន់លះបង់ទោសៈ ព្រោះតែមិនទាន់លះបង់ទោសៈ បានជាពួកជនដទៃ រមែងធ្វើឲ្យក្រោធបាន កាលបើពួកជនដទៃធ្វើឲ្យក្រោធហើយ ក៏រមែងធ្វើសេចក្តីក្រោធឲ្យប្រាកដឡើង

១ អ្នកធំក្នុងស្រុក ។ ២ ជាមនុស្សកាច ។

សោ ចណ្ឌោតេវ សង្ខំ គច្ឆតិ ។ មោហោ អប្បហីនោ ហោតិ មោហស្ស អប្បហីនត្តា បរេ កោបេន្តិ បរេហិ កោបិយមានោ កោបំ ចាតុករោតិ សោ ចណ្ឌោតេវ សង្ខំ គច្ឆតិ ។ អយំ ខោ គាមណិ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ ចណ្ឌោ ចណ្ឌោតេវ សង្ខំ គច្ឆតិ ។

[២២៩] ឥធ បន គាមណិ ឯកច្ចស្ស រាគោ បហីនោ ហោតិ រាគស្ស បហីនត្តា បរេ ន កោបេន្តិ បរេហិ កោបិយមានោ[១] កោបំ ន ចាតុករោតិ សោ សោរតោតេវ សង្ខំ គច្ឆតិ ។ ទោសោ បហីនោ ហោតិ ទោសស្ស បហីនត្តា បរេ ន កោបេន្តិ បរេហិ កោបិយ-មានោ កោបំ ន ចាតុករោតិ សោ សោរតោតេវ សង្ខំ គច្ឆតិ ។ មោហោ បហីនោ ហោតិ មោហស្ស បហី-នត្តា បរេ ន កោបេន្តិ បរេហិ កោបិយមានោ កោបំ ន ចាតុករោតិ សោ សោរតោតេវ សង្ខំ គច្ឆតិ អយំ ខោ គាមណិ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ សោរតោ សោរតោតេវ សង្ខំ គច្ឆតីតិ ។

---

១ ឱ. អកោបិយមានោ ។

បុគ្គលនោះទើបរាប់ថាជាអ្នកកាច ។ បុគ្គលដែលមិនទាន់លះបង់មោហៈ ព្រោះតែមិនទាន់លះបង់មោហៈ បានជាពួកជនដទៃ រមែងធ្វើឲ្យក្រោធបាន កាលបើពួកជនដទៃធ្វើឲ្យក្រោធហើយ ក៏រមែងធ្វើសេចក្តីក្រោធឲ្យប្រាកដឡើង បុគ្គលនោះទើបរាប់ថាជាអ្នកកាច ។ ម្នាលគាមណិ ហេតុនេះឯង បច្ច័យនេះឯង ដែលនាំឲ្យរាប់បុគ្គលពួកមួយក្នុងលោកនេះ ថាជាអ្នកកាច អ្នកកាច ។

[២២៩] ម្នាលគាមណិ បុគ្គលពួកមួយទៀតក្នុងលោកនេះ ជាអ្នកលះបង់រាគៈហើយ ព្រោះតែលះបង់រាគៈ បានជាពួកជនដទៃធ្វើឲ្យក្រោធមិនបាន ទោះបីពួកជនដទៃធ្វើឲ្យក្រោធ ក៏មិនធ្វើសេចក្តីក្រោធឲ្យប្រាកដ បុគ្គលនោះទើបរាប់ថាជាអ្នកស្លូត ។ បុគ្គលដែលបានលះបង់ទោសៈ ព្រោះតែលះបង់ទោសៈ បានជាពួកជនដទៃធ្វើឲ្យក្រោធមិនបាន ទោះបីពួកជនដទៃធ្វើឲ្យក្រោធ ក៏មិនធ្វើសេចក្តីក្រោធឲ្យប្រាកដ បុគ្គលនោះទើបរាប់ថាជាអ្នកស្លូត ។ បុគ្គលដែលបានលះបង់មោហៈ ព្រោះតែលះបង់មោហៈ បានជាពួកជនដទៃធ្វើឲ្យក្រោធមិនបាន ទោះបីពួកជនដទៃធ្វើឲ្យក្រោធ ក៏មិនធ្វើសេចក្តីក្រោធឲ្យប្រាកដ បុគ្គលនោះទើបរាប់ថាជាអ្នកស្លូត ម្នាលគាមណិ ហេតុនេះឯង បច្ច័យនេះឯង ដែលនាំឲ្យគេរាប់បុគ្គលពួកមួយក្នុងលោកនេះថាជាអ្នកស្លូត អ្នកស្លូត ។

២២៩

គាមណិសំយុត្តំ

[២៣០] ឯវំ វុត្តេ ចណ្ឌោ គាមណី ភគវន្តំ ឯតទ-
វោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ
និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស
វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធា-
រេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ។ ឯវមេវ ភគវតា
អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ
ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ
មំ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គ-
តន្តិ ។ បឋមំ ។

[២៣១] ឯកំ សមយំ ភគវា រាជគហេ វិហរតិ
វេឡុវនេ កលន្ទកនិវាបេ ។ អថខោ តាលបុត្តោ[១] នដ-
គាមណី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. ម. តលបុដោ ។

គាមណិសំយុត្ត

[២៣០] *កាលបើព្រះមានព្រះភាគ ទ្រង់សំដែងយ៉ាងនេះហើយ ចណ្ឌគាមណីក៏ពោលសរសើរព្រះមានព្រះភាគដូច្នេះថា ច្បាស់ណាស់ព្រះអង្គ ច្បាស់ណាស់ ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ដូចគេផ្ងាររបស់ដែលផ្កាប់ ឬបើករបស់ដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់អ្នកវង្វេងពុំនោះដូចគេទ្រោលប្រទីបក្នុងទីងងឹត ឲ្យអ្នកមានចក្ខុមើលឃើញរូបបានយ៉ាងណាមិញ ។ ធម៌ដែលព្រះអង្គប្រកាសហើយ ដោយអនេកបរិយាយក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានបុណ្យផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭកបពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះតទៅ ។ ចប់សូត្រទី ១ ។*

[២៣១] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ នដគាមណី*[១] *ឈ្មោះតាលបុត្ត ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់*

---

១ អ្នកធំក្នុងស្រុក ជាអ្នកលេងរបាំ ។

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ តាលបុត្តោ នដគាមណី ភគវន្តំ ឯតទវោច សុតមេតំ ភន្តេ បុព្វកានំ អាចរិយបាចរិយានំ នដានំ ភាសមានានំ យោ សោ នដោ រង្គមជ្ឈេ សមជ្ជមជ្ឈេ សច្ចាលិកេន ជនំ ហាសេតិ រមេតិ សោ កាយស្ស ភេទា បរំ មរណា បហាសានំ ទេវានំ សហាព្យតំ ឧបបជ្ជតីតិ ។ ឥធ ភគវា កិមាហាតិ ។ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។

[២៣២] ទុតិយម្បិ ខោ តាលបុត្តោ នដគាមណី ភគវន្តំ ឯតទវោច សុតមេតំ ភន្តេ បុព្វកានំ អាចរិយបាចរិយានំ នដានំ ភាសមានានំ យោ សោ នដោ រង្គមជ្ឈេ សមជ្ជមជ្ឈេ សច្ចាលិកេន ជនំ ហាសេតិ រមេតិ

ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះតាលបុត្តនដគាមណីអង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យរបស់ពួកអ្នកលេងរបាំ ជាអាចារ្យប្រធានលើអាចារ្យក្នុងកាលមុននិយាយថា អ្នកលេងរបាំឯណាធ្វើអ្នកផងឲ្យស្រស់ស្រាយ ឲ្យត្រេកអរ ដោយពាក្យពិតឬពាក្យឡេះឡោះ ក្នុងកណ្តាលរឿណរង្គ ក្នុងកណ្តាលមហោស្រព អ្នកលេងរបាំនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកបហាសទេវតា ។ ក្នុងរឿងនេះ តើព្រះមានព្រះភាគត្រាស់ដូចម្តេច ។ ព្រះអង្គត្រាស់ថា ណ្ហើយគាមណី រឿងនុ៎ះលើកទុកចុះ អ្នកកុំសួររឿងនុ៎ះនឹងតថាគតឡើយ ។

[២៣២] តាលបុត្តនដគាមណី ក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈ ២ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យរបស់ពួកអ្នកលេងរបាំ ជាអាចារ្យប្រធានលើអាចារ្យក្នុងកាលមុននិយាយថា អ្នកលេងរបាំឯណាធ្វើអ្នកផងឲ្យស្រស់ស្រាយ ឲ្យត្រេកអរ ដោយពាក្យពិតឬពាក្យឡេះឡោះ ក្នុងកណ្តាលរឿណរង្គ ក្នុងកណ្តាលមហោស្រព

## គាមណិសំយុត្តំ

សោ កាយស្ស ភេទា បរំ មរណា បហាសានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភគវា កិមាហាតិ ។ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ តតិយម្បិ ខោ តាលបុត្តោ នដគាមណី ភគវន្តំ ឯតទវោច សុ-តម្មេតំ ភន្តេ បុព្វកានំ អាចរិយប្បាចរិយានំ នដានំ ភាសមានានំ យោ សោ នដោ រង្គមជ្ឈេ សមជ្ជមជ្ឈេ សច្ចាលិកេន ជនំ ហាសេតិ រមេតិ សោ កាយស្ស ភេទា បរំ មរណា បហាសានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភគវា កិមាហាតិ ។

គាមណិសំយុត្ត

អ្នកលេងរបាំនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយ នឹងពួកបហាសទេវតា ។ ក្នុងរឿងនេះ តើព្រះអង្គត្រាស់ដូចម្តេច ។ ណ្ហើយគាមណិ រឿងនុ៎ះលើកទុកចុះ អ្នកកុំសួររឿងនុ៎ះនឹងតថាគត ឡើយ ។ តាលបុត្តនដគាមណិ ក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈ ៣ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យរបស់ពួក អ្នកលេងរបាំ ជាអាចារ្យប្រធានលើអាចារ្យក្នុងកាលមុននិយាយថា អ្នក លេងរបាំឯណាធ្វើអ្នកផងឲ្យស្រស់ស្រាយ ឲ្យត្រេកអរដោយពាក្យពិត ឬពាក្យឡេះឡោះ ក្នុងកណ្តាលរឿណរង្គ ក្នុងកណ្តាលមហោស្រព អ្នក លេងរបាំនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយ នឹងពួកបហាសទេវតា ។ ក្នុងរឿងនោះ តើព្រះអង្គត្រាស់ដូចម្តេច ។

[២៣៣] អទ្ធា ខោ ត្យាហំ គាមណិ ឧាលត្តំ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ អបិច ត្យាហំ ព្យាករិស្សាមិ ។ បុព្វេ ខោ គាមណិ សត្តា អវីតរាគា រាគពន្ធនពទ្ធា តេសំ នដោ រង្គមជ្ឈេ សមជ្ជមជ្ឈេ យេ ធម្មា រជនីយា តេ ឧបសំហរតិ ភិយ្យោ សរាគាយ[១] ។ បុព្វេ ខោ គាមណិ សត្តា អវីតទោសា ទោសពន្ធនពទ្ធា តេសំ នដោ រង្គមជ្ឈេ សមជ្ជមជ្ឈេ យេ ធម្មា ទោសនីយា តេ ឧបសំហរតិ ភិយ្យោ សទោសាយ ។ បុព្វេ ខោ គាមណិ សត្តា អវីតមោហា មោហពន្ធនពទ្ធា តេសំ នដោ រង្គមជ្ឈេ សមជ្ជមជ្ឈេ យេ ធម្មា មោហនីយា តេ ឧបសំហរតិ ភិយ្យោ សមោហាយ ។ សោ អត្តនា មត្តោ បមត្តោ បមាទេ បត្វា កាយស្ស ភេទា បរំ មរណា

១ ឱ. ភិយ្យោ សោមត្តាយ ។ ម. សរាគាយាតិ បាឋោ ន ហោតិ ។

[២៣៣] ម្នាលគាមណី តថាគតមិនបានដោះស្រាយនឹងអ្នកជាប្រាកដ ព្រោះតថាគតបានឃាត់អ្នកហើយថា ណ្ហើយគាមណី រឿងនុ៎ះលើកទុកចុះ អ្នកកុំសួររឿងនុ៎ះនឹងតថាគតឡើយ ។ ប៉ុន្តែបើអ្នកចេះតែសួរ តថាគតនឹងសំដែងឲ្យអ្នកស្តាប់ ។ ម្នាលគាមណី កាលពីមុនដែលពួកសត្វមិនទាន់ប្រាសចាករាគៈ ជាសត្វជាប់ចំណងគឺរាគៈ បណ្តាអ្នកលេងរបាំទាំងនោះ អ្នកលេងរបាំតែងប្រមូលយកធម៌ដែលជាបច្ច័យឲ្យកើតរាគៈ ដើម្បីឲ្យរីងរឹតតែប្រកបដោយរាគៈក្នុងកណ្តាលរឿណរង្គ ក្នុងកណ្តាលមហោស្រព ។ ម្នាលគាមណី កាលពីមុនដែលពួកសត្វមិនទាន់ប្រាសចាកទោសៈ ជាសត្វជាប់ចំណងគឺទោសៈ បណ្តាអ្នកលេងរបាំទាំងនោះ អ្នកលេងរបាំតែងប្រមូលយកធម៌ដែលជាបច្ច័យឲ្យកើតទោសៈ ដើម្បីឲ្យរឹងរឹតតែប្រកបដោយទោសៈ ក្នុងកណ្តាលរឿណរង្គ ក្នុងកណ្តាលមហោស្រព ។ ម្នាលគាមណី កាលពីមុនដែលពួកសត្វមិនទាន់ប្រាសចាកមោហៈ ជាសត្វជាប់ចំណងគឺមោហៈ បណ្តាអ្នកលេងរបាំទាំងនោះ អ្នកលេងរបាំតែងប្រមូលយកធម៌ ដែលជាបច្ច័យឲ្យកើតមោហៈ ដើម្បីឲ្យរឹងរឹតតែប្រកបដោយមោហៈ ក្នុងកណ្តាលរឿណរង្គ ក្នុងកណ្តាលមហោស្រព ។ អ្នកលេងរបាំនោះជាអ្នកស្រវឹង ជាអ្នកប្រមាទដោយខ្លួនឯង បិតនៅក្នុងសេចក្តីប្រមាទ លុះបែកធ្លាយរាងកាយស្លាប់ទៅ

បហាសោ នាម និរយោ តត្ថ ឧបបជ្ជតិ ។ សចេ ខោ បនស្ស ឯវំ ទិដ្ឋិ ហោតិ យោ សោ នដោ រង្គមជ្ឈេ សមជ្ជមជ្ឈេ សច្ចាលិកេន ជនំ ហាសេតិ រមេតិ សោ កាយស្ស ភេទា បរំ មរណា បហាសានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ សាស្ស ច ហោតិ មិច្ឆាទិដ្ឋិ ។ មិច្ឆាទិដ្ឋិកស្ស ខោ បនាហំ គាមណិ បុរិសបុគ្គលស្ស ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ និរយំ វា តិរច្ឆានយោនឹ វាតិ ។

[២៣៤] ឯវំ វុត្តេ តាលបុត្តោ នដគាមណិ បរោទិ អស្សូនិ បវត្តេសិ ។ ឯវំ ខោ ត្យាហំ គាមណិ នា-លត្ថំ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ នាហំ ភន្តេ ឯតំ រោទាមិ យំ មំ ភគវា ឯវមាហ ។ អបិ ចាហំ ភន្តេ បុព្វកេហិ អាចរិយបាចរិយេហិ នដេហិ ទីឃរត្តំ និកតោ វញ្ចិតោ បលុទ្ធោ យោ សោ នដោ រង្គមជ្ឈេ សមជ្ជមជ្ឈេ សច្ចាលិកេន ជនំ ហាសេតិ រមេតិ សោ កាយស្ស ភេទា បរំ មរណា

តែងទៅកើតឯបហាសនរក ។ បើគេមានសេចក្តីយល់យ៉ាងនេះថា អ្នកលេងរបាំឯណាធ្វើអ្នកផងឲ្យស្រស់ស្រាយ ឲ្យត្រេកអរដោយពាក្យពិតឬពាក្យឡេះឡោះ ក្នុងកណ្តាលរឿណរង្គ ក្នុងកណ្តាលមហោស្រព អ្នកលេងរបាំនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងបហាសទេវតាដូច្នេះ ។ សេចក្តីយល់នោះរបស់បុគ្គលនោះ ឈ្មោះថាមិច្ឆាទិដ្ឋិ ។ ម្នាលគាមណិ មួយទៀត បុរសបុគ្គលជាមិច្ឆាទិដ្ឋិ តថាគតពោលថាមានគតិតែ ២ យ៉ាងគឺ នរកឬតិរច្ឆានណាមួយមិនខាន ។

[២៣៤] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ តាលបុត្តនដគាមណិ ក៏យំសម្រក់ទឹកភ្នែក ។ ព្រះអង្គត្រាស់ថា ម្នាលគាមណិ តថាគតមិនបានថាឲ្យអ្នកឯងយ៉ាងនោះទេ ណ្ហើយគាមណិរឿងនុ៎ះលើកទុកចុះ អ្នកឯងកុំសួររឿងនុ៎ះនឹងតថាគតឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនយំពីព្រោះរឿងដែលទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតពួកអ្នកលេងរបាំជាអាចារ្យប្រធានលើអាចារ្យជាន់មុន បោកបញ្ឆោតកុហកខ្ញុំព្រះអង្គអស់កាលជាយូរអង្វែងហើយថា អ្នកលេងរបាំឯណាធ្វើអ្នកផងឲ្យស្រស់ស្រាយ ឲ្យត្រេកអរដោយពាក្យពិតឬពាក្យឡេះឡោះ ក្នុងកណ្តាលរឿណរង្គ ក្នុងកណ្តាលមហោស្រព បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ

បហាសានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ។ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ តាលបុត្តោ នដគាមណី ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ច បនាយស្មា តាលបុត្តោ ឯកោ វូបកដ្ឋោ

រមែងទៅកើតជាមួយនឹងបហាសទេវតា ។ តាលបុត្តនដគាមណី ពោល សរសើរព្រះមានព្រះភាគថា ច្បាស់ណាស់ ព្រះអង្គ ច្បាស់ណាស់ ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ដូចគេផ្ងាររបស់ដែលផ្កាប់ ឬបើករបស់ ដែលកំបាំង ឬប្រាប់ផ្លូវដល់មនុស្សវង្វេង ពុំនោះដូចគេទ្រោលប្រទីបប្រេង ក្នុងទីងងឹតឲ្យអ្នកមានភ្នែកមើលឃើញរូបបាន យ៉ាងណាមិញ ។ ធម៌ ដែលព្រះមានព្រះភាគប្រកាសហើយ ដោយអនេកបរិយាយក៏យ៉ាងនោះ ដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះមាន បុណ្យផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំ-ណាក់ព្រះមានបុណ្យ ។ តាលបុត្តនដគាមណី ក៏បានបព្វជ្ជា បាន ឧបសម្បទាក្នុងសំណាក់ព្រះមានបុណ្យ ។ លុះព្រះតាលបុត្តដ៏មាន អាយុបានឧបសម្បទាមិនយូរប៉ុន្មាន ជាបុគ្គលម្នាក់ឯងចេញចាកពួក

អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ។ បេ ។ អញ្ញត-

រោ ច បនាយស្មា តាលបុត្តោ អរហតំ អហោសីតិ ។

ទុតិយំ ។

[២៣៨] អថខោ យោធាជីវោ គាមណី យេន ភគវា

តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ ឯកមន្តំ និសិន្នោ

ខោ យោធាជីវោ គាមណី ភគវន្តំ ឯតទវោច សុតម្មេតំ

ភន្តេ បុព្វកានំ អាចរិយប្បាចរិយានំ យោធាជីវានំ ភា-

សមានានំ យោ សោ យោធាជីវោ សង្គាមេ ឧស្សហតិ

វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ

បរិយាបាទេន្តិ សោ កាយស្ស ភេទា បរំ មរណា

មិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះតាលបុត្តមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។ ចប់សូត្រទី ២ ។

[២៣៥] គ្រានោះ យោធាជីវគាមណិ[១] ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ។ បេ ។ លុះយោធាជីវគាមណិអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យរបស់ពួកយោធាជីវៈជាអាចារ្យប្រធានលើអាចារ្យជាន់មុននិយាយថា យោធាជីវៈឯណាប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ពួកជនដទៃសម្លាប់បំផ្លាញនូវយោធាជីវៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាម យោធាជីវៈនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ

---

១ អ្នកធំក្នុងស្រុកជាអ្នកចិញ្ចឹមជីវិតដោយចម្បាំង (មេទាហាន) ។

សរជិតានំ[1] ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភគវា កិមាហាតិ ។ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ យោធាជីវោ គាមណី ភគវន្តំ ឯតទវោច សុតម្មេតំ ភន្តេ បុព្វកានំ អាចរិយប្បាចរិយានំ យោធាជីវានំ ភាសមានានំ យោ សោ យោធាជីវោ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាបាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរជិតានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភគវា កិមាហាតិ ។ (អទ្ធា ខោ ត្យាហំ គាមណិ ជាលត្ថំ[2]) អលំ គាមណិ តិដ្ឋតេតំ

---

១ ឱ. សរញ្ជិតានំ ។ ២ ម. អទ្ធា ខោ ។ ល ។ នាលត្ថន្តិ បាឋោ នត្ថិ ។

តែងទៅកើតជាមួយនឹងពួកសរជិតទេវតា ។ ក្នុងរឿងនេះ តើព្រះអង្គ ត្រាស់ដូចម្តេច ។ ណ្ហើយគាមណិ រឿងនុ៎ះលើកទុកចុះ អ្នកកុំសួររឿង នុ៎ះនឹងតថាគតឡើយ ។ អស់វារៈ ២ ដង ។ បេ ។ យោធាជីវគាមណី ក្រាបបង្គំទូលចំពោះព្រះមានបុណ្យ អស់វារៈ ៣ ដងដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យរបស់យោធាជីវៈ ជាអាចារ្យប្រធាន លើអាចារ្យជាន់មុននិយាយថា យោធាជីវៈឯណា ប្រឹងប្រែងព្យាយាមក្នុង សង្គ្រាម ពួកជនដទៃសម្លាប់បំផ្លាញនូវយោធាជីវៈនោះ ដែលកំពុងប្រឹង ប្រែងព្យាយាម យោធាជីវៈនោះ លុះទម្លាយរាងកាយស្លាប់ទៅ តែងទៅ កើតជាមួយនឹងពួកសរជិតទេវតា ។ ក្នុងរឿងនេះ តើព្រះអង្គត្រាស់ដូច ម្តេច ។ (ម្នាលគាមណី តថាគតមិនបានដោះស្រាយនឹងអ្នកជាប្រាកដ) ព្រោះតថាគតបានឃាត់អ្នកហើយថា ណ្ហើយគាមណី រឿងនុ៎ះលើកទុកចុះ

២៣៧



មា មំ ឯតំ បុច្ឆិ ។ អបិច ត្យាហំ ព្យាករិស្សាមិ ។ យោ សោ គាមណិ យោធាជីវោ សង្គាមេ ឧស្សហតិ វាយមតិ តស្ស តំ ចិត្តំ បុព្វេ គហិតំ ទុក្កដំ[១] ទុប្បណិហិតំ ឥមេ សត្តា ហញ្ញន្តុ វា វជ្ឈន្តុ វា ឧច្ឆិជ្ជន្តុ វា វិនស្សន្តុ វា មា វា អហេសុំ ឥតិ វាតិ ។ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរជិតោ នាម[២] និរយោ តត្ថ ឧបបជ្ជតិ ។ សចេ ខោ បនស្ស ឯវំ ទិដ្ឋិ ហោតិ យោ សោ យោធាជីវោ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរជិតានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ សាស្ស ហោតិ មិច្ឆាទិដ្ឋិ ។ មិច្ឆាទិដ្ឋិកស្ស ខោ បនាហំ គាមណិ បុរិសបុគ្គលស្ស ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ និរយំ វា តិរច្ឆានយោនឹ វាតិ ។

---

១ ឱ. ហីនំ ទុក្កតំ ។ ម. គហិតំ ទុក្កហិតំ ។ ២ ឱ. សរាជិតា នាម ។ ម. បរជិតោ នាម ។

គាមណិសំយុត្ត

អ្នកកុំសួររឿងនុ៎ះនឹងតថាគតឡើយ ។ ប៉ុន្តែបើអ្នកចេះតែសួរ តថាគតនឹងសំដែងឲ្យអ្នកស្តាប់ ។ ម្នាលគាមណិ យោធាជីវៈឯណាប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ចិត្តរបស់យោធាជីវៈនោះ កាលពីមុនតែងកាន់អំពើអាក្រក់ តម្កល់ទុកអាក្រក់ថា ចូរឲ្យពួកសត្វទាំងនេះស្លាប់ទៅ ហិនហោចទៅ សាបសូន្យទៅ វិនាសទៅ ឬថា កុំឲ្យមានឡើយ ដូច្នេះ ។ ពួកជនដទៃក៏សម្លាប់បំផ្លាញយោធាជីវៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាម លុះយោធាជីវៈនោះ ទម្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសរជិតនរក ។ បើគេមានសេចក្តីយល់យ៉ាងនេះថា យោធាជីវៈឯណាប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ពួកជនដទៃសម្លាប់បំផ្លាញយោធាជីវៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម លុះយោធាជីវៈនោះទម្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងសរជិតទេវតាដូច្នេះ ។ សេចក្តីយល់នោះរបស់បុរសបុគ្គលនោះជាមិច្ឆាទិដ្ឋិ ។ ម្នាលគាមណិមួយទៀត បុរសបុគ្គលជាមិច្ឆាទិដ្ឋិ តថាគតពោលថាមានគតិតែ ២ យ៉ាងគឺ នរកឬតិរច្ឆានណាមួយមិនខាន ។

[២៣៦] ឯវំ វុត្តេ យោធាជីវោ គាមណិ បរោទិ អស្សូនិ បវត្តេសិ ។ ឯវំ ខោ ត្យាហំ គាមណិ ជាលត្ថំ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ នាហំ ភន្តេ ឯតំ រោទាមិ យំ មំ ភគវា ឯវមាហ ។ អបិ ចាហំ ភន្តេ បុព្វកេហិ អាចរិយបាចរិយេហិ យោធាជីវេហិ ទីឃរត្តំ និកតោ វញ្ចិតោ បលុទ្ធោ យោ សោ យោធាជីវោ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរជិតានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ ។ បេ ។ អជ្ជតគ្គេ បាណុបេតំ សរណាគតន្តិ ។ តតិយំ ។

[២៣៦] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ យោធាជីវគាមណី ក៏យំសម្រក់ទឹកភ្នែក ។ ព្រះអង្គត្រាស់ថា ម្នាលគាមណី តថាគតមិនបានថាឲ្យអ្នកឯងយ៉ាងនោះទេ ណ្ហើយគាមណី រឿងនុ៎ះលើកទុកចុះ អ្នកកុំសួររឿងនុ៎ះនឹងតថាគតឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនយំពីព្រោះរឿងដែលទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតពួកយោធាជីវៈជាអាចារ្យប្រធានលើអាចារ្យជាន់មុន បោកបញ្ឆោតកុហកខ្ញុំព្រះអង្គអស់កាលជាយូរអង្វែងហើយថា យោធាជីវៈឯណា ប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ពួកជនដទៃសម្លាប់បំផ្លាញយោធាជីវៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាម លុះយោធាជីវៈនោះ ទម្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកសរជិតទេវតា ។ យោធាជីវៈគាមណី ពោលសរសើរព្រះដ៏មានព្រះភាគថា ភ្លឺច្បាស់ណាស់ ព្រះអង្គ ភ្លឺច្បាស់ណាស់ ព្រះអង្គ ។ បេ ។ ដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

ចប់សូត្រទី ៣ ។

២៣៩



[២៣៧] អថខោ ហត្ថារោហោ គាមណី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ ចតុត្ថំ ។

[២៣៨] អថខោ អស្សារោហោ គាមណី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អស្សារោហោ គាមណី ភគវន្តំ ឯតទវោច សុតម្មេតំ ភន្តេ បុព្វកានំ អាចរិយប្បាចរិយានំ អស្សារោហានំ ភាសមានានំ យោ សោ អស្សារោហោ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាបាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរជិតានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភគវា កិមាហាតិ ។ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ អស្សារោហោ គាមណី ភគវន្តំ ឯតទវោច សុតម្មេតំ ភន្តេ បុព្វកានំ អាចរិយប្បាចរិយានំ អស្សារោហានំ ភាសមានានំ យោ សោ អស្សារោហោ

គាមណិសំយុត្ត

[២៣៧] គ្រានោះ ហត្ថារោហគាមណី[១] ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ ដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។ ចប់សូត្រទី ៤ ។

[២៣៨] គ្រានោះ អស្សារោហគាមណីចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក៏អង្គុយក្នុងទីសមគួរ ។ លុះអស្សារោហគាមណី អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យរបស់ពួកអស្សារោហៈជាអាចារ្យប្រធានលើអាចារ្យជាន់មុន និយាយថា អស្សារោហៈឯណាប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ពួកជនដទៃសម្លាប់បំផ្លាញនូវអស្សារោហៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាម លុះអស្សារោហៈនោះទម្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកសរជិតទេវតា ។ ក្នុងរឿងនេះ តើព្រះអង្គត្រាស់ដូចម្ដេច ។ ណ្ហើយគាមណី រឿងនុ៎ះលើកទុកចុះ អ្នកកុំសួររឿងនុ៎ះនឹងតថាគតឡើយ ។ អស់វារៈពីរដង ។ បេ ។ អស្សារោហគាមណី ក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈ ៣ ដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យរបស់ពួកអស្សារោហៈជាអាចារ្យប្រធានលើអាចារ្យជាន់មុន និយាយដូច្នេះថា អស្សារោហៈឯណា

១ អ្នកធំក្នុងស្រុក ជាអ្នកកាន់កាប់ការខាងដំរី (មេពលដំរី) ។

សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាបាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរញ្ជិតានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ ឥធ ភគវា កិមាហាតិ ។ អទ្ធា ខោ ត្យាហំ គាមណិ ណាលត្ថំ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ អបិច ខោ ត្យាហំ ព្យាករិស្សាមិ ។ យោ សោ គាមណិ អស្សារោហោ សង្គាមេ ឧស្សហតិ វាយមតិ តស្ស តំ ចិត្តំ បុព្វេ គហិតំ ទុក្កដំ ទុប្បណិហិតំ ឥមេ សត្តា ហញ្ញន្តុ វា វជ្ឈន្តុ វា ឧច្ឆិជ្ជន្តុ វា វិនស្សន្តុ វា មា វា អហេសុំ ឥតិ វាតិ ។ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាបាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរញ្ជិតោ នាម និរយោ តត្ថ ឧបបជ្ជតិ ។ សចេ ខោ បនស្ស ឯវំ ទិដ្ឋិ ហោតិ យោ សោ អស្សារោហោ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាបាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរញ្ជិតានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។ សាស្ស ហោតិ មិច្ឆាទិដ្ឋិ ។

ប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ពួកជនដទៃសម្លាប់បំផ្លាញនូវអស្សា-រោហៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាម លុះអស្សារោហៈនោះទម្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកសរជិតទេវតា ។ ក្នុងរឿងនេះ តើព្រះអង្គត្រាស់ដូចម្តេច ។ ម្នាលគាមណិ តថាគតមិនបានដោះស្រាយនឹងអ្នកជាប្រាកដ ព្រោះតថាគតឃាត់អ្នកហើយថា ណ្ហើយគាម-ណិ រឿងនុ៎ះលើកទុកចុះ អ្នកកុំសួររឿងនុ៎ះនឹងតថាគតឡើយ ។ ប៉ុន្តែបើអ្នកចេះតែសួរ តថាគតនឹងសំដែងឲ្យអ្នកស្តាប់ ។ ម្នាលគាមណិ អស្សា-រោហៈឯណាប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ចិត្តរបស់អស្សារោហៈកាលមុនតែងកាន់អំពើអាក្រក់ តម្កល់ទុកអាក្រក់ថា ចូរឲ្យពួកសត្វនេះស្លាប់ទៅ ហិនហោចទៅ សាបសូន្យទៅ វិនាសទៅ ឬថា កុំឲ្យមានឡើយ ដូច្នេះ ។ ពួកជនដទៃសម្លាប់បំផ្លាញនូវអស្សារោហៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាម លុះអស្សារោហៈនោះទម្លាយរាងកាយស្លាប់ទៅរមែងទៅកើតក្នុងសរជិតនរក ។ បើគេមានសេចក្តីយល់យ៉ាងនេះថា អស្សារោហៈឯណាប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ពួកជនដទៃសម្លាប់បំផ្លាញនូវអស្សារោហៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាម លុះអស្សា-រោហៈនោះទម្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកសរជិត-ទេវតាដូច្នេះ ។ សេចក្តីយល់នោះរបស់បុរសបុគ្គលនោះជាមិច្ឆាទិដ្ឋិ ។

មិច្ឆាទិដ្ឋិកស្ស ខោ បនាហំ គាមណិ បុរិសបុគ្គលស្ស ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ និរយំ វា តិរច្ឆានយោនឹ វាតិ ។

[២៣៩] ឯវំ វុត្តេ អស្សារោហោ គាមណី បរោទិ អស្សូនិ បវត្តេសិ ។ ឯវំ ខោ ត្យាហំ គាមណិ នាលត្ថំ អលំ គាមណិ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ នាហំ ភន្តេ ឯតំ រោទាមិ យំ មំ ភគវា ឯវមាហ ។ អបិ ចាហំ ភន្តេ បុព្វកេហិ អាចរិយបាចរិយេហិ អស្សារោ-ហេហិ ទីឃរត្តំ និកតោ វញ្ចិតោ បលុទ្ធោ យោ សោ អស្សារោហោ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាបាទេន្តិ សោ កាយស្ស ភេទា បរំ មរណា សរជិតានំ ទេវានំ ស-ហព្យតំ ឧបបជ្ជតីតិ ។ អភិក្កន្តំ ភន្តេ ។ បេ ។ អជ្ជតគ្គេ ចាណុបេតំ សរណង្គតន្តិ ។ បញ្ចមំ ។

[២៤០] ឯកំ សមយំ ភគវា នាឡន្ទាយំ វិហរតិ ចាវារកម្ពវនេ ។ អថខោ អសិពន្ធកបុត្តោ គាមណី

ម្នាលគាមណី មួយទៀត បុរសបុគ្គលជាមិច្ឆាទិដ្ឋិ តថាគតពោលថាមាន គតិតែ ២ យ៉ាងគឺ នរកឬតិរច្ឆានណាមួយមិនខាន ។

[២៣៩] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ អស្សា-រោហគាមណីក៏សម្រក់ទឹកភ្នែក ។ ព្រះអង្គត្រាស់ថា ម្នាលគាមណី តថាគតមិនបានថាឲ្យអ្នកឯងយ៉ាងនោះទេ ណ្ហើយគាមណី រឿងនុ៎ះលើកទុកចុះ អ្នកកុំសួររឿងនុ៎ះនឹងតថាគតឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនយំ ពីព្រោះតែរឿងដែលទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតពួកអស្សារោហៈជាអាចារ្យប្រធានលើអាចារ្យជាន់មុន បោកបញ្ឆោតកុហកខ្ញុំព្រះអង្គអស់កាលជាយូរអង្វែងហើយថា អស្សារោហៈឯណាប្រឹងប្រែងព្យាយាមក្នុងសង្គ្រាម ពួកជនដទៃសម្លាប់បំផ្លាញនូវអស្សារោហៈនោះ ដែលកំពុងប្រឹងប្រែងព្យាយាម លុះអស្សារោហៈនោះទម្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកសរជិតទេវតា ។ អស្សារោហគាមណីពោលសរសើរព្រះមានព្រះភាគថា ភ្លឺច្បាស់ណាស់ ព្រះអង្គ ។ បេ ។ ដល់នូវសរណគមន៍ស្មើដោយជីវិតតាំងអំពីថ្ងៃនេះជាដើមទៅ ។ ចប់សូត្រទី ៥ ។

[២៤០] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងបាវារិ-កម្ពវ័ន ជិតក្រុងនាឡន្ទា ។ គ្រានោះ គាមណីឈ្មោះអសិពន្ធកបុត្ត

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អសិពន្ធកបុត្តោ គាមណី ភគវន្តំ ឯតទវោច ព្រាហ្មណា ភន្តេ បច្ឆាភូមកា កាមណ្ឌលុកា សេ-វាលមាលិកា ឧទកោរោហកា អគ្គិបរិចារិកា តេ មតំ កាលកតំ ឧយ្យាបេន្តិ នាម សញ្ញាបេន្តិ នាម ឱក្កាសេន្តិ ។ ភគវា បន ភន្តេ អរហំ សម្មាសម្ពុទ្ធោ បហោតិ តថា កាតុំ យថា សព្វោ លោកោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យាតិ ។ តេនហិ គាមណិ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ ។ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ គាម-ណិ ឥធស្ស បុរិសោ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចោ ផរុស-វាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆា ទិដ្ឋិកោ តមេនំ មហាជនកាយោ សង្គម្ម សមាគម្ម អាយាចេយ្យ ថោមេយ្យ បញ្ជលិកោ អនុបរិសក្កេយ្យ

ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏-មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអសិពន្ធកបុត្តគាមណី អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍អ្នកនៅក្នុងស្រុកបច្ឆាភូមិ ជាអ្នកមានកំសៀវទឹក ជាអ្នកស្រង់យកសារាយមកប្រដាប់កាយ ជាអ្នកចុះត្រាំទឹក ជាអ្នកបម្រើភ្លើង ពួកព្រាហ្មណ៍ទាំងនោះឈ្មោះថា ធ្វើមនុស្សដែលស្លាប់ហើយ ធ្វើមរណកាលហើយ ឲ្យក្រោកឡើង ឲ្យដឹងខ្លួន ឲ្យឡើងកាន់ឋានសួគ៌បាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះមានព្រះភាគអ-រហន្តសម្មាសម្ពុទ្ធ តើអាចធ្វើសត្វលោកទាំងអស់ដែលបែកធ្លាយរាងកាយស្លាប់ទៅ ឲ្យទៅកើតឯសុគតិសួគ៌ទេវលោកបានដែរឬ ។ ម្នាលគាមណី បើដូច្នោះ តថាគតនឹងសួរអ្នកក្នុងដំណើរនេះវិញ ។ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយប្រស្នានោះយ៉ាងនោះចុះ ។ ម្នាលគាមណី អ្នកយល់សេចក្តីនោះដូចម្តេច ។ បុរសក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយកុហក និយាយញុះញង់ និយាយទ្រគោះ និយាយឥតប្រយោជន៍ សំឡឹងរំពៃចំពោះទ្រព្យគេ មានចិត្តគុំកួន មានគំនិតយល់ខុស ពួកមហាជនក៏មកចួបជុំព្រមព្រៀងគ្នា អង្វរ សរសើរ សំពះ តាមឈូងរ នូវបុរសនោះថា

អយំ បុរិសោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតូតិ ។ តំ កឹ មញ្ញសិ គាមណិ អបិ នុ សោ បុរិសោ មហតោ ជនកាយស្ស អាយាចនហេតុ វា ថោមនហេតុ វា បញ្ជលិកា អនុបរិសក្កនហេតុ វា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យាតិ ។ នោ ហេតំ ភន្តេ ។

[២៤១] សេយ្យថាបិ គាមណិ បុរិសោ មហន្តំ បុថុសិលំ គម្ភីរេ ឧទករហទេ បក្ខិបេយ្យ តមេនំ មហាជនកាយោ សង្គម្ម សមាគម្ម អាយាចេយ្យ ថោមេយ្យ បញ្ជលិកោ អនុបរិសក្កេយ្យ ឧម្មុជ្ជ ភោ បុថុសិលេ ឧប្លវ ភោ បុថុសិលេ ថលមុប្លវ ភោ បុថុសិលេតិ ។ តំ កឹ មញ្ញសិ គាមណិ អបិ នុ សា បុថុសិលា មហតោ ជនកាយស្ស អាយាចនហេតុ វា ថោមនហេតុ វា បញ្ជលិកា អនុបរិសក្កនហេតុ វា ឧម្មុជ្ជេយ្យ វា ឧប្លវេយ្យ វា ថលំ វា ឧប្លវេយ្យាតិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ គាមណិ យោ សោ បុរិសោ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចោ

បើបុរសនេះ បែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យបានទៅកើតឯសុគតិសួគ៌ទេវលោក ។ ម្នាលគាមណិ តើអ្នកយល់សេចក្តីនោះដូចម្តេច បុរសនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ គួរទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែពួកមហាជនអង្វរ សរសើរ សំពះ ផ្ទាមឈូធរ បានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។

[២៤១] ម្នាលគាមណិ ដូចបុរសបោះដុំថ្មធំទៅក្នុងអន្លង់ទឹកជំជ្រៅ មានពួកមហាជនមកចួបជុំព្រមព្រៀងគ្នា អង្វរ សរសើរ សំពះ ផ្ទាមឈូធរ នូវថ្មធំនោះថា នែដុំថ្មអើយ ចូរអ្នកឯងងើបឡើង នែដុំថ្ម ចូរឯងអណ្តែតឡើង នែដុំថ្ម ចូរឯងឡើងមកលើគោក ។ ម្នាលគាមណិ អ្នកយល់សេចក្តីនោះដូចម្តេច ដុំថ្មនោះគួរងើបឡើង អណ្តែតឡើង ឬឡើងមកលើគោក ព្រោះហេតុតែពួកមហាជនអង្វរ សរសើរ សំពះ ផ្ទាមឈូធរ បានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលគាមណិ រឿងនេះឯងក៏ដូច្នោះដែរ បុរសឯណាជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយកុហក និយាយញុះញង់

ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋិកោ ភិញ្ញាបិ តំ មហាជនកាយោ សង្គម្ម សមាគម្ម អាយាចេយ្យ ថោមេយ្យ បញ្ជលិកោ អនុ-បរិសក្កេយ្យ អយំ បុរិសោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតូតិ ។ អថខោ សោ បុរិសោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ។

[២៤២] តំ កឹ មញ្ញសិ គាមណិ ឥធស្ស បុរិសោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កា-មេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ បិសុ-ណាយ វាចាយ បដិវិរតោ ផរុសាយ វាចាយ បដិវិរតោ សម្ផប្បលាបា បដិវិរតោ អនភិជ្ឈាលុ អព្យាបន្នចិត្តោ សម្មាទិដ្ឋិកោ តមេនំ មហាជនកាយោ សង្គម្ម សមា-គម្ម អាយាចេយ្យ ថោមេយ្យ បញ្ជលិកោ អនុបរិ-សក្កេយ្យ អយំ បុរិសោ កាយស្ស ភេទា បរំ មរណា

និយាយទ្រគោះ និយាយឥតប្រយោជន៍ សំឡឹងរំពៃចំពោះទ្រព្យគេ មានចិត្តគុំកួន មានគំនិតយល់ខុស ទោះបីពួកមហាជនមកចួបជុំព្រមព្រៀងគ្នា អង្វរ សរសើរ សំពះ តាមឈូធរ នូវបុរសនោះថា បើបុរស-នេះ បែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យបានទៅកើតឯសុគតិសួគ៌ទេវ-លោកយ៉ាងណាក៏ដោយ ។ លុះបុរសនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៀងតែទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ដោយពិត ។

[២៤២] ម្នាលគាមណី អ្នកយល់សេចក្តីនោះដូចម្តេច បុរសក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ពួកមហាជនមកចួបជុំព្រមព្រៀងគ្នា អង្វរ សរសើរ សំពះ តាមឈូធរ នូវបុរសនោះថា បើបុរសនោះបែកធ្លាយរាងកាយស្លាប់ទៅ

អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតូតិ ។ តំ កឹ មញ្ញសិ គាមណិ អបិ នុ សោ បុរិសោ មហតោ ជនកាយស្ស អាយាចនហេតុ វា ថោមនហេតុ វា បញ្ជលិកា អនុបរិសក្កនហេតុ វា កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧប-បជ្ជេយ្យាតិ ។ នោ ហេតំ ភន្តេ ។

[២៤៣] សេយ្យថាបិ គាមណិ បុរិសោ សប្បិកុម្ភំ វា តេលកុម្ភំ វា គម្ភីរំ ឧទករហទំ ឱគាហិត្វា ភិន្ទេយ្យ តត្រ យស្ស សក្ខរា វា កឋលា វា សា អធោ-គាមី អស្ស យញ្ច ខ្វស្ស តត្រ សប្បិ វា តេលំ វា តំ ឧទ្ធង្គាមី អស្ស តមេនំ មហាជនកាយោ សង្គម្ម សមាគម្ម អាយាចេយ្យ ថោមេយ្យ បញ្ជ-លិកោ អនុបរិសក្កេយ្យ ឱសីទ ភោ សប្បិតេល សំសីទ ភោ សប្បិតេល អធោ គច្ឆ ភោ សប្បិតេ-លាតិ ។ តំ កឹ មញ្ញសិ គាមណិ អបិ នុ តំ សប្បិតេលំ មហតោ ជនកាយស្ស អាយាចនហេតុ វា

សូមឲ្យទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលគាមណី អ្នកយល់សេចក្តីនោះដូចម្តេច បុរសនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ គួរទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែមហាជនអង្វរ សរសើរ សំពះ តាមឈូឆរ បានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។

[២៤៣] ម្នាលគាមណី បុរសកាន់យកក្អមទឹកដោះរាវឬក្អមប្រេងចុះទៅកាន់អន្លង់ទឹកដ៏ជ្រៅហើយវាយបំបែក ក្រួសឬអម្បែងដែលនៅក្នុងក្អមនោះក៏លិចចុះទៅខាងក្រោម ចំណែកខាងទឹកដោះរាវឬប្រេងដែលនៅក្នុងក្អមនោះក៏អណ្តែតឡើងលើ ពួកមហាជនមកចួបជុំព្រមព្រៀងគ្នា អង្វរ សរសើរ សំពះ តាមឈូឆរ នូវទឹកដោះរាវនិងប្រេងនោះថា រុំយទឹកដោះរាងឬប្រេង ចូរឯងលិចទៅ ទឹកដោះរាវឬប្រេង ចូរឯងលិចបាត់ទៅ ទឹកដោះរាវឬប្រេង ចូរឯងចុះទៅខាងក្រោមទៅ ។ ម្នាលគាមណី អ្នកយល់សេចក្តីនោះដូចម្តេច ទឹកដោះរាងឬប្រេងនោះ លិចទៅ លិចបាត់ទៅ ឬចុះទៅក្រោម ព្រោះហេតុតែពួកមហាជនអង្វរ

ថោមនហេតុ វា បញ្ចលិកា អនុបរិសក្កនហេតុ វា ឱសីទេយ្យ វា សំសីទេយ្យ វា អធោ វា គច្ឆេយ្យាតិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ គាមណិ យោ សោ បុរិសោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ បិសុណាយ វាចាយ បដិវិរតោ ផរុសាយ វាចាយ បដិវិរតោ សម្ផប្បលាបា បដិវិរតោ អនភិជ្ឈាលុ អព្យាបន្នចិត្តោ សម្មាទិដ្ឋិកោ កិញ្ចាបិ តំ មហាជនកាយោ សង្គម្ម សមាគម្ម អាយាចេយ្យ ថោមេយ្យ បញ្ចលិកោ អនុបរិសក្កេយ្យ អយំ បុរិសោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតូតិ ។ អថខោ សោ បុរិសោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យាតិ ។

[២៤៤] ឯវំ វុត្តេ អសិពន្ធកបុត្តោ គាមណី ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ ។ បេ ។ អជ្ជតគ្គេ បាណុបេតំ សរណាគ្គតន្តិ ។ ឆដ្ឋំ ។

សរសើរ សំពះ តាមឈូធរ បានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលគាមណិ រឿងនេះឯងក៏ដូច្នោះដែរ បុរសឯណាវៀរចាកបាណាតិ-បាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ទោះបីពួកមហាជនមកចូបជុំព្រមព្រៀងគ្នា អង្វរ សរសើរ សំពះ តាមឈូធរ នូវបុរសនោះថា បើបុរសនេះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក យ៉ាងណាក៏ដោយ ។ លុះបុរសនោះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៀងតែទៅកើតឯសុគតិសួគ៌ទេវលោក ដោយពិត ។

[២៤៤] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ អសិ-ពន្ធកបុត្តគាមណិក៏សរសើរព្រះមានព្រះភាគដូច្នេះថា ភ្លឺច្បាស់ណាស់ព្រះអង្គ ។ បេ ។ ដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះតទៅ ។ ចប់សូត្រទី ៦ ។

២៤៧

## គាមណិសំយុត្តំ

[២៤៨] ឯកំ សមយំ ភគវា នាឡន្ទាយំ វិហរតិ បាវារិកម្ពវនេ ។ អថខោ អសិពន្ធកបុត្តោ គាមណី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អសិពន្ធកបុត្តោ គាមណី ភគវន្តំ ឯតទវោច ននុ ភន្តេ ភគវា សព្វបាណភូតហិតានុកម្បី វិហរតីតិ ។ ឯវំ គាមណិ តថាគតោ សព្វបាណភូតហិតានុកម្បី វិហរតីតិ ។ អថ កិញ្ចរហិ ភន្តេ ភគវា ឯកច្ចានំ សក្កច្ចំ ធម្មំ ទេសេតិ ឯកច្ចានំ នោ តថា សក្កច្ចំ ធម្មំ ទេសេតីតិ ។ តេនហិ គាមណិ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ ។ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ គាមណិ ឥធ កស្សកស្ស គហបតិនោ តីណិ ខេត្តានិ ឯកំ ខេត្តំ អគ្គំ ឯកំ ខេត្តំ មជ្ឈិមំ ឯកំ ខេត្តំ ហីនំ ជង្គលំ ឩសរំ បាបភូមិ ។

គាមណិសំយុត្ត

[២៤៥] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងបាវារិកម្ពវ័ន ជិតក្រុងនាឡន្ទា ។ គ្រានោះ អសិពន្ធកបុត្តគាមណីចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអសិពន្ធកបុត្តគាមណីអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគព្រះអង្គជាអ្នកអនុគ្រោះ ដើម្បីប្រយោជន៍ដល់សត្វទាំងពួងមែនឬ ។ ព្រះមានព្រះភាគត្រាស់ថា យ៉ាងហ្នឹងហើយ គាមណី ព្រះតថាគតជាអ្នកអនុគ្រោះដើម្បីប្រយោជន៍ដល់សត្វទាំងពួងមែន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះដូចម្ដេចបានជាចួនកាលព្រះមានព្រះភាគសំដែងធម៌ដល់ជនពួកខ្លះដោយអើពើ សំដែងធម៌ដល់ជនពួកខ្លះដោយមិនអើពើ ។ ម្នាលគាមណី បើដូច្នោះមានតែតថាគតនឹងត្រឡប់សួរអ្នកក្នុងដំណើរនេះវិញ ។ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះប្រស្នានោះយ៉ាងនោះចុះ ។ ម្នាលគាមណី អ្នកយល់សេចក្ដីនោះដូចម្ដេច គហបតីអ្នកភ្ជួររាស់ក្នុងលោកនេះ មានស្រែ ៣ គឺស្រែ ១ យ៉ាងល្អ ស្រែ ១ យ៉ាងកណ្ដាល ស្រែ ១ យ៉ាងអន់ ជាដីទួល ដីប្រៃ ដីអាក្រក់ ។

តំ កឹ មញ្ញសិ គាមណិ អសុ កស្សកោ គហបតិ ពីជានិ បតិដ្ឋបេតុកាមោ តត្ថ បឋមំ បតិដ្ឋបេយ្យ យំ វា អទុំ ខេត្តំ អគ្គំ យំ វា អទុំ ខេត្តំ មជ្ឈិមំ យំ វា អទុំ ខេត្តំ ហីនំ ជង្គលំ ឱសរំ បាបភូមិន្តិ ។ អសុ ភន្តេ កស្សកោ គហបតិ ពីជានិ បតិដ្ឋបេតុកាមោ យំ អទុំ ខេត្តំ អគ្គំ តត្ថ បតិដ្ឋបេយ្យ តត្ថ បតិដ្ឋបេត្វា យំ អទុំ ខេត្តំ មជ្ឈិមំ តត្ថ បតិដ្ឋបេយ្យ តត្ថ បតិដ្ឋបេត្វា យំ អទុំ ខេត្តំ ហីនំ ជង្គលំ ឱសរំ បាបភូមិ តត្ថ បតិដ្ឋបេយ្យបិ នោបិ បតិដ្ឋបេយ្យ ។ តំ កិស្ស ហេតុ ។ អន្តមសោ គោភត្តំបិ ភវិស្សតីតិ ។

[២៤៦] សេយ្យថាបិ គាមណិ យំ អទុំ ខេត្តំ អគ្គំ ឯវមេវ មយ្ហំ ភិក្ខូ ភិក្ខុនិយោ តេសាហំ ធម្មំ ទេសេមិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិ-យោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុ-ណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេមិ ។ តំ កិស្ស ហេតុ ។ ឯតេ ហិ គាមណិ មំទីបា មំលេណា

ម្នាលគាមណិ អ្នកយល់សេចក្តីនោះដូចម្តេច គហបតីអ្នកភ្ជួររាស់ឯណោះ មានបំណងនឹងដាក់ពូជក្នុងស្រែទាំងនោះ តើគេគួរដាក់ក្នុងស្រែណាមុន ដាក់ស្រែល្អឯណោះឬ ឬស្រែយ៉ាងកណ្តាលឯណោះ ឬក៏ស្រែយ៉ាងអន់ ជាដីទួល ដីប្រៃ ដីអាក្រក់ឯណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន គហបតីអ្នកភ្ជួររាស់ឯណោះមានបំណងនឹងដាក់ពូជ ស្រែណាល្អ ក៏ដាក់ក្នុងស្រែនោះ លុះដាក់ក្នុងស្រែនោះហើយ ទើបដាក់ក្នុងស្រែយ៉ាងកណ្តាល លុះដាក់ក្នុងស្រែនោះហើយ ទើបដាក់ក្នុងស្រែយ៉ាងអន់ ជាដីទួល ដ៏ប្រៃ ដីអាក្រក់ក៏មាន មិនដាក់ក៏មាន ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះថាដោយហោចទៅ គ្រាន់បានជាចំណីគោដែរ ។

[២៤៦] ម្នាលគាមណិ ស្រែដែលល្អឯណោះ ដូចជាពួកភិក្ខុភិក្ខុនី (ជាសាវ័ក) របស់តថាគត តថាគតសំដែងធម៌មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ដល់ពួកភិក្ខុភិក្ខុនីទាំងនោះ តថាគតប្រកាសព្រហ្មចរិយធម៌ប្រកបដោយអត្ថ ដោយព្យញ្ជនៈ បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលគាមណិ ព្រោះថាភិក្ខុភិក្ខុនីទាំងនុ៎ះ មានតថាគតជាទីពឹង មានតថាគតជាទីជ្រកកោន

មំតាណា មំសរណា វិហរន្តិ ។ សេយ្យថាបិ គាមណិ យំ អទុំ ខេត្តំ មជ្ឈិមំ ឯវមេវ មយ្ហំ ឧបាសកា ឧបាសិកាយោ តេសាហំ ធម្មំ ទេសេមិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេមិ ។ តំ កិស្ស ហេតុ ។ ឯតេ ហិ គាមណិ មំទីបា មំលេណា មំតាណា មំសរណា វិហរន្តិ ។ សេយ្យថាបិ គាមណិ យំ អទុំ ខេត្តំ ហីនំ ជង្គលំ ឱសរំ បាបភូមិ ឯវមេវ មយ្ហំ អញ្ញតិត្ថិយា សមណព្រាហ្មណបរិព្វាជកា តេសំ បាហំ ធម្មំ ទេសេមិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេមិ ។

គាមណិសំយុត្ត

មានតថាគតជាទីពំនាក់ មានតថាគតជាទីរឭក ។ ម្នាលគាមណី ស្រែ-យ៉ាងកណ្តាលឯណោះ ដូចជាពួកឧបាសក ឧបាសិកា (ជាសាវក) របស់តថាគត តថាគតសំដែងធម៌មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ដល់ឧបាសកឧបាសិកាទាំងនោះ តថាគតក៏ប្រកាសព្រហ្មចរិយធម៌ដ៏ប្រកបដោយអត្ថ ដោយព្យញ្ជនៈ បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលគាមណី ព្រោះថាឧបាសកឧបាសិកាទាំងនុ៎ះ មានតថាគតជាទីពឹង មានតថាគតជាទីជ្រកកោន មានតថាគតជាទីពំនាក់ មានតថាគតជាទីរឭក ។ ម្នាលគាមណី ស្រែយ៉ាងអន់ ជាដីទួល ដីប្រៃ ដីអាក្រក់ឯណោះ ដូចជាពួកសមណព្រាហ្មណបរិព្វាជកជាអន្យតិរ្ថិយ (ដែលចូលមកជាសាវ័ក) របស់តថាគត តថាគតសំដែងធម៌មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ដល់សមណព្រាហ្មណបរិព្វាជកទាំងនោះ តថាគតក៏ប្រកាសព្រហ្មចរិយធម៌ដ៏ប្រកបដោយអត្ថ ដោយព្យញ្ជនៈ បរិបូណ៌ បរិសុទ្ធទាំងអស់ ។

[២៤៧] តំ កិស្ស ហេតុ ។ អប្បេវនាម ឯក-
បទម្បិ អាជានេយ្យុំ តំ នេសំ អស្ស ទីឃរត្តំ ហិតា-
យ សុខាយ ។ សេយ្យថាបិ គាមណិ បុរិសស្ស ត-
យោ ឧទកមណិកា ឯកោ ឧទកមណិកោ អច្ឆិទ្ទោ
អហារិអបរិហារី ឯកោ ឧទកមណិកោ អច្ឆិទ្ទោ ហារិ-
បរិហារី ឯកោ ឧទកមណិកោ ឆិទ្ទោ ហារិបរិហារី ។
តំ កឹ មញ្ញសិ គាមណិ អសុ បុរិសោ ឧទកំ
និក្ខិបិតុកាមោ តត្ថ បឋមំ និក្ខិបេយ្យ យោ វា សោ
ឧទកមណិកោ អច្ឆិទ្ទោ អហារិអបរិហារី យោ វា
សោ ឧទកមណិកោ អច្ឆិទ្ទោ ហារិបរិហារី យោ វា
សោ ឧទកមណិកោ ឆិទ្ទោ ហារិបរិហារីតិ ។ អសុ
ភន្តេ បុរិសោ ឧទកំ និក្ខិបិតុកាមោ យោ សោ
ឧទកមណិកោ អច្ឆិទ្ទោ អហារិអបរិហារី តត្ថ និក្ខិ-
បេយ្យ តត្ថ និក្ខិបិត្វា យោ សោ ឧទកមណិកោ
អច្ឆិទ្ទោ ហារិបរិហារី តត្ថ និក្ខិបេយ្យ តត្ថ និក្ខិបិត្វា
យោ សោ ឧទកមណិកោ ឆិទ្ទោ ហារិបរិហារី

[២៤៧] ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះថា (តថាគត គិតថា) ធ្វើម្ដេចហ្ន៎ ទើបពួកសត្វដឹងច្បាស់នូវធម៌សូម្បីតែមួយបទ ការដឹងច្បាស់នោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលជាអង្វែង ដល់ពួកសត្វទាំងនោះ ។ ម្នាលគាមណិ ដូចបុរសមានពាងទឹក ៣ គឺ ពាងទឹកដែលមិនធ្លុះ ទឹកមិនជ្រាប មិនរីង ១ ពាងទឹកដែលមិនធ្លុះ តែទឹកជ្រាប រីង ១ ពាងទឹកដែលធ្លុះ ទឹកជ្រាប រីង ១ ។ ម្នាលគាមណិ អ្នកយល់សេចក្ដីនោះដូចម្ដេច បុរសឯណោះមានបំណងនឹងដាក់ទឹកក្នុងពាងទាំងនោះ តើគេគួរដាក់ក្នុងពាងទឹកណាមុន ដាក់ពាងទឹកដែលមិនធ្លុះ ទឹកមិនជ្រាប មិនរីងឬ ឬដាក់ពាងទឹកដែលមិនធ្លុះ តែទឹកជ្រាប រីង ឬក៏ដាក់ពាងទឹកដែលធ្លុះទាំងជ្រាបរីង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសឯណោះមានបំណងនឹងដាក់ទឹក ពាងទឹកឯណាដែលមិនធ្លុះ ទឹកមិនជ្រាប មិនរីង ក៏ដាក់ក្នុងពាងនោះ លុះដាក់ក្នុងពាងនោះហើយ ទើបដាក់ពាងទឹកដែលមិនធ្លុះ តែជ្រាបរីងនោះ លុះដាក់ក្នុងពាងទឹកនោះហើយ ទើបដាក់ពាងទឹកដែលធ្លុះ ទឹកជ្រាបរីងនោះក៏មាន

តត្ថ និក្ខិបេយ្យបិ ឆោបិ និក្ខិបេយ្យ ។ តំ កិស្ស ហេតុ ។ អដ្ឋមសោ ភណ្ឌាឆោវជំបិ ភវិស្សតីតិ ។

[២៤៨] សេយ្យថាបិ គាមណិ យោ សោ ឧឌ-កាមណិកោ អច្ឆិទ្ទោ អហារិអបរិហារី ឯវមេវ មយ្ហំ ភិក្ខូ ភិក្ខុនិយោ តេសាហំ ធម្មំ ទេសេមិ អាទិ-កល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេមិ ។ តំ កិស្ស ហេតុ ។ ឯតេ ហិ គាមណិ មំទីបា មំលេណា មំតាណា មំសរណា វិហរន្តិ ។ សេយ្យថាបិ គាមណិ យោ សោ ឧទកាមណិកោ អច្ឆិទ្ទោ ហារិបរិហារី ឯវមេវ មយ្ហំ ឧបាសកា ឧបាសិ-កាយោ តេសំ អហំ ធម្មំ ទេសេមិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យ-ញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេ-មិ ។ តំ កិស្ស ហេតុ ។ ឯតេ ហិ គាមណិ មំទីបា មំលេណា មំតាណា មំសរណា វិហរន្តិ ។ សេយ្យថាបិ គាមណិ យោ សោ ឧទកាមណិកោ ឆិទ្ទោ ហារិបរិហារី

មិនដាក់ក៏មាន ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះថាដោយហោចទៅ គ្រាន់បានលាងរបស់ដែរ ។

[២៤៨] ម្នាលគាមណិ ពាងទឹកដែលមិនធ្លុះ មិនជ្រាប មិនរីង ដូចពួកភិក្ខុ ភិក្ខុនី (ជាសាវ័ក) របស់តថាគត តថាគតសំដែងធម៌មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ដល់ភិក្ខុ ភិក្ខុនីទាំងនោះ តថាគតក៏ប្រកាសនូវព្រហ្មចរិយធម៌ដ៏ប្រកបដោយអត្ថ ដោយព្យញ្ជនៈ បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលគាមណិ ព្រោះថាភិក្ខុ ភិក្ខុនីទាំងនុ៎ះ មានតថាគតជាទីពឹង មានតថាគតជាទីជ្រកកោន មានតថាគតជាទីពំនាក់ មានតថាគតជាទីរឭក ។ ម្នាលគាមណិ ពាងទឹកដែលមិនធ្លុះ តែទឹកជ្រាប រីង ដូចពួកឧបាសក ឧបាសិកា (ជាសាវ័ក) របស់តថាគត តថាគតសំដែងធម៌មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ដល់ឧបាសក ឧបាសិកាទាំងនោះ តថាគតក៏ប្រកាសព្រហ្មចរិយធម៌ប្រកបដោយអត្ថ ដោយព្យញ្ជនៈ បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលគាមណិ ព្រោះថាឧបាសកឧបាសិកាទាំងនុ៎ះ មានតថាគតជាទីពឹង មានតថាគតជាទីជ្រកកោន មានតថាគតជាទីពំនាក់ មានតថាគតជាទីរឭក ។ ម្នាលគាមណិ ពាងទឹកដែលធ្លុះ ទាំងជ្រាបរីង

ឯវមេវ មយ្ហំ អញ្ញតិត្ថិយា សមណព្រាហ្មណាបរិព្វាជកា តេសំ អហំ ធម្មំ ទេសេមិ អាទិកល្យាណំ មជ្ឈេ-កល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេមិ ។ តំ កិស្ស ហេតុ ។ អប្បេវនាម ឯកបទម្បិ អាជានេយ្យុំ តំ នេសំ អស្សស ទីឃរត្តំ ហិតាយ សុខាយាតិ ។

[២៤៩] ឯវំ វុត្តេ អសិពន្ធកបុត្តោ គាមណី ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ សត្តមំ ។

[២៥០] ឯកំ សមយំ ភគវា នាឡន្ទាយំ វិហរតិ បាវារិកម្ពវនេ ។ អថខោ អសិពន្ធកបុត្តោ គាមណី

ដូចពួកសមណព្រាហ្មណបរិព្វាជក ជាអន្យតិរ្ថិយ (ដែលចូលមកជាសាវ័ក) របស់តថាគត តថាគតសំដែងធម៌មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ដល់សមណព្រាហ្មណ៍ទាំងនោះ តថាគតក៏ប្រកាសព្រហ្មចរិយធម៌ដ៏ប្រកបដោយអត្ថ ដោយព្យញ្ជនៈ បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះថា (តថាគតគិតថា) នឹងធ្វើម្តេចហ្ន៎ ទើបពួកសត្វដឹងច្បាស់នូវធម៌សូម្បីតែមួយទេ ការដឹងច្បាស់នោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាអង្វែង ដល់សមណព្រាហ្មណបរិព្វាជកទាំងនោះ ។

[២៤៩] លុះព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ អសិពន្ធកបុត្តគាមណី ក៏សរសើរព្រះមានព្រះភាគដូច្នេះថា ភ្លឺច្បាស់ណាស់ព្រះអង្គ ។ បេ ។ សូមព្រះអង្គចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមទៅ ។ ចប់សូត្រទី ៧ ។

[២៥០] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងបាវារិកម្ពវ័ន ជិតក្រុងនាឡន្ទា ។ គ្រានោះ គាមណីឈ្មោះអសិពន្ធកបុត្ត

និគ្គណ្ឋសាវកោ យេន ភគវា តេនុបសង្កមិ ឧបសង្ក-
មិត្វា ។ បេ ។ ឯកមន្តំ និសិន្នំ ខោ អសិពន្ធកបុត្តំ
គាមណឹ ភគវា ឯតទវោច កថំ នុ ខោ គាមណិ
និគ្គណ្ឋោ នាដបុត្តោ សាវកានំ ធម្មំ ទេសេតីតិ ។
ឯវំ ខោ ភន្តេ និគ្គណ្ឋោ នាដបុត្តោ សាវកានំ ធម្មំ
ទេសេតិ យោ កោចិ បាណំ អតិមាបេតិ[១] សព្វោ
សោ អាបាយិកោ នេរយិកោ យោ កោចិ អទិន្នំ
អាទិយតិ សព្វោ សោ អាបាយិកោ នេរយិកោ យោ
កោចិ កាមេសុ មិច្ឆាចរតិ សព្វោ សោ អាបាយិកោ
នេរយិកោ យោ កោចិ មុសា ភណតិ សព្វោ សោ
អាបាយិកោ នេរយិកោ យំ ពហុលំ យំ ពហុលំ
វិហរតិ តេន តេន និយ្យតីតិ ។ ឯវំ ខោ ភន្តេ
និគ្គណ្ឋោ នាដបុត្តោ សាវកានំ ធម្មំ ទេសេតីតិ ។

---

១ ម. អតិបាតេតិ ។

គាមណិសំយុត្ត

ជាសាវ័ករបស់និគ្រន្ថ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ លុះអសិពន្ធកបុត្តគាមណីអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគក៏ត្រាស់សួរដូច្នេះថា ម្នាលគាមណី និគ្គណ្ឋនាដបុត្ត រមែងសំដែងធម៌ដូចម្ដេចដល់ពួកសាវ័ក ។ បពិត្រព្រះអង្គដ៏ចម្រើន និគ្គណ្ឋ-នាដបុត្ត រមែងសំដែងធម៌ដល់ពួកសាវ័កយ៉ាងនេះថា បុគ្គលឯណាមួយសម្លាប់សត្វ បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក បុគ្គលឯណាមួយកាន់យកទ្រព្យដែលគេមិនឲ្យ បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក បុគ្គលឯណាមួយប្រព្រឹត្តខុសក្នុងកាមទាំងឡាយ បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក បុគ្គលឯណាមួយនិយាយកុហក បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក កម្មឯណាៗ ច្រើនជាង កម្មនោះៗ តែងនាំបុគ្គលទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន និគ្គណ្ឋនាបុត្តតែងសំដែងធម៌ដល់ពួកសាវ័កយ៉ាងនេះឯង ។

[២៥១] យំ ពហុលំ យំ ពហុលំ ច កាមណិ វិហរតិ តេន តេន និយ្យតីតិ ។ ឯវំ សន្តេ ន កោចិ អាចាយិកោ នេរយិកោ ភវិស្សតិ យថា និគណ្ឋស្ស នាដបុត្តស្ស វចនំ ។ តំ កឹ មញ្ញសិ កាមណិ យោ សោ បុរិសោ បាណាតិបាតី រត្តិយា វា ទិវសស្ស វា សមយាសមយំ ឧបាទាយ កតមោ ពហុតរោ សមយោ យំ សោ[១] បាណំ អតិមាបេតិ យំ វា សោ បាណំ នាតិមាបេតីតិ ។ យោ សោ ភន្តេ បុរិសោ បាណាតិបាតី រត្តិយា វា ទិវសស្ស វា សមយាសមយំ ឧបាទាយ អប្បតរោ សោ សមយោ យំ សោ បាណំ អតិមាបេតិ ។ អថខោ ស្វេវ ពហុតរោ សមយោ យំ សោ បាណំ នាតិមាបេតីតិ ។ យំ ពហុលំ យំ ពហុលំ ច កាមណិ វិហរតិ តេន តេន និយ្យតីតិ ។ ឯវំ សន្តេ ន កោចិ អាចាយិកោ នេរយិកោ ភវិស្សតិ យថា និគណ្ឋស្ស នាដបុត្តស្ស វចនំ ។

---

១ យំ សោ ។

[២៥១] ម្នាលគាមណិ កម្មឯណាៗ ដែលច្រើនជាង កម្មនោះៗ តែងនាំបុគ្គលទៅ ។ កាលបើយ៉ាងនេះ មិនមានបុគ្គលណាម្នាក់ទៅកើតក្នុងអបាយ ទៅកើតក្នុងនរកទេ បើតាមពាក្យរបស់និគ្គណ្ឋនាដបុត្ត ។ ម្នាលគាមណិ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច បុរសឯណាជាអ្នកសម្លាប់សត្វ ក្នុងវេលាយប់ឬវេលាថ្ងៃ ដោយប្រកាន់សម័យគួរនិងមិនគួរ ចុះសម័យដែលបុរសនោះសម្លាប់សត្វ និងសម័យដែលមិនសម្លាប់សត្វ តើសម័យណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសឯណាជាអ្នកសម្លាប់សត្វ ក្នុងវេលាយប់ឬវេលាថ្ងៃ ដោយប្រកាន់សម័យគួរនិងមិនគួរ ឯសម័យដែលបុរសនោះសម្លាប់សត្វ តិចជាង ។ សម័យដែលបុរសមិនសម្លាប់សត្វនោះ ច្រើនជាងដោយពិត ។ ម្នាលគាមណិ កម្មឯណាៗ ច្រើនជាង កម្មនោះៗ តែនាំបុគ្គលទៅ ។ កាលបើយ៉ាងនេះ មិនមានបុគ្គលណាម្នាក់ទៅកើតក្នុងអបាយ ទៅកើតក្នុងនរកទេ បើតាមពាក្យរបស់និគ្គណ្ឋនាដបុត្ត ។

គាមណិសំយុត្តំ

[២៤២] តំ កឹ មញ្ញសិ គាមណិ យោ សោ បុរិសោ អធិដ្ឋាធាយី រត្តិយា វា ទិវសស្ស វា សមយាសមយំ ឧបាទាយ កតមោ ពហុតរោ សមយោ យំ សោ អទិន្នំ អាទិយតិ យំ វា សោ អទិន្នំ នាទិយតីតិ ។ យោ សោ ភន្តេ បុរិសោ អធិដ្ឋាធាយី រត្តិយា វា ទិវ-សស្ស វា សមយាសមយំ ឧបាទាយ អប្បតរោ សោ សមយោ យំ សោ អទិន្នំ អាទិយតីតិ ។ អថខោ ស្វេវ ពហុតរោ សមយោ យំ សោ អទិន្នំ នាទិយ-តីតិ ។ យំ ពហុលំ យំ ពហុលំ ច គាមណិ វិហារតិ តេន តេន និយ្យតីតិ ។ ឯវំ សន្តេ ន កោចិ អា-បាយិកោ នេរយិកោ ភវិស្សតិ យថា និគ្គណ្ឋស្ស នាដបុត្តស្ស វចនំ ។

គាមណិសំយុត្ត

[២៥២] ម្នាលគាមណី អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសឯណាជាអ្នកកាន់យកទ្រព្យដែលគេមិនឲ្យ ក្នុងវេលាយប់ឬវេលាថ្ងៃ ដោយប្រកាន់សម័យគួរនិងមិនគួរ ចុះសម័យដែលបុរសនោះកាន់យកទ្រព្យដែលគេមិនឲ្យ និងសម័យដែលមិនបានកាន់យកទ្រព្យដែលគេមិនឲ្យ តើសម័យណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសឯណាជាអ្នកកាន់យកទ្រព្យដែលគេមិនឲ្យ ក្នុងវេលាយប់ឬវេលាថ្ងៃ ដោយប្រកាន់សម័យគួរនិងមិនគួរ ឯសម័យដែលបុរសនោះកាន់យកទ្រព្យដែលគេមិនឲ្យ តិចជាង ។ សម័យដែលបុរសនោះកាន់យកទ្រព្យដែលគេមិនឲ្យច្រើនជាងដោយពិត ។ ម្នាលគាមណី កម្មឯណាៗច្រើនជាង កម្មនោះៗតែងនាំបុគ្គលទៅ ។ កាលបើយ៉ាងនេះ មិនមានបុគ្គលណាម្នាក់ទៅកើតក្នុងអបាយ ទៅកើតក្នុងនរកទេ បើតាមពាក្យរបស់និគណ្ឋនាដបុត្ត ។

[២៨៣] តំ កឹ មញ្ញសិ គាមណិ យោ សោ បុរិសោ កាមេសុ មិច្ឆាចារី រត្តិយា វា ទិវសស្ស វា សមយាសមយំ ឧបាទាយ កតមោ ពហុតរោ សម-យោ យំ សោ កាមេសុ មិច្ឆាចរតិ យំ វា សោ កាមេសុ មិច្ឆា ន ចរតីតិ ។ យោ សោ ភន្តេ បុរិសោ កាមេសុ មិច្ឆាចារី រត្តិយា វា ទិវសស្ស វា សមយាសមយំ ឧបាទាយ អប្បតរោ សោ សមយោ យំ សោ កាមេសុ មិច្ឆាចរតិ ។ អថខោ ស្វេវ ពហុ-តរោ សមយោ យំ សោ កាមេសុ មិច្ឆា ន ចរតីតិ ។ យំ ពហុលំ យំ ពហុលំ ច គាមណិ វិហរតិ តេន តេន និយ្យតីតិ ។ ឯវំ សន្តេ ន កោចិ អាបាយិកោ នេរយិកោ ភវិស្សតិ យថា និគ្គណ្ឋស្ស នាដបុត្តស្ស វចនំ ។

[២៥៣] ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសឯណា ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ក្នុងវេលាយប់ឬវេលាថ្ងៃ ដោយប្រកាន់សម័យគួរនិងមិនគួរ ចុះសម័យដែលបុរសនោះប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និងសម័យដែលមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ តើសម័យណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសឯណាជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ក្នុងវេលាយប់ឬវេលាថ្ងៃ ដោយប្រកាន់សម័យគួរនិងមិនគួរ ឯសម័យដែលបុរសនោះប្រព្រឹត្តខុសក្នុងកាមទាំងឡាយ តិចជាង ។ សម័យដែលបុរសនោះ មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ច្រើនជាងដោយពិត ។ ម្នាលគាមណិ កម្មឯណាៗ ច្រើនជាង កម្មនោះៗ តែងនាំបុគ្គលទៅ ។ កាលបើយ៉ាងនេះ មិនមានបុគ្គលណាម្នាក់ទៅកើតក្នុងអបាយ ទៅកើតក្នុងនរកទេ បើតាមពាក្យរបស់និគ្គណ្ឋនាដបុត្ត ។

គាមណិសំយុត្តំ

[២៤៨] តំ កឹ មញ្ញសិ គាមណិ យោ សោ បុរិ-
សោ មុសាវាទី រត្តិយា វា ទិវសស្ស វា សមយាសម-
យំ ឧបាទាយ កតមោ ពហុតរោ សមយោ យំ សោ
មុសា ភណតិ យំ វា សោ មុសា ន ភណតីតិ ។
យោ សោ ភន្តេ បុរិសោ មុសាវាទី រត្តិយា វា ទិវ-
សស្ស វា សមយាសមយំ ឧបាទាយ អប្បតរោ សោ
សមយោ យំ សោ មុសា ភណតិ ។ អថខោ ស្វេវ
ពហុតរោ សមយោ យំ សោ មុសា ន ភណតីតិ ។
យំ ពហុលំ យំ ពហុលំ ច គាមណិ វិហរតិ តេន
តេន និយ្យតីតិ ។ ឯវំ សន្តេ ន កោចិ អាបាយិកោ
នេរយិកោ ភវិស្សតិ យថា និគ្គណ្ឋស្ស នាដបុត្តស្ស
វចនំ ។

[២៤៩] ឥធ គាមណិ ឯកច្ចោ សត្ថា ឯវំ-
វាទី ហោតិ ឯវំទិដ្ឋិ យោ កោចិ បាណមតិមាបេតិ
សព្វោ សោ អាបាយិកោ នេរយិកោ យោ កោចិ

គាមណិសំយុត្ត

[២៥៨] ម្នាលគាមណី អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសឯណាជាអ្នកនិយាយកុហក ក្នុងវេលាយប់ឬវេលាថ្ងៃ ដោយប្រកាន់សម័យគួរនិងមិនគួរ ចុះសម័យដែលបុរសនោះនិយាយកុហកនិងមិននិ-យាយកុហក តើសម័យណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសឯណាជាអ្នកនិយាយកុហក ក្នុងវេលាយប់ឬវេលាថ្ងៃ ដោយប្រកាន់សម័យគួរនិងមិនគួរ ឯសម័យដែលបុរសនោះនិយាយកុហក តិចជាង ។ សម័យដែលបុរសនោះមិននិយាយកុហក ច្រើនជាងដោយពិត ។ ម្នាលគាមណី កម្មឯណាៗច្រើនជាង កម្មនោះៗតែងនាំបុគ្គលទៅ ។ កាលបើយ៉ាងនេះ មិនមានបុគ្គលណាម្នាក់ទៅកើតក្នុងអបាយ ទៅកើតក្នុងនរកទេ បើតាមពាក្យរបស់និគ្គណ្ឋនាដបុត្ត ។

[២៥៩] ម្នាលគាមណី គ្រូពួកខ្លះក្នុងលោកនេះ ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណាមួយសម្លាប់សត្វ បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក បុគ្គលឯណាមួយ

អទិន្នំ អាទិយតិ សព្វោ សោ អាចាយិកោ នេរយិកោ យោ កោចិ កាមេសុ មិច្ឆាចរតិ សព្វោ សោ អាចាយិកោ នេរយិកោ យោ កោចិ មុសា ភណតិ សព្វោ សោ អាចាយិកោ នេរយិកោតិ ។

[២៤៦] តស្មឹ ខោ បន គាមណិ សត្ថរិ សាវកោ អភិប្បសន្នោ ហោតិ តស្ស ឯវំ ហោតិ មយ្ហំ ខោ សត្ថា ឯវំវាទី ឯវំទិដ្ឋិ យោ កោចិ បាណមតិបាតេតិ សព្វោ សោ អាចាយិកោ នេរយិកោតិ ។ អត្ថិ ខោ បន មយា បាណោ អតិបាតិតោ អហំបម្ហិ អាចាយិកោ នេរយិកោតិ ទិដ្ឋឹ បដិលភតិ តំ គាមណិ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ[១] និក្ខិត្តោ ឯវំ និរយេ ។ មយ្ហំ ខោ សត្ថា ឯវំវាទី ឯវំទិដ្ឋិ យោ កោចិ អទិន្នំ អាទិយតិ សព្វោ សោ អាចាយិកោ នេរយិកោតិ ។ អត្ថិ ខោ បន មយា អទិន្នំ អាទិយតិ អហំបម្ហិ អាចាយិកោ

១ ឱ. យថាហតំ ។

កាន់យកទ្រព្យដែលគេមិនឲ្យ បុគ្គលទាំងអស់នោះ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក បុគ្គលឯណាមួយប្រព្រឹត្តខុសក្នុងកាមទាំងឡាយ បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក បុគ្គលឯណាមួយនិយាយកុហក បុគ្គលទាំងអស់នោះ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ។

[២៥៦] ម្នាលគាមណិ សាវ័កដែលមានសេចក្តីជ្រះថ្លាក្រៃពេកនឹងគ្រូនោះ សាវ័កនោះរមែងយល់យ៉ាងនេះថា គ្រូរបស់អញមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណាមួយសម្លាប់សត្វ បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ។ ម្នាលគាមណិ សាវ័កនោះរមែងមានសេចក្តីយល់ថា ចំណែកអញបានសម្លាប់សត្វហើយ អញត្រូវទៅកើតក្នុងអបាយ ទៅកើតក្នុងនរកមិនខាន ហើយមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ មិនរលាស់ទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទម្លាក់ ។ គ្រូរបស់អញមានវាទយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណាមួយកាន់យកទ្រព្យដែលគេមិនបានឲ្យ បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ។ ម្នាលគាមណិ សាវ័កនោះរមែងមានសេចក្តីយល់ថា ចំណែកអញបានកាន់យកទ្រព្យដែលគេមិនឲ្យហើយ អញត្រូវទៅកើតក្នុងអបាយ

គាមណិសំយុត្តំ

នេរយិកោតិ ទិដ្ឋឹ បដិលភតិ តំ គាមណិ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ មយ្ហំ ខោ សត្ថា ឯវំវាទី ឯវំទិដ្ឋិ យោ កោចិ កាមេសុ មិច្ឆាចរតិ សព្វោ សោ អាបាយិកោ នេរយិកោតិ ។ អត្ថិ ខោ បន មយា កាមេសុ មិច្ឆាចារោ ចិណ្ណោ អហំបម្ហិ អាបាយិកោ នេរយិកោតិ ទិដ្ឋឹ បដិលភតិ តំ គាមណិ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ មយ្ហំ ខោ សត្ថា ឯវំវាទី ឯវំទិដ្ឋិ យោ កោចិ មុសា ភណតិ សព្វោ សោ អាបាយិកោ នេរយិកោតិ ។ អត្ថិ ខោ បន មយា មុសា ភណិតំ អហំបម្ហិ អាបាយិកោ នេរយិកោតិ ទិដ្ឋឹ បដិលភតិ តំ គាមណិ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

ទៅកើតក្នុងនរកមិនខាន ហើយមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ មិនរលាស់ទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទម្លាក់ ។ គ្រូរបស់អញមានវាទយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណាមួយប្រព្រឹត្តខុសក្នុងកាមទាំងឡាយ បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ។ ម្នាលគាមណិ សាវ័កនោះរមែងមានសេចក្តីយល់ថា ចំណែកអញបានសន្សំការប្រព្រឹត្តខុសក្នុងកាមទាំងឡាយហើយ អញត្រូវទៅកើតក្នុងអបាយ ទៅកើតក្នុងនរកមិនខាន ហើយមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ មិនរលាស់ទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទម្លាក់ ។ គ្រូរបស់អញមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណាមួយនិយាយកុហក បុគ្គលទាំងអស់នោះតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ។ ម្នាលគាមណិ សាវ័កនោះរមែងមានសេចក្តីយល់ថា ចំណែកអញបាននិយាយពាក្យកុហកហើយ អញត្រូវទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ហើយមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ មិនរលាស់ទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទម្លាក់ ។

[២៨៧] ឥធ បន គាមណិ តថាគតោ លោកេ ឧបបជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ។ សោ អនេកបរិយា-យេន ចាណាតិចាតំ គរហតិ វិគរហតិ ចាណាតិចាតា វិរមថាតិ ចាហ អទិន្នាទានំ គរហតិ វិគរហតិ អទិន្នា-ទានា វិរមថាតិ ចាហ កាមេសុ មិច្ឆាចារំ គរហតិ វិគរហតិ កាមេសុ មិច្ឆាចារា វិរមថាតិ ចាហ មុសា-វាទំ គរហតិ វិគរហតិ មុសាវាទា វិរមថាតិ ចាហ ។ តស្មឹ ខោ បន គាមណិ សត្ថរិ សាវកោ អភិប្ប-សន្នោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ ភគវា ខោ អនេកបរិយាយេន ចាណាតិចាតំ គរហតិ វិគរហតិ

[២៥៧] ម្នាលគាមណិ ចំណែកខាងព្រះតថាគត ជាអ្នកឆ្ងាយចាកសឹកសត្រូវគឺកិលេស ត្រាស់ដឹងដោយប្រពៃចំពោះខ្លួន បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ដឹងច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ជាសារថីទូន្មាននូវបុរសជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវសច្ចធម៌ មានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ បានកើតឡើងហើយក្នុងលោកនេះ ។ ព្រះតថាគតនោះ តែងបន្ទោស បន្ទុះបង្អាប់ នូវបាណាតិបាតផង សំដែងប្រាប់ថា ចូរអ្នកទាំងឡាយវៀរចាកបាណាតិបាតផង តែងបន្ទោស បន្ទុះបង្អាប់ នូវអទិន្នាទានផង សំដែងប្រាប់ថា ចូរអ្នកទាំងឡាយ វៀរចាកអ-ទិន្នាទានផង តែងបន្ទោស បន្ទុះបង្អាប់ នូវកាមេសុមិច្ឆាចារផង សំដែងប្រាប់ថា ចូរអ្នកទាំងឡាយវៀរចាកកាមេសុមិច្ឆាចារផង តែងបន្ទោស បន្ទុះបង្អាប់ នូវមុសាវាទផង សំដែងប្រាប់ថា ចូរអ្នកទាំងឡាយ វៀរចាកមុសាវាទផង ដោយអនេកបរិយាយ ។ ម្នាលគាមណិ សាវ័កក៏មានសេចក្តីជ្រះថ្លានឹងព្រះសាស្តានោះឯង ។ សាវ័កនោះ ពិចារណាដូច្នេះថា ព្រះមានព្រះភាគតែងបន្ទោស បន្ទុះបង្អាប់ នូវបាណាតិបាតផង

បាណាតិបាតា វិរមថាតិ ចាហ ។ អត្ថិ ខោ បន មយា បាណោ អតិមាបិតោ យាវតកោ វា តាវ-តកោ វា យោ ខោ បន មយា បាណោ អតិមាបិតោ យាវតកោ វា តាវតកោ វា តំ ន សុដ្ឋុ តំ ន សាធុ អហញ្ចេវ ខោ បន តប្បច្ចយា វិប្បដិសារី អស្សំ ន មេ តំ បាបកម្មំ អកាតំ ភវិស្សតីតិ ។ សោ ឥតិ បដិសង្ខាយ តញ្ចេវ បាណាតិបាតំ បជហាតិ អាយ-តិញ្ច បាណាតិបាតា បដិវិរតោ ហោតិ ។ ឯវមេតស្ស បាបស្ស កម្មស្ស បហានំ ហោតិ ឯវមេតស្ស បា-បស្ស កម្មស្ស សមតិក្កមោ ហោតិ ។

[២៤៨] ភគវា ខោ អនេកបរិយាយេន អទិន្នាទានំ គរហតិ វិគរហតិ អទិន្នាទានា វិរមថាតិ ចាហ ។ អត្ថិ ខោ បន មយា អទិន្នំ អាទិន្នំ យាវតកំ វា តាវ-

សំដែងប្រាប់ថា ចូរអ្នកទាំងឡាយវៀរចាកបាណាតិបាតផង ដោយអនេកបរិយាយ ។ ឯអញបានសម្លាប់សត្វតាមតែប្រទះ សត្វដែលអញសម្លាប់ទាំងប៉ុន្មាន អំពើនោះមិនល្អ អំពើនោះមិនប្រពៃទេ អញមុខជាមានសេចក្ដីក្ដៅក្រហាយព្រោះកម្មនោះជាបច្ច័យមិនខាន បាបកម្មនោះអញមិនមែនជាមិនធ្វើឡើយ ។ លុះសាវ័កនោះ ពិចារណាដូច្នេះហើយក៏លះបង់នូវបាណាតិបាតនោះចេញផង វៀរចាកបាណាតិបាតតទៅទៀតផង ។ ឯការលះបង់បាបកម្មនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ការកន្លងផុតបាបកម្មនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

[២៥៨] ព្រះមានព្រះភាគតែងបន្ទោស បន្ដុះបង្អាប់ នូវអទិន្នាទានផង សំដែងប្រាប់ថា ចូរអ្នកទាំងឡាយវៀរចាកអទិន្នាទានផង ដោយអនេកបរិយាយ ។ ឯអញបានកាន់យកទ្រព្យដែលគេមិនឲ្យតាមតែ

តកំ វា យំ ខោ បន មយា អទិន្នំ អាទិន្នំ យាវតកំ វា តាវតកំ វា តំ ន សុដ្ឋុ តំ ន សាធុ អហញ្ចេវ ខោ បន តប្បច្ចយា វិប្បដិសារី អស្សំ ន មេ តំ បាបកម្មំ អកតំ ភវិស្សតីតិ ។ សោ ឥតិ បដិសង្ខាយ តញ្ចេវ អទិន្នាទានំ បជហតិ អាយតិញ្ច អទិន្នាទានា បដិវិរតោ ហោតិ ។ ឯវមេតស្ស បាបស្ស កម្មស្ស បហានំ ហោតិ ឯវមេតស្ស បាបស្ស កម្មស្ស សមតិក្កមោ ហោតិ ។

[២៤៩] ភគវា ខោ អនេកបរិយាយេន កាមេសុ មិច្ឆាចារំ គរហតិ វិគរហតិ កាមេសុ មិច្ឆាចារា វិរមថាតិ ចាហ ។ អត្ថិ ខោ បន មយា កាមេសុ មិច្ឆា ចិណ្ណំ(១) យាវតកំ វា តាវតកំ វា យំ ខោ បន មយា កាមេសុ មិច្ឆា ចិណ្ណំ យាវតកំ វា តាវតកំ វា តំ ន សុដ្ឋុ តំ ន សាធុ អហញ្ចេវ ខោ បន តប្បច្ចយា វិប្បដិសារី អស្សំ ន មេ តំ បាបកម្មំ

១ ម. មិច្ឆាចារា ចិណ្ណំ ។

ប្រទះ ទ្រព្យដែលអញបានកាន់យកហើយទាំងប៉ុន្មាន អំពើនោះមិនល្អ អំពើនោះមិនប្រពៃទេ អញមុខជាមានសេចក្តីក្តៅក្រហាយព្រោះកម្មនោះជាបច្ច័យមិនខាន បាបកម្មនោះ អញមិនមែនជាមិនធ្វើឡើយ ។ លុះសាវ័កនោះពិចារណាដូច្នេះហើយ ក៏លះបង់នូវអទិន្នាទាននោះចេញផង វៀរចាកអទិន្នាទានតទៅទៀតផង ។ ឯការលះបង់បាបកម្មនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ការកន្លងផុតបាបកម្មនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

[២៥៩] ព្រះមានព្រះភាគតែងបន្ទោស បន្ទុះបង្អាប់ នូវកាមេសុមិច្ឆាចារផង សំដែងប្រាប់ថា ចូរអ្នកទាំងឡាយវៀរចាកកាមេសុមិច្ឆាចារផង ដោយអនេកបរិយាយ ។ ឯអញបានសន្សំការប្រព្រឹត្តខុសក្នុងកាមទាំងឡាយតាមតែប្រទះ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយដែលអញសន្សំទាំងប៉ុន្មាន អំពើនោះមិនល្អ អំពើនោះមិនប្រពៃទេ អញមុខជាមានសេចក្តីក្តៅក្រហាយព្រោះកម្មនោះជាបច្ច័យមិនខាន បាបកម្មនោះ

អកតំ ភវិស្សតីតិ ។ សោ ឥតិ បដិសង្ខាយ តញ្ចេវ កាមេសុ មិច្ឆាចារំ បជហតិ អាយតិញ្ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ។ ឯវមេតស្ស បាបស្ស កម្មស្ស បហានំ ហោតិ ឯវមេតស្ស បាបស្ស កម្មស្ស សមតិក្កមោ ហោតីតិ ។

[២៦០] ភគវា ខោ បន អនេកបរិយាយេន មុសាវាទំ គរហតិ វិគរហតិ មុសាវាទា វិរមថាតិ ចាហ ។ អត្ថិ ខោ បន មយា មុសា ភណិតំ យាវតកំ វា តាវតកំ វា យំ ខោ បន មយា មុសា ភណិតំ យាវតកំ វា តាវតកំ វា តំ ន សុដ្ឋុ តំ ន សាធុ អហញ្ចេវ ខោ បន តប្បច្ចយា វិប្បដិសារី អស្សំ ន មេ តំ បាបកម្មំ អកតំ ភវិស្សតីតិ ។ សោ ឥតិ បដិសង្ខាយ តញ្ចេវ មុសាវាទំ បជហតិ អាយតិញ្ច មុសាវាទា បដិវិរតោ ហោតិ ។ ឯវមេតស្ស បាបស្ស កម្មស្ស បហានំ ហោតិ ឯវមេតស្ស បាបស្ស កម្មស្ស សមតិក្កមោ ហោតិ ។

អញមិនមែនជាមិនធ្វើឡើយ ។ លុះសាវ័កនោះ ពិចារណាដូច្នេះហើយ ក៏លះបង់នូវកាមេសុមិច្ឆាចារនោះផង វៀរចាកកាមេសុមិច្ឆាចារតទៅទៀតផង ។ ឯការលះបង់នូវបាបកម្មនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ការកន្លងផុតបាបកម្មនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

[២៦០] ព្រះមានព្រះភាគតែងបន្ទោស បន្តុះបង្អាប់ នូវមុសាវាទផង សំដែងប្រាប់ថា ចូរអ្នកទាំងឡាយវៀរចាកមុសាវាទផង ដោយអនេកបរិយាយ ។ ឯអញបាននិយាយកុហកតាមតែប្រទះ ពាក្យដែលអញបាននិយាយកុហកទាំងប៉ុន្មាន ពាក្យនោះមិនល្អ ពាក្យនោះមិនប្រពៃទេ អញមុខជាមានសេចក្ដីក្ដៅក្រហាយព្រោះកម្មនោះជាបច្ច័យមិនខាន បាបកម្មនោះ អញមិនមែនជាមិនធ្វើឡើយ ។ លុះសាវ័កនោះពិចារណាដូច្នេះហើយ ក៏លះបង់នូវមុសាវាទនោះផង វៀរចាកមុសាវាទតទៅទៀតផង ។ ឯការលះបង់បាបកម្មនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ការកន្លងផុតបាបកម្មនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

[២៦១] សោ បាណាតិបាតំ បហាយ បាណាតិ-
បាតា បដិវិរតោ ហោតិ អទិន្នាទានំ បហាយ អទិន្នា-
ទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារំ បហាយ
កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទំ
បហាយ មុសាវាទា បដិវិរតោ ហោតិ បិសុណំ វាចំ
បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសំ
វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ
សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ
អភិជ្ឈំ បហាយ អនភិជ្ឈាលុ ហោតិ ព្យាបាទប្បទោ-
សំ បហាយ អព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋឹ បហា-
យ សម្មាទិដ្ឋិកោ ហោតិ ។ ស ខោ សោ គាមណិ
អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អ-
សម្មូឡ្ហោ សម្បជានោ បដិស្សតោ មេត្តាសហគតេន
ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ ។

[២៦១] សាវ័កនោះលះបង់បាណាតិបាត វៀរចាកបាណាតិបាត លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ លះបង់មុសាវាទ វៀរចាកមុសាវាទ លះបង់បិសុ-ណាវាចា វៀរចាកបិសុណាវាចា លះបង់ផរុសវាចា វៀរចាកផរុសវាចា លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ លះបង់អភិជ្ឈា មិនមានអភិជ្ឈា លះបង់ព្យាបាទប្រទូស្ត មានចិត្តមិនព្យាបាទ លះបង់មិច្ឆាទិដ្ឋិ មានចិត្តជាសម្មាទិដ្ឋិ ។ ម្នាលគាមណិ លុះអរិយសាវ័កនោះឯង ជាអ្នកប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទយ៉ាងនេះហើយ ក៏ជាអ្នកមិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ។

តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សេយ្យថាបិ គាមណិ ពលវា សង្ខធមោ អប្បកសិរេនេវ ចតុទ្ទិសា វិញ្ញា-បេយ្យ ។ ឯវមេវ ខោ គាមណិ ឯវំ ភាវិតាយ មេត្តាយ ចេតោវិមុត្តិយា ឯវំ ពហុលីកតាយ យំ បមាណកតំ កម្មំ ន តំ តត្រាវសិស្សតិ ន តំ តត្រាវតិដ្ឋតិ ។ ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ ករុណាសហគតេន ចេតសា ។ មុទិតាសហគតេន ចេតសា ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ ។ តថា តតិយំ ។

ទិសទី ៣ ដូចគ្នា ។ ទិសទី ៤ ដូចគ្នា ។ មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយយកខ្លួនមកប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួងហើយសម្រេចសម្រាន្តនៅដោយប្រការដូច្នេះ ។ ម្នាលគាមណិ បុរសអ្នកផ្លុំស័ង្ខដ៏មានកម្លាំង តែងញ៉ាំងជនក្នុងទិសទាំង ៤ ឲ្យដឹងបានដោយមិនលំបាក យ៉ាងណាមិញ ។ ម្នាលគាមណិ មេត្តាចេតោវិមុត្តិកាលបើបុគ្គលបានចម្រើនយ៉ាងនេះហើយ ធ្វើឲ្យច្រើនយ៉ាងនេះហើយកាមាវចរកម្មឯណាដែលបុគ្គលធ្វើត្រូវប្រមាណ កម្មនោះមិនក្រាញនៅតែត្រឹមរូបារូបាវចរកម្មប៉ុណ្ណោះ មិនឋិតនៅតែត្រឹមរូបារូបាវចរកម្មប៉ុណ្ណោះទេ ក៏យ៉ាងនោះដែរ ។ ម្នាលគាមណិ លុះអរិយសាវកនោះឯងជាអ្នកប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទយ៉ាងនេះហើយ ក៏ជាអ្នកមិនមានសេចក្ដីវង្វេង មានសេចក្ដីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយករុណា ។ មានចិត្តប្រកបដោយមុទិតា ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ។ ទិសទី ៣ ដូចគ្នា ។

តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្ត-
តាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា
វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យា-
បជ្ឈេន ផរិត្វា វិហរតិ ។ សេយ្យថាបិ គាមណិ ពលវា
សង្ខធមោ អប្បកសិរេនេវ ចតុទ្ទិសា វិញ្ញាបេយ្យ ។
ឯវមេវ ខោ គាមណិ ឯវំ ភាវិតាយ ឧបេក្ខាយ ចេ-
តោវិមុត្តិយា ឯវំ ពហុលីកតាយ យំ បមាណកតំ
កម្មំ ន តំ តត្រាវសិស្សតិ ន តំ តត្រាវតិដ្ឋតីតិ ។
ឯវំ វុត្តេ អសិពន្ធកបុត្តោ គាមណី និគណ្ឋសាវកោ
ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ
។ បេ ។ ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បា-
ណុបេតំ សរណាគតន្តិ ។ អដ្ឋមំ ។

ទិសទី ៤ ដូចគ្នា ។ មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយយកខ្លួនមកប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ហើយសម្រេចសម្រាន្តនៅដោយប្រការដូច្នេះ ។ ម្នាលគាមណិ បុរសអ្នកផ្លុំស័ង្ខដ៏មានកម្លាំង តែងញុំាងជនក្នុងទិសទាំង ៤ ឲ្យដឹងបានដោយមិនលំបាក យ៉ាងណាមិញ ។ ម្នាលគាមណិ កាលបើឧបេក្ខាចេតោវិមុត្តិដែលបុគ្គលបានចម្រើនយ៉ាងនេះហើយ ធ្វើឲ្យច្រើនយ៉ាងនេះហើយ កាមាវចរកម្មឯណាដែលបុគ្គលធ្វើត្រូវប្រមាណ កម្មនោះមិនក្រាញនៅតែត្រឹមរូបារូបាវចរកម្មប៉ុណ្ណោះ មិនឋិតនៅតែត្រឹមរូបារូបាវចរកម្មប៉ុណ្ណោះទេ ក៏យ៉ាងនោះដែរ ។ កាលបើព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ អសិពន្ធកបុត្តគាមណិ ជាសាវ័ករបស់និគ្រន្ថ ក៏សរសើរព្រះមានព្រះភាគដូច្នេះថា ភ្លឺច្បាស់ណាស់ ព្រះអង្គ ភ្លឺច្បាស់ណាស់ ព្រះអង្គ ។ បេ ។ សូមព្រះមានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះតទៅ ។ ចប់សូត្រទី ៨ ។

គាមណិសំយុត្តំ

[២៦២] ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន នាឡន្ទា តទវសរិ ។ តត្រ សុទំ ភគវា នាឡន្ទាយំ វិហរតិ បាវារិកម្ពវនេ ។ តេន ខោ បន សមយេន នាឡន្ទា ទុព្ភិក្ខា ហោតិ ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា ។ តេន ខោ បន សមយេន និគណ្ឋោ នាដបុត្តោ នាឡន្ទាយំ បដិវសតិ មហតិយា និគណ្ឋបរិសាយ សទ្ធឹ ។ អថខោ អសិពន្ធកបុត្តោ គាមណី និគណ្ឋសាវកោ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អសិពន្ធកបុត្តំ គាមណឹ និគណ្ឋោ នាដបុត្តោ ឯតទវោច ឯហិ ត្វំ គាមណិ សមណស្ស គោតមស្ស វាទំ អារោបេហិ ឯវំ តេ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆិស្សតិ

គាមណិសំយុត្ត

[២៦២] *សម័យមួយ ព្រះមានព្រះភាគទ្រង់ត្រាស់ទៅកាន់ចារិកក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃជាច្រើន ទ្រង់ស្តេចទៅដល់ក្រុងនាឡន្ទា ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងបាវារិកម្ពវ័នជិតក្រុងនាឡន្ទានោះ ។ សម័យនោះឯង ក្រុងនាឡន្ទាកើតទុរ្ភិក្ស អ្នកស្រុកមានសេចក្តីធុញថប់ដោយហេតុពីរយ៉ាង[១] មានឆ្អឹងសដេរដាស[២] មានសំទូងដូចជាស្លាក[៣] ។ សម័យនោះ និគ្គណ្ឋនាដបុត្តក៏អាស្រ័យនៅជិតក្រុងនាឡន្ទាដែរ ព្រមដោយនិគ្គណ្ឋបរិសទ្យជាច្រើន ។ គ្រានោះ អសិពន្ធកបុត្តគាមណីជាសាវ័ករបស់និគ្រន្ថ ចូលទៅរកនិគ្គណ្ឋនាដបុត្ត លុះចូលទៅដល់ ក៏ថ្វាយបង្គំនិគ្គណ្ឋនាដបុត្តហើយ អង្គុយក្នុងទីសមគួរ ។ លុះអសិពន្ធកបុត្តគាមណីអង្គុយក្នុងទីសមគួរហើយ និគ្គណ្ឋនាដបុត្តក៏ពោលដូច្នេះថា ម្នាលគាមណី អ្នកចូរមក អ្នកចូរលើកវាទៈរបស់សមណគោតម កិត្តិសព្ទដ៏ពីរោះ នឹងខ្ចរខ្ចាយសាយឡើងដល់អ្នកយ៉ាងនេះថា*

---

១ ធុញថប់ដោយហេតុ ២ យ៉ាងគឺ ធុញថប់ថាយើងនឹងរស់ដែរឬ ១ ធុញថប់ថាយើងនឹងមិនរស់ទេ ។ ២ មនុស្សអ្នកក្រុងនាឡន្ទាអត់បាយ ស្លាប់ចោលឆ្អឹងសដេរដាស ។ ៣ សំទូងដែលគេស្ទូងក៏មិនលូតលាស់ល្អ ។ អដ្ឋកថា ។

អសិពន្ធកបុត្តេន គាមណិនា សមណស្ស គោតមស្ស ឯវំមហិទ្ធិកស្ស ឯវំមហានុភាវស្ស វាចោ អារោបិតោតិ ។ កថំ បនាហំ ភន្តេ សមណស្ស គោតមស្ស ឯវំមហិទ្ធិកស្ស ឯវំមហានុភាវស្ស វាចំ អារោបេមីតិ ។ ឯហិ ត្វំ គាមណិ យេន សមណោ គោតមោ តេនុបសង្កមិ ឧបសង្កមិត្វា សមណំ គោតមំ ឯវំ វទេហិ ននុ ភន្តេ ភគវា អនេកបរិយាយេន កុលានំ អនុទយំ វណ្ណេតិ អនុរក្ខំ វណ្ណេតិ អនុកម្បំ វណ្ណេតីតិ ។ សចេ តេ គាមណិ សមណោ គោតមោ ឯវំ បុដ្ឋោ ឯវំ ព្យាករោតិ ឯវំ គាមណិ តថាគតោ អនេកបរិយាយេន កុលានំ អនុទយំ វណ្ណេតិ អនុរក្ខំ វណ្ណេតិ អនុកម្បំ វណ្ណេតីតិ ។ តមេនំ ត្វំ ឯវំ វទេយ្យាសិ អថ កិញ្ចរហិ ភន្តេ ភគវា នាឡន្ទេ[១] ទុព្ភិក្ខេ ទ្វីហិតិកេ សេតដ្ឋិកេ សលាកាវុត្តេ មហតា ភិក្ខុសង្ឃេន សទ្ធឹ ចារិកញ្ចរតិ

១ ឱ. ម. នាឡន្ទេតិ បទំ នត្ថិ ។

អសិពន្ធកបុត្តគាមណី បានលើកវាទៈរបស់សមណគោតមដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ។ អសិពន្ធកបុត្តគាមណីសួរថាបពិត្រលោកដ៏ចម្រើន ចុះឲ្យខ្ញុំលើកវាទៈរបស់សមណគោតមដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ថាដូចម្តេច ។ ម្នាលគាមណី អ្នកចូរមក ចូរអ្នកចូលទៅរកសមណគោតម លុះចូលទៅដល់ហើយ សួរសមណគោតមយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងពណ៌នានូវសេចក្តីអាណិត ពណ៌នានូវការរក្សា ពណ៌នានូវសេចក្តីអនុគ្រោះ ដល់ត្រកូលទាំងឡាយដោយអនេកបរិយាយ មិនមែនទេឬ ។ ម្នាលគាមណី បើអ្នកសួរយ៉ាងនេះហើយ សមណគោតមមុខជាដោះស្រាយយ៉ាងនេះថា យ៉ាងហ្នឹងហើយ គាមណី ព្រះតថាគតតែងពណ៌នានូវសេចក្តីអាណិត ពណ៌នានូវការរក្សា ពណ៌នានូវការអនុគ្រោះដល់ត្រកូលទាំងឡាយដោយអនេកបរិយាយមែន ។ អ្នកត្រូវនិយាយនឹងសមណគោតមនោះយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើដូច្នោះ ម្តេចក៏ព្រះមានព្រះភាគព្រមដោយភិក្ខុសង្ឃជាច្រើន ត្រាច់ទៅកាន់ចារិកក្នុងក្រុងនាឡន្ទាដែលកំពុងកើតទុរ្ភិក្ស អ្នកស្រុកមានសេចក្តីធុញថប់ដោយហេតុ ២ យ៉ាង មានឆ្អឹងសដេរដាស មានសំទូងដូចជាស្លាក

ឧច្ឆេទាយ ភគវា កុលានំ បដិបន្នោ អនយាយ ភគវា កុលានំ បដិបន្នោ ឧបឃាតាយ ភគវា កុ-លានំ បដិបន្នោតិ ។ ឥមំ ខោ តេ គាមណិ សមណោ គោតមោ ឧភតោកោដិកំ បញ្ហំ បុដ្ឋោ នេវ សក្ខតិ ឧគ្គិលិតុំ នេវ សក្ខតិ ឱគិលិតុន្តិ ។

[២៦៣] ឯវំ ភន្តេតិ ខោ អសិពន្ធកបុត្តោ គាម-ណី និគណ្ឋស្ស នាដបុត្តស្ស បដិស្សុត្វា ឧដ្ឋាយាស-នា និគណ្ឋំ នាដបុត្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិ-វាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អសិពន្ធកបុត្តោ គាមណី ភគវន្តំ ឯតទវោច ននុ ភន្តេ ភគវា អនេកបរិយាយេន កុលានំ អនុទយំ វណ្ណេតិ អនុរក្ខំ វណ្ណេតិ អនុកម្បំ វណ្ណេតីតិ ។ ឯវំ គាមណិ តថាគតោ អនេកបរិយាយេន កុលានំ អនុ-ទយំ វណ្ណេតិ អនុរក្ខំ វណ្ណេតិ អនុកម្បំ វណ្ណេតីតិ ។

(ដូច្នេះ) ព្រះមានព្រះភាគឈ្មោះថា ប្រតិបត្តិដើម្បីផ្តាច់បង់នូវត្រកូលទាំង-ឡាយ ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីសេចក្តីវិនាសដល់ត្រកូលទាំង-ឡាយ ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីបៀតបៀនត្រកូលទាំងឡាយហើយ ។ ម្នាលគាមណិ សមណគោតម បើអ្នកសួរប្រស្នាមានចុងពីរបែបនេះហើយ ប្រាកដជាមិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន គឺថានឹងលេបទៅស្ទាក់ខ្ជាក់ទៅស្ទែងពុំខានឡើយ ។

[២៦៣] អសិពន្ធកបុត្តគាមណិ ទទួលស្តាប់ពាក្យរបស់និគណ្ឋ-នាដបុត្តថា ករុណា លោកម្ចាស់ ក៏ក្រោកចាកអាសនៈថ្វាយបង្គំនិគណ្ឋ-នាដបុត្ត ធ្វើប្រទក្សិណហើយចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះអសិពន្ធកបុត្តគាមណិអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងពណ៌នានូវសេចក្តីអាណិត ពណ៌នានូវការរក្សា ពណ៌នានូវសេចក្តីអនុគ្រោះ ដល់ត្រកូលទាំងឡាយ ដោយអនេកបរិយាយមែនឬ ។ យ៉ាងហ្នឹងហើយ គាមណិ ព្រះតថាគតតែងពណ៌នានូវសេចក្តីអាណិត ពណ៌នានូវការរក្សា ពណ៌នានូវសេចក្តីអនុគ្រោះ ដល់ត្រកូលទាំងឡាយដោយអនេកបរិយាយមែន ។

អថ ភិញ្ញរហិ ភន្តេ ភគវា នាឡន្ទេ ទុព្ភិក្ខេ ទ្វីហិ-
តិកេ សេតដ្ឋិកេ សលាកាវុត្តេ មហតា ភិក្ខុសង្ឃេន
សទ្ធឹ ចារិកំ ចរតិ ឧច្ឆេទាយ ភគវា កុលានំ បដិ-
បន្នោ អនយាយ ភគវា កុលានំ បដិបន្នោ ឧបឃា-
តាយ ភគវា កុលានំ បដិបន្នោតិ ។

[២៦៤] ឥតោ សោ គាមណិ ឯកនវុតោ កប្បោ
យមហំ អនុស្សរាមិ នាភិជានាមិ កិញ្ចិ កុលំ
បក្កភិក្ខាទានេន[១] ឧបហតបុព្វំ ។ អថ ខោ យានិ
តានិ កុលានិ អឌ្ឍានិ មហទ្ធនានិ មហាភោគានិ
បហូតជាតរូបរជតានិ បហូតវិត្តូបករណានិ បហូ-
តធនធញ្ញានិ សព្វានិ តានិ ទានសម្ភូតានិ ចេវ

១ ឱ. ម. បក្កភិក្ខានុបទានមត្តេន ។

បពិត្រព្រះអង្គដ៏ចម្រើន កាលបើដូច្នោះ ម្តេចក៏ព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃជាច្រើន ត្រាច់ទៅកាន់ចារិកក្នុងក្រុងនាឡន្ទា ដែលកំពុងកើតទុរ្ភិក្ស អ្នកស្រុកមានសេចក្តីធុញថប់ដោយហេតុពីរយ៉ាង មានឆ្អឹងសដេរដាស មានសំទូងដូចជាស្លាក (ដូច្នេះ) ព្រះមានព្រះភាគឈ្មោះថាប្រតិបត្តិដើម្បីផ្តាច់បង់នូវត្រកូលទាំងឡាយ ព្រះមានព្រះភាគប្រតិបត្តិដើម្បីសេចក្តីវិនាសដល់ត្រកូលទាំងឡាយ ព្រះមានព្រះភាគប្រតិបត្តិដើម្បីបៀតបៀនត្រកូលទាំងឡាយហើយ ។

[២៦៨] ម្នាលគាមណិ តថាគតរឭកឃើញ ៩១ កប្ប រាប់អំពីភទ្រកប្បនេះ (ទៅក្រោយវិញ) តថាគតមិនឃើញត្រកូលណាមួយដែលធ្លាប់គេបៀតបៀនព្រោះតែឲ្យទានបាយឆ្អិនស្រាប់ឡើយ ។ ដែលពិតនោះ គឺត្រកូលទាំងឡាយឯណា ស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន សម្បូរមាសប្រាក់ សម្បូរគ្រឿងឧបករណ៍ សម្បូរទ្រព្យនឹងស្រូវ ត្រកូលទាំងអស់នោះ សុទ្ធតែចុំច្មើងដោយសារឲ្យទានផង

សច្ចសម្ភូតានិ ច សញ្ញមសម្ភូតានិ ច ។ អដ្ឋ គាមណិ ហេតូ អដ្ឋ បច្ចយា កុលានំ ឧបឃាតាយ រាជតោ វា កុលានិ ឧបឃាតំ គច្ឆន្តិ ចោរតោ វា កុលានិ ឧបឃាតំ គច្ឆន្តិ អគ្គិតោ វា កុលានិ ឧបឃាតំ គច្ឆន្តិ ឧទកតោ វា កុលានិ ឧបឃាតំ គច្ឆន្តិ និហិតំ វា ឋានា វិគច្ឆតិ[១] ទុប្បយុត្តា វា កម្មន្តា វិបជ្ជន្តិ កុលេ វា កុលង្គារោតិ ឧប្បជ្ជន្តិ យោ តេ ភោគេ វិកិរតិ វិធមតិ វិទ្ធំសេតិ អនិច្ចតាយេវ អដ្ឋមីតិ ។ ឥមេ ខោ គាមណិ អដ្ឋ ហេតូ អដ្ឋ បច្ចយា កុលានំ ឧបឃាតាយ ។ ឥមេសុ ខោ គាមណិ អដ្ឋសុ ហេតូសុ អដ្ឋសុ បច្ចយេសុ[២] សំវិជ្ជមានេសុ យោ មំ ឯវំ វទេយ្យ ឧច្ឆេទាយ ភគវា កុលានំ បដិបន្នោ អឃាយ ភគវា កុលានំ បដិបន្នោ ឧបឃាតាយ ភគវា កុលានំ បដិបន្នោតិ ។ តំ គាមណិ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា

១ នាធិគច្ឆន្តិ ។ ២ ឯត្ថន្តរេ សន្តេសូតិបិ បាឋោ ហោតិ ។

ថ្កុំថ្កើងដោយសារសច្ចធម៌ផង ថ្កុំថ្កើងដោយសារការសង្រួមផង ។ ម្នាលគាមណី ហេតុ ៨ យ៉ាង បច្ច័យ ៨ យ៉ាង ដែលប្រព្រឹត្តទៅដើម្បីបៀតបៀនត្រកូលទាំងឡាយ គឺត្រកូលដល់នូវការបៀតបៀនអំពីព្រះរាជា ១ ត្រកូលដល់នូវការបៀតបៀនអំពីចោរ ១ ត្រកូលដល់នូវការបៀតបៀនអំពីភ្លើង ១ ត្រកូលដល់នូវការបៀតបៀនអំពីទឹក ១ ទ្រព្យដែលត្រកូលកប់ទុកវិនាសបាត់ចាកកន្លែង ១ ការងារដែលត្រកូលប្រកបខុសរមែងវិនាសទៅ ១ សេចក្តីបាក់បែកត្រកូលកើតឡើងក្នុងត្រកូល ១ បុគ្គលឯណាពោយរាយខ្ជះខ្ជាយបំផ្លាញភោគសម្ប័ទ ភោគសម្ប័ទរបស់បុគ្គលនោះជារបស់មិនទៀង ១ គ្រប់ជា ៨ ។ ម្នាលគាមណី នេះឯង ជាហេតុ ៨ យ៉ាង បច្ច័យ ៨ យ៉ាង ប្រព្រឹត្តទៅដើម្បីបៀតបៀនត្រកូលទាំងឡាយ ។ ម្នាលគាមណី កាលបើមានហេតុ ៨ យ៉ាង បច្ច័យ ៨ យ៉ាងនេះហើយ បុគ្គលឯណានិយាយចំពោះតថាគតយ៉ាងនេះថា ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីផ្តាច់បង់នូវត្រកូលទាំងឡាយ ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីសេចក្តីវិនាសដល់ត្រកូលទាំងឡាយ ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីបៀតបៀនត្រកូលទាំងឡាយ ។ ម្នាលគាមណី បុគ្គលនោះបើមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ មិនរលាស់ទិដ្ឋិនោះចេញទេ

យថាភតំ និក្ខិត្តោ ឯវំ និរយេតិ ។ ឯវំ វុត្តេ អសិពន្ធ-
កបុត្តោ គាមណី ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ
អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសកំ មំ ភគវា ធារេតុ
អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ នវមំ ។

[២៦៨] ឯកំ សមយំ ភគវា រាជគហេ វិហរតិ
វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន
រាជន្តេបុរេ រាជបរិសាយ សន្និសិន្នានំ សន្និបតិតានំ
អយមន្តរាកថា ឧទបាទិ កប្បតិ សមណានំ សក្យ-
បុត្តិយានំ ជាតរូបរជតំ សាទិយន្តិ សមណា សក្យ-
បុត្តិយា ជាតរូបរជតំ បដិគ្គណ្ហន្តិ សមណា សក្យ-
បុត្តិយា ជាតរូបរជតន្តិ ។

នឹងធ្លាក់ទៅក្នុងនរកដូចគេនាំយកទៅទម្លាក់ចោល ។ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ អសិពន្ធកបុត្តគាមណី ក៏សរសើរព្រះដ៏មានព្រះភាគដូច្នេះថា ភ្លឺច្បាស់ណាស់ ព្រះអង្គ ភ្លឺច្បាស់ណាស់ ព្រះអង្គ ។ បេ ។ សូមព្រះមានព្រះភាគចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់សរណគមន៍ស្មើដោយជីវិត តាំងពីថ្ងៃនេះទៅ ។ ចប់សូត្រទី ៩ ។

[២៦៥] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័នជាកឡន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង អន្តរាកថា[១]នេះ កើតឡើងដល់ពួកជនដែលអង្គុយចួបជុំគ្នា នាកណ្តាលរាជបរិសទ្យ ខាងក្នុងព្រះរាជវាំងថា មាសនិងប្រាក់គួរដល់ពួកសមណសក្យបុត្តិយ៍ ពួកសមណសក្យបុត្តិយ៍ក៏ត្រេកអរចំពោះមាសនិងប្រាក់បាន ពួកសមណសក្យបុត្តិយ៍ទទួលនូវមាសនិងប្រាក់បាន ។

១ អន្តរាកថា គឺពាក្យជាចន្លោះនៃគុណធម៌ មានកម្មដ្ឋានមនសិការ ឬបាលីនិងអដ្ឋកថាជាដើម ។ អដ្ឋកថា ។

គាមណិសំយុត្តំ

[២៦៦] តេន ខោ បន សមយេន មណិចូឡកោ គាមណី តស្សំ បរិសាយំ និសិន្នោ ហោតិ ។ អថខោ មណិចូឡកោ គាមណី តំ បរិសំ ឯតទវោច មា អយ្យា ឯវំ អវចុត្ថ ន កប្បតិ សមណានំ សក្យបុត្តិយានំ ជាតរូបរជតំ ន សាទិយន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ ន បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ និក្ខិត្តមណិសុវណ្ណា សមណា សក្យបុត្តិ-យា អបេតជាតរូបរជតាតិ ។ អសក្ខិ ខោ មណិចូឡ-កោ គាមណី តំ បរិសំ សញ្ញាបេតុំ ។

[២៦៧] អថខោ មណិចូឡកោ គាមណី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មណិ-ចូឡកោ គាមណី ភគវន្តំ ឯតទវោច ឥធ ភន្តេ

គាមណិសំយុត្ត

[២៦៦] សម័យនោះ គាមណីឈ្មោះមណិចូឡកៈ អង្គុយក្នុងបរិសទ្យនោះដែរ ។ ទើបមណិចូឡកគាមណីនិយាយនឹងបរិសទ្យនោះដូច្នេះថា អស់លោកទាំងឡាយ លោកទាំងឡាយកុំនិយាយយ៉ាងហ្នឹងឡើយ មាសនិងប្រាក់មិនគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណ-សក្យបុត្តិយ៍មិនត្រេកអរចំពោះមាសនិងប្រាក់ទេ ពួកសមណសក្យបុត្តិយ៍មិនទទួលនូវមាសនិងប្រាក់ទេ ពួកសមណសក្យបុត្តិយ៍ជាអ្នកលះបោលកែវមណីនិងមាសហើយ ប្រាសចាកមាសប្រាក់ហើយ ។ មណិចូឡក-គាមណីក៏មិនអាចញុំាំងបរិសទ្យនោះឲ្យយល់បានសោះ ។

[២៦៧] គ្រានោះ មណិចូឡកគាមណីចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះមណិចូឡកគាមណីអង្គុយក្នុងទីសមគួរហើយក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន

រាជន្តេបុរេ រាជបរិសាយ សន្និសិន្នានំ សន្និបតិតានំ អ-
យមន្តរាកថា ឧទបាទិ កប្បតិ សមណានំ សក្យ-
បុត្តិយានំ ជាតរូបរជតំ សាទិយន្តិ សមណា សក្យបុត្តិ-
យា ជាតរូបរជតំ បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា
ជាតរូបរជតន្តិ ។ ឯវំ វុត្តេ អហំ ភន្តេ តំ បរិសំ ឯតទ-
វោចំ មា អយ្យា ឯវំ អវចុត្ថ ន កប្បតិ សមណានំ
សក្យបុត្តិយានំ ជាតរូបរជតំ ន សាទិយន្តិ សមណា
សក្យបុត្តិយា ជាតរូបរជតំ ន បដិគ្គណ្ហន្តិ សមណា
សក្យបុត្តិយា ជាតរូបរជតំ និក្ខិត្តមណិសុវណ្ណា ស-
មណា សក្យបុត្តិយា អបេតជាតរូបរជតាតិ ។ អសក្ខឹ
ខ្វាហំ ភន្តេ តំ បរិសំ សញ្ញាបេតុំ កច្ចាហំ ភន្តេ ឯវំ
ព្យាករមានោ វុត្តវាទី ចេវ ភគវតោ ហោមិ ន ច
ភគវន្តំ អភូតេន អព្ភាចិក្ខាមិ ធម្មស្ស ចានុធម្មំ ព្យា-
ករោមិ ន ច កោចិ សហធម្មិកោ វាទានុវាទោ
គារយ្ហំ ឋានំ អាគច្ឆតីតិ ។

អន្តរាកថានេះ កើតឡើងដល់ពួកជនអង្គុយចួបជុំគ្នា នាកណ្តាលរាជបរិសទ្យ ខាងក្នុងព្រះរាជវាំងនេះថា មាសនិងប្រាក់គួរដល់ពួកសមណសក្យបុត្តិយ៍ ពួកសមណសក្យបុត្តិយ៍ក៏ត្រេកអរចំពោះមាសនិងប្រាក់បាន ពួកសមណសក្យបុត្តិយ៍ទទួលមាសនិងប្រាក់បាន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេនិយាយយ៉ាងនេះ ខ្ញុំព្រះអង្គក៏និយាយនឹងបរិសទ្យនោះដូច្នេះថា បពិត្រអស់លោកទាំងឡាយ លោកទាំងឡាយកុំពោលយ៉ាងនេះឡើយ មាសនិងប្រាក់មិនគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណសក្យបុត្តិយ៍ មិនត្រេកអរចំពោះមាសនិងប្រាក់ទេ ពួកសមណសក្យបុត្តិយ៍មិនទទួលមាសនិងប្រាក់ទេ ពួកសមណសក្យបុត្តិយ៍លះបង់ចោលកែវមណីនិងមាសហើយ ប្រាកចាកមាសនិងប្រាក់ហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចនឹងញ៉ាំងបរិសទ្យនោះឲ្យយល់បានសោះ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គដោះស្រាយយ៉ាងនេះ ឈ្មោះថាពោលត្រូវតាមព្រះបន្ទូលព្រះមានព្រះភាគផង មិនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ដោះស្រាយនូវធម៌សមគួរដល់ធម៌ផង លំនាំពាក្យតូចធំណាមួយជាពាក្យប្រកបដោយធម៌ មិនដល់នូវហេតុគប្បីតិះដៀលផង បានដែរឬ ។

២៧៨

គាមណិសំយុត្តំ

[២៦៨] តត្ថ ត្វំ គាមណិ ឯវំ ព្យាករមានោ វុត្តវាទី ចេវ មេ អហោសិ ន ច មំ អភូតេន អព្ភាចិក្ខសិ ធម្មស្ស ចានុធម្មំ ព្យាករោសិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតិ ។ ន ហិ គាមណិ កប្បតិ សមណានំ សក្យបុត្តិយានំ ជាតរូបរជតំ ន សាទិយន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ ន បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ និក្ខិត្តមណិសុវណ្ណា សមណា សក្យបុត្តិយា អបេតជាតរូបរជតា ។ យស្ស ខោ គាមណិ ជាតរូបរជតំ កប្បតិ បញ្ចបិ តស្ស កាមគុណា កប្បន្តិ យស្ស បញ្ច កាមគុណា កប្បន្តិ (តស្សបិ ជាតរូបរជតំ កប្បតិ[១]) ឯកំសេនេតំ គាមណិ ធារេយ្យាសិ អស្សមណធម្មោ អសក្យបុត្តិយធម្មោតិ ។ អបិ ចាហំ គាមណិ ឯវំ វទាមិ

១ ឱ. ម. តស្សបិ ជាតរូបរជតំ កប្បតីតិបិ បាឋោ ន សន្តិ ។

គាមណិសំយុត្ត

[២៦៨] អើគាមណី អ្នកដោះស្រាយយ៉ាងនេះ ឈ្មោះថា ពោលត្រូវតាមពាក្យតថាគតផង មិនពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ដោះស្រាយនូវធម៌សមគួរដល់ធម៌ផង លំនាំពាក្យតូចធំណាមួយជាពាក្យប្រកបដោយធម៌ មិនដល់នូវហេតុគប្បីតិះដៀលផង ។ ម្នាលគាមណី មាសនិងប្រាក់មិនសមគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណសក្យបុត្តិយ៍មិនត្រេកអរចំពោះមាសនិងប្រាក់ទេ ពួកសមណ-សក្យបុត្តិយ៍មិនទទួលមាសនិងប្រាក់ទេ ពួកសមណសក្យបុត្តិយ៍លះចោលកែវមណីនិងមាសហើយ ប្រាសចាកមាសនិងប្រាក់ហើយ ។ ម្នាលគាមណី មាសនិងប្រាក់គួរដល់បុគ្គលណា កាមគុណ ៥ ក៏គួរដល់បុគ្គលនោះ កាមគុណ ៥ គួរដល់បុគ្គលណា (មាសនិងប្រាក់ក៏គួរដល់បុគ្គលនោះដែរ) ម្នាលគាមណី អ្នកគប្បីចាំទុកនូវការសម្រេចនៃកាមគុណទាំង ៥ នេះដោយពិតថា មិនមែនជាធម៌របស់សមណៈ មិនមែនជាធម៌របស់សក្យបុត្តិយ៍ទេ ។ ម្នាលគាមណីម្យ៉ាងទៀត តថាគតពោលយ៉ាងនេះថា

តិណំ តិណាត្តិភោន បរិយេសិតព្វំ ធារុំ ធារុត្តិភោន បរិយេសិតព្វំ សកដំ សកដត្តិភោន បរិយេសិតព្វំ បុរិសោ បុរិសត្តិភោន បរិយេសិតព្វោ ។ ន ត្វេវ វាហំ គាមណិ ភោនចិ បរិយាយេន ជាតរូបរជតំ សាទិតព្វំ បរិយេសិតព្វន្តិ វទាមីតិ ។ ទសមំ ។

[២៦៩] ឯកំ សមយំ ភគវា មល្លេសុ[១] វិហរតិ ឧរុវេលកប្បំ នាម មល្លានំ[២] និគមោ ។ អថខោ គន្ធភកោ[៣] គាមណី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ គន្ធភកោ គាមណី ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា ទុក្ខស្ស សមុទយញ្ច អត្ថង្គមញ្ច ទេសេតូតិ ។ អហំ ច តេ គាមណិ អតីតមទ្ធានំ អារព្ភ ទុក្ខស្ស សមុទយញ្ច អត្ថង្គមញ្ច ទេសេយ្យំ ឯវំ អហោសិ អតីតមទ្ធានន្តិ ។

១ ឱ. មលតេសុ ។ ២ មលតានំ ។ ៣ ភទ្រគតោ ។ ម. ភទ្រតោ ។

បុគ្គលអ្នកត្រូវការដោយស្មៅ គប្បីស្វែងរកស្មៅ បុគ្គលអ្នកត្រូវការដោយឈើ គប្បីស្វែងរកឈើ បុគ្គលអ្នកត្រូវការដោយរទេះ គប្បីស្វែងរករទេះ អ្នកត្រូវការដោយបុរស គប្បីស្វែងរកបុរស ។ ម្នាលគាមណិ តថាគតមិនដែលពោលថា សមណៈគប្បីត្រេកអរចំពោះមាសនិងប្រាក់ គប្បីស្វែងរកមាសនិងប្រាក់ដូច្នេះ ដោយបរិយាយណាមួយទេ ។ ចប់សូត្រទី ១០ ។

[២៦៩] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងឧរុវេលកប្បនិគមរបស់ពួកមល្លជន ក្នុងមល្លជនបទ ។ គ្រានោះឯង គន្ធភកគាមណិចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះគន្ធភកគាមណិអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទានព្រះមានព្រះភាគសំដែងនូវហេតុឲ្យកើតទុក្ខផង នូវសេចក្តីវិនាសទុក្ខផង ដល់ខ្ញុំព្រះអង្គ ។ ម្នាលគាមណិ តែតថាគតប្រារព្ធអតីតកាលហើយសំដែងនូវហេតុឲ្យកើតទុក្ខនិងសេចក្តីវិនាសទុក្ខថា អតីតកាលតែងមានយ៉ាងនោះ ឲ្យអ្នកស្តាប់ហើយ ។

២៧៧



តត្រ តេ សិយា កង្ខា សិយា វិមតិ ។ អហំ ច តេ គាមណិ អនាគតមទ្ធានំ អារព្ភ ទុក្ខស្ស សមុទយញ្ច អត្ថង្គមញ្ច ទេសេយ្យំ ឯវំ ភវិស្សតិ អនាគតមទ្ធានន្តិ ។ តត្រាបិ តេ សិយា កង្ខា សិយា វិមតិ អបិ ចាហំ គាមណិ ឥធេវ និសិន្នោ ឯត្ថ ច តេ និសិន្នស្ស ទុក្ខស្ស សមុទយញ្ច អត្ថង្គមញ្ច ទេសេស្សាមិ តំ សុណោហិ សាធុកំ មនសិ ករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ ភទ្រកោ គាមណី ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច តំ កឹ មញ្ញសិ គាមណិ អត្ថិ តេ ឧរុវេលកប្បេ មនុស្សា យេសំ តេ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ អត្ថិ មេ ភន្តេ ឧរុវេលកប្បេ មនុស្សា យេសំ មេ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ អត្ថិ បន តេ គាមណិ

អ្នកគង់មានសេចក្តីសង្ស័យ គង់មានសេចក្តីងឿងឆ្ងល់ ក្នុងអតីតកាលនោះ ។ ម្នាលគាមណិ តែតថាគតប្រារព្ធអនាគតកាលហើយសំដែងនូវហេតុឲ្យកើតទុក្ខនិងសេចក្តីវិនាសទុក្ខថា អនាគតកាលនឹងមានយ៉ាងនោះឲ្យអ្នកស្តាប់ហើយ ។ អ្នកគង់មានសេចក្តីសង្ស័យ គង់មានសេចក្តីងឿងឆ្ងល់ ក្នុងអនាគតកាលនោះ ម្នាលគាមណិ ប៉ុន្តែតថាគតអង្គុយក្នុងទីនេះឯង សំដែងនូវហេតុឲ្យកើតទុក្ខនិងសេចក្តីវិនាសទុក្ខ ឲ្យអ្នកដែលអង្គុយនៅក្នុងទីនុ៎ះស្តាប់ ចូរអ្នកស្តាប់ធម៌នោះ ធ្វើទុកក្នុងចិត្តដោយប្រពៃចុះតថាគតនឹងសំដែង ។ គន្ធភកគាមណិក៏ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត កើតឡើងដល់អ្នក ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចងក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃពួកមនុស្សដែលនៅក្នុងឧរុវេលកប្បនិគម ធ្លាប់មានដល់អ្នកដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត កើតឡើងដល់ខ្ញុំព្រះអង្គ ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចងក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃពួកមនុស្សដែលនៅក្នុងឧរុវេលកប្បនិគម ធ្លាប់មានដល់ខ្ញុំព្រះអង្គដែរ ។ ម្នាលគាមណិ

ឱរុវេលកប្បេ មនុស្សា យេសំ តេ វេធេន វា ពន្ធេន វា ជានិយា វា គរហាយ វា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខ-
ទោមនស្សុបាយាសាតិ ។ អត្ថិ មេ ភន្តេ ឱរុវេលកប្បេ មនុស្សា យេសំ មេ វេធេន វា ពន្ធេន វា ជានិយា វា គ-
រហាយ វា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបា-
យាសាតិ ។ កោ នុ ខោ គាមណិ ហេតុ កោ បច្ចយោ យេន តេ ឯកច្ចានំ ឱរុវេលកប្បិយានំ មនុស្សានំ វេធេន វា ពន្ធេន វា ជានិយា វា គរហាយ វា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសា ។ កោ វា បន គាមណិ ហេតុ កោ បច្ចយោ

ចុះសេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត មិនកើតឡើងដល់អ្នកព្រោះសេចក្ដីស្លាប់ក្ដី ព្រោះការចាប់ចងក្ដី ព្រោះការវិនាសទ្រព្យក្ដី ព្រោះការតិះដៀលក្ដី នៃពួកមនុស្សដែលនៅក្នុងឧរុវេលកប្បនិគម ធ្លាប់មានដល់អ្នកដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត មិនកើតឡើងដល់ខ្ញុំព្រះអង្គ ព្រោះសេចក្ដីស្លាប់ក្ដី ព្រោះការចាប់ចងក្ដី ព្រោះការវិនាសទ្រព្យក្ដី ព្រោះការតិះដៀលក្ដី នៃពួកមនុស្សដែលនៅក្នុងឧរុវេលកប្បនិគម ក៏ធ្លាប់មានដល់ខ្ញុំព្រះអង្គដែរ ។ ម្នាលគាមណី ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាសេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត កើតឡើងដល់អ្នក ព្រោះសេចក្ដីស្លាប់ក្ដី ព្រោះការចាប់ចងក្ដី ព្រោះការវិនាសទ្រព្យក្ដី ព្រោះការតិះដៀលក្ដី នៃមនុស្សទាំងឡាយពួកខ្លះ ដែលនៅក្នុងឧរុវេលកប្ប-និគម ។ ម្នាលគាមណី មួយទៀត ហេតុដូចម្ដេច បច្ច័យដូចម្ដេច

២៧៩

## គាមណិសំយុត្តំ

យេន តេ ឯកច្ចានំ ឧរុវេលកប្បិយានំ មនុស្សានំ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា នុប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ យេសំ មេ ភន្តេ ឧរុវេលកប្បិយានំ មនុស្សានំ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ អត្ថិ មេ តេសុ ឆន្ទរាគោ ។ យេសម្បន មេ ភន្តេ ឧរុវេលកប្បិយានំ មនុស្សានំ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា នុប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសា នត្ថិ មេ តេសុ ឆន្ទរាគោតិ ។ ឥមិនា ត្វំ គាមណិ ធម្មេន ទិដ្ឋេន វិទិតេន អកាលិកេន បត្តេន បរិយោគាឡ្ហេន អតីតានាគតេន នេហិ យំ ខោ កិញ្ចិ អតីតមទ្ធានំ ទុក្ខំ ឧប្បជ្ជមានំ ឧប្បជ្ជតិ

បានជាសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត មិនកើតឡើងដល់អ្នក ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចង៍ក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃមនុស្សទាំងឡាយពួកខ្លះដែលនៅក្នុងឧរុវេលកប្បនិគម ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត កើតឡើងដល់ខ្ញុំព្រះអង្គ ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចង៍ក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃពួកមនុស្សឯណាដែលនៅក្នុងឧរុវេលកប្បនិគម ព្រោះតែខ្ញុំព្រះអង្គមានឆន្ទរាគក្នុងមនុស្សទាំងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត មិនកើតឡើងដល់ខ្ញុំព្រះអង្គ ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចង៍ក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃពួកមនុស្សឯណាដែលនៅក្នុងឧរុវេ-លកប្បនិគម ព្រោះតែខ្ញុំព្រះអង្គមិនមានឆន្ទរាគក្នុងមនុស្សទាំងនោះទេ ។ ម្នាលគាមណិ ត្រូវអ្នកចូលចិត្តតាមធម៌នេះដែលអ្នកឃើញហើយ ដឹងហើយ ជាធម៌ឲ្យផលមិនកន្លងកាល ដែលធ្លាក់ចុះមកហើយ មានទាំងក្នុងអតីតកាលនិងអនាគតកាល ទុក្ខឯណានីមួយកើតឡើងក្នុងអតីតកាល

សព្វំ តំ ឆន្ទមូលកំ ឆន្ទនិទានំ ឆន្ទោ ហិ មូលំ ទុក្ខស្ស ។ យម្បិ ហិ កិញ្ចិ អនាគតមទ្ធានំ ទុក្ខំ ឧប្បជ្ជមានំ ឧប្បជ្ជិស្សតិ សព្វន្តំ ឆន្ទមូលកំ ឆន្ទនិទានំ ឆន្ទោ ហិ មូលំ ទុក្ខស្ស ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ តេន ភគវតា យំ កិញ្ចិ អតីត-មទ្ធានំ ទុក្ខំ ឧប្បជ្ជមានំ ឧប្បជ្ជតិ សព្វន្តំ ឆន្ទមូលកំ ឆន្ទនិទានំ ឆន្ទោ ហិ មូលំ ទុក្ខស្សាតិ ។ យំ កិញ្ចិ អនាគតមទ្ធានំ ទុក្ខំ ឧប្បជ្ជមានំ ឧប្បជ្ជិស្សតិ សព្វន្តំ ឆន្ទមូលកំ ឆន្ទនិទានំ ឆន្ទោ ហិ មូលំ ទុក្ខស្សាតិ ។ អត្ថិ មេ ភន្តេ ចិរវាសិ នាម កុមារោ ពហិ អាវ-សថេ បដិវសតិ សោ ខ្វាហំ ភន្តេ កាលស្សេវ វុដ្ឋាយ

ទុក្ខទាំងអស់នោះមានឆន្ទៈជាមូល មានឆន្ទៈជាហេតុ ព្រោះថាឆន្ទៈជាមូលនៃទុក្ខ ។ ទុក្ខឯណានីមួយនឹងកើតឡើងក្នុងអនាគតកាល ទុក្ខទាំងអស់នោះ ក៏មានឆន្ទៈជាមូល មានឆន្ទៈជាហេតុ ព្រោះថាឆន្ទៈជាមូលនៃទុក្ខ ។ អស្ចារ្យណាស់ ព្រះអង្គ ចំឡែកណាស់ ព្រះអង្គ ពាក្យដែលព្រះដ៏មានព្រះភាគអង្គនោះសំដែងហើយ ជាពាក្យសុភាសិតដោយពិត ទុក្ខឯណានីមួយកើតឡើងក្នុងអតីតកាល ទុក្ខទាំងអស់នោះ មានឆន្ទៈជាមូល មានឆន្ទៈជាហេតុ ព្រោះថាឆន្ទៈជាមូលនៃទុក្ខ ។ ទុក្ខឯណានីមួយនឹងកើតឡើងក្នុងអនាគតកាល ទុក្ខទាំងអស់នោះ ក៏មានឆន្ទៈជាមូល មានឆន្ទៈជាហេតុ ព្រោះថាឆន្ទៈជាមូលនៃទុក្ខ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានកុមារម្នាក់ឈ្មោះចិរវាសី អាស្រ័យនៅក្នុងលំនៅស្រុកក្រៅ[១] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ក្រោកឡើងអំពីព្រឹក

---

១ កុមារនេះជាកូនរបស់គន្ធភកគាមណីនោះ ដែលនៅរៀនសិល្បសាស្ត្រឯនគរក្រៅ ។ អដ្ឋកថា ។

បុរិសំ ឧយ្យោជេមិ គច្ឆ ភណេ ចិរវាសឹ កុមារំ ជានាហីតិ ។ យាវកីវញ្ច ភន្តេ សោ បុរិសោ នាគច្ឆតិ តស្ស មេ ហោតេវ អញ្ញថត្តំ មា ហេវំ ចិរវាសិស្ស កុមារស្ស កិញ្ចិ អាពាធយេថាតិ[១] ។

[២៧០] តំ កឹ មញ្ញសិ គាមណិ ចិរវាសិស្ស[២] កុមារស្ស វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ចិរវាសិស្ស មេ ភន្តេ កុមារស្ស វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា ជីវិតស្សបិ សិយា អញ្ញថត្តំ កឹ បន មេ នុប្បជ្ជិស្សន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឥមិនា ខោ ឯតំ គាមណិ បរិយាយេន វេទិតព្វំ យំ កិញ្ចិ ទុក្ខំ ឧប្បជ្ជមានំ ឧប្បជ្ជតិ សព្វន្តំ ឆន្ទ-

---

១ ឱ. អាពាធយ្យេស្សតិ ។ ២ ឱ. ចិរវាសិស្ស តេ ។

ប្រើបុរសម្នាក់ថា នែព្រះស្តេង អ្នកចូរដឹងនូវចិរវាសីកុមារចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះមិនទាន់មកដរាបណា ខ្ញុំព្រះអង្គក៏មានទុក្ខប្លែកដោយគិតថា សូមកុំឲ្យសេចក្តីទុក្ខនីមួយបៀតបៀន ដល់ចិរវាសីកុមារយ៉ាងនេះដរាបនោះដែរ ។

[២៧០] ព្រះមានព្រះភាគត្រាស់ថា ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត កើតឡើង (ដល់អ្នក) ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចងក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃចិរវាសីកុមារមែនដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីទុក្ខប្លែកមានដល់ខ្ញុំព្រះអង្គ ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចងក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃចិរវាសីកុមារ សូម្បីមានជីវិតនៅឡើយ ចុះធ្វើដូចម្តេច ទើបសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត នឹងមិនកើតឡើងដល់ខ្ញុំព្រះអង្គ ។ ម្នាលគាមណិ អ្នកត្រូវដឹងដំណើរនុ៎ះតាមបរិយាយនេះថា ទុក្ខឯណានីមួយកើតឡើង ទុក្ខទាំងអស់នោះមានឆន្ទៈ

មូលកំ ឆន្ទនិទានំ ឆន្ទោ ហិ មូលំ ទុក្ខស្សាតិ ។ តំ កឹ មញ្ញសិ គាមណិ យទា តេ ចិរវាសិ[១]មាតា អទិដ្ឋា អហោសិ អស្សុតា អហោសិ តេ ចិរវាសិមាតុយា ឆន្ទោ វា រាគោ វា បេមំ វាតិ ។ នោ ហេតំ ភន្តេ ។ ទស្សនំ វា តេ គាមណិ អាគម្ម សវនំ វា[២] ឯវំ តេ អហោសិ ចិរវាសិមាតុយា ឆន្ទោ វា រាគោ វា បេមំ វាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញសិ គាមណិ ចិរវាសិ-មាតុយា តេ វធេន វា ពន្ធេន វា ជានិយា វា គរហា-យ វា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយា-សាតិ ។ ចិរវាសិមាតុយា មេ ភន្តេ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា ជីវិតស្សបិ សិយា អញ្ញថត្តំ កឹ បន មេ នុប្បជ្ជិស្សន្តិ សោកបរិទេវទុក្ខទោមនស្សុបា-យាសាតិ ។ ឥមិនា ខោ ឯតំ គាមណិ បរិយាយេន វេទិតព្វំ យំ កិញ្ចិ ទុក្ខំ ឧប្បជ្ជមានំ ឧប្បជ្ជតិ សព្វន្តំ

---

១ ឱ. ចិរវាសិស្ស មាតា ។ ២ ឱ. ឯត្ថន្តរេ តេ គាមណិ អាគម្ម ។

ជាមូល មានឆន្ទៈជាហេតុ ព្រោះថាឆន្ទៈជាមូលនៃទុក្ខ ។ ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលដែលអ្នកមិនទាន់បានឃើញ មិនទាន់បានឮ មាតារបស់ចិរវាសីកុមារ តើឆន្ទៈក្តី រាគៈក្តី សេចក្តីស្រឡាញ់ក្តី ចំពោះមាតារបស់ចិរវាសីកុមារ មានដល់អ្នកដែរឬ ។ មិនដូច្នោះទេព្រះអង្គ ។ ម្នាលគាមណិ អ្នកមានឆន្ទៈក្តី រាគៈក្តី សេចក្តីស្រឡាញ់ក្តី ចំពោះមាតារបស់ចិរវាសីកុមារ ព្រោះតែអ្នកបានឃើញ បានឮយ៉ាងនេះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលគាមណិ អ្នកយល់សេចក្តីនោះដូចម្តេច សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត កើតឡើងដល់អ្នក ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចងក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃមាតារបស់ចិរវាសីកុមារដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីទុក្ខប្លែកមានដល់ខ្ញុំព្រះអង្គ ព្រោះសេចក្តីស្លាប់ក្តី ព្រោះការចាប់ចងក្តី ព្រោះការវិនាសទ្រព្យក្តី ព្រោះការតិះដៀលក្តី នៃមាតារបស់ចិរវាសីកុមារ សូម្បីមានជីវិតនៅឡើយ ចុះធ្វើដូចម្តេច ទើបសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត នឹងមិនកើតឡើងដល់ខ្ញុំព្រះអង្គ ។ ម្នាលគាមណិ អ្នកត្រូវដឹងដំណើរនុ៎ះដោយបរិយាយនេះថា ទុក្ខឯណានីមួយកើតឡើង ទុក្ខទាំងអស់នោះ

ឆន្ទមូលកំ ឆន្ទនិទានំ ឆន្ទោ ហិ មូលំ ទុក្ខស្សាតិ ។

ឯកាទសមំ ។

[២៧១] អថខោ រាសិយោ គាមណី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាសិយោ គាមណី ភគវន្តំ ឯតទវោច សុតម្មេតំ ភន្តេ សមណោ គោតមោ សព្វំ តបំ គរហតិ សព្វំ តបស្សឹ លូខជីវឹ ឯកំសេន ឧបវទតិ ឧបក្កោសតីតិ ។ យេ តេ ភន្តេ ឯវមាហំសុ សមណោ គោតមោ សព្វំ តបំ គរហតិ សព្វំ តបស្សឹ លូខជីវឹ ឯកំសេន ឧបវទតិ ឧបក្កោសតីតិ ។ កច្ចិ តេ ភន្តេ ភគវតោ វុត្តវាទិនោ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតីតិ ។ យេ តេ គាមណិ ឯវមាហំសុ

មានឆន្ទៈជាមូល មានឆន្ទៈជាហេតុ ព្រោះថាឆន្ទៈជាមូលនៃទុក្ខ ។ ចប់សូត្រទី ១១ ។

[២៧១] គ្រានោះ គាមណីឈ្មោះរាសិយៈ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះរាសិយគាមណីអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យដូច្នេះថា ព្រះសមណគោតម តិះដៀលតបវត្តទាំងអស់ ជេរប្រទេចនូវបុគ្គលអ្នកមានតបវត្តទាំងអស់ មានជីវិតសៅហ្មងជានិច្ច ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកជនឯណានិយាយយ៉ាងនេះថា ព្រះសមណគោតម តិះដៀលតបវត្តទាំងអស់ ជេរប្រទេចនូវបុគ្គលអ្នកមានតបវត្តទាំងអស់ មានជីវិតសៅហ្មងជានិច្ច ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកជនទាំងនោះ ឈ្មោះថា ពោលត្រូវតាមព្រះបន្ទូលដែលព្រះមានព្រះភាគ ត្រាស់ហើយផង មិនពោលបង្កាច់ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ពោលនូវធម៌សមគួរតាមធម៌ផង លំនាំនៃពាក្យតូចធំណាមួយ ជាពាក្យប្រកបដោយធម៌ មិនដល់នូវហេតុគួរតិះដៀលផងបានទេឬ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលគាមណី ពួកជនឯណានិយាយយ៉ាងនេះថា

សមណោ គោតមោ សព្វំ តបំ គរហតិ សព្វំ តបស្សឹ លូខជីវឹ ឯកំសេន ឧបវទតិ ឧបក្កោសតីតិ ។ ន មេ តេ វុត្តវាទិនោ អព្ភាចិក្ខន្តិ ច បន(១) មន្តេ អសតា អភូតេន(២) ។

[២៧២] ទ្វេមេ គាមណិ អន្តា បព្វជិតេន ន សេវិតព្វា យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ ហីនោ គម្មោ បោថុជ្ជនិកោ អនរិយោ អនត្ថសញ្ហិតោ យោ ចាយំ អត្តកិលមថានុយោគោ ទុក្ខោ អនរិយោ អនត្ថសញ្ហិតោ ។ ឯតេ តេ គាមណិ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា

១ ឱ. ន ច បន មំ ភន្តេ ។ ២ ម. អសតា តុច្ឆា អភូតេន ។

ព្រះសមណគោតម តិះដៀលតបវត្តទាំងអស់ ជេរប្រទេចនូវបុគ្គលអ្នកមានតបវត្តទាំងអស់ មានជីវិតសៅហ្មងជានិច្ច ។ ពួកជននោះឈ្មោះថាពោលមិនត្រូវតាមពាក្យតថាគតផង ពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ។

[២៧២] ម្នាលគាមណិ អន្តធម៌ (ធម៌អមខាងឬធម៌លាមក) ពីរប្រការនេះ បព្វជិតមិនត្រូវសេពគប់ឡើយ គឺធម៌ដែលប្រកបខ្លួនឲ្យជាប់ចំពាក់ដោយកាមក្នុងកាមទាំងឡាយ ជាធម៌ថោកទាប ជាធម៌របស់អ្នកស្រុក ជាធម៌របស់បុថុជ្ជន មិនមែនជាធម៌របស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ ១ ធម៌ដែលប្រកបសេចក្តីលំបាកដល់ខ្លួនជាហេតុនាំឲ្យលំបាកកាយទទេៗ មិនមែនជារបស់អរិយបុគ្គល មិនប្រ-កបដោយប្រយោជន៍ឡើយ ១ ។ ម្នាលគាមណិ មជ្ឈិមាបដិបទាមិនទាក់ទងនឹងអន្តធម៌ពីរយ៉ាងនុ៎ះផង ដែលតថាគតបានត្រាស់ដឹងហើយ

ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ កតមា ច សា គាមណិ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ ខោ សា គាមណិ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

គាមណិសំយុត្ត

ជាបដិបទាធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីដឹងដោយត្រឹមត្រូវ ដើម្បីរំលត់ទុក្ខ ។ ម្នាលគាមណិ ចុះមជ្ឈិមាបដិបទាដែលតថាគតបានត្រាស់ដឹងហើយ ជាបដិបទាធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីដឹងដោយត្រឹមត្រូវ ដើម្បីរំលត់ទុក្ខ តើដូចម្តេច ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ។ មគ្គប្រកបដោយអង្គ ៨ តើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលគាមណិ នេះឯងហៅថាមជ្ឈិមាបដិបទា ដែលតថាគតបានត្រាស់ដឹងហើយ ជាបដិបទាធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីដឹងដោយត្រឹមត្រូវ ដើម្បីរំលត់ទុក្ខ ។

[២៧៣] តយោមេ គាមណិ កាមភោគិនោ សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ ឥធ គាមណិ ឯកច្ចោ កាមភោគី អធម្មេន ភោគេ បរិយេ-សតិ សាហសេន អធម្មេន ភោគេ បរិយេសិត្វា សា-ហសេន ន អត្តានំ សុខេតិ ន បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គាមណិ ឯកច្ចោ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហសេន អធម្មេន ភោគេ បរិយេសិត្វា សាហសេន អត្តានំ សុខេតិ បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គាមណិ ឯកច្ចោ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហសេន អធម្មេន ភោគេ បរិយេសិត្វា សាហសេន អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ ។

[២៧៣] ម្នាលគាមណី កាមភោគី (បុគ្គលអ្នកបរិភោគកាម) ៣ ពួកនេះ មាននៅក្នុងលោក ។ កាមភោគីបុគ្គល ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលគាមណី កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហានបានហើយ ក៏មិនធ្វើខ្លួនឲ្យបានសុខ មិនឲ្យឆ្អែតឆ្អន់ ទាំងមិនចែករលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណី កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ប៉ុន្តែមិនចែករលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណី កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ទាំងចែករលែក ធ្វើបុណ្យទាំងឡាយផង ។

## ២៨៧

### គាមណិសំយុត្តំ

[២៧៤] ឥធ គាមណិ ឯកច្ចោ កាមភោគី ធម្មា-
ធម្មេន ភោគេ បរិយេសតិ សាហាសេនបិ អសាហាសេ-
នបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហាសេនបិ
អសាហាសេនបិ ន អត្តានំ សុខេតិ ន បិណេតិ ន
សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ គាមណិ ឯកច្ចោ
កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហា-
សេនបិ អសាហាសេនបិ ធម្មាធម្មេន ភោគេ បរិយេ-
សិត្វា សាហាសេនបិ អសាហាសេនបិ អត្តានំ សុខេតិ
បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ
គាមណិ ឯកច្ចោ កាមភោគី ធម្មាធម្មេន ភោគេ
បរិយេសតិ សាហាសេនបិ អសាហាសេនបិ ធម្មាធម្មេន
ភោគេ បរិយេសិត្វា សាហាសេនបិ អសាហាសេនបិ
អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ ។

## គាមណិសំយុត្ត

[២៧៤] ម្នាលគាមណិ កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទ័ដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាន និងមិនក្លាហាន លុះស្វែងរកភោគសម្បទ័ដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាន និងមិនក្លាហានបានហើយ ក៏មិនធ្វើខ្លួនឲ្យសុខ មិនឲ្យឆ្អែតឆ្អន់ ទាំងមិនចែករំលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទ័ដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាន និងមិនក្លាហាន លុះស្វែងរកភោគសម្បទ័ដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាន និងមិនក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ប៉ុន្តែមិនចែករំលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទ័ដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាន និងមិនក្លាហាន លុះស្វែងរកភោគសម្បទ័ដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាន និងមិនក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ទាំងចែករំលែក ធ្វើបុណ្យទាំងឡាយផង ។

[២៧៤] ឥធ បន គាមណិ ឯកច្ចោ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន ន អត្តានំ សុខេតិ ន បីណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គាមណិ ឯកច្ចោ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បីណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គាមណិ ឯកច្ចោ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បីណេតិ សំវិភជតិ បុញ្ញានិ ករោតិ តេ ច ភោគេ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ អនាទីនវទស្សាវី អនិស្សរណប្បញ្ញោ បរិភុញ្ជតិ ។ ឥធ បន គាមណិ ឯកច្ចោ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ

[២៧៥] ម្នាលគាមណិ កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហានបានហើយ ក៏មិនធ្វើខ្លួនឲ្យបានសុខ មិនឲ្យឆ្អែតឆ្អន់ ទាំងមិនចែករំលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ប៉ុន្តែមិនចែករំលែក មិនធ្វើបុណ្យទាំង-ឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ទាំងចែករំលែក ធ្វើបុណ្យទាំងឡាយទៀត តែប្រើប្រាស់ភោគសម្បទទាំងនោះ ជប់ ជ្រុលជ្រប់ ផ្តេកផ្តួល មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរលាស់ខ្លួនចេញសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលពួកខ្លះ ក្នុងលោកនេះ ស្វែងរកភោគសម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ

បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ តេ ច ភោគេ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ ។

[២៧៦] តត្រ គាមណិ យ្វាយំ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហាសេន អធម្មេន ភោគេ បរិយេសិត្វា សាហាសេន ន អត្តានំ សុខេតិ ន បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ អយំ គាមណិ កាមភោគី តីហិ ឋានេហិ គារយ្ហោ ។ កតមេហិ តីហិ ឋានេហិ គារយ្ហោ ។ អធម្មេន ភោគេ បរិយេសតិ សាហាសេនាតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ។ ន អត្តានំ សុខេតិ ន បិណេតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន គារយ្ហោ ។ អយំ គាមណិ កាមភោគី ឥមេហិ តីហិ ឋានេហិ គារយ្ហោ ។

ឲ្យឆ្អែតឆ្អន់ ទាំងចែករលែក ធ្វើបុណ្យទាំងឡាយទៀត ទាំងប្រើប្រាស់ភោគសម្ប័ទទាំងនោះ មិនជប់ មិនជ្រុលជ្រប់ មិនផ្តេកផ្តួល ជាអ្នកឃើញទោស មានបញ្ញាជាគ្រឿងរលាស់ខ្លួនចេញ ។

[២៧៦] ម្នាលគាមណិ បណ្តាកាមភោគីបុគ្គលទាំងនោះ កាមភោគីបុគ្គលឯណា ស្វែងរកភោគសម្ប័ទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្ខាហាន លុះស្វែងរកភោគសម្ប័ទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្ខាហានបានហើយ ក៏មិនធ្វើខ្លួនឲ្យបានសុខ មិនឲ្យឆ្អែតឆ្អន់ ទាំងមិនចែករលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះឯង ដែលបណ្ឌិតគួរតិះដៀលដោយហេតុ ៣ យ៉ាង ។ គួរតិះដៀលដោយហេតុ ៣ យ៉ាងតើដូចម្តេចខ្លះ ។ គួរតិះដៀលដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលស្វែងរកភោគសម្ប័ទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្ខាហាន ។ គួរតិះដៀលដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលមិនធ្វើខ្លួនឲ្យបានសុខ មិនឲ្យឆ្អែតឆ្អន់ ។ គួរតិះដៀលដោយហេតុទី ៣ ដូច្នេះថា កាមភោគីបុគ្គលមិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ ដែលបណ្ឌិតគួរតិះដៀលដោយហេតុទាំង ៣ ប្រការនេះឯង ។

[២៧៧] តត្រ គាមណិ យ្វាយំ កាមភោគី អ-
ធម្មេន ភោគេ បរិយេសតិ សាហសេន អធម្មេន ភោគេ
បរិយេសិត្វា សាហសេន អត្តានំ សុខេតិ បិណេតិ
ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ អយំ គាមណិ
កាមភោគី ទ្វីហិ ឋានេហិ គារយ្ហោ ឯកេន ឋានេន
បាសំសោ ។ កតមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ។
អធម្មេន ភោគេ បរិយេសតិ សាហសេនាតិ ឥមិនា
បឋមេន ឋានេន គារយ្ហោ ។ ន សំវិភជតិ ន បុញ្ញានិ
ករោតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។
កតមេន ឯកេន ឋានេន បាសំសោ ។ អត្តានំ សុ-
ខេតិ បិណេតីតិ ឥមិនា ឯកេន ឋានេន បាសំសោ ។
អយំ គាមណិ កាមភោគី ឥមេហិ ទ្វីហិ ឋានេហិ
គារយ្ហោ ឥមិនា ឯកេន ឋានេន បាសំសោ ។

[២៧៧] ម្នាលគាមណិ បណ្តាកាមភោគីបុគ្គលទាំងនោះ កាមភោគីបុគ្គលឯណា ស្វែងរកភោគសម្ប័ទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្ប័ទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ប៉ុន្តែមិនចែករលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះឯង គួរតិះដៀលដោយហេតុ ២ ប្រការ គួរសរសើរដោយហេតុ ១ ប្រការ ។ គួរតិះដៀលដោយហេតុ ២ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្ប័ទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន ។ គួរតិះដៀលដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះមិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ គួរសរសើរដោយហេតុ ១ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុ ១ ប្រការដូច្នេះថា កាមភោគីបុគ្គលនោះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ ដែលបណ្ឌិតគួរតិះដៀលដោយហេតុទាំង ២ ប្រការនេះ គួរសរសើរដោយហេតុ ១ ប្រការនេះឯង ។

គាមណិសំយុត្តំ

[២៧៨] តត្រ គាមណិ យ្វាយំ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហាសេន អធម្មេន ភោគេ បរិយេសិត្វា សាហាសេន អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ ។ មយំ គាមណិ កាម-ភោគី ឯកេន ឋានេន គារយ្ហោ ទ្វីហិ ឋានេហិ បាសំសោ ។ កតមេន ឯកេន ឋានេន គារយ្ហោ ។ អធម្មេន ភោគេ បរិយេសតិ សាហាសេនាតិ ឥមិនា ឯកេន ឋានេន គារយ្ហោ ។ កតមេហិ ទ្វីហិ ឋានេហិ បាសំសោ ។ អត្តានំ សុខេតិ បិណេតីតិ ឥមិនា បឋមេន ឋានេន បាសំសោ ។ សំវិភជតិ បុញ្ញានិ ករោតីតិ ឥមិនា ទុតិយេន ឋានេន បាសំសោ ។ អយំ គាមណិ កាមភោគី ឥមិនា ឯកេន ឋានេន គារយ្ហោ ឥមេហិ ទ្វីហិ ឋានេហិ បាសំសោ ។

គាមណិសំយុត្ត

[២៧៨] ម្នាលគាមណិ បណ្តាកាមភោគីបុគ្គលទាំងនោះ កាម-ភោគីបុគ្គលឯណា ស្វែងរកភោគសម្បត្តិដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បត្តិដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ទាំងចែករំលែក ធ្វើបុណ្យទាំងឡាយផង ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរតិះដៀលដោយហេតុ ១ ប្រការ គួរសរសើរដោយហេតុ ២ ប្រការ ។ គួរតិះដៀលដោយហេតុ ១ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុ ១ ប្រការដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្បត្តិដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន ។ គួរសរសើរដោយហេតុ ២ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុទី ១ ដូច្នេះថា កាមភោគី-បុគ្គលនោះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ។ គួរសរសើរដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះចែករំលែក ធ្វើបុណ្យទាំងឡាយ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ ដែលបណ្ឌិតគួរតិះដៀលដោយហេតុ ១ ប្រការនេះ គួរសរសើរដោយហេតុ ២ ប្រការនេះឯង ។

[២៧៩] តត្រ គាមណិ យ្វាយំ កាមភោគី ធម្មា-
ធម្មេ ភោគេ បរិយេសតិ សាហាសេនបិ អសាហា-
សេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហាសេ-
នបិ អសាហាសេនបិ ន អត្តានំ សុខេតិ ន បិណេតិ
ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ អយំ គាមណិ
កាមភោគី ឯកេន ឋានេន ចាសំសោ តីហិ ឋានេហិ
គារយ្ហោ ។ កតមេន ឯកេន ឋានេន ចាសំសោ ។
ធម្មេន ភោគេ បរិយេសតិ អសាហាសេនាតិ ឥមិនា
ឯកេន ឋានេន ចាសំសោ ។ កតមេហិ តីហិ ឋា-
នេហិ គារយ្ហោ ។ អធម្មេន ភោគេ បរិយេសតិ សាហា-
សេនាតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ។ ន
អត្តានំ សុខេតិ ន បិណេតីតិ ឥមិនា ទុតិយេន ឋានេន
គារយ្ហោ ។ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា
តតិយេន ឋានេន គារយ្ហោ ។ អយំ គាមណិ
កាមភោគី ឥមិនា ឯកេន ឋានេន ចាសំសោ ឥមេហិ
តីហិ ឋានេហិ គារយ្ហោ ។

[២៧៩] ម្នាលគាមណិ បណ្តាកាមភោគីបុគ្គលទាំងនោះ កាម-ភោគីបុគ្គលឯណា ស្វែងរកភោគសម្បទដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាននិងមិនក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាននិងមិនក្លាហានបានហើយ ក៏មិនធ្វើខ្លួនឲ្យបានសុខ មិនឲ្យឆ្អែតឆ្អន់ ទាំងមិនចែករលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ១ ប្រការ គួរតិះដៀលដោយហេតុ ៣ ប្រការ ។ គួរសរសើរដោយហេតុ ១ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុ ១ ប្រការដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្បទដោយធម៌ មិនជាអំពើដ៏ក្លាហាន ។ គួរតិះដៀលដោយហេតុ ៣ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្បទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន ។ គួរតិះដៀលដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះមិនធ្វើខ្លួនឲ្យបានសុខ មិនឲ្យឆ្អែតឆ្អន់ ។ គួរតិះដៀលដោយហេតុទី ៣ ដូច្នេះថា កាមភោគីបុគ្គលនោះមិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ១ ប្រការនេះ គួរតិះដៀលដោយហេតុ ៣ ប្រការនេះឯង ។

[២៨០] តត្រ គាមណិ យ្វាយំ កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហាសេនបិ អសាហាសេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហាសេនបិ អសាហាសេនបិ អត្តានំ សុខេតិ បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ អយំ គាមណិ កាមភោគី ទ្វីហិ ឋានេហិ បាសំសោ ទ្វីហិ ឋានេហិ គារយ្ហោ ។ កតមេហិ ទ្វីហិ ឋានេហិ បាសំសោ ។ ធម្មេន ភោគេ បរិយេសតិ អសាហាសេនាតិ ឥមិនា បឋមេន ឋានេន បាសំសោ ។ អត្តានំ សុខេតិ បិណេតីតិ ឥមិនា ទុតិយេន ឋានេន បាសំសោ ។ កតមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ។ អធម្មេន ភោគេ បរិយេសតិ សាហាសេនាតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ។ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។ អយំ គាមណិ កាមភោគី ឥមេហិ ទ្វីហិ ឋានេហិ បាសំសោ ឥមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ។

គាមណិសំយុត្ត

[២៨០] ម្នាលគាមណិ បណ្តាកាមភោគីបុគ្គលទាំងនោះ កាមភោគីបុគ្គលឯណា ស្វែងរកភោគសម្ប័ទដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាននិងមិនក្លាហាន លុះស្វែងរកភោគសម្ប័ទដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាននិងមិនក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ប៉ុន្តែមិនចែករំលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ២ ប្រការ គួរតិះដៀលដោយហេតុ ២ ប្រការ ។ គួរសរសើរដោយហេតុ ២ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្ប័ទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន ។ គួរសរសើរដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ។ គួរតិះដៀលដោយហេតុ ២ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះ ស្វែងរកភោគសម្ប័ទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន ។ គួរតិះដៀលដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះមិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ២ ប្រការនេះ គួរតិះដៀលដោយហេតុ ២ ប្រការនេះឯង ។

[២៨១] តត្រ គាមណិ យ្វាយំ កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហាសេនបិ អសាហាសេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហាសេនបិ អសាហាសេនបិ អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ ។ អយំ គាមណិ កាមភោគី តីហិ ឋានេហិ ចាសំសោ ឯកេន ឋានេន បាសំសោ ។ កតមេហិ តីហិ ឋានេហិ ចាសំសោ ។ ធម្មេន ភោគេ បរិយេសតិ អសាហាសេនាតិ ឥមិនា បឋមេន ឋានេន ចាសំសោ ។ អត្តានំ សុខេតិ បិណេតីតិ ឥមិនា ទុតិយេន ឋានេន ចាសំសោ ។ សំវិភជតិ បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន ចាសំសោ ។ កតមេន ឯកេន ឋានេន បាសំសោ ។ អធម្មេន ភោគេ បរិយេសតិ សាហាសេនាតិ ឥមិនា ឯកេន ឋានេន បាសំសោ ។ អយំ គាមណិ កាមភោគី ឥមេហិ តីហិ ឋានេហិ ចាសំសោ ឥមិនា ឯកេន ឋានេន បាសំសោ ។

[២៨១] ម្នាលគាមណិ បណ្តាកាមភោគីបុគ្គលទាំងនោះ កាមភោគីបុគ្គលឯណា ស្វែងរកភោគសម្បទដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាននិងមិនក្លាហាន លុះស្វែងរកភោគសម្បទដោយអំពើជាធម៌ខ្លះ មិនមែនជាធម៌ខ្លះ ជាអំពើដ៏ក្លាហាននិងមិនក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ទាំងចែករលែក ធ្វើបុណ្យទាំងឡាយទៀត ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ៣ ប្រការ គួរតិះដៀលដោយហេតុ ១ ប្រការ ។ គួរសរសើរដោយហេតុ ៣ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះ ស្វែងរកភោគសម្បទដោយអំពើជាធម៌ ជាអំពើមិនក្លាហាន ។ គួរសរសើរដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ។ គួរសរសើរដោយហេតុទី ៣ ដូច្នេះថា កាមភោគីបុគ្គលនោះចែករលែក ធ្វើបុណ្យទាំងឡាយ ។ គួរតិះដៀលដោយហេតុ ១ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុ ១ ប្រការដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្បទដោយអំពើមិនមែនជាធម៌ ជាអំពើដ៏ក្លាហាន ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះឯង គួរសរសើរដោយហេតុ ៣ ប្រការនេះ គួរតិះដៀលដោយហេតុ ១ ប្រការនេះឯង ។

គាមណិសំយុត្តំ

[២៨២] តត្រ គាមណិ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហាសេន ធម្មេន ភោគេ បរិយេសិត្វា អសាហាសេន ន អត្តានំ សុខេតិ ន បីណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ អយំ គាមណិ កាមភោគី ឯកេន ឋានេន បាសំសោ ទ្វីហិ ឋានេហិ គារយ្ហោ ។ កតមេន ឯកេន ឋានេន បាសំសោ ។ ធម្មេន ភោគេ បរិយេសតិ អសាហាសេនាតិ ឥមិនា ឯកេន ឋានេន បាសំសោ ។ កតមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ។ ន អត្តានំ សុខេតិ ន បីណេតីតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ។ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។ អយំ គាមណិ កាមភោគី ឥមិនា ឯកេន ឋានេន បាសំសោ ឥមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ។

[២៨២] ម្នាលគាមណិ បណ្តាកាមភោគីបុគ្គលទាំងនោះ កាមភោគីបុគ្គលឯណា ស្វែងរកភោគសម្ប័ទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្ប័ទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហានបានហើយ ក៏មិនធ្វើខ្លួនឲ្យបានសុខ មិនឲ្យឆ្អែតឆ្អន់ ទាំងមិនចែករលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ១ ប្រការ គួរតិះដៀលដោយហេតុ ២ ប្រការ ។ គួរសរសើរដោយហេតុ ១ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុ ១ ប្រការដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្ប័ទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន ។ គួរតិះដៀលដោយហេតុ ២ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះមិនធ្វើខ្លួនឲ្យបានសុខ មិនឲ្យឆ្អែតឆ្អន់ ។ គួរតិះដៀលដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះមិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ១ ប្រការនេះ គួរតិះដៀលដោយហេតុ ២ ប្រការនេះឯង ។

[២៨៣] តត្រ គាមណិ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហាសេន ធម្មេន ភោគេ បរិយេសិត្វា អសាហាសេន អត្តានំ សុខេតិ បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ អយំ គាមណិ កាមភោគី ទ្វីហិ ឋានេហិ បាសំសោ ឯកេន ឋានេន គារយ្ហោ ។ កតមេហិ ទ្វីហិ ឋានេហិ បាសំសោ ។ ធម្មេន ភោគេ បរិយេសតិ អសាហាសេនាតិ ឥមិនា បឋមេន ឋានេន បាសំសោ ។ អត្តានំ សុខេតិ បិណេតីតិ ឥមិនា ទុតិយេន ឋានេន បាសំសោ ។ កតមេន ឯកេន ឋានេន គារយ្ហោ ។ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា ឯកេន ឋានេន គារយ្ហោ ។ អយំ គាមណិ កាមភោគី ឥមេហិ ទ្វីហិ ឋានេហិ បាសំសោ ឥមិនា ឯកេន ឋានេន គារយ្ហោ ។

[២៨៣] ម្នាលគាមណិ បណ្ដាកាមភោគីបុគ្គលទាំងនោះ កាមភោគីបុគ្គលឯណា ស្វែងរកភោគសម្បត្តិដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បត្តិដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ប៉ុន្តែមិនចែករលែក មិនធ្វើបុណ្យទាំងឡាយសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះឯង គួរសរសើរដោយហេតុ ២ ប្រការ គួរតិះដៀលដោយហេតុ ១ ប្រការ ។ គួរសរសើរដោយហេតុ ២ ប្រការតើដូចម្ដេច ។ គួរសរសើរដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្បត្តិដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន ។ គួរសរសើរដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ។ គួរតិះដៀលដោយហេតុ ១ ប្រការតើដូចម្ដេច ។ គួរតិះដៀលដោយហេតុ ១ ប្រការដូច្នេះថា កាមភោគីបុគ្គលនោះមិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ២ ប្រការនេះ គួរតិះដៀលដោយហេតុ ១ ប្រការនេះឯង ។

## គាមណិសំយុត្តំ

[២៨៤] តត្រ គាមណិ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ តេ ច ភោគេ គធិតោ មុច្ឆិ-តោ អជ្ឈាបន្នោ អនាទីនវទស្សាវី អនិស្សរណប្បញ្ញោ បរិភុញ្ជតិ ។ អយំ គាមណិ កាមភោគី តីហិ ឋានេហិ បាសំសោ ឯកេន ឋានេន គារយ្ហោ ។ កតមេហិ តីហិ ឋានេហិ បាសំសោ ។ ធម្មេន ភោគេ បរិយេសតិ អសាហសេនាតិ ឥមិនា បឋមេន ឋានេន បាសំសោ ។

គាមណិសំយុត្ត

[២៨២] ម្នាលគាមណិ បណ្តាកាមភោគីបុគ្គលទាំងនោះ កាម-ភោគីបុគ្គលឯណា ស្វែងរកភោគសម្បត្តិដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បត្តិដោយអំពើជាធម៌ មិនជាអំពើដ៏ក្លា-ហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ទាំងចែករលែក ធ្វើបុណ្យទាំងឡាយ ប៉ុន្តែប្រើប្រាស់ភោគសម្បត្តិទាំងនោះ ងប់ ជ្រុលជ្រប់ផ្តេកផ្តួល មិនឃើញទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ចេញសោះ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ៣ ប្រការ គួរតិះដៀលដោយហេតុ ១ ប្រការ ។ គួរសរសើរដោយហេតុ ៣ ប្រការ តើដូចម្តេច ។ គួរសរសើរដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគសម្បត្តិដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន ។

អត្តានំ សុខេតិ បិណេតីតិ ឥមិនា ទុតិយេន ឋានេន ចាសំសោ ។ សំវិភជតិ បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន ចាសំសោ ។ ឯកេន ឋានេន ការយ្ហោ ។ តេ ច ភោគេ គធិតោ មុច្ឆិតោ អជ្ឈោបន្នោ អនាទីនវទស្សាវី អនិស្សរណបញ្ញោ បរិភុញ្ជតីតិ ឥមិនា ឯកេន ឋានេន ការយ្ហោ ។ អយំ គាមណិ កាមភោគី ឥមេហិ តីហិ ឋានេហិ ចាសំសោ ឥមិនា ឯកេន ឋានេន ការយ្ហោ ។

[២៨៥] តត្រ គាមណិ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ តេ ច ភោគេ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវទស្សាវី និស្សរ-

គួរសរសើរដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ។ គួរសរសើរដោយហេតុទី ៣ ដូច្នេះថា កាមភោគីបុគ្គលនោះចែករលែក ធ្វើបុណ្យទាំងឡាយ ។ គួរតិះដៀលដោយហេតុ ១ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុ ១ ប្រការដូច្នេះថា កាមភោគីបុគ្គលនោះ ប្រើប្រាស់ភោគសម្បត្តិទាំងនោះ ងប់ ជ្រុលជ្រប់ ផ្តេកផ្តួល មិនឃើញទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញសោះ ។ ម្នាលគាមណី កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ៣ ប្រការនេះ គួរតិះដៀលដោយហេតុ ១ ប្រការនេះឯង ។

[២៨៥] ម្នាលគាមណី បណ្តាកាមភោគីបុគ្គលទាំងនោះ កាមភោគីបុគ្គលឯណា ស្វែងរកភោគសម្បត្តិដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន លុះស្វែងរកភោគសម្បត្តិដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហានបានហើយ ក៏ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ទាំងចែករលែក ធ្វើបុណ្យទាំងឡាយ ទាំងប្រើប្រាស់ភោគសម្បត្តិទាំងនោះ មិនងប់ មិនជ្រុលជ្រប់ មិនផ្តេកផ្តួល ជាអ្នកឃើញទោស មានប្រាជ្ញាជាគ្រឿង

ណប្បញ្ញោ បរិភុញ្ជតិ ។ អយំ គាមណិ កាមភោគី ចតូហិ ឋានេហិ បាសំសោ ។ កតមេហិ ចតូហិ ឋានេហិ បាសំសោ ។ ធម្មេន ភោគេ បរិយេសតិ អសាហសេនាតិ ឥមិនា បឋមេន ឋានេន បាសំសោ ។ អត្តានំ សុខេតិ បីណេតីតិ ឥមិនា ទុតិយេន ឋានេន បាសំសោ ។ សំវិភជតិ បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន បាសំសោ ។ តេ ច ភោគេ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតីតិ ឥមិនា ចតុត្ថេន ឋានេន បាសំសោ ។ អយំ គាមណិ កាមភោគី ឥមេហិ ចតូហិ ឋានេហិ បាសំសោ ។

រលាស់ខ្លួនចេញ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ៤ ប្រការ ។ គួរសរសើរដោយហេតុ ៤ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុទី ១ ដូច្នេះថា កាមភោគីបុគ្គលនោះស្វែងរកភោគ-សម្បទដោយអំពើជាធម៌ មិនជាអំពើដ៏ក្លាហាន ។ គួរសរសើរដោយហេតុទី ២ ដូច្នេះថា កាមភោគីបុគ្គលនោះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតឆ្អន់ ។ គួរសរសើរដោយហេតុទី ៣ ដូច្នេះថា កាមភោគីបុគ្គលនោះចែករលែក ធ្វើបុណ្យទាំងឡាយ ។ គួរសរសើរដោយហេតុទី ៤ ដូច្នេះថា កាមភោគីបុគ្គលនោះប្រើប្រាស់ភោគសម្បទទាំងនោះ មិនងប់ មិនជ្រុលជ្រប់ មិនផ្តេកផ្តួល ជាអ្នកឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ ។ ម្នាលគាមណិ កាមភោគីបុគ្គលនេះ គួរសរសើរដោយហេតុ ៤ ប្រការនេះឯង ។

[២៨៦] តយោមេ គាមណិ តបស្សិនោ លូខជីវិនោ សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ ឥធ គាមណិ ឯកច្ចោ តបស្សី លូខជីវី សទ្ធោ[១] អគារស្មា អនគារិយំ បព្វជិតោ ហោតិ អប្បេវនាម កុសលំ ធម្មំ អធិគច្ឆេយ្យំ អប្បេវនាម ឧត្តរិមនុស្សធម្មំ[២] អលមរិយញ្ញាណទស្សនវិសេសំ សច្ឆិករេយ្យន្តិ ។ សោ អត្តានំ អាតាបេតិ បរិតាបេតិ កុសលញ្ច ធម្មំ នាធិគច្ឆតិ ឧត្តរិមនុស្សធម្មំ អលមរិយសញ្ញាណទស្សនវិសេសំ ន សច្ឆិករោតិ ។ ឥធ បន គាមណិ ឯកច្ចោ តបស្សី លូខជីវី សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ អប្បេវនាម កុសលំ ធម្មំ អធិគច្ឆេយ្យំ អប្បេវនាម ឧត្តរិមនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ សច្ឆិករេយ្យន្តិ ។ សោ អត្តានំ អាតាបេតិ

១ ឱ. ម. សទ្ធា ។ ២ ឧត្តរិមនុស្សធម្មា ។

[២៨៦] ម្នាលគាមណី បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មង ៣ ពួកនេះ មាននៅក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្តេច ។ ម្នាលគាមណី បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មង មានសទ្ធា ចេញចាកផ្ទះទៅបួសដោយគិតថា ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីបានសម្រេចនូវកុសលធម៌ ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរ ។ បុគ្គលនោះធ្វើខ្លួនឲ្យក្តៅក្រហាយឲ្យខ្លោចផ្សាផង មិនបានសម្រេចនូវកុសលធម៌ផង មិនធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរផង ។ ម្នាលគាមណី បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មង មានសទ្ធា ចេញចាកផ្ទះទៅបួសដោយគិតថា ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីបានសម្រេចនូវកុសលធម៌ ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរ ។ បុគ្គលនោះធ្វើខ្លួនឲ្យក្តៅក្រហាយ

បរិតាបេតិ កុសលំ ហិ ខោ ធម្មំ អធិគច្ឆតិ ឧត្តរិម-
នុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ ន សច្ឆិក-
រោតិ ។ ឥធ បន គាមណិ ឯកច្ចោ តបស្សី លូខជីវី
សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ អប្បេវ-
នាម កុសលំ ធម្មំ អធិគច្ឆេយ្យំ អប្បេវនាម ឧត្តរិ-
មនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ សច្ឆិក-
រេយ្យន្តិ ។ សោ អត្តានំ អាតាបេតិ បរិតាបេតិ កុស-
លញ្ច ធម្មំ អធិគច្ឆតិ ឧត្តរិមនុស្សធម្មំ អលមរិយញ្ញា-
ណទស្សនវិសេសំ សច្ឆិករោតិ ។

[២៨៧] តត្រ គាមណិ យ្វាយំ តបស្សី លូខជីវី
អត្តានំ អាតាបេតិ បរិតាបេតិ កុសលញ្ច ធម្មំ នាធិ-
គច្ឆតិ ឧត្តរិមនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ
ន សច្ឆិករោតិ ។ អយំ គាមណិ តបស្សី លូខ-

ឲ្យខ្លោចផ្សា ក៏បានសម្រេចនូវកុសលធម៌នោះឯង តែមិនធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរឡើយ ។ ម្នាលគាមណិ បុគ្គលពួកមួយក្នុងលោកនេះ មានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មង មានសទ្ធា ចេញចាកផ្ទះទៅបួស ដោយគិតថាធ្វើម្តេចហ្ន៎ អាត្មាអញគប្បីបានសម្រេចនូវកុសលធម៌ ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិ-សេស ដែលគួរឃើញដោយញាណដ៏ប្រសើរ ។ បុគ្គលនោះធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យខ្លោចផ្សា ក៏បានសម្រេចនូវកុសលធម៌ផង ធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរផង ។

[២៨៧] ម្នាលគាមណិ បណ្តាបុគ្គលទាំងនោះ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏ស្មៅហ្មងឯណា ធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យខ្លោចផ្សាផង មិនបានសម្រេចនូវកុសលធម៌ មិនធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរផង ។ ម្នាលគាមណិ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅ-

ជីវី តីហិ ឋានេហិ គារយ្ហោ ។ កតមេហិ តីហិ ឋានេហិ គារយ្ហោ ។ អត្តានំ អាតាបេតិ បរិតាបេតីតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ។ កុសលញ្ច ធម្មំ នាធិគច្ឆតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។ ឧត្តរិមនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ ន សច្ឆិករោតីតិ ឥមិនា តតិយេន ឋានេន គារយ្ហោ ។ អយំ គាមណិ តបស្សី លូខជីវី ឥមេហិ តីហិ ឋានេហិ គារយ្ហោ ។

[២៨៨] តត្រ គាមណិ យ្វាយំ តបស្សី លូខជីវី អត្តានំ អាតាបេតិ បរិតាបេតិ កុសលញ្ហិ ខោ ធម្មំ អធិគច្ឆតិ ឧត្តរិមនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ ន សច្ឆិករោតិ ។ អយំ គាមណិ តបស្សី លូខជីវី ទ្វីហិ ឋានេហិ គារយ្ហោ ឯកេន ឋានេន ចាសំសោ ។ កតមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ។ អត្តានំ អាតាបេតិ បរិតាបេតីតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ។

ហ្នឹងនេះ គួរតិះដៀលដោយហេតុ ៣ ប្រការ ។ គួរតិះដៀលដោយហេតុ ៣ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុទី ១ ដូច្នេះថា បុគ្គលនោះធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យខ្វោចផ្សា ។ គួរតិះដៀលដោយហេតុទី ២ ដូច្នេះថា បុគ្គលនោះមិនបានសម្រេចនូវកុសលធម៌ ។ គួរតិះ-ដៀលដោយហេតុទី ៣ ដូច្នេះថា បុគ្គលនោះមិនធ្វើឲ្យជាក់ច្បាស់នូវឧត្តរិ-មនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរ ។ ម្នាលគាមណិ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មងនេះ គួរតិះដៀលដោយហេតុ ៣ ប្រការនេះឯង ។

[២៨៨] ម្នាលគាមណិ បណ្តាបុគ្គលទាំងនោះ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មងឯណា ធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យខ្វោចផ្សា ក៏បានសម្រេចនូវកុសលធម៌ តែមិនធ្វើឲ្យជាក់ច្បាស់នូវឧត្តរិ-មនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរ ។ ម្នាលគាមណិ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មងនេះ គួរតិះដៀលដោយហេតុ ២ ប្រការ គួរសរសើរដោយហេតុ ១ ប្រការ ។ គួរតិះដៀលដោយហេតុ ២ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុទី ១ ដូច្នេះថា បុគ្គលនោះធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យខ្វោចផ្សា ។

ឧត្តរិមនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ ន សច្ឆិករោតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។ កតមេន ឯកេន ឋានេន បាសំសោ ។ កុសលំ ហិ ខោ ធម្មំ អធិគច្ឆតីតិ ឥមិនា ឯកេន ឋានេន បាសំសោ ។ អយំ គាមណិ តបស្សី លូខជីវី ឥមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ឥមិនា ឯកេន ឋានេន បាសំសោ ។

[២៨៩] តត្រ គាមណិ យ្វាយំ តបស្សី លូខជីវី អត្តានំ អាតាបេតិ បរិតាបេតិ កុសលំ ច ធម្មំ អធិគច្ឆតិ ឧត្តរិមនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ សច្ឆិករោតិ ។ អយំ គាមណិ តបស្សី លូខជីវី ឯកេន ឋានេន គារយ្ហោ ទ្វីហិ ឋានេហិ បាសំសោ ។ កតមេន ឯកេន ឋានេន គារយ្ហោ ។ អត្តានំ អាតាបេតិ បរិតាបេតីតិ ឥមិនា ឯកេន ឋានេន គារយ្ហោ ។ កតមេហិ ទ្វីហិ ឋានេហិ បាសំសោ ។ កុសលំ ច ធម្មំ អធិគច្ឆតីតិ ឥមិនា បបមេន ឋានេន បាសំសោ ។

គួរតិះដៀលដោយហេតុទី ២ ដូច្នេះថា បុគ្គលនោះមិនធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរ ។ គួរសរសើរដោយហេតុ ១ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុ ១ ប្រការដូច្នេះថា បុគ្គលនោះបានសម្រេចនូវកុសលធម៌ ។ ម្នាលគាមណិ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មងនេះ គួរតិះដៀលដោយហេតុ ២ ប្រការនេះ គួរសរសើរដោយហេតុ ១ ប្រការនេះឯង ។

[២៨៩] ម្នាលគាមណិ បណ្តាបុគ្គលទាំងនោះ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មងឯណា ធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យខ្លោចផ្សា ក៏បានសម្រេចនូវកុសលធម៌ផង បានធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរផង ។ ម្នាលគាមណិ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មងនេះ គួរតិះដៀលដោយហេតុ ១ ប្រការ គួរសរសើរដោយហេតុ ២ ប្រការ ។ គួរតិះដៀលដោយហេតុ ១ ប្រការតើដូចម្តេច ។ គួរតិះដៀលដោយហេតុ ១ ប្រការដូច្នេះថា បុគ្គលនោះធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យខ្លោចផ្សា ។ គួរសរសើរដោយហេតុ ២ ប្រការតើដូចម្តេច ។ គួរសរសើរដោយហេតុទី ១ ដូច្នេះថា បុគ្គលនោះបានសម្រេចនូវកុសលធម៌ ។

ឧត្តរិមនុស្សធម្មំ អលមរិយញ្ញាណទស្សនវិសេសំ សច្ឆិ-
ករោតីតិ ឥមិនា ទុតិយេន ឋានេន ចាសំសោ ។ អយំ
គាមណិ តបស្សី លូខជីវី ឥមិនា ឯកេន ឋានេន
គារយ្ហោ ឥមេហិ ទ្វីហិ ឋានេហិ ចាសំសោ ។

[២៩០] តិស្សោ ឥមា គាមណិ សន្ទិដ្ឋិកា និជ្ជ-
រា អកាលិកា ឯហិបស្សិកា ឱបនយិកា បច្ចត្តំ
វេទិតព្វា វិញ្ញូហិ ។ កតមា តិស្សោ ។ យំ រត្តោ
រាគាធិករណំ អត្តព្យាពាធាយបិ[១] ចេតេតិ បរព្យាពា-
ធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ រាគេ
បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យា-
ពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេ-
តេតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិ-
កា ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហិ ។ យំ
ទុដ្ឋោ ទោសាធិករណំ អត្តព្យាពាធាយបិ ចេតេតិ

១ ម. អត្តព្យាបាទាយបិ ។

គួរសរសើរដោយហេតុទី ២ ដូច្នេះថា បុគ្គលនោះធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេស ដែលគួរឃើញដោយញាណដ៏ប្រសើរ ។ ម្នាលគាមណិ បុគ្គលអ្នកមានតបៈ មានការចិញ្ចឹមជីវិតដ៏សៅហ្មងនេះ គួរតិះដៀលដោយហេតុ ១ ប្រការនេះ គួរសរសើរដោយហេតុ ២ ប្រការនេះឯង ។

[២៩០] ម្នាលគាមណិ ធម្មជាតិ ៣ ប្រការនេះជាធម្មជាតិដែលបុគ្គលឃើញច្បាស់ខ្លួនឯង មិនចេះចាស់ ឲ្យផលមិនរង់ចាំកាល គួរដល់ឯហិបស្សវិធី គួរបង្អោនចូលមកទុកក្នុងចិត្ត អ្នកប្រាជ្ញទាំងឡាយគួរដឹងច្បាស់ចំពោះខ្លួន ។ ធម្មជាតិ ៣ ប្រការតើដូចម្តេច ។ បុគ្គលអ្នកមានតម្រេក តែងត្រិះរិះដើម្បីបៀតបៀនខ្លួនឯងផង ត្រិះរិះដើម្បីបៀតបៀនបុគ្គលដទៃផង ត្រិះរិះដើម្បីបៀតបៀនទាំងពីរខាងផង ព្រោះមានតម្រេកជាហេតុ កាលបើបុគ្គលលះបង់តម្រេកបានហើយ ព្រោះមានតម្រេកបៀតបៀនខ្លួនឯងផង មិនត្រិះរិះដើម្បីបៀតបៀនបុគ្គលដទៃផង មិនត្រិះរិះដើម្បីបៀតបៀនទាំងពីរខាងផង (នេះ) ជាធម្មជាតិដែលបុគ្គលឃើញច្បាស់ខ្លួនឯង មិនចេះចាស់ ឲ្យផលមិនរង់ចាំកាល គួរដល់ឯហិបស្សវិធី គួរបង្អោនមកទុកក្នុងចិត្ត អ្នកប្រាជ្ញទាំងឡាយគួរដឹងច្បាស់ចំពោះខ្លួន ។ បុគ្គលអ្នកមានចិត្តប្រទូស្ត តែងត្រិះរិះដើម្បីបៀតបៀនខ្លួនឯងផង

បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ទោសេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេ-តេតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហិ ។ យំ មូឡ្ហោ មោហាភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពា-ធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ មោហេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យា-ពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេតេតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា ឱប-នយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហិ ។ ឥមា ខោ គាមណិ តិស្សោ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា

ត្រិះរិះដើម្បីបៀតបៀនបុគ្គលដទៃផង ត្រិះរិះដើម្បីបៀតបៀនទាំងពីរខាងផង ព្រោះមានចិត្តប្រទូស្តជាហេតុ កាលបើបុគ្គលលះបង់ចិត្តប្រទូស្តបានហើយ ទើបមិនត្រិះរិះដើម្បីបៀតបៀនខ្លួនឯងផង មិនត្រិះរិះដើម្បីបៀតបៀនបុគ្គលដទៃផង មិនត្រិះរិះដើម្បីបៀតបៀនទាំងពីរខាងផង (នេះ) ជាធម្មជាតិដែលបុគ្គលឃើញច្បាស់ខ្លួនឯង មិនបេះចាស់ ឲ្យផលមិនរង់ចាំកាល គួរដល់ឯហិបស្សវិធី គួរបង្អោនមកទុកក្នុងចិត្ត អ្នកប្រាជ្ញទាំង-ឡាយ គួរដឹងច្បាស់ចំពោះខ្លួន ។ បុគ្គលអ្នកវង្វេង តែងត្រិះរិះដើម្បីបៀតបៀនខ្លួនឯងផង ត្រិះរិះដើម្បីបៀតបៀនបុគ្គលដទៃផង ត្រិះរិះដើម្បីបៀតបៀនទាំងពីរខាងផង ព្រោះមានសេចក្តីវង្វេងជាហេតុ កាលបើបុគ្គលលះបង់សេចក្តីវង្វេងបានហើយ ទើបមិនត្រិះរិះដើម្បីបៀតបៀនខ្លួនឯងផង មិនត្រិះរិះដើម្បីបៀតបៀនបុគ្គលដទៃផង មិនត្រិះរិះដើម្បីបៀតបៀនទាំងពីរខាងផង (នេះ) ជាធម្មជាតិដែលបុគ្គលឃើញច្បាស់ខ្លួនឯង មិនបេះចាស់ ឲ្យផលមិនរង់ចាំកាល គួរដល់ឯហិបស្សវិធី គួរបង្អោនមកទុកក្នុងចិត្ត អ្នកប្រាជ្ញទាំងឡាយគួរដឹងច្បាស់ចំពោះខ្លួន ។ ម្នាលគាមណិ ធម្មជាតិទាំង ៣ ប្រការនេះឯង ជាធម្មជាតិដែលបុគ្គលឃើញច្បាស់ខ្លួនឯង មិនបេះចាស់ ឲ្យផលមិនរង់ចាំកាល គួរដល់ ឯហិបស្សវិធី

ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហីតិ ។ ឯវំ វុត្តេ

រាសិយោ គាមណី ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ

អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសកំ មំ ភគវា ធារេតុ

អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ ទ្វាទសមំ ។

[២៩១] ឯកំ សមយំ ភគវា កោឡិយេសុ

វិហរតិ ឧត្តរន្នាម កោឡិយានំ និគមោ ។ អថខោ

បាដលិយោ គាមណី យេន ភគវា តេនុបសង្កមិ

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

គួរបង្អោនមកទុកក្នុងចិត្ត អ្នកប្រាជ្ញទាំងឡាយគួរដឹងចំពោះខ្លួន ។ កាល បើព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ រាសិយគាមណី ពោល សរសើរព្រះមានព្រះភាគដូច្នេះថា ភ្លឺច្បាស់ណាស់ ព្រះអង្គ ភ្លឺច្បាស់ ណាស់ ព្រះអង្គ ។ បេ ។ សូមព្រះមានព្រះភាគទ្រង់ចាំទុកនូវខ្ញុំព្រះ អង្គថាជាឧបាសក អ្នកដល់សរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះ ជាដើមតទៅ ។ ចប់សូត្រទី ១២ ។

[១៩១] សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងនិគមឈ្មោះ ឧត្តរ របស់ពួកក្សត្រិយ៍កោឡិយៈ ក្នុងកោឡិយជនបទ ។ គ្រានោះ គាមណីឈ្មោះបាដលិយៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅ ដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។

## ៣០៧



ឯកមន្តំ និសិន្នោ ខោ បាដលិយោ គាមណី ភគវន្តំ ឯតទវោច សុតមេតំ ភន្តេ សមណោ គោតមោ មាយំ ជានាតីតិ ។ យេ តេ ភន្តេ ឯវមាហំសុ សមណោ គោតមោ មាយំ ជានាតីតិ ។ កច្ចិ តេ ភន្តេ ភគវតោ វុត្តវាទិនោ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុបាតោ គារយ្ហំ ឋានំ អាគច្ឆតិ ។ អនព្ភក្ខាតុកាមា[១] ហិ មយំ ភន្តេ ភគវន្តន្តិ ។ យេ តេ គាមណិ ឯវមាហំសុ សមណោ គោតមោ មាយំ ជានាតីតិ ។ វុត្តវាទិនោ ចេវ មេ តេ ន ច មំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុបាតោ គារយ្ហំ ឋានំ អាគច្ឆតីតិ ។ សច្ចំយេវ កិរ ភោ មយំ តេសំ សមណព្រាហ្មណានំ ន សទ្ទហាម សមណោ គោតមោ មាយំ ជានាតីតិ ។ សមណោ ខលុ ភោ គោតមោ មាយាវីតិ ។ យោ នុ ខោ គាមណិ

១ ម. អនព្ភាចិក្ខិតុកាមា ។

លុះបាដលិយគាមណីអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏-មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដូច្នេះថា ព្រះសមណគោតមចេះមាយា (កលឧបាយ) ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកជនឯណាជាអ្នកពោលថា ព្រះសមណគោតមចេះមាយាដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងនោះឈ្មោះថាជាអ្នកពោលតាមពាក្យដែលព្រះមានព្រះភាគត្រាស់ហើយផង មិនមែនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ពោលនូវធម៌សមគួរដល់ធម៌ផង លំអានពាក្យតូចធំណាមួយ ជាពាក្យប្រកបដោយធម៌ មិនដល់នូវហេតុគួរតិះដៀលទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គមិនមែនជាអ្នកចង់ពោលបង្កាច់ព្រះមានព្រះភាគទេ ។ ព្រះអង្គត្រាស់ថា ម្នាលគាមណី ពួកជនឯណាពោលថា ព្រះសមណគោតមចេះមាយាដូច្នេះ ។ ជនទាំងនោះឈ្មោះថា ពោលតាមពាក្យដែលតថាគតពោលហើយផង មិនមែនពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ពោលនូវធម៌សមគួរដល់ធម៌ផង លំអានពាក្យតូចធំណាមួយ ជាពាក្យប្រកបដោយធម៌ មិនដល់នូវហេតុគួរតិះដៀលទេ ។ យីអើ យើងមិនជឿសមណព្រាហ្មណ៍ទាំងនោះសោះ ឥឡូវឮថាព្រះសមណគោតមចេះមាយាពិតមែនហើយ ។ យីអើ ព្រះសមណគោតម ជាអ្នកមានមាយាដែរតើ ។ ម្នាលគាមណី បុគ្គលឯណា

ឯវំ វទេតិ អហំ មាយំ ជានាមីតិ ។ សោ ឯវំ វទេតិ អហំ មាយាវីតិ ។ តត្ថេវ តំ ភគវា ហោតិ តថេវ តំ សុគត[១] ហោតីតិ ។ តេនហិ គាមណិ តញ្ញេ[២]វេត្ថ បដិបុច្ឆិស្សាមិ ។ យថា តេ ខមេយ្យ តថា តំ ព្យាករេយ្យាសិ ។

[២៩២] តំ កឹ មញ្ញសិ គាមណិ ជានាសិ ត្វំ[៣] កោឡិយានំ លម្ពចូឡកេ ភដេតិ ។ ជានាមហំ ភន្តេ កោឡិយានំ លម្ពចូឡកេ ភដេតិ ។ តំ កឹ មញ្ញសិ គាមណិ កិមត្ថិយា កោឡិយានំ លម្ពចូឡកា ភដាតិ ។ យេ ច ភន្តេ កោឡិយានំ ចោរា តេ ច បដិសេធេតុំ យានិ ច កោឡិយានំ ទូតេយ្យានិ តានិ ច បហាតុំ[៤] ឯតទត្ថិយា ភន្តេ កោឡិយានំ លម្ពចូឡកា ភដាតិ ។ តំ កឹ មញ្ញសិ គាមណិ ជានាសិ ត្វំ កោឡិយានំ និគមេ លម្ពចូឡកេ ភដេ សីលវន្តេ វា តេ ទុស្សីលា

១ ឱ. សុគតោ ។ ២ តញ្ញេវេត្ថ ។ ៣ ឱ. ឯត្ថន្តរេ គាមណីតិបិ បាឋោ ហោតិ ។ ៤ វហាតុំ ។

ពោលថា ខ្ញុំចេះមាយាដូច្នេះ ។ បុគ្គលនោះក៏ដូចជាពោលថា ខ្ញុំជាអ្នកមានមាយាដូច្នេះដែរ ។ បពិត្រព្រះមានព្រះភាគ ពាក្យនោះរមែងមានក្នុងរឿងនោះ បពិត្រព្រះសុគត ពាក្យនោះរមែងមានដូច្នោះឯង ។ ម្នាលគាមណិ បើដូច្នោះ តថាគតនឹងសួរអ្នកក្នុងរឿងនុ៎ះ ។ អ្នកគាប់ចិត្តយ៉ាងណា អ្នកគប្បីព្យាកររឿងនោះយ៉ាងនោះចុះ ។

[២៩២] ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកស្គាល់ពួកលម្ពចូឡកៈ ជាអមាត្យរបស់ពួកក្សត្រិយ៍កោឡិយៈដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្គាល់ពួកលម្ពចូឡកៈជាអមាត្យរបស់ពួកក្សត្រិយ៍កោឡិយៈដែរ ។ ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច ពួកលម្ពចូឡកៈជាអមាត្យរបស់ពួកក្សត្រិយ៍កោឡិយៈមានប្រយោជន៍អ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកលម្ពចូឡកៈជាអមាត្យរបស់ពួកក្សត្រិយ៍កោឡិយៈមានប្រយោជន៍ដូច្នេះគឺ ដើម្បីរាំងរាពួកចោរនៃពួកកោឡិយៈផង ដើម្បីនាំទៅនូវទូតកម្មនៃពួកកោឡិយៈផង ។ ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកស្គាល់ពួកលម្ពចូឡកៈជាអមាត្យក្នុងនិគមរបស់ពួកកោឡិយៈថា អមាត្យទាំងនោះជាអ្នកមានសីលឬទ្រុស្ត

រាតិ ។ ជានាមហំ ភន្តេ កោលិយានំ លម្ពចូឡកេ ភដេ ទុស្សីលេ បាបធម្មេ យេ ច លោកេ ទុស្សីលា បាបធម្មា កោលិយានំ លម្ពចូឡកា ភដា តេសំ អញ្ញតរាតិ ។ យោ នុ ខោ គាមណិ ឯវំ វទេយ្យ បាដលិយោ គាមណី ជានាតិ កោលិយានំ លម្ព-ចូឡកេ ភដេ ទុស្សីលេ បាបធម្មេ បាដលិយោបិ គាមណី ទុស្សីលោ បាបធម្មោតិ សម្មា នុ ខោ សោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ អញ្ញេ ភន្តេ កោលិយានំ លម្ពចូឡកា ភដា អញ្ញោហ-មស្មិ អញ្ញថា ធម្មា កោលិយានំ លម្ពចូឡកា ភដា អញ្ញថា ធម្មោហមស្មីតិ ។ ត្វំ ហិ នាម គាមណិ ន លច្ឆសិ បាដលិយោ គាមណី ជានាតិ កោលិយានំ លម្ពចូឡកេ ភដេ ទុស្សីលេ បាបធម្មេ ន បាដ-លិយោ គាមណី ទុស្សីលោ បាបធម្មោតិ តស្មា[១]

---

១ ឱ. ម. កស្មា ។

សីលដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្គាល់ពួកលម្ពចូឡកៈជាអមាត្យរបស់ពួកក្សត្រិយ៍កោឡិយៈថាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់មួយទៀត ពួកជនឯណាអ្នកទ្រុស្តសីល មានធម៌អាក្រក់ក្នុងលោក បណ្តាជនទាំងនោះ ពួកលម្ពចូឡកៈជាអមាត្យរបស់ពួកក្សត្រិយ៍កោឡិយៈក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់មួយដែរ ។ ម្នាលគាមណិ ជនឯណាពោលយ៉ាងនេះថា បាដលិយគាមណិ ស្គាល់ពួកលម្ពចូឡកៈជាអមាត្យរបស់ពួក្សត្រិយ៍កោឡិយៈថាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ឯបាដលិយគាមណិក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ដែរ កាលបើជនទាំងនោះពោលដូច្នេះ តើឈ្មោះថាពោលដោយត្រឹមត្រូវដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកលម្ពចូឡកៈជាអមាត្យរបស់ពួកក្សត្រិយ៍កោឡិយៈជាពួកផ្សេង ខ្ញុំព្រះអង្គជាមនុស្សផ្សេង ពួកលម្ពចូឡកៈជាអមាត្យរបស់ពួកក្សត្រិយ៍កោឡិយៈមានធម៌ផ្សេង ខ្ញុំព្រះអង្គក៏មានធម៌ផ្សេង ។ ម្នាលគាមណិ អ្នកឯងមិនបាននូវពាក្យវោហារថា បាដលិយគាមណិ ស្គាល់ពួកលម្ពចូឡកៈជាអមាត្យរបស់ពួក្សត្រិយ៍កោឡិយៈថាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ចំណែកបាដលិយ-គាមណិក៏មិនមែនជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ទេ ព្រោះហេតុនោះ

តថាគតោ ន លច្ឆតិ តថាគតោ មាយំ ជានាតិ ន ច តថាគតោ មាយាវីតិ ។

[២៩៣] មាយញ្ចាហំ គាមណិ បជានាមិ មាយាយ ច វិបាកំ យថាបដិបន្នោ ច មាយាវី កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ បាណាតិបាតញ្ចាហំ គាមណិ បជានាមិ បាណាតិបាតស្ស ច វិបាកំ យថាបដិបន្នោ ច បាណាតិបាតី កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ អទិន្នាទានំ ចាហំ គាមណិ បជានាមិ អទិន្នាទានស្ស ច វិបាកំ យថាបដិបន្នោ ច អទិន្នាទាយី កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ កាមេសុ មិច្ឆាចារញ្ចាហំ គាមណិ បជានាមិ

ព្រះតថាគតក៏មិនបាននូវពាក្យរោហារថា ព្រះតថាគតស្គាល់មាយាមែន តែតថាគតមិនមែនជាអ្នកមានមាយាទេ ។

[២៩៣] ម្នាលគាមណិ តថាគតស្គាល់ច្បាស់នូវមាយានិងផល នៃមាយា ទាំងបុគ្គលអ្នកមានមាយា ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគត ស្គាល់ច្បាស់នូវបាណាតិបាតនិងផលនៃបាណាតិបាត ទាំងបុគ្គលអ្នក ធ្វើបាណាតិបាត ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់ នូវអទិន្នាទាននិងផលនៃអទិន្នាទាន ទាំងបុគ្គលអ្នកធ្វើអទិន្នាទាន ប្រតិ-បត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំ-ណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់នូវកាមេសុមិច្ឆាចារ

៣១១

គាមណិសំយុត្តំ

កាមេសុ មិច្ឆាចារស្ស ច វិបាកំ យថាបដិបន្នោ ច កាមេសុ មិច្ឆាចារី កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ មុសាវាទញ្ចាហំ គាមណិ បជានាមិ មុសាវាទស្ស ច វិបាកំ យថាបដិបន្នោ ច មុសាវាទី កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ បិសុណាវាចំ ចាហំ គាមណិ បជានាមិ បិសុណាវាចាយ ច វិបាកំ យថាបដិបន្នោ ច បិសុណាវាចោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ ផរុសវាចំ ចាហំ គាមណិ បជានាមិ ផរុសវាចាយ ច វិបាកំ យថាបដិបន្នោ ច ផរុសវាចោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ សម្ផប្បលាបញ្ចាហំ គាមណិ បជានាមិ

និងផលនៃកាមេសុមិច្ឆាចារ ទាំងបុគ្គលអ្នកប្រព្រឹត្តកាមេសុមិច្ឆាចារ ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់នូវមុសាវាទនិងផលនៃមុសាវាទ ទាំងបុគ្គលអ្នកពោលមុសាវាទ ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់ នូវបិសុណាវាចានិងផលនៃបិសុណាវាចា ទាំងបុគ្គលអ្នកពោលបិសុណាវាចា ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់នូវផរុសវាចានិងផលនៃផរុសវាចា ទាំងបុគ្គលអ្នកពោលផរុសវាចា ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់នូវសម្ផប្បលាបៈ

សម្ផប្បលាបស្ស ច វិបាកំ យថាបដិបន្នោ ច សម្ផប្ប-
លាបី កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ
វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ អ-
ភិជ្ឈញ្ចាហំ គាមណិ បជានាមិ អភិជ្ឈាយ ច វិបាកំ
យថាបដិបន្នោ ច អភិជ្ឈាលុ កាយស្ស ភេទា បរំ
មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច
បជានាមិ ។ ព្យាបាទប្បទោសញ្ចាហំ គាមណិ បជានា-
មិ ព្យាបាទប្បទោសស្ស ច វិបាកំ យថាបដិបន្នោ ច
ព្យាបន្នចិត្តោ កាយស្ស ភេទា បរំ មរណា អបាយំ
ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។
មិច្ឆាទិដ្ឋឹ ចាហំ គាមណិ បជានាមិ មិច្ឆាទិដ្ឋិយា ច
វិបាកំ យថាបដិបន្នោ ច មិច្ឆាទិដ្ឋិកោ កាយស្ស
ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ
ឧបបជ្ជតិ តញ្ច បជានាមិ ។

និងផលនៃសម្ផប្បលាបៈ ទាំងបុគ្គលអ្នកពោលសម្ផប្បលាបៈ ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់នូវអភិជ្ឈានិងផលនៃអភិជ្ឈា ទាំងបុគ្គលអ្នកមានអភិជ្ឈា ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់ នូវសេចក្តីប្រទូស្តដោយអំណាចព្យាបាទនិងផល នៃសេចក្តីប្រទូស្តដោយអំណាចព្យាបាទ ទាំងបុគ្គលអ្នកមានចិត្តព្យាបាទ ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។ ម្នាលគាមណិ តថាគតស្គាល់ច្បាស់នូវមិច្ឆាទិដ្ឋិនិងផលនៃមិច្ឆាទិដ្ឋិ ទាំងបុគ្គលជាមិច្ឆាទិដ្ឋិ ប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកនោះសោត ក៏តថាគតស្គាល់ច្បាស់ដែរ ។

គាមណិសំយុត្តំ

[២៩៤] សន្តិ ហិ គាមណិ ឯកេ សមណព្រាហ្ម-
ណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យោ កោចិ បាណមតិ-
មាបេតិ សព្វោ សោ និរយំ ជម្មេ ទុក្ខំ ទោមនស្សំ
បដិសំវេទយតិ យោ កោចិ អទិន្នំ អាទិយតិ សព្វោ
សោ និរយំ ជម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ
យោ កោចិ កាមេសុ មិច្ឆាចរតិ សព្វោ សោ និរយំ
ជម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ យោ កោចិ
មុសា ភណាតិ សព្វោ សោ និរយំ ជម្មេ ទុក្ខំ ទោម-
នស្សំ បដិសំវេទយតីតិ ។

[២៩៥] ទិស្សតិ ខោ ច បន គាមណិ ឥធេកច្ចោ
មាលី កុណ្ឌលី សុនហាតោ សុវិលិត្តោ កប្បិតកេ-
សមស្សុ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេន្តោ ។

គាមណិសំយុត្ត

[២៩៤] ម្នាលគាមណី សមណព្រាហ្មណ៍ពួកមួយ ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណានីមួយសម្លាប់សត្វ បុគ្គលទាំងអស់នោះតែងសោយទុក្ខទោមនស្សក្នុងបច្ចុប្បន្ន បុគ្គលឯណានីមួយកាន់យកទ្រព្យដែលគេមិនបានឲ្យ បុគ្គលទាំងអស់នោះតែងសោយទុក្ខទោមនស្សក្នុងបច្ចុប្បន្ន បុគ្គលឯណានីមួយ ប្រព្រឹត្តខុសក្នុងកាមទាំង-ឡាយ បុគ្គលទាំងអស់នោះតែងសោយទុក្ខទោមនស្សក្នុងបច្ចុប្បន្ន បុគ្គលឯណានីមួយពោលពាក្យមុសា បុគ្គលទាំងអស់នោះតែងសោយទុក្ខទោ-មនស្សក្នុងបច្ចុប្បន្ន ។

[២៩៥] ម្នាលគាមណី បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានកម្រងផ្កា មានកុណ្ឌល ជម្រះកាយស្អាត ស្អិតស្អាងស្អាតបាត កាត់សក់និងពុកមាត់ ឲ្យស្ត្រីបម្រើដោយកាមទាំងឡាយហាក់ដូចជាព្រះរាជា ។

តមេនំ ឯវមាហំសុ(១) អម្ភោ អយំ បុរិសោ កឹ អកាសិ មាលី កុណ្ឌលី សុនហាតោ សុវិលិត្តោ កប្បិតកេសមស្សុ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេតីតិ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ រញ្ញោ បច្ចត្ថិកំ បសយ្ហ ជីវិតា វោរោបេតិ(២) រាជា អត្តមនោ អភិហារមទាសិ តេនាយំ បុរិសោ មាលី កុណ្ឌលី សុនហាតោ សុវិលិត្តោ កប្បិតកេសមស្សុ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេតីតិ ។ ទិស្សតិ ខោ គាមណិ ឥធេកច្ចោ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយា រថិយំ(៣) សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខមិត្វា ទក្ខិណតោ នគរស្ស សីសំ ឆិន្ទមានោ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ កឹ អកាសិ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា

១ ឱ. តមេតមាហំសុ ។ ២ វោរោបេសិ ។ ៣ រថិយាយ រថិយំ ។

ជនទាំងឡាយនិយាយនឹងបុគ្គលនោះយ៉ាងនេះថា យីអើ បុរសនេះតើបាន ធ្វើអំពើអ្វី បានជាមានកម្រងផ្កា មានកុណ្ឌល ជម្រះកាយស្អាត ស្អិតស្អាងស្អាតបាត កាត់សក់និងពុកមាត់ ឲ្យស្ត្រីបម្រើដោយកាមទាំង-ឡាយហាក់ដូចជាព្រះរាជា ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះ បានគ្របសង្កត់បុគ្គលដែលជាសត្រូវនឹងស្ដេចផ្ដាច់ផ្ដិលចាកជីវិត ទើបស្ដេចមានព្រះហឫទ័យត្រេកអរ បានព្រះរាជទានគ្រឿងសក្ការបូជា ព្រោះហេតុនោះ បានជាបុរសនេះមានកម្រងផ្កា មានកុណ្ឌល ជម្រះកាយស្អាត ស្អិតស្អាងស្អាតបាត កាត់សក់និងពុកមាត់ ឲ្យស្ត្រីបម្រើដោយកាមទាំងឡាយហាក់ដូចជាព្រះរាជា ។ ម្នាលគាមណី បុគ្គលពួកខ្លះក្នុងលោកនេះ ត្រូវគេចងស្លាបសេកដោយខ្សែដ៏មាំ កោរត្រងោលបណ្ដើរអាក្រោសពីច្រកមួយទៅច្រកមួយ ពីផ្លូវត្រឡែងកែងមួយទៅផ្លូវត្រឡែងកែងមួយ ដោយស្គរជ័យមានសំឡេងលាន់ឮខ្លាំង ចេញតាមទ្វារខាងត្បូងទៅកាត់ក្បាលខាងត្បូងព្រះនគរ ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះតើបានធ្វើអំពើអ្វី បានជាគេចងស្លាបសេកដោយខ្សែដ៏មាំ កោរត្រងោល

ខរស្សរេន បណវេន រថិយា រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខមិត្វា ទក្ខិណតោ នគរស្ស សីសំ ឆិន្ទតីតិ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ រាជវេរី ឥត្ថឹ វា បុរិសំ វា ជីវិតា វោរោបេតិ តេន នំ រាជានោ គហេត្វា ឯវរូបានិ កម្មករណានិ(១) ករោន្តីតិ(២) ។ តំ កឹ មញ្ញសិ គាមណិ អបិ នុ តេ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។ ទិដ្ឋញ្ច នោ ភន្តេ សុតញ្ច សុយ្យិស្សតិ ចាតិ ។

[២៩៦] តត្រ គាមណិ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យោ កោចិ បាណមតិបាតេតិ សព្វោ សោ ទិដ្ឋេវ ធម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទយតីតិ ។ សច្ចំ វា តេ អាហំសុ មុសា វាតិ ។ មុសា ភន្តេ ។ យេ បន តេ តុច្ឆំ មុសា វិលបន្តិ សីលវន្តោ វា តេ ទុស្សីលា វាតិ ។ ទុស្សីលា ភន្តេ ។ យេ បន

១ ឱ. ឯវរូបំ កម្មករណំ ។ ២ ករោន្តីតិ ។

បណ្តើរអាក្រោសពីច្រកមួយទៅច្រកមួយ ពីផ្លូវត្រទ្បែងកែងមួយទៅផ្លូវត្រទ្បែងកែងមួយ ដោយស្គរជ័យមានសំឡេងលាន់ឮខ្លាំង ចេញតាមទ្វារខាងត្បូង ទៅកាត់ក្បាលខាងត្បូងព្រះនគរដូច្នេះ ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានផ្តាច់ជីវិតស្ត្រីឬបុរសដែលមានពៀរនឹងស្តេច ព្រោះហេតុនោះ បានជាពួកស្តេចចាប់បុរសនោះបានហើយ ឲ្យធ្វើកម្មករណៈ មានសភាពយ៉ាងនេះ ។ ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច អំពើមានសភាពយ៉ាងនេះ អ្នកបានឃើញឬបានឮខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន អំពើមានសភាពយ៉ាងនេះ ខ្ញុំព្រះអង្គបានឃើញបានឮហើយគង់នឹងបានឮផង ។

[២៩៦] ម្នាលគាមណិ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ឯណា ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណានីមួយសម្លាប់សត្វ បុគ្គលទាំងអស់នោះតែងសោយទុក្ខទោមនស្សក្នុងបច្ចុប្បន្ន ។ ចុះសមណព្រាហ្មណ៍ទាំងនោះ ពោលពាក្យសច្ចៈ ឬមុសា ។ មុសា ព្រះអង្គ ។ មួយវិញទៀត សមណព្រាហ្មណ៍ឯណាពោលពាក្យទទេ ពាក្យកុហក សមណព្រាហ្មណ៍ទាំងនោះជាអ្នកមានសីលឬទ្រុស្តសីល ។ ជាអ្នកទ្រុស្តសីល ព្រះអង្គ ។ ចុះសមណ-

តេ ទុស្សីលា បាបធម្មា មិច្ឆាបដិបន្នា វា តេ សម្មា-
បដិបន្នា វាតិ ។ មិច្ឆាបដិបន្នា ភន្តេ ។ យេ បន
តេ មិច្ឆាបដិបន្នា មិច្ឆាទិដ្ឋិកា វា តេ សម្មាទិដ្ឋិកា
វាតិ ។ មិច្ឆាទិដ្ឋិកា ភន្តេ ។ យេ បន តេ មិច្ឆាទិដ្ឋិកា
កល្លំ នុ តេសុ បសីទិតុន្តិ ។ នោ ហេតំ ភន្តេ ។

[២៩៧] ឋិស្សតិ ខោ បន គាមណិ ឥធេកច្ចោ
មាលី កុណ្ឌលី ។ បេ ។ ឥត្ថិកាមេហិ រាជា មញ្ញេ
បរិចារេន្តោ[១] ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិ-
សោ កឹ អកាសិ មាលី កុណ្ឌលី ។ បេ ។ ឥត្ថិកាមេ-
ហិ រាជា មញ្ញេ បរិចារេតីតិ ។ តមេនំ ឯវមាហំសុ អម្ភោ
អយំ បុរិសោ រញ្ញោ បច្ចត្ថិកស្ស បសយ្ហ អធិន្នំ អាទិយ-
តិ[២] តស្ស រាជា អត្តមនោ អភិហារមទាសិ តេនាយំ
បុរិសោ មាលី កុណ្ឌលី ។ បេ ។ ឥត្ថិកាមេហិ រាជា មញ្ញេ
បរិចារេតីតិ ។ ឋិស្សតិ ខោ ។ បេ ។ គាមណិ ឥធេកច្ចោ

១ ម. បរិចារេតីតិ ។ ២ ឱ. បសយ្ហ រតនមហាសិ ។

ព្រាហ្មណ៍ឯណា ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ សមណព្រាហ្មណ៍ទាំងនោះជាអ្នកប្រតិបត្តិខុសឬប្រតិបត្តិត្រូវ ។ ជាអ្នកប្រតិបត្តិខុស ព្រះអង្គ ។ ចុះសមណព្រាហ្មណ៍ឯណាជាអ្នកប្រតិបត្តិខុស សមណព្រាហ្មណ៍ទាំងនោះជាអ្នកមិច្ឆាទិដ្ឋិឬជាអ្នកសម្មាទិដ្ឋិ ។ ជាអ្នកមិច្ឆាទិដ្ឋិ ព្រះអង្គ ។ ចុះពួកសមណព្រាហ្មណ៍ឯណាជាអ្នកមិច្ឆាទិដ្ឋិ អ្នកផង៍គួរជ្រះថ្លានឹងសមណព្រាហ្មណ៍ទាំងនោះដែរឬ ។ ការទុំះមិនគួរទេ ព្រះអង្គ ។

[២៩៧] ម្នាលគាមណី បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានកម្រងផ្កា មានកុណ្ឌល ។ បេ ។ ឲ្យស្ត្រីទាំងឡាយបម្រើដោយកាម ហាក់ដូចជាព្រះរាជា ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានធ្វើអំពើអ្វី បានជាមានកម្រងផ្កា មានកុណ្ឌល ។ បេ ។ ឲ្យស្ត្រីទាំងឡាយបម្រើដោយកាម ហាក់ដូចជាព្រះរាជា ។ ជនទាំងឡាយក៏និយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានគ្របសង្កត់បុគ្គលដែលជាសត្រូវនឹងស្តេច ហើយកាន់យកទ្រព្យដែលគេមិនបានឲ្យ ទើបស្តេចមានព្រះហឫទ័យត្រេកអរ បានព្រះរាជទានគ្រឿងសក្ការបូជាដល់បុរសនោះ ព្រោះហេតុនោះ បានជាបុរសនេះមានកម្រងផ្កា មានកុណ្ឌល ។ បេ ។ ឲ្យស្ត្រីទាំងឡាយបម្រើដោយកាម ហាក់ដូចជាព្រះរាជា ។បេ។ ម្នាលគាមណី បុគ្គលពួកខ្លះក្នុងលោកនេះ

ឧឡ្ហាយ រជ្ជុយា ។ បេ ។ ឧក្ខិណាតោ ឧតស្ស សីសំ ឆិជ្ជមានោ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ កឹ អកាសិ ឧឡ្ហាយ រជ្ជុយា ។ បេ ។ ឧក្ខិណាតោ ឧតស្ស សីសំ ឆិន្ទតីតិ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ គាមា វា អរញ្ញា វា អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ តេន នំ រាជានោ ឯវរូបំ កម្មការណំ ការេន្តីតិ[១] ។ តំ កឹ មញ្ញសិ គាមណិ អបិ នុ តេ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។ ទិដ្ឋញ្ច នោ ភន្តេ សុតញ្ច សុយ្យិស្សតិ ចាតិ ។

[២៩៨] តត្រ គាមណិ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យោ កោចិ អទិន្នំ អាទិយតិ សព្វោ សោ ទិដ្ឋេវ ធម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទយតីតិ ។ សច្ចំ វា តេ អាហំសុ មុសា វាតិ ។ បេ ។ កល្លំ នុ តេសុ បសីទិតុន្តិ ។ នោ ហេតំ ភន្តេ ។

១ ឱ. ករោន្តីតិ ។

ត្រូវគេចងស្ទាបសេកដោយខ្សែដ៏មាំ ។ បេ ។ កាត់ក្បាលខាងត្បូងព្រះនគរ ។ ជនទាំងឡាយបាននិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានធ្វើអំពើអ្វី បានជាគេចងស្ទាបសេកដោយខ្សែដ៏មាំ ។ បេ ។ កាត់ក្បាលខាងត្បូងព្រះនគរ ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានកាន់យកទ្រព្យដែលគេមិនបានឲ្យ អំពីស្រុកក្តី អំពីព្រៃក្តី ដោយចំណែកនៃចិត្តជាចោរ ព្រោះហេតុនោះ បានជាពួកស្តេចចាប់បុរសនោះបានហើយ ឲ្យធ្វើកម្មករណៈមានសភាពយ៉ាងនេះ ។ ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច អំពើមានសភាពយ៉ាងនេះ អ្នកបានឃើញឬបានឮខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញបានឮហើយគង់នឹងបានឮផង ។

[២៩៨] ម្នាលគាមណិ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកណា ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណានីមួយកាន់យកទ្រព្យដែលគេមិនបានឲ្យ បុគ្គលទាំងអស់នោះតែងសោយទុក្ខទោមនស្សក្នុងបច្ចុប្បន្ន ។ សមណព្រាហ្មណ៍ទាំងនោះ ពោលពាក្យសច្ចៈឬមុសា ។ បេ ។ អ្នកផងគួរជ្រះថ្លានឹងសមណព្រាហ្មណ៍ទាំងនោះដែរឬ ។ ការនុ៎ះមិនគួរទេ ព្រះអង្គ ។

[៦៩៩] ទិស្សតិ ខោ បន គាមណិ ឥធេកច្ចោ មាលី កុណ្ឌលី ។ បេ ។ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេន្តោ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ កឹ អកាសិ មាលី កុណ្ឌលី ។ បេ ។ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេតីតិ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ រញ្ញោ បច្ចត្ថិកស្ស ជាវេសុ ចារិត្តំ អាបជ្ជិ តស្ស រាជា អត្តមនោ អភិហារមទាសិ តេនាយំ បុរិសោ មាលី កុណ្ឌលី ។ បេ ។ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេតីតិ ។ ទិស្សតិ ខោ គាមណិ ឥធេកច្ចោ ទឡ្ហាយ រជ្ជុយា ។ បេ ។ ទក្ខិណតោ នគរស្ស សីសំ ឆិជ្ជមានោ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ កឹ អកាសិ ទឡ្ហាយ រជ្ជុយា ។ បេ ។ ទក្ខិណតោ នគរស្ស សីសំ ឆិន្ទតីតិ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ កុលិត្ថីសុ កុលកុមារីសុ ចារិត្តំ អាបជ្ជិ តេន

[២៩៩] ម្នាលគាមណិ បុគ្គលពួកខ្លះក្នុងលោកនេះ មានកម្រងផ្កា មានកុណ្ឌល ។ បេ ។ ឲ្យស្ត្រីទាំងឡាយបម្រើដោយកាមហាក់ដូចជាព្រះរាជា ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះតើបានធ្វើអំពើអ្វី បានជាមានកម្រងផ្កា មានកុណ្ឌល ។ បេ ។ ឲ្យស្ត្រីទាំងឡាយបម្រើដោយកាមហាក់ដូចជាព្រះរាជា ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានប្រព្រឹត្តល្មើសក្នុងប្រពន្ធរបស់បុគ្គលដែលជាសត្រូវនឹងស្ដេច ទើបស្ដេចមានព្រះហឫទ័យត្រេកអរ បានព្រះរាជទានគ្រឿងសក្ការបូជាដល់បុរសនោះ ព្រោះហេតុនោះ បានជាបុរសនេះមានកម្រងផ្កា មានកុណ្ឌល ។ បេ ។ ឲ្យស្ត្រីទាំងឡាយបម្រើដោយកាមហាក់ដូចជាព្រះរាជា ។ ម្នាលគាមណិ បុគ្គលពួកខ្លះក្នុងលោកនេះ ត្រូវគេចាប់ចងស្វាបសេកដោយខ្សែដ៏មាំ ។ បេ ។ កាត់ក្បាលខាងត្បូងព្រះនគរ ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះតើបានធ្វើអំពើអ្វី ទើបត្រូវគេចងស្វាបសេកដោយខ្សែដ៏មាំ ។ បេ ។ កាត់ក្បាលខាងត្បូងព្រះនគរ ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានប្រព្រឹត្តល្មើសក្នុងពួកស្ត្រីរបស់ត្រកូល ក្នុងពួកកុមារីរបស់ត្រកូល ព្រោះហេតុនោះ

នំ រាជានោ គហេត្វា ឯវរូបំ កម្មការណំ ការេន្តីតិ ។ តំ កឹ មញ្ញសិ គាមណិ អបិ នុ តេ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។ ទិដ្ឋញ្ច នោ ភន្តេ សុតំ ច សុយ្យិស្សតិ ចាតិ ។

[៣០០] តត្រ គាមណិ យេ តេ សមណព្រា-ហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យោ កោចិ កា-មេសុ មិច្ឆាចរតិ សព្វោ សោ ទិដ្ឋេវ ធម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទយតីតិ ។ សច្ចំ វា តេ អាហំ-សុ មុសា វាតិ ។ បេ ។ កល្លំ នុ តេសុ បសីទិតុន្តិ ។ នោ ហេតំ ភន្តេ ។

[៣០១] ទិស្សតិ ខោ បន គាមណិ ឥធេកច្ចោ មាលី កុណ្ឌលី សុនហាតោ សុវិលិត្តោ កប្បិត-កេសមស្សុ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេន្តោ

ពួកស្តេចចាប់បុរសនោះបានហើយ ទើបឲ្យធ្វើកម្មករណៈមានសភាពយ៉ាងនេះ ។ ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច អំពើមានសភាពយ៉ាងនេះ អ្នកបានឃើញឬបានឮខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន អំពើមានសភាពយ៉ាងនេះ ខ្ញុំព្រះអង្គបានឃើញ បានឮ ហើយគង់នឹងបានឮផង ។

[៣០០] ម្នាលគាមណិ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ឯណា ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណានីមួយប្រព្រឹត្តខុសក្នុងកាមទាំងឡាយ បុគ្គលទាំងអស់នោះតែងសោយទុក្ខទោមនស្សក្នុងបច្ចុប្បន្ន ។ សមណព្រាហ្មណ៍ទាំងនោះ ឈ្មោះថាពោលពាក្យសច្ចៈឬមុសា ។ បេ ។ អ្នកផង់គួរជ្រះថ្លានឹងសមណព្រាហ្មណ៍ទាំងនោះដែរឬ ។ ការនុ៎ះមិនគួរទេ ព្រះអង្គ ។

[៣០១] ម្នាលគាមណិ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានកម្រងផ្កា មានកុណ្ឌល ជម្រះកាយស្អាត ស្អិតស្អាងស្អាតបាត កាត់សក់នឹងពុកមាត់ ឲ្យស្ត្រីទាំងឡាយបម្រើដោយកាមហាក់ដូចជាព្រះរាជា ។

តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ កឹ អកាសិ មាលី កុណ្ឌលី សុនហាតោ សុវិលិត្តោ កប្បិតកេសមស្សុ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេតីតិ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ រាជានំ មុសាវាទេន ហាសេតិ តស្ស រាជា អត្តមនោ អភិហារមទាសិ តេនាយំ បុរិសោ មាលី កុណ្ឌលី សុនហាតោ សុវិលិត្តោ កប្បិតកេសមស្សុ ឥត្ថិកាមេហិ រាជា មញ្ញេ បរិចារេតីតិ ។ ទិស្សតិ ខោ គាមណិ ឥធេកច្ចោ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយា រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខមិត្វា ទក្ខិណតោ នគរស្ស សីសំ ឆិន្ទមានោ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ កឹ អកាសិ

ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះតើបាន ធ្វើអំពើអ្វី ទើបមានកម្រងផ្កា មានកុណ្ឌល ជម្រះកាយស្អាត ស្អិតស្អាង ស្អាតបាត កាត់សក់និងពុកមាត់ ឲ្យពួកស្ត្រីទាំងឡាយបម្រើដោយកាម ហាក់ដូចជាព្រះរាជា ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានញុំាងស្តេចឲ្យសប្បាយរីករាយដោយពាក្យមុសាស្តេច មានព្រះហឫទ័យត្រេកអរ បានព្រះរាជទានគ្រឿងសក្ការបូជាដល់បុរស នោះ ព្រោះហេតុនោះ បានជាបុរសនោះមានកម្រងផ្កា មានកុណ្ឌល ជម្រះកាយស្អាត ស្អិតស្អាងស្អាតបាត កាត់សក់និងពុកមាត់ ឲ្យស្ត្រីទាំង-ឡាយបម្រើដោយកាមហាក់ដូចជាព្រះរាជា ។ ម្នាលគាមណិ បុគ្គល ពួកខ្លះក្នុងលោកនេះ ត្រូវគេចាប់ចងស្ទាបសេកដោយខ្សែដ៏មាំ កោរ ត្រងោលបណ្តើរអាក្រោសពីច្រកមួយទៅច្រកមួយ ពីផ្លូវត្រឡែងកែង មួយទៅផ្លូវត្រឡែងកែងមួយ ដោយស្គរជ័យមានសំឡេងលាន់ឮខ្លាំង ចេញតាមទ្វារខាងត្បូង កាត់ក្បាលខាងត្បូងព្រះនគរ ។ ជនទាំងឡាយ ក៏និយាយនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះតើបានធ្វើអំពើអ្វី

ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយា រថិ-យំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខមិត្វា ទក្ខិណតោ នគរស្ស សីសំ ឆិន្ទ-តីតិ ។ តមេនំ ឯវមាហំសុ អម្ភោ អយំ បុរិសោ គហបតិស្ស វា គហបតិបុត្តស្ស វា មុសាវាទេន អត្ថំ ភញ្ជិ តេន នំ រាជានោ គហេត្វា ឯវរូបានិ កម្មករ-ណានិ ការេន្តីតិ ។ តំ កឹ មញ្ញសិ គាមណិ អបិ នុ តេ ឯវរូបំ ទិដ្ឋំ វា សុតំ វាតិ ។ ទិដ្ឋញ្ច នោ ភន្តេ សុតញ្ច សុយ្យិស្សតិ ចាតិ ។

[៣០២] តត្រ គាមណិ យេ តេ សមណព្រាហ្ម-ណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យោ កោចិ មុសា ភណតិ សព្វោ សោ ទិដ្ឋេវ ធម្មេ ទុក្ខំ ទោមនស្សំ បដិសំវេ-ទយតីតិ ។ សច្ចំ វា តេ អាហំសុ មុសា វាតិ ។ មុសា ភន្តេ ។ យេ បន តេ តុច្ឆំ មុសា វិលបន្តិ សីលវន្តោ វា តេ ទុស្សីលា វាតិ ។ ទុស្សីលា ភន្តេ ។

ទើបត្រូវគេចាប់ចងស្ទាបសេកដោយខ្សែដ៏មាំ កោរត្រងោលបណ្តើរអាក្រាសពីច្រកមួយទៅច្រកមួយ ពីផ្លូវត្រឡែងកែងមួយទៅផ្លូវត្រឡែងកែងមួយ ដោយស្គរជ័យមានសំឡេងលាន់ឮខ្លាំង ចេញតាមទ្វារខាងត្បូង កាត់ក្បាលខាងត្បូងព្រះនគរ ។ ជនទាំងឡាយពោលនឹងបុរសនោះយ៉ាងនេះថា យីអើ បុរសនេះបានកាច់បង់ប្រយោជន៍របស់គហបតី ឬគហបតិបុត្ត ដោយពាក្យមុសា ព្រោះហេតុនោះ ពួកស្តេចចាប់បុរសនោះបានហើយ ឲ្យធ្វើកម្មករណៈមានសភាពយ៉ាងនេះ ។ ម្នាលគាមណិ អ្នកសំគាល់សេចក្តីនោះដូចម្តេច អំពើមានសភាពយ៉ាងនេះ អ្នកបានឃើញឬបានឮខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញបានឮហើយ គង់នឹងបានឮផង ។

[៣០២] ម្នាលគាមណិ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ឯណា ជាអ្នកមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលឯណាមួយពោលពាក្យមុសា បុគ្គលទាំងអស់នោះតែងសោយទុក្ខទោមនស្សក្នុងបច្ចុប្បន្ន ។ សមណព្រាហ្មណ៍ទាំងនោះ ឈ្មោះថាពោលពាក្យសច្ចៈឬមុសា ។ មុសា ព្រះអង្គ ។ ពួកសមណព្រាហ្មណ៍ឯណា ពោលពាក្យទទេ ពាក្យមុសា សមណព្រាហ្មណ៍ទាំងនោះជាអ្នកមានសីលឬទ្រុស្តសីល ។ ជាអ្នកទ្រុស្តសីល ព្រះអង្គ ។

យេ បន តេ ទុស្សីលា បាបធម្មា មិច្ឆាបដិបន្នា វា តេ សម្មាបដិបន្នា វាតិ ។ មិច្ឆាបដិបន្នា ភន្តេ ។ យេ បន តេ មិច្ឆាបដិបន្នា មិច្ឆាទិដ្ឋិកា វា តេ សម្មាទិដ្ឋិកា វា-តិ ។ មិច្ឆាទិដ្ឋិកា ភន្តេ ។ យេ បន តេ មិច្ឆាទិដ្ឋិកា កល្លំ នុ តេសុ បសីទិតុន្តិ ។ នោ ហេតំ ភន្តេ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ អត្ថិ មេ ភន្តេ អាវសថាគារំ តត្ថ អត្ថិ មញ្ចកានិ អត្ថិ អាសនានិ អត្ថិ ឧទក-មណិកោ អត្ថិ តេលប្បទីបោ ។ តត្ថ យោ សមណោ វា ព្រាហ្មណោ វា វាសំ ឧបេតិ តេនាហំ យថាសត្តិ យថាពលំ សំវិភជាមិ ។

ចុះសមណព្រាហ្មណ៍ទាំងឡាយឯណា ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ សមណព្រាហ្មណ៍ទាំងនោះជាអ្នកប្រតិបត្តិខុសឬប្រតិបត្តិត្រូវ ។ ជាអ្នកប្រតិបត្តិខុស ព្រះអង្គ ។ ចុះសមណព្រាហ្មណ៍ទាំងឡាយឯណា ជាអ្នកប្រតិបត្តិសុខ សមណព្រាហ្មណ៍ទាំងនោះជាអ្នកមិច្ឆាទិដ្ឋិ ឬជាអ្នកសម្មាទិដ្ឋិ ។ ជាអ្នកមិច្ឆាទិដ្ឋិ ព្រះអង្គ ។ ចុះពួកសមណព្រាហ្មណ៍ឯណា ជាអ្នកមិច្ឆាទិដ្ឋិ អ្នកផងគួរជ្រះថ្លានឹងសមណព្រាហ្មណ៍ទាំងនោះដែរឬ ។ ការនុ៎ះមិនគួរទេ ព្រះអង្គ ។ អស្ចារ្យណាស់ ព្រះអង្គ ចម្លែកណាស់ ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានផ្ទះសំណាក់មួយ ក្នុងផ្ទះសំណាក់នោះ មានគ្រែតូច មានអាសនៈ មានក្អមទឹក មានប្រទីបប្រេង ។ សមណៈឬព្រាហ្មណ៍ឯណាចូលទៅអាស្រ័យក្នុងផ្ទះសំណាក់នោះ ខ្ញុំព្រះអង្គក៏ចាត់ចែងចែកប្រគេនសមណៈឬព្រាហ្មណ៍នោះសមគួរតាមស័ក្តិ តាមកម្លាំង ។

គាមណិសំយុត្តំ

[៣០៣] ភូតបុព្វំ ភន្តេ ចត្តារោ សត្ថារោ នានាទិដ្ឋិកា នានាខន្តិកា នានារុចិកា តស្មឹ អាវសថាគារេ វាសំ ឧបគច្ឆឹសុ[1] ។ ឯកោ សត្ថា ឯវំវាទី ឯវំទិដ្ឋិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។

១ ឱ. ម. ឧបគច្ឆុំ ។

គាមណិសំយុត្ត

[៣០៣] បពិត្រព្រះអង្គដ៏ចម្រើន កាលពីមុនមានសាស្តា ៤ នាក់ ជាអ្នកមានយោបល់ផ្សេងគ្នា មានសេចក្តីគាប់ចិត្តផ្សេងគ្នា មានសេចក្តីចូលចិត្តផ្សេងគ្នា ចូលទៅអាស្រ័យនៅក្នុងផ្ទះសំណាក់នោះ ។ សាស្តាម្នាក់មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់ មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯង ហើយប្រកាសនូវលោកនេះនឹងលោកខាងមុខបាន ក៏មិនមានក្នុងលោក ។

[៣០៤] ឯកោ សត្ថា ឯវំវាទី ឯវំទិដ្ឋិ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។

[៣០៥] ឯកោ សត្ថា ឯវំវាទី ឯវំទិដ្ឋិ ករោតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បាចយ-តោ សោចតោ សោចយតោ កិលមតោ កិលមយ-តោ ផន្ទតោ ផន្ទាបយតោ បាណមតិមាបយតោ អ-ទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ

[៣០៤] សាស្ដាម្នាក់ទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយរមែងមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ ពួកសត្វដែលជាឱបបាតិកៈមាន ពួកសមណព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯង ហើយប្រកាសនូវលោកនេះនិងលោកខាងមុខ ក៏មានក្នុងលោក ។

[៣០៥] សាស្ដាម្នាក់ទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាបខ្លួនឯង ប្រើអ្នកដទៃឲ្យធ្វើ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើអ្នកដទៃឲ្យកាត់ បៀតបៀនខ្លួនឯង ប្រើអ្នកដទៃឲ្យបៀតបៀន សោយសោកខ្លួនឯង ធ្វើអ្នកដទៃឲ្យសោយសោក ធ្វើខ្លួនឯងឲ្យលំបាក ធ្វើអ្នកដទៃឲ្យលំបាក អន្ទះអន្ទែងខ្លួនឯង ធ្វើអ្នកដទៃឲ្យអន្ទះអន្ទែង សម្លាប់សត្វខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់តំណ (ជញ្ជាំង) ប្លន់យកទ្រព្យពួកអ្នកស្រុក

៣២៨

គាមណិសំយុត្តំ

ឯកាការិកំ កាហេតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណោតោ ការេតោ ន ការីយតិ ចាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា ចាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ ការេយ្យ នត្ថិ តតោនិទានំ ចាបំ នត្ថិ ចាបស្ស អាគមោ ។ ទក្ខិណំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ ចាចេន្តោ នត្ថិ តតោនិទានំ ចាបំ នត្ថិ ចាបស្ស អាគមោ ។ ឧត្តរំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យាជេន្តោ នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ។ ទានេន ទមេន សំយមេន សច្ចវជ្ជេន នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។

ប្លន់យកទ្រព្យក្នុងផ្ទះមួយ ឈរចាំលួចធក់ក្បែរផ្លូវធំ គប់រកប្រពន្ធអ្នកដទៃ ពោលពាក្យមុសា បាបដែលបុគ្គលនោះធ្វើ ឈ្មោះថាមិនបានធ្វើទេ ទោះបីបុគ្គលណាធ្វើពពួកសត្វលើប្រឹថពីនេះ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ ដោយចក្រមានខ្នងកង់ដ៏មុត បាបដែលមានអំពើនោះជាហេតុក៏មិនមាន ដំណើរមកនៃបាបក៏មិនមាន ។ ទោះបីបុគ្គលច្លងទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វដោយខ្លួនឯង ប្រើអ្នកដទៃឲ្យសម្លាប់ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេខ្លួនឯង ប្រើអ្នកដទៃឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុក៏មិនមាន ដំណើរមកនៃបាបក៏មិនមាន ។ ទោះបីបុគ្គលច្លងទៅកាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទានខ្លួនឯង ប្រើអ្នកដទៃឲ្យឲ្យទាន បូជាខ្លួនឯង ប្រើអ្នកដទៃឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុក៏មិនមាន ដំណើរមកនៃបុណ្យក៏មិនមាន ។ បុណ្យក៏មិនមានដោយការឲ្យទាន ដោយការទូន្មាន ដោយការសង្រួម ដោយការពោលពាក្យសច្ចៈ ដំណើរមកនៃបុណ្យក៏មិនមាន ។

[៣០៦] ឯកោ សត្ថា ឯវំវាទី ឯវំទិដ្ឋិ ករតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បាចយតោ សោចតោ សោចយតោ កិលមតោ កិលមយតោ ផន្ទតោ ផន្ទាបយតោ បាណមតិមាបយតោ អទិន្នំ អា-ទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិ-កំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណតោ ករតោ ករីយតិ បាបំ ខុរបរិយន្តេន ចក្កេន ចេបិ យោ ឥមិស្សា បថវិយា បាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ ករេយ្យ អត្ថិ តតោនិទានំ បាបំ អត្ថិ បាបស្ស អាគមោ ។ ទក្ខិណំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ

[៣០៦] សាស្តាម្នាក់ទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បាបដែលបុគ្គលធ្វើដោយខ្លួនឯង ប្រើអ្នកដទៃឲ្យធ្វើ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេខ្លួនឯង ប្រើអ្នកដទៃឲ្យបៀតបៀន សោយសោកខ្លួនឯង ធ្វើអ្នកដទៃឲ្យសោយសោក ធ្វើខ្លួនឯងឲ្យលំបាក ធ្វើអ្នកដទៃឲ្យលំបាក អន្ទះអន្ទែងខ្លួនឯង ធ្វើអ្នកដទៃឲ្យអន្ទះអន្ទែង សម្លាប់សត្វខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់តំណ (ជញ្ជាំង) ប្លន់យកទ្រព្យពួកអ្នកស្រុក ប្លន់យកទ្រព្យក្នុងផ្ទះមួយៗ ឈរចាំលួចឆក់ក្បែរផ្លូវធំ គប់រកប្រពន្ធអ្នកដទៃ ពោលពាក្យមុសា បាបដែលបុគ្គលនោះធ្វើ ឈ្មោះថាធ្វើមែន ទោះបីបុគ្គលឯណាធ្វើនូវពពួកសត្វលើប្រឹថពីនេះ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ ដោយចក្រមានខ្នងកង់ដ៏មុត បាបដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបាបក៏មាន ។ ទោះបីបុគ្គលច្ឆងទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វខ្លួនឯង ប្រើអ្នកដទៃឲ្យសម្លាប់ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើអ្នកដទៃឲ្យកាត់

៣២៧



បចន្តោ បាចេន្តោ អត្ថិ តតោនិទានំ បាបំ អត្ថិ បាបស្ស អាគមោ ។ ឧត្តរំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យាជេន្តោ អត្ថិ តតោនិទានំ បុញ្ញំ អត្ថិ បុញ្ញស្ស អាគមោ ។ ទានេន ទមេន សំយមេន សច្ចវជ្ជេន អត្ថិ បុញ្ញំ អត្ថិ បុញ្ញស្ស អាគមោតិ ។ តស្ស មយ្ហំ ភន្តេ អហុ ទេវ កង្ខា អហុ វិចិកិច្ឆា កោ សុ នាម ឥមេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ អាហ កោ មុសាតិ ។ អលំ ហិ តេ គាមណិ កង្ខិតុំ អលំ វិចិកិច្ឆិតុំ កង្ខនីយេ ច បន[១]ឋានេ វិចិកិច្ឆា ឧប្បន្នាតិ ។ ឯវំ បសន្នាហំ ភន្តេ ភគវតិ បហោតិ មេ ភគវា តថា ធម្មំ ទេសេតុំ យថាហំ ឥមំ កង្ខាធម្មំ បជហេយ្យន្តិ ។

---

១ ឱ. ឯត្ថន្តរេ តេ ឥតិសទ្ទោ ហោតិ ។

បៀតបៀនគេខ្លួនឯង ប្រើអ្នកដទៃឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបាបក៏មាន ។ ទោះបីបុគ្គលធ្វើទៅកាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទានដោយខ្លួនឯង ប្រើអ្នកដទៃឲ្យឲ្យទាន បូជាដោយខ្លួនឯង ប្រើអ្នកដទៃឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបុណ្យក៏មាន ។ បុណ្យក៏មានដោយការឲ្យទាន ដោយការទូន្មាន ដោយការសង្រួម ដោយការពោលពាក្យសច្ចៈ ដំណើរមកនៃបុណ្យក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីសង្ស័យ មានសេចក្តីងឿងឆ្ងល់ថា បណ្តាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះ សមណព្រាហ្មណ៍ណាពោលពាក្យសច្ចៈ សមណព្រាហ្មណ៍ណាពោលពាក្យមុសា ។ ម្នាលគាមណិ ពិតហើយ គួរឲ្យអ្នកសង្ស័យ គួរឲ្យអ្នកងឿងឆ្ងល់ដែរ មួយទៀត សេចក្តីសង្ស័យរបស់អ្នកកើតមានក្នុងហេតុដែលគួរសង្ស័យ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លាចំពោះព្រះមានព្រះភាគដោយគិតដូច្នេះថា ព្រះដ៏មានព្រះភាគអាចទ្រង់សំដែងធម៌ដល់ខ្ញុំព្រះអង្គ តាមទំនងដែលខ្ញុំព្រះអង្គគួរលះបង់នូវសេចក្តីសង្ស័យនេះចេញបាន ។

[៣០៧] អត្ថិ គាមណិ ធម្មសមាធិ តត្រ ចេ ត្វំ ចិត្តសមាធឹ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ ។ កតមា ច គាមណិ ធម្មសមាធិ ។ ឥធ គាមណិ អរិយសាវកោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ អភិជ្ឈំ បហាយ អនភិជ្ឈាលុ ហោតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋឹ បហាយ សម្មាទិដ្ឋិកោ ហោតិ ។

[៣០៧] ម្នាលគាមណី ធម្មសមាធិមាន បើអ្នកបានចិត្តសមាធិ[១] ក្នុងធម្មសមាធិនោះ អ្នកក៏គប្បីលះបង់សេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។ ម្នាលគាមណី ចុះធម្មសមាធិតើដូចម្តេច ។ ម្នាលគាមណី អរិយសាវ័កក្នុងសាសនានេះ បានលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន លះបង់កាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារ លះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ លះបង់បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា លះបង់ផរុសវាចា វៀរស្រឡះចាកផរុសវាចា លះបង់សម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ លះបង់អភិជ្ឈា ជាអ្នកមិនមានអភិជ្ឈា លះបង់សេចក្តីប្រទូស្តដោយអំណាចព្យាបាទ ជាអ្នកមានចិត្តមិនព្យាបាទ លះបង់មិច្ឆាទិដ្ឋិ ជាអ្នកសម្មាទិដ្ឋិ ។

---

១ អដ្ឋកថា កែត្រង់ធម្មសមាធិនិងចិត្តសមាធិនេះជា ៣ ន័យ ន័យទី ១ ថា ទសកុសលកម្មបថធម៌ ឈ្មោះថាធម្មសមាធិ មគ្គទាំង ៤ ព្រមទាំងវិបស្សនា ឈ្មោះថាចិត្តសមាធិ ។ ន័យទី ២ ថា ធម៌ ៤ យ៉ាង គឺបាមោជ្ជៈ បីតិ បស្សទ្ធិ សមាធិ ឈ្មោះថាធម្មសមាធិ មគ្គទាំង ៤ ព្រមទាំងវិបស្សនា ឈ្មោះថាចិត្តសមាធិ ។ ន័យទី ៣ ថា ព្រហ្មវិហារទាំង ៤ ឈ្មោះថាធម្មសមាធិ ឯកគ្គតាចិត្តដែលកើតឡើងដល់បុគ្គលកំពុងចម្រើនព្រហ្មវិហារ ឈ្មោះថាចិត្តសមាធិ ។

៣២៩

គាមណិសំយុត្តំ

[៣០៨] ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យ្វាយំ សត្ថា ឯវំវាទី ឯវំទិដ្ឋិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។

[៣០៨] ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាសចាក អភិជ្ឈា ប្រាសចាកព្យាបាទយ៉ាងនេះហើយ ជាអ្នកមិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយ មេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ មាន ចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិន មានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិស ខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយយកខ្លួនមកប្រៀបផ្ទឹមនឹង សត្វទាំងពួង ក្នុងទីទាំងពួង សម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយ ប្រការដូច្នេះ ។ អរិយសាវ័កនោះ រមែងពិចារណាឃើញដូច្នេះថា សាស្តាណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យ ហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផល-វិបាករបស់កម្មដែលសត្វធ្វើល្អ ធ្វើអាក្រក់ មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វ ជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិ ត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯង ហើយ ប្រកាសនូវលោកនេះនិងលោកខាងមុខបាន ក៏មិនមានក្នុងលោក ។

៣៣០



សចេ តស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អបណ្ណកតាយ មយ្ហំ យោហំ ន កិញ្ចិ ព្យាពាធេមិ តសំ វា ថាវរំ វា ឧភយមេត្ថ កដគ្គាហោ យំ ចម្ហិ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ យញ្ច កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ។ តស្ស បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ ខោ គាមណិ ធម្មសមាធិ ។ តត្រ ចេ ត្វំ ចិត្តសមាធឹ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ ។

បើពាក្យរបស់សាស្តាដ៏ចម្រើននោះ ជាពាក្យសច្ចៈ ដោយហេតុមិនខុសនឹងអញ ឥឡូវអញមិនបៀតបៀនសត្វណាមួយ ដែលមានសេចក្តីតក់ស្លុតឬមិនមានសេចក្តីតក់ស្លុតទេ អញក៏បានឈ្មោះថាជាអ្នកកាន់យកនូវជ័យជម្នះទាំងពីរយ៉ាងក្នុងលោកនេះ គឺថាអញបានសង្រួមកាយ សង្រួមវាចា សង្រួមចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ អញនឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បាមោជ្ជៈ (សេចក្តីត្រេកអរទន់) ក៏កើតឡើងដល់អរិយសាវ័កនោះ កាលបើមានបាមោជ្ជៈហើយ បីតិ (សេចក្តីត្រេកអរខ្លាំង) ក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់ លុះមានកាយស្ងប់ហើយ រមែងសោយសុខ ចិត្តរបស់អរិយសាវ័កដែលមានសុខ រមែងតម្កល់មាំ ។ ម្នាលគាមណិ នេះឯងហៅថាធម្មសមាធិ ។ បើអ្នកបានចិត្តសមាធិក្នុងធម្មសមាធិនោះ អ្នកមុខជាលះបង់សេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។

គាមណិសំយុត្តំ

[៣០៩] ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យ្វាយំ សត្ថា ឯវំវាទី ឯវំទិដ្ឋិ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកត-ទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ

គាមណិសំយុត្ត

[៣០៩] ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាសចាក អភិជ្ឈា ប្រាសចាកព្យាបាទ យ៉ាងនេះហើយ ជាអ្នកមិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយ មេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមាន ពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិស ខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយយកខ្លួន មកប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រាន្តនៅដោយឥរិ-យាបថទាំង ៤ ដោយប្រការដូច្នេះ ។ អរិយសាវ័កនោះ រមែងពិចារណា ឃើញដូច្នេះថា សាស្តាណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមាន ផល ផលវិបាករបស់កម្មដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន លោកនេះមាន

អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ សចេ តស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អបណ្ណកតាយ មយ្ហំ យោហំ ន កិញ្ចិ ព្យាពាធេមិ តសំ វា ថាវរំ វា ឧភយមេត្ថ កដគ្គាហោ យញ្ចម្ហិ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ យញ្ច កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ។ តស្ស បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ ខោ គាមណិ ធម្មសមាធិ ។ តត្រ ចេ ត្វំ ចិត្តសមាធិ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ ។

លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ ពួកសត្វជាឱបបាតិកៈកំណើតមាន ពួកសមណព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯង ហើយប្រកាសនូវលោកនេះ និងលោកខាងមុខបាន ក៏មាននៅក្នុងលោក ។ បើពាក្យរបស់សាស្តាដ៏ចម្រើននោះ ជាពាក្យសច្ចៈ ដោយហេតុមិនខុសនឹងអញ ឥឡូវអញមិនបៀតបៀនសត្វណាមួយ ដែលមានសេចក្តីតក់ស្លុត ឬមិនមានសេចក្តីតក់ស្លុតទេ អញក៏បានឈ្មោះថាជាអ្នកកាន់យកនូវជ័យជម្នះទាំងពីរយ៉ាងក្នុងលោកនេះ គឺថាអញបានសង្រួមកាយ សង្រួមវាចា សង្រួមចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ អញនឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បាមោជ្ជៈក៏កើតឡើងដល់អរិយសាវ័កនោះ កាលបើមានបាមោជ្ជៈហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់ លុះមានកាយស្ងប់ហើយ រមែងសោយសុខ ចិត្តរបស់អរិយសាវ័កដែលមានសុខ រមែងតម្កល់មាំ ។ ម្នាលគាមណី នេះឯងហៅថាធម្មសមាធិ ។ បើអ្នកបានចិត្តសមាធិក្នុងធម្មសមាធិនោះ អ្នកមុខជាលះបង់សេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។

គាមណិសំយុត្តំ

[៣១០] ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យ្វាយំ សត្ថា ឯវំវាទី ឯវំទិដ្ឋិ ករតោការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បាចយតោ សោចតោ សោចយតោ

គាមណិសំយុត្ត

[៣១០] ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាសចាក អភិជ្ឈា ប្រាសចាកព្យាបាទ យ៉ាងនេះហើយ ជាអ្នកមិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ទិស ទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ មាន ចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិន មានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិស ខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយយកខ្លួនប្រៀបផ្ទឹមនឹងសត្វ ទាំងពួង ក្នុងទីទាំងពួង សម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយប្រ-ការដូច្នេះ ។ អរិយសាវ័កនោះ រមែងពិចារណាឃើញដូច្នេះថា សាស្តា ណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ប្រើគេឲ្យធ្វើ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើគេឲ្យកាត់ បៀតបៀនគេខ្លួន ឯង ប្រើគេឲ្យបៀតបៀន សោយសោកខ្លួនឯង ធ្វើគេឲ្យសោយសោក

កិលមតោ កិលមយតោ ផន្ទតោ ផន្ទាបយតោ ចា-
ណាមតិមាបយតោ អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ
និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ
បរទារំ គច្ឆតោ មុសា ភណតោ ករោតោ ន ករីយតិ
ចាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា
បឋវិយា ចាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ
ករេយ្យ នត្ថិ តតោនិទានំ ចាបំ នត្ថិ ចាបស្ស អាគ-
មោ ។ ទក្ខិណំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ
ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ ចាចេន្តោ
នត្ថិ តតោនិទានំ ចាបំ នត្ថិ ចាបស្ស អាគមោ ។
ឧត្តរំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទា-

ធ្វើខ្លួនឯងឲ្យលំបាក ធ្វើគេឲ្យលំបាក អន្ទះទន្ទែងខ្លួនឯង ធ្វើគេឲ្យអន្ទះអន្ទែង សម្លាប់សត្វខ្លួនឯង ឬប្រើគេឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់ទូវតំណ (ជញ្ជាំង) ប្លន់យកទ្រព្យពួកអ្នកស្រុក ប្លន់យកទ្រព្យក្នុងផ្ទះមួយៗ ឈរចាំលួចឆក់ក្បែរផ្លូវធំ គប់រកប្រពន្ធបុគ្គលដទៃ ពោលពាក្យមុសា បាបដែលបុគ្គលនោះធ្វើ ឈ្មោះថាមិនបានធ្វើទេ ទោះបីបុគ្គលឯណា ធ្វើពពួកសត្វលើប្រឹថពីនេះ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ ដោយចក្រដែលមានខ្នងកង់ដ៏មុត បាបដែលមានអំពើនោះជាហេតុក៏មិនមាន ដំណើរមកនៃបាបក៏មិនមាន ។ ទោះបីបុគ្គលច្លងទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វខ្លួនឯង ប្រើអ្នកដទៃឲ្យសម្លាប់ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេខ្លួនឯង ប្រើអ្នកដទៃឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុក៏មិនមាន ដំណើរមកនៃបាបក៏មិនមាន ។ ទោះបីបុគ្គលច្លងទៅកាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទានខ្លួនឯង ប្រើអ្នកដទៃ

៣៣៨



បេន្តោ យជន្តោ យាជេន្តោ នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សំយមេន សច្ចវជ្ជេន នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។ សចេ តស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អបណ្ណកតាយ មយ្ហំ យ្វាហំ ន កិញ្ចិ ព្យាពាធេមិ តសំ វា ថាវរំ វា ឧភយមេត្ថ កដគ្គាហោ យញ្ចម្ហិ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ យញ្ច កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ។ តស្ស ចាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ ខោ គាមណិ ធម្មសមាធិ ។ តត្រ ចេ ត្វំ ចិត្តសមាធឹ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ ។

ឲ្យឲ្យទាន បូជាខ្លួនឯង ប្រើអ្នកដទៃឲ្យបូជា បុណ្យដែលមានអំពើនោះ ជាហេតុក៏មិនមាន ដំណើរមកនៃបុណ្យក៏មិនមាន បុណ្យក៏មិនមាន ដោយការឲ្យទាន ដោយការទូន្មាន ដោយការសង្រួម ដោយការពោល ពាក្យសច្ចៈ ដំណើរមកនៃបុណ្យក៏មិនមាន ។ បើពាក្យរបស់សាស្តា ដ៏ចម្រើននោះ ជាពាក្យសច្ចៈ ដោយហេតុមិនខុសនឹងអញ ឥឡូវអញមិន បៀតបៀនសត្វណាមួយ ដែលមានសេចក្តីតក់ស្លុតឬមិនមានសេចក្តីតក់ ស្លុតទេ អញក៏បានឈ្មោះថាជាអ្នកកាន់យកនូវជ័យជម្នះទាំងពីរយ៉ាង ក្នុង លោកនេះ គឺថាអញបានសង្រួមកាយ សង្រួមវាចា សង្រួមចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ អញនឹងទៅកើតក្នុងសុគតិសួគ៌ទេវ-លោក ។ បាមោជ្ជៈក៏កើតឡើងដល់អរិយសាវ័កនោះ កាលបើមាន បាមោជ្ជៈហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ កាយ ក៏ស្ងប់ លុះមានកាយស្ងប់ហើយ រមែងសោយសុខ ចិត្តរបស់អរិយ-សាវកដែលមានសុខ រមែងតម្កល់មាំ ។ ម្នាលគាមណិ នេះឯងហៅ ថាធម្មសមាធិ ។ បើអ្នកបានចិត្តសមាធិក្នុងធម្មសមាធិនោះ អ្នកមុខជា នឹងលះបង់សេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។

[៣១១] ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យ្វាយំ សត្ថា ឯវំវាទី ឯវំទិដ្ឋិ ករោតោ ការយតោ ឆិន្ទតោ ឆេទា-បយតោ បចតោ បាចយតោ សោចតោ សោចយតោ កិលមតោ កិលមយតោ ផន្ទតោ ផន្ទាបយតោ បាណមតិមាបយតោ អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ

[៣១១] ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាសចាក អភិជ្ឈា ប្រាសចាកព្យាបាទ យ៉ាងនេះហើយ ជាអ្នកមិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ មានចិត្តប្រកប ដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ដោយប្រការដូច្នេះ ។ អរិយសាវ័កនោះ រមែង ពិចារណាឃើញដូច្នេះថា សាស្តាណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាង នេះថា បាបដែលបុគ្គលធ្វើខ្លួនឯង ប្រើគេឲ្យធ្វើ កាត់ (អវយវៈគេ) ខ្លួន ឯង ប្រើគេឲ្យកាត់ បៀតបៀនគេខ្លួនឯង ប្រើគេឲ្យបៀតបៀន សោយ សោកខ្លួនឯង ធ្វើគេឲ្យសោយសោក ធ្វើខ្លួនឯងឲ្យលំបាក ធ្វើគេឲ្យលំ-បាក អន្ទះអន្ទែងខ្លួនឯង ធ្វើគេឲ្យអន្ទះអន្ទែង សម្លាប់សត្វខ្លួនឯង ឬប្រើ គេឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់តំណ (ជញ្ជាំង)

គាមណិសំយុត្តំ

និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណតោ ករោតោ ករិយតិ បាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា បាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ ករេយ្យ អត្ថិ តតោនិទានំ បាបំ អត្ថិ បាបស្ស អាគមោ ។ ទក្ខិណំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ បាចេន្តោ អត្ថិ តតោនិទានំ បាបំ អត្ថិ បាបស្ស អាគមោ ។ ឧត្តរំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យាជេន្តោ អត្ថិ តតោនិ-ទានំ បុញ្ញំ អត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សំយមេន សច្ចវជ្ជេន អត្ថិ បុញ្ញំ អត្ថិ បុញ្ញស្ស អាគមោតិ ។ សចេ តស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អបណ្ណកតាយ ។ មយ្ហំ យម្ហំ ន កិញ្ចិ ព្យាពាធេមិ តសំ វា ថាវរំ វា ឧភយមេត្ថ កដគ្គា-ហោ យញ្ចម្ហិ កាយេន សំវុតោ វាចាយ សំវុតោ

ប្ញន់យកទ្រព្យពួកអ្នកស្រុក ប្ញន់យកទ្រព្យក្នុងផ្ទះមួយៗ ឈរចាំលួចធក់ក្បែរផ្លូវធំ គប់រកប្រពន្ធបុគ្គលដទៃ និយាយមុសា បាបដែលបុគ្គលនោះធ្វើឈ្មោះថាធ្វើមែន បើបុគ្គលឯណាធ្វើពពួកសត្វលើប្រឹថពីនេះ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ ដោយចក្រមានខ្នងកង់ដ៏មុត បាបដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបាបក៏មាន ។ បើបុគ្គលឆ្លងទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វខ្លួនឯង ប្រើគេឲ្យសម្លាប់ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើគេឲ្យកាត់ បៀតបៀនគេខ្លួនឯង ប្រើគេឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបាបក៏មាន ។ បើបុគ្គលឆ្លងទៅកាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទានខ្លួនឯង ប្រើគេឲ្យឲ្យទាន បូជាខ្លួនឯង ប្រើគេឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបុណ្យក៏មាន បុណ្យក៏មានដោយការឲ្យទាន ដោយការទូន្មាន ដោយការសង្រួម ដោយការពោលពាក្យសច្ចៈ ដំណើរមកនៃបុណ្យក៏មាន ។ បើពាក្យរបស់សាស្តាដ៏ចម្រើននោះ ជាពាក្យសច្ចៈ ដោយហេតុមិនខុសនឹងពាក្យអញ ឥឡូវអញមិនបៀតបៀនសត្វណាមួយ ដែលមានសេចក្តីតក់ស្លុតឬមិនមានសេចក្តីតក់ស្លុតទេ អញបានឈ្មោះថាជាអ្នកកាន់យកនូវជ័យជម្នះទាំងពីរយ៉ាងក្នុងលោកនេះ គឺថាអញបានសង្រួមកាយ សង្រួមវាចា

មនសា សំវុតោ យញ្ច កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ។ តស្ស បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ ខោ គាមណិ ធម្មសមាធិ ។ តត្រ ចេ ត្វំ ចិត្តសមាធឹ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ ។

[៣១២] ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ ករុណាសហគតេន ចេតសា

សង្រួមចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ អញនឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បាមោជ្ជៈក៏កើតឡើងដល់អរិយសាវ័កនោះ កាលបើមានបាមោជ្ជៈ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់ លុះមានកាយស្ងប់ រមែងសោយសុខ ចិត្តរបស់អរិយសាវ័កដែលមានសុខ រមែងតម្កល់មាំ ។ ម្នាលគាមណិ នេះឯងហៅថាធម្មសមាធិ ។ បើអ្នកបានចិត្តសមាធិក្នុងធម្មសមាធិនោះ អ្នកមុខជាលះបង់សេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។

[៣១២] ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ យ៉ាងនេះហើយ មិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយករុណា

ឯកំ ទិសំ ផរិត្វា វិហរតិ ។ មុទិតាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យ្វាយំ សត្ថា ឯវំវាទី ឯវំទិដ្ឋិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា

ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ យ៉ាងនេះហើយ មិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូចៗ ដោយយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយប្រការដូច្នេះ ។ អរិយសាវ័កនោះ រមែងពិចារណាឃើញដូច្នេះថា សាស្តាឯណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្មដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ

នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ សចេ តស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អបណ្ណកតាយ មយ្ហំ យ្វាហំ ន កិញ្ចិ ព្យាពាធេមិ តសំ វា ថាវរំ វា ឧភយមេត្ថ កដគ្គាហោ យញ្ចម្ហិ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ យញ្ច កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ។ តស្ស បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ ខោ គាមណិ ធម្មសមាធិ ។ តត្រ ចេ ត្វំ ចិត្តសមាធឹ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ ។

ពួកសត្វជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯង ហើយប្រកាសនូវលោកនេះនិងលោកខាងមុខបាន ក៏មិនមានក្នុងលោក ។ បើពាក្យរបស់សាស្តាដ៏ចម្រើននោះ ជាពាក្យសច្ចៈ ដោយហេតុមិនខុសនឹងពាក្យអញ ឥឡូវអញមិនបៀតបៀនសត្វណាមួយ ដែលមានសេចក្តីតក់ស្លុតឬគ្មានសេចក្តីតក់ស្លុត អញក៏បានឈ្មោះថាជាអ្នកកាន់យកនូវជ័យជម្នះទាំងពីរយ៉ាងក្នុងលោកនេះ គឺថាអញបានសង្រួមកាយ សង្រួមវាចា សង្រួមចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ អញនឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក បាមោជ្ជៈក៏កើតឡើងដល់អរិយ-សាវ័កនោះ កាលបើមានបាមោជ្ជៈ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់ លុះមានកាយស្ងប់ រមែងសោយសុខ ចិត្តរបស់អរិយសាវ័កដែលមានសុខ រមែងតម្កល់មាំ ។ ម្នាលគាមណិ នេះឯងហៅថាធម្មសមាធិ ។ បើអ្នកបានចិត្តសមាធិក្នុងធម្មសមាធិនោះ អ្នកមុខជាលះបង់នូវសេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។

គាមណិសំយុត្តំ

[៣១៣] ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្ប-ជានោ បដិស្សតោ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេ-រេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិ-សញ្ចិក្ខតិ យ្វាយំ សត្ថា ឯវំវាទី ឯវំទិដ្ឋិ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា

គាមណិសំយុត្ត

[៣១៣] ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាស ចាកអភិជ្ឈា ប្រាសចាកព្យាបាទ យ៉ាងនេះហើយ ជាអ្នកមិនមានសេចក្តី វង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកប ដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថ ទាំង ៤ ។ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូច គ្នា ។ មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិន មានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិស ខាងលើ ទិសខាងក្រោម និងទិសទទឹងគឺទិសតូចៗ ដោយយកខ្លួនប្រៀប ផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយប្រការដូច្នេះ ។ អរិយសាវ័កនោះ រមែងពិចារណាឃើញដូច្នេះថា សាស្តាណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គល ឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាក របស់កម្មដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន លោកនេះមាន លោកខាង មុខមាន មាតាមានគុណ បិតាមានគុណ ពួកសត្វជាឱបបាតិកៈ មាន

អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ សចេ តស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អបណ្ណកតាយ មយ្ហំ យ្វាហំ ន កិញ្ចិ ព្យាពាធេមិ តសំ វា ថាវរំ វា ឧភយមេត្ថ កដគ្គាហោ យញ្ចម្ហិ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ យញ្ច កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ។ តស្ស បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ ខោ គាមណិ ធម្មសមាធិ ។ តត្រ ចេ ត្វំ ចិត្តសមាធឹ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ ។

ពួកសមណព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯង ហើយប្រកាសនូវលោកនេះនិងលោកខាងមុខបាន ក៏មានក្នុងលោក ។ បើពាក្យរបស់សាស្តាដ៏ចម្រើននោះ ជាពាក្យសច្ចៈ ដោយហេតុមិនខុសនឹងពាក្យអញ ឥឡូវអញមិនបៀតបៀនសត្វណាមួយ ដែលមានសេចក្តីតក់ស្លុតឬមិនមានសេចក្តីតក់ស្លុតទេ អញក៏បានឈ្មោះថាជាអ្នកកាន់យកនូវជ័យជម្នះទាំងពីរយ៉ាងក្នុងលោកនេះ គឺថាអញបានសង្រួមកាយ សង្រួមវាចា សង្រួមចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ អញនឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បាមោជ្ជៈក៏កើតឡើងដល់អរិយសាវ័កនោះ កាលបើមានបាមោជ្ជៈ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់ លុះមានកាយស្ងប់ រមែងសោយសុខ ចិត្តរបស់អរិយសាវ័កដែលមានសុខ រមែងតម្កល់មាំ ។ ម្នាលគាមណិ នេះឯងហៅថាធម្មសមាធិ ។ បើអ្នកបានចិត្តសមាធិក្នុងធម្មសមាធិនោះ អ្នកមុខជាលះបង់នូវសេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។

[៣១៤] ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យ្វាយំ សត្ថា ឯវំវាទី ឯវំទិដ្ឋិ ករតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បាចយតោ សោចតោ សោចយតោ កិលម-តោ កិលមយតោ ផន្ទតោ ផន្ទាបយតោ បាណមតិ-

គាមណិសំយុត្ត

[៣១៤] ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាស ចាកអភិជ្ឈា ប្រាសចាកព្យាបាទ យ៉ាងនេះហើយ ជាអ្នកមិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងគឺទិសតូចៗ ដោយយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយប្រការដូច្នេះ ។ អរិយសាវ័កនោះ រមែងពិចារណាឃើញដូច្នេះថា សាស្តាណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ប្រើអ្នកដទៃឲ្យធ្វើ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេខ្លួនឯង ប្រើអ្នកដទៃឲ្យបៀតបៀន សោយ-សោកខ្លួនឯង ធ្វើគេឲ្យសោយសោក ធ្វើខ្លួនឯងឲ្យលំបាក ធ្វើអ្នកដទៃឲ្យលំបាក អន្ទះអន្ទែងខ្លួនឯង ធ្វើអ្នកដទៃឲ្យអន្ទះអន្ទែង សម្លាប់សត្វ

មាបយតោ អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ
ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ
គច្ឆតោ មុសា ភណតោ ករោតោ ន ករីយតិ បាបំ
ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បថវិយា
បាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ ករេយ្យ នត្ថិ
តតោនិទានំ បាបំ នត្ថិ បាបស្ស អាគមោ ។ ទក្ខិណំ
ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ
ឆេទាបេន្តោ បចន្តោ បាចេន្តោ នត្ថិ តតោនិទានំ បាបំ
នត្ថិ បាបស្ស អាគមោ ។ ឧត្តរំ ចេបិ គង្គាយ តីរំ គច្ឆេ-
យ្យ ទទន្តោ ទាបេន្តោ យជន្តោ យាជេន្តោ នត្ថិ តតោនិ-
ទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សំ-
យមេន សច្ចវជ្ជេន នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។
សចេ តស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អបណ្ណក-
តាយ មយ្ហំ យ្វាហំ ន កិញ្ចិ ព្យាពាធេមិ តសំ វា

ខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់តំណ (ជញ្ជាំង) ប្លន់យកទ្រព្យពួកអ្នកស្រុក ប្លន់យកទ្រព្យក្នុងផ្ទះមួយៗ ឈរចាំលួចឆក់ក្បែរផ្លូវធំ គប់រកប្រពន្ធបុគ្គលដទៃ ពោលពាក្យមុសា បាបដែលបុគ្គលនោះធ្វើ ឈ្មោះថាមិនបានធ្វើទេ ទោះបីបុគ្គលណាធ្វើពពួកសត្វលើផែនដីនេះ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ ដោយចក្រមានខ្នងកង់ដ៏មុត បាបដែលមានអំពើនោះជាហេតុក៏មិនមាន ទាំងដំណើរមកនៃបាបក៏មិនមាន ។ ទោះបីបុគ្គលច្លងទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វខ្លួនឯង ប្រើគេឲ្យសម្លាប់ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើគេឲ្យកាត់ បៀតបៀនខ្លួនឯង ប្រើគេឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុក៏មិនមាន ដំណើរមកនៃបាបក៏មិនមាន ។ ទោះបីបុគ្គលច្លងទៅកាន់ត្រើយទន្លេគង្គាខាងជើងហើយឲ្យទានខ្លួនឯង ប្រើគេឲ្យឲ្យទាន បូជាខ្លួនឯង ប្រើគេឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុក៏មិនមាន ដំណើរមកនៃបុណ្យក៏មិនមាន បុណ្យមិនមានដោយការឲ្យទាន ដោយការទូន្មាន ដោយការសង្រួម ដោយការពោលពាក្យសច្ចៈ ដំណើរមកនៃបុណ្យក៏មិនមាន ។ បើពាក្យរបស់សាស្តាដ៏ចម្រើននោះ ជាពាក្យសច្ចៈ ដោយហេតុមិនខុសនឹងពាក្យអញ ឥឡូវអញមិនបៀតបៀនសត្វណាមួយ ដែលមានសេចក្តីតក់ស្លុត

ឋានំ វា ឧភយមេត្ថ កដគ្គាហោ យញ្ចម្ហិ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ យញ្ច កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ។ តស្ស បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធ-កាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ ខោ គាមណិ ធម្មសមាធិ ។ តត្រ ចេ ត្វំ ចិត្ត-សមាធឹ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ ។

[៣១៤] ស ខោ សោ គាមណិ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជា-នោ បដិស្សតោ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន

ឬមិនមានសេចក្តីតក់ស្លុតទេ អញក៏បានឈ្មោះថាជាអ្នកកាន់យកនូវជ័យជម្នះទាំងពីរយ៉ាងក្នុងលោកនេះ គឺថាអញបានសង្រួមកាយ សង្រួមវាចា សង្រួមចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ អញនឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បាមោជ្ជៈក៏កើតឡើងដល់អរិយសាវ័កនោះ កាលបើមានបាមោជ្ជៈ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់ លុះមានកាយស្ងប់ រមែងសោយសុខ ចិត្តរបស់អរិយសាវកដែលមានសុខ រមែងតម្កល់មាំ ។ ម្នាលគាមណិ នេះឯងហៅថាធម្មសមាធិ ។ បើអ្នកបានចិត្តសមាធិក្នុងធម្មសមាធិនោះ អ្នកមុខជាលះបង់សេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។

[៣១៥] ម្នាលគាមណិ អរិយសាវ័កនោះឯង ជាអ្នកប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ យ៉ាងនេះហើយ ជាអ្នកមិនមានសេចក្តីវង្វេង មានសេចក្តីដឹងសព្វគ្រប់ មានស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ

អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យ្វាយំ សត្ថា ឯវំវាទី ឯវំទិដ្ឋិ ករតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បាចយតោ សោចតោ សោចយតោ កិលមតោ កិលមយតោ ផន្ទតោ ផន្ទាបយតោ បាណមតិមាបយតោ អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណតោ ករតោ ករីយតិ បាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា បាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ ករេយ្យ អត្ថិ តតោនិទានំ បាបំ អត្ថិ បាបស្ស អាគមោ ។ ទក្ខិណំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃា-

មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោមនិងទិសទទឹង គឺទិសតូចៗ ដោយយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង សម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយប្រការដូច្នេះ ។ អរិយសាវ័កនោះ រមែងពិចារណាឃើញដូច្នេះថា សាស្តាណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ប្រើគេឲ្យធ្វើ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើគេឲ្យកាត់ បៀតបៀនគេខ្លួនឯង ប្រើគេឲ្យបៀតបៀន សោយសោកខ្លួនឯង ធ្វើគេឲ្យសោយសោក ធ្វើខ្លួនឯងឲ្យលំបាក ធ្វើគេឲ្យលំបាក អន្ទះអន្ទែងខ្លួនឯង ធ្វើគេឲ្យអន្ទះអន្ទែង សម្លាប់សត្វខ្លួនឯង ឬប្រើគេឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់តំណ (ជញ្ជាំង) ប្លន់យកទ្រព្យពួកអ្នកស្រុក ប្លន់យកទ្រព្យក្នុងផ្ទះមួយៗ ឈរចាំលួចឆក់ក្បែរផ្លូវធំ គប់រកប្រពន្ធបុគ្គលដទៃ និយាយកុហក បាបដែលបុគ្គលនោះធ្វើ ឈ្មោះថាធ្វើមែន បើបុគ្គលឯណាធ្វើពពួកសត្វលើប្រឹថពីនេះ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ ដោយចក្រមានខ្នងកង់ដ៏មុត បាបដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបាបក៏មាន ។ ទោះបីបុគ្គលធ្វងទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វខ្លួនឯង ប្រើគេឲ្យ

គាមណិសំយុត្តំ

តេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ បាចេន្តោ អត្ថិ តតោនិទានំ បាបំ អត្ថិ បាបស្ស អាគមោ ។ ឧត្តរិំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យាជេន្តោ អត្ថិ តតោនិទានំ បុញ្ញំ អត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សំយមេន សច្ចវជ្ជេន អត្ថិ បុញ្ញំ អត្ថិ បុញ្ញស្ស អាគមោតិ ។ សចេ តស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អបណ្ណកតាយ មយ្ហំ យ្វាហំ ន កិញ្ចិ ព្យាពាធេមិ តសំ វា ថាវរំ វា ឧភយមេត្ថ កដគ្គាហោ យញ្ចម្ហិ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ យញ្ច កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ។ តស្ស បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ ខោ គាមណិ ធម្មសមាធិ ។

សម្លាប់ កាត់ (អវយវៈគេ) ខ្លួនឯង ប្រើគេឲ្យកាត់ បៀតបៀនគេខ្លួនឯង ប្រើគេឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបាបក៏មាន ។ ទោះបីបុគ្គលច្នេងទៅកាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទានខ្លួនឯង ប្រើគេឲ្យឲ្យទាន បូជាខ្លួនឯង ប្រើគេឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុក៏មាន ដំណើរមកនៃបុណ្យក៏មានដែរ បុណ្យក៏មាន ដោយការឲ្យទាន ដោយការទូន្មាន ដោយការសង្រួម ដោយការពោលពាក្យសច្ចៈ ដំណើរមកនៃបុណ្យក៏មាន ។ បើពាក្យរបស់សាស្តាដ៏ចម្រើននោះ ជាពាក្យសច្ចៈ ដោយហេតុមិនខុសនឹងអញ ឥឡូវអញមិនបៀតបៀនសត្វណាមួយ ដែលមានសេចក្តីតក់ស្លុតឬមិនមានសេចក្តីតក់ស្លុតទេ អញក៏បានឈ្មោះថាជាអ្នកកាន់យកនូវជ័យជម្នះទាំងពីរយ៉ាងក្នុងលោកនេះ គឺថាអញបានសង្រួមកាយ សង្រួមវាចា សង្រួមចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ អញនឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បាមោជ្ជៈក៏កើតឡើងដល់អរិយសាវ័កនោះ កាលបើមានបាមោជ្ជៈ បីតិក៏កើត កាលបើមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់ លុះមានកាយស្ងប់ រមែងសោយសុខ ចិត្តរបស់អរិយសាវ័កដែលមានសុខ រមែងតម្កល់មាំ ។ ម្នាលគាមណិ នេះឯងហៅថាធម្មសមាធិ ។

តត្រ ចេ ត្វំ ចិត្តសមាធឹ បដិលភេយ្យាសិ ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសីតិ ។ ឯវំ វុត្តេ បាដលិយោ គាមណិ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ ។ បេ ។ អជ្ជតគ្គេ បាណុបេតំ សរណាគតន្តិ ។ តេរសមំ ។

គាមណិសំយុត្តំ សមត្តំ ។

## តស្សុទ្ទានំ

ចណ្ឌបុត្តោ[១] យោធាជីវោ
ហត្ថិ ហយោ ច ភូមកោ[២]
ទេសនាសង្ខា កុលំ មណិចូឡំ
គន្ធភកការាសិយបាដលីតិ[៣] ។

១ ឱ. ម. ចណ្ឌោ បុដោ ។ ២ ហត្ថិហយោ បច្ឆាភូមកោ ។ ៣ ភទ្រក រាសសបា-ដលីតិ ។

បើអ្នកបានចិត្តសមាធិក្នុងធម្មសមាធិនោះ អ្នកមុខជាលះបង់សេចក្តីសង្ស័យនេះចេញបាន ដោយប្រការដូច្នេះ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ បាដលិយគាមណីក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា ភ្លឺច្បាស់ណាស់ ព្រះអង្គ ភ្លឺច្បាស់ណាស់ ព្រះអង្គ ។ បេ ។ ជាអ្នកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។ ចប់សូត្រទី ១៣ ។

ចប់ គាមណិសំយុត្ត ។

## ឧទ្ទាននៃគាមណិសំយុត្តនោះគឺ

និយាយអំពីចណ្ឌគាមណី ១ អំពីតាលបុត្តគាមណី ១ អំពីយោធាជីវគាមណី ១ អំពីហត្ថារោហគាមណី ១ អំពីអស្សារោហគាមណី ១ អំពីពួកព្រាហ្មណ៍ស្រុកបច្ឆាភូមិ ១ អំពីការសំដែងធម៌ ១ អំពីការពិចារណា ១ អំពីសេចក្តីអនុគ្រោះត្រកូល ១ អំពីមណិចូឡកគាមណី ១ អំពីគន្ធភកគាមណី ១ អំពីរាសិយគាមណី ១ អំពីបាដលិយគាមណី ១ ។

# អសង្ខតសំយុត្តស្ស បឋមវគ្គោ

[៣១៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អសង្ខតញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសង្ខតគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ អសង្ខតំ ។ យោ ភិក្ខវេ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ។ ឥទំ វុច្ចតិ ភិក្ខវេ អសង្ខតំ ។ កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ កាយគតាសតិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥតិ ខោ ភិក្ខវេ ទេសិតំ វោ មយា អសង្ខតំ ទេសិតោ អសង្ខតគាមិមគ្គោ ។ យំ ភិក្ខវេ

# អសង្ខតសំយុត្ត បឋមវគ្គ

[៣១៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងអសង្ខតធម៌ (ធម៌ដែលបច្ច័យតាក់តែងមិនបាន) ផង អសង្ខតគាមិមគ្គ (ផ្លូវជាដំណើរទៅកាន់អសង្ខតធម៌) ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះអសង្ខតធម៌តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សភាវៈដែលជាទីក្ស័យរាគៈ ក្ស័យទោសៈ ក្ស័យមោហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតធម៌ ។ ម្នាលភិក្ខុទាំងឡាយ ចុះអសង្ខតគាមិមគ្គតើដូចម្តេច ។ (អសង្ខតគាមិមគ្គនោះ) គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខត-ធម៌ តថាគតបានសំដែងហើយ អសង្ខតគាមិមគ្គ តថាគតក៏បានសំដែងហើយដល់អ្នកទាំងឡាយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ

សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេ-ន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ ភិក្ខវេ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ។ ឈាយថ[១] ភិក្ខវេ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ ។ អយំ វោ[២] អម្ហាកំ អនុសាសនីតិ ។

[៣១៧] អសង្ខតញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសង្ខតគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ អសង្ខតំ ។ យោ ភិក្ខវេ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ។ ឥទំ វុច្ចតិ ភិក្ខវេ អសង្ខតំ ។ កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ សមថោ ច វិបស្សនា ច ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិ-មគ្គោ ។ បេ ។

១ ម. និជ្ឈាយថ ។ ២ ឱ. អយំ ខោ វោ ។

កិច្ចឯណាដែលសាស្តាជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យសេចក្តីអនុគ្រោះ ត្រូវធ្វើដល់សាវ័កទាំងឡាយ កិច្ចនោះតថាគតបានធ្វើដល់អ្នកទាំងឡាយរួចហើយ ។ ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងនុ៎ះគឺម្ចប់ឈើ កិច្ចទាំងនុ៎ះគឺផ្ទះស្ងាត់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសំឡឹងយក[១] (នូវអារម្មណ៍) កុំបីប្រមាទ កុំបីមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។ នេះឯងជាអនុសាសនី គឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[៣១៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងអសង្ខតធម៌ផង អសង្ខតគាមិមគ្គផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះអសង្ខតធម៌តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សភាវៈដែលជាទីក្ស័យរាគៈ ក្ស័យទោសៈ ក្ស័យមោហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតធម៌ ។ ម្នាលភិក្ខុទាំងឡាយ ចុះអសង្ខតគាមិមគ្គតើដូចម្តេច ។ គឺសមថៈ ១ វិបស្សនា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។ បេ ។

---

១ អដ្ឋកថាពន្យល់ថា ត្រូវសំឡឹងយកនូវអារម្មណ៍ទាំង ៣៨ ដោយអារម្មណូបនិជ្ឈានផង សំឡឹងយកនូវអាយតនៈទាំងឡាយមានខន្ធាយតនៈជាដើម ដោយអនិច្ចាទិលក្ខណៈដោយលក្ខណូបនិជ្ឈានផង រួមសេចក្តីថា អ្នកទាំងឡាយត្រូវខំចម្រើននូវសមថៈនិងវិបស្សនា ។

[៣១៨] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ សវិតក្កសវិចារោ សមាធិ អវិតក្កវិចារមត្តោ សមាធិ អវិតក្កអវិចារោ សមាធិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣១៩] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ សុញ្ញតោ សមាធិ អនិមិត្តោ សមាធិ អប្បណិហិតោ សមាធិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣២០] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ចត្តារោ សតិបដ្ឋានា ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣២១] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ចត្តារោ សម្មប្បធានា ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣២២] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ចត្តារោ ឥទ្ធិបាទា ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣១៨] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ គឺសមាធិដែលមានវិតក្កៈ មានវិចារៈ ១ សមាធិដែលគ្មានវិតក្កៈ មានតែវិចារៈ ១ សមាធិដែលគ្មានវិតក្កៈគ្មានវិចារៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣១៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ គឺសុញ្ញតសមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣២០] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ គឺសតិបដ្ឋាន ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣២១] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ គឺសម្មប្បធាន ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣២២] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ គឺឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣២៣] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ បញ្ចិន្ទ្រិយានិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិ-មគ្គោ ។

[៣២៤] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ បញ្ច ពលានិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិ-មគ្គោ ។

[៣២៥] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ សត្ត ពោជ្ឈង្គា ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិ-មគ្គោ ។

[៣២៦] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ អរិយោ អដ្ឋង្គិកោ មគ្គោ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខ-តគាមិមគ្គោ ។ ឥតិ ខោ ភិក្ខវេ ទេសិតំ វោ មយា អសង្ខតំ ទេសិតោ អសង្ខតគាមិមគ្គោ ។ យំ ភិក្ខវេ

[៣២៣] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ គឺឥន្ទ្រិយ ៥ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខត-គាមិមគ្គ ។

[៣២៤] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ គឺពលៈ ៥ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខត-គាមិមគ្គ ។

[៣២៦] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អសង្ខតគាមិ-មគ្គតើដូចម្តេច ។ គឺអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតធម៌ តថាគតបានសំដែងហើយ អសង្ខតគាមិមគ្គ តថាគតក៏បានសំដែងហើយដល់អ្នកទាំងឡាយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ

សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ ភិក្ខវេ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ។ ឈាយថ ភិក្ខវេ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ ។ អយំ វោ អម្ហាកំ អនុសាសនីតិ ។

អសង្ខតសំយុត្តស្ស បឋមវគ្គោ សមត្តោ ។

## តស្សុទ្ទានំ

កាយោ សមថោ វិតក្កោ
សុញ្ញតា សតិបដ្ឋានា
សម្មប្បធានា ឥទ្ធិបាទា
ឥន្ទ្រិយា ពលពោជ្ឈង្គា
មគ្គេន ឯកាទសមំ
តស្សុទ្ទានំ បវុច្ចតិ[១] ។

១ ម. ឥច្ចុទ្ទានំ បវុច្ចតិ ។ ឱ. ឥមេ បាឋា នត្ថិ ។

កិច្ចឯណាដែលសាស្តាជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យសេចក្តីអនុគ្រោះ ត្រូវធ្វើដល់សាវកទាំងឡាយ កិច្ចនោះតថាគតក៏បានធ្វើដល់អ្នកទាំងឡាយរួចហើយ ។ ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងនុ៎ះគឺម្លប់ឈើ កិច្ចទាំងនុ៎ះគឺផ្ទះស្ងាត់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសំឡឹងយក (នូវអារម្មណ៍) កុំបីប្រមាទ កុំបីមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។ នេះឯងជាអនុសាសនី គឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

ចប់ អសង្ខតសំយុត្ត បឋមវគ្គ ។

# ឧទ្ទាននៃអសង្ខតសំយុត្តនោះគឺ

និយាយអំពីកាយគតាសតិ ១ សមថៈនិងវិបស្សនា ១ សមាធិដែលប្រកបដោយវិតក្កៈជាដើម ១ សមាធិមានសុញ្ញតសមាធិជាដើម ១ សតិបដ្ឋាន ១ សម្មប្បធាន ១ ឥទ្ធិបាទ ១ ឥន្ទ្រិយ ១ ពលៈ ១ ពោជ្ឈង្គ ១ ជា ១១ និងអដ្ឋង្គិកមគ្គ ហៅថា ឧទ្ទាននៃអសង្ខតសំយុត្តនោះ ។

# អសង្ខតសំយុត្តស្ស ទុតិយវគ្គោ

[៣២៧] អសង្ខតញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសង្ខតគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ អសង្ខតំ ។ យោ ភិក្ខវេ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ។ ឥទំ វុច្ចតិ ភិក្ខវេ អសង្ខតំ ។ កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ សមថោ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥតិ ខោ ភិក្ខវេ ទេសិតំ វោ មយា អសង្ខតំ ទេសិតោ អសង្ខតគាមិមគ្គោ ។ យំ ភិក្ខវេ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ ភិក្ខវេ

# អសង្ខតសំយុត្ត ទុតិយវគ្គ

[៣២៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងអសង្ខតធម៌ផង អសង្ខតគាមិមគ្គផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតធម៌តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សភាវៈដែលជាទីក្ស័យរាគៈ ក្ស័យទោសៈ ក្ស័យមោហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតធម៌ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតគាមិមគ្គ តើដូចម្តេច ។ គឺសមថធម៌ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតធម៌ តថាគតបានសំដែងហើយ អសង្ខតគាមិមគ្គ តថាគតក៏បានសំដែងហើយ ដល់អ្នកទាំងឡាយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ កិច្ចឯណាដែលសាស្តាជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យសេចក្តីអនុគ្រោះ ត្រូវធ្វើដល់សាវ័កទាំងឡាយ កិច្ចនោះតថាគតក៏បានធ្វើដល់អ្នកទាំងឡាយរួចហើយ ។ ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងនុ៎ះ

រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ។ ឈាយថ ភិក្ខវេ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ ។ អយំ វោ អម្ហាកំ អនុសាសនីតិ ។

[៣៦៨] អសង្ខតញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសង្ខតគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ អសង្ខតំ ។ យោ ភិក្ខវេ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ។ ឥទំ វុច្ចតិ ភិក្ខវេ អសង្ខតំ ។ កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ វិបស្សនា ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥតិ ខោ ភិក្ខវេ ទេសិតំ វោ មយា អសង្ខតំ ។ បេ ។ អយំ វោ ភិក្ខវេ ទេសិតំ វោ មយា អសង្ខតំ ។ បេ ។ អយំ វោ អម្ហាកំ អនុសាសនីតិ ។ បេ ។

[៣៦៩] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ សវិតក្កោ សវិចារោ សមាធិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

គឺម្ចប់ឈើ កិច្ចទាំងនុ៎ះគឺផ្ទះស្ងាត់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយចូរសំឡឹងយក (នូវអារម្មណ៍) កុំបីប្រមាទ កុំបីមានសេចក្ដីក្ដៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។ នេះឯងជាអនុសាសនី គឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[៣២៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងអសង្ខតធម៌ផង អសង្ខតគាមិមគ្គផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្ដាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតធម៌ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សភាវៈដែលជាទីក្ស័យរាគៈ ក្ស័យទោសៈ ក្ស័យមោហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតធម៌ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតគាមិមគ្គតើដូចម្ដេច ។ គឺវិបស្សនាធម៌ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតធម៌ តថាគតបានសំដែងហើយ ដល់អ្នកទាំងឡាយ ដោយប្រការដូច្នេះឯង ។ បេ ។ នេះឯងជាអនុសាសនី គឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។ បេ ។

[៣២៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ គឺសមាធិប្រកបដោយវិតក្កៈ វិចារៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៣០] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ អវិតក្កោ វិចារមត្តោ សមាធិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។ បេ ។

[៣៣១] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ អវិតក្កោ អវិចារោ សមាធិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៣២] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ សុញ្ញតោ សមាធិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៣៣] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ អនិមិត្តោ សមាធិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៣៤] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ អប្បណិហិតោ សមាធិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៣០] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ គឺសមាធិដែលគ្មានវិតក្កៈ មានតែវិចារៈ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។ បេ ។

[៣៣១] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ គឺសមាធិដែលគ្មានវិតក្កៈ គ្មានវិចារៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៣២] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ គឺសុញ្ញតសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣៣៣] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ គឺអនិមិត្តសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣៣៤] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ គឺអប្បណិហិតសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣៣៥] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។ បេ ។

[៣៣៦] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៣៧] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៣៨] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៣៥] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានបញ្ញាស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។ បេ ។

[៣៣៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៣៧] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្ត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៣៨] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៣៩] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អា-រភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៤០] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អា-រភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៤១] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៣៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឆន្ទៈឲ្យកើតព្យាយាម ប្រារព្ធសេចក្តីខ្នះខ្នែង ផ្គូផ្គង ប្រុងចិត្ត ដើម្បីញ៉ាំងអកុសលធម៌ដ៏លាមកទាំងឡាយដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៤០] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធសេចក្តីខ្នះខ្នែង ផ្គូផ្គង ប្រុងចិត្ត ដើម្បីលះបង់អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៤១] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឆន្ទៈឲ្យកើតព្យាយាម ប្រារព្ធសេចក្តីខ្នះខ្នែង ផ្គងចិត្តប្រុងចិត្ត ដើម្បីញ៉ាំងកុសលធម៌ទាំង-ឡាយដែលមិនទាន់កើត ឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

អសង្ខតសំយុត្តស្ស ទុតិយវគ្គោ

[៣៤២] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៤៣] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៤៤] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

អសង្ខតសំយុត្ត ទុតិយវគ្គ

[៣៤២] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធសេចក្តីខ្នះខ្នែង ផ្គងផ្គង់ ប្រុងចិត្ត ដើម្បីញុំាងកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ឲ្យខ្ជាប់ខ្ជួន មិនឲ្យវិនាស ឲ្យធំទូលាយ ចម្រើនបរិបូណ៌ជាភិយ្យោភាព ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៤៣] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយបធានសង្ខារ (សេចក្តីព្យាយាម) ពោលគឺឆន្ទសមាធិ (សមាធិដែលអាស្រ័យនូវសេចក្តីពេញចិត្ត) ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៤៤] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយបធានសង្ខារ ពោលគឺវីរិយសមាធិ (សមាធិដែលអាស្រ័យនូវសេចក្តីព្យាយាម) ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៤៥] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខត-គាមិមគ្គោ ។

[៣៤៦] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ វីមំសាសមាធិប្បធានសង្ខារស-មន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតិ ភិក្ខវេ អ-សង្ខតគាមិមគ្គោ ។

[៣៤៧] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធិន្ទ្រិយំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៤៨] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ វីរិយិន្ទ្រិយំ ភាវេតិ វិវេកនិស្សិតំ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៨៥] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទដែលប្រកបដោយបធានសង្ខារ ពោលគឺចិត្តសមាធិ (សមាធិអាស្រ័យនូវសេចក្តីគិតនឹក) ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៨៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយបធានសង្ខារ ពោលគឺវីមំសាសមាធិ (សមាធិអាស្រ័យសេចក្តីពិចារណា) ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៨៧] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសទ្ធិន្ទ្រិយដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេកអាស្រ័យសេចក្តីរលត់ បង្អោនទៅកាន់សេចក្តីលះបង់ជាប្រក្រតី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៨៨] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនវីរិយិន្ទ្រិយដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៤៩] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សតិន្ទ្រិយំ ភាវេតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៥០] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សមាធិន្ទ្រិយំ ភាវេតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៥១] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ញិន្ទ្រិយំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៥២] កតមោ ច ភិក្ខវេ អសង្ខតគាមិ-មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធាពលំ ភាវេតិ វិវេក-និស្សិតំ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគា-មិមគ្គោ ។

[៣៨៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសតិន្ទ្រិយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៩០] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសមា-ធិន្ទ្រិយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៩១] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនបញ្ញិន្ទ្រិយ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ បង្អោនទៅកាន់សេចក្តីលះបង់ជាប្រក្រតី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៩២] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសទ្ធាពលៈ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៨៣] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ វីរិយពលំ ភាវេតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៨៤] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សតិពលំ ភាវេតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៨៥] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សមាធិពលំ ភាវេតិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៨៦] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ញាពលំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៥៣] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនវីរិយ-ពលៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៥៤] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គ តើ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសតិពលៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៥៥] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសមាធិ-ពលៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

[៣៥៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនបញ្ញាពលៈ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ បង្អោនទៅកាន់សេចក្តីលះបង់ជាប្រក្រតី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសង្ខតគាមិមគ្គ ។

អសង្ខតសំយុត្តស្ស ទុតិយវគ្គោ

[៣៨៧] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៨៨] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ វីរិយសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ បីតិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ សមា-ធិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគា-មិមគ្គោ ។

[៣៥៧] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ បង្អោនទៅកាន់សេចក្តីលះបង់ជាប្រក្រតី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣៥៨] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ ចម្រើនវីរិយសម្ពោជ្ឈង្គ ។ បេ ។ ចម្រើនសមាធិសម្ពោជ្ឈង្គ ។ បេ ។ ចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ បង្អោនទៅកាន់សេចក្តីលះបង់ជាប្រក្រតី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣៥៩] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។

[៣៦០] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាសង្កប្បំ ភាវេតិ ។ សម្មាវាចំ ភាវេតិ ។ សម្មាកម្មន្តំ ភាវេតិ ។ សម្មាអាជីវំ ភាវេតិ ។ សម្មាវាយាមំ ភាវេតិ ។ សម្មាសតឹ ភាវេតិ ។

[៣៦១] កតមោ ច ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ អយំ វុច្ចតិ ភិក្ខវេ អសង្ខតគាមិមគ្គោ ។ ឥតិ ខោ ភិក្ខវេ ទេ-សិតំ វោ មយា អសង្ខតំ ទេសិតោ អសង្ខតគាមិមគ្គោ ។

[៣៥៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យសេចក្ដីប្រាសចាកតម្រេក អាស្រ័យសេចក្ដីរលត់ បង្អោនទៅកាន់សេចក្ដីលះបង់ជាប្រក្រតី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។

[៣៦០] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាសង្កប្បៈ ។ ចម្រើនសម្មាវាចា ។ ចម្រើនសម្មាកម្មន្តៈ ។ ចម្រើនសម្មាអាជីវៈ ។ ចម្រើនសម្មាវាយាមៈ ។ ចម្រើនសម្មាសតិ ។

[៣៦១] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសង្ខតគាមិមគ្គតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាសមាធិ ដែលអាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យសេចក្ដីប្រាសចាកតម្រេក អាស្រ័យសេចក្ដីរលត់ បង្អោនទៅកាន់សេចក្ដីលះបង់ជាប្រក្រតី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអសង្ខតគាមិមគ្គ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតធម៌ តថាគតសំដែងហើយ អសង្ខតគាមិមគ្គក៏តថាគតសំដែងហើយ ដល់អ្នកទាំងឡាយ ដោយប្រការដូច្នេះឯង ។

យំ ភិក្ខវេ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ ភិក្ខវេ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ។ ឈាយថ ភិក្ខវេ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ ។ អយំ វោ អម្ហាកំ អនុសាសនីតិ ។

[៣៦២] អនតញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនតគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ អនតំ ។ បេ ។ (យថា អសង្ខតំ វិត្ថារិតំ តថា វិត្ថារេតព្វំ) ។

ម្នាលភិក្ខុទាំងឡាយ កិច្ចឯណាដែលសាស្តាជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យសេចក្តីអនុគ្រោះ ត្រូវធ្វើដល់សាវកទាំង-ឡាយ កិច្ចនោះតថាគតក៏បានធ្វើដល់អ្នកទាំងឡាយរួចហើយ ។ ម្នាល ភិក្ខុទាំងឡាយ កិច្ចទាំងនុ៎ះគឺម្លប់ឈើ កិច្ចទាំងនុ៎ះគឺផ្ទះស្ងាត់ ។ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសំឡឹងយក (នូវអារម្មណ៍) កុំបីប្រមាទ កុំបីមានសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ ។ នេះឯងជា អនុសាសនី គឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[៣៦២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវអនតធម៌[១] (ធម៌មិនបង្អោនទៅរកពាគាទិកិលេសគឺព្រះនិព្វាន) ផង នូវអនតគាមិមគ្គ (ផ្លូវជាដំណើរទៅកាន់អនតធម៌) ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ អនតធម៌តើដូចម្តេច ។ បេ ។ (អសង្ខតធម៌ដែលបានសំដែងដោយពិស្តារហើយយ៉ាងណា បណ្ឌិតត្រូវសំដែងធម៌នេះឲ្យពិស្តារយ៉ាងនោះចុះ) ។

---

១ មិនមានសេចក្តីត្រេកអរដោយតណ្ហា ។ អដ្ឋកថា ។

[៣៦៣] អជាសវញ្ច វោ ភិក្ខវេ ទេសិស្សាមិ អជាសវគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ អជាសវំ ។ បេ ។

[៣៦៤] សច្ចញ្ច វោ ភិក្ខវេ ទេសិស្សាមិ សច្ច-គាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ សច្ចំ ។ បេ ។

[៣៦៥] ចារញ្ច វោ ភិក្ខវេ ទេសិស្សាមិ ចារគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ ចារំ ។ បេ ។

[៣៦៦] និបុណញ្ច វោ ភិក្ខវេ ទេសិស្សាមិ និបុ-ណគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ និបុណំ ។ បេ ។

[៣៦៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងអនាសវធម៌ (ធម៌មិនមានអាសវៈ) ផង អនាសវគាមិមគ្គ (ផ្លូវជាដំណើរទៅកាន់អនាសវធម៌) ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ អនាសវធម៌តើដូចម្តេច ។ បេ ។

[៣៦៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវសច្ចធម៌ផង សច្ចគាមិមគ្គផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សច្ចធម៌តើដូចម្តេច ។ បេ ។

[៣៦៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវត្រើយគឺព្រះនិព្វានផង នូវមគ្គជាដំណើរទៅកាន់ត្រើយគឺព្រះនិព្វានផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ត្រើយគឺព្រះនិព្វានតើដូចម្តេច ។ បេ ។

[៣៦៦] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដ៏ល្អិតផង មគ្គជាដំណើរទៅកាន់ធម៌ដ៏ល្អិតផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដ៏ល្អិតតើដូចម្តេច ។ បេ ។

អសង្ខតសំយុត្តស្ស ទុតិយវគ្គោ

[៣៦៧] សុទុទ្ទសញ្ច វោ ភិក្ខវេ ទេសិស្សាមិ សុទុទ្ទសគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ សុទុទ្ទសំ ។ បេ ។

[៣៦៨] អជជ្ជរញ្ច វោ ភិក្ខវេ ទេសិស្សាមិ អជជ្ជ-រគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ អជជ្ជរំ ។ បេ ។

[៣៦៩] ធុវញ្ច វោ ភិក្ខវេ ទេសិស្សាមិ ធុវគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ ធុវំ ។ បេ ។

អសង្ខតសំយុត្ត ទុតិយវគ្គ

[៣៦៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលសត្វឃើញបានដោយកម្រពន់ពេកផង មគ្គជាដំណើរទៅកាន់ធម៌ដែលសត្វឃើញបានដោយកម្រពន់ពេកផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលសត្វឃើញបានដោយកម្រពន់ពេកតើដូចម្តេច ។ បេ ។

[៣៦៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលគ្មានសេចក្តីចាស់គ្រាំគ្រាផង មគ្គជាដំណើរទៅកាន់ធម៌ដែលគ្មានសេចក្តីចាស់គ្រាំគ្រាផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគ្មានសេចក្តីចាស់គ្រាំគ្រាតើដូចម្តេច ។ បេ ។

[៣៦៩] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដ៏ទៀងទាត់ផង មគ្គជាដំណើរទៅកាន់ធម៌ដ៏ទៀងទាត់ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដ៏ទៀងទាត់តើដូចម្តេច ។ បេ ។

[៣៧០] អបលោកិតញ្ច[១] ភោ ភិក្ខវេ ទេសិស្សាមិ អបលោកិតគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ អបលោកិតំ ។ បេ ។

[៣៧១] អនិទស្សនញ្ច ភោ ភិក្ខវេ ទេសិស្សាមិ អនិទស្សនគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ អនិទស្សនំ ។ បេ ។

[៣៧២] និប្បបញ្ចំ ច ភោ ភិក្ខវេ ទេសិស្សាមិ និប្បបញ្ចគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ និប្បបញ្ចំ ។ បេ ។

[៣៧៣] សន្តញ្ច ភោ ភិក្ខវេ ទេសិស្សាមិ សន្ត-គាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ សន្តំ ។ បេ ។

---

១ ឱ. អបលោកិតញ្ច ។

[៣៧០] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលមិនមានសេចក្តីវិនាសផង មគ្គជាដំណើរទៅកាន់ធម៌ដែលមិនមានសេចក្តីវិនាសផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនមានសេចក្តីវិនាសតើដូចម្តេច ។ បេ ។

[៣៧១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលមើលមិនឃើញដោយចក្ខុវិញ្ញាណផង មគ្គជាដំណើរទៅកាន់ធម៌ដែលមើលមិនឃើញដោយចក្ខុវិញ្ញាណផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមើលមិនឃើញដោយចក្ខុវិញ្ញាណតើដូចម្តេច ។ បេ ។

[៣៧២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលគ្មានដំណើរយឺតយូរផង មគ្គជាដំណើរទៅកាន់ធម៌ដែលគ្មានដំណើរយឺតយូរផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគ្មានដំណើរយឺតយូរតើដូចម្តេច ។ បេ ។

[៣៧៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ស្ងប់ផង មគ្គជាដំណើរទៅកាន់ធម៌ស្ងប់ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ស្ងប់តើដូចម្តេច ។បេ។

[៣៧៤] អមតញ្ច វោ ភិក្ខវេ ទេសិស្សាមិ អម-
តគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ
អមតំ ។ បេ ។

[៣៧៥] បណីតញ្ច វោ ភិក្ខវេ ទេសិស្សាមិ ប-
ណីតគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ
បណីតំ ។ បេ ។

[៣៧៦] សិវញ្ច វោ ភិក្ខវេ ទេសិស្សាមិ សិវគាមិញ្ច
មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ សិវំ ។ បេ ។

[៣៧៧] ខេមញ្ច វោ ភិក្ខវេ ទេសិស្សាមិ ខេ-
មគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ
ខេមំ ។ បេ ។

[៣៧៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលមិនស្លាប់ផង មគ្គជាដំណើរទៅកាន់ធម៌ដែលមិនស្លាប់ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនស្លាប់តើដូចម្តេច ។ បេ ។

[៣៧៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដ៏ថ្លៃថ្លាផង មគ្គជាដំណើរទៅកាន់ធម៌ដ៏ថ្លៃថ្លាផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដ៏ថ្លៃថ្លាតើដូចម្តេច ។ បេ ។

[៣៧៦] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងសិវធម៌ (ធម៌ជាទីសម្រាន្ត) ផង មគ្គជាដំណើរទៅកាន់សិវធម៌ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សិវធម៌តើដូចម្តេច ។ បេ ។

[៣៧៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដ៏ក្សេមផង មគ្គជាដំណើរទៅកាន់ធម៌ដ៏ក្សេមផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដ៏ក្សេមតើដូចម្តេច ។ បេ ។

[៣៧៨] តណ្ហាក្ខយញ្ច វោ ភិក្ខវេ ទេសិស្សាមិ តណ្ហាក្ខយគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ តណ្ហាក្ខយំ ។ បេ ។

[៣៧៩] អច្ឆរិយញ្ច វោ ភិក្ខវេ ទេសិស្សាមិ អច្ឆរិយគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ អច្ឆរិយំ ។ បេ ។

[៣៨០] អព្ភុតញ្ច វោ ភិក្ខវេ ទេសិស្សាមិ អព្ភុតគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ អព្ភុតំ ។ បេ ។

[៣៨១] អនីតិកញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនីតិកគាមិញ្ច មគ្គំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ អនីតិកំ ។ បេ ។

[៣៧៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ជាទីក្ស័យតណ្ហាផង មគ្គជាដំណើរទៅកាន់ធម៌ជាទីក្ស័យតណ្ហាផង ដល់អ្នកទាំង-ឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីក្ស័យនៃតណ្ហាតើដូចម្តេច ។ បេ ។

[៣៧៩] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ជាទីអស្ចារ្យផង មគ្គជាដំណើរទៅកាន់ធម៌ជាទីអស្ចារ្យផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីអស្ចារ្យតើដូចម្តេច ។ បេ ។

[៣៨០] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលមិនធ្លាប់មានផង មគ្គជាដំណើរទៅកាន់ធម៌ដែលមិនធ្លាប់មានផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនធ្លាប់មានតើដូចម្តេច ។ បេ ។

[៣៨១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងសេចក្តីមិនអន្តរាយផង មគ្គជាដំណើរទៅកាន់សេចក្តីមិនអន្តរាយផង ដល់អ្នកទាំង-ឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនអន្តរាយតើដូចម្តេច ។ បេ ។

អសង្ខតសំយុត្តស្ស ទុតិយវគ្គោ

[៣៨២] អនីតិកាឩម្មញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនីតិកាឩម្មគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ អនីតិកាឩម្មំ ។ បេ ។

[៣៨៣] និព្វានញ្ច វោ ភិក្ខវេ ទេសិស្សាមិ និព្វា-នគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ និព្វានំ ។ បេ ។

[៣៨៤] អព្យាបជ្ឈញ្ច វោ ភិក្ខវេ ទេសិស្សាមិ អព្យាបជ្ឈគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ អព្យាបជ្ឈំ ។ បេ ។

[៣៨៥] វិរាគញ្ច វោ ភិក្ខវេ ទេសិស្សាមិ វិរា-គគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមោ ច ភិក្ខវេ វិរាគោ ។ បេ ។

[៣៨២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌មិនមានអន្តរាយផង មគ្គជាដំណើរទៅកាន់ធម៌មិនមានអន្តរាយផង ដល់អ្នកទាំង-ឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនមានអន្តរាយតើដូចម្តេច ។ បេ ។

[៣៨៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងព្រះនិព្វានផង មគ្គជាដំណើរទៅកាន់ព្រះនិព្វានផង ដល់អ្នកទាំងឡាយ អ្នកទាំង-ឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ និព្វានតើដូចម្តេច ។ បេ ។

[៣៨៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌មិនព្យា-បាទផង មគ្គជាដំណើរទៅកាន់ធម៌មិនព្យាបាទផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនព្យាបាទតើដូចម្តេច ។ បេ ។

[៣៨៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ប្រាសចាកតម្រេកផង មគ្គជាដំណើរទៅកាន់ធម៌ប្រាសចាកតម្រេកផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ប្រាសចាកតម្រេកតើដូចម្តេច ។ បេ ។

[៣៨៦] សុទ្ធិញ្ច វោ ភិក្ខវេ ទេសិស្សាមិ សុទ្ធិគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមា ច ភិក្ខវេ សុទ្ធិ ។ បេ ។

[៣៨៧] មុត្តិញ្ច វោ ភិក្ខវេ ទេសិស្សាមិ មុត្តិគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមា ច ភិក្ខវេ មុត្តិ ។ បេ ។

[៣៨៨] អនាលយញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនាលយគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមោ ច ភិក្ខវេ អនាលយោ ។ បេ ។

[៣៨៩] ទីបញ្ច វោ ភិក្ខវេ ទេសិស្សាមិ ទីបគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ ទីបំ ។ បេ ។

[៣៨៦] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដ៏បរិសុទ្ធផង មគ្គជាដំណើរទៅកាន់ធម៌ដ៏បរិសុទ្ធផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដ៏បរិសុទ្ធតើដូចម្តេច ។ បេ ។

[៣៨៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ជាទីផុតចាកកិលេសផង មគ្គជាដំណើរទៅកាន់ធម៌ជាទីផុតចាកកិលេសផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីផុតចាកកិលេសតើដូចម្តេច ។ បេ ។

[៣៨៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌មិនមានអាល័យផង មគ្គជាដំណើរទៅកាន់ធម៌មិនមានអាល័យផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនមានអាល័យតើដូចម្តេច ។ បេ ។

[៣៨៩] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ជាទីពឹងផង មគ្គជាដំណើរទៅកាន់ធម៌ជាទីពឹងផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីពឹងតើដូចម្តេច ។ បេ ។

[៣៩០] លេណញ្ច វោ ភិក្ខវេ ទេសិស្សាមិ លេណគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ លេណំ ។ បេ ។

[៣៩១] តាណញ្ច វោ ភិក្ខវេ ទេសិស្សាមិ តាណគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ តាណំ ។ បេ ។

[៣៩២] សរណញ្ច វោ ភិក្ខវេ ទេសិស្សាមិ សរណគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ សរណំ ។ បេ ។

[៣៩៣] បរាយនញ្ច វោ ភិក្ខវេ ទេសិស្សាមិ បរាយនគាមិញ្ច មគ្គំ តំ សុណាថ ។ កាតមញ្ច ភិក្ខវេ បរាយនំ ។ យោ ភិក្ខវេ រាគក្ខយោ ទោសក្ខយោ មោ-

[៣៩០] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ជាទីពួនផង មគ្គជាដំណើរទៅកាន់ធម៌ជាទីពួនផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីពួនតើដូចម្តេច ។ បេ ។

[៣៩១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ជាទីការពារផង មគ្គជាដំណើរទៅកាន់ធម៌ជាទីការពារផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីការពារតើដូចម្តេច ។ បេ ។

[៣៩២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ជាទីរឭកផង មគ្គជាដំណើរទៅកាន់ធម៌ជាទីរឭកផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីរឭកតើដូចម្តេច ។ បេ ។

[៣៩៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ជាទីប្រព្រឹត្តទៅខាងមុខផង មគ្គជាដំណើរទៅកាន់ធម៌ជាទីប្រព្រឹត្តទៅខាងមុខផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីប្រព្រឹត្តទៅខាងមុខតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សភាវៈដែលជាទីក្ស័យរាគៈ ក្ស័យទោសៈ ក្ស័យ

ហាត្វាយោ ។ ឥធំ វុច្ចតិ ភិក្ខវេ បរាយនំ ។ កតមោ ច ភិក្ខវេ បរាយនគាមិមគ្គោ ។ កាយគតាសតិ ។ អយំ វុច្ចតិ ភិក្ខវេ បរាយនគាមិមគ្គោ ។ ឥតិ ខោ ភិក្ខវេ ទេសិតំ វោ មយា បរាយនំ ទេសិតោ បរាយនគាមិមគ្គោ ។ យំ ភិក្ខវេ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបា-ទាយ កតំ វោ តំ មយា ។ ឯតានិ ភិក្ខវេ រុក្ខមូ-លានិ ឯតានិ សុញ្ញាគារានិ ។ ឈាយថ ភិក្ខវេ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ ។ អយំ វោ អម្ហាកំ អនុសាសនីតិ ។ (យថា អសង្ខតំ វិត្ថារិតំ តថា វិត្ថារេតព្វំ) ។

អសង្ខតសំយុត្តស្ស ទុតិយវគ្គោ សមត្តោ ។

មោហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាធម៌ជាទីប្រព្រឹត្តទៅខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ មគ្គជាដំណើរទៅកាន់ធម៌ជាទីប្រព្រឹត្តទៅខាងមុខតើដូចម្តេច ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាមគ្គជាដំណើរទៅកាន់ធម៌ជាទីប្រព្រឹត្តទៅខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីប្រព្រឹត្តទៅខាងមុខ តថាគតបានសំដែងហើយ មគ្គជាដំណើរទៅកាន់ធម៌ជាទីប្រព្រឹត្តទៅខាងមុខ តថាគតក៏បានសំដែងហើយ ដល់អ្នកទាំងឡាយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ កិច្ចឯណាដែលសាស្តាជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុ-គ្រោះ អាស្រ័យសេចក្តីអនុគ្រោះ ត្រូវធ្វើដល់សាវ័កទាំងឡាយ កិច្ចនោះតថាគតក៏បានធ្វើដល់អ្នកទាំងឡាយរួចហើយ ។ ម្នាលភិក្ខុទាំង-ឡាយ កិច្ចទាំងនុ៎ះគឺម្ហប់ឈើ កិច្ចទាំងនុ៎ះគឺផ្ទះស្ងាត់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសំឡឹងយក (នូវអារម្មណ៍) កុំបីប្រមាទកុំបីមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។ នេះឯងជាអនុសាសនីរបស់តថាគតចំពោះអ្នកទាំងឡាយ ។ (បណ្ឌិតគប្បីសំដែងឲ្យពិស្តារតាមទំនងអសង្ខតធម៌ដែលបានសំដែងរួចមកហើយចុះ) ។

ចប់ អសង្ខតសំយុត្ត ទុតិយវគ្គ ។

# តស្សុទ្ទានំ

អសង្ខតំ អនតំ អនាសវំ
សច្ចញ្ច ចារំ និបុណំ សុទុទ្ទសំ
អជជ្ជរន្តំ ធុវំ អបលោកិនំ
អនិទស្សនំ និប្បបញ្ច សន្តំ ។
អមតំ បណីតញ្ច សិវញ្ច ខេមំ
តណ្ហាក្ខយោ អច្ឆរិយញ្ច អព្ភុតំ
អនីតិកំ អនីតិកធម្មំ
និព្វានមេតំ សុគតេន ទេសិតំ ។
អព្យាបជ្ឈោ វិរាគោ ច
សុទ្ធិ មុត្តិ អនាលយោ
ទីបំ លេណញ្ច តាណញ្ច
សរណញ្ច បរាយនន្តិ ។

អសង្ខតសំយុត្តំ សមត្តំ ។

# ឧទ្ទាននៃអសង្ខតសំយុត្តនោះគឺ

*និយាយអំពីអសង្ខតធម៌ ១ ធម៌មិនបង្អោនទៅរករាគាទិកិ្កលេស ១ ធម៌មិនមានអាសវៈ ១ ធម៌ពិត ១ ត្រើយគឺព្រះនិព្វាន ១ ធម៌ល្អិត ១ ធម៌ដែលសត្វឃើញបានដោយកម្រក្រៃពេក ១ ធម៌មិនចាស់គ្រាំគ្រា ១ ធម៌ទៀងទាត់ ១ ធម៌មិនវិនាស ១ ធម៌ដែលមើលមិនឃើញដោយចក្ខុវិញ្ញាណ ១ ធម៌គ្មានដំណើរយឺតយូរ ១ ធម៌ស្ងប់ ១ ។ ធម៌មិនស្លាប់ ១ ធម៌ដ៏ថ្លៃថ្លា ១ សិវធម៌ (ធម៌ជាទីសម្រាន្ត) ១ ធម៌ជាទីក្សេម ១ ធម៌ជាទីក្ស័យតណ្ហា ១ ធម៌ជាទីអស្ចារ្យ ១ ធម៌មិនធ្លាប់មាន ១ សេចក្តីមិនអន្តរាយ ១ ធម៌មិនមានអន្តរាយ ១ និព្វាន ១ នេះព្រះសុគតទ្រង់សំដែងទុកហើយ ។ ធម៌មិនមានព្យាបាទ ១ ធម៌ប្រាសចាកតម្រេក ១ ធម៌បរិសុទ្ធ ១ ធម៌ជាទីផុតចាកកិលេស ១ ធម៌មិនមានអាល័យ ១ ធម៌ជាទីពឹង ១ ធម៌ជាទីពួន ១ ធម៌ជាទីការពារ ១ ធម៌ជាទីរឭក ១ ធម៌ជាទីប្រព្រឹត្តទៅខាងមុខ ១ ។*

ចប់ អសង្ខតសំយុត្ត ។

# អព្យាកតសំយុត្តំ

[៣៩៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ខេមា ភិក្ខុនី កោសលេសុ ចារិកំ ចរមានា អន្តរា ច សាវត្ថឹ អន្តរា ច សាកេតំ តោរណវត្ថុស្មឹ វាសំ ឧបគតា ហោតិ ។ អថខោ រាជា បសេនទិកោសលោ សាកេតា សាវត្ថឹ គច្ឆន្តោ អន្តរា ច សាវត្ថឹ អន្តរា ច សាកេតំ តោរណវត្ថុស្មឹ ឯករត្តិវាសំ ឧបគច្ឆតិ ។ អថខោ រាជា បសេនទិកោសលោ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស តោរណវត្ថុស្មឹ តថារូបំ សមណំ វា ព្រាហ្មណំ វា ជាន យមហំ អជ្ជ បយិរុបាសេយ្យន្តិ ។ ឯវំ ទេវាតិ ខោ សោ បុរិសោ រញ្ញោ បសេនទិកោសលស្ស បដិស្សុត្វា កេវលកប្បំ តោរណវត្ថុំ អាហិណ្ឌន្តោ នាទ្ទស តថារូបំ សមណំ វា ព្រាហ្មណំ វា យំ រាជា បសេនទិកោសលោ បយិរុបាសេយ្យ ។

# អព្យាកតសំយុត្ត

[៣៩៤] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង នាងខេមាភិក្ខុនីត្រាច់ទៅកាន់ចារិកក្នុងកោសលជនបទ បានចូលទៅអាស្រ័យនៅក្នុងស្រុកឈ្មោះតោរណវត្ថុ ជាចន្លោះក្រុងសាវត្ថីនិងចន្លោះក្រុងសាកេត ។ លំដាប់នោះ ព្រះបាទបសេនទិកោសលស្តេចចេញចាកក្រុងសាកេតហើយ ទៅកាន់ក្រុងសាវត្ថី ស្តេចចូលទៅសំណាក់អស់មួយរាត្រីក្នុងស្រុកតោរណវត្ថុ ដែលជាចន្លោះនៃក្រុងសាវត្ថីនិងក្រុងសាកេត ។ គ្រានោះ ព្រះបាទបសេនទិកោសលទ្រង់ត្រាស់នឹងបុរសម្នាក់ថា នែបុរសដ៏ចម្រើន អ្នកឯងមកអាយ អ្នកឯងចូរដឹង (គយគន់មើល) នូវសមណៈឬព្រាហ្មណ៍ក្នុងស្រុកតោរណវត្ថុ ដែលល្មមអញចូលទៅរកក្នុងថ្ងៃនេះ ។ បុរសនោះទទួលព្រះរាជឱង្ការព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស ហើយត្រាច់រង្គាត់ទៅសព្វស្រុកតោរណវត្ថុ ក៏មិនឃើញសមណៈឬព្រាហ្មណ៍ណាមួយ ដែលល្មមព្រះបាទបសេនទិកោសលទ្រង់ចូលទៅរកសោះឡើយ ។

## អព្យាកតសំយុត្តំ

[៣៩៨] អទ្ទសា ខោ សោ បុរិសោ ខេមំ ភិក្ខុនឹ តោរណវត្ថុស្មឹ វាសំ ឧបគតំ ទិស្វាន យេន រាជា បសេនទិកោសលោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ បសេនទិកោសលំ ឯតទវោច នត្ថិ ខោ ទេវ តោរណវត្ថុស្មឹ តថារូបោ សមណោ វា ព្រាហ្មណោ វា យំ ទេវោ បយិរុបាសេយ្យ ។ អត្ថិ ច ខោ ទេវ ខេមា នាម ភិក្ខុនី តស្ស ភគវតោ សាវិកា អរហតោ សម្មាសម្ពុទ្ធស្ស ។ តស្សា ខោ បន អយ្យាយ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ បណ្ឌិតា ព្យត្តា មេធាវិនី ពហុស្សុតា ចិត្តកថី កល្យាណប្បដិភាណាតិ ។ តំ ទេវោ បយិរុបាសតូតិ ។

អព្យាកតសំយុត្ត

[៣៩៥] បុរសនោះ ស្រាប់តែបានឃើញខេមាភិក្ខុនីចូលទៅអា-
ស្រ័យនៅក្នុងស្រុកតោរណវត្ថុ លុះឃើញហើយ ក៏ចូលទៅគាល់ព្រះ
បាទបសេនទិកោសល លុះចូលទៅដល់ បានក្រាបបង្គំទូលព្រះបាទ
បសេនទិកោសលដូច្នេះថា បពិត្រព្រះសម្មតិទេព ក្នុងស្រុកតោរណវត្ថុ
មិនមានសមណៈឬព្រាហ្មណ៍ណាមួយ ដែលល្មមព្រះអង្គស្តេចចូលទៅ
រកឡើយ ។ បពិត្រព្រះសម្មតិទេព មានតែភិក្ខុនី ១ រូប ឈ្មោះខេមា
ជាសាវិការបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ឯកិត្តិ-
សព្ទដ៏ពីរោះរបស់នាងជាម្ចាស់នោះ ល្បីខ្ចរខ្ចាយទៅយ៉ាងនេះថា នាងជា
អ្នកប្រាជ្ញ ឈ្លាសវៃ មានប្រាជ្ញា ជាពហុស្សូត មានសំដីដ៏វិចិត្រ មាន
បដិភាណល្អ ។ សូមព្រះអង្គស្តេចចូលទៅរកខេមាភិក្ខុនីនោះចុះ ។

[៣៩៦] អថខោ រាជា បសេនទិកោសលោ យេន ខេមា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា ខេមំ ភិក្ខុនឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ខេមំ ភិក្ខុនឹ ឯតទវោច កឹ នុ ខោ អយ្យេ ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ មហារាជ ភគវតា ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បនយ្យេ ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ មហា-រាជ អព្យាកតំ ភគវតា ន ហោតិ តថាគតោ បរំ មរណាតិ ។ កឹ នុ ខោ អយ្យេ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ មហារាជ ភគវតា ហោតិ ច ន ច ហោតិ តថា-គតោ បរំ មរណាតិ ។ កឹ បនយ្យេ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ មហារាជ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។

[៣៩៦] លំដាប់នោះ ព្រះបាទបសេនទិកោសល ក៏ស្តេចចូលទៅរកខេមាភិក្ខុនី លុះចូលទៅដល់ ទ្រង់ថ្វាយបង្គំខេមាភិក្ខុនី ហើយគង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសលទ្រង់គង់ក្នុងទីសមគួរហើយ ទ្រង់មានព្រះបន្ទូលនឹងខេមាភិក្ខុនីដូច្នេះថា បពិត្រនាងជាម្ចាស់ សត្វស្លាប់ទៅកើតទៀតឬទេ ។ បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ បពិត្រនាងជាម្ចាស់ ចុះសត្វស្លាប់ទៅមិនកើតទៀតឬអ្វី ។ បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ បពិត្រនាងជាម្ចាស់ ចុះសត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានឬអ្វី ។ បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាននេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ បពិត្រនាងជាម្ចាស់ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។

## អព្យាកតសំយុត្តំ

[៣៩៧] កឹ នុ ខោ អយ្យេ ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋា សមានា អព្យាកតំ ខោ ឯតំ មហារាជ ភគវតា ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កឹ បនយ្យេ ន ហោតិ តថាគតោ បរំ មរ-ណាតិ ឥតិ បុដ្ឋា សមានា ឯតម្បិ ខោ មហារាជ អព្យាកតំ ភគវតា ន ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កឹ នុ ខោ អយ្យេ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋា សមានា អព្យា-កតំ ខោ ឯតំ មហារាជ ភគវតា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កឹ បនយ្យេ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋា សមានា ឯតម្បិ ខោ មហារាជ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កោ នុ ខោ អយ្យេ ហេតុ កោ បច្ចយោ យេនេតំ អព្យាកតំ ភគវតាតិ ។

អព្យាកតសំយុត្ត

[៣៩៧] កាលដែលខ្ញុំសួរដូច្នេះថា បពិត្រនាងជាម្ចាស់ សត្វស្លាប់ទៅកើតទៀតឬទេ នាងឆ្លើយថា បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ កាលដែលខ្ញុំសួរដូច្នេះថា បពិត្រនាងជាម្ចាស់ ចុះសត្វស្លាប់ទៅមិនកើតទៀតឬអ្វី នាងឆ្លើយថា បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ កាលដែលខ្ញុំសួរដូច្នេះថា បពិត្រនាងជាម្ចាស់ ចុះសត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានឬអ្វី នាងឆ្លើយថា បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាននេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ កាលដែលខ្ញុំសួរដូច្នេះថា បពិត្រនាងជាម្ចាស់ ចុះសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី នាងឆ្លើយថា បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ បពិត្រនាងជាម្ចាស់ អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំព្រះមានព្រះភាគមិនឲ្យទ្រង់ព្យាករពាក្យនេះ ។

[៣៩៨] តេនហិ មហារាជ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ មហារាជ អត្ថិ តេ កោចិ គណកោ វា មុទ្ទិកោ វា សង្ខាយកោ វា យោ បហោតិ គង្គាយ វាលិកំ[១] គណេតុំ ឯត្តកា វាលិកា ឥតិ វា ឯត្តកានិ វាលិកសតានិ ឥតិ វា ឯត្តកានិ វាលិកសហស្សានិ ឥតិ វា ឯត្តកានិ វាលិកសតសហស្សានិ ឥតិ វាតិ ។ នោ ហេតំ អយ្យេ ។ អត្ថិ បន តេ កោចិ គណកោ វា មុទ្ទិកោ វា សង្ខាយកោ វា យោ បហោតិ មហាសមុទ្ទេ ឧទកំ គណេតុំ[២] ឯត្តកានិ ឧទកាឡ្ហកានិ ឥតិ វា ឯត្តកានិ ឧទកាឡ្ហកសតានិ ឥតិ វា ឯត្តកានិ ឧទកាឡ្ហកសហស្សានិ ឥតិ វា ឯត្តកានិ ឧទកាឡ្ហកសតសហស្សានិ ឥតិ វាតិ ។ នោ ហេតំ អយ្យេ ។ តំ កិស្ស ហេតុ ។ មហាយ្យេ សមុទ្ទោ[៣] គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាហោតិ[៤] ។

១ ឱ. ម. វាលុកំ ។ ២ ឱ. មនិតុំ ។ ៣ ម. មហាសមុទ្ទោ ។ ៤ ទុប្បរិយោគាឡ្ហោតិ វា បាហោ ។

[៣៩៨] បពិត្រមហារាជ បើដូច្នោះ អាត្មាភាពសូមសបសួរព្រះអង្គក្នុងសេចក្តីនេះវិញ សូមព្រះអង្គទ្រង់ព្យាករសេចក្តីនោះ តាមទំនងដែលព្រះអង្គសព្វព្រះហឫទ័យចុះ ។ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច បើមានរាជបុរសណាមួយរបស់ព្រះអង្គ ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីទព្វន្តក្តី ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយម្រាមដៃក្តី ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីបូកក្តី តើអាចនឹងរាប់ខ្សាច់ក្នុងទន្លេគង្គាថាខ្សាច់មានប្រមាណប៉ុណ្ណោះក្តី ខ្សាច់មានប៉ុណ្ណោះរយក្តី ខ្សាច់មានប៉ុណ្ណោះពាន់ក្តី ខ្សាច់មានប៉ុណ្ណោះសែនក្តី ដូច្នេះបានឬទេ ។ មិនអាចរាប់បានទេ នាងជាម្ចាស់ ។ មួយវិញទៀត បើមានរាជបុរសណាមួយរបស់ព្រះអង្គ ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីទព្វន្តក្តី ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយម្រាមដៃក្តី ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីបូកក្តី តើគេអាចនឹងរាប់ទឹកក្នុងមហាសមុទ្រថា ទឹកមានប្រមាណប៉ុណ្ណោះអាឡ្ហកៈក្តី មានប៉ុណ្ណោះរយអាឡ្ហកៈក្តី មានប៉ុណ្ណោះពាន់អាឡ្ហកៈក្តី មានប៉ុណ្ណោះសែនអាឡ្ហកៈក្តី ដូច្នេះបានឬទេ ។ មិនអាចរាប់បានទេ នាងជាម្ចាស់ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ បពិត្រនាងជាម្ចាស់ ព្រោះថាសមុទ្រធំ ជ្រៅ កំណត់ប្រមាណមិនបាន ស្ទង់បានដោយកម្រក្រៃពេក ។

អព្យាកតសំយុត្តំ

[៣៩៩] ឯវមេវ ខោ មហារាជ យេន រូបេន តថាគតំ បញ្ញាបយមានោ បញ្ញបេយ្យ តំ រូបំ តថាគតស្ស បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ ។ រូបសង្ខ្យា[១] វិមុត្តោ ខោ មហារាជ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាឡ្ហោ សេយ្យថាបិ មហារាជ មហាសមុទ្ទោ ។ ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ។ យាយ វេទនាយ តថាគតំ បញ្ញាបយមានោ បញ្ញបេយ្យ សា វេទនា តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ វេទនាសង្ខ្យា វិមុត្តោ ខោ មហារាជ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាឡ្ហោ សេយ្យថាបិ មហារាជ មហាសមុទ្ទោ ។

---

១ ឱ. ម. រូបសង្ខាយ ។

អព្យាកតសំយុត្ត

[៣៩៩] បពិត្រមហារាជ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ បុគ្គលកាលបញ្ញត្ត គួរបញ្ញត្តនូវសត្វដោយរូបណា រូបនោះព្រះតថាគតក៏បានលះបង់ចោលហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាពមានសភាពមិនកើតឡើងទៅទៀតឡើយ ។ បពិត្រមហារាជ ព្រះតថាគតផុតចាកការរាប់នូវរូប ជាបុគ្គលជ្រៅ កំណត់ប្រមាណមិនបានស្ទង់បានដោយកម្រក្រៃពេក បពិត្រមហារាជ ដូចជាមហាសមុទ្រដែរ ។ ព្រះតថាគតមិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅមិនកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ បុគ្គលកាលបញ្ញត្តគួរបញ្ញត្តនូវសត្វដោយវេទនាឯណា វេទនានោះព្រះតថាគតបានលះបង់ចោលហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតឡើងតទៅទៀតឡើយ ។ បពិត្រមហារាជ ព្រះតថាគតផុតចាកការរាប់ដោយវេទនា ជាបុគ្គលជ្រៅ កំណត់ប្រមាណមិនបានស្ទង់បានដោយកម្រក្រៃពេក បពិត្រមហារាជ ដូចជាមហាសមុទ្រដែរ ។

ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ។ យាយ សញ្ញាយ តថាគតំ ។ បេ ។ យេហិ សង្ខារេហិ តថាគតំ បញ្ញាបយមានោ បញ្ញ-បេយ្យ តេ សង្ខារា តថាគតស្ស បហីនា ឧច្ឆិន្ន-មូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បា-ធម្មា ។ សង្ខារសង្ខ្យា វិមុត្តោ ខោ មហារាជ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាហោ សេយ្យថាបិ មហារាជ មហាសមុទ្ទោ ។ ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិបិ ។ យេន វិញ្ញាណេន តថាគតំ បញ្ញាបយ-មានោ បញ្ញបេយ្យ តំ វិញ្ញាណំ តថាគតស្ស បហីនំ

ព្រះតថាគតមិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅមិនកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ នូវសត្វដោយសញ្ញាឯណា ។ បេ ។ បុគ្គលកាលបញ្ញត្ត គួរបញ្ញត្តនូវសត្វដោយសង្ខារទាំងឡាយឯណា សង្ខារទាំងនោះព្រះតថាគតបានលះបង់ចោលហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតឡើងតទៅទៀតឡើយ ។ បពិត្រមហារាជ ព្រះតថាគតផុតស្រឡះចាកការរាប់នូវសង្ខារ ជាបុគ្គលជ្រៅ កំណត់ប្រមាណមិនបាន ស្ទង់បានដោយកម្រក្រៃពេក បពិត្រមហារាជ ដូចជាមហាសមុទ្រដែរ ។ ព្រះតថាគតមិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅមិនកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ បុគ្គលកាលបញ្ញត្ត គួរបញ្ញត្តនូវសត្វដោយវិញ្ញាណឯណា វិញ្ញាណនោះព្រះតថាគតបានលះបង់ចោលហើយ

អព្យាកតសំយុត្តំ

ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ ។ វិញ្ញាណសង្ខយា វិមុត្តោ ខោ មហារាជ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាហោ សេយ្យថាបិ មហារាជ មហាសមុទ្ទោ ។ ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ។ អថខោ រាជា បសេនទិកោសលោ ខេមាយ ភិក្ខុនិយា ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ខេមំ ភិក្ខុនឹ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតឡើងតទៅទៀតឡើយ ។ បពិត្រមហារាជ ព្រះតថាគតផុតស្រឡះចាកការរាប់នូវវិញ្ញាណ ជាបុគ្គលជ្រៅ កំណត់ប្រមាណមិនបាន ស្ទង់បានដោយកម្រក្រៃពេក បពិត្រមហារាជ ដូចជាមហាសមុទ្រដែរ ។ ព្រះតថាគតមិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅមិនកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ គ្រានោះ ព្រះបាទបសេនទិកោសលមានព្រះរាជហឫទ័យត្រេកអរអនុមោទនា ចំពោះភាសិតរបស់ខេមាភិក្ខុនី ហើយទ្រង់ក្រោកចាកអាសនៈ ថ្វាយបង្គំខេមាភិក្ខុនីធ្វើប្រទក្សិណ ស្តេចចេញទៅ ។

[៤០០] អថខោ រាជា បសេនទិកោសលោ អបរេន សមយេន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិកោសលោ ភគវន្តំ ឯតទវោច កឹ នុ ខោ ភន្តេ ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ មហារាជ មយា ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បន ភន្តេ ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ មហារាជ អព្យាកតំ មយា ន ហោតិ តថាគតោ បរំ មរណាតិ ។ កឹ នុ ខោ ភន្តេ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ មហារាជ មយា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បន ភន្តេ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ មហារាជ អព្យាកតំ មយា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ កឹ នុ ខោ ភន្តេ ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋោ សមានោ

[៤០០] លុះសម័យខាងក្រោយមក ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសលគង់ក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតឬទេ ។ បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតនុ៎ះ តថាគតមិនបានព្យាករទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសត្វស្លាប់ទៅមិនកើតទៀតឬអ្វី ។ បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនុ៎ះ តថាគតមិនបានព្យាករទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានឬអ្វី ។ បពិត្រមហា-រាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាននុ៎ះ តថាគតមិនបានព្យាករទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននុ៎ះ តថាគតមិនបានព្យាករទេ ។ កាលដែលខ្ញុំព្រះអង្គក្រាបទូលសួរដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតឬទេ ព្រះអង្គត្រាស់ថា

អព្យាកតំ ខោ ឯតំ មហារាជ មយា ហោតិ តថា-
គតោ បរំ មរណាតិ វទេសិ ។ បេ ។ កឹ បន ភន្តេ
នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ឥតិ
បុដ្ឋោ សមានោ ឯតម្បិ ខោ មហារាជ អព្យាកតំ មយា
នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ
វទេសិ ។ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ
យេនេតំ អព្យាកតំ ភគវតាតិ ។

[៤០១] តេនហិ មហារាជ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ
យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ
កឹ មញ្ញសិ មហារាជ អត្ថិ តេ កោចិ គណកោ វា
មុទ្ទិកោ វា សង្ខាយកោ វា យោ បហោតិ គង្គាយ
វាលិកំ គណេតុំ ឯត្តកា វាលិកា ឥតិ វា ។ បេ ។

បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតនុ៎ះ តថាគតមិនបានព្យាករទេ ។ បេ ។ កាលដែលខ្ញុំព្រះអង្គក្រាបទូលសួរដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ព្រះអង្គត្រាស់ថា បពិត្រមហារាជ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននុ៎ះ តថាគតមិនបានព្យាករទេ ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំព្រះដ៏មានព្រះភាគមិនឲ្យទ្រង់ព្យាករពាក្យនុ៎ះ ។

[៤០១] បពិត្រមហារាជ បើដូច្នោះ តថាគតនឹងសូមសបសួរព្រះអង្គក្នុងសេចក្ដីនោះវិញ សូមព្រះអង្គទ្រង់ព្យាករសេចក្ដីនោះតាមទំនងដែលព្រះអង្គសព្វព្រះហឫទ័យផងចុះ ។ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច បើមានរាជបុរសណាមួយរបស់ព្រះអង្គ ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីនព្វន្តក្ដី ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយម្រាមដៃក្ដី ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីបូកក្ដី តើអាចនឹងរាប់គ្រាប់ខ្សាច់ក្នុងទន្លេគង្គាថា គ្រាប់ខ្សាច់មានប្រមាណប៉ុណ្ណោះក្ដី ។ បេ ។

ឯត្តកានិ វាលិកសតសហស្សានិ ឥតិ វាតិ ។ នោ ហេតំ ភន្តេ ។ អត្ថិ បន តេ កោចិ គណកោ វា មុទ្ទិកោ វា សង្ខាយកោ វា យោ បហោតិ មហាសមុទ្ទេ ឧទកំ គណេតុំ[១] ឯត្តកានិ ឧទកាឡ្ហកានិ ឥតិ វា ។ បេ ។ ឯត្តកានិ ឧទកាឡ្ហកសតសហស្សានិ ឥតិ វាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ មហា ហិ ភន្តេ សមុទ្ទោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាហោតិ ។

[៤០២] ឯវមេវ ខោ មហារាជ យេន រូបេន តថាគតំ បញ្ញាបយមានោ បញ្ញាបេយ្យ តំ រូបំ តថាគតស្ស បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ

១ ឱ. ឧទកម្បមេតុំ ។

គ្រាប់ខ្សាច់មានប្រមាណប៉ុណ្ណោះសែនគ្គី បានឬទេ ។ រាប់មិនបានទេ ព្រះអង្គ ។ មួយវិញទៀត បើមានរាជបុរសណាមួយរបស់ព្រះអង្គ ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីនព្វន្តក្តី ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយម្រាមដៃក្តី ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីបូកក្តី តើអាចនឹងរាប់ទឹកក្នុងមហាសមុទ្រថា ទឹកមានប្រមាណប៉ុណ្ណោះអាឡ្ហកៈក្តី ។ បេ ។ មានប៉ុណ្ណោះសែនអាឡ្ហកៈក្តី បានឬទេ ។ រាប់មិនបានទេ ព្រះអង្គ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាសមុទ្រធំមានជម្រៅ កំណត់ប្រមាណមិនបាន ស្ទង់បានដោយកម្រក្រៃពេក ។

[៤០២] បពិត្រមហារាជ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ បុគ្គលកាលបញ្ញត្ត គួរបញ្ញត្តនូវសត្វដោយរូបឯណា រូបនោះតថាគតបានលះបង់ចោលហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព

៣៨៧



អាយតឹ អនុប្បាទធម្មំ ។ រូបសង្ខ្យា វិមុត្តោ ខោ ម-
ហារាជ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគា-
ហោ សេយ្យថាបិ មហារាជ មហាសមុទ្ទោ ។ ហោតិ
តថាគតោ បរំ មរណាតិបិ ន ឧបេតិ ន ហោតិ តថា-
គតោ បរំ មរណាតិបិ ន ឧបេតិ ហោតិ ច ន ច ហោតិ
តថាគតោ បរំ មរណាតិបិ ន ឧបេតិ នេវ ហោតិ ន
ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ។
យាយ វេទនាយ ។ យាយ សញ្ញាយ ។ យេហិ
សង្ខារេហិ ។ យេន វិញ្ញាណេន តថាគតំ បញ្ញាប-
យមានោ បញ្ញាបេយ្យ តំ វិញ្ញាណំ តថាគតស្ស
បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អា-
យតឹ អនុប្បាទធម្មំ ។ វិញ្ញាណសង្ខ្យា វិមុត្តោ ខោ
មហារាជ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិ-
យោគាហោ សេយ្យថាបិ មហារាជ មហាសមុទ្ទោ ។

មានសភាពមិនកើតឡើងតទៅទៀតឡើយ ។ បពិត្រមហារាជ តថាគតផុតស្រឡះចាកការរាប់នូវរូប ជាបុគ្គលជ្រៅ កំណត់ប្រមាណមិនបាន ស្ទង់បានដោយកម្រក្រៃពេក បពិត្រមហារាជ ដូចជាមហាសមុទ្រដែរ ។ តថាគតមិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅមិនកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ (បុគ្គលកាលបញ្ញត្ត គួរបញ្ញត្តនូវសត្វ) ដោយវេទនាឯណា ។ ដោយសញ្ញាឯណា ។ ដោយសង្ខារទាំងឡាយឯណា ។ បុគ្គលកាលបញ្ញត្ត គួរបញ្ញត្តនូវសត្វដោយវិញ្ញាណឯណា វិញ្ញាណនោះ តថាគតបានលះបង់ចោលហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតឡើងតទៅទៀតឡើយ ។ បពិត្រមហារាជ តថាគតផុតស្រឡះចាកការរាប់នូវវិញ្ញាណ ជាបុគ្គលជ្រៅ កំណត់ប្រមាណមិនបាន ស្ទង់បានដោយកម្រក្រៃពេក បពិត្រមហារាជ ដូចជាមហាសមុទ្រដែរ ។

ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិ ន ឧបេតីតិ ។

[៤០៣] អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យត្ត[១] ហិ នាម សត្ថុ ចេវ សាវិកាយ ច[២] អត្ថេន អត្ថោ ព្យញ្ជនេន ព្យញ្ជនំ សំសន្ទិស្សតិ សមេស្សតិ ន វិហាយិស្សតិ[៣] យទិទំ អគ្គបទស្មឹ ។ ឯកមិទាហំ ភន្តេ សមយំ ខេមំ ភិក្ខុនឹ ឧបសង្កមិត្វា ឯតមត្ថំ អបុច្ឆឹ ។ សាបិ មេ អយ្យា ឯតេហិ បទេហិ ឯតេហិ ព្យញ្ជនេហិ ឯតមត្ថំ ព្យាកាសិ សេយ្យថាបិ ភគវា ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យត្ត ហិ នាម សត្ថុ ចេវ សាវិកាយ ច អត្ថេន អត្ថោ ព្យញ្ជនេន ព្យញ្ជនំ សំសន្ទិស្សតិ សមេស្សតិ ន វិហាយិស្សតិ យទិទំ អគ្គ-

---

១ ឱ. ម. យត្រ ។ ២ សត្ថុនោ សាវិកាយ ច ។ ៣ ន វិរោធយិស្សតិ ។

តថាគតមិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅមិនកើតទៀតក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានក្តី មិនប្រកាន់ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។

[៤០៣] បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ ព្រោះថាបើនឹងប្រៀបធៀបអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ របស់ព្រះសាស្តាផង របស់សាវិកាផង នឹងឃើញសមគ្នា មិនឃ្លៀងឃ្លាតគ្នាក្នុងបទដ៏ប្រសើរនេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យមួយ ក្នុងទីឯណោះ ខ្ញុំព្រះអង្គចូលទៅរកខេមាភិក្ខុនី ហើយបានសួរសេចក្តីនុ៎ះ ។ ឯខេមាភិក្ខុនីជាម្ចាស់នោះ បានព្យាករសេចក្តីនុ៎ះ ដោយបទទាំងនុ៎ះ ដោយព្យញ្ជនៈទាំងនុ៎ះ ដល់ខ្ញុំព្រះអង្គ មានទំនងដូចជាព្រះមានព្រះភាគដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ ព្រោះថាបើប្រៀបធៀបអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ របស់ព្រះសាស្តាផង របស់សាវិកាផង នឹងឃើញសមគ្នាមែន មិនឃ្លៀងឃ្លាតគ្នាក្នុងបទ

អព្យាកតសំយុត្តំ

បនស្មឹ ។ ហន្ទនានិ មយំ ភន្តេ តប្ចាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ មហារាជ កាលំ មញ្ញសីតិ ។ អថខោ រាជា បសេនទិកោ- សលោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមីតិ ។ បឋមំ ។

[៤០៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។

ដ៏ប្រសើរនេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ ខ្ញុំព្រះអង្គសូមលាទៅក្នុងកាលឥឡូវនេះ (ព្រោះ) ខ្ញុំព្រះអង្គជាអ្នកមានកិច្ចច្រើន មានការងារច្រើន ។ បពិត្រមហារាជ ព្រះអង្គសំគាល់នូវកាលគួរក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះឯង ព្រះបាទបសេនទិកោសលទ្រង់ត្រេកអរអនុមោទនា ចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ រួចធ្វើប្រទក្សិណស្តេចចេញទៅ ។ ចប់សូត្រទី ១ ។

[៤០៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងកូដាគារសាលា នាមហាវន ជិតក្រុងវេសាលី ។

តេន ខោ បន សមយេន អាយស្មា អនុរាធោ ភគវតោ អវិទូរេ អរញ្ញកុដិកាយំ វិហរតិ ។ អថខោ សម្ពហុលា អញ្ញតិត្ថិយា បរិព្វាជកា យេនាយស្មា អនុរាធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អនុរាធេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ អញ្ញតិត្ថិយា បរិព្វាជកា អាយស្មន្តំ អនុរាធំ ឯតទវោចុំ យោ សោ អាវុសោ អនុរាធ តថាគតោ ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំ តថាគតោ ឥមេសុ ចតូសុ ឋានេសុ បញ្ញាបយមានោ បញ្ញាបេតិ ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

សម័យនោះឯង ព្រះអនុរាធមានអាយុគង់ក្នុងអរញ្ញកុដិកា (កុដិតូចតាំងនៅក្នុងព្រៃ) ជិតព្រះមានព្រះភាគ ។ លំដាប់នោះ ពួកបរិព្វាជកជាអន្យតិរ្ថិយច្រើនគ្នា ចូលសំដៅទៅរកព្រះអនុរាធមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះអនុរាធមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះបរិព្វាជកជាអន្យតិរ្ថិយទាំងនោះអង្គុយក្នុងទីសមគួរហើយ ទើបនិយាយនឹងព្រះអនុរាធមានអាយុដូច្នេះថា ម្នាលអាវុសោអនុរាធ សត្វឯណាជាបុរសដ៏ឧត្តម ជាបុរសដ៏ប្រសើរក្រៃលែង ដល់នូវចំណែកនៃគុណដ៏ក្រៃលែង ព្រះតថាគតកាលបញ្ញត្ត ក៏បញ្ញត្តនូវសត្វនោះក្នុងហេតុទាំង ៤ នេះ គឺថាសត្វស្លាប់ទៅកើតទៀត ១ សត្វស្លាប់ទៅមិនកើតទៀត ១ សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាន ១ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ១ ។

យោ សោ អាវុសោ តថាគតោ ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំ តថាគតោ អញ្ញត្រ ឥមេហិ ចតូហិ ឋានេហិ បញ្ញាបយមានោ បញ្ញាបេតិ ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

[៤០៥] ឯវំ វុត្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា អាយស្មន្តំ អនុរាធំ ឯតទវោចុំ សោ ចាយំ ភិក្ខុ នវោ ភវិស្សតិ អចិរបព្វជិតោ ថេរោ វា បន ពាលោ អព្យត្តោតិ ។ អថខោ តេ អញ្ញតិត្ថិយា បរិព្វាជកា អាយស្មន្តំ អនុរាធំ នវវាទេន ច ពាលវាទេន ច អបសាទេត្វា ឧដ្ឋាយាសនា បក្កមឹសុ ។ អថខោ អាយស្មតោ អនុរាធស្ស អចិរបក្កន្តេសុ អញ្ញតិត្ថិយេសុ បរិព្វាជកេសុ ឯតទហោសិ សចេ ខោ[១]

១ ឱ. ម. សចេ ខោ មំ តេ ។

ម្នាលអាវុសោ សត្វឯណាជាបុរសដ៏ឧត្តម ជាបុរសដ៏ប្រសើរក្រៃលែង ដល់នូវចំណែកនៃគុណដ៏ក្រៃលែង ព្រះតថាគតកាលបញ្ញត្ត រមែង បញ្ញត្តនូវសត្វនោះ ដោយវៀរចាកហេតុទាំង ៤ នេះចេញ គឺថាសត្វស្លាប់ទៅកើតទៀត ១ សត្វស្លាប់ទៅមិនកើតទៀត ១ សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាន ១ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ១ ។

[៤០៥] កាលបើព្រះអនុរាធត្ថេរពោលយ៉ាងនេះហើយ ទើបពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ បានពោលទៅនឹងព្រះអនុរាធមានអាយុដូច្នេះថា ភិក្ខុនេះជាភិក្ខុថ្មី ទើបតែនឹងបួស ឬជាភិក្ខុចាស់ ប៉ុន្តែល្ងង់ខ្លៅមិនឈ្លាសវៃ ។ ទើបពួកបរិព្វាជកអន្យតិរ្ថិយទាំងនោះ ពោលបង្អាប់ព្រះអនុរាធមានអាយុដោយពាក្យថាជាភិក្ខុថ្មីផង ដោយពាក្យថាជាមនុស្សល្ងង់ខ្លៅផង ហើយនាំគ្នាក្រោកចាកអាសនៈដើរចេញទៅ ។ លំដាប់នោះ កាលដែលពួកបរិព្វាជកជាអន្យតិរ្ថិយដើរចេញទៅមិនយូរប៉ុន្មាន ព្រះអនុរាធមានអាយុក៏មានសេចក្តីត្រិះរិះដូច្នេះថា ប្រសិនបើ

តេ អញ្ញតិត្ថិយា បរិព្វាជកា ឧត្តរឹ បុច្ឆេយ្យុំ កថំ ព្យាករមានោ នុ ខ្វាហំ តេសំ អញ្ញតិត្ថិយានំ បរិព្វា-ជកានំ វុត្តវាទីចេវ ភគវតោ អស្សំ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យំ ធម្មស្ស ចានុធម្មំ ព្យាករេយ្យំ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។

[៤០៦] អថខោ អាយស្មា អនុរាធោ យេន ភគ-វា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយ-ស្មា អនុរាធោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ ភគវ-តោ អវិទូរេ អរញ្ញកុដិកាយំ វិហរាមិ ។ អថខោ ភន្តេ សម្ពហុលា អញ្ញតិត្ថិយា បរិព្វាជកា យេនាហំ តេនុ-បសង្កមឹសុ ឧបសង្កមិត្វា មយា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ ភន្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា មំ ឯតទវោចុំ យោ សោ អាវុសោ អនុរាធ

ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ គប្បីសួរតទៅទៀត តើអាត្មាអញគួរព្យាករដល់ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ ដូចម្តេចហ្ន៎ ទើបឈ្មោះថាជាអ្នកពោលនូវពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយផង មិនគប្បីពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង គប្បីព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងលំអាននៃពាក្យដែលប្រកបដោយធម៌ណាមួយ ក៏មិនដល់នូវហេតុដែលគួរតិះដៀលផង ។

[៤០៦] លំដាប់នោះ ព្រះអនុរាធមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយគង់ក្នុងទីសមគួរ ។ លុះព្រះអនុរាធមានអាយុ គង់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះខ្ញុំព្រះអង្គនៅក្នុងអរញ្ញកុដិកា ជិតព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួកបរិព្វាជកជាអន្យតិរ្ថិយច្រើននាក់ បានចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងខ្ញុំព្រះអង្គ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួរជាទីរឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ អង្គុយក្នុងទីសមគួរហើយបាននិយាយនឹងខ្ញុំព្រះអង្គដូច្នេះថា ម្នាលអាវុសោអនុរាធ សត្វឯណា

៣៩៣



តថាគតោ ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំ តថាគតោ ឥមេសុ ចតូសុ ឋានេសុ បញ្ញាបយមានោ បញ្ញបេតិ ហោតិ តថាគតោ បរំ មរណាតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ ឯវំ វុត្តាហំ ភន្តេ តេ អញ្ញតិត្ថិយេ បរិព្វាជកេ ឯតទវោចំ យោ សោ អាវុសោ តថាគតោ ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំ តថាគតោ អញ្ញត្រិមេហិ ចតូហិ ឋានេហិ បញ្ញាបយមានោ បញ្ញបេតិ ហោតិ តថាគតោ បរំ មរណាតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។ ឯវំ វុត្តេ ភន្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា មំ ឯតទវោចុំ សោ ចាយំ ភិក្ខុ នវោ ភវិស្សតិ អចិរប្បព្វជិតោ ថេរោ វា បន ពាលោ

ជាបុរសដ៏ឧត្តម ជាបុរសដ៏ប្រសើរក្រៃលែង ជាអ្នកដល់នូវចំណែកនៃគុណដ៏ក្រៃលែង ព្រះតថាគតកាលបញ្ញត្ត ក៏រមែងបញ្ញត្តនូវសត្វនោះក្នុងហេតុទាំង ៤ យ៉ាងនេះ គឺជាសត្វស្លាប់ទៅកើតទៀត ១ ។ បេ ។ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ១ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើពួកបរិព្វាជកជាអន្យតិរ្ថិយពោលយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏បានពោលទៅនឹងពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះដូច្នេះថា ម្នាលអាវុសោ សត្វឯណាជាបុរសដ៏ឧត្តម ជាបុរសដ៏ប្រសើរក្រៃលែង ជាអ្នកដល់នូវចំណែកនៃគុណដ៏ក្រៃលែង ព្រះតថាគតកាលបញ្ញត្ត ក៏រមែងបញ្ញត្តនូវសត្វនោះ ដោយវៀរចាកហេតុទាំង ៤ យ៉ាងនេះចេញ គឺជាសត្វស្លាប់ទៅកើតទៀត ១ ។ បេ ។ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ១ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ បរិព្វាជកជាអន្យតិរ្ថិយទាំងនោះ បានពោលនឹងខ្ញុំព្រះអង្គដូច្នេះថា លោកនេះជាភិក្ខុថ្មី ទើបតែនឹងបួស ឬជាភិក្ខុចាស់ តែល្ងង់ខ្លៅ

អព្យត្តោតិ ។ អថខោ មំ ភន្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា នវាទេន ច ពាលវាទេន ច អបសាទេត្វា ឧដ្ឋាយាសនា បក្កមឹសុ ។ តស្ស មយ្ហំ ភន្តេ អចិរបក្កន្តេសុ តេសុ អញ្ញតិត្ថិយេសុ បរិព្វាជកេសុ ឯតទហោសិ សចេ ខោ មំ តេ អញ្ញតិត្ថិយា បរិព្វាជកា ឧត្តរឹ បុច្ឆេយ្យុំ កថំ ព្យាករមានោ នុ ខ្វាហំ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ វុត្តវាទី ចេវ ភគវតោ អស្សំ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យំ ធម្មស្ស ចានុធម្មំ ព្យាករេយ្យំ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ គច្ឆេយ្យាតិ ។

មិនឈ្លាសវៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ទើបបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ បានពោលបង្អាប់ខ្ញុំព្រះអង្គដោយពាក្យថាជាភិក្ខុថ្មីផង ដោយពាក្យថាល្ងង់ខ្លៅផង ហើយនាំគ្នាក្រោកចាកអាសនៈដើរចេញទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ ចេញទៅមិនយូរប៉ុន្មាន ខ្ញុំព្រះអង្គក៏មានសេចក្ដីត្រិះរិះដូច្នេះថា ប្រសិនបើពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ គប្បីសួរអាត្មាអញតទៅទៀត តើគួរអាត្មាអញព្យាករដល់ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះដូចម្ដេចហ្ន៎ ទើបឈ្មោះថាជាអ្នកពោលតាមពាក្យ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយផង មិនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង គប្បីព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងការពោលតាមលំអាននៃពាក្យដែលប្រកបដោយធម៌ណាមួយ ក៏មិនដល់នូវហេតុដែលគួរតិះដៀលផង ។

អព្យាកតសំយុត្តំ

[៤០៧] តំ កឹ មញ្ញសិ អនុរាធ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ វេទនា និច្ចា វា អនិច្ចា វាតិ ។ បេ ។ សញ្ញា សង្ខារា វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[៤០៨] តស្មាតិហ អនុរាធ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា

[៤០៧] ម្នាលអនុរាធ អ្នកសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ រូបឯណាមិនទៀង តើរូបនោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ រូបឯណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរូបនោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ ហេតុនោះមិនគួរទេ ព្រះអង្គ ។ ចុះវេទនាទៀងឬមិនទៀង ។ បេ ។ ចុះសញ្ញា សង្ខារ វិញ្ញាណ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះវិញ្ញាណឯណាមិនទៀង តើវិញ្ញាណនោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះវិញ្ញាណឯណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវវិញ្ញាណនោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ ហេតុនេះមិនគួរទេ ព្រះអង្គ ។

[៤០៨] ម្នាលអនុរាធ ព្រោះហេតុនោះ រូបឯណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ទោះខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ថ្លៃថ្លាក្តី រូបឯណាដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី

សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា យា កាចិ សញ្ញា យេ កេចិ សង្ខារា យំ កិញ្ចិ វិញ្ញាណំ អតីតា-នាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ អនុរាធ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។

រូបទាំងអស់នោះគ្រាន់តែជារូបប៉ុណ្ណោះ បុគ្គលគប្បីយល់ឃើញនូវរូបនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញទេ នុ៎ះមិនមែនជាអាត្មាអញទេ នុ៎ះមិនមែនជាខ្លួនអាត្មាអញទេ ។ វេទនាឯណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន សញ្ញាឯណានីមួយ សង្ខារទាំងឡាយឯណានីមួយ វិញ្ញាណឯណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ទោះខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ថ្លៃថ្លាក្តី វិញ្ញាណឯណាដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះគ្រាន់តែជាវិញ្ញាណប៉ុណ្ណោះ បុគ្គលគប្បីយល់ឃើញនូវវិញ្ញាណនុ៎ះដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញទេ នុ៎ះមិនមែនជាអាត្មាអញទេ នុ៎ះមិនមែនជាខ្លួនអាត្មាអញទេ ។ ម្នាលអនុរាធ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយ ចិត្តក៏ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះចាក (អាសវៈ) ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។

ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។

[៤០៩] តំ កឹ មញ្ញសិ អនុរាធ រូបំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ វេទនំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ សញ្ញំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ សង្ខារេ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ វិញ្ញាណំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។

[៤១០] តំ កឹ មញ្ញសិ អនុរាធ រូបស្មឹ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ អញ្ញត្រ រូបា តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ វេទនាយ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ អញ្ញត្រ វេទនាយ ។ បេ ។ សញ្ញាយ ។ បេ ។ អញ្ញត្រ សញ្ញាយ ។ បេ ។ សង្ខារេសុ ។ បេ ។

អរិយសាវ័កនោះដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅស្រេចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវ-នាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៤០៩] ម្នាលអនុរាធ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច អ្នកពិចារណាឃើញនូវរូបថាជាសត្វឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញនូវវេទនាថាជាសត្វឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញនូវសញ្ញាថាជាសត្វឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញនូវសង្ខារទាំងឡាយថាជាសត្វឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញនូវវិញ្ញាណថាជាសត្វឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។

[៤១០] ម្នាលអនុរាធ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច អ្នកពិចារណាឃើញថាសត្វក្នុងរូបឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញថាសត្វក្រៅអំពីរូបឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញថាសត្វក្នុងវេទនាឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញថាសត្វក្រៅអំពីវេទនាឬ ។ បេ ។ ក្នុងសញ្ញាឬ ។ បេ ។ ក្រៅអំពីសញ្ញាឬ ។ បេ ។ ក្នុងសង្ខារទាំងឡាយឬ ។ បេ ។

អញ្ញត្រ សង្ខារេហិ ។ បេ ។ វិញ្ញាណស្មិំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ អញ្ញត្រ វិញ្ញាណំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។

[៤១១] តំ កឹ មញ្ញសិ អនុរាធ រូបំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។

[៤១២] តំ កឹ មញ្ញសិ អនុរាធ អយំ សោ អរូបី អវេទនោ អសញ្ញី អសង្ខារោ អវិញ្ញាណោ តថាគតោតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ ឯត្ថ ច តេ អនុរាធ ទិដ្ឋេវ ធម្មេ សច្ចតោ ថេតតោ អនុបលព្ភនីយសមានោ[១] កល្លំ នុ តេតំ វេយ្យាករណំ យោ សោ អាវុសោ តថាគតោ ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំ តថាគតោ អញ្ញត្រិមេហិ ចតូហិ ឋានេហិ បញ្ញាបយមានោ បញ្ញបេតិ ហោតិ តថាគតោ បរំ មរណាតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ។

---

១ ម. អនុបលព្ភិយមានោ ។ ឱ. អនុបលព្ភមានេ ។

ក្រៅអំពីសង្ខារទាំងឡាយឬ ។ បេ ។ អ្នកពិចារណាឃើញថាសត្វក្នុងវិញ្ញាណឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ អ្នកពិចារណាឃើញថាសត្វក្រៅអំពីវិញ្ញាណឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។

[៤១១] ម្នាលអនុរាធ អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកពិចារណាឃើញនូវរូប វេទនា សញ្ញា សង្ខារ វិញ្ញាណថាជាសត្វឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។

[៤១២] ម្នាលអនុរាធ អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកពិចារណាឃើញថាសត្វនេះគ្មានរូប គ្មានវេទនា គ្មានសញ្ញា គ្មានសង្ខារ គ្មានវិញ្ញាណឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលអនុរាធ សភាវៈដែលអ្នកមិនត្រូវបានដោយពិតឬដោយទៀងទាត់ក្នុងបច្ចុប្បន្ននេះ អ្នកគួរឃើញដែរឬ ត្រង់ពាក្យព្យាករណ៍នេះថា ម្នាលអាវុសោ សត្វឯណាជាបុរសដ៏ឧត្តម ជាបុរសដ៏ប្រសើរក្រៃលែង ជាអ្នកដល់នូវចំណែកនៃគុណដ៏ក្រៃលែង ព្រះតថាគតកាលបញ្ញត្ត ក៏រមែងបញ្ញត្តនូវសត្វនោះដោយវៀរចាកហេតុទាំង ៤ នោះចេញ គឺថាសត្វស្លាប់ទៅកើតទៀត ១ ។ បេ ។ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ១ ។

ជោ ហោតំ ភន្តេ ។ សាធុ សាធុ អនុរាធ បុព្វេ ចាហំ អនុរាធ ឯតរហិ ច ទុក្ខញ្ចេវ បញ្ញបេមិ ទុក្ខស្ស ច និរោធន្តិ ។ ទុតិយំ ។

[៤១៣] ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា មហា-កោដ្ឋិតោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អា-យស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច កឹ នុ ខោ អាវុសោ សារីបុត្ត ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ អាវុសោ ភគវតា ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បនាវុសោ ន ហោតិ តថាគតោ បរំ មរណាតិ ។

មិនមែនដូច្នោះទេ ព្រះអង្គ ។ សាធុៗ អនុរាធ ម្នាលអនុរាធ ក្នុងកាលពីមុនក្តី ក្នុងកាលឥឡូវនេះក្តី តថាគតក៏បញ្ញត្តនូវទុក្ខនិងហេតុជាទីរលត់នៃទុក្ខប៉ុណ្ណោះឯង ។ ចប់សូត្រទី ២ ។

[៤១៣] សម័យមួយ ព្រះសារីបុត្តមានអាយុនិងព្រះមហាកោដ្ឋិតៈមានអាយុ គង់ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ លំដាប់នោះ ព្រះមហាកោដ្ឋិតៈមានអាយុចេញចាកទីសម្ងំក្នុងវេលាសាយណ្ហសម័យ បានចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួរជាទីរឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ លុះព្រះមហាកោដ្ឋិតៈមានអាយុគង់ក្នុងទីសមគួរហើយ បានពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត សត្វស្លាប់ទៅកើតទៀតឬទេ ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ ម្នាលអាវុសោ សត្វស្លាប់ទៅមិនកើតទៀតទេឬ ។

ឯតម្បិ ខោ អាវុសោ អព្យាកតំ ភគវតា ន ហោតិ តថាគតោ បរំ មរណាតិ ។ កឹ នុ ខោ អាវុសោ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ អាវុសោ ភគវតា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បនាវុសោ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ អាវុសោ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ កឹ នុ ខោ អាវុសោ ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋោ សមានោ អព្យាកតំ ខោ ឯតំ អាវុសោ ភគវតា ហោតិ តថា-គតោ បរំ មរណាតិ វទេសិ ។ បេ ។ កឹ បនាវុសោ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋោ សមានោ ឯតម្បិ ខោ អាវុសោ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កោ នុ ខោ អាវុសោ ហេតុ កោ បច្ចយោ យេនេតំ អព្យាកតំ ភគវតាតិ ។

ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ ម្នាលអាវុសោ ចុះសត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មានឬអ្វី ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាននេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ ម្នាលអាវុសោ ចុះសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករដែរ ។ កាលដែលខ្ញុំសួរថា ម្នាលអាវុសោ ចុះសត្វស្លាប់ទៅកើតទៀតឬទេ លោកឆ្លើយថា ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ ព្រះមានព្រះភាគទ្រង់មិនបានព្យាករទេ ។ បេ ។ កាលដែលខ្ញុំសួរយ៉ាងនេះថា ម្នាលអាវុសោ ចុះសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី លោកឆ្លើយថា ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ព្រះមានព្រះភាគក៏ទ្រង់មិនបានព្យាករទេ ។ ម្នាលអាវុសោ អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំព្រះមានព្រះភាគមិនឲ្យទ្រង់ព្យាករពាក្យនេះ ។

[៤១៤] ហោតិ តថាគតោ បរំ មរណាតិ ខោ អាវុសោ រូបគតមេតំ ។ ន ហោតិ តថាគតោ បរំ មរណាតិ រូបគតមេតំ ។ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ រូបគតមេតំ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ រូបគតមេតំ ។ ហោតិ តថាគតោ បរំ មរណាតិ ខោ អាវុសោ វេទនាគតមេតំ ។ ន ហោតិ តថាគតោ បរំ មរណាតិ វេទនាគតមេតំ ។ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វេទនាគតមេតំ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វេទនាគតមេតំ ។ ហោតិ តថាគតោ បរំ មរណាតិ ខោ អាវុសោ សញ្ញាគតមេតំ ។

[៨១៨] ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ គ្រាន់តែជារូបទេ ។ ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនេះ ក៏គ្រាន់តែជារូបដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្វះក៏មាន មិនកើតទៀតខ្វះក៏មាននេះ គ្រាន់តែជារូបដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ គ្រាន់តែជារូបដែរ ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ គ្រាន់តែជាវេទនាទេ ។ ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនេះ គ្រាន់តែជាវេទនាដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្វះក៏មាន មិនកើតទៀតខ្វះក៏មាននេះ ក៏គ្រាន់តែជាវេទនាដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ក៏គ្រាន់តែជាវេទនាដែរ ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ គ្រាន់តែជាសញ្ញាទេ ។

ន ហោតិ តថាគតោ បរំ មរណាតិ សញ្ញាគតមេតំ ។ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ សញ្ញាគតមេតំ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ សញ្ញាគតមេតំ ។ ហោតិ តថាគតោ បរំ មរណាតិ ខោ អាវុសោ សង្ខារគតមេតំ ។ ន ហោតិ តថាគតោ បរំ មរណាតិ សង្ខារគតមេតំ ។ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ សង្ខារគតមេតំ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ សង្ខារគតមេតំ ។ ហោតិ តថាគតោ បរំ មរណាតិ ខោ អាវុសោ វិញ្ញាណគតមេតំ ។ ន ហោតិ តថាគតោ បរំ មរណាតិ វិញ្ញាណគតមេតំ ។ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វិញ្ញាណគតមេតំ ។ នេវ ហោតិ ន ន ហោតិ តថា-គតោ បរំ មរណាតិ វិញ្ញាណគតមេតំ ។ អយំ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេនេតំ អព្យាកតំ ភគវតាតិ ។ តតិយំ ។

ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនេះ គ្រាន់តែជាសញ្ញាដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាននេះ គ្រាន់តែជាសញ្ញាដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ គ្រាន់តែជាសញ្ញាដែរ ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ គ្រាន់តែជាសង្ខារទេ ។ ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនេះ គ្រាន់តែជាសង្ខារដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាននេះ គ្រាន់តែជាសង្ខារដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ក៏គ្រាន់តែជាសង្ខារដែរ ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតនេះ គ្រាន់តែជាវិញ្ញាណទេ ។ ពាក្យថា សត្វស្លាប់ទៅមិនកើតទៀតនេះ គ្រាន់តែជាវិញ្ញាណដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាននេះ គ្រាន់តែជាវិញ្ញាណដែរ ។ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ក៏គ្រាន់តែជាវិញ្ញាណដែរ ។ ម្នាលអាវុសោ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករពាក្យនេះ ។ ចប់សូត្រទី ៣ ។

អព្យាកតសំយុត្តំ

[៤១៥] ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ បេ ។ សាយេវ បុច្ឆា កោ នុ ខោ អាវុសោ ហេតុ កោ បច្ចយោ យេនេតំ អព្យា-កតំ ភគវតាតិ ។

[៤១៦] រូបំ ខោ អាវុសោ អជានតោ អបស្សតោ យថាភូតំ រូបសមុទយំ អជានតោ អបស្សតោ យថា-ភូតំ រូបនិរោធំ អជានតោ អបស្សតោ យថាភូ-តំ រូបនិរោធគាមិនីបដិបទំ អជានតោ អបស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។ ន ហោតិ តថាគតោ បរំ មរណាតិ-បិស្ស ហោតិ ។ ហោតិ ច ន ច ហោតិ តថាគ-តោ បរំ មរណាតិបិស្ស ហោតិ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។

អព្យាកតសំយុត្ត

[៤១៥] សម័យមួយ ព្រះសារីបុត្តមានអាយុ និងព្រះមហាកោដ្ឋិតៈមានអាយុ នៅក្នុងព្រៃឥសិបតនមិគទាយៈ ជិតក្រុងពារាណសី ។ បេ ។ ការជណ្តឹងសួរនោះក៏កើតឡើងថា ម្នាលអាវុសោ ហេតុដូចម្តេចហ្ន៎ បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។

[៤១៦] ម្នាលអាវុសោ កាលបើបុគ្គល មិនដឹង មិនឃើញ នូវរូបតាមសភាវៈពិត មិនដឹង មិនឃើញ នូវហេតុជាទីកើតឡើងនៃរូបតាមសភាវៈពិត មិនដឹង មិនឃើញ នូវសេចក្តីរលត់នៃរូបតាមសភាវៈពិត មិនដឹង មិនឃើញ នូវបដិបទាដើម្បីដល់នូវសេចក្តីរលត់នៃរូបតាមសភាវៈពិតទេ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅមិនកើតទៀតក៏មាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ ក៏មាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។

វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អជានតោ អបស្សតោ យថាភូតំ វិញ្ញាណសមុទយំ អជានតោ អបស្សតោ យថាភូតំ វិញ្ញាណនិរោធំ អជានតោ អបស្សតោ យថាភូតំ វិញ្ញាណនិរោធគាមិនីបដិបទំ អជានតោ អបស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណា-តិបិស្ស ហោតិ ។ ន ហោតិ តថាគតោ បរំ មរណាតិ-បិស្ស ហោតិ ។ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។

កាលបើបុគ្គល មិនដឹង មិនឃើញនូវវេទនា សញ្ញា សង្ខារទាំងឡាយ និងវិញ្ញាណតាមសភាវៈពិត មិនដឹង មិនឃើញ នូវហេតុជាទីកើតឡើង នៃវិញ្ញាណតាមសភាវៈពិត មិនដឹង មិនឃើញ នូវសេចក្តីរលត់នៃ វិញ្ញាណតាមសភាវៈពិត មិនដឹង មិនឃើញ នូវបដិបទាដើម្បីដល់នូវ សេចក្តីរលត់នៃវិញ្ញាណតាមសភាវៈពិត បុគ្គលនោះទើបមានសេចក្តីត្រិះរិះ ដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះ ដូច្នេះថា សត្វស្លាប់ទៅមិនកើតទៀតក៏មាន ។ បុគ្គលនោះមានសេចក្តី ត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

អព្យាកតសំយុត្តំ

[៤១៧] រូបញ្ច ខោ អាវុសោ ជានតោ បស្សតោ យថាភូតំ រូបសមុទយំ ជានតោ បស្សតោ យថាភូតំ រូបនិរោធំ ជានតោ បស្សតោ យថាភូតំ រូបនិរោធគាមិនីបដិបទំ ជានតោ បស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ ជានតោ បស្សតោ យថាភូតំ វិញ្ញាណសមុទយំ ជានតោ បស្សតោ យថាភូតំ វិញ្ញាណនិរោធំ ជានតោ បស្សតោ យថាភូតំ វិញ្ញាណនិរោធគាមិនីបដិបទំ ជានតោ បស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ អយំ ខោ អាវុសោ

[៨១៧] ម្នាលអាវុសោ កាលបើបុគ្គល ដឹង ឃើញ នូវរូបតាមសភាវៈពិត ដឹង ឃើញ នូវហេតុជាទីកើតឡើងនៃរូបតាមសភាវៈពិត ដឹង ឃើញ នូវសេចក្តីរលត់នៃរូបតាមសភាវៈពិត ដឹង ឃើញ នូវបដិបទាដើម្បីដល់នូវសេចក្តីរលត់នៃរូបតាមសភាវៈពិតហើយ បុគ្គលនោះក៏មិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀត ។ បេ ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ កាលបើបុគ្គលដឹង ឃើញ នូវវេទនា សញ្ញា សង្ខារទាំងឡាយ និងវិញ្ញាណតាមសភាវៈពិត ដឹង ឃើញ នូវហេតុជាទីកើតឡើងនៃវិញ្ញាណតាមសភាវៈពិត ដឹង ឃើញ នូវសេចក្តីរលត់នៃវិញ្ញាណតាមសភាវៈពិត ដឹង ឃើញ នូវបដិបទាដើម្បីដល់នូវសេចក្តីរលត់នៃវិញ្ញាណតាមសភាវៈពិត បុគ្គលនោះក៏មិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅមិនកើតទៀតក៏មាន ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មាន ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលអាវុសោ នេះឯង

ហេតុ អយំ បច្ចយោ យេនេតំ[1] អព្យាកតំ ភគវ-

តាតិ ។ ចតុត្ថំ ។

[៤១៨] ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ បេ ។ សាយេវ បុច្ឆា កោ នុ ខោ អាវុសោ ហេតុ កោ បច្ចយោ យេនេតំ អព្យាកតំ ភគវតាតិ ។

[៤១៩] រូបេ ខោ អាវុសោ អវិគតរាគស្ស អវិគតច្ឆន្ទស្ស អវិគតបេ្បមស្ស អវិគតបិបាសស្ស អវិគតបរិឡាហស្ស អវិគតតណ្ហាស្ស ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។

១ ឱ. យេន តំ ។

ជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។ ចប់សូត្រទី ៤ ។

[៤១៨] សម័យមួយ ព្រះសារីបុត្តមានអាយុនិងព្រះមហាកោដ្ឋិតៈមានអាយុ នៅក្នុងព្រៃឥសិបតនមិគទាយៈ ជិតក្រុងពារាណសី ។ បេ ។ ការសាកសួរនោះឯងកើតឡើងថា ម្នាលអាវុសោ ហេតុដូចម្តេចហ្ន៎ បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។

[៤១៩] ម្នាលអាវុសោ កាលបើបុគ្គលមិនប្រាសចាកតម្រេក មិនប្រាសចាកសេចក្តីពេញចិត្ត មិនប្រាសចាកសេចក្តីស្រឡាញ់ មិនប្រាសចាកសេចក្តីស្រេកឃ្លាន មិនប្រាសចាកសេចក្តីក្តៅក្រហាយ មិនប្រាសចាកចំណង់ក្នុងរូបទេ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ អវិគតរា-
គស្ស អវិគតច្ឆន្ទស្ស អវិគតបេ្បមស្ស អវិគតបិចាសស្ស
អវិគតបរិឡាហស្ស អវិគតតណ្ហាស្ស ហោតិ តថាគតោ
បរំ មរណាតិបិស្ស ហោតិ ។ បេ ។ នេវ ហោតិ ន ន
ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។

[៤២០] រូបេ ច ខោ អាវុសោ វិគតរាគស្ស ។ បេ ។
វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ វិគតរា-
គស្ស វិគតច្ឆន្ទស្ស វិគតបេ្បមស្ស វិគតបិចាសស្ស
វិគតបរិឡាហស្ស វិគតតណ្ហាស្ស ហោតិ តថាគតោ
បរំ មរណាតិបិស្ស ន ហោតិ ។ បេ ។ នេវ ហោតិ ន
ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។
អយំ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេនេតំ
អព្យាកតំ ភគវតាតិ ។ បញ្ចមំ ។

កាលបើបុគ្គលមិនប្រាសចាកតម្រេក មិនប្រាសចាកសេចក្តីពេញចិត្ត មិនប្រាសចាកសេចក្តីស្រឡាញ់ មិនប្រាសចាកសេចក្តីស្រេកឃ្លាន មិនប្រាសចាកសេចក្តីក្តៅក្រហាយ មិនប្រាសចាកចំណង់ក្នុងវេទនា សញ្ញា សង្ខារទាំងឡាយ និងវិញ្ញាណទេ បុគ្គលនោះរមែងមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

[៤២០] ម្នាលអាវុសោ កាលបើបុគ្គលប្រាសចាកតម្រេកក្នុងរូប ។ បេ ។ កាលបើបុគ្គលប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកចំណង់ ក្នុងវេទនា សញ្ញា សង្ខារទាំងឡាយ និងវិញ្ញាណហើយ បុគ្គលនោះក៏មិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀត ។ បេ ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលអាវុសោ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។ ចប់សូត្រទី ៥ ។

[៤២១] ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា មហាកោដ្ឋិតោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាកោដ្ឋិតេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហា-កោដ្ឋិតំ ឯតទវោច កឹ នុ ខោ អាវុសោ មហាកោដ្ឋិត ហោតិ តថាគតោ បរំ មរណាតិ ។ បេ ។ កឹ បនាវុសោ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឥតិ បុដ្ឋោ សមានោ ឯតម្បិ ខោ អាវុសោ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កោ នុ ខោ អាវុសោ ហេតុ កោ បច្ចយោ យេនេតំ អព្យាកតំ ភគវតាតិ ។

[៤២១] *សម័យមួយ ព្រះសារីបុត្តមានអាយុនិងព្រះមហាកោដ្ឋិតមានអាយុ នៅក្នុងព្រៃឥសិបតនមិគទាយៈ ជិតក្រុងពារាណសី ។ គ្រានោះឯង ព្រះសារីបុត្តមានអាយុ ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ក៏ចូលទៅរកព្រះមហាកោដ្ឋិតមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមហាកោដ្ឋិតមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តមានអាយុអង្គុយក្នុងទីសមគួរហើយ បានពោលនឹងព្រះមហាកោដ្ឋិតមានអាយុដោយពាក្យដូច្នេះថា ម្នាលអាវុសោមហាកោដ្ឋិត សត្វស្លាប់ទៅកើតទៀតដែរឬហ្ន៎ ។ បេ ។ ម្នាលអាវុសោ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ លុះព្រះសារីបុត្តមានអាយុសួរយ៉ាងនេះហើយ ព្រះមហាកោដ្ឋិតដ៏មានអាយុក៏ឆ្លើយថា អាវុសោ ពាក្យថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ទុកជាព្រះមានព្រះភាគក៏ទ្រង់មិនបានព្យាករ ។ ម្នាលអាវុសោ ហេតុដូចម្ដេចហ្ន៎ បច្ច័យដូចម្ដេចហ្ន៎ ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។*

អព្យាកតសំយុត្តំ

[៤២២] រូបារាមស្ស ខោ អាវុសោ រូបរតស្ស រូប-
សមុទិតស្ស រូបនិរោធំ អជានតោ អបស្សតោ យថា-
ភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។
ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។
ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិស្ស
ហោតិ ។ នេវ ហោតិ ន ន ហោតិ តថាគតោ
បរំ មរណាតិបិស្ស ហោតិ ។ វេទនារាមស្ស ខោ
អាវុសោ វេទនារតស្ស វេទនាសមុទិតស្ស វេទនានិរោធំ
អជានតោ អបស្សតោ យថាភូតំ ហោតិ តថាគតោ
បរំ មរណាតិបិស្ស ហោតិ ។ បេ ។ សញ្ញារាមស្ស
ខោ អាវុសោ ។ សង្ខារារាមស្ស ខោ អាវុសោ ។

អព្យាកតសំយុត្ត

[៨២២] ម្នាលអាវុសោ កាលបើបុគ្គលមានសេចក្តីត្រេកត្រអាលក្នុងរូប ត្រេកអរក្នុងរូប រីករាយក្នុងរូប មិនដឹង មិនឃើញ នូវសេចក្តីរលត់នៃរូបតាមសភាវៈពិត បុគ្គលនោះរមែងមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅមិនកើតទៀតក៏មាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ ក៏មាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលអាវុសោ កាលបើបុគ្គលមានសេចក្តីត្រេកត្រអាលក្នុងវេទនា ត្រេកអរក្នុងវេទនា រីករាយក្នុងវេទនា មិនដឹង មិនឃើញ នូវសេចក្តីរលត់នៃវេទនាតាមសភាវៈពិត បុគ្គលនោះរមែងមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ ម្នាលអាវុសោ កាលបើបុគ្គលមានសេចក្តីត្រេកត្រអាលក្នុងសញ្ញា ។ ម្នាលអាវុសោ កាលបើបុគ្គលមានសេចក្តីត្រេកត្រអាលក្នុងសង្ខារ ។

វិញ្ញាណាភាមស្ស ខោ អាវុសោ វិញ្ញាណារតស្ស វិញ្ញា-ណាសមុទិតស្ស វិញ្ញាណនិរោធំ អជានតោ អបស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។

[៤២៣] ន រូបារាមស្ស ខោ អាវុសោ ន រូបរតស្ស ន រូបសមុទិតស្ស រូបនិរោធំ ជានតោ បស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណា-តិបិស្ស ន ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ ន វេទនារាមស្ស ខោ អាវុសោ ។ ន សញ្ញារាមស្ស ខោ អាវុសោ ។ ន សង្ខារារាមស្ស ខោ អាវុសោ ។ ន វិញ្ញាណារាមស្ស ខោ អាវុសោ ន វិញ្ញាណរតស្ស

ម្នាលអាវុសោ កាលបើបុគ្គល មានសេចក្តីត្រេកត្រអាលក្នុងវិញ្ញាណ ត្រេកអរក្នុងវិញ្ញាណ រីករាយក្នុងវិញ្ញាណ មិនដឹង មិនឃើញ នូវសេចក្តីរលត់នៃវិញ្ញាណតាមសភាវៈពិត បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

[៤២៣] ម្នាលអាវុសោ កាលបើបុគ្គល មិនមានសេចក្តីត្រេក-ត្រអាលក្នុងរូប មិនត្រេកអរក្នុងរូប មិនរីករាយក្នុងរូប ក៏ដឹង ឃើញនូវសេចក្តីរលត់នៃរូបតាមសភាវៈពិត បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ទៅ កើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលអាវុសោ កាលបើបុគ្គលមិនមានសេចក្តីត្រេកត្រអាលក្នុងវេទនា ។ ម្នាលអាវុសោ កាលបើបុគ្គលមិនមានសេចក្តីត្រេកត្រអាលក្នុងសញ្ញា ។ ម្នាលអាវុសោ កាលបើបុគ្គលមិនមានសេចក្តីត្រេកត្រអាលក្នុងសង្ខារ ។ ម្នាលអាវុសោ កាលបើបុគ្គលមិនមានសេចក្តីត្រេកត្រអាលក្នុងវិញ្ញាណ ។ មិនត្រេកអរក្នុងវិញ្ញាណ

ន វិញ្ញាណសមុទិតស្ស វិញ្ញាណនិរោធំ ជានតោ បស្ស-តោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ ន ហោតិ តថាគតោ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ អយម្បិ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេនេតំ អព្យាកតំ ភគវតាតិ ។

[៤២៤] សិយា បនាវុសោ អញ្ញោបិ បរិយាយោ យេន បរិយាយេនេតំ អព្យាកតំ ភគវតាតិ ។ សិយា អាវុសោ ។ ភវារាមស្ស ខោ អាវុសោ ភវរតស្ស ភវស-មុទិតស្ស ភវនិរោធំ អជានតោ អបស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។

មិនរីករាយក្នុងវិញ្ញាណ ដឹង ឃើញ នូវសេចក្តីរលត់នៃវិញ្ញាណ តាមសភាវៈពិត ទើបបុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ មិនកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មាន ។ ម្នាលអាវុសោ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។

[៤២៤] ម្នាលអាវុសោ នៅមានបរិយាយដទៃទៀត ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះដែរឬ ។ ម្នាលអាវុសោ បរិយាយនោះមាន ។ ម្នាលអាវុសោ កាលបើបុគ្គលមានសេចក្តីត្រេកត្រអាលក្នុងភព ត្រេកអរក្នុងភព រីករាយក្នុងភព មិនដឹង មិនឃើញនូវសេចក្តីរលត់នៃភពតាមសភាវៈពិត បុគ្គលនោះរមែងមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

[៤២៥] ន ភវារាមស្ស ខោ អាវុសោ ន ភវរតស្ស ន ភវសមុទិតស្ស ភវនិរោធំ ជានតោ បស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ អយម្បិ ខោ អាវុសោ បរិយាយោ យេនេតំ អព្យាកតំ ភគវតាតិ ។

[៤២៦] សិយា បនាវុសោ អញ្ញោបិ បរិយាយោ យេនេតំ អព្យាកតំ ភគវតាតិ ។ សិយា អាវុសោ ។ ឧបាទានារាមស្ស ខោ អាវុសោ ឧបាទានរតស្ស ឧបាទានសមុទិតស្ស ឧបាទាននិរោធំ អជានតោ អបស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។

[៤២៥] កាលបើបុគ្គលមិនមានសេចក្ដីត្រេកត្រអាលក្នុងភព មិនត្រេកអរក្នុងភព មិនរីករាយក្នុងភព ដឹង ឃើញ នូវសេចក្ដីរលត់នៃភពតាមសភាវៈពិត បុគ្គលនោះមិនមានសេចក្ដីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមិនមានសេចក្ដីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលអាវុសោ នេះឯងជាបរិយាយដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។

[៤២៦] ម្នាលអាវុសោ នៅមានបរិយាយដទៃទៀត ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះដែរឬ ។ ម្នាលអាវុសោ បរិយាយនោះមាន ។ ម្នាលអាវុសោ កាលបើបុគ្គលមានសេចក្ដីត្រេកត្រអាលក្នុងឧបាទាន ត្រេកអរក្នុងឧបាទាន រីករាយក្នុងឧបាទាន មិនដឹង មិនឃើញ នូវសេចក្ដីរលត់នៃឧបាទានតាមសភាវៈពិត បុគ្គលនោះរមែងមានសេចក្ដីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលមានសេចក្ដីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

៤១៣

អព្យាកតសំយុត្តំ

[៤២៧] ន ឧបាទានារាមស្ស ខោ អាវុសោ ន ឧបាទានរតស្ស ន ឧបាទានសម្មុទិតស្ស ឧបាទាននិ-រោធំ ជានតោ បស្សតោ យថាភូតំ ហោតិ តថា-គតោ បរំ មរណាតិបិស្ស ន ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ អយម្បិ ខោ អាវុសោ បរិយាយោ យេនេតំ អព្យាកតំ ភគវតាតិ ។

[៤២៨] សិយា បនាវុសោ អញ្ញោបិ បរិយាយោ យេនេតំ អព្យាកតំ ភគវតាតិ ។ សិយា អាវុសោ ។ តណ្ហារាមស្ស ខោ អាវុសោ តណ្ហារតស្ស តណ្ហា-សម្មុទិតស្ស តណ្ហានិរោធំ អជានតោ អបស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ហោតិ ។

អព្យាកតសំយុត្ត

[៦២៧] ម្នាលអាវុសោ កាលបើបុគ្គលមិនមានសេចក្តីត្រេកត្រអាលក្នុងឧបាទាន មិនត្រេកអរក្នុងឧបាទាន មិនរីករាយក្នុងឧបាទាន ដឹង ឃើញ នូវសេចក្តីរលត់នៃឧបាទានតាមសភាវៈពិត ទើបបុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលអាវុសោ នេះឯងជាបរិយាយដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។

[៦២៨] ម្នាលអាវុសោ នៅមានបរិយាយដទៃទៀត ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះដែរឬ ។ ម្នាលអាវុសោ បរិយាយនោះមាន ។ ម្នាលអាវុសោ កាលបើបុគ្គលមានសេចក្តីត្រេកត្រអាលក្នុងតណ្ហា ត្រេកអរក្នុងតណ្ហា រីករាយក្នុងតណ្ហា មិនដឹង មិនឃើញ នូវសេចក្តីរលត់នៃតណ្ហាតាមសភាវៈពិត បុគ្គលនោះរមែងមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។

[៤២៩] ន តណ្ហាកាមស្ស ខោ អាវុសោ ន តណ្ហារតស្ស ន តណ្ហាសមុជិតស្ស តណ្ហានិរោធំ ជា-ជតោ បស្សតោ យថាភូតំ ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបិស្ស ន ហោតិ ។ អយំ ខោ អាវុសោ បរិយាយោ យេនេតំ អព្យាកតំ ភគវតាតិ ។ សិយា បនាវុសោ អញ្ញោបិ បរិយាយោ យេនេតំ អព្យាកតំ ភគវតាតិ ។ ឯត្តជានិ អាវុសោ សារីបុត្ត ឥតោ ឧត្តរឹ កឹ ឥច្ឆសិ តណ្ហាសង្ខយវិមុត្តស្ស អាវុសោ សារីបុត្ត ភិក្ខុនោ វត្តុំ[១] នត្ថិ បញ្ញាបនា-យាតិ ។ ឆដ្ឋំ ។

១ ឱ. វដ្ដុំ ។

[៤២៩] ម្នាលអាវុសោ កាលបើបុគ្គលមិនមានសេចក្តីត្រេកត្រអាលក្នុងតណ្ហា មិនត្រេកអរក្នុងតណ្ហា មិនរីករាយក្នុងតណ្ហា ដឹងឃើញ នូវសេចក្តីរលត់នៃតណ្ហាតាមសភាវៈពិត បុគ្គលនោះរមែងមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មាន ។ បេ ។ បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មាន ។ ម្នាលអាវុសោ នេះឯងជាបរិយាយដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះ ។ ម្នាលអាវុសោ នៅមានបរិយាយដទៃទៀត ដែលនាំឲ្យព្រះមានព្រះភាគមិនទ្រង់ព្យាករនូវពាក្យនេះដែរឬ ។ ម្នាលអាវុសោសារីបុត្ត ក្នុងសេចក្តីនុ៎ះលោកចង់សួររឿងអ្វីតទៅទៀត អំពីហេតុនេះ ក្នុងកាលឥឡូវនេះ ម្នាលអាវុសោសារីបុត្ត វត្តរបស់ភិក្ខុដែលផុតស្រឡះព្រោះការអស់ទៅនៃតណ្ហាមិនមានប្រាកដឡើយ ។ ចប់សូត្រទី ៦ ។

អព្យាកតសំយុត្តំ

[៤៣០] អថខោ វច្ឆគោត្តោ បរិព្វាជកោ យេនា-
យស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា
អាយស្មតា មហាមោគ្គល្លានេន សទ្ធឹ សម្មោទិ សម្មោ-
ទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និ-
សីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ
អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច កឹ នុ ខោ ភោ
មោគ្គល្លាន សស្សតោ លោកោតិ ។ អព្យាកតំ ខោ
ឯតំ វច្ឆ ភគវតា សស្សតោ លោកោតិ ។ កឹ បនាវុសោ
ភោ មោគ្គល្លាន អសស្សតោ លោកោតិ ។ ឯតម្បិ
ខោ វច្ឆ អព្យាកតំ ភគវតា អសស្សតោ លោកោតិ ។
កឹ នុ ខោ ភោ មោគ្គល្លាន អន្តវា លោកោតិ ។
អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា អន្តវា លោកោតិ ។
កឹ បន ភោ មោគ្គល្លាន អនន្តវា លោកោតិ ។ ឯតម្បិ
ខោ វច្ឆ អព្យាកតំ ភគវតា អនន្តវា លោកោតិ ។
កឹ នុ ខោ ភោ មោគ្គល្លាន តំ ជីវំ តំ សរីរន្តិ ។

អព្យាកតសំយុត្ត

[៤៣០] គ្រានោះឯង វច្ឆគោត្តបរិព្វាជកចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមហាមោគ្គល្លានមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិព្វាជកអង្គុយក្នុងទីសមគួរហើយ បានពោលនឹងព្រះមហាមោគ្គល្លានមានអាយុដូច្នេះថា បពិត្រព្រះមោគ្គល្លានដ៏ចម្រើន លោកទៀងឬអ្វីហ្ន៎ ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា លោកទៀងដូច្នេះទេ ។ ម្នាលអាវុសោមោគ្គល្លានដ៏ចម្រើន ចុះលោកមិនទៀងទេឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនទ្រង់ព្យាករថា លោកមិនទៀងដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន លោកមានទីបំផុតឬអ្វីហ្ន៎ ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា លោកមានទីបំផុតដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ចុះលោកមិនមានទីបំផុតឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា លោកមិនមានទីបំផុតដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ជីវិតនោះក៏គឺសរីរៈនោះឬអ្វីហ្ន៎ ។

អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា តំ ជីវំ តំ សរីរន្តិ ។ កឹ បន ភោ មោគ្គល្លាន អញ្ញំ ជីវំ អញ្ញំ សរីរន្តិ ។ ឯតម្បិ ខោ វច្ឆ អព្យាកតំ ភគវតា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ ។ កឹ បន ភោ មោគ្គល្លាន ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បន ភោ មោគ្គល្លាន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ វច្ឆ អព្យាកតំ ភគវតា ន ហោតិ តថា-គតោ បរំ មរណាតិ ។ កឹ នុ ខោ ភោ មោគ្គល្លាន ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បន ភោ មោគ្គល្លាន នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ វច្ឆ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។

ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា ជីវិតនោះគឺសរីរៈនោះដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ជីវិតដទៃ សរីរៈដទៃឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតដែរឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះដ៏មានព្រះភាគមិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅកើតទៀតដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ចុះសត្វស្លាប់ទៅមិនកើតទៀតឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគក៏មិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅមិនកើតទៀតដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះដ៏មានព្រះភាគមិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគក៏មិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះទេ ។

អព្យាកតសំយុត្តំ

[៤៣១] កោ នុ ខោ ភោ មោគ្គល្លាន ហេតុ កោ បច្ចយោ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ បុដ្ឋានំ ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អ-នន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ កោ បន ភោ មោគ្គល្លាន ហេតុ កោ បច្ចយោ យេន សមណស្ស គោតមស្ស ឯវំ បុដ្ឋស្ស ន ឯវំ វេយ្យាករណំ[១] ហោតិ សស្សតោ លោកោតិបិ អសស្សតោ លោកោតិបិ អន្តវា លោកោតិបិ អនន្តវា លោកោតិបិ តំ ជីវំ តំ សរីរន្តិបិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិបិ ហោតិ

១ ឱ. វ្យាករណំ ។

អព្យាកតសំយុត្ត

[៤៣១] បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ហេតុដូចម្តេចហ្ន៎ បច្ច័យដូចម្តេចហ្ន៎ កាលបើអន្យតិរ្ថិយបរិព្វាជកត្រូវគេសួរយ៉ាងហ្នឹងហើយ ទើបមានពាក្យដោះស្រាយយ៉ាងនេះថា លោកទៀងក្តី ថាលោកមិនទៀងក្តី ថាលោកមានទីបំផុតក្តី ថាលោកមិនមានទីបំផុតក្តី ថាជីវិតនោះគឺសរីរៈនោះក្តី ថាជីវិតដទៃ សរីរៈដទៃក្តី ថាសត្វស្លាប់ទៅកើតទៀតក្តី សត្វស្លាប់ទៅមិនកើតទៀតក្តី សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះក្តី សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច កាលបើព្រះសមណគោតមត្រូវគេសួរយ៉ាងហ្នឹងហើយ ក៏មិនមានពាក្យព្យាករយ៉ាងនេះថា លោកទៀងខ្លះ លោកមិនទៀងខ្លះ លោកមានទីបំផុតខ្លះ លោកមិនមានទីបំផុតខ្លះ ថាជីវិតនោះគឺសរីរៈនោះខ្លះ ជីវិតដទៃសរីរៈដទៃខ្លះ

តថាគតោ បរំ មរណាតិបិ ន ហោតិ តថាគតោ បរំ មរណាតិបិ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបីតិ ។

[៤៣២] អញ្ញតិត្ថិយា ច ខោ វច្ឆ បរិព្វាជកា ចក្ខុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សន្តិ ។ បេ ។ ជិវ្ហំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សន្តិ ។ បេ ។ មនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សន្តិ ។ តស្មា អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ បុដ្ឋានំ ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ តថាគតោ ច ខោ វច្ឆ អរហំ សម្មាសម្ពុទ្ធោ ចក្ខុំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ បេ ។ ជិវ្ហំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ បេ ។ មនំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។

សត្វស្លាប់ទៅកើតទៀតខ្លះ សត្វស្លាប់ទៅមិនកើតទៀតខ្លះ សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានខ្លះ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ។

[៤៣២] ម្នាលវច្ឆៈ ឯពួកអន្យតិរ្ថិយបរិព្វាជក ពិចារណាឃើញនូវចក្ខុថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ បេ ។ ពិចារណាឃើញនូវអណ្តាតថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ បេ ។ ពិចារណាឃើញនូវចិត្តថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ ហេតុនោះ កាលបើពួកអន្យតិរ្ថិយបរិព្វាជកត្រូវគេសួរយ៉ាងនេះហើយ ទើបមានពាក្យព្យាករយ៉ាងនេះថា លោកទៀងក្តី ។ បេ ។ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ ម្នាលវច្ឆៈ ឯព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ពិចារណាឃើញនូវចក្ខុថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ បេ ។ ទ្រង់ពិចារណាឃើញនូវអណ្តាតថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ បេ ។ ទ្រង់ពិចារណាឃើញនូវចិត្តថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។

តស្មា តថាគតស្ស ឯវំ ពុទ្ធស្ស ន ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិបិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបីតិ ។

[៤៣៣] អថខោ វច្ឆគោត្តោ បរិព្វាជកោ ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កឹ នុ ខោ ភោ គោតម សស្សតោ លោកោតិ ។ អព្យាកតំ ខោ ឯតំ វច្ឆ មយា សស្សតោ លោកោតិ ។ បេ ។ កឹ បន ភោ គោតម នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ វច្ឆ អព្យាកតំ មយា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ បុដ្ឋានំ ឯវំ វេយ្យា-

ព្រោះហេតុនោះ កាលបើព្រះតថាគតត្រូវគេសួរយ៉ាងនេះហើយ ទើបមិនមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងខ្លះៗ បេ ។ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ។

[៨៣៣] គ្រានោះឯង វច្ឆគោត្តបរិព្វាជកក្រោកចាកអាសនៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន លោកទៀងឬទេ ។ ម្នាលវច្ឆៈ ពាក្យនេះ តថាគតមិនបានព្យាករថា លោកទៀងដូច្នេះទេ ។ បេ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ តថាគតក៏មិនបានព្យាករថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេចហ្ន៎ បច្ច័យដូចម្តេចហ្ន៎ កាលបើពួកអន្យតិរ្ថិយបរិព្វាជកត្រូវគេសួរយ៉ាងនេះហើយ ទើបមានពាក្យព្យាករណ៍

ការណំ ហោតិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ កោ បន ភោ គោតម ហេតុ កោ បច្ចយោ យេន ភោតោ គោតមស្ស ឯវំ បុដ្ឋស្ស ន ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិបិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបីតិ ។

[៤៣៤] អញ្ញតិត្ថិយា ខោ វច្ឆ បរិព្វាជកា ចក្ខុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សន្តិ ។ បេ ។ ជិវ្ហំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សន្តិ ។ បេ ។ មនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សន្តិ ។ តស្មា អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ បុដ្ឋានំ ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិ វា ។ បេ ។

យ៉ាងនេះថា លោកទៀងក្តី ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច កាលបើព្រះគោតមដ៏ចម្រើន ត្រូវគេសួរយ៉ាងនេះហើយ មិនមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងខ្លះ ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ។

[៤៣៤] ម្នាលវច្ឆៈ ពួកអន្យតិរ្ថិយបរិព្វាជក រមែងពិចារណាឃើញនូវចក្ខុថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ បេ ។ ពិចារណាឃើញនូវអណ្តាតថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ បេ ។ ពិចារណាឃើញនូវចិត្តថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ ព្រោះហេតុនោះ កាលបើពួកអន្យតិរ្ថិយបរិព្វាជកត្រូវគេសួរយ៉ាងនេះហើយ ទើបមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងក្តី ។ បេ ។

៤២១



នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ តថាគតោ ច ខោ វច្ឆ អរហំ សម្មាសម្ពុទ្ធោ ចក្ខុំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ បេ ។ ជិវ្ហំ នេតំ មម នេសោហ-មស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ បេ ។ មនំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ តស្មា តថាគតស្ស ឯវំ បុដ្ឋស្ស ន ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិបិ អសស្សតោ លោកោតិបិ អន្តវា លោកោតិបិ អ-នន្តវា លោកោតិបិ តំ ជីវំ តំ សរីរន្តិបិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិបិ ហោតិ តថាគតោ បរំ មរណាតិបិ ន ហោតិ តថាគតោ បរំ មរណាតិបិ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបីតិ ។

ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ ម្នាល វច្ឆៈ ឯព្រះតថាគតអរហន្តសម្មាសម្ពុទ្ធពិចារណាឃើញនូវចក្ខុថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ បេ ។ ពិចារណាឃើញនូវអណ្តាតថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ បេ ។ ពិចារណាឃើញនូវចិត្តថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ ព្រោះហេតុនោះ កាលតថាគតត្រូវគេសួរយ៉ាងនេះហើយ ទើបមិនមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងខ្លះ ថាលោកមិនទៀងខ្លះ ថាលោកមានទីបំផុតខ្លះ ថាលោកមិនមានទីបំផុតខ្លះ ថាជីវិតនោះគឺសរីរៈនោះខ្លះ ថាជីវិតដទៃសរីរៈដទៃខ្លះ ថាសត្វស្លាប់ទៅកើតទៀតខ្លះ ថាសត្វស្លាប់ទៅមិនកើតទៀតខ្លះ ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានខ្លះ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ។

[៤៣៩] អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យត្ត ហិ នាម សត្ថុ ច សាវកស្ស ច អត្ថេន អត្ថោ ព្យញ្ជនេន ព្យញ្ជនំ សំសន្ទិស្សតិ សមេស្សតិ ន វិហាយិស្សតិ យទិទំ អគ្គបទស្មឹ ។ ឥទានាហំ ភោ គោតម សមណំ មហាមោគ្គល្លានំ ឧបសង្កមិត្វា ឯតមត្ថំ អបុច្ឆឹ សមណោបិ មេ មហាមោគ្គល្លានោ ឯតេហិ បទេហិ ឯតេហិ ព្យញ្ជនេហិ ឯតមត្ថំ ព្យាកាសិ សេយ្យថាបិ ភវំ គោតមោ ។ អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យត្ត ហិ នាម សត្ថុ ច សាវកស្ស ច អត្ថេន អត្ថោ ព្យញ្ជនេន ព្យញ្ជនំ សំសន្ទិស្សតិ សមេស្សតិ ន វិហាយិស្សតិ យទិទំ អគ្គបទស្មិន្តិ ។ សត្តមំ ។

[៤៣៥] បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន មិនធ្លាប់មានទេ ព្រោះថាអត្ថនិងព្យញ្ជនៈរបស់ព្រះសាស្តានិងសាវ័កត្រូវគ្នាដូចគ្នា មិនខុសដោយអត្ថនិងព្យញ្ជនៈ ត្រង់បទដ៏ប្រសើរណាមួយឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំព្រះអង្គបានចូលទៅរកព្រះសមណមហាមោគ្គល្លាន ហើយបានសួរសេចក្តីនុ៎ះ ឯព្រះសមណមហាមោគ្គល្លាន បានព្យាករនូវសេចក្តីនុ៎ះ ដោយបទនិងព្យញ្ជនៈទាំងឡាយនុ៎ះដល់ខ្ញុំព្រះអង្គ ដូចជាព្រះគោតមដ៏ចំ-ម្រើនដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោ-តមដ៏ចម្រើន មិនធ្លាប់មានទេ ព្រោះថាអត្ថនិងព្យញ្ជនៈរបស់ព្រះសាស្តានិងសាវ័កត្រូវគ្នាដូចគ្នា មិនខុសដោយអត្ថនិងព្យញ្ជនៈ ត្រង់បទដ៏ប្រសើរណាមួយឡើយ ។ ចប់សូត្រទី ៧ ។

## អព្យាកតសំយុត្តំ

[៤៣៦] អថខោ វច្ឆគោត្តោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កឹ នុ ខោ ភោ គោតម សស្សតោ លោកោតិ ។ អព្យាកតំ ខោ ឯតំ វច្ឆ មយា សស្សតោ លោកោតិ ។ បេ ។ កឹ បន ភោ គោតម នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ វច្ឆ អព្យាកតំ មយា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ បុដ្ឋានំ ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ កោ បន ភោ គោតម ហេតុ កោ បច្ចយោ

អព្យាកតសំយុត្ត

[៤៣៦] គ្រានោះឯង វច្ឆគោត្តបរិព្វាជកក៏ចូលទៅគាល់ព្រះដ៏-មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួរឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិព្វាជកអង្គុយក្នុងទីសម-គួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន លោកទៀងឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ តថាគតមិនបានព្យាករថា លោកទៀងដូច្នេះទេ ។ បេ ។ បពិត្រព្រះគោតមដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ ម្នាលវច្ឆៈ ទុកជាពាក្យនេះតថាគតក៏មិនបានព្យាករថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេចហ្ន៎ បច្ច័យដូចម្តេចហ្ន៎ កាលបើពួកអន្យតិរ្ថិយបរិព្វាជកត្រូវគេសួរយ៉ាងនេះហើយ ទើបមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងក្តី ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច

យេន ភោតោ គោតមស្ស ឯវំ បុដ្ឋស្ស ន ឯវំ វេយ្យា-
ករណំ ហោតិ សស្សតោ លោកោតិបិ ។ បេ ។ នេវ
ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបីតិ ។

[៤៣៧] អញ្ញតិត្ថិយា ខោ វច្ឆ បរិព្វាជកា រូបំ
អត្តតោ សមនុបស្សន្តិ រូបវន្តំ វា អត្តានំ អត្តនិ
វា រូបំ រូបស្មឹ វា អត្តានំ ។ វេទនំ អត្តតោ
សមនុបស្សន្តិ ។ បេ ។ សញ្ញំ សង្ខារេ វិញ្ញាណំ
អត្តតោ សមនុបស្សន្តិ វិញ្ញាណវន្តំ វា អត្តានំ
អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។
តស្មា អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ បុដ្ឋានំ ឯវំ
វេយ្យាករណំ ហោតិ សស្សតោ លោកោតិ វា
។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ
មរណាតិ វា ។ តថាគតោ ច ខោ វច្ឆ អរហំ

កាលបើព្រះគោតមដ៏ចម្រើន ត្រូវគេសួរយ៉ាងនេះហើយ ក៏មិនមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងខ្លះ ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ។

[៤៣៧] ម្នាលវច្ឆៈ ពួកអន្យតិរ្ថិយបរិព្វាជករមែងពិចារណាឃើញនូវរូបថាជាខ្លួន ពិចារណាឃើញខ្លួនថាមានរូបខ្លះ ពិចារណាឃើញរូបក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងរូបខ្លះ ។ ពិចារណាឃើញវេទនាថាជាខ្លួន ។ បេ ។ ពិចារណាឃើញសញ្ញា សង្ខារ និងវិញ្ញាណថាជាខ្លួន ពិចារណាឃើញខ្លួនថាមានវិញ្ញាណខ្លះ ពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្លះ ។ ព្រោះហេតុនោះ កាលបើពួកអន្យតិរ្ថិយបរិព្វាជកត្រូវគេសួរយ៉ាងនេះហើយ ទើបមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងក្តី ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ ម្នាលវច្ឆៈ ព្រះតថាគតអរហន្ត-

សម្មាសម្ពុទ្ធោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ។ ន វេទនំ អត្តតោ សមនុបស្សតិ ។ បេ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ តស្មា តថាគតស្ស ឯវំ ពុទ្ធស្ស ន ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិបិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបីតិ ។

[៤៣៨] អថខោ វច្ឆគោត្តោ បរិព្វាជកោ ឧដ្ឋាយាសនា យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាមោគ្គល្លានេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច កឹ នុ ខោ ភោ មោគ្គល្លាន

សម្មាសម្ពុទ្ធ មិនពិចារណាឃើញរូបថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានរូបខ្លះ មិនពិចារណាឃើញរូបក្នុងខ្លួនខ្លះ មិនពិចារណាឃើញខ្លួនក្នុងរូបខ្លះ មិនពិចារណាឃើញវេទនាថាជាខ្លួន ។ បេ ។ មិនពិចារណាឃើញសញ្ញា ។ មិនពិចារណាឃើញសង្ខារទាំងឡាយ ។ មិនពិចារ-ណាឃើញវិញ្ញាណថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានវិញ្ញាណខ្លះ មិនពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្លះ មិនពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្លះ ព្រោះហេតុនោះ កាលបើព្រះតថាគតត្រូវគេសួរយ៉ាងនេះហើយ ទើបមិនមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងខ្លះ ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ។

[៤៣៨] លំដាប់នោះឯង វច្ឆគោត្តបរិញ្វាជកក៏ក្រោកចាកអាសនៈចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមហាមោគ្គល្លានមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិញ្វាជកអង្គុយក្នុងទីសមគួរហើយ បានសួរព្រះមហាមោគ្គល្លានមានអាយុដូច្នេះថា បពិត្រព្រះមោគ្គល្លានដ៏ចម្រើន

សស្សតោ លោកោតិ ។ អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា សស្សតោ លោកោតិ ។ បេ ។ កឹ បន ភោ មោគ្គល្លាន នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ វច្ឆ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ កោ នុ ខោ ភោ មោគ្គល្លាន ហេតុ កោ បច្ចយោ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ បុដ្ឋានំ ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ កោ បន ភោ មោគ្គល្លាន ហេតុ កោ បច្ចយោ យេន សមណស្ស គោតមស្ស ឯវំ បុដ្ឋស្ស ន ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិបិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបីតិ ។

លោកទៀងឬអ្វីហ្ន៎ ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបាន ទ្រង់ព្យាករថា លោកទៀងដូច្នេះទេ ។ បេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ ម្នាលវច្ឆៈ ទុកជាពាក្យនេះ ក៏ព្រះមានព្រះភាគទ្រង់មិនបានព្យាករថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ហេតុដូចម្តេចហ្ន៎ បច្ច័យដូចម្តេចហ្ន៎ កាលបើពួកអន្យតិរ្ថិយបរិព្វាជកត្រូវគេសួរយ៉ាងនេះហើយ ទើបមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងក្តី ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច កាលបើព្រះសមណគោតម ត្រូវគេសួរយ៉ាងនេះហើយ ក៏មិនមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងខ្លះ ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ។

៤២៧

## អព្យាកតសំយុត្តំ

[៤៣៩] អញ្ញតិត្ថិយា ខោ វច្ឆ បរិព្វាជកា រូបំ អត្តតោ សមនុបស្សន្តិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ ។ វេទនំ អត្តតោ សមនុបស្សន្តិ ។ បេ ។ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សន្តិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ តស្មា អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ បុដ្ឋានំ ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ តថាគតោ ច វច្ឆ អរហំ សម្មាសម្ពុទ្ធោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ។ ន វេទនំ អត្តតោ សមនុបស្សតិ ។ បេ ។ ន សញ្ញំ ។ ន សង្ខារេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។

អព្យាកតសំយុត្ត

[៤៣៩] ម្នាលវច្ឆៈ ពួកអន្យតិរ្ថិយបរិព្វាជក រមែងពិចារណាឃើញរូបថាជាខ្លួន ពិចារណាឃើញខ្លួនថាមានរូបខ្លះ ពិចារណាឃើញរូបក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងរូបខ្លះ ។ ពិចារណាឃើញវេទ-នាថាជាខ្លួន ។ បេ ។ ពិចារណាឃើញសញ្ញា សង្ខារទាំងឡាយនិងវិញ្ញាណថាជាខ្លួនខ្លះ ពិចារណាឃើញខ្លួនថាមានវិញ្ញាណខ្លះ ពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្លះ ។ ព្រោះហេតុនោះ កាលបើពួកអន្យតិរ្ថិយបរិព្វាជក ត្រូវគេសួរយ៉ាងនេះហើយទើបមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងក្តី ។ បេ ។ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី ។ ម្នាលវច្ឆៈឯព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ មិនពិចារណាឃើញរូបថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានរូបខ្លះ មិនពិចារណាឃើញរូបក្នុងខ្លួនខ្លះ មិនពិចារណាឃើញខ្លួនក្នុងរូបខ្លះ ។ មិនពិចារណាឃើញវេទនាថាជាខ្លួន ។ បេ ។ មិនពិចារណាឃើញសញ្ញា ។ មិនពិចារណាឃើញសង្ខារទាំងឡាយ ។ មិនពិចារណាឃើញវិញ្ញាណថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានវិញ្ញាណ ខ្លះ មិនពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្លះមិនពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្លះ ។

តស្មា តថាគតស្ស ឯវំ បុដ្ឋស្ស ន ឯវំ វេយ្យាករណំ ហោតិ សស្សតោ លោកោតិបិ អសស្សតោ លោកោតិបិ អន្តវា លោកោតិបិ អនន្តវា លោកោតិបិ តំ ជីវំ តំ សរីរន្តិបិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិបិ ហោតិ តថាគតោ បរំ មរណាតិបិ ន ហោតិ តថាគតោ បរំ មរណាតិបិ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិបិ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិបីតិ ។

[៤៤០] អច្ឆរិយំ ភោ មោគ្គល្លាន អព្ភុតំ ភោ មោគ្គល្លាន យត្រ ហិ នាម សត្ថុ ចេវ សាវកស្ស ច អត្ថេន អត្ថោ ព្យញ្ជនេន ព្យញ្ជនំ សំសន្ទិស្សតិ សមេស្សតិ ន វិហាយិស្សតិ យទិទំ អគ្គបទស្មឹ ។ ឥទានាហំ ភោ មោគ្គល្លាន សមណំ គោតមំ ឧបសង្កមិត្វា ឯតមត្ថំ អបុច្ឆឹ សមណោបិ មេ គោតមោ ឯតេហិ បទេហិ ឯតេហិ ព្យញ្ជនេហិ ឯតមត្ថំ ព្យាកាសិ សេយ្យថាបិ ភវំ មោគ្គល្លានោ ។ អច្ឆរិយំ ភោ មោគ្គល្លាន

ព្រោះហេតុនោះ កាលព្រះតថាគតត្រូវគេសួរយ៉ាងនេះហើយ ទើបមិនមានពាក្យព្យាករណ៍យ៉ាងនេះថា លោកទៀងខ្វះ ថាលោកមិនទៀងខ្វះ ថាលោកមានទីបំផុតខ្វះ ថាលោកមិនមានទីបំផុតខ្វះ ថាជីវិតនោះគឺសរីរៈនោះខ្វះ ថាជីវិតដទៃ សរីរៈដទៃខ្វះ ថាសត្វស្លាប់ទៅកើតទៀតខ្វះ ថាសត្វស្លាប់ទៅមិនកើតទៀតខ្វះ ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានខ្វះ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្វះ ។

[៤៤០] បពិត្រព្រះមោគ្គល្លានដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន មិនធ្លាប់មានទេ ព្រោះថាអត្ថនិងព្យញ្ជនៈរបស់ព្រះសាស្តានិងសាវ័កត្រូវគ្នាដូចគ្នា មិនខុសដោយអត្ថនិងព្យញ្ជនៈត្រង់បទដ៏ប្រសើរណាមួយឡើយ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំព្រះករុណាបានចូលទៅគាល់ព្រះសមណគោតម បានទូលសួរសេចក្តីនុ៎ះរួចហើយ ឯព្រះសមណគោតមក៏ទ្រង់ព្យាករនូវសេចក្តីនុ៎ះដល់ខ្ញុំព្រះករុណា ដោយបទនិងព្យញ្ជនៈទាំងឡាយនេះ ដូចជាព្រះមោគ្គល្លានដ៏ចម្រើន សំដែងប្រាប់ដល់ខ្ញុំដែរ ។ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន

អព្ភុតំ ភោ មោគ្គល្លាន យត្រ ហិ នាម សត្ថុ ចេវ សាវកស្ស ច អត្ថេន អត្ថោ ព្យញ្ជនេន ព្យញ្ជនំ សំសន្ទិស្សតិ សមេស្សតិ ន វិហាយិស្សតិ យទិទំ អគ្គបទស្មិន្តិ ។ អដ្ឋមំ ។

[៤៤១] អថខោ វច្ឆគោត្តោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច បុរិមានិ ភោ គោតម ទិវសានិ បុរិមតរានិ សម្ពហុលានំ អញ្ញតិត្ថិយានំ[១] សមណព្រាហ្មណបរិព្វាជកានំ កុតុហលសាលាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរា កថា ឧទបាទិ អយំ ខោ បូរណោ កស្សបោ សង្ឃី ចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស

១ ឱ. នានាតិត្ថិយានំ ។

អស្ចារ្យណាស់ បពិត្រព្រះមោគ្គល្លានដ៏ចម្រើន មិនធ្លាប់មានទេ ព្រោះថា អត្ថនិងព្យញ្ជនៈ របស់ព្រះសាស្តានិងសាវ័កត្រូវគ្នាដូចគ្នា មិនខុសដោយអត្ថនិងព្យញ្ជនៈត្រង់បទដ៏ប្រសើរណាមួយឡើយ ។ ចប់សូត្រទី ៨ ។

[៤៤១] គ្រានោះឯង វច្ឆគោត្តបរិព្វាជកក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររព្ញកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិព្វាជកអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន កាលពីថ្ងៃមុនៗ មក មានពួកសមណព្រាហ្មណ៍និងបរិព្វាជកជាអន្យតិរ្ថិយមានចំនួនច្រើន អង្គុយប្រជុំគ្នាក្នុងកុតុហលសាលាមានអន្តរាកថា (ពាក្យជាចន្លោះ) កើតឡើងដូច្នេះថា គ្រូឈ្មោះបូរណកស្សបនេះ ជាមេពួក ជាមេគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលជនច្រើនសន្មតថាជាមនុស្សល្អ

សោ[១] សាវកំ អព្ភតីតំ កាលកតំ ឧបបត្តីសុ ព្យាក-
រោតិ អសុ អមុត្រ ឧបបន្នោ អសុ អមុត្រ ឧបបន្នោ-
តិ ។ យោបិស្ស សាវកោ ឧត្តមបុរិសោ បរមបុរិសោ
បរមបត្តិបត្តោ តម្បិ សាវកំ អព្ភតីតំ កាលកតំ
ឧបបត្តីសុ ព្យាករោតិ អសុ អមុត្រ ឧបបន្នោ អសុ
អមុត្រ ឧបបន្នោតិ ។ អយម្បិ ខោ មក្ខលិ គោសា-
លោ ។ អយម្បិ ខោ និគណ្ឋោ នាដបុត្តោ ។ អ-
យម្បិ ខោ សញ្ជយោ វេលដ្ឋបុត្តោ ។ អយម្បិ ខោ
បកុធោ កច្ចានោ[២] ។ អយម្បិ ខោ អជិតោ កេ-
សកម្ពលោ សង្ឃី ចេវ គណី ច គណាចរិយោ
ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ
ពហុជនស្ស សោបិ សាវកំ អព្ភតីតំ កាលក-
តំ ឧបបត្តីសុ ព្យាករោតិ អសុ អមុត្រ ឧបបន្នោ

១ សោបិ ។ ២ កច្ចាយនោតិ វា បាឋោ ។

គ្រូឈ្មោះបូរណកស្សបនោះ តែងព្យាករសាវ័កដែលធ្វើមរណកាលកន្លងហួសទៅហើយ ក្នុងកំណើតទាំងឡាយថា សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ ។ សាវ័កឯណា របស់គ្រូឈ្មោះបូរណកស្សបនោះ ជាឧត្តមបុរស ជាបុរសដ៏ប្រសើរក្រៃលែង ដល់នូវចំណែកនៃគុណដ៏ប្រសើរក្រៃលែង គ្រូឈ្មោះបូរណកស្សប ក៏ព្យាករសាវ័កដែលធ្វើមរណកាលកន្លងទៅហើយនោះ ក្នុងកំណើតទាំងឡាយថា សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ ។ គ្រូឈ្មោះមក្ខលិគោសាលនេះក្តី ។ គ្រូឈ្មោះនិគ្គណ្ឋនាដបុត្តនេះក្តី ។ គ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តនេះក្តី ។ គ្រូឈ្មោះបកុធកច្ចាន:នេះក្តី ។ គ្រូឈ្មោះអជិតកេសកម្ពលនេះក្តី ក៏ជាមេពួក ជាមេគណ: ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយសជាមេលទ្ធិ ដែលជនច្រើនសន្មតថាជាមនុស្សល្អ ឯគ្រូឈ្មោះអជិតកេស-កម្ពលនោះ ក៏ព្យាករសាវ័ក ដែលធ្វើមរណកាលកន្លងហួសទៅហើយ ក្នុងកំណើតទាំងឡាយថា សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ

៤៣១

អព្យាកតសំយុត្តំ

អសុ អមុត្រ ឧបបន្នោតិ ។ យោបិស្ស សាវកោ ឧត្តមបុរិសោ បរមបុរិសោ បរមបត្តិបត្តោ តំបិ សាវកំ អព្ភតីតំ កាលកតំ ឧបបត្តីសុ ព្យាករោតិ អសុ អមុត្រ ឧបបន្នោ អសុ អមុត្រ ឧបបន្នោតិ ។ អយម្បិ ខោ សមណោ គោតមោ សង្ឃី ចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស សោបិ សាវកំ អព្ភតីតំ កាលកតំ ឧបបត្តីសុ ព្យាករោតិ អសុ អមុត្រ ឧបបន្នោ អសុ អមុត្រ ឧបបន្នោតិ ។ យោ ច ខ្វស្ស សាវកោ ឧត្តមបុរិសោ ។ បេ ។ អសុ អមុត្រ ឧបបន្នោ

សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ ។ ឯសាវ័កឯណា របស់គ្រូឈ្មោះអជិតកេសកម្ពលនោះ ជាឧត្តមបុរស ជាបុរសដ៏ប្រសើរក្រៃលែង ដល់នូវចំណែកនៃគុណដ៏ប្រសើរក្រៃលែង ក៏ព្យាករនូវសាវ័កនោះដែលធ្វើមរណកាលកន្លងហួសទៅហើយ ក្នុងកំណើតទាំងឡាយថា សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ ។ ចំណែកខាងព្រះសមណគោតមនេះសោតទៀត ក៏ជាមេពួក មេគណៈ ជាគណាចារ្យ មានព្រះនាមល្បីល្បាញ ព្រះអង្គមានយសជាមេលទ្ធិ ដែលជនច្រើនសន្មតថាជាសប្បុរស ព្រះអង្គសោតក៏ទ្រង់ព្យាករនូវសាវ័កដែលធ្វើមរណកាលកន្លងហួសទៅហើយ ក្នុងកំណើតទាំងឡាយថា សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ ។ ក៏ឯសាវ័កឯណា របស់ព្រះអង្គ ជាឧត្តមបុរស ។ បេ ។ ទ្រង់ព្យាករថា សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ

អសុ អមុត្រ ឧបបន្នោតិ ។ អបិច ខោ នំ ឯវំ ព្យាក-រោតិ អច្ឆេជ្ជិ តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មាមានា-ភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។ តស្ស មយ្ហំ ភោ គោតម អហុទេវ កង្ខា អហុ វិចិកិច្ឆា កថញ្ហិ នាម សមណស្ស គោតមស្ស ធម្មោ អភិញ្ញេយ្យោតិ ។

[៤៤២] អលញ្ហិ តេ វច្ឆ កង្ខិតុំ អលំ វិចិកិច្ឆិតុំ កង្ខានិយេ ច បន តេ ឋានេ វិចិកិច្ឆា ឧប្បន្នា ។ សឧបាទានស្ស ខ្វាហំ វច្ឆ ឧបបត្តឹ បញ្ញបេមិ នោ អនុបាទានស្ស ។ សេយ្យថាបិ វច្ឆ អគ្គិ សឧបាទា-នោ ជលតិ នោ អនុបាទានោ ឯវមេវ ខ្វាហំ វច្ឆ

សាវ័កឯណោះ ទៅកើតក្នុងភពឯណោះ ។ មួយវិញទៀត ព្រះសមណ-គោតមទ្រង់ព្យាករនូវសាវ័កនោះយ៉ាងនេះថា សាវ័កនេះបានផ្ដាច់បង់នូវតណ្ហា គាស់រំលើងនូវសញ្ញោជនៈ ហើយធ្វើនូវទីបំផុតនៃសេចក្ដីទុក្ខ ព្រោះត្រាស់ដឹងនូវមានះបានដោយល្អ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្ដីសង្ស័យ មានសេចក្ដីងឿងឆ្ងល់ថា ព្រះធម៌ដែលព្រះសមណគោតមទ្រង់កំណត់ដឹងដោយប្រការដូចម្ដេច ។

[៤៤២] ម្នាលវច្ឆៈ អ្នកឯងគួរមានសេចក្ដីសង្ស័យ គួរមានសេចក្ដីងឿងឆ្ងល់ មួយវិញទៀត សេចក្ដីងឿងឆ្ងល់កើតឡើងដល់អ្នកឯងក្នុងហេតុដែលគួរងឿងឆ្ងល់មែន ។ ម្នាលវច្ឆៈ តថាគតបញ្ញត្តនូវកំណើតនៃសត្វដែលមានឧបាទាន មិនបញ្ញត្តនូវកំណើតនៃសត្វដែលមិនមានឧបាទានឡើយ ។ ម្នាលវច្ឆៈ ដូចភ្លើងមានឧបាទានតែងឆេះភ្លឺរុងរឿង មិនមានឧបាទានមិនឆេះភ្លឺរុងរឿង យ៉ាងណា ម្នាលវច្ឆៈ តថាគត

សឧបាទានស្ស ឧបបត្តឹ បញ្ញបេមិ នោ អនុបាទា-
នស្សាតិ ។ យស្មឹ[១] ភោ គោតម សមយេ អច្ចិ វាតេន
ខិត្តា ទូរំបិ គច្ឆតិ ឥមិស្សា បន ភវំ គោតមោ កឹ ឧ-
បាទានស្មឹ បញ្ញបេតីតិ ។ យស្មឹ ខោ វច្ឆ សមយេ អច្ចិ
វាតេន ខិត្តា ទូរំបិ គច្ឆតិ តមហំ វាតុបាទានំ បញ្ញ-
បេមិ[២] វាតោ ហិស្ស វច្ឆ តស្មឹ សមយេ ឧបាទានំ
ហោតីតិ ។ យស្មឹ[៣] ភោ គោតម សមយេ ឥមញ្ច
កាយំ និក្ខិបតិ សត្តោ ច អញ្ញតរំ កាយំ អនុប-
បន្នោ ហោតិ ។ ឥមស្ស បន ភវំ គោតមោ កឹ
ឧបាទានស្មឹ បញ្ញបេតីតិ ។ យស្មឹ ខោ វច្ឆ សមយេ
ឥមញ្ច កាយំ និក្ខិបតិ សត្តោ ច អញ្ញតរំ កាយំ
អនុបបន្នោ ហោតិ តមហំ តណ្ហុបាទានំ វទាមិ តណ្ហា
ហិស្ស វច្ឆ តស្មឹ សមយេ ឧបាទានំ ហោតីតិ ។ ឯវំ ។

---

១ ឱ. ឯត្ថន្តរេ យស្មឹ បនាតិ ទិស្សតិ ។ ២ ឱ. វទាមិ ។ ៣ ឱ. យស្មឹ ច បន ។

បញ្ញត្តនូវកំណើតនៃសត្វដែលមានឧបាទាន មិនបញ្ញត្តនូវកំណើតនៃសត្វដែលមិនមានឧបាទានឡើយ ក៏យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន សម័យណាអណ្តាតភ្លើងដែលត្រូវខ្យល់បក់រមែងទៅកាន់ទីឆ្ងាយ ចុះព្រះគោតមដ៏ចម្រើន ទ្រង់បញ្ញត្តនូវអ្វីថាជាឧបាទាននៃអណ្តាតភ្លើងនេះ ។ ម្នាលវច្ឆៈ សម័យណាអណ្តាតភ្លើងដែលត្រូវខ្យល់បក់រមែងទៅកាន់ទីឆ្ងាយ តថាគតក៏បញ្ញត្តនូវអណ្តាតភ្លើងនោះថាមានខ្យល់ជាឧបាទាន ម្នាលវច្ឆៈ ព្រោះថាខ្យល់ជាឧបាទាននៃភ្លើងនោះ តែងមានក្នុងសម័យនោះ ។ បពិត្រព្រះគោតមដ៏ចម្រើន សត្វតែងដាក់ចុះនូវកាយនេះ មិនចូលទៅកាន់កាយណាមួយ មានក្នុងសម័យណា ។ ចុះព្រះគោតមដ៏ចម្រើន ទ្រង់បញ្ញត្តនូវអ្វីថាជាឧបាទាននៃកាយនេះ ។ ម្នាលវច្ឆៈ សត្វដាក់ចុះនូវកាយនេះ មិនចូលទៅកាន់កាយណាមួយ មានក្នុងសម័យណា តថាគតក៏ពោលនូវកាយនោះថាមានតណ្ហាជាឧបាទាន ម្នាលវច្ឆៈ ព្រោះថាតណ្ហាជាឧបាទាននៃកាយ រមែងមានក្នុងសម័យនោះ ។ ចប់សូត្រទី ៩ ។

[៤៤៣] អថខោ វច្ឆគោត្តោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កឹ នុ ខោ ភោ គោ-តម អត្ថត្តាតិ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ កឹ បន ភោ គោតម នត្ថត្តាតិ ។ ទុតិយម្បិ ខោ ភគវា តុណ្ហី អហោសិ ។ អថខោ វច្ឆគោត្តោ បរិព្វាជកោ ឧដ្ឋាយាសនា បក្កាមិ ។

[៤៤៤] អថខោ អាយស្មា អានន្ទោ អចិរប្បក្កន្តេ វច្ឆគោត្តេ បរិព្វាជកេ ភគវន្តំ ឯតទវោច កឹ នុ ខោ ភន្តេ ភគវា វច្ឆគោត្តស្ស បរិព្វាជកស្ស បញ្ហំ បុដ្ឋោ ន ព្យាកាសីតិ ។ អហញ្ចានន្ទ វច្ឆគោត្តស្ស បរិព្វាជកស្ស អត្ថត្តាតិ បុដ្ឋោ សមានោ អត្ថត្តាតិ ព្យាករេយ្យំ ។ យេ តេ អានន្ទ សមណព្រាហ្មណា

[៤៤៣] គ្រានោះឯង វច្ឆគោត្តបរិព្វាជកក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្លួនមានដែរឬហ្ន៎ ។ ព្រះមានព្រះភាគ កាលដែលវច្ឆគោត្តបរិព្វាជក ក្រាបបង្គំទូលសួរយ៉ាងនេះហើយ ព្រះអង្គទ្រង់នៅស្ងៀម ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះខ្លួនមិនមានទេឬអ្វី ។ ព្រះដ៏មានព្រះភាគទ្រង់នៅស្ងៀមអស់វារៈជាគម្រប់ ២ ។ គ្រានោះឯង វច្ឆគោត្តបរិព្វាជកក៏ក្រោកចាកអាសនៈដើរចេញទៅ ។

[៤៤៤] លំដាប់នោះឯង ព្រះអានន្ទមានអាយុ កាលដែលវច្ឆគោត្តបរិព្វាជកដើរចេញទៅមិនយូរប៉ុន្មាន បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ កាលវច្ឆគោត្តបរិព្វាជកទូលសួរប្រស្នា ព្រះអង្គមិនទ្រង់ព្យាករដល់វច្ឆគោត្តបរិព្វាជក តើព្រោះហេតុអ្វីហ្ន៎ ។ ម្នាលអានន្ទ ក៏ឯតថាគត កាលបើវច្ឆគោត្តបរិព្វាជកសួរថាខ្លួនមានដែរឬ គប្បីព្យាករដល់វច្ឆគោត្តបរិព្វាជកថាខ្លួនមាន ។ ម្នាលអានន្ទ ពួកសមណព្រាហ្មណ៍ទាំងអម្បាលម៉ាន

សស្សតវាទា តេសមេតំ សច្ចំ អភវិស្ស ។ អហញ្ចានន្ទ វច្ឆគោត្តស្ស បរិព្វាជកស្ស នត្ថត្តាតិ បុដ្ឋោ សមានោ នត្ថត្តាតិ ព្យាករេយ្យំ ។ យេ តេ អានន្ទ សមណព្រាហ្មណា ឧច្ឆេទវាទា តេសមេតំ សច្ចំ អភវិស្ស ។ អហញ្ចានន្ទ វច្ឆគោត្តស្ស បរិព្វាជកស្ស អត្ថត្តាតិ បុដ្ឋោ សមានោ អត្ថត្តាតិ ព្យាករេយ្យំ ។ អបិ នុ មេតំ អានន្ទ អនុលោមំ អភវិស្ស ញាណស្ស ឧប្បាទាយ សព្វេ ធម្មា អនត្តាតិ ។ នោ ហេតំ ភន្តេ ។ អហញ្ចានន្ទ វច្ឆគោត្តស្ស បរិព្វាជកស្ស នត្ថត្តាតិ បុដ្ឋោ សមានោ នត្ថត្តាតិ ព្យាករេយ្យំ ។ សម្មូឡ្ហស្ស អានន្ទ វច្ឆគោត្តស្ស បរិព្វាជកស្ស ភិយ្យោសម្មោហាយ អភវិស្ស អហុ វា មេ នូន បុព្វេ អត្តា សោ ឯតរហិ នត្ថីតិ ។ ទសមំ ។

ដែលជាសស្សតវាទ ការព្យាករនេះមុខជានឹងមានជាមួយនឹងពួកសមណព្រាហ្មណ៍ជាសស្សតវាទទាំងនោះហើយ ។ ម្នាលអានន្ទ ក៏ឯតថាគត កាលបើវច្ឆគោត្តបរិព្វាជកសួរថាខ្លួនគ្មានទេឬ គប្បីព្យាករដល់វច្ឆគោត្តបរិព្វាជកថាខ្លួនគ្មានទេ ។ ម្នាលអានន្ទ ពួកសមណព្រាហ្មណ៍ទាំងអម្បាលម៉ាន ដែលជាឧច្ឆេទវាទ សេចក្ដីព្យាករនេះមុខជានឹងមានជាមួយនឹងពួកសមណព្រាហ្មណ៍ជាឧច្ឆេទវាទទាំងនោះហើយ ។ ម្នាលអានន្ទ ក៏ឯតថាគត កាលបើវច្ឆគោត្តបរិព្វាជកសួរថាខ្លួនមានដែរឬ គប្បីព្យាករដល់វច្ឆគោត្តបរិព្វាជកថាខ្លួនមាន ។ ម្នាលអានន្ទ ចុះពាក្យព្យាករណ៍នេះ ជាការប្រព្រឹត្តទៅដ៏សមគួរដើម្បីឲ្យកើតញាណថា ធម៌ទាំងឡាយទាំងពួងជាអនត្តាដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះមិនមានទេ ។ ម្នាលអានន្ទ ក៏ឯតថាគត កាលបើវច្ឆគោត្តបរិព្វាជកសួរថាខ្លួនគ្មានទេឬ គប្បីព្យាករថាខ្លួនគ្មាន ។ ម្នាលអានន្ទ ពាក្យព្យាករណ៍នុ៎ះ នឹងប្រព្រឹត្តទៅដើម្បីសេចក្ដីវង្វេងជ្រុល ដល់វច្ឆគោត្តបរិព្វាជកជាអ្នកវង្វេងស្រាប់ថា ខ្លួនរបស់អាត្មាអញកាលពីមុនមានដោយពិតហើយ ខ្លួននោះមិនមានក្នុងកាលឥឡូវនេះទេ ។ ចប់សូត្រទី ១០ ។

[៤៤៨] ឯកំ សមយំ អាយស្មា សភិយោ កច្ចានោ ញាតិកេ វិហរតិ គិញ្ជកាវសថេ ។ អថខោ វច្ឆគោត្តោ បរិព្វាជកោ យេនាយស្មា សភិយោ កច្ចា-នោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សភិយេន កច្ចានេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារា-ណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និ-សិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ អាយស្មន្តំ សភិយំ កច្ចានំ ឯតទវោច កឹ នុ ខោ ភោ កច្ចាន ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បន ភោ កច្ចាន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ វច្ឆ អព្យាកតំ ភគវតា ន ហោតិ តថា-គតោ បរំ មរណាតិ ។ កឹ នុ ខោ ភោ កច្ចាន ហោតិ ច

[៤៤៥] សម័យមួយ ព្រះសភិយកច្ចានៈមានអាយុនៅក្នុងរោង ដែលគេសង់ដោយឥដ្ឋ ក្នុងញាតិកគ្រាម ។ គ្រានោះ វច្ឆគោត្ត-បរិព្វាជកចូលទៅរកព្រះសភិយកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះសភិយកច្ចានៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះសភិយកច្ចានៈមានអាយុដូច្នេះថា បពិត្រព្រះកច្ចានៈដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតដែរឬទេ ។ ម្នាលវច្ឆៈ ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់មិនព្យាករថា សត្វស្លាប់ទៅកើតទៀតដូច្នេះទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន ចុះសត្វស្លាប់ទៅមិនកើតទៀតទេឬអ្វី ។ ម្នាលវច្ឆៈ ទុកជាពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅមិនកើតទៀតដូច្នេះទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន សត្វស្លាប់ទៅកើតទៀតខ្លះ

ន ច ហោតិ តថាគតោ បរំ មរណាតិ ។ អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ។ កឹ បន ភោ កច្ចាន នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ ឯតម្បិ ខោ វច្ឆ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ។ កឹ នុ ខោ ភោ កច្ចាន ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋោ សមានោ អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កឹ បន ភោ កច្ចាន ន ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋោ សមានោ អព្យាកតំ ខោ ឯតំ វច្ឆ ភគ-វតា ន ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។

មិនកើតទៀតខ្លះឬអ្វី ។ ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបាន ទ្រង់ព្យាករថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន ចុះសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ។ ម្នាលវច្ឆៈ ទុកជាពាក្យនេះ ព្រះមានព្រះភាគក៏មិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន លោកកាលដែលខ្ញុំសួរថា សត្វស្លាប់ទៅកើតទៀតឬទេ ឆ្លើយថា ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅកើតទៀតដូច្នេះទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន លោកកាលដែលខ្ញុំសួរថា សត្វស្លាប់ទៅមិនកើតទៀតឬអ្វី ឆ្លើយថា ម្នាលវច្ឆៈ ពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅមិនកើតទៀតដូច្នេះទេ ។

កឹ នុ ខោ ភោ កច្ចាន ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋោ សមានោ អព្យាកតំ ខោ ឯតំ វច្ឆ ភគវតា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កឹ បន ភោ កច្ចាន នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ឥតិ បុដ្ឋោ សមានោ ឯតម្បិ ខោ វច្ឆ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វទេសិ ។ កោ នុ ខោ ភោ កច្ចាន ហេតុ កោ បច្ចយោ យេនេតំ អព្យាកតំ សមណេន គោតមេន ។ យោ ច វច្ឆ ហេតុ យោ ច បច្ចយោ បញ្ញាបនាយ[១] រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា សោ ច ហេតុ សោ ច បច្ចយោ សព្វេន សព្វំ សព្វថា សព្វំ អបរិសេសំ និរុជ្ឈេយ្យ ។

១ ម. ឯត្ថន្តរេ បញ្ញាបយមានោ បញ្ញបេយ្យាតិ វា ភវតិ ។

បពិត្រព្រះកច្ចានៈដ៏ចម្រើន លោកកាលដែលខ្ញុំសួរថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះឬអ្វី ឆ្លើយថា ម្នាលវច្ឆៈ ពាក្យនេះព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន លោកកាលដែលខ្ញុំសួរថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬអ្វី ឆ្លើយថា ម្នាលវច្ឆៈ ទុកជាពាក្យនេះ ព្រះមានព្រះភាគមិនបានទ្រង់ព្យាករថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន ហេតុដូចម្តេចហ្ន៎ បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យព្រះសមណគោតមមិនទ្រង់ព្យាករនូវពាក្យនេះ ។ ម្នាលវច្ឆៈ ហេតុនិងបច្ច័យឯណាដែលបញ្ញត្តថា សត្វមានរូបដូច្នេះក្តី មិនមានរូបដូច្នេះក្តី មានសញ្ញាដូច្នេះក្តី មិនមានសញ្ញាដូច្នេះក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនដូច្នេះក្តី ហេតុនិងបច្ច័យនោះគប្បីរលត់ទៅមិនមានសេសសល់ សព្វប្រការទាំងពួង សព្វអាការទាំងពួង ។

## អព្យាកតសំយុត្តំ

យេន នំ[១] បញ្ញាបយមានោ បញ្ញាបេយ្យ រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វាតិ ។ កីវចិរំ បព្វជិតោសិ ភោ កច្ចានាតិ ។ ន ចិរំ អាវុសោ តីណិ វស្សានីតិ ។ យស្ស បស្ស អាវុសោ ឯត្តកេន ឯត្តកមេវ តំ បស្ស ពហុ[២] ភោតោ បន វាទោ ឯវំ អភិក្កន្តេតិ ។ ឯកាទសមំ ។

---

១ តេន នំ ។ ២ ឱ. ពហុំ ។

អព្យាកតសំយុត្តំ សមត្តំ ។

ហេតុម្តេច ក៏កាលបុគ្គលបញ្ញត្តនូវហេតុនិងបច្ច័យនោះ ទើបបញ្ញត្តថា សត្វមានរូបដូច្នេះខ្លះ មិនមានរូបដូច្នេះខ្លះ មានសញ្ញាដូច្នេះខ្លះ មិនមានសញ្ញាដូច្នេះខ្លះ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនដូច្នេះខ្លះ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន លោកបួសបានប៉ុន្មានវស្សាហើយ ។ ម្នាលអាវុសោ អាត្មាបួសមិនទាន់បានយូរប៉ុន្មានទេ ទើបនឹងបាន ៣ វស្សាប៉ុណ្ណោះ ។ ម្នាលអាវុសោ ពាក្យព្យាករណ៍មានប្រមាណប៉ុណ្ណោះ ដោយកាលមានប្រមាណប៉ុណ្ណោះ គប្បីមានដល់បុគ្គលណា ពាក្យព្យា-ករណ៍នោះ ឈ្មោះថាមានច្រើនដល់បុគ្គលនោះ នឹងបាច់ពោលទៅថ្វីក្នុងពាក្យព្យាករណ៍ដ៏ច្បាស់លាស់យ៉ាងនេះ ។ ចប់សូត្រទី ១១ ។

ចប់ អព្យាកតសំយុត្ត ។

## តស្សុទ្ទានំ

ខេមា ថេរី អនុរាធោ
សារីបុត្តាតិ កោដ្ឋិតោ
មោគ្គល្លានោ ច វច្ឆោ ច
កុតុហលសាលានន្ទោ
សភិយោ ឯកាទសមន្តិ ។

សឡាយតនវគ្គសំយុត្តំ សមត្តំ ។

## តស្សុទ្ទានំ

សឡាយតនវេទនា មាតុគ្គាមោ
ជម្ពុខាទកោ សាមណ្ឌកោ
មោគ្គល្លានោ ចិត្តោ
គាមណិសង្ខតំ អព្យាកតន្តិ ទស ចាតិ ។

# ឧទ្ទាននៃអព្យាកតសំយុត្តនោះគឺ

*ពោលអំពីនាងខេមាថេរី ១ អំពីអនុរាធត្ថេរ ១ អំពីព្រះសារីបុត្ត មាន ៣ លើក អំពីព្រះមហាកោដ្ឋិត ១ អំពីព្រះមហាមោគ្គល្លាន ១ អំពីវច្ឆគោត្តបរិព្វាជក ១ អំពីពួកសមណព្រាហ្មណ៍ប្រជុំគ្នាក្នុងកុតុហលសាលា ១ អំពីព្រះអានន្ទមានអាយុ ១ អំពីព្រះសភិយកច្ចានៈ ១ ជាគម្រប់ ១១ ។*

ចប់ សឡាយតនវគ្គសំយុត្ត ។

# ឧទ្ទាននៃសឡាយតនវគ្គនោះគឺ

*សឡាយតនសំយុត្ត ១ វេទនាសំយុត្ត ១ មាតុគ្គាមសំយុត្ត ១ ជម្ពុខាទកសំយុត្ត ១ សាមណ្ឌកសំយុត្ត ១ មោគ្គល្លានសំយុត្ត ១ ចិត្តគហបតិបុច្ឆាសំយុត្ត ១ គាមណិសំយុត្ត ១ អសង្ខតសំយុត្ត ១ អព្យាកតសំយុត្ត ១ រួមជា ១០ ។*

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស សឡាយតនវគ្គោ

# អដ្ឋមោ ភាគោ

## មាតិកា

អង្កេ


*វេទនាសំយុត្តំ* ........................................ ១

*បឋមកសគាថវគ្គោ* ........................................ ១

*រហោគតវគ្គោ* ........................................ ៣០

*អដ្ឋសតបរិយាយវគ្គោ* ........................................ ៦១

*មាតុគ្គាមសំយុត្តំ* ........................................ ៨២

*បេយ្យាលវគ្គោ* ........................................ ៨២

*មាតុគ្គាមពលវគ្គោ* ........................................ ៩៦

*ជម្ពុខាទកសំយុត្តំ* ........................................ ១០៨

*សាមណ្ឌកសំយុត្តំ* ........................................ ១២៧

# សុត្តន្តបិដក

# សំយុត្តនិកាយ សឡាយតនវគ្គ

# អដ្ឋមភាគ

## មាតិកា

ទំព័រ


វេទនាសំយុត្ត ........ ១

បឋមកសគាថវគ្គ ........ ១

រហោគតវគ្គ ........ ៣០

អដ្ឋសតបរិយាយវគ្គ ........ ៦១

មាតុគ្គាមសំយុត្ត ........ ៨២

បេយ្យាលវគ្គ ........ ៨២

មាតុគ្គាមពលវគ្គ ........ ៩៦

ជម្ពុខាទកសំយុត្ត ........ ១០៨

សាមណ្ឌកសំយុត្ត ........ ១២៧

# មាតិកាបត្តានិ

## មាតិកា

អង្កេ

*មោគ្គល្លានសំយុត្តំ* ........................................................ *១៣១*

*ចិត្តគហបតិបុច្ឆាសំយុត្តំ* ................................................ *១៧៤*

*គាមណិសំយុត្តំ* ............................................................ *២២៧*

*អសង្ខតសំយុត្តស្ស បឋមវគ្គោ* ........................ *៣២៩*

*អសង្ខតសំយុត្តស្ស ទុតិយវគ្គោ* ....................... *៣៥៤*

*ព្យាកតសំយុត្តំ* ............................................................. *៣៧៦*

# សង្ខឹកាចង្អុលប្រាប់មាតិកា

## មាតិកា ទំព័រ

មោគ្គល្លានសំយុត្ត........................................................................ ១៣១

ចិត្តគហបតិបុច្ឆាសំយុត្ត.................................................................... ១៧៤

គាមណិសំយុត្ត............................................................................... ២២៧

អសង្ខតសំយុត្ត បឋមវគ្គ .................................................... ៣៤៩

អសង្ខតសំយុត្ត ទុតិយវគ្គ.................................................... ៣៥៤

អព្យាកតសំយុត្ត.............................................................................. ៣៧៦

# រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

# គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្ដីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់ មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក

សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្ដីសុខសួស្ដី

សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា

សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

MAHA PANNA VIHARA FOUNDATION ORGANIZATION

大般若寺基金會

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ
ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៩៧ ៥១១ ៦៧៨៨

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org